# ការសារភាព
# CONFESSIONS

លោកគ្រូ អូគូស្ទីន
AUGUSTINE

Confessions by Aurelius Augustine

English Text Copyright © 2020 by Nathan Wells

Modernized and abridged based on Albert C. Outler's 1955 public domain translation.

This edition in Khmer copyright © 2022 by ACTION Cambodia

All rights reserved.

រក្សាសិទ្ធិគ្រប់បែបយ៉ាង © ២០២២

ផលិតដោយ៖ អង្គការសកម្មភាពកម្ពុជា resources@actioncambodia.org

ប្រអប់សំបុត្រលេខ ១១៧៨ រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា

បកប្រែដោយ៖ លោក ឈាង បូរ៉ា

ជំនួយការបកប្រែ៖ លោក វើល ណាថាន

ពិនិត្យផ្ទៀងផ្ទាត់ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង,  លោក ប៊ុន ធីម៉ូថេ និងលោក ឯក សត្យា

សូមថ្លែងអំណរគុណចំពោះ៖ លោកស្រី កែវ សិរីវុឌ្ឍី, លោក ថាច់ ទិត្យសូរិយា,  លោកស្រី ឡូញ ស្រីរ័ត្ន,  កញ្ញា លី វួចឡេង, លោក ជួប ប៊ុនហាក់, លោកស្រី ពូល រដ្ឋា, លោក ផុន ស្រីអែម, លោកស្រី ថាវ ប៊ុនរី និងលោកគ្រូ តឹក អ៊ែនឌ្រូ

យើងខ្ញុំបានរក្សាអក្ខរាវិរុទ្ធនៃសម្រង់ខគម្ពីរដែលមាននៅក្នុងព្រះគម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរសញ្ញាថ្មី កែសម្រួល រក្សាសិទ្ធិ © ឆ្នាំ២០១៤, ២០១៦ (គកស) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរដ៏វិសុទ្ធជាភាសាខ្មែរបច្ចុប្បន្ន រក្សាសិទ្ធិ © ឆ្នាំ២០០៥ (គខប) ដោយសមាគមព្រះគម្ពីរសកល, ព្រះគម្ពីរគ្រិស្តបរិស័ទខ្មែរ រក្សាសិទ្ធិ © ឆ្នាំ២០១៤ (គគខ) ដោយព័ន្ធកិច្ចព្រះបន្ទូលនៃជីវិត, ក៏ដូចជាអសាធារណនាមមួយចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទទាំងមូលយើងខ្ញុំបានខិតខំព្យាយាមគោរពតាមអក្ខរាវិរុទ្ធនៃវចនានុក្រមខ្មែររបស់សម្ដេចសង្ឃរាជ ជួន ណាត។

អ្នករចនាអត្ថបទភាសាខ្មែរ៖ លោក វើល ណាថាន និងលោក ខែម បូឡុង

For ordering information please visit:

ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖

confessionskhmer.com

បោះពុម្ពលើកទី១ ចំនួន២.០០០ក្បាល ២០២២ នៃគ.ស.

ISBN-13: 9789924566021

# មាតិកា


អារម្ភកថា ..........................................................................៧

សេចក្តីផ្តើមៈ អំណរដ៏ឧត្តុង្គឧត្តម ................................................ ១១

១ ភាពឧត្តុង្គឧត្តមរបស់ព្រះជាម្ចាស់ .............................................៥៣

២ ភាពជាទារក ........................................................................ ៥៧

៣ បទពិសោធន៍នៃការជិតស្លាប់ ..................................................៦៣

៤ ការលួចផ្លែព័រ .......................................................................៦៩

៥ ជីវិតនៅឯទីក្រុងកាតធេ .........................................................៧៧

៦ ការវង្វេងដោយហោរាសាស្រ្ត ..................................................៩៣

៧ ការស្លាប់របស់មិត្តភក្តិទូលបង្គំ ................................................៩៩

៨ ពេលវេលាមិនចេះឈប់ ........................................................១០៧

៩ ការស្រឡាញ់ភាពស្រស់ស្អាតដ៏តូចទាប ................................... ១១១

១០ ការបាត់បង់សេចក្តីសង្ឃឹម .................................................១២៥

១១ ការរើទៅទីក្រុងរ៉ូម ............................................................ ១៣៣

១២ ការរៀនសូត្រពីលោកគ្រូ ផៅមប្រូស៍ ..................................... ១៤១

១៣ អ្នកម្តាយទូលបង្គំនៅឯទីក្រុងមីឡាន ..................................១៤៧

១៤ អំណរដែលមិនពិត ..............................................................១៥៣

១៥ ភាពជាទាសករក្នុងអំណរខាងឯផ្លូវភេទ ...................................១៦៣

១៦ ការតស៊ូរបស់ទូលបង្គំក្នុងការយល់អំពីព្រះជាម្ចាស់ ................... ១៦៩

១៧ ការស្វែងយល់អំពីបុព្វហេតុនៃអំពើអាក្រក់..........................................១៧៥
១៨ របៀបនៃការដែលទូលបង្គំបដិសេធហោរាសាស្ត្រ.................................១៧៩
១៩ ការយល់អំពីប្រភពនៃអំពើអាក្រក់ ..................................................... ១៨៥
២០ ការតយុទ្ធជាមួយនឹងសេចក្ដីប្រាថ្នាពីរយ៉ាង ..........................................១៩៧
២១ សេចក្ដីសង្គ្រោះ....................................................................................២០៩
២២ ការលូតលាស់ខាងឯជំនឿ ................................................................ ២២១
២៣ ពិធីជ្រមុជទឹក ...................................................................................... ២៣១
២៤ មរណភាពរបស់អ្នកម្ដាយទូលបង្គំ..................................................... ២៣៥
២៥ ភាពអស្ចារ្យនៃការចងចាំ ................................................................... ២៥៣
២៦ ការស្វែងរកជីវិតដ៏អរសប្បាយ............................................................ ២៧១
២៧ ព្រះអង្គគឺជាសេចក្ដីមេត្តាករុណា.......................................................២៧៧
២៨ ការកាត់ស្រាយ កាលដើមដំបូង ...........................................................២៩១
២៩ ការបន្ទាបខ្លួនក្នុងការកាត់ស្រាយ.........................................................៣០៥
៣០ ការសម្រាករបស់យើងគឺនៅក្នុងព្រះអង្គ..............................................៣១៩

*“នៅពេលដែលគេចោទប្រកាន់លោកគ្រូ ម៉ាធិន លូសើរ (Martin Luther) និងលោកគ្រូ ចន ខិលវិន (John Calvin) ថាពួកគាត់កំពុងតែបង្រៀនគោលជំនឿថ្មី នោះពួកគាត់ក៏បានចង្អុលទៅកាន់លោកគ្រូ អហ្គូស្ទីន ថាជាគំរូនៃបុគ្គលម្នាក់ដែលបានបង្រៀននូវអ្វីៗដែលពួកគាត់កំពុងតែបង្រៀនដែរ...សៀវភៅ "ការលន់តួ" របស់គាត់គឺជាសៀវភៅជីវប្រវត្តិមួយដ៏សំខាន់បំផុតដែលធ្លាប់បានសរសេរឡើង។”*

*—R.C. Sproul*

*“អស់ប្រមាណជា១៦០០ឆ្នាំ សំឡេងរបស់លោកគ្រូ អហ្គូស្ទីន នៅបន្តស្រែកហៅមនុស្សមានបាបដែលស្រេកឃ្លានឲ្យទៅទទួលទានលើសេរីភាព និងអំណរដ៏ឧត្ដុង្គឧត្ដមរបស់ព្រះយេស៊ូវគ្រីស្ទ។”*

*—John Piper*

*“យកវាឡើងហើយអានវាចុះ។ យកវាឡើងហើយអានវាចុះ។”*

*—Leland Ryken*

*“ប្រសិនបើលោកអ្នករាយតារាងនៃសៀវភៅដ៏ល្អៗបំផុតពីលោកខាងលិច ហើយចម្រាញ់វាឲ្យសល់តែប្រាំក្បាល នោះសៀវភៅនៃ "ការលន់តួ" របស់លោកគ្រូ អហ្គូស្ទីន នឹងនៅតែមានកន្លែងសុវត្ថិភាពនៅក្នុងបញ្ជីនោះ។”*

*—Fred Sanders*

*“សៀវភៅ "ការលន់តួ" គឺមិនមែនគ្រាន់តែជាស្នាដៃឯកអក្សរសិល្ប៍គ្រីស្ទបរិស័ទប៉ុណ្ណោះនោះទេ ប៉ុន្តែគឺជាស្នាដៃឯកអក្សរសិល្ប៍ទូទៅ។”*

*—Carl R. Trueman*

*“ក្នុង “ការលន់តួ” របស់គាត់ លោកគ្រូ អហ្គូស្ទីន បានបង្កើតអក្សរសិល្ប៍ទេវវិទ្យាជីវប្រវត្តិ។ នេះគឺជាលើកដំបូងដែលអ្នកជឿម្នាក់នេះបានបើកបង្ហាញព្រលឹងរបស់គាត់ទៅកាន់ក្រុមជំនុំ អារម្មណ៍របស់គាត់ ក៏ដូចជាគំនិតរបស់គាត់ អំពើបាបក៏ដូចជាការលួតលាស់របស់គាត់ក្នុងព្រះគុណ។ មិនមែនថារាល់ជីវប្រវត្តិខាងឯវិញ្ញាណស័ក្តិសមនឹងទទួលបានពេលវេលារបស់យើងនោះទេ។ ប៉ុន្តែលោកគ្រូ អហ្គូស្ទីន គឺជាអ្នកគិតដ៏ពិសេសម្នាក់ ហើយទាក់ទងនឹងរាល់អំពើបាបរបស់គាត់ នោះគាត់ក៏ជាបុរសគំរូម្នាក់ដែរ។ ជីវិតរបស់គាត់ជាមួយនឹងព្រះជាម្ចាស់បានប្រទានពរដល់ក្រុមជំនុំអស់ជាច្រើនសតវត្សរ៍ ហើយឥឡូវនេះក៏ជាព្រះពរដល់យើងផងដែរ”។*

*—John Frame*

លោកអ្នកអាចស្តាប់សៀវភៅនេះជាសំឡេង
ដោយគ្រាន់តែចូលទៅកាន់គេហទំព័រ៖
confessionskhmer.com

# អារម្ភកថា

ប្រសិនបើលោកអ្នកបានសិក្សាប្រវត្តិសាស្ត្រក្រុមជំនុំ នោះចំណុចដំបូងដែលលោកអ្នកនឹងឃើញគឺថា នៅពេលដែលព្រះវិញ្ញាណបរិសុទ្ធបានឈប់បណ្ដាលឲ្យមនុស្សតែងព្រះគម្ពីរ មនុស្សយើងក៏បានចាប់ផ្ដើមបន្ថែមគំនិត និងប្រពៃណីរបស់ខ្លួនទៅលើសេចក្ដីពិត ទោះបើពួកគាត់បានព្យាយាមមានភាពស្មោះត្រង់ចំពោះព្រះគ្រីស្ទក៏ដោយ (កណ្ឌគម្ពីរវិវរណៈជាកណ្ឌចុងក្រោយដែលត្រូវបាននិពន្ធឡើងជិតឆ្នាំ៩៥នៃគ.ស.)។[១] លោកគ្រូអ៊ើលទ្បីស៍ អហ្គស្ទីន ដែលជាអ្នកនិពន្ធសៀវភៅនេះក៏មិនខុសពីហ្នឹងដែរ។ ដូចយើងទាំងអស់គ្នា គាត់ក៏មានចំណុចខុសឆ្គងខ្លះៗផងដែរ។ ប៉ុន្តែ ផ្ទុយពីយើង ភាពល្បីល្បាញ និងការជះឥទ្ធិពលរបស់លោកគ្រូ អហ្គស្ទីន មិនអាចមានការវាស់វែងបានឡើយ។ ដូចដែលលោកគ្រូ លោក អាដូហ្វ ហាន់ខេក (Adolf Harnack) បានលើកឡើងថា “លោកគ្រូអហ្គស្ទីន គឺជាគំរូដ៏ល្អបំផុតដែលក្រុមជំនុំធ្លាប់មានក្នុងចន្លោះសម័យរវាងសាវ័ក ប៉ុល និងលោកគ្រូ ម៉ាធិន លូសើរ ដែលជាអ្នកកំណែទម្រង់។ ក្រុមជំនុំគ្រីស្ទបរិស័ទមិនដែលមានបុគ្គលណាដែលអាចប្រៀបផ្ទឹមនឹងលោកគ្រូ អហ្គស្ទីន បានទេ។ ហើយទាក់ទងនឹងជ្រុងជ្រោយនៃការជះឥទ្ធិពលក៏មិនមានបុគ្គលណាអាចមកប្រៀបធៀបបានជាមួយនឹងគាត់បានដែរ”។[២]

រាល់ពេលដែលយើងអានអ្វីមួយ វាជារឿងសំខាន់ណាស់ដែលយើងត្រូវតែថ្លឹងថ្លែងអំពីអ្វីដែលយើងកំពុងអាននោះជាមួយនឹងព្រះបន្ទូល។ ហើយមិនថាជាមួយនឹងអ្នកនិពន្ធណាក៏ដោយ លើកលែងតែអ្នកនិពន្ធព្រះបន្ទូលដែលព្រះជាម្ចាស់បានបណ្ដាលឲ្យតែងនោះមិនមែនថារាល់គ្រប់អ្វីៗដែលលោកគ្រូ អហ្គស្ទីន បានបង្រៀនក៏មានភាពស៊ីគ្នាជាមួយនឹងព្រះគម្ពីរទាំងស្រុងផងដែរ។ ដ្បិតខណៈពេលដែលអ្នកកំណែទម្រង់ដូចជាលោក

---

១ លោកគ្រូ G. K. Beale, *The Book of Revelation: A Commentary on the Greek Text*, New International Greek Testament Commentary (Grand Rapids, MI; Carlisle, Cumbria: W.B. Eerdmans; Paternoster Press, ឆ្នាំ១៩៩៩), ទំព័រ៤។

២ លោកគ្រូ Harnack, Adolf. *Monasticism: Its Ideals and History*, and *The Confessions of St. Augustine: Two Lectures* by Adolf Harnack (Crown Theological Library, ឆ្នាំ១៩០១), ទំព័រ១២៣។

គ្រូ ចន ខិលវិន (John Calvin) និងលោកគ្រូ ម៉ាធិន លូសើរ (Martin Luther) “បានលើកឡើងសម្រង់សម្ដីរបស់លោកគ្រូ អហ្គស្ទីន ច្រើនជាងទេវវិទូផ្សេងៗទៀតនោះទេ”[៣] នោះក្រុមជំនុំរ៉ូមកាតូលិកក៏គោរពគាត់ថាជាគ្រូដ៏ល្អបំផុតម្នាក់របស់ខ្លួនផងដែរ។ នេះមានន័យថាលោកគ្រូ អហ្គស្ទីន មានគំនិតខ្វែងគ្នាក្នុងសេចក្ដីបង្រៀនរបស់គាត់ដែលអនុញ្ញាតឲ្យទាំងពួករ៉ូម៉ាំងកាតូលិក និងអ្នកកំណែទម្រង់សម្លឹងមើលទៅគាត់ជាប្រភពមួយ ដើម្បីធ្វើជាអំណះអំណាងនៃការកាត់ស្រាយព្រះគម្ពីរថាជាសេចក្ដីពិតរបស់ខ្លួន។ ឧទាហរណ៍៖ លោកគ្រូ អហ្គស្ទីន បានបង្រៀនយ៉ាងច្បាស់លាស់ថា ការទទួលបានសេចក្ដីសង្គ្រោះគឺតាមរយៈព្រះគុណដោយជំនឿតែមួយគត់ ទាំងតាមរយៈការសរសេរចុះអំពីជីវប្រវត្តិរបស់គាត់នៅក្នុងសៀវភៅ “ការលន់តួ” និងក្នុងការនិពន្ធនានារបស់គាត់។ គាត់ក៏បានដឹងដែរថា គាត់ក៏មានចំណុចកំហុសឆ្គងខ្លះៗ។ គាត់ក៏បានដឹងថា ខ្លួនក៏ជាមនុស្សមានបាបដែរ។ ហើយថាគាត់ក៏មិនទទួលបានសេចក្ដីសង្គ្រោះតាមរយៈការប្រព្រឹត្តទង្វើល្អដែលគាត់បានធ្វើនោះទេ។ ដូចដែលគាត់បានសរសេរ៖ “ឱព្រះអម្ចាស់អើយ! ទ្រង់គឺជាជំនួយ និងជាព្រះអង្គប្រោសលោះរបស់ទូលបង្គំ។ ឥឡូវ ទូលបង្គំនឹងប្រកាស ហើយលន់តួក្នុងព្រះនាមរបស់ព្រះអង្គអំពីរបៀបដែលទ្រង់បានរំដោះទូលបង្គំចេញពីច្រវាក់នៃការប្រាថ្នាខាងឯផ្លូវភេទដែលទូលបង្គំបានជាប់ចំណងយ៉ាងខ្លាំង និងចេញពីភាពជាទាសករនៃលោកីយ៍ខាងឯការប្រព្រឹត្ត”។[៤] ហើយថា “គ្មានបុគ្គលណាអាចទទួលបានការរាប់ជាសុចរិតតាមរយៈទង្វើល្អរបស់ខ្លួននោះទេ ដោយសារគាត់មិនអាចធ្វើទង្វើល្អបាន លុះត្រាតែគាត់បានទទួលការរាប់ជាសុចរិតជាមុនសិន។ ប៉ុន្តែ ព្រះជាម្ចាស់រាប់ពួកសាសន៍ដទៃថាសុចរិតតាមរយៈជំនឿ”។[៥] ប៉ុន្តែ ក្នុងពេលតែមួយ ក៏គាត់បានប្រកាន់ខ្ជាប់នូវទស្សនៈនៃការជ្រមុជទឹកដែលហាក់បីដូចជាបង្ហាញថាទង្វើនៃបុគ្គលណាម្នាក់ក៏សំខាន់ដែរក្នុងការទទួលបានការកើតជាថ្មី។ ប៉ុន្តែ ការជ្រមុជទឹកនៃការកើតជាថ្មី និងសេចក្ដីសង្គ្រោះតាមរយៈព្រះគុណដោយជំនឿតែមួយគត់មិនមានភាពស៊ីគ្នានោះទេ។ ហើយរបៀបដែលលោកគ្រូ អហ្គស្ទីន និយាយអំពីការជ្រមុជទឹកហាក់បីដូចជាមានភាពផ្ទុយគ្នាទាំងស្រុង

៣ លោកគ្រូ Matthews, Gareth B. *The Augustinian Tradition.* United Kingdom: University of California Press, ឆ្នាំ១៩៩៩, ទំព័រ២៥២។

៤ *“ការលន់តួ”* សៀវភៅទី៨, ជំពូកទី២១, កថាខណ្ឌទី១៣។ ការសង្កត់អត្ថន័យគឺពីអ្នកនិពន្ធ។

៥ លោកគ្រូ John H. S. Burleigh, *Augustine: Earlier Writings, The Library of Christian Classics* (Philadelphia: The Westminster Press, ឆ្នាំ១៩៥៣), ទំព័រ៣៨៩។

នឹងបទពិសោធន៍នៃសេចក្តីសង្គ្រោះនៃព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការដាស់តឿន និងការបង្កើតជាថ្មីក្នុងជីវិតរបស់គាត់តាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែរ។ គាត់ក៏ហាក់បីដូចជាបានលើកឡើងនៅក្នុងសៀវភៅ «ការលន់តួ» ថានៅពេលដែលមិត្តភក្តិម្នាក់របស់គាត់បានទទួលពិធីជ្រមុជទឹក ខណៈពេលដែលគាត់បាត់បង់ស្មារតី ការនោះហាក់បីដូចជាមានឥទ្ធិពលនៃការសម្អាតមិត្តភក្តិរបស់គាត់ផងដែរ។[៦] ប៉ុន្តែ មើលទៅហាក់បីដូចជាថាលោកគ្រូ អហ្គូស្ទីន មានការតស៊ូជាមួយនឹងការដាក់ពិធីជ្រមុជទឹកនៅកម្រិតដូចគ្នាជាមួយនឹងជំនឿ ដោយសារគាត់បានសរសេរថា «ដោយពិចារណាលើចំណុចនេះម្តងហើយម្តងទៀត នោះខ្ញុំមិនគ្រាន់តែឃើញថា ការរងទុក្ខសម្រាប់ព្រះនាមព្រះគ្រីស្ទក៏អាចផ្តល់ជូននូវអ្វីដែលខ្វះខាតតាមរយៈពិធីជ្រមុជទឹកប៉ុណ្ណោះទេ ប៉ុន្តែសូម្បីតែជំនឿ និងការផ្លាស់ប្រែចិត្ត ប្រសិនបើទំនងដោយសារកាលៈទេសៈនៃពេលវេលានោះមិនអាចមានជំនួយតាមរយៈការប្រារព្ធនូវអាថ៌កំបាំងនៃការជ្រមុជទឹកដែរ»។[៧] ហើយក៏នៅមានសេចក្តីបង្រៀនមួយចំនួនទៀតដែលមានបញ្ហាផងដែរៈ ការអធិស្ឋានសម្រាប់អ្នកស្លាប់ ការមានអ្នកស្នងតំណែងដោយគ្មានការរំខានចាប់ពីសាវ័ក ពេត្រុស ក្នុងនាមជាព្រឹទ្ធាចារ្យដំបូងនៃទីក្រុងរ៉ូម ភាពជាក្រមុំព្រហ្មចារីដ៏អចិន្ត្រៃយ៍របស់នាង ម៉ារា ហើយថែមទាំងបានក្រាលផ្លូវសម្រាប់សេចក្តីបង្រៀនថានាង ម៉ារា ផ្ទាល់ក៏មិនមានអំពើបាបដែរ។

ដូច្នេះ តើនេះមានន័យថា យើងត្រូវតែបោះបង់ចោលនូវរាល់គ្រប់អ្វីទាំងអស់ដែលលោកគ្រូ អហ្គូស្ទីន បានសរសេរមែនឬ? យើងខ្ញុំគិតថាទេ! ដ្បិតខណៈពេលដែលចំណុចខ្វាក់ និងអំពើបាបរបស់គាត់ទំនងជាមានភាពខុសគ្នាៗពីយើង នោះអាចមានន័យថាចំណុចដែលគាត់បានឃើញយ៉ាងច្បាស់លាស់គឺជាចំណុចដែលយើងកំពុងតែមានការខ្វាក់ជាមួយផងដែរ។ យើងខ្ញុំជឿថា ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងថ្លឹងថ្លែងជីវិតនៃអស់អ្នកដែលបានធ្លាប់រស់នៅមុនយើង ជាពិសេសអស់អ្នកដែលបានរស់នៅយ៉ាងយូរពីមុន ហើយឃើញភាពស្រស់ស្អាតនៃព្រះគុណរបស់ទ្រង់តាមរយៈជំនឿមិនល្អឥតខ្ចោះរបស់ពួកគាត់។ ដូចដែលអ្នកនិពន្ធកណ្ឌគម្ពីរទំនុកតម្កើងម្នាក់បានលើកឡើងថា «សេចក្តីនេះនឹងបានកត់ទុកសម្រាប់ដំណមនុស្សជាន់ក្រោយ ឲ្យបណ្តាមនុស្សដែលនឹងកើតឡើង

៦ *«ការលន់តួ»* សៀវភៅទី៤, ជំពូកទី៧, កថាខណ្ឌទី៨។

៧ លោកគ្រូ អហ្គូស្ទីន, *On Baptism, Against the Donatists*, ៤:២២:២៩។

បានសរសើរតម្កើងដល់ព្រះយេហូវ៉ា» (ទំនុកតម្កើង ១០២:១៨)។ ហើយជាពិសេសក្នុងករណីនៃលោកគ្រូ អហ្គូស្ទីន ខណៈពេលដែលក្រុមជំនុំរ៉ូម៉ាំងកាតូលិកឲ្យតម្លៃយ៉ាងខ្ពស់ដល់គាត់ គឺតាមរយៈចលនាកំណែទម្រង់នៅសតវត្សរ៍ទី១៦នោះហើយដែលយើងឃើញថា «អ្នកកំណែទម្រង់បានឃើញនូវជ័យជម្នះជាមូលដ្ឋាននៃគោលជំនឿព្រះគុណរបស់លោកគ្រូ អហ្គូស្ទីន លើគោលជំនឿនៃក្រុមជំនុំរបស់លោកគ្រូ អហ្គូស្ទីន»។[៨]

ក្នុងដំណើររឿងរបស់លោកគ្រូ អហ្គូស្ទីន ក៏ដូចជាខ្លួនយើងម្នាក់ៗដែរ គឺជាដំណើររឿងនៃការដែលព្រះគុណរបស់ព្រះជាម្ចាស់កំពុងតែចែងចាំងពន្លឺភ្លឺជាងចំណុចខុសឆ្គងរបស់យើង។ ដូចដែលលោកគ្រូ ចន ផាបភ័រ បានសរសេរ៖ «សម្រាប់លោកគ្រូ អហ្គូស្ទីន អំណាចដ៏ខ្លាំងនៃព្រះគុណគឺជាអំណាចនៃ "អំណរដ៏ឧត្តុង្គឧត្តម"។ តាមរយៈចំណុចនៃការមួយនេះ នោះគាត់ក៏ទទួលបានការរំដោះចេញពីចំណងជីវិតនៃការបំពេញកាមតណ្ហាខាងឯផ្លូវភេទ និងការមានអំនួតក្នុងទស្សនវិជ្ជា។ ដោយរកឃើញថា នៅក្រោមអំណាចនៃការអួតអាងរបស់មនុស្សមានឆន្ទៈដ៏ពុះកញ្ជ្រោលនៃសេចក្តីប្រាថ្នាដែលកំពុងឃុំយើងទុកជាឈ្លើយចំពោះការជ្រើសរើសដែលមិនសមហេតុសមផល ដែលការនោះបានបើកផ្លូវឲ្យឃើញព្រះគុណថាជាជ័យជម្នះនៃ "អំណរដ៏ឧត្តុង្គឧត្តម"»។[៩]

សេចក្តីអធិស្ឋានរបស់យើងខ្ញុំគឺថា ខណៈពេលដែលលោកអ្នកអានសៀវភៅនេះ នោះជាថ្មីម្តងទៀត ភាពស្រស់ស្អាតនៃដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនឹងទាក់ទាញលោកអ្នក ហើយថាជំនឿរបស់លោកអ្នកនឹងទទួលការពង្រឹងតាមរយៈការស្វែងយល់អំពីជីវិតរបស់លោកគ្រូ អ៊ូរេលាស អហ្គូស្ទីន។

---

៨ លោកគ្រូ Warfield, *Calvin and Augustine*, ទំព័រ៣២២-៣២៣។

៩ លោកគ្រូ Piper, John. *The Legacy of Sovereign Joy.* (Wheaton, IL: Crossway, ឆ្នាំ២០០០), ទំព័រ១១។

សេចក្តីផ្តើម

# អំណរដ៏ឧត្តុង្គឧត្តម

*និពន្ធដោយ លោកគ្រូ ចន ផាបភ័រ*[១]

*អំណាចដែលនាំឲ្យមានសេរីនៃភាពអរសប្បាយដ៏បរិសុទ្ធក្នុងជីវិត និងគំនិតរបស់លោកគ្រូ អហ្គូស្ទីន*

## ទីបញ្ចប់នៃចក្រភពមួយ

នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ៤១០នៃគ.ស. រឿងដែលមិននឹកស្មានដល់បានកើតឡើង។ បន្ទាប់ពីប្រមាណ៩០០ឆ្នាំនៃសន្តិភាពដែលមិនអាចឆ្លងចូលបាន នោះទីក្រុងរ៉ូមក៏ត្រូវបានបំផ្លាញចោលដោយទ័ពពួកអាឡឺម៉ង់ (Germans) ដឹកនាំដោយលោក អ័ល៉ារិក (Alaric)។ លោកគ្រូ ជេរ៉ូម (Jerome) ដែលជាអ្នកបកប្រែព្រះគម្ពីរទៅជាភាសាឡាតាំង កាលនោះគាត់កំពុងនៅស្រុក ប៉ាឡេស្ទីន (Palestine) ហើយគាត់ក៏បានសរសេរថា “ប្រសិនបើទីក្រុងរ៉ូមវិនាស តើអ្វីទៅអាចមានសន្តិភាពបាន?”។[២] ចក្រភពរ៉ូមមិនបានវិនាសភ្លាមៗ។ ហើយប្រមាណជា៦៦ឆ្នាំកន្លងមកទៀត នោះទើបពួកអាឡឺម៉ង់ ធ្វើឲ្យអធិរាជដួលរលំ។ ប៉ុន្តែរញ្ជួយរលកនៃការវាយលុកបានរាលដាលដល់ទីក្រុងហិផ្ប៉ូ (Hippo) ប្រមាណជា

១ លោកគ្រូ Piper, John. The Legacy of Sovereign Joy. (Wheaton, IL: Crossway, ឆ្នាំ២០០០), ទំព័រ៤១-៧៤។ បកប្រែដោយមានការអនុញ្ញាត។

២ លោកគ្រូ Peter Brown, Augustine of Hippo (Berkeley, CA: University of California Press, ឆ្នាំ១៩៦៩), ទំព័រ២៨៩។

៧២០ គីឡូម៉ែត្រនៃទិសខាងត្បូងឆៀងខាងលិចនៃទីក្រុងរ៉ូមនៅលើឆ្នេរសមុទ្រអាហ្វ្រិកខាងជើង ដែលជាទីកន្លែងដែលលោកគ្រូ អហ្គូស្ទីន ជាគ្រូគង្វាល។ កាលនោះគាត់មានអាយុ៥៥ឆ្នាំហើយក៏កំពុងតែពេញកម្លាំងក្នុងព័ន្ធកិច្ចរបស់គាត់ដែរ។ ហើយគាត់ក៏នឹងបន្តរស់នៅប្រមាណជា២០ឆ្នាំទៀត ហើយស្លាប់នៅថ្ងៃទី២៨ ខែសីហាឆ្នាំ៤៣០ ខណៈពេលដែលពួកវិនដូលស៍ (Vandals) ដែលមានចំនួនប្រមាណជា៨០,០០០នាក់កំពុងតែត្រៀមខ្លួនវាយឆ្មក់ទីក្រុង។ និយាយម្យ៉ាងវិញទៀតទៅលោកគ្រូ អហ្គូស្ទីន បានរស់នៅក្នុងពេលវេលាដ៏ច្របូកច្របល់មួយរវាងការផ្លាស់ប្តូររដ្ឋទាំងមូល។

គាត់បានឮអំពីការដែលពួកវិនដូលស៍ធ្វើទារុណកម្មគ្រូខាងឯកាតូលិកពីរនាក់ រហូតដល់ស្លាប់នៅពេលដែលពួកគេវាយលុក ប៉ុន្តែនៅពេលដែលមិត្តភក្តិរបស់គាត់បានលើកឡើងនូវព្រះបន្ទូលរបស់ព្រះយេស៊ូវទៅកាន់គាត់៖ "ចូរគេចចេញទៅក្រុងមួយទៀត" (ម៉ាថាយ ១០:២៣) នោះគាត់ក៏បានឆ្លើយតបវិញថា "សូមកុំអនុញ្ញាតឲ្យបុគ្គលណាម្នាក់មានបំណងចិត្តកាន់នាវារបស់យើងដោយឲ្យតម្លៃតិចត្រង់ថា នាវិកជាពិសេសកាប់ពីតែនគួរបោះបង់នាវានោះចោលក្នុងគ្រាគ្រោះថ្នាក់ឡើយ"។[៣] គាត់បានធ្វើជាគ្រូគង្វាលនៅទីក្រុងហិផផូ តាំងពីឆ្នាំ៣៩០នៃគ.ស. ហើយមុននោះក៏បានធ្វើជាអ្នកចាស់ទុំម្នាក់ដែលអធិប្បាយអស់រយៈពេល៥ឆ្នាំ។ ដូច្នេះ គាត់បានបម្រើក្រុមជំនុំអស់រយៈពេលជិត៤០ឆ្នាំ ហើយក្នុងសង្គមគ្រីស្ទបរិស័ទក៏មានគេស្គាល់គាត់ជាច្រើនថាជាអ្នកលង់ស៊ុបជាមួយនឹងព្រះជាម្ចាស់ និងព្រះគម្ពីរ ជាអ្នកគង្វាលក្រុមជំនុំរបស់គាត់ដែលមានជំនាញខាងឯវោហារ និងការបង្ហាត់បង្រៀន។ ហើយក៏ជាអ្នកដែលការពារជំនឿប្រឆាំងនឹងការគំរាមកំហែងលើគោលជំនឿចម្បងៗនៅយុគសម័យរបស់គាត់ ជាពិសេសជាមួយនឹងពួកមានិហ្កៀន[៤] ពួក

---

៣ ក្នុងសៀវភៅដដែល, ទំព័រ៤២៥។

៤ ពីអាយុ១៩-២៨ឆ្នាំលោកគ្រូ អហ្គូស្ទីន កំពុងតែស្រឡាញ់ក្រុមមានិហ្កៀនយ៉ាងខ្លាំង ប៉ុន្តែបន្ទាប់មកក៏មានការស្រងាកចិត្តយ៉ាងខ្លាំងជាមួយនឹងក្រុមនោះវិញ ហើយក៏បានក្លាយជាអ្នកជម្លោះដ៏ខ្លាំងម្នាក់ក្នុងការជែកញែកខាងឯទស្សនវិជ្ជា (អ៊ែរិលលីអូស៍ អហ្គូស្ទីន, "*ការលន់តួ*, បានបកប្រែដោយលោកគ្រូ R. S. Pine-Coffin [New York: Penguin Books, ឆ្នាំ១៩៦១], ទំព័រ៧១ [IV, ១])។ ក្រុមមានិហ្កៀនគឺជាក្រុមខុសឆ្គងដែលឃ្លាតចាកពីសេចក្តីពិតនៃជំនឿគ្រីស្ទបរិស័ទ ដែលលោក ម៉ែនី បានបង្កើត គាត់បានអះអាងថាគាត់បានទទួលសារដែលព្រះជាម្ចាស់បានប្រទានឲ្យគាត់នៅឯស្រុកមេសូប៉ូតាមី (Mesopotamia) ប៉ុន្តែរាជរដ្ឋាភិបាលពើស៊ានបានសម្លាប់គាត់ចោលនៅក្នុងឆ្នាំ២៧៦នៃគ.ស.។ ជំនឿគ្រីស្ទបរិស័ទ "ថ្មី" មួយនេះ ដែលគាត់បានបង្កើត បានចាត់ទុកព្រះគម្ពីរសញ្ញាចាស់ថា មិនពាក់ព័ន្ធខាងឯព្រលឹងវិញ្ញាណ ហើយក៏គួរជាទីស្អប់ខ្ពើមដែរ។ ក្នុងជំនឿគ្រីស្ទបរិស័ទរបស់លោក ម៉ែនី "ព្រះគ្រីស្ទមិនត្រូវការទីបន្ទាល់របស់ពួកសាសន៍ហេប្រឺ៖ ព្រះអង្គមានបន្ទូលសម្រាប់ខ្លួនឯង ទៅកាន់ព្រលឹងផ្ទាល់ តាមរយៈសារដ៏ថ្លៃថ្នូរខ្ពង់ខ្ពស់របស់ទ្រង់ តាមរយៈព្រះប្រាជ្ញា និងការអស្ចារ្យរបស់ទ្រង់។ ព្រះជាម្ចាស់មិនត្រូវការអាសនាណាផ្សេង ក្រៅពីព្រះចិន្តារបស់ទ្រង់ទេ។" (លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ៤៣-៤៤)។ បញ្ហានៃអំពើអាក្រក់គឺនៅក្នុងចំណុចស្នូលនៃការដែលលោកគ្រូ អហ្គូស្ទីន មានការពាក់ព័ន្ធជាមួយនៅក្រុមមានិហ្កៀន។ "ពួកគាត់ប្រកាន់ខ្ជាប់តាមទ្វេភាពនិយម៖ ពួកគេមានការជឿជាក់យ៉ាងខ្លាំងថា អំពើអាក្រក់មិនអាចកើតចេញ

ដូណាតទីស៍[៥] និងពួកភីលេហ្គៀន។[៦]

## ការជះឥទ្ធិពលដែលមិនអាចប្រៀបផ្ទឹមបាន ហើយក៏មិនសមហេតុផល

លោកគ្រូ អហ្គូស្ទីន បាននាំឲ្យមានរបរាំងក្នុងប្រវត្តិសាស្ត្រនៃក្រុមជំនុំគ្រីស្ទបរិស័ទតាមរយៈវេទិកានេះនៅអាហ្វ្រិកខាងជើង និងតាមរយៈភាពស្មោះត្រង់ដែលគួរឲ្យកត់សម្គាល់

---

ពីព្រះជាម្ចាស់ដ៏ល្អបាននោះឡើយ ហើយពួកគាត់បានជឿថា អំពើអាក្រក់កើតចេញពីការវាយលុកលើអំពើល្អ—“នគរនៃពន្លឺ”—តាមរយៈទ័ពសត្រូវនៃអំពើអាក្រក់ គ្មានអំណាចស្មើគ្នា នៅអស់កល្បជានិច្ច មានការដាច់ដោយឡែកពីគ្នាទាំងស្រុងពី—“នគរនៃភាពងងឹត” (លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ៤៧)។ “តម្រូវការនៃសេចក្ដីសង្គ្រោះជាប្រភពទឹកដ៏ល្អឥតខ្ចោះដែលមិនមានភាពស្រអាប់បាត់បង់ក្នុងខ្លួនឯងផ្ទាល់ក៏បានផុសឡើង ទំនងនេះគឺជាការប្រឡាក់ដ៏ធ្ងន់ធ្ងរបំផុតក្នុងការដែលដែលលោកគ្រូ អហ្គូស្ទីន ប្រកាន់ខ្ជាប់តាមក្រុមមានិហ្គៀន....“ទូលបង្គំនៅតែជឿថា “គឺមិនមែនយើងទេដែលជាអ្នកប្រព្រឹត្តអំពើបាប ប៉ុន្តែនិស្ស័យមួយផ្សេងទៀតដែលធ្វើអំពើបាបក្នុងយើង”” ([*“ការលន់តួ”*, V, x, ១៨] លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ៥១)។ លោកគ្រូ អហ្គូស្ទីន ផ្ដល់ជូននូវការពន្យល់របស់គាត់ផ្ទាល់អំពីមូលហេតុដែលគាត់លង់ក្នុងសេចក្ដីខុសឆ្គងនៃក្រុមមានិហ្គៀននោះ៖ “ទូលបង្គំបានគិតថា ទ្រង់គឺជាព្រះអង្គដ៏ជាព្រះជាម្ចាស់នៃសេចក្ដីពិតគឺជាពន្លឺដ៏ចែងចាំង ដែលមិនមានព្រំដែនខាងឯសាច់ឈាម ហើយទូលបង្គំគឺជាដុំតូចមួយដែលបានបែកចេញពីនោះ” (*“ការលន់តួ”*, ទំព័រ៨៩ [V, ១៦])។ “ទូលបង្គំបានគិតថា អ្វីណាមួយដែលមិនមានការវាស់វែងបាននៅលើលំហអាកាស ដាច់ខាតគឺមិនមែនជាអ្វីទាល់តែសោះ....ទូលបង្គំមិនបានដឹងថាអំណាចនៃការគិត ដែលទូលបង្គំបានប្រើប្រាស់ ដើម្បីបង្កើតរូបភាពទាំងនេះ គឺវាផ្ទាល់មានចំណុចខុសៗគ្នាទាំងស្រុងពីពួកវា។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយក៏វាមិនអាចបង្កើតពួកវាបាន លុះត្រាតែពួកវាផ្ទាល់គឺជាចំណុចណាមួយផងដែរ ហើយក៏ជាចំណុចអ្វីមួយដែលខ្លាំងល្មមក្នុងការធ្វើការនោះបាន” (*“ការលន់តួ”*, ទំព័រ១៣៤ [VII, ១])។ “ដោយសារការគោរពប្រតិបត្តិព្រះដែលទូលបង្គំមានតិចតួចបែបនោះបានបង្ខំឲ្យទូលបង្គំជឿថាព្រះអង្គល្អ ដូច្នេះទ្រង់មិនអាចបង្កើតឲ្យមានប្រភពនៃអំពើអាក្រក់បានឡើយ ដូច្នេះទូលបង្គំក៏បាននឹកស្រមៃថា មានភាគីពីរដែលជំទាស់គ្នា ដែលទាំងពីរគ្មានព្រំដែន ប៉ុន្តែអំពើអាក្រក់មានកម្រិតតូចតាច ហើយអំពើល្អមានកម្រិតធំជាង (*“ការលន់តួ”*, ទំព័រ១០៤ [V, ១០]។ ចេញពីការជាប់អន្ទាក់នេះលោកគ្រូ អហ្គូស្ទីន ក៏បានក្លាយជាអ្នកជជែកវែកញែកការពារជំនឿដ៏ពិតនៃព្រះគម្ពីរដ៏ឆ្នើមម្នាក់អំពីអធិបតេយ្យភាពអតិសេដ្ឋរបស់ព្រះជាម្ចាស់។

៥ ពួកដូណាតទីស៍ “គឺជាចលនាគ្រីស្ទបរិស័ទនៅក្នុងសតវត្សទី៤ និង៥ ដែលបានអះអាងថា សុពលភាពនៃពិធីបង្គ្រព្រះគុណគឺអាស្រ័យទៅលើលក្ខណសម្បត្តិខាងឯសីលធម៌របស់គ្រូ។ ជាលទ្ធផលនៃការតែងតាំងគ្រូគង្វាលម្នាក់នៅឯក្រុងកាតធេ វាបានងើបក្បាលឡើងនៅឆ្នាំ៣១១នៃគ.ស.។ ក្នុងចំណោមគ្រូគង្វាលបីនាក់ដែលគេបានតែងតាំង គេជឿថាម្នាក់គឺជាអ្នកប្រកាន់ខ្ជាប់តាមទំនៀមទម្លាប់ ដែលនេះមានន័យថាគាត់គឺជាគ្រូម្នាក់ក្នុងចំណោមគ្រូនានាដែលមានពិរុទ្ធភាពក្នុងការឲ្យច្បាប់ចម្លងព្រះគម្ពីរទៅកាន់អធិរាជ ដៃអូក្លេសិន (Diocletian) ដែលជាទ័ពជិះជាន់។ មានគ្រូគង្វាល៧០នាក់ក៏បានជុំគ្នាធ្វើជាក្រុមប្រឹក្សាជំទាស់នៅឯក្រុងកាតធេ ហើយក៏បានប្រកាសថាការតែងតាំងគ្រូម្នាក់នោះគឺមិនត្រឹមត្រូវទេ។ ពួកគាត់ប្រកាន់ខ្ជាប់ថា ដាច់ខាត ក្រុមជំនុំត្រូវតែបដិសេធបុគ្គលបែបនោះដែលមានពិរុទ្ធភាពទាក់ទងទៅនឹងអំពើបាបដ៏ធ្ងន់ធ្ងរ ហើយជាលទ្ធផល អ្នកប្រកាន់ខ្ជាប់តាមទំនៀមទម្លាប់ដូចមនុស្សបែបនោះមិនអាចចាត់ចែងពិធីបង្គ្រព្រះគុណបានទេ។ ក្រុមប្រឹក្សាជំទាស់ក៏បានដកសិទ្ធិ និងអភ័យឯកសិទ្ធិរបស់គ្រូពីក្រុងកាតធេនៅពេលដែលគាត់បានបដិសេធមិនមកជួបពួកគេ។ បួនឆ្នាំក្រោយមក នៅពេលដែលគ្រូគង្វាលថ្មីម្នាក់បានស្លាប់លោក ដូណាតទីស៍ ដែលជាទេវវិទូដ៏ឆ្នើមម្នាក់ក៏បានក្លាយជាគ្រូគង្វាលនៅឯក្រុងកាតធេ ហើយក្រោយមកទៀត ចលនានោះក៏បានយកឈ្មោះគាត់មកប្រើប្រាស់” (*Donatism*, Microsoft ® Encarta ® Encyclopedia ៩៩, © ១៩៩៣-១៩៩៨ Microsoft Corporation. រក្សាសិទ្ធិគ្រប់បែបយ៉ាង)។ ក្នុងជម្លោះមួយនេះ យើងឃើញអំពីការគាំទ្ររបស់លោកគ្រូ អហ្គូស្ទីន ជាមួយនឹងពិធីបង្គ្រព្រះគុណដែលមានលក្ខណៈត្រាប់តាមក្រុមជំនុំកាតូលិកដែលយើងបានសួរនាំពីក្នុងសេចក្ដីផ្ដើម។ (Note: we may not need the last sentence because our Intro is not like Piper’s.) សូមមើលទំព័រ២៦-២៧។

៦ យើងនឹងពន្យល់បន្ថែមទៀតលើសេចក្ដីបង្រៀនរបស់លោក ភីលេហ្គៀស៍ នៅក្នុងជំពូកក្រោយៗ។

របស់គាត់ក្នុងការអនុម័ត និងការការពារជំនឿគ្រីស្ទបរិស័ទសម្រាប់សម័យរបស់គាត់។ ឥទ្ធិពលរបស់គាត់នៅលោកខាងលិចគឺពិតជាគួរឲ្យភ្ញាក់ផ្អើលមែន។ លោក អាដូហ្វ ហាន់ខេក (Adolf Harnack) បានមានប្រសាសន៍ថា លោកគ្រូ អហ្គូស្ទីន គឺជាគំរូដ៏ល្អបំផុតដែលក្រុមជំនុំធ្លាប់មានក្នុងចន្លោះរវាងសាវ័ក ប៉ុល និងលោកគ្រូ ម៉ាធិន លូសើរ ដែលជាអ្នកធ្វើកំណែទម្រង់។[៧] លោកគ្រូ បេនយ៉ាមីន វ័រហ្វៀល (Benjamin Warfield) បានវែកញែកថាតាមរយៈការនិពន្ធរបស់លោកគ្រូ អហ្គូស្ទីន នោះគាត់ "ក៏បានជ្រាបចូលក្នុងទាំងក្រុមជំនុំ និងអ្នកខាងឯលោកីយ៍ហើយក៏មានឥទ្ធិពលដែលនាំឲ្យមានការផ្លាស់ប្តូរ ហើយក៏មិនគ្រាន់តែបានបង្កើតឥទ្ធិពលដ៏សំខាន់ក្នុងប្រវត្តិសាស្ត្រក្រុមជំនុំប៉ុណ្ណោះទេ ប៉ុន្តែ...ក៏បានរៀបចំផ្លូវនៃប្រវត្តិសាស្ត្ររបស់ក្រុមជំនុំនៅឯលោកខាងលិចដល់បច្ចុប្បន្នកាលនេះផងដែរ"។[៨] គាត់មាន "អំណោយទានខាងឯអក្សរសាស្ត្រ...គ្មានគូប្រៀបបានក្នុងព្រឹត្តិការណ៍ប្រវត្តិសាស្ត្រក្រុមជំនុំ"។[៩] "ការអភិវឌ្ឍទាំងមូលនៃជីវិតរបស់លោកខាងលិច ក្នុងគ្រប់ចំណុចទាំងអស់ គឺសុទ្ធតែទទួលបានឥទ្ធិពលយ៉ាងខ្លាំងតាមរយៈការបង្រៀនរបស់គាត់"។[១០] អ្នកបោះពុម្ពទស្សនាវដ្តី "ប្រវត្តិសាស្ត្រគ្រីស្ទបរិស័ទ" បានលើកឡើងយ៉ាងសាមញ្ញថា "បន្ទាប់ពីព្រះយេស៊ូវ និងសាវ័ក ប៉ុល នោះលោកគ្រូ អហ្គូស្ទីន គឺជាបុគ្គលដែលជះឥទ្ធិពលខ្លាំងជាងគេក្នុងប្រវត្តិសាស្ត្រគ្រីស្ទបរិស័ទ"។[១១]

ចំណុចពិតដែលគួរឲ្យកត់សម្គាល់ខ្លាំងជាងគេអំពីឥទ្ធិពលរបស់លោកគ្រូ អហ្គូស្ទីន គឺត្រង់ថាគាត់ជះឥទ្ធិពលលើចលនាពីរក្រុមដែលប្រឆាំងគ្នា។ ក្រុមជំនុំរ៉ូម៉ាំងកាតូលិកស្រឡាញ់គាត់យ៉ាងខ្លាំងក្នុងចំណោមគ្រូៗដ៏អស្ចារ្យផ្សេងទៀត[១២] ប៉ុន្តែទោះជាយ៉ាងណាក៏

---

៧ ដកស្រង់ចេញពី *Monasticism and the Confessions of St. Augustine,* ក្នុងសៀវភៅរបស់លោកគ្រូ Benjamin B. Warfield, *Calvin and Augustine* (Philadelphia: The Presbyterian and Reformed Publishing Co., ឆ្នាំ១៩៥៦), ទំព័រ៣០៦។

៨ ក្នុងសៀវភៅដដែល។

៩ ក្នុងសៀវភៅដដែល, ទំព័រ៣១២។

១០ ក្នុងសៀវភៅដដែល, ទំព័រ៣១០។

១១ សៀវភៅ *"ប្រវត្តិសាស្ត្រគ្រីស្ទបរិស័ទ" (Christian History)*, Vol. VI, លេខ៣, ទំព័រ២។

១២ "ក្រុមប្រឹក្សានៅឯទីក្រុង អូរ៉ុង *(The Council of Orange)* បានទទួលស្គាល់សេចក្តីបង្រៀនរបស់គាត់លើព្រះគុណ។ ក្រុមប្រឹក្សានៅឯទីក្រុង ត្រេន *(The Council of Trent)* បានទទួលស្គាល់សេចក្តីបង្រៀនរបស់គាត់លើអំពើបាបដែលជាមរតក និងការរាប់ជាសុចរិត។ ក្រុមប្រឹក្សានៅឯទីក្រុង វ៉ាទីកង់ *(The Council of Vatican I)* បានទទួលស្គាល់សេចក្តីបង្រៀនរបស់គាត់លើទំនាក់ទំនងរវាងហេតុផល និងជំនឿ។ ហើយនៅក្នុងសម័យកាលយើងផ្ទាល់ លោក វ៉ាទីកង់ ទី២ បានយកមកធ្វើជាសេចក្តីបង្រៀនរបស់គាត់ផ្ទាល់លើអាថ៌កំបាំងនៃក្រុមជំនុំ និងអាថ៌កំបាំងនៃបុគ្គលិកលក្ខណៈជាមនុស្ស..." (លោកគ្រូ Agostino Trapè, *Saint Augustine: Man, Pastor, Mystic* [New York: Catholic Book Publishing, ឆ្នាំ១៩៨៦], ទំព័រ៣៣៣)។

ដោយក៏លោកគ្រូ អហ្គូស្ទីន ជាអ្នកដែល "ផ្តល់នូវកំណែទម្រង់មកយើង"—មិនមែនគ្រាន់តែដោយសារ "លោកគ្រូ ម៉ាធិន លូសើរ គឺជាសង្ឃក្រោមក្រុមលោកគ្រូ អហ្គូស្ទីន ឬក៏ថាដោយសារលោកគ្រូ ចន ខិលវិន បានលើកឡើងសម្រង់សម្ដីរបស់លោកគ្រូ អហ្គូស្ទីន ច្រើនជាងទេវវិទូផ្សេងៗទៀតនោះទេ...[ប៉ុន្តែដោយសារ] កំណែទម្រង់បានឃើញជ័យជម្នះមូលដ្ឋាននៃគោលជំនឿព្រះគុណរបស់លោកគ្រូ អហ្គូស្ទីន លើកើ្ដដំណែលរបស់លោកគ្រូ ភីលេហ្គៀន ទាក់ទងនឹងទស្សនៈអំពីមនុស្សជាតិ"។[១៣] ទាំងសងខាង ក្នុងភាពខ្វែងគំនិតគ្នា [រវាងអ្នកកំណែទម្រង់ និង អ្នកប្រឆាំងនឹងការកែទម្រង់ (ពួកកាតូលិក)] បានយកការនិពន្ធរបស់លោកគ្រូ អហ្គូស្ទីន ជាអំណះអំណាងយ៉ាងខ្លាំង។[១៤]

លោក ហេនរី ឆាដវេក (Henry Chadwick) ព្យាយាមបង្ហាញពីវិសាលភាពនៃឥទ្ធិពលរបស់លោកគ្រូ អហ្គូស្ទីន ដោយចង្អុលបង្ហាញថា "លោកគ្រូ អានសឹម (Anselm), លោកគ្រូ អាហ្គីណាស៍ (Aquinas), លោកគ្រូ ពេត្រាក (Petrarch) (មិនដែលទៅណាដោយមិនមានសៀវភៅ "ការលន់តួ" ជាមួយគាត់នោះឡើយ), លោកគ្រូ ម៉ាធិន លូសើរ, លោកគ្រូ បិលឡាមីន (Bellarmine), លោកគ្រូ ផាស្កាល់ (Pascal), និងលោកគ្រូ ខារខីហ្គាដ (Kierkegaard) សុទ្ធតែឈរក្រោមម្លប់ដើមសែនដ៏ធំរបស់លោកគ្រូ អហ្គូស្ទីន។ ការនិពន្ធរបស់គាត់គឺមាននៅក្នុងចំណោមសៀវភៅដែលលោកគ្រូ វិចិនស្ទែន (Wittgenstein) ចូលចិត្តផងដែរ។ គាត់គឺជាអ្នកដែលពួកនីតស៍ឈី (Nietzsche) មិនសូវចូលចិត្ត។ ការវិភាគនៃចិត្តសាស្ត្ររបស់លោកគ្រូ អហ្គូស្ទីន បានរំពឹងទុកផ្នែកជាមុនរបស់លោក ផ្រ្ហយដ៍ (Freud)៖ លោកគ្រូ អហ្គូស្ទីន គឺជាបុគ្គលដំបូងដែលបានរកឃើញមានសតិសម្បជញ្ញៈបន្ទាប់បន្សំ។[១៥]

មានមូលហេតុនានាសម្រាប់ការជះឥទ្ធិពលដ៏ចម្លែកនេះ។ លោក អាហ្គូស្ទូណូ ត្រាពី (Agostino Trapè) បានលើកឡើងជាសង្ខេបយ៉ាងល្អអំពីសមត្ថភាពរបស់លោកគ្រូ អហ្គូស្ទីន ដែលបណ្តាលឲ្យគាត់ក្លាយជាបុគ្គលដែលមិនអាចប្រៀបផ្ទឹមបានក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ៖

១៣ លោកគ្រូ អ. ស៊ី. ស្ព្រូល, *Augustine and Pelagius*, ក្នុងសៀវភៅ *Tabletalk*, ខែមិថុនា ឆ្នាំ១៩៩៦, ទំព័រ១១។ "ទស្សនៈលើមនុស្សរបស់លោក ភីលេហ្គៀស៍" មានន័យថាមនុស្សមានសមត្ថភាពក្នុងការប្ដេជ្ញាចិត្តដោយខ្លួនឯងជាចុងក្រោយក្នុងការយកឈ្នះលើភាពជាទាសកររបស់គាត់ចំពោះអំពើបាប។ សូមមើលខាងក្រោមក្នុងជំពូកនេះលើទស្សនៈរបស់លោក ភីលេហ្គៀស៍។

១៤ លោកគ្រូ Henry Chadwick, *Augustine* (Oxford: Oxford University Press, ១៩៨៦), ទំព័រ២។

១៥ ក្នុងសៀវភៅដដែល, ទំព័រ៣។

"លោកគ្រូ អហ្គូស្ទីន ជា...ទស្សនវិទូ ទេវវិទូ អ្នកមានជំនឿទាក់ទងនឹងរឿងអាថ៌កំបាំង និងជាកវីក្នុងពេលតែមួយ....សមត្ថភាពដ៏ខ្ពង់ខ្ពស់របស់គាត់បំពេញបន្ថែមលើគ្នាទៅវិញទៅមកដើម្បីឲ្យកាន់តែប្រសើរឡើង ហើយការនេះក៏បានធ្វើឲ្យគាត់ក្លាយជាបុគ្គលម្នាក់ដែលគួរឲ្យចាប់អារម្មណ៍ក្នុងរបៀបដ៏គួរឲ្យពិបាកក្នុងការបដិសេធ។ គាត់គឺជាទស្សនវិទូ ប៉ុន្តែមិនមែនជាអ្នកគិតសោះកក្រោះនោះទេ។ គាត់គឺជាទេវវិទូម្នាក់ ប៉ុន្តែគាត់ក៏ជាអ្នកដ៏ឆ្នើមម្នាក់ក្នុងជីវិតខាងឯព្រលឹងវិញ្ញាណដែរ។ គាត់គឺជាអ្នកជឿលើអធិធម្មជាតិ ប៉ុន្តែគាត់ក៏ជាគ្រូគង្វាលម្នាក់ដែរ។ គាត់ជាកវី ប៉ុន្តែក៏ជាអ្នកខ្វែងគំនិតគ្នាដែរ។ ហេតុដូច្នេះហើយបានអ្នកអានគ្រប់គ្នារកឃើញនូវចំណុចអ្វីណាមួយដែលទាក់ទាញចំណាប់អារម្មណ៍ ហើយក៏ថែមទាំងរំភើបទៀតផង៖ ការយល់ដឹងនៃបរមត្ថវិជ្ជាដ៏ជ្រាលជ្រៅ ភស្តុតាងជាច្រើនខាងឯទេវវិទ្យា ថាមពលនិងកម្លាំងសារធាតុសំយោគ ចិត្តសាស្ត្រដ៏ជ្រៅដែលមានបង្ហាញក្នុងចំណោតខាងឯព្រលឹងវិញ្ញាណ និងការនឹកស្រមៃ សុភវិនិច្ឆ័យជាច្រើន និងអ្នកមានជំនឿទាក់ទងនឹងរឿងអាថ៌កំបាំង»។[១៦]

## ការទៅលេងភ្នំអាល់ដោយមិនបានឃើញទាំងអស់

ស្ទើរតែគ្រប់គ្នាដែលនិយាយអំពី និងសរសេរអំពីលោកគ្រូ អហ្គូស្ទីន ត្រូវតែទទួលស្គាល់ថាខ្លួនមិនបានលើកឡើងគ្រប់ជ្រុងជ្រោយឡើយ។ លោកគ្រូ បិនណាឌិតហ្គូសឆែល (Benedict Groeschel) ជាបុគ្គលដែលបានសរសេរសេចក្តីផ្តើមថ្មីៗនេះអំពីលោកគ្រូ អហ្គូស្ទីន បានទៅលេងវិទ្យាស្ថានមរតក អហ្គូស្ទីន (Augustinian Heritage Institute) ដែលនៅម្តុំកែងមហាវិទ្យាល័យវិលឡិនណូវ៉ា (Villanova University) ដែលជាទីកន្លែងគេផ្ទុកសៀវភៅរបស់លោកគ្រូ អហ្គូស្ទីន គឺថាមានសៀវភៅមួយបណ្ណាល័យផ្ទាល់រួចបាត់ទៅហើយ។ បន្ទាប់មក គេក៏បានណែនាំគាត់អំពីពាក្យប្រមាណជាប្រាំលានរបស់លោកគ្រូ អហ្គូស្ទីន នៅក្នុងកុំព្យូទ័រដែលគេបានរាប់។ គាត់បាននិយាយជំនួសយើងជាច្រើននាក់នៅពេលដែលគាត់លើកឡើងថា៖

---

១៦ លោកគ្រូ Trapè, *Saint Augustine: Man, Pastor, Mystic*, ទំព័រទី៣៣៥។

«ខ្ញុំមានអារម្មណ៍ថាខ្លួនជាបុរសម្នាក់ដែលចាប់ផ្ដើមសរសេរសៀវភៅណែនាំអំពីភ្នំអាល់នៅឯប្រទេសស្វីស....បន្ទាប់ពី៤០ឆ្នាំក្រោយមក ខ្ញុំនៅបន្តសញ្ជឹងគិតលើសៀវភៅនៃ «ការលន់តួ»...ក្នុងអំឡុងពេលនៃការដើរលេងអស់រយៈពេលមួយអាទិត្យ ហើយក៏បានត្រឡប់មកវិញដោយនៅមានការខកចិត្តដោយសារនៅមានមាសជាច្រើនក្នុងការជីកយកក្នុងតែពីរបីទំព័រនោះ។ ខ្ញុំផ្ទាល់ដឹងថា ខ្លួននឹងមិនអាចគេចផុតចេញពីជីវិតនៃភ្នំអាល់របស់លោកគ្រូ អហ្គស្ទីន»។[១៧]

ប៉ុន្តែ ចំណុចពិតដែលថា គ្មានអ្នកណាអាចរៀបរាប់យ៉ាងក្បោះក្បាយទាំងអស់អំពីភ្នំអាល់ក៏មិនបានរារាំងមិនឲ្យមនុស្សម្នាទៅលេងវាដែរ សូម្បីតែមនុស្សសាមញ្ញ។ ប្រសិនបើលោកអ្នកឆ្ងល់ថា ខ្លួនគួរចាប់ផ្ដើមអាននៅត្រង់ណា នោះស្ទើរតែគ្រប់គ្នានឹងប្រាប់ថាសូមចាប់ផ្ដើមក្នុងសៀវភៅ «ការលន់តួ» ដែលជាដំណើររឿងរបស់លោកគ្រូ អហ្គស្ទីន រហូតមកដល់ពេលគាត់កែប្រែចិត្ត នឹងមរណភាពរបស់អ្នកម្ដាយគាត់ចុះ។ សៀវភៅបួនក្បាលដ៏ «ល្អ» ទៀតគឺ៖ «លើគោលជំនឿគ្រីស្ទបរិស័ទ», «សៀវភៅណែនាំ»៖ លើជំនឿសេចក្ដីសង្ឃឹម និងសេចក្ដីស្រឡាញ់» ដែលលោកគ្រូ បេនយ៉ាមីន វ័រហ្វៀល បានមានប្រសាសន៍ថា «ការដែលគាត់ខំយ៉ាងម៉ត់ចត់ក្នុងការព្យាយាមរៀបរៀងរចនាសម្ព័ន្ធនូវគំនិតរបស់គាត់»[១៨] «លើព្រះត្រៃឯក» ដែលផ្ដល់នូវការសម្រេចជាផ្លូវការនូវការការពារសេចក្ដីបង្រៀនអំពីព្រះត្រៃឯក និង «ទីក្រុងរបស់ព្រះជាម្ចាស់» ដែលជាការឆ្លើយតបរបស់លោកគ្រូ អហ្គស្ទីន អំពីការដួលរលំនៃចក្រភពរ៉ូម និងជាការដែលគាត់ព្យាយាមបង្ហាញអំពីអត្ថន័យនៃប្រវត្តិសាស្ត្រ។ ការពន្យល់យ៉ាងសង្ខេប អំពីការណែនាំភ្នំអាល់គឺមានការខុសគ្នាក្នុងទំហំយ៉ាងឆ្ងាយអំពីប្រធានបទដ៏អស្ចារ្យ និងចំណុចសំខាន់របស់វាសម្រាប់សម័យយើងឥឡូវនេះ។ វាមានប្រយោជន៍សម្រាប់ព័ន្ធកិច្ចរបស់យើង—មិនថាជាអ្នកបម្រើពេញសិទ្ធិ ឬក៏ជាអ្នកបម្រើស្ម័គ្រចិត្ត—ហើយជាពិសេសសម្រាប់ចលនាទៅមុខនៃជំនឿកំណែទម្រង់ព្រះគម្ពីរក្នុងសម័យយើង។ ចំណងជើងនៅជំពូកនេះគឺ៖ «អំណរដ៏ឧត្តុង្គឧត្តម៖ អំណាចដែលនាំឲ្យមានសេរីនៃភាពអរសប្បាយដ៏បរិសុទ្ធក្នុងជីវិត និងគំនិតរបស់លោកគ្រូ អហ្គស្ទីន»។ ចំណងជើងបន្ទាប់បន្សំមួយទៀតអាចទំនងជាដាក់ថា «ទីកន្លែងអរសប្បាយក្នុងការកាត់

---

១៧ លោកគ្រូ Benedict J. Groeschel, *Augustine: Major Writings* (New York: The Crossroad Publishing Co., ឆ្នាំ១៩៩៦), ទំព័រ១-២។

១៨ លោកគ្រូ Warfield, *Calvin and Augustine*, ទំព័រ៣០៧។

ស្រាយ និងការពារដំណឹងល្អ»។ ឬក៏ចំណាងជើងមួយទៀតគឺ «ឫសគល់របស់លោកគ្រូ អហ្គូស្ទីន នៃភាពសប្បាយនិយមរបស់គ្រីស្ទបរិស័ទ»។[១៩]

## ជីវប្រវត្តិត្រួសៗរបស់លោកគ្រូ អហ្គូស្ទីន

លោកគ្រូ អហ្គូស្ទីន កើតនៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ៣៥៤ នៅស្រុកថាហ្គាស្ទេ (Thagaste) នៅជិតទីក្រុងហិផូ ដែលបច្ចុប្បន្ននេះជាប្រទេសអាល់ហ្សេរី (Algeria)។ លោក ផាទ្រីស៊ីអូស៍ (Patricius) ជាឪពុករបស់គាត់ ដែលជាកសិករមធ្យមក្នុងប្រាក់ចំណូល ហើយមិនមែនជាអ្នកជឿនោះទេ។

ឪពុករបស់លោកគ្រូ អហ្គូស្ទីន បានខំធ្វើការយ៉ាងខ្លាំង ដើម្បីផ្តល់ជូននូវការរៀនសូត្រដ៏ល្អបំផុតផ្នែកវោហារសាស្ត្រតាមដែលគាត់អាចធ្វើបានជាដំបូងនៅឯស្រុក ម៉ាឌូរ៉ា (Madaura) ប្រមាណជា ៣២ គីឡូម៉ែត្រពីទីនោះ ពីអាយុ១១ឆ្នាំដល់អាយុ១៥ឆ្នាំ។ ហើយបន្ទាប់ពីបានចំណាយពេលមួយឆ្នាំនៅផ្ទះ គាត់ក៏បានទៅរៀននៅឯទីក្រុងកាតធេចាប់ពីអាយុ១៧ឆ្នាំដល់អាយុ២០ឆ្នាំ។ ឪពុករបស់គាត់បានទទួលជឿព្រះអង្គនៅឆ្នាំ៣៧០នៃ គ.ស. មួយឆ្នាំមុនឪពុករបស់គាត់ទទួលមរណភាព កាលលោកគ្រូ អហ្គូស្ទីន មានអាយុ១៦ឆ្នាំ។ គាត់បានលើកឡើងអំពីមរណភាពរបស់ឪពុកគាត់តែមួយដងគត់ក្នុងការនិពន្ធជាច្រើនរបស់គាត់។ ការនេះពិតជាគួរឲ្យភ្ញាក់ផ្អើលមែន នៅពេលដែលយើងធ្វើការពិចារណាលើទំព័រជាច្រើនដែលគាត់បានចំណាយលើការកាន់ទុក្ខការបាត់បង់មិត្តភក្តិរបស់គាត់។

គាត់បានសរសេរថា «កាលទូលបង្គំនៅវ័យជំទង់នៅឡើយ ទូលបង្គំប្រាថ្នាចង់ទទួលបានការស្កប់ចិត្តជាមួយអ្វីៗដែលមានក្នុងលោកីយ៍នេះណាស់ ហើយទូលបង្គំក៏ជាក្មេងស្ទាវឈោមរាវដែរ...ក្រុមគ្រួសាររបស់យើងខ្ញុំមិនបានខំធ្វើអ្វីទេក្នុងការសង្គ្រោះទូលបង្គំពីការធ្លាក់តាមរយៈជីវិតអាពាហ៍ពិពាហ៍។ អ្វីដែលពួកគាត់ចាប់អារម្មណ៍លើតែមួយនោះ

១៩ សប្បាយនិយមគ្រីស្ទានគឺជាឈ្មោះដែលខ្ញុំបានផ្តល់លើការសម្តែងអំពីព្រះជាម្ចាស់ និងជីវិតរស់នៅរបស់គ្រីស្ទបរិស័ទ និងការអនុវត្តក្នុងព័ន្ធកិច្ចជាពិសេសក្នុង Desiring God, *Meditations of a Christian Hedonist* (Sisters, OR: Multnomah Press, ឆ្នាំ១៩៨៦)។

គឺថាឲ្យទូលបង្គំខំរៀន ដើម្បីឲ្យចេះនិយាយឲ្យបានល្អ ហើយឲ្យចេះបញ្ចុះបញ្ចូលអ្នកដទៃតាមរយៈពាក្យពេចន៍របស់ទូលបង្គំតែប៉ុណ្ណោះ»។[២០] ជាពិសេស គាត់បានលើកឡើងថាឪពុករបស់គាត់ «មិនបានរវីរវល់ខ្លួនទាល់តែសោះទាក់ទងត្រង់ថា៖ តើទូលបង្គំកំពុងធ្វើដំណើរដល់ដំណាក់កាលណាឆ្ពោះទៅរកព្រះអង្គ ឬក៏ថាទូលបង្គំកំពុងរស់នៅយ៉ាងបរិសុទ្ធខាងផ្លូវភេទ ពោលគឺគាត់ខ្វល់ខ្វាយតែត្រង់ថា តើទូលបង្គំមានទេពកោសល្យខ្លាំងប៉ុណ្ណាក្នុងវោហារសាស្ត្រ។[២១] ការខកចិត្តដ៏ខ្លាំងក្លាលើការដែលឪពុករបស់គាត់មិនយកចិត្តទុកដាក់នឹងគាត់បានបណ្ដាលឲ្យលោកគ្រូ អហ្គស្ទីន មិនលើកឡើងអំពីឪពុករបស់គាត់អស់មួយជីវិត។

មុនគាត់ចេញទៅទីក្រុងកាតធេ ដើម្បីសិក្សាអស់រយៈពេលបីឆ្នាំទៀត អ្នកម្ដាយរបស់គាត់បានព្រមានគាត់យ៉ាងម៉ឺងម៉ាត់ថា «ចូរកុំធ្វើអំពើបាបខាងឯការរួមភេទមុនពេលរៀបការ ហើយលើសពីនោះចូរកុំប្រលោមដោយប្រទ្បាក់ប្រទ្បូសជាមួយប្រពន្ធរបស់បុរសម្នាក់ទៀតឡើយ»។ «ទូលបង្គំបានទៅទីក្រុងកាតធេ ជាកន្លែងដែលមានឆ្នាំងខ្ទះកម្ដៅនៃភាពត្រេកត្រអាលដែលមិនបរិសុទ្ធកំពុងតែពុះកញ្ជ្រោលនៅជុំវិញទូលបង្គំ....ឱព្រះជាម្ចាស់អើយ! ដ្បិតការស្រេកឃ្លានដ៏ពិតប្រាកដរបស់ទូលបង្គំគឺជាម្ហូបអាហារដែលនឹងផ្គត់ផ្គង់ព្រលឹងទូលបង្គំ ពោលគឺការស្រេកឃ្លានព្រះអង្គ។ ប៉ុន្តែ ទូលបង្គំមិនដឹងអំពីការស្រេកឃ្លាននេះទេ»។[២២] «ទោះជាយ៉ាងណាក្ដី ក៏ទូលបង្គំនៅមានចិត្តប្រាថ្នាចង់ទៅលួច ហើយក៏បានទៅលួច អំពើចោរកម្មមួយនោះកើតឡើងមិនមែនមកពីទូលបង្គំស្រេកឃ្លាន ឬក៏ក្រីក្រនោះទេ»។[២៣] «ទូលបង្គំគឺជាសិស្សដែលជាប់ចំណាត់ថ្នាក់លេខ១ក្នុងថ្នាក់នៃសាលាវោហារសាស្ត្រ ហើយទូលបង្គំពេញចិត្តកិត្តិយសនោះណាស់ ហើយក៏មានអំនួតយ៉ាងខ្លាំង.... ទូលបង្គំប្រាថ្នាចង់ក្លាយជាអ្នកនិយាយដ៏ល្បីល្បាញម្នាក់ ទោះបើចេញពីការជំរុញចិត្តដែលគួរឲ្យស្អីបខ្ពើមក៏ដោយ៖ ការចូលចិត្តអួតអាង»។[២៤] នៅឯទីក្រុងកាតធេ គាត់បានយកស្រីកំណាន់ម្នាក់ ហើយគាត់បានរស់នៅជាមួយនឹងស្ត្រីនោះរយៈពេល១៥ឆ្នាំ ហើយក៏បានមានកូនប្រុសម្នាក់ជាមួយនឹងគាត់ឈ្មោះលោក អាឌីអូដាទីស៍ (Adeodatus)។

២០ លោកគ្រូ អហ្គស្ទីន, *«ការលន់តួ»*, ទំព័រ៦៩។
២១ ក្នុងសៀវភៅដដែល, ទំព័រ៧១។
២២ ក្នុងសៀវភៅដដែល, ទំព័រ៧៧។
២៣ ក្នុងសៀវភៅដដែល, ទំព័រ៧៣។
២៤ ក្នុងសៀវភៅដដែល, ទំព័រ៨២។

គាត់ក៏បានក្លាយជាគ្រូបង្រៀនតាមប្រពៃណីបុរាណ ដោយបង្រៀនវោហារសាស្ត្រអស់រយៈពេល១១ឆ្នាំនៃជីវិតរបស់គាត់—ពីអាយុ១៩ឆ្នាំដល់អាយុ៣០ឆ្នាំ—ហើយបន្ទាប់មកក៏បានចំណាយ៤៤ឆ្នាំចុងក្រោយនៃជីវិតរបស់គាត់ជាសង្ឃដែលមិនបានរៀបការ និងជាគ្រូគង្វាល។ បើនិយាយម្យ៉ាងវិញទៀតទៅគឺថា គាត់បានចំណាយជីវិតយ៉ាងខ្ជះខ្ជាយក្នុងលក្ខណៈអសីលធម៌រហូតដល់គាត់មានអាយុ៣១ឆ្នាំ ហើយបន្ទាប់មករស់នៅក្នុងលក្ខណៈជានៅលីវបែបឈាមរាវរហូតដល់គាត់មានអាយុ៧៥ឆ្នាំ។ ប៉ុន្តែ ការកែប្រែចិត្តរបស់គាត់មិនបានកើតឡើងមានភ្លាមៗដូចដែលគេបានគិតជាទូទៅនោះទេ។

កាលគាត់មានអាយុ១៩ឆ្នាំក្នុង «ភាពត្រេកត្រអាលនៅឯទីក្រុងកាតធេ» ពេញទៅដោយអំនួត ហើយប្រឡូកប្រឡាក់យ៉ាងខ្លាំងក្នុងភាពអរសប្បាយខាងឯផ្លូវភេទ នោះគាត់ក៏បានអានសៀវភៅដែលលោកគ្រូ សិសារូ (Cicero) បានសរសេរដែលមានចំណងជើងថា «ហូតធីនស៊ីស» (Hortensius) ដែលកាលនោះឯងគឺជាលើកដំបូងដែលសៀវភៅនេះបានទាក់ទាញចំណាប់អារម្មណ៍របស់គាត់តាមរយៈប្រធានបទរបស់វា មិនមែនទម្រង់វោហារសាស្ត្រនោះទេ។ សៀវភៅ «ហូតធីនស៊ីស» បានឲ្យតម្លៃលើការស្វែងរកប្រាជ្ញា និងសេចក្ដីពិតលើសភាពអរសប្បាយខាងឯសាច់ឈាម។

«ប្រាកដណាស់ គឺសៀវភៅនេះហើយដែលបានបំផ្លាស់បំប្រែឥរិយាបថរបស់ទូលបង្គំទាំងស្រុង បង្វែរការអធិស្ឋានរបស់ទូលបង្គំទៅកាន់ព្រះអង្គ ផ្ដល់នូវសេចក្ដីសង្ឃឹម និងសេចក្ដីប្រាថ្នាថ្មីដល់ទូលបង្គំ។ ភ្លាមៗនោះរាល់ក្ដីសង្ឃឹមដែលឥតប្រយោជន៍ក៏បានក្លាយជាឥតតម្លៃចំពោះទូលបង្គំ ហើយដោយមានភាពកក់ក្ដៅដែលមិនអាចជឿបាននោះដួងចិត្តរបស់ទូលបង្គំក៏ស្រេកឃ្លានចង់បានប្រាជ្ញាអមតៈ ហើយពេលនោះក៏ចាប់ផ្ដើមងើបឡើង ដើម្បីនឹងត្រឡប់ទៅរកទ្រង់វិញ....ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! កាលនោះទូលបង្គំឆេះឆួលយ៉ាងខ្នះខ្នែងណាស់ក្នុងការហោះចេញពីអ្វីៗនៅលើផែនដីនេះដើម្បីទៅកាន់ព្រះអង្គ។ ហើយទូលបង្គំក៏មិនដឹងថាព្រះអង្គកំពុងធ្វើការអ្វីខ្លះក្នុងទូលបង្គំទៀតផងនៅកាលនោះ។ ដ្បិតជាមួយព្រះអង្គគឺមានប្រាជ្ញា។ ក្នុងភាសាក្រិក គេហៅការស្រឡាញ់ប្រាជ្ញាថា "ទស្សនៈវិជ្ជា" ហើយគឺដោយការស្រឡាញ់ទស្សនៈវិជ្ជានេះហើយដែលធ្វើឲ្យទូលបង្គំឆេះឆួល»។[២៥]

---

២៥ ក្នុងសៀវភៅដដែល, ទំព័រ៨៤។

ការនេះបានកើតឡើងប្រមាណជា៩ឆ្នាំមុនគាត់ទទួលជឿព្រះគ្រីស្ទ ប៉ុន្តែវាបាននាំឲ្យមានការប្តូរទិសយ៉ាងខ្លាំងក្នុងការអាន និងការគិតរបស់គាត់ឲ្យកាន់តែសំដៅទៅរកសេចក្តីពិតជាជាងលើរបៀប ដែលនេះគឺជាការល្អក្នុងយុគសម័យណាក៏បាន។

ប្រមាណជា៩ឆ្នាំទៅមុខទៀត គាត់ក៏បានលង់ស្នេហ៍ក្នុងសេចក្តីបង្រៀនមិនដែលជឿថាជាទ្វេភាពនិយម[២៦]ឈ្មោះ មានិហ្កៀន (Manichaeism) រហូតដល់ពេលគាត់ស្រងាកចិត្តជាមួយនឹងអ្នកដឹកនាំម្នាក់ពេលគាត់មានអាយុ២៨ឆ្នាំ។ កាលគាត់អាយុ២៩ឆ្នាំ គាត់ក៏បានចាកចេញពីទីក្រុងកាតធេទៅទីក្រុងរ៉ូម ដើម្បីបង្រៀន ប៉ុន្តែឆ្អែតចិត្តយ៉ាងខ្លាំងជាមួយនឹងអាកប្បកិរិយារបស់ពួកសិស្សដល់ថ្នាក់ថា គាត់ក៏បានរើទីកន្លែងបង្រៀនទៅឯទីក្រុងមីឡាន (Milan) នៅប្រទេសអ៊ីតាលី (Italy) នៅឆ្នាំ៣៨៤នៃគ.ស.។ ការនេះគឺជាការកើតឡើងទាន់ពេលក្នុងពីរបីរបៀបតាមរយៈការចុះអន្តរាគមន៍របស់ព្រះជាម្ចាស់។ ពេលនោះឯងគឺជាពេលដែលគាត់បានរកឃើញពួកផ្លាតូនិយម (Platonists) ហើយក៏ជាពេលដែលគាត់បានជួបលោកគ្រូគង្វាលដ៏ល្អម្នាក់ឈ្មោះ អែមប្រូស៍ (Ambrose)។ ពេលនោះគាត់មានអាយុ៣០ឆ្នាំ ហើយក៏នៅមានកូនប្រុសរបស់គាត់ និងស្រីកំណាន់របស់គាត់—ជាស្ត្រីដែលគួរឲ្យវេទនាម្នាក់ដែលគេបានភ្លេច ព្រោះលោកគ្រូ អហ្គស្ទីន មិនដែលលើកឡើងឈ្មោះរបស់នាងក្នុងការនិពន្ធរបស់គាត់ឡើយ។

ក្នុងដើមខែប្រាំងនៅឆ្នាំ៣៨៦នៃគ.ស. គាត់បានរកឃើញការនិពន្ធរបស់លោកផ្លូតូនូស៍ (Platonus) ដែលជាអ្នកនីអូ-ផ្លាតូនិយម (neo-Platonist)[២៧] ដែលបានស្លាប់នៅក្នុងឆ្នាំ២៧០នៃគ.ស.។ នេះគឺជាការបំផ្លាស់បំប្រែចិត្តលើកទី២របស់លោកគ្រូ អហ្គស្ទីន បន្ទាប់ពីគាត់បានអានសៀវភៅរបស់លោកគ្រូ សិសារូ ប្រមាណ១១ឆ្នាំពីមុន។ គាត់ក៏ជញ្ជក់យកទស្សនៈរបស់ក្រុមផ្លាតូនិយម (Platonic) ដោយមានចិត្តរំភើប។ ទាក់ទងនឹងការជួបប្រទះមួយនេះលោកគ្រូ ភិធ័រ ប្រោន (Peter Brown) បានមានប្រសាសន៍ថា “មិន

២៦ ដែលជាការតយុទ្ធរវាងល្អ ភពនៃពន្លឺខាងឯវិញ្ញាណ និងអាក្រក់ ភពនៃសេចក្តីងងឹតខាងឯសាច់ឈាម។

២៧ លោក ផ្លូតីនូស៍ គឺជាអ្នកបង្កើតក្រុមនីអូ-ផ្លាតូនិយម (ឆ្នាំ២០៥-២៧០នៃគ.ស.) ហើយរចនាសម្ព័ន្ធនៃមូលដ្ឋានគ្រឹះរបស់គាត់គឺរំពឹងលើទ្រឹស្តីនៃគំនិតរបស់លោក ផ្លាតូ ជាគោល។ លោក ផ្លូតីនូស៍ បានបង្រៀនថា ភាពពេញលេញ (the Absolute Being) មានការពាក់ព័ន្ធជាមួយនឹងស្ថានការណ៍តាមរយៈលំដាប់នៃការភាយចេញមួយចំនួនតាមរយៈលទ្ធផលមួយចំនួនទៀត ដែលទីមួយគឺភាពឈ្លាសវៃ ឬក៏ប្រាជ្ញាដ៏ជ្រះថ្លាផ្ទាល់។ ចេញពីលំហូរនៃនេះ នោះក៏មានព្រលឹងនៃផែនដី ហើយជាលទ្ធផលចេញពីការនេះក៏មានលំហូរនៃព្រលឹងមនុស្សលោក និងសត្វជាតិ ហើយនៅចុងបញ្ចប់សារធាតុទាំងឡាយ។ លោកគ្រូ អហ្គស្ទីន បានរកឃើញចំណុចជាច្រើនក្នុងទស្សនវិជ្ជានេះដែលមិនមានភាពស៊ីគ្នាជាមួយនឹងព្រះគម្ពីរនៃជំនឿគ្រីស្ទបរិស័ទ—ឧទាហរណ៍៖ វាជាការជំទាស់គ្នាយ៉ាងប្រាកដប្រជារវាងព្រលឹង និងសារធាតុ។ ក្នុងពិភពនៃហេតុផលក៏មានការមិនចូលចិត្ត ហេតុដូច្នេះហើយបានជាចាំបាច់ត្រូវមានការរំដោះចេញពីជីវិតនៃហេតុផលតាមរយៈការដាក់វិន័យបែបជាតាបសយ៉ាងម៉ឺងម៉ាត់។

បានធ្វើអ្វីតិចជាងការផ្លាស់ទីកណ្ដាលលេខទំនាញនៃជីវិតខាងឯព្រលឹងវិញ្ញាណរបស់លោកគ្រូ អហ្គូស្ទីន ទេ។ គាត់លែងរាប់ខ្លួនជាមួយនឹងព្រះរបស់គាត់ [ដូចគេធ្វើនៅក្នុងក្រុមមានិហ្កៀន]៖ ព្រះមួយនេះសម្បើមក្រៃលែងមហិមាដែលគាត់ជឿលើឥឡូវនេះ។[២៨]

ប៉ុន្តែ គាត់នៅជាប់ក្នុងសេចក្ដីងងឹតនៅឡើយ។ លោកអ្នកអាចឃើញឥទ្ធិពលនៃទស្សនៈផ្លាតូនិយមរបស់គាត់ក្នុងការវាយតម្លៃលើសម័យកាលនោះ៖ «ទូលបង្គំដាក់ខ្នងទៅឯពន្លឺ ហើយមុខទូលបង្គំក៏បែរទៅកាន់អ្វីៗដែលវាបំភ្លឺ ដើម្បីឲ្យភ្នែករបស់ទូលបង្គំដែលតាមរយៈវាទូលបង្គំឃើញនូវអ្វីៗដែលឈរក្នុងពន្លឺ គឺនៅក្នុងសេចក្ដីងងឹតផ្ទាល់វិញ។

មកដល់ពេលនេះគឺជាពេលវេលានៃការរើចុងក្រោយ ការរើចេញពីផ្លាតូនិយមទៅកាន់សាវ័ក ប៉ុល តាមរយៈការជះឥទ្ធិពលយ៉ាងខ្លាំងក្លាពីលោកគ្រូ អែមប្រូស៍ ដែលមានអាយុ១៤ឆ្នាំចាស់ជាងលោកគ្រូ អហ្គូស្ទីន។ «ហើយនៅពេលដែលទូលបង្គំមកដល់ទីក្រុងមីឡាន នោះទូលបង្គំក៏ជួបលោកគ្រូ អែមប្រូស៍ ដែលជាគ្រូគង្វាល ដែលមានភាពល្បីល្បាញទូទាំងពិភពលោកថាជាបុរសដ៏ល្អម្នាក់ ហើយក៏ជាបុគ្គលដែលមានភក្ដីភាពបែបជាអ្នកបម្រើរបស់ព្រះអង្គយ៉ាងខ្លាំង។ នៅពេលនោះសេចក្ដីអធិប្បាយដ៏ក្បោះក្បាយរបស់គាត់បានផ្ដត់ផ្គង់ដល់រាស្ត្ររបស់ទ្រង់នូវម្សៅនៃស្រូវសាលីរបស់ទ្រង់ ភាពអរសប្បាយនៃប្រេងរបស់ទ្រង់ និងភាពរីករាយដ៏ភ្ញាក់ខ្លួននៃស្រារបស់ព្រះអង្គ»។[២៩]

ទស្សនៈផ្លាតូនិយមរបស់លោកគ្រូ អហ្គូស្ទីន បាននាំឲ្យមានការប៉ះទង្គិចជាខ្លាំងតាមរយៈការបង្រៀនចេញពីព្រះគម្ពីរថា «ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម»។ ប៉ុន្តែ ពីអាទិត្យមួយទៅអាទិត្យមួយទៀត គាត់នៅបន្តស្ដាប់ការអធិប្បាយរបស់លោកគ្រូអែមប្រូស៍។ «ទូលបង្គំបានស្ដាប់យ៉ាងយកចិត្តទុកដាក់លើពាក្យសម្ដីរបស់គាត់ ហើយទូលបង្គំក៏បានចាប់ផ្ដើមស្គាល់សេចក្ដីពិតនៃអ្វីៗដែលគាត់បានលើកឡើង ទោះបើបន្តិចម្ដងៗក៏ដោយ»។ «ទូលបង្គំមានការរំភើបជាមួយនឹងសេចក្ដីស្រឡាញ់ និងភាពភ័យរន្ធត់ក្នុងពេលតែមួយ។ ទូលបង្គំបានយល់ថា ខ្លួននៅឆ្ងាយពីព្រះអង្គ...ហើយនៅពីចម្ងាយ នោះទូលបង្គំក៏បានឮព្រះសូរសៀងរបស់ទ្រង់មានបន្ទូលថា អញគឺជាព្រះដែលមានព្រះជន្ម។ ទូលបង្គំបានឮព្រះសូរសៀងរបស់ព្រះអង្គ ដូចដែលយើងឮសំឡេងនិយាយមកកាន់ដួង

---

២៨ លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ១០។

២៩ ក្នុងសៀវភៅដដែល, ទំព័រ១៤២។

ចិត្តយើង ហើយក្នុងពេលនោះទូលបង្គំក៏លែងមានបុព្វហេតុនៃមន្ទិលសង្ស័យទៀតដែរ»។

ប៉ុន្តែ បទពិសោធន៍មួយនោះមិនមែនជាការកែប្រែចិត្តដ៏ពិតទេ។ «ទូលបង្គំបានមានការភ្ញាក់ផ្អើលថា ទោះបើឥឡូវនេះទូលបង្គំបានស្រឡាញ់ព្រះអង្គក៏ដោយ...ក៏ទូលបង្គំមិនបានបន្តមានអំណរជាមួយនឹងព្រះជាម្ចាស់នៃទូលបង្គំដែរ។ ភាពស្រស់សង្ហាររបស់ព្រះអង្គបានទាក់ទាញទូលបង្គំ ប៉ុន្តែមិនយូរប៉ុន្មាននោះទូលបង្គំក៏ត្រូវបានអូសចេញពីព្រះអង្គតាមរយៈទម្ងន់របស់ខ្លួន ហើយក្នុងភាពស្រងាកចិត្តនោះទូលបង្គំក៏បានធ្លាក់ក្នុងអ្វីៗដែលមានលើផែនដីនេះជាថ្មីម្តងទៀត...ហាក់បីដូចជាថាទូលបង្គំបានស្គាល់ក្លិនតម្លៃនៃភាពក្រអូប ប៉ុន្តែមិនទាន់អាចទទួលទានបាននៅឡើយ»។

សូមកត់សម្គាល់លើការផុសឡើងនៃឃ្លា «ការមានអំណរជាមួយនឹងព្រះជាម្ចាស់»។ ពេលនោះលោកគ្រូ អហ្គុស្ទីន បានស្រមើស្រមៃអំពីគោលបំណងនៃជីវិតរបស់គាត់ថាជាការស្វែងរកអំណរដ៏រឹងមាំ និងមិនអាចរង្គើបានលើព្រះដ៏ពិត។ នេះគឺជាមូលដ្ឋានគ្រឹះនៃការគិតរបស់គាត់អំពីអ្វីៗទាំងអស់ ជាពិសេសក្នុងការតយុទ្ធដ៏ខ្លាំងរបស់គាត់ជាមួយនឹងពួកភីលេហ្គៀននៅគ្រាចុងក្រោយនៃជីវិតរបស់គាត់ប្រមាណជា៤០ឆ្នាំចាប់ពីពេលនេះតទៅ។

ពេលនោះ គាត់បានដឹងថា គាត់មិនបានទទួលការឃាត់ឃាំងតាមរយៈចំណុចណាមួយខាងឯប្រាជ្ញានោះទេ ប៉ុន្តែតាមរយៈភាពត្រេកត្រអាលខាងឯផ្លូវភេទទៅវិញ៖ «ទូលបង្គំបាននៅបន្តទទួលការកាន់យ៉ាងជាប់ក្នុងចំណងនៃការស្រឡាញ់របស់ស្ត្រី»។ ដូច្នេះភាពអរសប្បាយណាមួយដែលគាត់ប្រាថ្នាចង់បានខ្លាំងជាងក្នុងជីវិតរបស់គាត់នឹងយកឈ្នះលើសង្គ្រាម។ «ទូលបង្គំក៏ស្វែងរករបៀបមួយចំនួនក្នុងការទទួលបានកម្លាំងល្មមដើម្បីមានអំណរក្នុងព្រះអង្គ [សូមកត់សម្គាល់លើសមរភូមិ៖ តើខ្ញុំអាចរកកម្លាំងពីណាក្នុងការមានអំណរក្នុងព្រះជាម្ចាស់ជាជាងការរួមភេទ?] ប៉ុន្តែ ទូលបង្គំមិនបានរកឃើញទាល់តែទូលបង្គំទទួលស្គាល់ «អ្នកកណ្តាលតែមួយ រវាងព្រះនឹងមនុស្ស គឺព្រះគ្រីស្ទយេស៊ូវ ដែលជាមនុស្ស»។[៣០]

លោកស្រី ម៉ូនីកា ដែលជាអ្នកម្តាយរបស់គាត់ បានអធិស្ឋានសម្រាប់គាត់អស់មួយជីវិត ក៏បានមកទីក្រុងមីឡាននៅក្នុងនិទាឃរដូវនៃឆ្នាំ៣៨៥នៃគ.ស. ហើយក៏បានចាប់ផ្តើមរៀបចំពិធីអាពាហ៍ពិពាហ៍ត្រឹមត្រូវសម្រាប់គាត់ជាមួយនឹងក្រុមគ្រួសារគ្រីស្ទបរិស័ទមាន

---

៣០ ក្នុងសៀវភៅដដែល, ទំព័រ១៩២, ទំព័រ២៨៧។

បានល្មមសមរម្យម្នាក់នៅទីនោះ។ ការនេះបានដាក់លោកគ្រូ អហ្គូស្ទីន ក្នុងវិបត្តិខាងឯផ្លូវចិត្តយ៉ាងខ្លាំង ហើយក៏បានបើកផ្លូវឲ្យគាត់កាន់តែធ្លាក់ខ្លាំងជាងមុនក្នុងអំពើបាប ទោះបើការផ្លាស់ប្តូរជំនឿរបស់គាត់ជិតនឹងកើតឡើងក៏ដោយ។ គាត់បានចាត់ឲ្យស្រីកំណាន់ដែលគាត់បានចំណាយពេលជាមួយអស់រយៈពេល១៥ឆ្នាំឲ្យត្រឡប់ទៅប្រទេសអាហ្វ្រិកវិញ ដោយមិនរស់នៅជាមួយនាងទៀតឡើយ។ «ស្ត្រីដែលទូលបង្គំកំពុងតែរស់នៅជាមួយក៏ត្រូវបានដកចេញពីទូលបង្គំ ពីព្រោះគាត់គឺជាឧបសគ្គចំពោះអាពាហ៍ពិពាហ៍របស់ទូលបង្គំ ហើយបេះដូងទូលបង្គំដែលបានភ្ជាប់ជាមួយនឹងគាត់ក៏ត្រូវបានរហែកចេញ ហើយត្រូវរងរបួសរហូតដល់វាហូរឈាម។ ទូលបង្គំបានស្រឡាញ់គាត់យ៉ាងខ្លាំង។ គាត់ក៏បានត្រឡប់ទៅទ្វីបអាហ្វ្រិកវិញ គាត់បានស្បថថានឹងមិនប្រគល់ខ្លួនទៅកាន់បុរសណាផ្សេងទៀតទេ....ប៉ុន្តែ ទូលបង្គំមិនសប្បាយចិត្ត ហើយក៏ខ្សោយពេកក្នុងការត្រាប់តាមគំរូដាក់ពីមុខទូលបង្គំតាមរយៈស្ត្រី....ហេតុដូច្នេះ ទូលបង្គំក៏ទៅយកស្ត្រីកំណាន់ម្នាក់ផ្សេងទៀតដោយមិនបានរៀបការ»។[៣១]

## ការផ្លាស់ប្តូរជំនឿដែលសំខាន់ក្នុងប្រវត្តិសាស្ត្រសម្រាប់អនាគត

បន្ទាប់មក ថ្ងៃដ៏សំខាន់បំផុតមួយក្នុងប្រវត្តិសាស្ត្រក្រុមជំនុំក៏បានមកដល់។ «ឱព្រះអម្ចាស់អើយ! ទ្រង់គឺជាជំនួយ និងជាព្រះអង្គប្រោសលោះរបស់ទូលបង្គំ។ ឥឡូវ ទូលបង្គំនឹងប្រកាស ហើយលន់តួក្នុងព្រះនាមរបស់ព្រះអង្គអំពីរបៀបដែលទ្រង់បានរំដោះទូលបង្គំចេញពីច្រវាក់នៃការប្រាថ្នាខាងឯផ្លូវភេទដែលទូលបង្គំបានជាប់ចំណងយ៉ាងខ្លាំង នឹងចេញពីភាពជាទាសករនៃលោកីយ៍ខាងឯទង្វើ»។[៣២] នេះគឺជាចំណុចស្នូលនៃសៀវភៅរបស់គាត់ដែលមានចំណងជើងថា «ការលន់តួ» ហើយក៏ជាព្រឹត្តិការណ៍ដ៏អស្ចារ្យមួយនៃព្រះគុណក្នុងប្រវត្តិសាស្ត្រ ហើយវាក៏ពិតជាសង្គ្រាមដ៏ខ្លាំងមួយដែរ។ សូមអានដោយយកចិត្តទុកដាក់អំពីរបៀបនៃការយកឈ្នះរបស់វា (នៅក្នុងសៀវភៅទី៨ នៃសៀវភៅ «ការលន់តួ» មានរៀបរាប់យ៉ាងក្បោះក្បាយជាងនេះ)។

៣១ ក្នុងសៀវភៅដដែល, ទំព័រ១៦៦។
៣២ ក្នុងសៀវភៅដដែល, ទំព័រ២០៩។

សូម្បីតែថ្ងៃនោះក៏ស្មុគស្មាញជាងការរៀបរាប់អំពីដំណើររឿងជាទូទៅដែរ ប៉ុន្តែដើម្បីឈានចូលចំណុចស្នូលនៃសង្គ្រាមបាន ចូរយើងផ្តោតលើវិបត្តិចុងក្រោយសិន។ នៅចុងខែសីហា ឆ្នាំ៣៨៦នៃគ.ស.។ លោកគ្រូ អហ្គូស្ទីន ជិតមានអាយុ៣២ឆ្នាំ។ គាត់បាននិយាយជាមួយនឹងលោក អាលីពឹស៍ ដែលជាមិត្តភក្តិស្និទ្ធស្នាលម្នាក់របស់គាត់ អំពីការលះបង់ និងភាពបរិសុទ្ធដ៏គួរឲ្យកត់សម្គាល់អំពីលោក អែនថូនី ដែលជាតាបសម្នាក់ពីប្រទេសអេហ្ស៊ីប។ លោកគ្រូ អហ្គូស្ទីន មានការភ្ញាក់ផ្អើលជាមួយនឹងចំណងនៃភាពព្រៃផ្សៃរបស់គាត់ខាងឯភាពត្រេកត្រអាល ខណៈពេលដែលអ្នកដទៃមានសេរីភាពហើយក៏បរិសុទ្ធក្នុងព្រះគ្រីស្ទដែរ។

"មានសួនច្បារតូចមួយជាប់នឹងផ្ទះដែលយើងរស់នៅ។ ខ្យល់បក់បោកនៅក្នុងដួងចិត្តរបស់ទូលបង្គំបានបណ្តាលឲ្យទូលបង្គំចេញទៅសួនច្បារនោះ ដែលទំនងជានឹងមិនមានអ្នកណាមកឆាឆៅការតយុទ្ធដ៏ឆេះឆួលដែលទូលបង្គំកំពុងតែប្រឈមមុខជាមួយនឹងខ្លួនឯងនោះទេ....ទូលបង្គំកំពុងតែឆ្កួតជាមួយនឹងការភ្លីភ្លើដែលនឹងនាំឲ្យទូលបង្គំជាលា។ ទូលបង្គំកំពុងតែស្លាប់ក្នុងសេចក្តីស្លាប់ដែលនាំឲ្យទូលបង្គំមានជីវិត....ទូលបង្គំមានទុក្ខកង្វល់យ៉ាងខ្លាំងក្នុងព្រលឹង ខឹងខ្លួនឯងដែលមិនបានឈានចូលការតាំងសេចក្តីសញ្ញាជាមួយនឹងព្រះអង្គ....ព្រលឹងទូលបង្គំក៏ស្រែកយំថាទូលបង្គំគួរតែចូល។ ទូលបង្គំបានទាញសក់ខ្លួនឯង ហើយវាយថ្ងាសខ្លួនឯងជាមួយនឹងដៃរបស់ទូលបង្គំ ទូលបង្គំក៏បានសម្រួលដៃចូលគ្នា ហើយឱបជង្គង់របស់ខ្លួន"។[៣៣]

ប៉ុន្តែ គាត់បានចាប់ផ្តើមឃើញយ៉ាងច្បាស់លាស់ថា ការទទួលបាននោះធំខ្លាំងជាងការបាត់បង់ ហើយតាមរយៈការអស្ចារ្យនៃព្រះគុណ នោះគាត់ក៏ចាប់ផ្តើមឃើញភាពស្រស់ស្អាតនៃភាពបរិសុទ្ធខាងឯផ្លូវភេទក្នុងព្រះវត្តមានរបស់ព្រះគ្រីស្ទ។

"តាមពិតទៅ ទូលបង្គំនៅមានចំណាប់អារម្មណ៍ជាមួយនឹងអំពើបាបដែលទូលបង្គំនៅស្រឡាញ់ ដែលជាអំពើបាបដែលមានពេញទៅដោយភាពឥតប្រយោជន៍ដ៏ឥតប្រយោជន៍។ ពួកវាបានព្យាយាមទាញទូលបង្គំចូលភាពត្រេកត្រអាលខាងឯសាច់ឈាម។ ហើយបានបន្តខ្សឹបខ្សៀវមកកាន់ទូលបង្គំថា៖ "តើលោកនឹងចេញពីពួកយើងមែនឬ? តើលោកនឹងចេញពីពួកយើងជារៀងរហូតមែនឬ? តើលោកមិនដឹងទេថា ពេលលោកចាក

៣៣ ក្នុងសៀវភៅដដែល, ទំព័រ២១២។

ចេញពីយើង នោះលោកមិនអាចបកត្រឡប់មករកយើងវិញបានទេ?”...ហើយខណៈពេលដែលទូលបង្គំឈរនៅក្បែរបាំងដោយមានការញាប់ញ័រ នៅម្ខាងទៀត នោះទូលបង្គំអាចឃើញភាពស្រស់ស្អាតបរិសុទ្ធរបស់ប្រាជ្ញា ដែលកំពុងស្រែកហៅឲ្យទូលបង្គំឆ្លងទៅ ហើយកុំឲ្យមានការស្ទាក់ស្ទើរទៀត។ ប៉ុន្តែ ទូលបង្គំនៅខ្លាចក្នុងការឈានទៅមុខ។ ប្រាជ្ញាបានទាញដៃដ៏បរិសុទ្ធ ដើម្បីទទួល និងឱបទូលបង្គំ»។[៣៤]

ដូច្នេះ នៅពេលនោះ ភាពស្រស់ស្អាតនៃប្រាជ្ញា និងការស្រឡាញ់ដែលមានពេញទៅដោយការថ្នាក់ថ្នមរបស់នាងគឺជាចំណុចសម្រេចចិត្តចុងក្រោយក្នុងសង្គ្រាម ដែលកំពុងតែប្រកួតជាមួយនឹងភាពកំប៉ិកកំប៉ុកដែលកំពុងតែទាញសាច់ឈាមរបស់គាត់។

“ទូលបង្គំក៏បានទម្លាក់ខ្លួនចុះក្រោមដើមល្វាមួយ ដោយមិនដឹងថាទូលបង្គំបានទៅដល់ទីនោះ ហើយទឹកភ្នែករបស់ទូលបង្គំក៏បានចាប់ផ្តើមហូរយ៉ាងសេរី....ទូលបង្គំក៏ផ្ញើសម្រែកយំដែលពេញទៅដោយទុក្ខព្រួយនេះឡើង៖ “តើដល់កាលណាទៀត? តើដល់កាលណាទៀត? ថ្ងៃស្អែក និងថ្ងៃបន្ទាប់ពីថ្ងៃនេះមែនឬ? ហេតុអ្វីបានជាមិនតឡូវនេះ? ហេតុអ្វីបានជាមិនកម្ចាត់ចោលជីវិតមិនបរិសុទ្ធរបស់ខ្លួននៅវេលាម៉ោងនេះភ្លាមអញ្ចឹង?”...ហើយភ្លាមនោះទូលបង្គំក៏ឮសំឡេងរបស់ក្មេងប្រុស ឬក៏ក្មេងស្រីម្នាក់។ ទូលបង្គំមិនប្រាកដថាមួយណានោះទេ។ សំឡេងនោះចេញមកពីផ្ទះអ្នកជិតខាង។ សូត្រឃ្លានេះម្តងហើយម្តងទៀត៖ “យកវាឡើង ហើយអានវាចុះ! យកវាឡើង ហើយអានវាចុះ!”។[៣៥] ភ្លាមៗនោះទូលបង្គំក៏ឈប់យំ ហើយក៏បានចាប់ផ្តើមឆ្ងល់ថា តើឃ្លានេះគឺជាផ្នែកមួយនៃល្បែងក្មេងៗលេងមែនឬ។ ប៉ុន្តែ ទូលបង្គំមិនបានចាំថា វាជាឃ្លាដែលទូលបង្គំធ្លាប់ឮពីមុននោះទេ។ ដូច្នេះ ទូលបង្គំក៏ទប់ទឹកភ្នែក ហើយងើបឈរឡើង។ ហើយទូលបង្គំមិនអាចគិតអំពីអ្វីផ្សេងទៀត ក្រៅពីការជឿថា នេះគឺជាបញ្ជាពីព្រះជាម្ចាស់ឲ្យបើកព្រះគម្ពីរ ហើយអាន។ ជាពិសេសអត្ថបទដំបូងដែលទូលបង្គំទំនងជារកឃើញ»។[៣៦]

“ទូលបង្គំក៏ត្រឡប់ទៅបង់អង្គុយដែលលោក អាលីពីស៍ កំពុងអង្គុយភ្លាម។ ដ្បិតទូលបង្គំបានទុកព្រះគម្ពីរសាវ័កនៅកន្លែងនោះពីមុន។ ទូលបង្គំក៏យកវា ហើយបើកវា ហើយក្នុងភាពស្ងៀមស្ងាត់ក៏អាននូវកថាខណ្ឌដែលភ្នែកទូលបង្គំបានឃើញមុនគេបង្អស់។ ទី

៣៤ ក្នុងសៀវភៅដដែល, ទំព័រ២១៤។
៣៥ នេះគឺជាឃ្លាដ៏ល្បីមួយ “Tolle, lege; tolle, lege.”។
៣៦ ក្នុងសៀវភៅដដែល, ទំព័រ២១៧។

នោះមានសរសេរដូចតទៅ៖ “មិនមែនដោយស៊ីផឹក លេងល្បែង ឬមានស្រីញី ឬដោយឈ្លោះប្រកែក និងឈ្នានីស នោះឡើយ។ ផ្ទុយទៅវិញ ត្រូវប្រដាប់ខ្លួនដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយកុំបំពេញតាមសេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាមឡើយ”។[៣៧] ទូលបង្គំមិនចង់អានទៅមុខទៀត ហើយទូលបង្គំក៏មិនចាំបាច់ដែរ។ ពីព្រោះជាមួយនឹងពាក្យចុងក្រោយនៃប្រយោគ នោះក៏ហាក់បីដូចជាមានពន្លឺក្នុងលក្ខណៈដ៏ពិសេសមួយបានជ្រាបចូលដួងចិត្តរបស់ទូលបង្គំ ដែលមានពេញទៅដោយភាពប្រាកដប្រជា។ ហើយភ្លាមៗនោះ រាល់ភាពស្រពេចស្រពិលនៃមន្ទិលសង្ស័យក៏បានរលាយបាត់ទៅ»។[៣៨]

## កន្លែងដែលមិនបានជ្រើសរើសទុក និងការគ្រោងទុករបស់ព្រះជាម្ចាស់

បទពិសោធន៍នៃព្រះគុណរបស់ព្រះជាម្ចាស់ក្នុងការបំផ្លាស់បំប្រែចិត្តរបស់គាត់ក៏បានរៀបជាគន្លងសម្រាប់ទេវវិទ្យានៃព្រះគុណរបស់គាត់ដែលនាំឲ្យគាត់ឈ្លោះប្រកែកគ្នាជាមួយនឹងលោក ភីលេហ្គៀស៍ ហើយការនេះក៏បានបណ្ដាលឲ្យគាត់ក្លាយជាប្រភពនៃពួកធ្វើកំណែទម្រង់ប្រមាណជារាប់ពាន់ឆ្នាំក្រោយមក។ ហើយទេវវិទ្យានៃព្រះគុណដ៏មានពេញទៅដោយអធិបតេយ្យភាពមួយនេះក៏ជាទេវវិទ្យានៃការយល់ដឹងយ៉ាងពេញលេញអំពីជ័យជម្នះនៃការមានអំណរក្នុងព្រះជាម្ចាស់ផងដែរ។

នៅក្នុងថ្ងៃបុណ្យព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញនៅឆ្នាំបន្ទាប់ គឺ៣៨៧នោះគាត់ក៏បានទទួលពិធីជ្រមុជទឹក នៅទីក្រុងមីឡានតាមរយៈលោកគ្រូគង្វាល អែមប្រូស៍។ នៅខែប្រាំង អ្នកម្ដាយរបស់គាត់បានទទួលមរណៈភាព។ អ្នកម្ដាយរបស់គាត់បានទទួលមរណៈភាពក្នុងលក្ខណៈជាស្ត្រីដែលសប្បាយចិត្តយ៉ាងខ្លាំង ពីព្រោះកូនប្រុសដែលគាត់បានបង្ហូរទឹកភ្នែកជាច្រើនឆ្នាំបានមានសុវត្ថិភាពក្នុងព្រះគ្រីស្ទហើយ។ នៅឆ្នាំ៣៨៨នៃគ.ស. (កាលគាត់ជិតមានអាយុ៣៤ឆ្នាំ) គាត់ក៏បានត្រឡប់ទៅឯប្រទេសអាហ្វ្រិកវិញ ដោយ

៣៧ រ៉ូម ១៣:១៣។

៣៨ ក្នុងសៀវភៅដដែល, ទំព័រ២១៨។

មានទស្សនៈចង់បង្កើតសាលាមួយសម្រាប់គាត់ និងមិត្តភក្តិរបស់គាត់ ដែលគាត់បានហៅថា “អ្នកបម្រើរបស់ព្រះជាម្ចាស់”។ គាត់បានបោះបង់ផែនការនៃការរៀបការចោល ហើយបានប្តេជ្ញាខ្លួនរស់នៅក្នុងជីវិតនៅលីវ និងភាពក្រីក្រ—ដែលនេះគឺថា ការមានជីវិតរស់នៅដ៏សាមញ្ញៗជាមួយអ្នកដទៃក្នុងសង្គមមួយ។[៣៩] គាត់ប្រាថ្នាចង់បានជីវិតដែលចំណាយពេលលើទស្សនវិជ្ជាក្នុងសាលនៅឯវិហារមួយ។

ប៉ុន្តែ ព្រះជាម្ចាស់មានផែនការផ្សេង។ លោក អាឌីអូដាទឹស ដែលជាកូនប្រុសរបស់លោកគ្រូ អហ្គូស្ទីន បានស្លាប់នៅឆ្នាំ៣៨៩នៃគ.ស.។ សេចក្តីស្រមៃនៃការត្រឡប់ទៅក្នុងជីវិតស្ងប់ស្ងាត់នៅឯ ធាហ្គាស្ទេ ដែលជាស្រុកកំណើតរបស់គាត់ ក៏បានរលាយបាត់ទៅក្នុងពន្លឺនៃភាពអស់កល្បជានិច្ច។ លោកគ្រូ អហ្គូស្ទីន បានឃើញថាវាទំនងជាយុទ្ធសាស្ត្រដ៏ល្អក្នុងការរើទីតាំងសាលាដែលជាសង្គមរបស់គាត់ទៅឯទីក្រុង ហិផូ ដែលធំជាងនោះ។ គាត់ជ្រើសរើសទីក្រុង ហិផូ ពីព្រោះនៅទីនោះគេមានគ្រូគង្វាលរួចស្រេចហើយ ដែលការនេះនឹងនាំឲ្យគាត់មិនសូវមានឱកាសក្នុងការដែលគេជំរុញឲ្យគាត់ទទួលតួនាទីនោះ។ ប៉ុន្តែ គាត់គណនាខុស—ដូចជាលោកគ្រូ ចន ខែលវិន ប្រមាណជាង១០០០ឆ្នាំក្រោយមកដែរ។ ក្រុមជំនុំក៏បានមករកលោកគ្រូ អហ្គូស្ទីន ហើយបើនិយាយឲ្យខ្លីទៅក៏បានបង្ខំគាត់ឲ្យធ្វើជាសង្ឃ ហើយបន្ទាប់មកជាគ្រូគង្វាលនៃទីក្រុង ហិផូ ដែលជាទីកន្លែងដែលគាត់បានរស់នៅក្នុងជីវិតនៅសល់របស់គាត់។

ជាច្រើនឆ្នាំកន្លងមកទៀតក្នុងសេចក្តីអធិប្បាយមួយរបស់គាត់ លោកគ្រូ អហ្គូស្ទីន បានលើកឡើងទៅកាន់សមាជិកក្រុមជំនុំរបស់គាត់ថា “បាវបម្រើមិនអាចជំទាស់នឹងចៅហ្វាយរបស់ខ្លួនបានទេ។ យើងខ្ញុំបានមកទីក្រុងនេះ ដើម្បីជួបមិត្តភក្តិម្នាក់ ដែលយើងខ្ញុំបានគិតថាអាចនឹងនាំគាត់ឲ្យទទួលជឿព្រះជាម្ចាស់បាន ដើម្បីឲ្យគាត់ទំនងជាមករស់នៅជាមួយយើងនៅឯសាលា។ យើងខ្ញុំមានសន្តិភាពដោយសារកន្លែងនេះមានគ្រូគង្វាលរួចស្រាប់ទៅហើយ។ ពេលនោះអ្នករាល់គ្នាក៏បានចាប់យើងខ្ញុំ។ អ្នករាល់គ្នាក៏បានយកយើងខ្ញុំធ្វើជាសង្ឃ...ហើយបន្ទាប់មកយើងខ្ញុំក៏បានក្លាយជាគ្រូគង្វាលរបស់អ្នករាល់គ្នា”។[៤០]

ដូច្នេះ ដូចមនុស្សជាច្រើននាក់ដែលមានឥទ្ធិពលយូរអង្វែងនៅក្នុងប្រវត្តិសាស្ត្រនៃ

---

៣៩ លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ១១៦។

៤០ ក្នុងសៀវភៅដដែល, ទំព័រ១៣៨។

ក្រុមជំនុំ នោះគាត់ក៏ត្រូវបានដកចេញ (នៅអាយុ៣៦ឆ្នាំ) ពីជីវិតនៃការចង់សញ្ជឹងគិត ហើយបោះចូលក្នុងជីវិតដែលមានសកម្មភាពវិញ។ តួនាទីនៃគ្រូគង្វាលមានរួមទាំងការដោះស្រាយការឈ្លោះប្រកែកគ្នាខាងឯផ្លូវច្បាប់ក្នុងចំណោមសមាជិកក្រុមជំនុំ និងការគ្រប់គ្រងទំនួលខុសត្រូវជាច្រើនក្នុងសង្គម។ “គាត់ត្រូវទៅសួរសុខទុក្ខពន្ធនាគារ ដើម្បីការពារអ្នកជាប់គុកពីការធ្វើបាប។ គាត់ត្រូវចូលធ្វើអន្តរាគមន៍...ដើម្បីសង្គ្រោះឧក្រិដ្ឋជនពីការធ្វើបាបពីតុលាការ និងការប្រហារជីវិត។ លើសពីនោះ ពួកគេរំពឹងឲ្យគាត់រក្សាសន្តិភាពក្នុងក្រុមជំនុំរបស់ពួកគេតាមរយៈមជ្ឈត្តកម្មក្នុងបណ្តឹងរបស់ពួកគេផងដែរ”។[៤១]

លោកគ្រូ អហ្គូស្ទីន បានបង្កើតសាលានៅលើបរិវេណវិហារ ហើយអស់ប្រមាណជិត៤០ឆ្នាំគាត់ក៏បានបណ្តុះបណ្តាលពួកសង្ឃនិងគ្រូគង្វាលជាច្រើននាក់ដែលជ្រួតជ្រាបទៅដោយព្រះគម្ពីរ ដែលបានចេញទៅបម្រើស្ទើរតែគ្រប់ទីកន្លែងនៅអាហ្វ្រិក ហើយចលនានោះក៏បាននាំមកនូវនៅការបំផ្លាស់បំប្រែចំពោះក្រុមជំនុំជាច្រើនដែរ។ គាត់បានចាត់ទុកខ្លួនឯងជាចំណែកមួយនៃសាលា ដោយបរិភោគម្ហូបបួស និងរស់នៅក្នុងភាពក្រីក្រ និងភាពបរិសុទ្ធ។ មានការហាមប្រាមយ៉ាងតឹងរឹងមិនអនុញ្ញាតឲ្យមនុស្សស្រីមកលេង។ មានការប្រថុយប្រថានខ្លាំងពេក ហើយគាត់ក៏ស្គាល់ចំណុចខ្សោយរបស់ខ្លួនផងដែរ។ គាត់មិនដែលរៀបការ។ នៅពេលដែលគាត់ទទួលមរណភាព គាត់ក៏មិនមានលិខិតបណ្តាំចុងក្រោយ ពីព្រោះគ្រប់អ្វីៗដែលជាកម្មសិទ្ធិរបស់គាត់ក៏ជាកម្មសិទ្ធិសាធារណៈក្នុងសាលាដែរ។ ការនិពន្ធ គ្រូៗដែលគាត់បានបង្ហាត់បង្រៀន និងសាលារបស់គាត់គឺកេរ្តិ៍ដំណែលរបស់គាត់។

## ជ័យជម្នះនៃព្រះគុណជា “អំណរដ៏ឧត្តុង្គឧត្តម”

ឥឡូវ ត្រឡប់មកជ័យជម្នះនៃព្រះគុណក្នុងជីវប្រវត្តិរបស់លោកគ្រូ អហ្គូស្ទីន និងទេវវិទ្យារបស់គាត់។ លោកគ្រូ អហ្គូស្ទីន ក៏បានទទួលបទពិសោធន៍នៃព្រះគុណនេះ ហើយក៏បានអភិវឌ្ឍវាជាទេវវិទ្យានៃអំណរដ៏ឧត្តុង្គឧត្តមនៃការយល់ដឹងយ៉ាងពេញលេញ។ លោក

៤១ ក្នុងសៀវភៅដដែល, ទំព័រ១៩៥។

គ្រូ អ. ស៊ី. ស្រ្ពូល (R. C. Sproul) បានលើកឡើងថា សព្វថ្ងៃនេះ ក្រុមជំនុំស្ថិតក្នុងការឃុំឃាំងរបស់ពួកភីលេហ្គៀនយ៉ាងខ្លាំង។[៤២] ទំនងវេជ្ជបញ្ជាសម្រាប់ការព្យាបាលក្រុមជំនុំ ហើយជាពិសេសសម្រាប់អស់អ្នកដែលស្រឡាញ់អធិបតេយ្យភាពរបស់ព្រះជាម្ចាស់ឲ្យជាសះស្បើយគឺតាមរយៈការទទួលយកគោលជំនឿនៃ «អំណរដ៏ឧត្តុង្គឧត្តម» របស់លោកគ្រូ អហ្គូស្ទីន ឡើងវិញ។ សព្វថ្ងៃនេះ ក្នុងការគិត និងការអធិប្បាយជាច្រើនរបស់គ្រីស្ទបរិស័ទ (ដែលមានរួមទាំងការគិត និងការអធិប្បាយរបស់ពួកធ្វើកំណែទម្រង់) គឺមិនទាន់បានជ្រៀតចូលទៅដល់ឫសនៃដំណើរការដ៏ពិតនៃរបៀបដែលព្រះគុណមានជ័យជម្នះ ជាពិសេសតាមរយៈអំណរ ដែលជាក់ស្តែងប្រកាន់ខ្ជាប់តាមសេចក្តីបង្រៀនរបស់លោកគ្រូ អហ្គូស្ទីន តែពាក់កណ្តាល ប្រកាន់ខ្ជាប់តាមព្រះគម្ពីរតែពាក់កណ្តាល និងប្រកាន់ខ្ជាប់តាមភាពស្រស់ស្អាតតែពាក់កណ្តាលប៉ុណ្ណោះ។

ជីវប្រវត្តិ និងគោលគំនិតរបស់លោកគ្រូ អហ្គូស្ទីន នាំយើងត្រឡប់មកឫសគល់នៃអំណរនេះវិញ។ លោក ភីលេហ្គាស៍ (Pelagius) គឺជាសង្ឃម្នាក់មកពីប្រទេសអង់គ្លេស (ដែលបានរស់នៅឯទីក្រុងរ៉ូមក្នុងសម័យលោកគ្រូ អហ្គូស្ទីន) បានបង្រៀនថា «ទោះបើព្រះគុណទំនងជាសម្របសម្រួលការសម្រេចនូវសេចក្តីសុចរិតក៏ដោយក៏វាមិនចាំបាច់។[៤៣] គាត់បានបដិសេធគោលជំនឿនៃអំពើបាបដែលជាមរតក ហើយក៏បានអះអាងថាក្នុងចំណុចស្នូលនៃធម្មជាតិរបស់មនុស្សលោកគឺល្អ ហើយក៏អាចធ្វើនូវរាល់គ្រប់អ្វីៗដែលព្រះជាម្ចាស់បញ្ជាឲ្យធ្វើបានដែរ។ ហេតុដូច្នេះបានជាលោក ភីលេហ្គាស៍ មានការភ្ញាក់ផ្អើលនៅពេលដែលគាត់អានក្នុងសៀវភៅ «ការលន់តួ» របស់លោកគ្រូ អហ្គូស្ទីន «សូមប្រទាននូវអ្វីដែលទ្រង់បញ្ជា [ឱព្រះអម្ចាស់អើយ] ហើយបញ្ជានូវអ្វីដែលទ្រង់សព្វព្រះហឫទ័យ!...ឱព្រះដ៏បរិសុទ្ធអើយ...នៅពេលដែលយើងស្តាប់តាមបញ្ជារបស់ព្រះអង្គគឺវាពីព្រះអង្គហើយដែលយើងទទួលបានអំណាចក្នុងការស្តាប់តាមបញ្ជានោះបាន»។[៤៤] លោក ភីលេហ្គាស៍ ឃើញថាចំណុចនេះគឺជាការវាយប្រហារលើភាពល្អរបស់មនុស្ស និងទំនួល

---

៤២ «តើលោក លូសើរ នឹងគិតយ៉ាងដូចម្តេចអំពីអស់អ្នកដែលបន្តតំណែងសព្វថ្ងៃនេះពីសម័យកំណែទម្រង់? ខ្ញុំនិយាយថាគាត់ទំនងជានឹងសរសេរអំពីការដែលក្រុមជំនុំជាប់ក្នុងភាពជាឈ្លើយរបស់ពួកភីលេហ្គៀនជាមិនខាន» លោកគ្រូ អ. ស៊ី. ស្រ្ពូល បានលើកឡើងក្នុងសៀវភៅ *Willing to Believe: The Controversy Over Free Will* (Grand Rapids: Baker Books, ឆ្នាំ១៩៩៧), ទំព័រ២១។

៤៣ លោកគ្រូ ស្រ្ពូល, *«លោកគ្រូ អហ្គូស្ទីន និងលោក ភីលេហ្គៀស៍»*, ទំព័រ១៣។

៤៤ លោកគ្រូ អហ្គូស្ទីន, *«ការលន់តួ»*, ទំព័រ២៨២, ទំព័រ២៨៥។

ខុសត្រូវរបស់មនុស្ស។ លោក ភីលេហ្គាស៍ គិតថា ប្រសិនបើព្រះជាម្ចាស់ត្រូវតែប្រទាននូវអ្វីដែលទ្រង់បញ្ជា នោះយើងក៏នឹងមិនអាចធ្វើនូវអ្វីដែលទ្រង់បញ្ជា ហើយក៏មិនមានទំនួលខុសត្រូវក្នុងការធ្វើនូវអ្វីដែលទ្រង់បញ្ជា ហើយច្បាប់សីលធម៌ក៏នឹងដួលរលំដែរ។

លោកគ្រូ អហ្គូស្ទីន មិនបានឈានដល់ទស្សនៈនេះរបស់គាត់យ៉ាងឆាប់រហ័សនោះទេ។ ក្នុងសៀវភៅរបស់គាត់ «លើសេរីភាពនៃឆន្ទៈ» (“On the Freedom of the Will”) ដែលគាត់បាននិពន្ធនៅក្នុងចន្លោះឆ្នាំ៣៨៨-៣៩១នៃគ.ស. គាត់បានការពារសេរីភាពនៃឆន្ទៈក្នុងរបៀបដែលនាំឲ្យលោក ភីលេហ្គាស៍ ស្រង់សម្រង់សម្ដីចេញពីសៀវភៅរបស់លោកគ្រូ អហ្គូស្ទីន ផ្ទាល់ក្នុងការទាស់ប្រឆាំងជាមួយនឹងគាត់នៅពេលក្រោយក្នុងជីវិតរបស់គាត់។[៤៥] ប៉ុន្តែ មកដល់ពេលដែលលោកគ្រូ អហ្គូស្ទីន បាននិពន្ធសៀវភៅ «ការលន់តួ» ប្រមាណជា១០ឆ្នាំក្រោយមក បញ្ហានោះក៏ត្រូវបានរកដំណោះស្រាយរួចទៅហើយ។ នេះគឺជាអ្វីដែលគាត់បានសរសេរ (នេះទំនងជាកថាខណ្ឌដ៏សំខាន់បំផុតក្នុងការយល់អំពីចំណុចស្នូលនៃគោលគំនិតនៃសេចក្ដីបង្រៀនរបស់លោកគ្រូ អហ្គូស្ទីន)៖

«តើឆន្ទៈសេរីរបស់ទូលបង្គំនៅឯណាក្នុងអំឡុងឆ្នាំ [នៃការបះបោរ] ទាំងអស់នោះ? ឱព្រះគ្រីស្ទយេស៊ូវអើយ! ហើយតើចេញពីជម្រៅណាដែលទូលបង្គំបានទទួលការត្រាស់ហៅឲ្យទូលបង្គំចុះចូលក្រោម «នឹមងាយ» ស្រួលរបស់ព្រះអង្គ?...ការនេះក៏បានក្លាយជាផ្អែមល្ហែមភ្លាមៗដល់ទូលបង្គំក្នុងការមិនមានភាពអរសប្បាយដ៏ល្ងីល្ងើដែលទូលបង្គំធ្លាប់សប្បាយជាមួយពីមុន! ហើយឥឡូវនេះទូលបង្គំក៏មានអំណរក្នុងការបោះបង់ចោលនូវអ្វីដែលពីមុនទូលបង្គំធ្លាប់មានការភ័យខ្លាចក្នុងការបាត់បង់។ ឱភាពផ្អែមល្ហែមដ៏ពិត និងខ្ពង់ខ្ពស់អើយ! ដ្បិតគឺព្រះអង្គហើយដែលបានបោះបង់សេចក្ដីប្រាថ្នាទាំងនោះរបស់ទូលបង្គំចោល។ [នេះគឺជាឃ្លាគន្លឹះ និងឃ្លាដ៏ពិតក្នុងការយល់អំពីចំណុចស្នូលនៃអហ្គូស្ទីននិយម។] ព្រះអង្គបានបោះបង់វាចោល ហើយព្រះអង្គផ្ទាល់ក៏បានយកកន្លែងរបស់វា—ផ្អែមលើសជាងភាពអរសប្បាយទាំងអស់ ទោះបើមិនទៅកាន់សាច់ឈាម ភ្លឺខ្លាំងជាងពន្លឺទាំងអស់ ប៉ុន្តែមានរបាំងលើសជាងអាថ៌កំបាំងទាំងអស់ មានការលើកតម្កើងខ្ពង់ខ្ពស់ហួសកិត្តិយសទាំងអស់ ប៉ុន្តែមិនមែនចំពោះអស់អ្នកដែលគិតខ្ពស់អំពីខ្លួន....ឱព្រះអម្ចាស់

៤៥ «ដូច្នេះ ដែលមិនសមហេតុសមផល នោះសត្រូវដ៏ធំមួយរបស់លោកគ្រូ អហ្គូស្ទីន ក្នុងវ័យចំណាស់របស់គាត់ គឺបានទទួលអភិប្រាយទាំងនោះពីទស្សនវិទូវ័យក្មេង ដែលលោកគ្រូ អហ្គូស្ទីន បានការពារសេរីភាពនៃឆន្ទៈទាស់ប្រឆាំងនឹងការប្ដេជ្ញារបស់ក្រុមមានិហ្កៀន» (លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ១៤៩)។

ដ៏ជាព្រះជាម្ចាស់នៃទូលបង្គំអើយ! ទូលបង្គំក៏បាននិយាយប៉ប៉ាច់ប៉ប៉ោចដូចជាកូនក្មេងម្នាក់ទៅកាន់ព្រះអង្គ—ពន្លឺរបស់ទូលបង្គំ ទ្រព្យសម្បត្តិរបស់ទូលបង្គំ និងសេចក្ដីសង្គ្រោះរបស់ទូលបង្គំ»។[៤៦]

នេះគឺជាការយល់ឃើញរបស់លោកគ្រូ អហ្គូស្ទីន អំពីព្រះគុណ។ ព្រះគុណគឺជាការដែលព្រះជាម្ចាស់ប្រទានអំណរដ៏ឧត្ដុង្គឧត្ដមក្នុងព្រះអង្គមកកាន់យើងដែលនាំឲ្យយើងមានជ័យជម្នះលើអំណរក្នុងអំពើបាប។ និយាយម្យ៉ាងវិញទៀត ព្រះជាម្ចាស់ធ្វើការយ៉ាងជ្រៅក្នុងដួងចិត្តរបស់មនុស្សយើង ដើម្បីបំផ្លាស់បំប្រែក្បាលទឹកនៃអំណរ ដើម្បីឲ្យយើងស្រឡាញ់ព្រះអង្គខ្លាំងជាងការរួមភេទ ឬក៏អ្វីណាមួយផ្សេងទៀត។ ក្នុងគំនិតរបស់លោកគ្រូ អហ្គូស្ទីន ការស្រឡាញ់ព្រះជាម្ចាស់គឺមិនមែនជាការបន្ថយចុះទៅជាទង្វើនៃការស្ដាប់បង្គាប់ ឬក៏ទង្វើនៃអំណាចនៃការរក្សាទឹកចិត្តឡើយ។ គាត់មិនបានលើកឡើងពីកណ្ឌគម្ពីរ យ៉ូហាន ១៤:១៥ («បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ») ក្នុងរបៀបខុសឆ្គង ហើយអះអាងថាការស្រឡាញ់គឺដូចគ្នាទៅនឹងការរក្សាបញ្ញត្តិរបស់ព្រះនោះទេ នៅពេលដែលខគម្ពីរបានលើកឡើងថា ការរក្សាបញ្ញត្តិរបស់ព្រះគ្រីស្ទគឺជាលទ្ធផលនៃការស្រឡាញ់ព្រះគ្រីស្ទ។ «បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ»។ ហើយគាត់ក៏មិនបានធ្វើខុសដោយលើកឡើងពីកណ្ឌគម្ពីរ ១យ៉ូហាន ៥:៣ («ដ្បិតនេះហើយជាសេចក្ដីស្រឡាញ់របស់ព្រះ គឺឲ្យយើងកាន់តាមបទបញ្ជារបស់ព្រះអង្គ ឯបទបញ្ជារបស់ព្រះអង្គ មិនមែនជាបន្ទុកធ្ងន់ទេ» គកស) ហើយមើលរំលងចំណុចដែលថាការស្រឡាញ់ពីព្រះជាម្ចាស់មានន័យថាជាការរក្សាបញ្ញត្តិរបស់ទ្រង់ក្នុងរបៀបបែបនេះដែលថាបញ្ញត្តិរបស់ព្រះអង្គមិនមែនជាបន្ទុកធ្ងន់នោះដែរ។ ការស្រឡាញ់ព្រះជាម្ចាស់គឺជាការមានភាពស្កប់ស្កល់ក្នុងទ្រង់ ហើយក៏មានភាពពេញចិត្តក្នុងរាល់គ្រប់ចំណុចនៃទ្រង់សម្រាប់យើងរហូតដល់ថ្នាក់ថាបញ្ញត្តិរបស់ទ្រង់លែងជាបន្ទុកទៀត។ លោកគ្រូ អហ្គូស្ទីន បានឃើញចំណុចនេះ។ ហើយសព្វថ្ងៃនេះយើងក៏ត្រូវការគាត់យ៉ាងខ្លាំងដែរក្នុងការជួយយើងឲ្យស្វែងរកឫសគល់នៃជីវិតរស់នៅជាប្រចាំថ្ងៃសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗគ្នាក្នុងអំណរដែលមានជ័យជម្នះក្នុងព្រះអង្គ ដែលដកចេញនូវអធិបតេយ្យភាពនៃភាពខ្ជិលច្រអូស ភាពត្រេកត្រអាល និងភាពច្រណែនចោល។

---

៤៦ លោកគ្រូ អហ្គូស្ទីន, *«ការលន់តួ»*, ទំព័រ២២២, ការផ្ដោតលើគឺជាការបន្ថែម។

ចំពោះលោកគ្រូ អហ្គូស្ទីន ការស្រឡាញ់ព្រះជាម្ចាស់គឺតែងតែជាការមានភាពពេញចិត្តក្នុងព្រះអង្គ និងក្នុងអ្វីៗផ្សេងទៀតលុះត្រាតែវាជាប្រយោជន៍ដល់ព្រះជាម្ចាស់តែប៉ុណ្ណោះ។ គាត់បានផ្តល់អត្ថន័យយ៉ាងច្បាស់លាស់ក្នុងសៀវភៅ "លើគោលជំនឿគ្រីស្ទបរិស័ទ" ("On Christian Doctrine" III, x, ១៦)។ "ខ្ញុំហៅ "សេចក្តីស្រឡាញ់" ថាជាចលនានៃព្រលឹងទៅកាន់ការមានអំណរក្នុងព្រះជាម្ចាស់សម្រាប់ប្រយោជន៍ដល់ទ្រង់ផ្ទាល់ និងការមានអំណរក្នុងខ្លួនឯងផ្ទាល់ និងក្នុងអ្នកជិតខាង ដើម្បីជាប្រយោជន៍ដល់ព្រះជាម្ចាស់"។[៤៧] ជាមូលដ្ឋាន ការស្រឡាញ់ព្រះជាម្ចាស់គឺជាការពេញចិត្តក្នុងព្រះអង្គ និងក្នុងអ្វីមួយណាផ្សេងទៀតសម្រាប់ជាប្រយោជន៍ដល់ទ្រង់ដែរ។

លោកគ្រូ អហ្គូស្ទីន បានវិភាគលើហេតុផលរបស់គាត់ផ្ទាល់រហូតដល់ឫសគល់។ គ្រប់អ្វីៗទាំងអស់ផុសចេញពីការពេញចិត្ត។ គាត់បានឃើញចំណុចនេះថាជាចំណុចសកលៈ "មនុស្សគ្រប់ៗរូប មិនថាក្នុងស្ថានភាពណាក៏ដោយ សុទ្ធតែចង់មានការអរសប្បាយ។ គ្មានមនុស្សណាមិនប្រាថ្នាបែបនេះនោះទេ ហើយគ្រប់ៗគ្នាក៏សុទ្ធតែប្រាថ្នាវាដោយមានបំណងចិត្តយ៉ាងខ្លាំង ដល់ថ្នាក់ថាគាត់ចូលចិត្តវាលើសជាងអ្វីៗទាំងអស់ផ្សេងទៀត។ តាមពិតទៅ មិនថាបុគ្គលណាក៏ដោយដែលមានបំណងប្រាថ្នាអ្វីមួយផ្សេងទៀតគឺសុទ្ធតែប្រាថ្នាវាឲ្យបានសម្រាប់ឲ្យទៅដល់គោលដៅនេះតែមួយគត់"។[៤៨] នេះគឺជាអ្វីដែលណែនាំ និងគ្រងលើអ្វីដែលយើងហៅថាឆន្ទៈ ពោលគឺជាអ្វីដែលយើងរាប់ថាជាការពេញចិត្តរបស់យើង។

ប៉ុន្តែ នេះជាចំណុចស្នូលដែលធ្វើឲ្យលោក ភីលេហ្គៀស៍ ខឹងយ៉ាងខ្លាំង។ លោកគ្រូ អហ្គូស្ទីន បានជឿជាក់ថា វាមិនអាស្រ័យលើអំណាចរបស់យើងនោះទេក្នុងការប្តេជ្ញាថាអ្វីទៅជាការពេញចិត្ត។

"តើអ្នកណាទៅមានអំណាចក្នុងខ្លួនឯងផ្ទាល់ដល់ថ្នាក់ថាមានមូលហេតុ ដែលបើក

---

៤៧ លោកគ្រូ អហ្គូស្ទីន, "លើគោលជំនឿគ្រីស្ទបរិស័ទ" *(On Christian Doctrine)*, បកប្រែដោយលោកគ្រូ D. W. Robertson, Jr. (Upper Saddle River, NJ: Prentice Hall, ១៩៥៨), ទំព័រ៨៨។ គាត់បានបន្ថែមថា ""ការពេញចិត្តលើទ្រព្យសម្បត្តិ" គឺជាចលនារបស់ព្រលឹងទៅកាន់ការមានអំណរជាមួយនឹងខ្លួនឯង អ្នកជិតខាងរបស់ខ្លួនឯង ឬអ្វីផ្សេងទៀតរួមគ្នា ដើម្បីជាប្រយោជន៍អ្វីមួយផ្សេងទៀតជាជាងព្រះជាម្ចាស់"។

៤៨ លោកគ្រូ Thomas A. Hand, *Augustine on Prayer* (New York: Catholic Book Publishing Co., ១៩៨៦), ទំព័រ១៣ (សេចក្តីអត្ថាធិប្បាយ #៣០៦)។ លោកគ្រូ អហ្គូស្ទីន, *"ការលន់តួ"*, ទំព័រ២២៨ (X, ២១): "ដោយគ្មានករណីលើកលែង យើងទាំងអស់គ្នាសុទ្ធតែប្រាថ្នាចង់បានការអរសប្បាយ....គ្រប់គ្នាសុទ្ធតែឯកភាពថាខ្លួនចង់អរសប្បាយ....ពួកគេទំនងជាស្វែងរកវាក្នុងរបៀបខុសៗគ្នា ប៉ុន្តែគ្រប់គ្នាសុទ្ធតែខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាពរបស់ខ្លួនក្នុងការឈោងចាប់គោលដៅដូចគ្នាដែរ នោះគឺថាអំណរ"។

ជាបទបង្ហាញទៅកាន់គំនិតរបស់គាត់ដល់ថ្នាក់ថាឆន្ទៈរបស់គាត់នឹងទទួលឥទ្ធិពលឲ្យទទួលជឿបាន? តើអ្នកណាអាចស្វាគមន៍មកកាន់គំនិតរបស់គាត់ដែលមិនផ្ដល់ជូនការពេញចិត្តដល់គាត់បាន? ប៉ុន្តែ តើអ្នកណាទៅមានអំណាចក្នុងខ្លួនឯងផ្ទាល់ក្នុងការធានាថា អ្វីមួយនឹងធ្វើឲ្យគាត់ពេញចិត្តនឹងលេចឡើងមកជាមិនខាន? ឬក៏ថា គាត់នឹងពេញចិត្តនឹងអ្វីដែលលេចឡើងមក? ប្រសិនបើអ្វីៗទាំងនោះធ្វើឲ្យយើងពេញចិត្តមែន ដែលជាយានធ្វើឲ្យយើងកាន់តែរីកចម្រើនឡើងទៅកាន់ព្រះជាម្ចាស់ នោះវាមិនមែនកើតឡើងចេញពីបំណងប្រាថ្នា ការខិតខំប្រឹងប្រែង ឬក៏ទង្វើនៃគុណសម្បត្តិរបស់យើងផ្ទាល់ឡើយ ប៉ុន្តែគឺជាការជំរុញពីព្រះជាម្ចាស់ និងពីព្រះគុណដែលទ្រង់បានបំពាក់លើទេតើ»។[៤៩]

ក្នុងទស្សនៈរបស់លោកគ្រូ អហ្គូស្ទីន ព្រះគុណដែលសង្គ្រោះ ព្រះគុណដែលផ្លាស់ប្ដូរគឺជា៖ ការដែលព្រះជាម្ចាស់ប្រទានមកកាន់យើងនូវអំណរដ៏ឧត្ដុង្គឧត្ដមក្នុងព្រះអង្គដែលមានជ័យជម្នះលើគ្រប់អំណរផ្សេងៗ ហើយដូច្នេះវានឹងជះឥទ្ធិពលលើឆន្ទៈ។ ឆន្ទៈរបស់មនុស្សយើងមានសេរីភាពក្នុងការជ្រើសរើសអ្វីដែលធ្វើឲ្យវាពេញចិត្តយ៉ាងពេញទី ប៉ុន្តែវាមិនអាស្រ័យលើអំណាចនៃឆន្ទៈរបស់យើងផ្ទាល់ក្នុងការប្ដេជ្ញាថា តើអ្វីទៅជាអំណរដ៏ឧត្ដុង្គឧត្ដមនេះបានឡើយ។ ដូច្នេះ លោកគ្រូ អហ្គូស្ទីន ក៏បានធ្វើសេចក្ដីសន្និដ្ឋានដូចតទៅ៖

«ប្រាកដណាស់! ឆន្ទៈសេរីរបស់បុគ្គលណាម្នាក់មិនចាប់យកប្រយោជន៍អ្វីក្រៅពីការប្រព្រឹត្តអំពើបាបនោះទេ ប្រសិនបើគាត់មិនស្គាល់ផ្លូវនៃសេចក្ដីពិត ហើយសូម្បីតែបន្ទាប់ពីគាត់បានចាប់ផ្ដើមស្គាល់តួនាទី និងគោលដៅដ៏ត្រឹមត្រូវរបស់គាត់ក៏ដោយ លុះត្រាតែគាត់មានការពេញចិត្តក្នុងវា និងមានអារម្មណ៍ស្រឡាញ់វា នោះគាត់ក៏នឹងមិនបំពេញតួនាទី ឬក៏ចាប់ផ្ដើមបំពេញ ឬក៏រស់នៅឲ្យបានត្រឹមត្រូវផងដែរ។ ដូច្នេះ ដើម្បីឲ្យគន្លងបែប

---

៤៩ លោកគ្រូ T. Kermit Scott, *Augustine: His Thought in Context* (New York: Paulist Press, ១៩៩៥), ទំព័រ២០៣ (ជូនចំពោះលោកគ្រូ សិមភ្លីស៊ីអន្ទស៍, ii, ២១)។ នៅកន្លែងមួយទៀត គាត់បានលើកឡើងថា «ពិតណាស់! វាជារឿងឥតប្រយោជន៍ចំពោះយើងក្នុងការមានឆន្ទៈ លុះត្រាតែព្រះជាម្ចាស់មានសេចក្ដីមេត្តាករុណា។ ប៉ុន្តែ ខ្ញុំមិនដឹងថា វាអាចទៅរួចបានដោយរបៀបណាក្នុងការលើកឡើងថា វាជារឿងឥតប្រយោជន៍ចំពោះព្រះជាម្ចាស់ក្នុងការមានសេចក្ដីមេត្តាករុណាបាន លុះត្រាតែយើងស្ម័គ្រចិត្តចុះចូល។ ប្រសិនបើព្រះជាម្ចាស់មានសេចក្ដីមេត្តាករុណា នោះយើងក៏នឹងមានឆន្ទៈដែរ ដ្បិតអំណាចនៃការមានឆន្ទៈក៏ទទួលបានដោយក្ដីមេត្តាករុណាផ្ទាល់។ ព្រះជាម្ចាស់គឺជាអង្គដែលធ្វើការក្នុងយើងក្នុងការមានឆន្ទៈ និងក្នុងការអនុវត្តនូវអ្វីដែលទ្រង់សព្វព្រះហឫទ័យ។ ប្រសិនបើយើងសួរថា តើឆន្ទៈល្អគឺជាអំណោយទានពីព្រះជាម្ចាស់ នោះខ្ញុំនឹងមានការភ្ញាក់ផ្អើល បើបុគ្គលណាម្នាក់ហ៊ានបដិសេធការនោះ។ ប៉ុន្តែ ដោយសារឆន្ទៈល្អមិនបានកើតឡើងមុនការត្រាស់ហៅ ប៉ុន្តែការត្រាស់ហៅកើតមុនឆន្ទៈ នោះចំណុចពិតដែលថាយើងមានឆន្ទៈល្អគឺដោយសារព្រះជាម្ចាស់បានត្រាស់ហៅយើង ហើយចំណុចពិតដែលថាយើងបានទទួលការត្រាស់ហៅគឺមិនមែនកើតមកពីខ្លួនឯងនោះទេ (លោកគ្រូ Scott, *Augustine: His Thought in Context*, ទំព័រ២០១ [ជូនចំពោះលោកគ្រូ សិមភ្លីស៊ីអន្ទស៍, ii, ១២])។

នេះអាចចាប់អារម្មណ៍លើសុច្ឆន្ទៈរបស់យើងបាន នោះ "សេចក្តីស្រឡាញ់របស់ព្រះបាន បង្ហូរមកក្នុងចិត្តយើង" មិនមែនតាមរយៈឆន្ទៈសេរីដែលកើតចេញពីខ្លួនយើងផ្ទាល់នោះទេ ប៉ុន្តែ "តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមកយើង" វិញ (រ៉ូម ៥:៥)»។[៥០]

នៅឆ្នាំ៤២៧នៃគ.ស. គាត់បានមើលត្រឡប់ក្រោយលើជីវិតនៃគំនិតទាក់ទងលើបញ្ហានេះ ហើយក៏បានសរសេរទៅកាន់លោកគ្រូ សិមភ្លីស៊ីអនុស៍ (Simplicianus) ដូចតទៅ៖ "ក្នុងការព្យាយាមឆ្លើយសំណួរនេះ ខ្ញុំបានព្យាយាមយ៉ាងខ្លាំងក្នុងការរក្សាទុកជម្រើសសេរីនៃឆន្ទៈរបស់មនុស្សជាតិ ប៉ុន្តែព្រះគុណរបស់ព្រះជាម្ចាស់បានមានជ័យជម្នះលើវា»។[៥១] ភាពខ្វែងគំនិតគ្នាគឺជាការងារប្រចាំថ្ងៃរបស់លោកគ្រូ អហ្គូស្ទីន។ នៅជិតគ្រាចុងក្រោយនៃជីវិតរបស់គាត់ គាត់បានសរសេរចុះនូវសេចក្តីបង្រៀនខុសឆ្គងប្រមាណ ៨០ដែលគាត់បានប្រឆាំង។[៥២] ហេតុអ្វីបានជាគាត់ខិតខំប្រឹងប្រែងការពារយ៉ាងខ្លាំងម្ល៉េះក្នុងទស្សនៈដ៏ជ្រាលជ្រៅរបស់គាត់ក្នុងការប្រាថ្នាចង់បាននូវអំណរក្នុងព្រះជាម្ចាស់យ៉ាងដូច្នេះ? គាត់បានផ្តល់នូវចម្លើយមួយក្នុងសៀវភៅ "ការលន់តួ"៖ "ប្រាកដណាស់ វាគឺជាការពិតដែលថាការបង្ហាញថាមនុស្សម្នាក់បានបង្រៀនអ្វីដែលខុសឆ្គង នោះផ្តល់ជូននូវភាពឧត្តុង្គឧត្តមខ្ពស់ចំពោះសេចក្តីជំនឿគោលៗនៃក្រុមជំនុំរបស់ទ្រង់ [ឱព្រះអម្ចាស់អើយ!] និងគោលការណ៍នៃគោលជំនឿត្រឹមត្រូវ។ ដាច់ខាត! ត្រូវតែមានបក្សពួក ដើម្បីញែកលោហៈធាតុពិតចេញជាទីសម្គាល់ពីអ្វីៗដែលនៅសល់"។

ប៉ុន្តែ មានមូលហេតុជ្រៅជាងនោះទៅទៀតទាក់ទងទៅនឹងការតយុទ្ធជាយូរឆ្នាំរបស់គាត់ជាមួយនឹងពួកភីលេហ្គៀន។ នៅពេលដែលលោក ប៉ូលិនូស៍ (Paulinus) ដែលត្រូវជាមិត្តភក្តិរបស់គាត់បានសួរគាត់អំពីមូលហេតុដែលគាត់ក៏បានបន្តវិនិយោគកម្លាំងរបស់គាត់ជាច្រើនក្នុងជម្លោះនេះជាមួយនឹងពួកភីលេហ្គៀន ហើយសូម្បីតែក្នុងនាមជាបុរសដែលមានវ័យ៧០ឆ្នាំជាងក៏ដោយ ក៏គាត់បានឆ្លើយដូចតទៅ៖ "ជាគោលគឺដោយសារគ្មានប្រធានបទណាផ្សេងទៀត [លើកលែងតែព្រះគុណ] ដែលផ្តល់មកកាន់ខ្ញុំនូវភាពអរសប្បាយលើសនេះនោះទេ។ ដ្បិតតើគួរមានអ្វីផ្សេងទៀតដែលគួរទាក់ទាញចំណាប់

---

៥០ លោកគ្រូ Scott, *Augustine: His Thought in Context*, ទំព័រ២០៨ (Spirit and Letter, V)។

៥១ លោកគ្រូ Scott, *Augustine: His Thought in Context*, ទំព័រ២១១ (ជូនចំពោះលោកគ្រូ សិមភ្លីស៊ីអនុស៍, II, ១)។

៥២ លោកគ្រូ អហ្គូស្ទីន បានសរសេរនៅ "លើសេចក្តីបង្រៀនខុសឆ្គង" *(On Heresies)* ក្នុងអំឡុងឆ្នាំ៤២៨-៤២៩ ហើយវានៅមិនទាន់ចប់ដោយសារគាត់បានទទួលមរណភាព។ ក្នុងសៀវភៅនោះ គាត់បានសរសេរចុះនូវសេចក្តីបង្រៀនខុសឆ្គងប្រមាណ ៨០ ពីលោក ស៊ីម៉ូន ម៉ាហ្គោស (Simon Magus) ជូនទៅកាន់ពួកភីលេហ្គៀន (លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ៣៥-៥៦)។

អារម្មណ៍យើងដែលជាមនុស្សឈឺជាជាងព្រះគុណ ដែលតាមរយៈព្រះគុណ នោះយើងទទួលបានការព្យាបាល យើងដែលជាមនុស្សខ្ជិលជាជាងព្រះគុណ ដែលតាមរយៈព្រះគុណ នោះយើងទទួលបានសេចក្ដីប្រាថ្នាយ៉ាងខ្លាំង យើងដែលជាមនុស្សដែលប្រាថ្នាចង់មានសកម្មភាពជាជាងព្រះគុណ ដែលតាមរយៈព្រះគុណ នោះយើងទទួលបានជំនួយ?»។[៥៣] ចម្លើយមួយនេះនឹងកាន់តែមានអំណាចលើសដើម នៅពេលដែលលោកអ្នករក្សាទុកក្នុងគំនិតថា គ្រប់ការព្យាបាល ការទទួលបានសេចក្ដីប្រាថ្នាយ៉ាងខ្លាំង ការទទួលបានជំនួយ ព្រះគុណដែលបង្កើតសមត្ថភាពដែលលោកគ្រូ អហ្គស្ទីន ធ្វើឲ្យរីករាយជាមួយគឺជា*ការប្រទាននូវអំណរដែលទាក់ទាញអារម្មណ៍ និងធ្វើឲ្យមានជ័យជម្នះ*។ ព្រះគុណគ្រប់គ្រងលើជីវិតតាមរយៈការប្រទានឲ្យនូវអំណរដ៏ឧត្ដុង្គឧត្ដមក្នុងភាពឧត្ដុង្គឧត្ដមរបស់ព្រះជាម្ចាស់។

លោកគ្រូ អហ្គស្ទីន មានការប្ដេជ្ញាចិត្តយ៉ាងខ្លាំងចំពោះទំនួលខុសត្រូវខាងសីលធម៌នៃឆន្ទៈរបស់មនុស្សលោក ទោះបើថាឆន្ទៈទទួលបានការគ្រប់គ្រងទាំងស្រុងតាមរយៈការពេញចិត្តនៃព្រលឹងដែលទទួលបានការរៀបរៀងជាចុងក្រោយតាមរយៈព្រះជាម្ចាស់ក៏ដោយ។ នៅពេលដែលគេបានបង្ខំឲ្យគាត់ពន្យល់ នៅចុងក្រោយគាត់ក៏បានស្ម័គ្រចិត្តដោយពឹងផ្អែកលើព្រះបន្ទូលដែលថា «សេចក្ដីអាថ៌កំបាំងនេះជ្រៅណាស់»។ យើងអាចឃើញចំណុចនេះក្នុងសម្រង់សម្ដីពីរខាងក្រោម៖

«ប្រសិនបើមាននរណាម្នាក់មកបង្ខិតបង្ខំយើងក្នុងការត្រួតពិនិត្យលើសេចក្ដីអាថ៌កំបាំងដ៏ជ្រៅនេះត្រង់ថា ហេតុអ្វីបានជាបុគ្គលម្នាក់ទទួលការបញ្ចុះបញ្ចូលឲ្យចុះចូល ហើយបុគ្គលម្នាក់ទៀតមិនដូច្នោះ នោះមានខគម្ពីរតែពីរដែលផុសឡើងក្នុងគំនិតយើងខ្ញុំដែលយើងខ្ញុំនឹងប្រើប្រាស់ ដើម្បីឆ្លើយចំពោះបុគ្គលនេះ៖ "អើហ្ន៎ប្រាជ្ញា និងចំណេះដ៏បរិបូររបស់ព្រះជ្រៅណាស់!" (រ៉ូម ១១:៣៣) និង "តើព្រះមានសេចក្ដីទុច្ចរិតឬអី?" (រ៉ូម ៩:១៤)។ ប្រសិនបើមានបុគ្គលណាម្នាក់មិនពេញចិត្តជាមួយនឹងចម្លើយបែបនេះ នោះគាត់ត្រូវតែស្វែងរកអ្នកសួរដេញដោលចេះជាងនោះ៖ ប៉ុន្តែសូមឲ្យគាត់ប្រុងប្រយ័ត្នក្រែងលោគាត់រកឃើញអ្នកឥតកោតក្រែង»។[៥៤]

---

៥៣ លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ៣៥៥ (Epistle ១៨៦, XII, ១៣៩)។

៥៤ លោកគ្រូ Scott, *Augustine: His Thought in Context,* ទំព័រ២០៩-២១០ (Spirit and Letter, LX)។

"ដូច្នេះ ចូរឲ្យសេចក្តីពិតនេះនៅជាប់ និងមិនអាចរង្គើបានក្នុងគំនិតដែលបរិសុទ្ធ មឹុងម៉ាត់ និងស្ថិតស្ថេរក្នុងជំនឿត្រង់ថា គ្មានសេចក្តីទុច្ចរិតក្នុងព្រះជាម្ចាស់ទេ។ ចូរឲ្យយើងជឿជាក់ឲ្យរឹងមាំ និងយ៉ាងជាប់លាប់ផងដែរថា ព្រះជាម្ចាស់មានសេចក្តីមេត្តាលើអស់អ្នកដែលទ្រង់នឹងជ្រើសរើស ហើយព្រះអង្គធ្វើឲ្យបុគ្គលណាម្នាក់មានចិត្តរឹងរូសតាមដែលទ្រង់សព្វព្រះហឫទ័យ ដែលនេះមានន័យថាព្រះអង្គមាន ឬក៏មិនមានសេចក្តីមេត្តាលើអ្នកដែលទ្រង់សព្វព្រះហឫទ័យ។ ចូរឲ្យយើងជឿថា ការនេះគឺជាកម្មសិទ្ធិយុត្តិធម៌លាក់កំបាំងដ៏ជាក់លាក់មួយដែលការស្វែងរកតាមរយៈស្តង់ដារនៃការវាស់វែងរបស់មនុស្សមិនអាចឃើញបាន ទោះបើថាយើងអាចសង្កេតមើលលទ្ធផលក្នុងហេតុការណ៍មនុស្សលោក និងការរៀបរៀងលើផែនដីនេះបានក៏ដោយ"។[៥៥]

ចំណុចដែលថា ព្រះគុណគ្រប់គ្រងលើជីវិត តាមរយៈការប្រទានឲ្យនូវអំណរដ៏ឧត្តុង្គឧត្តមក្នុងភាពឧត្តុង្គឧត្តមរបស់ព្រះជាម្ចាស់ នោះក៏ពន្យល់អំពីមូលហេតុដែលថាសេចក្តីបង្រៀនអំពីសេរីភាពរបស់គ្រីស្ទបរិស័ទមានចំណុចខុសគ្នាយ៉ាងខ្លាំងរវាងលោកគ្រូ អហ្គូស្ទីន និងលោកភីលេហ្គៀស៍។ ចំពោះលោកគ្រូ អហ្គូស្ទីន សេរីភាពគឺជាការស្រឡាញ់ព្រះជាម្ចាស់ និងរបៀបរបស់ទ្រង់យ៉ាងខ្លាំងដល់ថ្នាក់ថាហួសពីបទពិសោធន៍នៃកម្រិតជ្រើសរើសផ្ទាល់តែម្តង។ ឧត្តមគតិនៃសេរីភាពគឺមិនមែនជាសេរីភាពឯករាជ្យដែលនៅនឹងនរជាមួយនឹងអធិបតេយ្យភាពលក្ខណៈសោយរាជ្យដោយខ្លួនឯងរវាងល្អ និងអាក្រក់នោះទេ។ ឧត្តមគតិនៃសេរីភាពគឺជាការចេះថ្លឹងថ្លែងខាងវិញ្ញាណយ៉ាងខ្លាំងអំពីភាពសង្ហាររបស់ព្រះជាម្ចាស់ និងការស្រឡាញ់ព្រះជាម្ចាស់យ៉ាងខ្លាំងដល់ថ្នាក់ថាបុគ្គលម្នាក់នឹងមិនឈរជាមួយនឹងការសោយរាជ្យដោយខ្លួនឯងរវាងព្រះជាម្ចាស់ និងជម្រើសណាមួយផ្សេងទៀតនោះឡើយ។ ផ្ទុយទៅវិញ បុគ្គលម្នាក់នឹងបង្ហួសបទពិសោធន៍នៃជម្រើស ហើយបន្តដើរក្រោមឥទ្ធិពលនៃអំណរដ៏ឧត្តុង្គឧត្តមក្នុងព្រះជាម្ចាស់វិញ។ ក្នុងទស្សនៈរបស់លោកគ្រូ អហ្គូស្ទីន បទពិសោធន៍នៃការដឹងខ្លួនដោយខ្លួនឯងទាក់ទងនឹងការគិតគូរអំពីជម្រើសគឺមិនមែនជាចំណុចសម្គាល់នៃសេរីភាពរបស់ឆន្ទៈនោះទេ ប៉ុន្តែគឺជាការបែកបាក់នៃឆន្ទៈទៅវិញទៅតើ។ ការប្រកួតប្រជែងនៃជម្រើសគឺជាអំពើអាក្រក់ដែលចាំបាច់ក្នុងផែនដីដែលបានធ្លាក់ក្នុងអំពើបាបនេះ រហូតដល់ថ្ងៃដែលនឹងមកដល់ដែល

៥៥ លោកគ្រូ Scott, *Augustine: His Thought in Context*, ទំព័រ២១២ (ជូនចំពោះលោកគ្រូ សិមភ្លីស៊ីអន្ទស៍, II, ១៦)។

ពេលនោះជាពេលនៃការវិនិច្ឆ័យ និងការពេញចិត្តមានការរួបរួមគ្នាក្នុងចិត្តយ៉ាងល្អឥតខ្ចោះអំពីអ្វីដែលមានការពេញចិត្តឥតព្រំដែនពោលគឺព្រះ។

ចំណុចបន្តបន្ទាប់នៃទស្សនៈរបស់លោកគ្រូ អហ្គូស្ទីន អំពីព្រះគុណថាជាការប្រទានអំណោយដ៏ឧត្តុង្គឧត្តមដែលយកឈ្នះលើ «សេចក្ដីអំណរទទឹងច្បាប់»[៥៦] គឺត្រង់ថា ជីវិតគ្រីស្ទបរិស័ទទាំងមូលគឺជាការស្វែងរកអំណរយ៉ាងពេញទីឥតឈប់ឈរក្នុងព្រះជាម្ចាស់។ គាត់បានលើកឡើងថា «ជីវិតទាំងមូលនៃគ្រីស្ទបរិស័ទល្អម្នាក់គឺជាការមានសេចក្ដីប្រាថ្នាដែលបរិសុទ្ធ»។[៥៧] បើនិយាយម្យ៉ាងវិញទៀតទៅ គន្លឹះនៃជីវិតរស់នៅជាប្រចាំថ្ងៃរបស់គ្រីស្ទបរិស័ទគឺជាការស្រេកឃ្លានចង់បានព្រះជាម្ចាស់។ ហើយមូលហេតុដ៏ចម្បងមួយដែលមនុស្សជាច្រើននាក់មិនយល់ ឬក៏ដកបទពិសោធន៍ក្នុងអធិបតេយ្យភាពនៃព្រះគុណ និងដំណើរការរបស់វាតាមរយៈការភ្ញាក់ឡើងនៃអំណរដ៏ឧត្តុង្គឧត្តមគឺត្រង់ថា ភាពស្រេកឃ្លានរបស់ពួកគាត់សម្រាប់ព្រះជាម្ចាស់គឺមានលក្ខណៈតូចតាចណាស់។ ការអស់សង្ឃឹមក្នុងការមានភាពរីករាយសម្រាប់ជាប្រយោជន៍នៃការថ្វាយបង្គំ និងភាពបរិសុទ្ធដែលជាការដែលពួកគេយល់មិនបាន។ ខាងក្រោមនេះគឺជាគោលដៅ និងជាបញ្ហាតាមដែលលោកគ្រូ អហ្គូស្ទីន បានសង្កេតមើលឃើញ៖

«ព្រលឹងមនុស្សលោកនឹងសង្ឃឹមឡើងក្រោមស្រមោលនៃចំអេងស្លាបរបស់ព្រះអង្គ។ ពួកគេនឹងស្រវឹងជាមួយនឹងភាពពេញលេញនៃព្រះដំណាក់របស់ទ្រង់។ ហើយចេញពីលំហូរនៃភាពអរសប្បាយរបស់ទ្រង់ នោះព្រះអង្គនឹងប្រទានឲ្យពួកគេបរិភោគ ដ្បិតតើក្នុងព្រះអង្គគឺជាប្រភពនៃជីវិត ហើយក្នុងទ្រង់ក៏ជាពន្លឺដែលយើងនឹងឃើញពន្លឺមែនឬ? សូមមើលបុគ្គលដែលកំពុងតែលង់ស្នេហ៍៖ គាត់ដឹងអំពីអ្វីដែលទូលបង្គំចង់មានន័យ។ សូមមើលបុគ្គលដែលកំពុងតែចង់បាន សូមមើលបុគ្គលដែលកំពុងតែស្រេកឃ្លាន សូមមើលបុគ្គលដែលកំពុងតែនៅយ៉ាងឆ្ងាយក្នុងទីរហោស្ថាន ដែលគាត់កំពុងតែស្រេកទឹក ហើយដកដង្ហើមធំៗដោយចង់បានក្បាលទឹកពីប្រទេសដ៏នៅអស់កល្បជានិច្ច។ សូម

---

[៥៦] លោកគ្រូ អហ្គូស្ទីន, *«ការលន់តួ»*។ «ព្រះអង្គតែងតែមានព្រះវត្តមាន ពេញទៅដោយសេចក្ដីក្រោធ ប៉ុន្តែក៏មានសេចក្ដីមេត្តាក្នុងពេលតែមួយដែរ ដោយគ្រប់ដណ្ដប់លើការឈឺចាប់នៃភាពល្វីងជូរចត់លើរាល់ភាពអរសប្បាយល្មើសច្បាប់របស់ទូលបង្គំក្នុងការនាំទូលបង្គំទៅរកមើលអ្នកដទៃដែលមិនបរិសុទ្ធក្នុងការឈឺចាប់។ ឱព្រះអម្ចាស់អើយ! ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យទូលបង្គំរកវាឃើញនៅកន្លែងណាមួយក្រៅពីក្នុងទ្រង់ផ្ទាល់នោះទេ ដ្បិតព្រះអង្គបង្រៀនយើងតាមរយៈការធ្វើឲ្យឈឺចាប់ ព្រះអង្គវាយយើងយ៉ាងខ្លាំង ដើម្បីឲ្យទ្រង់អាចព្យាបាល ហើយព្រះអង្គសម្លាប់យើង ដើម្បីកុំឲ្យយើងទំនងជាស្លាប់ដោយដាច់ចេញពីទ្រង់»។

[៥៧] លោកគ្រូ Hand, *Augustine on Prayer*, ទំព័រ២០ (អភិប្រាយកណ្ឌគម្ពីរ ១យ៉ូហាន ៤:៦)។

មើលបុគ្គលបែបនោះ៖ គាត់ដឹងអំពីអ្វីដែលទូលបង្គំចង់មានន័យ។ ប៉ុន្តែ ប្រសិនបើទូលបង្គំនិយាយទៅកាន់មនុស្សដែលមានចិត្តត្រជាក់ នោះគាត់មិនដឹងអំពីអ្វីដែលទូលបង្គំកំពុងតែនិយាយអំពីនោះទេ...»។[៥៨]

ពាក្យពេចន៍ទាំងនេះពីលោកគ្រូ អហ្គូស្ទីន គួរធ្វើឲ្យចិត្តយើងឆេះឆួលដោយមានការប្រាថ្នាចង់បានព្រះជាម្ចាស់ជាថ្មី។ ហើយវាក៏គួរជួយឲ្យយើងឃើញអំពីមូលហេតុនៃការបង្ហាញសេរីល្អនៃដំណឹងល្អទៅកាន់មនុស្សម្នាគឺពិបាកណាស់។ មូលហេតុគឺដោយសារមនុស្សជាច្រើនមិនប្រាថ្នាចង់បានអ្វីប៉ុន្មានទេ។ ពួកគេមិនសូវប្រឹងប្រែងប៉ុន្មានទេ ហើយក៏ចេះតែទៅតាមតែដំណើរប៉ុណ្ណោះ។ ពួកគេមិនមានភាពឆេះឆួលអំពីអ្វីសោះ។ ពួកគេមិនគ្រាន់តែមាន «ភាពត្រជាក់» ចំពោះសិរីល្អរបស់ព្រះគ្រីស្ទក្នុងដំណឹងល្អប៉ុណ្ណោះនោះទេ ប៉ុន្តែក៏ថែមទាំងមានលើគ្រប់អ្វីៗទាំងអស់ផងដែរ។ សូម្បីទាំងអំពើបាបរបស់ពួកគេ ក៏ពួកគេបានធ្វើលំៗជាជាងធ្វើយ៉ាងអស់ពីចិត្ត។

## តួនាទីនៃការអធិស្ឋានក្នុងការសង្វាតដេញតាមអំណរ

ប្រាកដណាស់! ថ្នាំព្យាបាលពីខាងព្រះជាម្ចាស់សម្រាប់កាលៈទេសៈនៃ «ភាពត្រជាក់» នេះ គឺជាការដាស់ដោយព្រះគុណនៃអំណរដ៏ឧត្តុង្គឧត្តម។ ប៉ុន្តែ ពីខាងមនុស្ស ការអធិស្ឋាន និងការដែលព្រះជាម្ចាស់បើកសម្តែងរូបអង្គទ្រង់ផ្ទាល់ក្នុងលក្ខណៈដែលថាទ្រង់គួរឲ្យប្រាថ្នាចង់បានលើសជាងអ្វីៗទាំងអស់ក្នុងចំណោមរបស់សព្វសារពើ។ អក្សរសាស្ត្រនៃរបៀបសរសេរសៀវភៅ «ការលន់តួ» ដែលមានប្រមាណជា៣៥០ទំព័រ គឺមិនមែនគ្រាន់តែជាយុទ្ធសាស្ត្រនៃការអធិស្ឋានប៉ុណ្ណោះនោះទេ។ គ្រប់ឃ្លាឃ្លោងគឺជាការទូលទៅកាន់ព្រះជាម្ចាស់។ នេះគឺពិតជាគួរឲ្យភ្ញាក់ផ្អើលមែន។ វាទំនងជាបានទាមទារឲ្យមានការគ្រប់គ្រងខ្លួនឯងយ៉ាងតឹងតែង ដើម្បីឲ្យលោកគ្រូ អហ្គូស្ទីន សរសេរដោយប្រើប្រាស់តែទម្រង់នៃការអធិស្ឋានសម្រាប់សៀវភៅទាំងមូលដោយមិនដែលប្រើប្រាស់ទម្រង់ណាផ្សេងទៀត។ មូលហេតុនៃការគ្រប់គ្រងខ្លួនឯងយ៉ាងតឹងតែងបែបនេះគឺថាលោកគ្រូ អហ្គូស្ទីន មានការពឹងផ្អែកទាំងស្រុងលើព្រះជាម្ចាស់សម្រាប់ការដាស់ឲ្យស្រឡាញ់ព្រះជាម្ចាស់។ ហើយវាក៏

---

៥៨ លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ៣៧៤-៣៧៥ (*"Tractatus in Joannis evangelium"*, ២៦, ៤)។

មិនមែនជារឿងចៃដន្យដែរ ដែលសេចក្តីអធិស្ឋានរបស់លោកស្រី ម៉ូនីកា ដែលត្រូវជាអ្នកម្តាយរបស់លោកគ្រូ អហ្គូស្ទីន បានសាយភាយពាសពេញសៀវភៅ «ការលន់តួ» នោះដែរ។ លោកស្រីបានអង្វរករទៅកាន់ព្រះជាម្ចាស់សម្រាប់គាត់ ខណៈពេលដែលលោកគ្រូ អហ្គូស្ទីន មិនបានអង្វរករសម្រាប់ខ្លួនឯង។[៥៩]

លោកគ្រូ អហ្គូស្ទីន ផ្តល់ការប្រឹក្សាដល់យើងដូចតទៅ «ចូរនិយាយដូចអ្នកនិពន្ធទំនុកៈ "ខ្ញុំបានសូមសេចក្តីតែមួយពីព្រះយេហូវ៉ា ហើយនឹងស្វែងរកសេចក្តីនោះឯង គឺឲ្យខ្ញុំបាននៅក្នុងដំណាក់របស់ព្រះយេហូវ៉ារាល់តែថ្ងៃអស់មួយជីវិតរបស់ខ្ញុំ ដើម្បីរំពឹងមើលសោភ័ណភាពរបស់ព្រះយេហូវ៉ា ហើយពិនិត្យពិចារណានៅក្នុងព្រះវិហាររបស់ព្រះអង្គ"» (ទំនុកតម្កើង ២៧:៤ គកស)។ បន្ទាប់មក គាត់បានលើកឡើងថា «ព្រះអង្គដែលជាជីវិតដ៏ពិត និងពេញដោយព្រះពរបានបង្រៀនយើងឲ្យអធិស្ឋាន ដើម្បីឲ្យយើងអាចទទួលជីវិតដ៏សប្បាយនេះបាន»។[៦០] លោកគ្រូ អហ្គូស្ទីន បង្ហាញយើងអំពីរបៀបដែលគាត់បានអធិស្ឋានសម្រាប់អំណរដែលមានជ័យជម្នះក្នុងព្រះជាម្ចាស់៖ «ឱព្រះអម្ចាស់អើយ! ដើម្បីឲ្យទូលបង្គំអាចស្រឡាញ់ទ្រង់ [យ៉ាងសេរី] ដ្បិតទូលបង្គំមិនអាចរកឃើញនូវអ្វីណាផ្សេងទៀតដែលមានតម្លៃលើសនេះនោះទេ សូមកុំបែរព្រះភ័ក្ត្ររបស់ទ្រង់ពីទូលបង្គំឡើយ ដើម្បីឲ្យទូលបង្គំអាចរកឃើញនូវអ្វីដែលទូលបង្គំកំពុងតែស្វែងរក។ សូមកុំបែរចេញពីអ្នកបម្រើរបស់ទ្រង់ក្នុងសេចក្តីក្រោធ ក្រែងលោក្នុងការស្វែងរកព្រះអង្គ នោះទូលបង្គំរត់ទៅកាន់អ្វីមួយផ្សេងទៀត....សូមធ្វើជាអ្នកជំនួយទូលបង្គំ។ ឱព្រះដ៏ជាព្រះអង្គសង្គ្រោះនៃទូលបង្គំអើយ! សូមកុំចាកចេញពីទូលបង្គំ ឬក៏ស្អប់ទូលបង្គំ»។[៦១]

ការអធិស្ឋានរបស់អ្នកម្តាយគាត់បានក្លាយជាសាលារៀនដែលគាត់បានរៀនអំពីចំណុចដ៏ជ្រៅៗជាច្រើនអំពីព្រះបន្ទូលរបស់ព្រះយេស៊ូវក្នុងកណ្ឌគម្ពីរ យ៉ូហាន ១៦:២៤ «មកទល់ពេលនេះ អ្នករាល់គ្នាមិនបានទូលសូមអ្វីក្នុងនាមខ្ញុំទេ។ ចូរទូលសូមចុះ អ្នករាល់គ្នានឹងបានទទួល ដើម្បីឲ្យអំណររបស់អ្នករាល់គ្នាបានពោរពេញ» (គកស)។ ការអធិស្ឋានគឺជាវិថីទៅកាន់ភាពពេញលេញខាងឯអំណរដ៏ឧត្តុង្គឧត្តម។ ប៉ុន្តែ វិថីនេះពិតជាចម្លែក ហើយក៏ជាដំណើរប្រយោលមួយដែរ! លោកស្រី ម៉ូនីកា បានរៀនចេះអត់ធ្មត់ក្នុងការ

---

៥៩ សូមមើលការកត់សម្គាល់ក្នុងលេខ ៦៧, ៦៩, ៧០។

៦០ លោកគ្រូ Hand, *Augustine on Prayer*, ទំព័រ២៥ (សំបុត្រលេខ #១៣០, ១៥)។

៦១ ក្នុងសៀវភៅដដែល, ទំព័រ២៧។

ឈើចាប់នៃសេចក្តីអធិស្ឋាន ដែលមិនមានការឆ្លើយតបអស់ជាច្រើនឆ្នាំ។ ឧទាហរណ៍ៈ លោក ផាទ្រីស៊ីអូស៍ ដែលជាប្តីរបស់គាត់ មិនមានភាពស្មោះត្រង់ជាមួយនឹងគាត់ឡើយ។ ប៉ុន្តែ លោកគ្រូ អហ្គស្ទីន បានលើកឡើងក្នុងសៀវភៅ "ការលន់តួ" ថា "គាត់ទ្រាំទ្រដោយមានការអត់ធ្មត់ទាក់ទងនឹងអំពើផិតក្បត់របស់ប្តីគាត់ ហើយក៏មិនដែលទាស់ប្រឆាំងឈ្លោះប្រកែកជាមួយគាត់អំពីប្រធានបទនេះទៀតផង។ គាត់បន្តរង់ចាំសេចក្តីមេត្តាករុណារបស់ព្រះអង្គលើប្តីរបស់គាត់រហូតដល់គាត់ទំនងជានឹងក្លាយជាមនុស្សបរិសុទ្ធតាមរយៈជំនឿលើព្រះអង្គ....នៅទីបំផុត ខណៈពេលដែលប្តីរបស់គាត់ឈានដល់គ្រាចុងក្រោយនៃពេលវេលាលើផែនដីនេះ គាត់ក៏បានយកឈ្នះលើប្តីរបស់គាត់សម្រាប់ព្រះអង្គ"។[៦២]

ហើយការដូចនេះក៏នឹងកើតឡើងចំពោះកូនប្រុសរបស់គាត់ដែរ។ គាត់ "បានយំច្រើនជាងសម្រាប់ការស្លាប់ខាងឯព្រលឹងវិញ្ញាណរបស់ទូលបង្គំ" លោកគ្រូ អហ្គស្ទីន បានលើកឡើង "ច្រើនជាងម្តាយផ្សេងៗទៀតបានយំសម្រាប់ការស្លាប់ខាងឯសាច់ឈាមរបស់កូនខ្លួនទៅទៀត"។ កាលកូនប្រុសរបស់គាត់ដើរជាមួយពួកមានិហ្គៀនដែលជាពួកខុសឆ្គង នោះលោកស្រី ម៉ូនីកា ក៏បានទៅរកគ្រូគង្វាលវ័យចំណាស់ម្នាក់មកជួយ។ ការប្រឹក្សារបស់លោកគ្រូគឺមិនមែនជាអ្វីដែលលោកស្រី ម៉ូនីកា ចង់ឮនោះទេ៖ គាត់ក៏ធ្លាប់ជាបុគ្គលម្នាក់ក្នុងក្រុមពួកមានិហ្គៀនដែរ ប៉ុន្តែបានឃើញភាពល្ងីល្ងើរបស់ខ្លួន។ "ទុកគាត់តែឯងសិនទៅ" លោកគ្រូនោះបានលើកឡើង "គ្រាន់តែអធិស្ឋានទៅកាន់ព្រះជាម្ចាស់សម្រាប់គាត់បានហើយ។ តាមរយៈការអានដោយខ្លួនឯង នោះគាត់នឹងឃើញកំហុសខុសឆ្គងរបស់ខ្លួន ហើយនឹងឃើញពីភាពស្អប់ខ្ពើមដ៏ខ្លាំងក្លារបស់ព្រះជាម្ចាស់....សូមចេញទៅ! ខណៈពេលដែលនាងបន្តរស់នៅ វាមិនអាចទៅរួចបានទេដែលកូនប្រុសនៃអ្នកម្តាយដែលបង្ហូរទឹកភ្នែកដូចឯងនឹងវិនាស"។[៦៣]

នៅឆ្នាំ៣៧១នៃគ.ស. កាលគាត់មានអាយុ១៦ឆ្នាំ មិនយូរប៉ុន្មានបន្ទាប់ពីឪពុករបស់គាត់បានទទួលមរណភាព នោះលោកគ្រូ អហ្គស្ទីន បានលួចរត់ចេញពីម្តាយរបស់គាត់ទៅឯទីក្រុងកាតធេ ហើយបានឡើងនាវាទៅទីក្រុងរ៉ូម។ "នាពេលយប់នោះ ទូលបង្គំលួចចេញស្ងៀមស្ងាត់ តែគាត់នៅបន្តអធិស្ឋាន និងយំ"។[៦៤] តើសេចក្តីអធិស្ឋានទាំងនោះ

៦២ លោកគ្រូ អហ្គស្ទីន, *"ការលន់តួ"*, ទំព័រ២៤០។
៦៣ ក្នុងសៀវភៅដដែល, ទំព័រ៩០-៩១។
៦៤ ក្នុងសៀវភៅដដែល, ទំព័រ១៣៥។

ទទួលបានការឆ្លើយតបដោយរបៀបណា? មិនមែនក្នុងរបៀបដែលលោកស្រី ម៉ូនីកា បានសង្ឃឹមនៅពេលនោះទេ។ មានតែនៅពេលក្រោយប៉ុណ្ណោះដែលគាត់បានឃើញសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះយេស៊ូវបានធ្វើការក្នុងជីវិតរបស់គាត់—ត្រង់ថាការអធិស្ឋានគឺជាវិថីទៅកាន់អំណរដ៏ជ្រាលជ្រៅបំផុត។ «ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! ហើយថាតើអ្នកម្តាយទូលបង្គំបានទូលសូមអ្វីខ្លះពីទ្រង់ ជាមួយនឹងទឹកភ្នែកទាំងអស់នោះ ក្រៅពីការដែលទូលសូមព្រះអង្គឲ្យរារាំងទូលបង្គំពីការចុះនាវា? ប៉ុន្តែ ព្រះអង្គមិនបានឆ្លើយតបតាមអ្វីដែលគាត់បានទូលសូមពីទ្រង់នោះទេ។ ប្រាកដណាស់! ក្នុងជម្រៅនៃព្រះប្រាជ្ញាញាណរបស់ទ្រង់ ព្រះអង្គបានប្រទានសេចក្តីប្រាថ្នាដែលកៀកបំផុតក្នុងដួងចិត្តរបស់គាត់។ ព្រះអង្គបានប្រព្រឹត្តមកកាន់ទូលបង្គំនូវអ្វីដែលគាត់តែងតែទទូចសូមឲ្យទ្រង់ធ្វើ»។

ក្រោយមកទៀត បន្ទាប់ពីការសន្ទនារបស់គាត់ នោះគាត់ក៏បានទៅប្រាប់អ្នកម្តាយរបស់គាត់អំពីអ្វីដែលព្រះជាម្ចាស់បានធ្វើក្នុងការឆ្លើយតបសេចក្តីអធិស្ឋានរបស់គាត់៖

«បន្ទាប់មក យើងក៏នាំគ្នាទៅជួបអ្នកម្តាយរបស់ទូលបង្គំ ហើយបានប្រាប់គាត់អំពីអ្វីដែលបានកើតឡើង។ គាត់ក៏មានពេញទៅដោយអំណរ។ យើងបានប្រាប់គាត់អំពីរបៀបដែលវាបានកើតឡើង។ គាត់បានលោតឡើងដែលមានពេញទៅដោយអំណរដែលមានជ័យជម្នះ ហើយក៏បានថ្លែងការអរព្រះគុណទៅកាន់ព្រះអង្គដែរ។ តាមរយៈការមានប្រសាសន៍ថាព្រះអង្គ "អាចនឹងធ្វើហួសសន្ធឹក លើសជាងអ្វីៗដែលយើងសូម ឬគិត ដោយព្រះចេស្តាដែលធ្វើការនៅក្នុងយើង"។[៦៥] ដ្បិតគាត់ឃើញថា ព្រះអង្គបានប្រទានទៅកាន់គាត់លើសជាងអ្វីដែលគាត់បានទទូចសូមក្នុងរាល់ចំណុចដែលគួរឲ្យអាណិតអាសូរ និងការកាន់ទុក្ខដែលបានធ្លាក់ចុះ។ ព្រះអង្គបាននាំឲ្យទូលបង្គំទទួលជឿ ដើម្បីកុំឲ្យទូលបង្គំស្វែងរកប្រពន្ធ ឬក៏ក្តីសង្ឃឹមរបស់លោកីយ៍នេះណាផ្សេងទៀត។ ប៉ុន្តែ ព្រះអង្គបានដាក់ជើងរបស់ទូលបង្គំយ៉ាងមាំលើខ្សែរង្វាស់នៃជំនឿ ដែលទ្រង់បានបើកសម្តែងទៅកាន់អ្នកម្តាយទូលបង្គំជាច្រើនឆ្នាំមុននោះក្នុងការសុបិនរបស់គាត់អំពីទូលបង្គំ។ ហើយព្រះអង្គបានបង្វែរទុក្ខព្រួយរបស់គាត់ឲ្យក្លាយទៅជាអំណរច្រើនជាងគាត់អាចហ៊ានសង្ឃឹមថានឹងមានបានទៅទៀត។ អំណរដែលជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ និងបរិសុទ្ធលើសជាង

៦៥ អេភេសូរ ៣:២០។

គាត់ធ្លាប់ប្រាថ្នាថាគាត់នឹងមានពីមុនៗតាមរយៈកូនចៅរបស់ទូលបង្គំ»។[៦៦]

នោះគឺជាមេរៀនដែលលោកគ្រូ អហ្គស្ទីន បានរៀនចេញពីភាពឥតស្រាកស្រាន្តក្នុងស្ថានភាពពិបាកនៃសេចក្ដីអធិស្ឋានរបស់អ្នកម្ដាយរបស់គាត់។ មិនមែនជាអ្វីដែលគាត់បានគិតថាគាត់ចង់បានក្នុងពេលខ្លីនោះទេ ប៉ុន្តែជាអ្វីដែលគាត់ប្រាថ្នាចង់បានយ៉ាងខ្លាំងបំផុតក្នុងពេលយូរអង្វែង—ព្រះជាម្ចាស់បានប្រទានទៅកាន់គាត់នូវ «អំណរដ៏ពេញខ្លាំងជាងអ្វីដែលគាត់ធ្លាប់ប្រាថ្នាចង់បានយ៉ាងខ្លាំង»។ «ចូរទូលសូមចុះ អ្នករាល់គ្នានឹងបានទទួល ដើម្បីឲ្យអំណររបស់អ្នករាល់គ្នាបានពោរពេញ» (យ៉ូហាន ១៦:២៤)។

## ការបង្ហាញការពេញចិត្តយ៉ាងខ្ពង់ខ្ពស់នៃការស្គាល់ព្រះជាម្ចាស់

ប៉ុន្តែ អមជាមួយនឹងការអធិស្ឋាន ថ្នាំមួយទៀតពីមនុស្សដែលគ្មានការឆេះឆួល និងគ្មានការស្រេកឃ្លានសម្រាប់ព្រះជាម្ចាស់គឺការបង្ហាញអំពីព្រះជាម្ចាស់ផ្ទាល់ថាទ្រង់គួរឲ្យប្រាថ្នាចង់បានឥតព្រំដែន—និងគួរឲ្យមានការស្កប់ស្កល់ចិត្ត—លើសរបស់សព្វសារពើទាំងអស់។ ភាពឆេះឆួលរបស់លោកគ្រូ អហ្គស្ទីន សម្រាប់ព្រលឹងមនុស្សប្រុសមនុស្សស្រីគឺថាឲ្យពួកគេរកឃើញភាពសង្ហាររបស់ព្រះជាម្ចាស់ ហើយស្រឡាញ់ទ្រង់។ «ប្រសិនបើការពេញចិត្តរបស់លោកអ្នកគឺក្នុងព្រលឹង នោះចូរស្រឡាញ់ពួកគេក្នុងព្រះជាម្ចាស់ចុះ... ហើយនាំឲ្យបានច្រើនតាមដែលលោកអ្នកអាចធ្វើបានជាមួយនឹងលោកអ្នកទៅកាន់ព្រះអង្គចុះ»។ «[ឱព្រះជាម្ចាស់អើយ!] ដ្បិតព្រះអង្គផ្ទាល់ហើយដែលជាអំណររបស់ពួកគេ។ ការមានអំណរក្នុងព្រះអង្គ សម្រាប់ព្រះអង្គ និងដោយសារព្រះអង្គគឺជាភាពអរសប្បាយ។ នេះគឺជាការអរសប្បាយដ៏ពិត ហើយក៏គ្មានអ្វីផ្សេងទៀតដែរ»។

ដូច្នេះ លោកគ្រូ អហ្គស្ទីន ក៏បានខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាពរបស់គាត់ខាងឯព្រលឹងវិញ្ញាណ អក្សរសាស្ត្រ និងប្រាជ្ញា ដើម្បីជួយឲ្យមនុស្សឃើញហើយស្គាល់អំពីភាពឧត្តុង្គឧត្តមរបស់ព្រះជាម្ចាស់ ដែលផ្ដល់នូវការស្កប់ស្កល់ចិត្តលើសគេទាំងអស់លើរាល់គ្រប់អ្វីៗ។

៦៦ លោកគ្រូ អហ្គស្ទីន, «ការលន់តួ», ទំព័រ២១៩។

“ប៉ុន្តែ តើអ្វីទៅដែលទូលបង្គំស្រឡាញ់អំពីការស្រឡាញ់ព្រះអង្គ?...មិនមែនភាពពីរោះផ្អែមល្ហែមនៃបទចម្រៀងដែលមានច្រើនប្រភេទ ហើយក៏មិនមែនភាពក្រអូបនៃផ្កា ក្រមួន និងគ្រឿងទេស មិនមែននំម៉ាណា និងទឹកឃ្មុំ ឬក៏ដៃជើងដែលឱបគ្នាក្នុងការស្រឡាញ់ខាងឯសាច់ឈាមដែរ—ទាំងនេះគឺមិនមែនជាអ្វីដែលទូលបង្គំស្រឡាញ់ ពេលដែលទូលបង្គំស្រឡាញ់ព្រះជាម្ចាស់របស់ទូលបង្គំទេ។ ទោះជាយ៉ាងណាក្តី ពិតណាស់ទូលបង្គំក៏ស្រឡាញ់ប្រភេទនៃពន្លឺមួយចំនួន និងសំឡេង និងក្លិនក្រអូប និងម្ហូប ហើយក៏ឱបក្រសោបក្នុងការស្រឡាញ់ព្រះជាម្ចាស់របស់ទូលបង្គំដែរ ព្រះអង្គគឺជាពន្លឺ សំឡេង ក្លិន ម្ហូប និងការឱបក្រសោបនៃភាពជាមនុស្សខាងក្នុងរបស់ទូលបង្គំ—ដែលជាទីកន្លែងនៃពន្លឺនោះបានចែងចាំងក្នុងព្រលឹងរបស់ទូលបង្គំដែលគ្មានកន្លែងណាផ្សេងអាចផ្ទុកបាន ជាកន្លែងដែលពេលវេលាមិនអាចឆក់យកសំឡេងដែលគួរឲ្យស្រឡាញ់បាន ជាកន្លែងដែលគ្មានខ្យល់អាចបក់ក្លិនក្រអូបឲ្យរសាត់បាន ជាកន្លែងដែលការបរិភោគមិនអាចបន្ថយម្ហូបដែលផ្គត់ផ្គង់ចុះបាន និងជាកន្លែងដែលការឱបក្រសោបមិនអាចមានភាពឆ្អែតឆ្អន់ក្នុងការញែកបំបែកបាន។ នេះគឺជាអ្វីដែលទូលបង្គំស្រឡាញ់ ជាពេលដែលទូលបង្គំស្រឡាញ់ព្រះជាម្ចាស់របស់ទូលបង្គំ”។[៦៧]

មានមនុស្សតិចនាក់ណាស់ក្នុងប្រវត្តិសាស្ត្រនៃក្រុមជំនុំដែលបានពណ៌នាអំពីភាពឧត្តុង្គឧត្តម ភាពសង្ហារ និងការប្រាថ្នាចង់បានព្រះជាម្ចាស់លើសជាងការពណ៌នារបស់លោកគ្រូ អហ្គូស្ទីន។ គាត់បានទទួលការបញ្ចុះបញ្ចូលទាំងស្រុងតាមរយៈព្រះបន្ទូល និងបទពិសោធន៍ត្រង់ថា “បុគ្គលដែលអរសប្បាយគឺជាបុគ្គលដែលមានព្រះជាម្ចាស់ជាកម្មសិទ្ធិ”។[៦៨] “ព្រះអង្គបានបង្កើតយើងសម្រាប់ទ្រង់ផ្ទាល់ ហើយចិត្តរបស់យើងក៏មិនអាចសម្រាកបាន លុះត្រាតែចិត្តរបស់យើងរកឃើញការសម្រាកនៅក្នុងទ្រង់សិន”។[៦៩] គាត់នឹងខិតខំព្យាយាមប្រឹងប្រែងអស់ពីសមត្ថភាពរបស់គាត់ឲ្យគេស្គាល់ និងស្រឡាញ់ព្រះនៃអធិបតេយ្យភាពដែលពេញដោយព្រះគុណនេះ និងអំណារដ៏ឧត្តុង្គឧត្តមលើផែនដីនេះ។

“ព្រះអង្គនឹងនរ ប៉ុន្តែមិនត្រូវការការគាំទ្រទេ....ព្រះអង្គតែងតែប្រមូលទុក ប៉ុន្តែទ្រង់មិនមានតម្រូវការអ្វីទេ....ព្រះអង្គកាន់ទុក្ខសម្រាប់អំពើខុស ប៉ុន្តែមិនមានការឈឺចាប់ឡើយ។

---

៦៧ ក្នុងសៀវភៅដដែល, ទំព័រ២៥៧។

៦៨ លោកគ្រូ Hand, *Augustine on Prayer*, ទំព័រ១៧ (“លើជីវិតដ៏អរសប្បាយ” *(On the Happy Life)*, ១១)។

៦៩ លោកគ្រូ អហ្គូស្ទីន, *“ការលន់តួ”*, ទំព័រ៤៧, ទំព័រ៥៤។

ព្រះអង្គមានសេចក្តីក្រោធ ប៉ុន្តែក៏គង់នៅយ៉ាងក្សេមក្សាន្តដែរ។ ព្រះអង្គផ្លាស់ប្តូរផ្លូវ ប៉ុន្តែទ្រង់មិនផ្លាស់ប្តូរផែនការទេ....ព្រះអង្គស្វាគមន៍អស់អ្នកដែលមករកទ្រង់ ប៉ុន្តែទ្រង់មិនដែលធ្លាប់បាត់ពួកគាត់ឡើយ។ ព្រះអង្គមិនដែលត្រូវការអ្វីទេ ប៉ុន្តែទ្រង់ក៏មានអំណរក្នុងការទទួលបានផងដែរ។ ទ្រង់មិនចេះលោភលន់ ប៉ុន្តែទ្រង់ទាមទារភាគរយចំណេញនៃភាគហ៊ុន....នៅពេលដែលព្រះអង្គលុបបំណុលណាមួយចោល ទ្រង់ក៏មិនបានបាត់បង់អ្វីសោះដែរ។ ឱព្រះដ៏ជាម្ចាស់នៃជីវិត និងជាអំណរដ៏បរិសុទ្ធរបស់ទូលបង្គំអើយ! តើទូលបង្គំបាននិយាយអំពីអ្វីទៅហ្ន៎? តើឲ្យមនុស្សដែលតែងនឹងស្លាប់អាចនិយាយបានអ្វីខ្លះអំពីព្រះអង្គ? ប៉ុន្តែ វេទនាហើយដល់អស់អ្នកណាដែលមិននិយាយអំពីព្រះអង្គ»។[៧០]

លោកគ្រូ អហ្គូស្ទីន គឺជាគ្រូគង្វាលដែលមានភាពឆេះឆួលក្នុងការមិននៅ «ស្ងៀម» អំពីការអរសប្បាយដែលស្កប់ស្កល់ជាងគេបង្អស់នៅឯព្រះហស្តខាងស្តាំរបស់ព្រះជាម្ចាស់! «តើឲ្យមនុស្សដែលតែងនឹងស្លាប់អាចនិយាយបានអ្វីខ្លះអំពីព្រះអង្គ?»។ គាត់បានពន្យល់ទៅកាន់សមាជិកក្រុមជំនុំរបស់គាត់អំពីរបៀបដែលគាត់ទទួលបានការអធិប្បាយរបស់គាត់៖ «ខ្ញុំផ្គត់ផ្គង់ដល់ខ្លួនឯង ដើម្បីឲ្យខ្ញុំអាចផ្តល់ជូនដល់បងប្អូនឲ្យអាចបរិភោគបានដែរ។ ខ្ញុំគឺជាអ្នកបម្រើ ជាអ្នកយកម្ហូបមក មិនមែនជាចៅហ្វាយផ្ទះនោះទេ។ ខ្ញុំដាក់នូវអ្វីនៅមុខលោកអ្នកដែលខ្ញុំក៏ទទួលបានសម្រាប់ជីវិតខ្លួនឯងដែរ»។[៧១] នេះគឺជារបៀបសិក្សារបស់គាត់៖ គាត់ស្វែងរកម្ហូបអាហារខាងឯព្រលឹងវិញ្ញាណ ដើម្បីឲ្យគាត់អាចផ្គត់ផ្គង់ដល់ខ្លួនឯងពី «ការពេញចិត្តដ៏បរិសុទ្ធ» របស់ព្រះជាម្ចាស់ ហើយបន្ទាប់មកផ្គត់ផ្គង់ក្រុមជំនុំរបស់គាត់។

សូម្បីតែក្នុងសមត្ថភាពរបស់គាត់—និងសមត្ថភាពរបស់អ្នកស្តាប់គាត់—ក្នុងការយល់សេចក្តីពិតនៃព្រះបន្ទូលក៏ទទួលបានការគ្រប់គ្រងមួយផ្នែកតាមរយៈការពេញចិត្តដែលគាត់មានក្នុងអ្វីដែលគាត់បានរកឃើញនៅទីនោះដែរ។ គាត់តែងតែប្រាប់អ្នកអានថា ដាច់ខាតពួកគាត់ត្រូវតែ «មើលក្នុងព្រះបន្ទូល [ជាមួយនឹង] ភ្នែកនៃដួងចិត្តរបស់ពួកគេលើចំណុចស្នូលនៃព្រះបន្ទូល»។ នេះមានន័យថា បុគ្គលម្នាក់ត្រូវតែមើលដោយមានសេចក្តីស្រឡាញ់លើអ្វីដែលគាត់គ្រាន់តែអាចមើលឃើញបានតែមួយផ្នែក៖ «វាមិនអាចទៅរួច

៧០ ក្នុងសៀវភៅដដែល, ទំព័រ៥៥។

៧១ លោកគ្រូ Brown, *Augustine of Hippo,* ទំព័រ២៥២ (Epistle ៧៣, II, ៥)។

បានទេក្នុងការស្រឡាញ់នូវអ្វីដែលយើងមិនអាចស្គាល់បានទាល់តែសោះ ប៉ុន្តែនៅពេលដែលយើងស្រឡាញ់អ្វីមួយនោះដែលយើងបានស្គាល់ ទោះបើថាក្នុងលក្ខណៈយ៉ាងតិចតួចបំផុតក៏ដោយ នោះសមត្ថភាពដ៏តូចតាចនោះផ្ទាល់ក្នុងការស្រឡាញ់ធ្វើឲ្យវាល្អប្រសើរ ហើយក៏កាន់តែឲ្យស្គាល់យ៉ាងពេញទីជាងមុនផងដែរ»។[៧២] បើនិយាយម្យ៉ាងវិញទៀតទៅ ការស្រឡាញ់ ឬក៏ការពេញចិត្តក្នុងអ្វីដែលយើងស្គាល់អំពីព្រះជាម្ចាស់ក្នុងព្រះបន្ទូលនឹងក្លាយជាគន្លឹះដែលបើកបង្ហាញព្រះបន្ទូលជាងមុន។ ដូច្នេះ សម្រាប់លោកគ្រូ អហ្គូស្ទីន ការសិក្សា និងការអធិប្បាយគឺមិនមែនជាការនៅដាច់តែឯង ឬការមិនមានលម្អៀងនោះទេ ដូចជាការសិក្សាមួយចំនួននេះដែលជាទូទៅគេយល់ឃើញសព្វថ្ងៃនេះឡើយ។

គាត់បានពន្យល់ទៅកាន់លោកគ្រូ ជេរ៉ូម ដែលជាអ្នកប្រាជ្ញខាងឯព្រះគម្ពីរដ៏ឆ្នើមម្នាក់ថា ដូច្នេះគាត់មិនអាចធ្វើជាអ្នកប្រាជ្ញដែល «លែងចាប់អារម្មណ៍» បាននោះទេ ពីព្រោះ «ប្រសិនបើខ្ញុំទទួលបានចំណេះដឹងណាមួយ [ក្នុងព្រះបន្ទូល] ភ្លាមៗនោះខ្ញុំត្រូវតែប្រគល់ជូនដល់រាស្ត្ររបស់ព្រះជាម្ចាស់»។[៧៣] ហើយតើគាត់បានបង្ហាញ និងផ្តត់ផ្គង់អ្វីដល់ពួកគេ? គឺអំណរផ្ទាល់ដែលគាត់បានរកឃើញក្នុងព្រះជាម្ចាស់៖ «គំនិតនៃពាក្យពេចន៍របស់យើងនឹងផុសចេញតាមរយៈអំណរដែលយើងមានក្នុងអ្វីដែលយើងកំពុងតែនិយាយជាមិនខាន»។[៧៤] នោះគឺជាគន្លឹះក្នុងសេចក្តីអធិប្បាយរបស់គាត់ ហើយក៏ជាគន្លឹះក្នុងជីវិតរបស់គាត់ដែរ—គាត់មិនអាចបន្តឈប់ស្វែងរក នឹងនិយាយអំពីអំណរដ៏ឧត្តុង្គឧត្តមក្នុងព្រះជាម្ចាស់ដែលបានរំដោះគាត់ឲ្យមានសេរីភាពតាមរយៈអំណាចនៃការស្អប់ស្អល់ចិត្តធំឧត្តមជាងនោះទេ។

---

៧២ ក្នុងសៀវភៅដដែល, ទំព័រ២៧៩ (*Tractatus in Joannis evangelium*, ៩៦, ៤)។

៧៣ ក្នុងសៀវភៅដដែល, ទំព័រ២៥២ (Epistle ៧៣, II, ៥)។

៧៤ ក្នុងសៀវភៅដដែល, ទំព័រ២៥៦។

# ភាពមិនផ្លាស់ប្តូរទាក់ទងនឹងព្រះគុណក្នុងនាមជា "អំណរដ៏ឧត្តុង្គឧត្តម"

លទ្ធផលនៃបទពិសោធន៍ និងទេវវិទ្យារបស់លោកគ្រូ អហ្គូស្ទីន ទាក់ទងនឹងអំណរដ៏ឧត្តុង្គឧត្តមមានប្រយោជន៍យ៉ាងខ្លាំងមិនមែនគ្រាន់តែក្នុងការអធិប្បាយប៉ុណ្ណោះទេ ប៉ុន្តែក៏ក្នុងការផ្សាយដំណឹងល្អផងដែរ។ អ្វីដែលបានកើតឡើងចំពោះគាត់ក៏អាចកើតឡើងចំពោះអ្នកដទៃបានដែរ ពីព្រោះគ្រប់ដួងចិត្តរបស់មនុស្សលោកគឺដូចគ្នាក្នុងរបៀបនេះ។ "ខ្ញុំមិនមែនមានតែឯងក្នុងសេចក្តីប្រាថ្នា [សម្រាប់ការស្ថិតក្នុងការអរសប្បាយដែលមានពេញទៅដោយព្រះពរនោះទេ] ហើយក៏មិនមែនថាមានតែមនុស្សពីរបីនាក់ដែលមានសេចក្តីប្រាថ្នាដូចខ្ញុំនោះដែរ៖ ដោយគ្មានករណីលើកលែង យើងទាំងអស់គ្នាសុទ្ធតែប្រាថ្នាចង់បានការអរសប្បាយ....គ្រប់គ្នាសុទ្ធតែឯកភាពថាខ្លួនចង់អរសប្បាយ....ពួកគេទំនងជាស្វែងរកវាក្នុងរបៀបខុសៗគ្នា ប៉ុន្តែគ្រប់គ្នាសុទ្ធតែខិតខំប្រឹងប្រែងយ៉ាងអស់ពីសមត្ថភាពរបស់ខ្លួនក្នុងការឈោងចាប់គោលដៅដូចគ្នាដែរនោះគឺថាអំណរ"។[៧៥] នេះគឺជាទីកន្លែងដ៏សាមញ្ញបំផុតក្នុងការផ្សាយដំណឹងល្អក្នុងគ្រប់សម័យកាល។ ជ្រៅជាង "អារម្មណ៍ត្រូវការ" គឺតម្រូវការដ៏ពិតៈ ព្រះជាម្ចាស់។ មិនមែនគ្រាន់តែថា យើងមានបទពិសោធន៍ជាមួយនឹងព្រះជាម្ចាស់ដោយមិនមានការជះឥទ្ធិពលខាងឯអារម្មណ៍នោះទេ ប៉ុន្តែផ្ទុយទៅវិញគឺការមានបទពិសោធន៍ជាមួយនឹងព្រះអង្គក្នុងលក្ខណៈជា "ការពេញចិត្តដ៏បរិសុទ្ធ"។ "ព្រះអង្គបានបង្កើតយើងសម្រាប់ទ្រង់ផ្ទាល់ ហើយចិត្តរបស់យើងក៏មិនអាចសម្រាកបាន លុះត្រាតែចិត្តរបស់យើងរកឃើញការសម្រាកនៅក្នុងទ្រង់សិន"។[៧៦] ការសម្រាកនេះគឺជាវត្តមាននៃការទទួលបានក៏អរសប្បាយយ៉ាងជ្រាលជ្រៅ។ "បុគ្គលដែលអរសប្បាយគឺជាបុគ្គលដែលមានព្រះជាម្ចាស់ជាកម្មសិទ្ធិ"។[៧៧] មិនមែនមកពីដោយសារព្រះជាម្ចាស់ប្រទានសុខភាព ទ្រព្យសម្បត្តិ ភាពចម្រុងចម្រើននោះទេ ប៉ុន្តែគឺដោយសារព្រះជាម្ចាស់គឺជាកន្លែងដែលព្រលឹងរបស់យើងសម្រាកដែលមានពេញទៅដោយអំណរទៅវិញទេតើ។ ការនាំឲ្យគេស្គាល់អំពីនេះ និងមានបទពិសោធន៍នេះតាមរយៈព្រះយេស៊ូវគ្រីស្ទគឺ

៧៥ លោកគ្រូ អហ្គូស្ទីន, "*ការលន់តួ*", ទំព័រ២២ (X, ២១)។

៧៦ ក្នុងសៀវភៅដដែល, ទំព័រ៥៤ (I, ១)។

៧៧ លោកគ្រូ Hand, *Augustine on Prayer*, ទំព័រ១៧ ("លើជីវិតដ៏អរសប្បាយ" *(On the Happy Life)*, ១១)។

ជាគោលដៅនៃការផ្សាយដំណឹងល្អ និងបេសកកម្មសាកលផងដែរ។

សេចក្តីបង្រៀនរបស់លោកគ្រូ អហ្គូស្ទីន អំពីការពេញចិត្តក្នុងព្រះជាម្ចាស់គឺជាឫសគល់នៃជីវិតប្រចាំថ្ងៃរបស់គ្រីស្ទបរិស័ទគ្រប់ៗរូប។ គាត់នាំឲ្យយើងឃើញនូវលទ្ធផលក្នុងការអនុវត្តដ៏សាមញ្ញក្នុងជីវិតរស់នៅ ហើយក៏បង្ហាញថា គ្រប់ឱកាសក្នុងគ្រប់កាលៈទេសៈគឺយើងកំពុងតែឈរលើគែមក្នុងការធ្លាក់ក្នុងការថ្វាយបង្គំព្រះក្លែងក្លាយ ឬក៏ការពេញចិត្តក្នុងការឃើញ និងស្គាល់ព្រះជាម្ចាស់។ ទំនងពេលខ្លះគាត់បានធ្វើខុសដោយឈរនៅខាងតាបសខ្លាំងពេកក្នុងការមានប្រតិកម្មចំពោះភាពត្រេកត្រអាលនៃភាពជាយុវវ័យរបស់គាត់។ ប៉ុន្តែ ក្នុងគោលការណ៍គាត់ហាក់បីដូចជាយល់បានយ៉ាងត្រឹមត្រូវ។ ឧទាហរណ៍៖ ច្បាប់ចម្បងរបស់គាត់ទាក់ទងនឹងការប្រើប្រាស់របស់របរលើផែនដីនេះគឺថាឲ្យយើងទទួលវាដោយដឹងគុណក្នុងនាមជាអំណោយទានពីព្រះជាម្ចាស់ ប៉ុន្តែកុំឲ្យក្លាយជាព្រះក្លែងក្លាយរបស់យើងឡើយ គាត់បានលើកឡើងអំពីចំណុចនោះក្នុងការអធិស្ឋានមួយនេះ៖ “បុគ្គលដែលស្រឡាញ់ព្រះអង្គតិចពេកគឺជាបុគ្គលដែលស្រឡាញ់អ្វីណាមួយផ្សេងទៀតជាមួយនឹងព្រះអង្គ ដែលគាត់ស្រឡាញ់មិនមែនជាប្រយោជន៍ដល់ព្រះអង្គ”។[៧៨] គាត់ពន្យល់ដូចតទៅ៖

“ឧបមាថា បុរសម្នាក់បានធ្វើចិញ្ចៀនសម្រាប់គូដណ្តឹងរបស់គាត់ ហើយនាងក៏បានស្រឡាញ់ចិញ្ចៀននោះយ៉ាងអស់ពីចិត្តខ្លាំងជាងគូដណ្តឹងរបស់ខ្លួនដែលបានធ្វើឲ្យនាង.... ប្រាកដណាស់ ចូរឲ្យនាងស្រឡាញ់អំណោយរបស់គាត់ចុះ៖ ប៉ុន្តែ ប្រសិនបើនាងលើកឡើងថា “ចិញ្ចៀននេះគ្រប់គ្រាន់ហើយ។ ខ្ញុំមិនចង់ឃើញមុខគាត់ជាថ្មីម្តងទៀតទេ”។ តើយើងគួរនិយាយយ៉ាងដូចម្តេចអំពីនាង?...ការសច្ចាគឺត្រូវបានឲ្យទៅកាន់នាងតាមរយៈគូដណ្តឹងបែបនោះ ក្នុងការសច្ចារបស់បុរសនោះ គឺគាត់ចង់ទទួលបានសេចក្តីស្រឡាញ់ពីនាង។ ដូច្នេះ ព្រះជាម្ចាស់បានប្រទានមកកាន់លោកអ្នកនូវរាល់គ្រប់អ្វីៗទាំងអស់។ ចូរស្រឡាញ់ទ្រង់ដែលបានបង្កើតវាមកចុះ»។[៧៩]

ផ្ទុយពីការបន្ទាបតម្លៃនៃភាពអស្ចារ្យ និងភាពស្រស់ស្អាតនៃលោកីយ៍នេះលោកគ្រូ អហ្គូស្ទីន បានសរសើរវា ហើយក៏បានប្រើប្រាស់វាថាជាយាននៃការប្រាថ្នាចង់បាន

៧៨ លើកឡើងជាសម្រង់សម្តីក្នុង *Documents of the Christian Church,* លោកគ្រូ Henry Bettenson, ed. (London: Oxford University Press, ឆ្នាំ១៩៦៧), ទំព័រ៥៤។

៧៩ លោកគ្រូ Brown, *Augustine of Hippo*, ទំព័រ៣២៦ (Tractate on the Epistle of យ៉ូហាន ២:១១)។

ទីក្រុងរបស់ព្រះ ដែលទាំងអស់នេះគ្រាន់តែជាស្រមោលរបស់វា។ «តាមរយៈអំណោយទានរបស់ព្រះអង្គ ដែលទ្រង់បានបាចសាចទាំងលើមនុស្សល្អ និងមនុស្សអាក្រក់ដូចគ្នា ក្នុងជីវិតដែលពោរពេញទៅដោយព្រួយកង្វល់របស់យើង ចូរឲ្យយើង ដោយមានជំនួយពីព្រះអង្គ ព្យាយាមលើកឡើងឲ្យបានគ្រប់គ្រាន់អំពីអ្វីដែលយើងនឹងដកបទពិសោធន៍នៅឯអនាគត»។[៨០] គាត់ពិចារណាលើភាពអស្ចារ្យនៃរូបកាយរបស់មនុស្ស នឹងលើ «ការតុបតែងយ៉ាងប្រថុយប្រថាននៃពុកមាត់របស់មនុស្សប្រុស» ហើយថែមទាំងបែរទៅសរសើរការរៀនសូត្ររបស់សាសនាខុសឆ្គងផងដែរ៖ «តើអ្នកណាអាចផ្តល់យុត្តិធម៌យ៉ាងពេញលេញទៅលើប្រាជ្ញាដ៏ភ្លឺរលោងដែលត្រូវបានបើកបង្ហាញឡើងតាមរយៈទស្សនវិទូ និងអ្នកខុសឆ្គងក្នុងការការពារកំហុសខុសឆ្គង និងយោបល់មិនត្រឹមត្រូវរបស់ពួកគេបាន?»។[៨១]

ការពេញចិត្តរបស់គាត់លើធម្មជាតិបានផុសឡើងទាក់ទងទៅនឹងចំណុចមួយនេះ ទំនងជាបានកើតឡើងនៅពេលដែលគាត់មើលឈូងសមុទ្រ ហិផូ (Bay of Hippo)៖ «សមុទ្រផ្ទាល់មានភាពអស្ចារ្យដែលគួរឲ្យភ្ញាក់ផ្អើល ខណៈពេលដែលរលករលេញចុះឡើងៗក្នុងពណ៌ជាច្រើនដូចជារ៉ូប ហើយក្នុងរំពេចមួយមានពណ៌បៃតង រំពេចមួយទៀតពណ៌ស្វាយ ហើយរំពេចមួយទៀតពណ៌ខៀវដូចជាផ្ទៃមេឃ....ហើយទាំងអស់នេះគឺគ្រាន់តែជាការរង្វេងលួងចិត្តសម្រាប់យើងតែប៉ុណ្ណោះ សម្រាប់យើងដែលមិនសប្បាយចិត្ត មនុស្សដែលទទួលទារុណកម្ម៖ វាមិនមែនជារង្វាន់សម្រាប់អ្នកមានពរនោះទេ។ ដូច្នេះ តើទាំងអស់នេះអាចមានលក្ខណៈយ៉ាងដូចម្តេចទៅ ប្រសិនបើឥឡូវនេះរបស់ដូចនោះមានយ៉ាងច្រើនធំសម្បើម ហើយក៏មានគុណភាពទៀតផង?»។[៨២] ការផ្តោតឥតឈប់ឈររបស់លោកគ្រូ អហ្គស្ទីន លើទីក្រុងរបស់ព្រះជាម្ចាស់មិនបានរារាំងគាត់ពីការមើលឃើញភាពស្រស់ស្អាតរបស់ផែនដីនេះ ហើយមានអំណរជាមួយនឹងវាក្នុងលក្ខណៈរបស់វាឡើយ—គាត់រាប់ទាំងអស់នោះជាអំណោយទានដ៏ល្អរបស់ព្រះជាម្ចាស់ថាកាន់តែចង្អុលបង្ហាញយើងទៅកាន់ព្រះអង្គដែលប្រទាន និងអំណរដ៏ឧត្តុង្គឧត្តមនៃព្រះវត្តមានរបស់ទ្រង់។ យើងត្រូវតែស្តាប់ការស្រែកហៅមិនឈប់ឈររបស់លោកគ្រូ អហ្គស្ទីន ក្នុងការមានសេរីភាពចេញពីស្ថានភាពអាក្រក់នៃការពេញចិត្តលោកីយ៍នេះ មិនមែនដោយសារវាអាក្រក់ដោយខ្លួន

៨០ ក្នុងសៀវភៅដដែល, ទំព័រ៣២៨ (*«ទីក្រុងរបស់ព្រះ» (City of God)*, XXII, ២១, ទំព័រ២៦)។
៨១ ក្នុងសៀវភៅដដែល, ទំព័រ៣២៩ (*«ទីក្រុងរបស់ព្រះ» (City of God)*, XXII, ២៤, ទំព័រ១៦០)។
៨២ ក្នុងសៀវភៅដដែល, ទំព័រ៣២៩ (*«ទីក្រុងរបស់ព្រះ» (City of God)*, XXII ២៤, ទំព័រ១៧៥)។

ផ្ទាល់នោះទេ ប៉ុន្តែគឺដោយសារមានតិចនាក់ណាស់ក្នុងចំណោមយើងដែលប្រើប្រាស់វាក្នុងលក្ខណៈដែលយើងគួរប្រើប្រាស់វា៖ «ប្រសិនបើអ្វីៗនៅលើផែនដីនេះធ្វើឲ្យលោកអ្នកពេញចិត្ត ចូរសរសើរព្រះជាម្ចាស់ដោយសារពួកវា ប៉ុន្តែសូមបែរសេចក្ដីស្រឡាញ់របស់លោកអ្នកចេញពីពួកវា ហើយថ្វាយវាទៅកាន់ព្រះអាទិកររបស់វាចុះ ដើម្បីឲ្យថាក្នុងអ្វីៗដែលធ្វើឲ្យលោកអ្នកសប្បាយចិត្តនឹងមិនធ្វើឲ្យព្រះអង្គមិនសព្វព្រះហឫទ័យ»។

ទស្សនៈរបស់លោកគ្រូ អហ្គូស្ទីន លើសេចក្ដីសង្គ្រោះតាមរយៈព្រះយេស៊ូវគ្រីស្ទ និងទស្សនៈលើជីវិតរស់នៅរបស់គ្រីស្ទបរិស័ទមានឫសគល់ក្នុងការយល់ដឹង និងបទពិសោធន៍របស់គាត់អំពីព្រះគុណ—ជាអំណោយទានពីព្រះអង្គនៃអំណរដែលមានជ័យជម្នះក្នុងព្រះជាម្ចាស់។ អំណាចដែលសង្គ្រោះ និងញែកជាបរិសុទ្ធគឺជាព័ន្ធកិច្ចរបស់ព្រះជាម្ចាស់យ៉ាងជ្រៅជ្រែកក្រោមឆន្ទៈរបស់មនុស្សក្នុងការផ្លាស់ប្ដូរក្បាលទឹកនៃអំណរ ដើម្បីឲ្យយើងអាចស្រឡាញ់ព្រះជាម្ចាស់ខ្លាំងជាងការរួមភេទ សមុទ្រ ការសិក្សា ម្ហូបអាហារ មិត្តភក្តិ ភាពល្បីល្បាញ គ្រួសារ ឬក៏លុយកាក់។ ព្រះគុណគឺជាគន្លឹះ ពីព្រោះវាឥតគិតថ្លៃ ហើយក៏បង្កើតដួងចិត្តថ្មីជាមួយនឹងការពេញចិត្តថ្មីដែលគ្រប់គ្រងលើឆន្ទៈ និងព័ន្ធកិច្ចនៃជីវិតរបស់យើង។ «ដូច្នេះ មិនមែនស្រេចលើបំណង ឬការខំប្រឹងប្រែងរបស់មនុស្សឡើយ គឺស្រេចលើព្រះ ដែលទ្រង់មេត្តាករុណាវិញ» (រ៉ូម ៩:១៦)។

ប្រសិនបើវាពិតមែន ដូចដែលលោកគ្រូ អ. ស៊ី. ស្រ្ទួល បានលើកឡើងថា ថ្ងៃនេះ «យើងមិនទាន់បានដោះខ្លួនចេញពីភាពជាឈ្លើយរបស់ពួកភីលេហ្គៀនក្នុងក្រុមជំនុំនៅឡើយទេ»[៨៣]—ភាពជាឈ្លើយដែលលោកគ្រូ អហ្គូស្ទីន បានធ្វើសង្គ្រាមប្រឆាំងជាមួយអស់ជាច្រើនឆ្នាំ ដើម្បីជាប្រយោជន៍សម្រាប់អំណរដ៏ឧត្តុង្គឧត្តម—ដូច្នេះយើងគួរអធិស្ឋាន អធិប្បាយ និពន្ធ បង្រៀន និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពរបស់យើងក្នុងការផ្ដាច់ច្រវាក់ដែលចងយើងភ្ជាប់ក្នុងភាពជាឈ្លើយ។ លោកគ្រូ អ. ស៊ី. ស្រ្ទួល បានលើកឡើងថា «យើងត្រូវថាបុគ្គលម្នាក់ដូចជាលោកគ្រូ អហ្គូស្ទីន ឬក៏លោកគ្រូ លូសើរ ដើម្បីនិយាយមកកាន់យើងជាថ្មីម្ដងទៀតក្រែងលោពន្លឺនៃព្រះគុណរបស់ព្រះជាម្ចាស់ត្រូវបានមានស្រមោលមកគ្របបាំងពីលើ ឬក៏លុបបំបាត់ចោលទាំងស្រុងក្នុងយុគសម័យរបស់

---

៨៣ លោកគ្រូ អ. ស៊ី. ស្រ្ទួល, *Augustine and Pelagius,* ទំព័រ៥២។

យើង»។[៨៤] ប្រាកដណាស់! យើងត្រូវការ។ ប៉ុន្តែ យើងក៏ត្រូវការគ្រូគង្វាល និងមនុស្សធម្មតារាប់ពាន់នាក់ដែលមានភាពរំភើបយ៉ាងខ្លាំងជាមួយនឹងអំណាចយ៉ាងចម្លែកនៃអំណរក្នុងព្រះជាម្ចាស់ដែរ។

ហើយយើងក៏ត្រូវការរកឃើញជាថ្មីម្តងទៀតនូវការយល់ដឹងដ៏ចម្លែករបស់លោកគ្រូ អហ្គស្ទីន—ជាការយល់ដែលរំពឹងលើព្រះគម្ពីរ—លើព្រះគុណថាជាអំណោយទានឥតគិតថ្លៃនៃអំណរដ៏ឧត្តុង្គឧត្តមក្នុងព្រះជាម្ចាស់ដែលរំដោះយើងចេញពីចំណងនៃអំពើបាប។ យើងត្រូវតែគិតសារឡើងវិញជាថ្មីម្តងទៀតលើគោលជំនឿកំណែទម្រង់របស់យើងអំពីសេចក្តីសង្គ្រោះ ដើម្បីឲ្យថាគ្រប់អវយវៈ និងមេឈើលើដើមឈើគឺកំពុងតែហូរតាមជ័រនៃការពេញចិត្តរបស់លោកគ្រូ អហ្គស្ទីន។ យើងត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់ថា *ភាពមិនអាចធ្វើឲ្យព្រះជាម្ចាស់គាប់ព្រះហឫទ័យបាន*គឺមិនមែនគ្រាន់តែជាអំពើអាក្រក់នោះទេ ប៉ុន្តែក៏ជាការខ្វាក់ចំពោះភាពស្រស់ស្អាត និងការស្លាប់ចំពោះអំណរផងដែរ។ ហើយថា*ការជ្រើសតាំងដោយឥតលក្ខខណ្ឌ*មានន័យថាជាការពេញលេញនៃអំណររបស់យើងក្នុងព្រះយេស៊ូវ ពោលគឺព្រះអង្គបានគ្រោងទុកសម្រាប់យើងមុនយើងមានជីវិតទៅទៀត។ ហើយថា*ការធ្វើធួននឹងបាបមានកម្រិត*គឺជាការធានាអំពីអំណរដែលមិនអាចបំផ្លាញចោលបានក្នុងព្រះជាម្ចាស់ ដែលព្រះអង្គបានធានាទុកដោយមិនអាចបរាជ័យបានសម្រាប់យើងតាមរយៈព្រះលោហិតនៃសេចក្តីតាំងសញ្ញា។ ហើយថា*ព្រះគុណមិនអាចទប់ទល់បាន*គឺជាការប្តេជ្ញាចិត្ត និងអំណាចនៃសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ក្នុងការប្រាកដថាកុំឲ្យយើងឧបក្រសោបភាពអរសប្បាយដែលនាំឲ្យយើងសម្លាប់ខ្លួនឯងចោល ហើយដើម្បីរំដោះយើងឲ្យមានសេរីភាពតាមរយៈអំណាចនៃអធិបតេយ្យភាពនៃការពេញចិត្តដ៏ឧត្តុង្គឧត្តម។ ហើយថា*ការស៊ូទ្រាំរបស់ពួកបរិសុទ្ធ*គឺជាព័ន្ធកិច្ចដែលពេញទៅដោយអំណាចព្រះចេស្តារបស់ព្រះជាម្ចាស់ក្នុងការរក្សាយើងទុកឆ្លងកាត់ទុក្ខកង្វល់ និងទុក្ខវេទនាទាំងអស់ ដើម្បីទទួលបានមរតកនៃភាពអរសប្បាយនៅឯព្រះហស្តខាងស្តាំរបស់ព្រះជាម្ចាស់យ៉ាងអស់កល្បជានិច្ច។

ចំណុចសម្គាល់នៃអធិបតេយ្យភាព និងជ័យជម្នះនៃអំណរនេះគឺជាចំណុចខ្វះខាតយ៉ាងខ្លាំងក្រៃលែងក្នុងទេវវិទ្យា និងការថ្វាយបង្គំរបស់គ្រីស្ទបរិស័ទ (ជាពិសេសក្នុង

៨៤ ក្នុងសៀវភៅដដែល។

ចំណោមពួកកំណែទម្រង់)។ ទំនងសំណួរដែលយើងគួរសួរខ្លួនឯងគឺថា តើវាដូច្នេះមកពីយើងមិនមានបទពិសោធន៍ក្នុងជ័យជម្នះនៃអំណរដ៏ឧត្តុង្គឧត្តមក្នុងជីវិតជាប្រចាំថ្ងៃរបស់យើងមែនឬ។ តើយើងអាចនិយាយដូចអ្វីដែលលោកគ្រូ អហ្គស្ទីន បានលើកឡើងខាងក្រោមនេះដែរឬទេ?

“ការនេះក៏បានក្លាយជាផ្អែមល្ហែមភ្លាមៗដល់ទូលបង្គំក្នុង*ការមិនមានភាពអរសប្បាយដ៏ល្ងីល្ងើ*ដែលទូលបង្គំធ្លាប់សប្បាយជាមួយពីមុន...*ដ្បិតគឺព្រះអង្គហើយដែលបានបោះបង់សេចក្ដីប្រាថ្នាទាំងនោះរបស់ទូលបង្គំចោល*។ ព្រះអង្គបានបោះបង់វាចោល ហើយព្រះអង្គផ្ទាល់ក៏បានយកកន្លែងរបស់វា....ឱព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់នៃទូលបង្គំអើយ...ពន្លឺរបស់ទូលបង្គំ ទ្រព្យសម្បត្តិរបស់ទូលបង្គំ និងសេចក្ដីសង្គ្រោះរបស់ទូលបង្គំ”។[៨៥]

ឬក៏ថាយើងនៅជាប់ក្នុងចំណងនៃភាពអរសប្បាយរបស់លោកីយ៍នេះនៅឡើយ ដូច្នេះទោះបើយើងនិយាយស្ដីច្រើនអំពីសិរីល្អរបស់ព្រះជាម្ចាស់ នោះយើងនៅស្រឡាញ់ការមើលទូរទស្សន៍ ម្ហូបអាហារ ការដេកពួន ការរួមភេទ លុយកាក់ និងការសរសើរពីមនុស្សម្នាដូចអ្នកដទៃមែនឬ? បើដូច្នោះមែន ចូរឲ្យយើងកែប្រែចិត្ត ហើយបានកាត់ចិត្តឲ្យរឹងដូចថ្មដែកភ្លើងទៅកាន់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ចុះ។ ហើយសូមឲ្យយើងអធិស្ឋាន៖ ឱព្រះអម្ចាស់អើយ! សូមបើកភ្នែកទូលបង្គំឲ្យឃើញភាពឧត្តុង្គឧត្តមដែលថាក្នុងព្រះវត្តមានរបស់ព្រះអង្គមានពេញទៅដោយអំណរ ហើយថានៅខាងព្រះហស្តស្តាំរបស់ព្រះអង្គមានសេចក្ដីអរសប្បាយជាដរាបតទៅ (ទំនុកតម្កើង ១៦:១១)។ ឱព្រះជាម្ចាស់អើយ! សូមអនុញ្ញាតឲ្យយើងអាចរស់នៅក្នុងកើ្តដំណែលនៃអំណរដ៏ឧត្តុង្គឧត្តម។

៨៥ លោកគ្រូ អហ្គស្ទីន, “*ការលន់តួ*”, ទំព័រ២២២, ការផ្ដោតលើគឺជាការបន្ថែម។

សៀវភៅទី១

# ១

# ភាពឧត្តុង្គឧត្តមរបស់ព្រះជាម្ចាស់

១. «ព្រះអម្ចាស់ធំ ហើយគួរឲ្យសរសើរតម្កើងយ៉ាងក្រៃលែង អំណាចព្រះចេស្តាទ្រង់ក៏ធំអស្ចារ្យ ហើយព្រះប្រាជ្ញាញាណរបស់ទ្រង់ក៏គ្មានព្រំដែនដែរ»។[១]

ទោះជាយ៉ាងណាក្ដី ក៏យើងដែលជាមនុស្សដែលតូចទាបនៅប្រាថ្នាចង់សរសើរតម្កើងព្រះអង្គ ដ្បិតយើងជាផ្នែកមួយនៃការបង្កើតរបស់ទ្រង់។ សេចក្ដីពិតដែលថា យើងនឹងស្លាប់ គឺជាភស្តុតាងនៃអំពើបាបរបស់យើង ហើយក៏ជាភស្តុតាងដែលថា ព្រះអង្គទាស់ប្រឆាំងនឹងមនុស្សដែលមានអំនួតដែរ។ ទោះជាយ៉ាងណាក្ដី ក៏យើងនៅតែប្រាថ្នាចង់សរសើរតម្កើងព្រះអង្គ ទោះបើយើងគ្រាន់តែជាផ្នែកដ៏តូចមួយនៃការបង្កើតរបស់ទ្រង់ក៏

១ សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ ទំនុកតម្កើង ១៤៥:៣ «ព្រះយេហូវ៉ាធំ ហើយគួរសរសើរតម្កើងយ៉ាងក្រៃលែង ភាពធំអស្ចារ្យរបស់ព្រះអង្គ នោះរកយល់មិនបាន» និង ១៤៧:៥ «ព្រះអម្ចាស់របស់យើងធំអស្ចារ្យ ហើយមានពេញដោយព្រះចេស្ដា ប្រាជ្ញាញាណរបស់ព្រះអង្គ មិនអាចវាស់ស្ទង់បានឡើយ»។

ដោយ។ ព្រះអង្គបានធ្វើការក្នុងយើងឲ្យមានសេចក្ដីប្រាថ្នាដែលចង់សរសើរតម្កើងទ្រង់ ដ្បិតព្រះអង្គបានបង្កើតយើងសម្រាប់ទ្រង់ផ្ទាល់ ហើយចិត្តរបស់យើងក៏មិនអាចសម្រាកបាន លុះត្រាតែចិត្តរបស់យើងរកឃើញការសម្រាកនៅក្នុងទ្រង់សិន។

ឱព្រះអម្ចាស់អើយ! សូមប្រទានឲ្យទូលបង្គំស្គាល់ និងយល់ថាជាដំបូង តើទូលបង្គំគួរអធិស្ឋានទៅកាន់ទ្រង់ ឬក៏គួរសរសើរតម្កើងទ្រង់ ឬក៏ថាជាដំបូងទូលបង្គំត្រូវស្គាល់ទ្រង់ ឬអំពាវនាវទៅកាន់ទ្រង់។ ប៉ុន្តែ តើអ្នកណាអាចអំពាវនាវទៅទ្រង់បាន ប្រសិនបើគេមិនទាន់ស្គាល់ទ្រង់នៅឡើយ? ដ្បិតបុគ្គលដែលមិនស្គាល់ព្រះអង្គទំនងជាអាចនឹងអំពាវនាវទៅកាន់អ្វីដែលមិនត្រឹមត្រូវក៏អាចថាបាន។ ទំនងជាយើងគួរតែអំពាវនាវទៅកាន់ព្រះអង្គ ដើម្បីឲ្យយើងអាចស្គាល់ទ្រង់បាន។ ប៉ុន្តែ «តើឲ្យគេអំពាវនាវទៅរកទ្រង់បានដោយរបៀបណាខណៈពេលដែលពួកគេមិនទាន់ជឿនៅឡើយ? ឬក៏ថា តើឲ្យពួកគេទទួលជឿលើទ្រង់យ៉ាងដូចម្ដេចបាន ប្រសិនបើគ្មានអ្នកណាប្រកាសទៅកាន់ពួកគេ?»។ [២]

ប៉ុន្តែ «អស់អ្នកដែលស្វែងរកព្រះយេហូវ៉ានឹងសរសើរតម្កើងព្រះអង្គ»[៣] ដ្បិតអស់អ្នកដែល «ស្វែងរក នោះអ្នកនឹងបានឃើញ»[៤] ហើយដោយសារគេរកឃើញទ្រង់ នោះពួកគេក៏នឹងសរសើរតម្កើងទ្រង់ដែរ។ ឱព្រះអម្ចាស់អើយ! ទូលបង្គំនឹងស្វែងរកទ្រង់ ហើយនឹងអំពាវនាវរកទ្រង់។ ឱព្រះអម្ចាស់អើយ! ទូលបង្គំអំពាវនាវរកទ្រង់ក្នុងជំនឿដែលទ្រង់បានប្រទានមកទូលបង្គំ ដែលទ្រង់បានផ្លុំខ្យល់ដង្ហើមមកកាន់ទូលបង្គំតាមរយៈការយាងមកយកកំណើតរបស់ព្រះរាជបុត្រាទ្រង់ និងតាមរយៈព័ន្ធកិច្ចនៃគ្រូអធិប្បាយរបស់ព្រះអង្គ។[៥]

៤. «ដ្បិតតើអ្នកណាជាព្រះអម្ចាស់លើកលែងតែព្រះអម្ចាស់ផ្ទាល់?» «តើអ្នកណាជាព្រះជាម្ចាស់ក្រៅពីព្រះជាម្ចាស់ផ្ទាល់?»។ ព្រះដ៏ខ្ពង់ខ្ពស់។ ព្រះដ៏ឧត្ដុង្គឧត្ដម។ ព្រះដ៏ពេញទៅដោយអំណាចព្រះចេស្ដា។ ព្រះដ៏ពេញទៅដោយសព្វានុភាព។ ព្រះដ៏ពេញទៅដោយសេចក្ដីមេត្តាករុណា ហើយក៏ពេញទៅដោយសេចក្ដីយុត្តិធម៌ដែរ។ ព្រះដ៏ពេញទៅដោយ

២ រ៉ូម ១០:១៤ «ប៉ុន្តែ ធ្វើដូចម្ដេចឲ្យគេអំពាវនាវរកព្រះអង្គបាន បើគេមិនជឿ? ធ្វើដូចម្ដេចឲ្យគេជឿដល់ព្រះអង្គបាន បើគេមិនដែលឮ? ហើយធ្វើដូចម្ដេចឲ្យគេឮបាន បើគ្មានអ្នកណាប្រកាស?»។

៣ ទំនុកតម្កើង ២២:២៦ «មនុស្សទន់ទាបនឹងបានបរិភោគឆ្អែត អស់អ្នកដែលស្វែងរកព្រះយេហូវ៉ានឹងសរសើរតម្កើងព្រះអង្គ សូមឲ្យចិត្តអ្នករាល់គ្នារស់នៅជាដរាប!»។

៤ ម៉ាថាយ ៧:៧ «ចូរសូម នោះនឹងឲ្យមកអ្នក ចូរស្វែងរក នោះអ្នកនឹងបានឃើញ ចូរគោះ នោះនឹងបើកឲ្យអ្នក»។

៥ មានអ្នកវិភាគមួយចំនួនបានលើកឡើងថា ត្រង់នេះលោកគ្រូអធិប្បាយដែលលោកគ្រូ អហ្គស្ទីន កំពុងតែរៀបរាប់គឺជាលោកគ្រូអធិប្បាយ អមប្រូស៍ (Ambrose) ដែលការបង្រៀនរបស់គាត់បានជួយឲ្យលោកគ្រូ អហ្គស្ទីន ទទួលបានសេចក្ដីសង្គ្រោះ។ ប៉ុន្តែ តាមរយៈបរិបទនេះ យើងឃើញថា មានតែព្រះយេស៊ូវគ្រីស្ទម្នាក់គត់ដែលជា «គ្រូអធិប្បាយ» ដែលអាចប្រទានចំណេះដឹងអំពីព្រះជាម្ចាស់ និងការសរសើរតម្កើងបាន។

អាថ៌កំបាំង ហើយក៏គង់នៅគ្រប់ទីកន្លែងផងដែរ។ ព្រះដ៏សង្ហា ហើយខ្លាំងក្លា។

ព្រះអង្គនឹងនរ ប៉ុន្តែមិនត្រូវការការគាំទ្រទេ។ ព្រះអង្គមិនចេះផ្លាស់ប្រែ ប៉ុន្តែព្រះអង្គបំផ្លាស់បំប្រែនូវរាល់អ្វីៗទាំងអស់។ ព្រះអង្គមិនចេះថ្មី ហើយក៏មិនចេះចាស់ដែរ។ ព្រះអង្គធ្វើឲ្យនូវរាល់គ្រប់អ្វីៗថ្មីឡើងវិញ ប៉ុន្តែទ្រង់ក៏ធ្វើឲ្យមនុស្សដែលមានអំនួតក្លាយទៅជាមនុស្សចាស់ដោយពួកគេមិនដឹងខ្លួនផងដែរ។ ព្រះអង្គធ្វើការជានិច្ច ប៉ុន្តែទ្រង់ក៏សម្រាកជានិច្ចដែរ។ ព្រះអង្គតែងតែប្រមូលទុក ប៉ុន្តែទ្រង់មិនមានតម្រូវការអ្វីទេ។ ទ្រង់កំពុងផ្គត់ផ្គង់ កំពុងបំពេញ និងកំពុងការពារ។ ព្រះអង្គកំពុងបង្កើត កំពុងថែបំប៉ន និងក៏កំពុងអភិវឌ្ឍន៍ដែរ។ ទ្រង់ក៏កំពុងស្វែងរក ប៉ុន្តែទ្រង់ក៏ជាម្ចាស់នូវរាល់គ្រប់អ្វីៗទាំងអស់រួចស្រេចទៅហើយដែរ។ ព្រះអង្គស្រឡាញ់ ប៉ុន្តែគ្មានតណ្ហាពុះកញ្ជ្រោលឡើយ។ ទ្រង់ច្រណែន ប៉ុន្តែមិនមានការព្រួយបារម្ភឡើយ។ ព្រះអង្គលន់តួ ប៉ុន្តែគ្មានវិប្បដិសារីទេ។ ព្រះអង្គមានសេចក្តីក្រោធ ប៉ុន្តែក៏គង់នៅយ៉ាងក្សេមក្សាន្តដែរ។ ព្រះអង្គផ្លាស់ប្តូរផ្លូវ ប៉ុន្តែទ្រង់មិនផ្លាស់ប្តូរផែនការទេ។ ព្រះអង្គទទួលបានវិញនូវអ្វីដែលទ្រង់មិនធ្លាប់បាត់បង់។ ព្រះអង្គមិនដែលត្រូវការអ្វីទេ ប៉ុន្តែទ្រង់ក៏មានអំណរក្នុងការទទួលបានផងដែរ។ ទ្រង់មិនចេះលោភលន់ ប៉ុន្តែទ្រង់ទាមទារភាគរយចំណេញនៃភាគហ៊ុន។ មនុស្សយើងបង់ថ្លៃលើសតម្រូវការ ដែលការនោះនាំឲ្យទ្រង់ក្លាយដូចជាអ្នកជាប់បំណុល។ ប៉ុន្តែ តើឲ្យនរណាធ្វើជាម្ចាស់នៅលើអ្វីមួយបានយ៉ាងដូចម្តេចទៅ ព្រោះរាល់អ្វីៗទាំងអស់គឺជារបស់ផងទ្រង់ផ្ទាល់រួចស្រេចទៅហើយ? ទ្រង់មិនជំពាក់អ្វីនឹងនរណាម្នាក់ទេ ប៉ុន្តែទ្រង់បង់ថ្លៃទៅកាន់ពួកគេហាក់បីដូចជាទ្រង់ជំពាក់បំណុលទៅកាន់អ្វីៗដែលទ្រង់បានបង្កើតអញ្ចឹង។ ហើយនៅពេលដែលព្រះអង្គលុបបំណុលណាមួយចោល ទ្រង់ក៏មិនបានបាត់បង់អ្វីសោះដែរ។

ប៉ុន្តែ ឱព្រះដ៏ជាម្ចាស់នៃជីវិត និងជាអំណរដ៏បរិសុទ្ធរបស់ទូលបង្គំអើយ! តើទូលបង្គំបាននិយាយអំពីអ្វីទៅហ្ន៎? តើឲ្យមនុស្សដែលតែងនឹងស្លាប់អាចនិយាយបានអ្វីខ្លះអំពីព្រះអង្គ? ប៉ុន្តែ វេទនាហើយដល់អស់អ្នកណាដែលមិននិយាយអំពីព្រះអង្គ—ទោះបើពួកគេនិយាយយ៉ាងក្បោះក្បាយអំពីប្រធានបទណាផ្សេង—ដ្បិតពួកគេមិនបាននិយាយអំពីទ្រង់ដែលជាប្រធានបទដ៏សំខាន់បំផុត។

៥. សូមឲ្យទូលបង្គំសម្រាកក្នុងទ្រង់។ ឱព្រះអង្គអើយ! សូមទ្រង់យាងចូលមកកាន់ដួងចិត្តរបស់ទូលបង្គំ ហើយបំបាក់វាហូតដល់ទូលបង្គំនឹងភ្លេចអំពីអំពើអាក្រក់ដែលទូលបង្គំ

បានប្រព្រឹត្ត ហើយឲ្យទូលបង្គំឱបក្រសោបទ្រង់ ដែលជាព្រះដ៏ល្អតែមួយគត់វិញចុះ។ តើព្រះអង្គត្រូវជាអ្វីជាមួយនឹងទូលបង្គំ? សូមអាណិតអាសូរដល់ទូលបង្គំ ហើយសូមណែនាំឲ្យទូលបង្គំចេះរៀបរាប់អំពីការនោះផងដែរ។ តើទូលបង្គំត្រូវជាអ្វីនឹងព្រះអង្គដែលគួរឲ្យព្រះអង្គបញ្ជាឲ្យទូលបង្គំស្រឡាញ់ទ្រង់ ហើយប្រសិនបើទូលបង្គំមិនស្រឡាញ់ទ្រង់ នោះទ្រង់នឹងមានសេចក្ដីក្រោធ ហើយគំរាមកំហែងដល់ទូលបង្គំថា ទូលបង្គំនឹងប្រឈមមុខនឹងសេចក្ដីវេទនាយ៉ាងអាក្រក់? ហាក់បីដូចជាការមិនស្រឡាញ់ទ្រង់ នោះមិនមែនជាសេចក្ដីវេទនាគ្រប់គ្រាន់ហើយទេឬអី! ឱព្រះអង្គដ៏ជាម្ចាស់ទូលបង្គំអើយ! សូមប្រាប់ទូលបង្គំតាមរយៈសេចក្ដីមេត្តាករុណារបស់ទ្រង់ថា តើព្រះអង្គត្រូវជាអ្វីនឹងទូលបង្គំ។ សូមមានបន្ទូលមកកាន់ព្រលឹងទូលបង្គំថា «យើងជាព្រះសង្គ្រោះអ្នក»។[៦] សូមមានបន្ទូល ដើម្បីឲ្យទូលបង្គំអាចនឹងឮបាន។ មើល៍! ឱព្រះអម្ចាស់អើយ! ត្រចៀកនៃចិត្តទូលបង្គំកំពុងតែស្ដាប់។ សូមបើកត្រចៀកនៃចិត្តទូលបង្គំ ហើយមានបន្ទូលមកកាន់ព្រលឹងទូលបង្គំថា «យើងជាព្រះសង្គ្រោះអ្នក»។ ទូលបង្គំនឹងសង្វាតដេញតាមព្រះសូរសៀងមួយនោះ ហើយទូលបង្គំនឹងចាប់កាន់ទ្រង់ផ្ទាល់តែម្ដង។ សូមកុំលាក់ព្រះភ័ក្ត្ររបស់ទ្រង់ពីទូលបង្គំ។ ទោះបើទូលបង្គំនឹងស្លាប់ ក៏ទូលបង្គំសូមអង្វរឲ្យទ្រង់បង្ហាញព្រះភ័ក្ត្រទ្រង់ ព្រោះបើមិនដូច្នោះទេ នោះទូលបង្គំនឹងស្លាប់ជាមិនខាន។

៦ ទំនុកតម្កើង ៣៥:៣ "សូមលើកលំពែង និងដែកពួយប្រហារពួកអ្នកដែលដេញតាមទូលបង្គំទៅ! សូមមានព្រះបន្ទូលមកព្រលឹងទូលបង្គំថា «យើងជាព្រះសង្គ្រោះអ្នក!" (គកស)។

# ២

# ភាពជាទារក

៦. ផ្ទះនៃព្រលឹងទូលបង្គំគឺតូចពេកហើយសម្រាប់ឲ្យព្រះអង្គយាងចូលមក។ ឱព្រះអង្គអើយ! សូមទ្រង់ពង្រីកព្រលឹងទូលបង្គំ។ វាកំពុងស្ថិតក្នុងការហិនហោចទាំងស្រុង។ សូមស្តារព្រលឹងទូលបង្គំឡើងវិញ! ទូលបង្គំទទួលស្គាល់ ហើយដឹងថាមានចំណុចជាច្រើនក្នុងព្រលឹងទូលបង្គំដែលជាអំពើល្មើសចំពោះព្រះនេត្រព្រះអង្គ។ ប៉ុន្តែ តើអ្នកណានឹងសម្អាតព្រលឹងទូលបង្គំ? តើឲ្យទូលបង្គំអំពាវនាវទៅរកអ្នកណាក្រៅពីព្រះអង្គ? «សូមជម្រះទូលបង្គំឲ្យបានស្អាតពីកំហុសដែលលាក់កំបាំងផង» ឱព្រះអម្ចាស់អើយ «សូមរាំងរាទូលបង្គំជាអ្នកបម្រើព្រះអង្គពីអំពើបាបដែលធ្វើដោយល្មើសដែរ»។[១] «ខ្ញុំបានជឿ ទោះជាពេលដែលខ្ញុំពោល»។[២] ប៉ុន្តែ ឱព្រះអម្ចាស់អើយ! ទ្រង់បានជ្រាបអំពីការនេះរួចស្រេចទៅហើយ។ ទូលបង្គំបានលន់តួអំពើរំលងរបស់ទូលបង្គំចំពោះព្រះអង្គ ហើយព្រះអង្គក៏បានអត់ទោសដល់ទូលបង្គំ។[៣]

៧. ឱព្រះអម្ចាស់អើយ! សូមអនុញ្ញាតឲ្យទូលបង្គំរៀបរាប់អំពីក្តីមេត្តាករុណារបស់ទ្រង់

---

១ ទំនុកតម្កើង ១៩:១២, ១៣។

២ ទំនុកតម្កើង ១១៦:១០។

៣ ទំនុកតម្កើង ៣២:៥។

នោះ ទោះបើទូលបង្គំគ្រាន់តែជាធូលីដី និងផេះក៏ដោយ។ សូមអនុញ្ញាតឲ្យទូលបង្គំរៀបរាប់ ដ្បិតការរៀបរាប់នោះគឺទៅកាន់ព្រះអង្គ និងអំពីសេចក្តីមេត្តាករុណារបស់ទ្រង់ដែលទូលបង្គំនិយាយរៀបរាប់ មិនមែនទៅកាន់មនុស្សដែលចង់និយាយសើចចំអកអំពីទូលបង្គំទេ។ ព្រះអង្គទេតើដែលគួរសើចចំអកដាក់ទូលបង្គំ ប៉ុន្តែទ្រង់បែរជាមានសេចក្តីមេត្តាករុណាលើទូលបង្គំទៅវិញ។

ឱព្រះអង្គដ៏ជាម្ចាស់នៃទូលបង្គំអើយ! ទូលបង្គំមិនស្គាល់ពីទីកន្លែងដែលទូលបង្គំបានចេញមក ហើយចូលទៅកាន់ «ជីវិតក្នុងការស្លាប់» ទេ។ ឬក៏ទូលបង្គំគួរហៅវាថា «សេចក្តីស្លាប់ក្នុងជីវិត»? ទូលបង្គំមិនដឹងទេ។ តែទោះជាយ៉ាងណាក្តីក៏សេចក្តីមេត្តាករុណាដ៏សប្បុរសរបស់ព្រះអង្គបានទ្រទ្រង់ទូលបង្គំតាំងពីដើមមកម្ល៉េះ។ ទូលបង្គំមិនចងចាំទេ ប៉ុន្តែទូលបង្គំធ្លាប់បានឮអំពីសេចក្តីមេត្តាករុណានោះពីឪពុកម្តាយខាងឯសាច់ឈាមរបស់ទូលបង្គំ។ ដូច្នេះ ទោះបើពួកគាត់បានផ្គត់ផ្គង់ទូលបង្គំតាមរយៈទឹកដោះស្ត្រីក៏ដោយ ក៏ទាំងអ្នកម្តាយទូលបង្គំ និងម៉ែដោះទូលបង្គំមិនបានបំពេញទឹកដោះដោយខ្លួនឯងនោះទេ ប៉ុន្តែព្រះអង្គបានប្រទានតាមរយៈពួកគេ បានផ្គត់ផ្គង់ម្ហូបសម្រាប់ទារកដល់ទូលបង្គំយោងតាមបទបញ្ញារបស់ទ្រង់ និងភាពបរិបូណ៌របស់ព្រះអង្គដែលទ្រទ្រង់រាល់គ្រប់អ្វីៗទាំងអស់។ ដ្បិតគឺព្រះអង្គហើយដែលបណ្តាលឲ្យទូលបង្គំមិនចង់បានលើសជាងអ្វីដែលព្រះអង្គប្រទានឲ្យ ហើយក៏ព្រះអង្គដែរដែលប្រទានដល់អស់អ្នកដែលបានផ្គត់ផ្គង់មកដល់ទូលបង្គំនូវឆន្ទៈក្នុងការផ្គត់ផ្គង់នូវអ្វីដែលទ្រង់បានប្រទានដល់ពួកគេ។ ហើយពួកគេ តាមរយៈការស្រឡាញ់ដោយឯងៗដែលទ្រង់បានប្រទានក៏មានឆន្ទៈក្នុងការផ្គត់ផ្គង់ដល់ទូលបង្គំនូវអ្វីដែលទ្រង់បានប្រទានយ៉ាងបរិបូណ៌ដែរ។ អាហារដែលពួកគេផ្គត់ផ្គង់ដល់ទូលបង្គំក៏ជាអ្វីដែលល្អសម្រាប់ពួកគេផងដែរ ពីព្រោះតាមពិតទៅគឺវាមិនមែនមកពីពួកគេផ្ទាល់នោះទេ ប៉ុន្តែគឺមកពីព្រះអង្គទេតើ។ ឱព្រះជាម្ចាស់អើយ! ដ្បិតគឺមកពីព្រះអង្គនោះហើយដែលមានរាល់គ្រប់អ្វីៗដែលល្អ។ ហើយសុខភាពរបស់ទូលបង្គំក៏មកពីព្រះជាម្ចាស់ទាំងស្រុងដែរ។ នេះហើយគឺជាអ្វីដែលទូលបង្គំបានរៀនតាំងពីទូលបង្គំនៅជាទារក ដូចដែលទ្រង់បានបើកបង្ហាញយ៉ាងច្បាស់លាស់ដ៏បរិបូណ៌តាមរយៈអ្វីដែលទូលបង្គំឃើញទ្រង់ប្រទានមកកាន់ទូលបង្គំ និងអស់អ្នកដែលនៅជុំវិញទូលបង្គំ។ ប៉ុន្តែ កាលទូលបង្គំនៅជាទារក ទូលបង្គំចេះបៅដោះ ចេះដេកនៅស្ងៀមពេលទូលបង្គំ

ឆ្អែត ហើយចេះស្រែកយំពេលទូលបង្គំឈឺ។ ទូលបង្គំមិនចេះអ្វីផ្សេងទៀតក្រៅពីហ្នឹងទេ។

៨. បន្ទាប់មក ទូលបង្គំក៏ចាប់ផ្ដើមញញឹម—ជាដំបូង ពេលទូលបង្គំកំពុងគេង ហើយបន្ទាប់មកពេលទូលបង្គំភ្ញាក់ឡើង។ ទូលបង្គំមិនអាចចាំអំពីការនេះដោយខ្លួនឯងបាននោះទេ ប៉ុន្តែមនុស្សម្នាបានប្រាប់ទូលបង្គំអំពីទូលបង្គំទាក់ទងនឹងការនេះ ហើយទូលបង្គំក៏ជឿ ព្រោះទូលបង្គំឃើញអំពីចំណុចនេះក្នុងទារកនានា។

បន្ទាប់មក បន្តិចម្ដងៗ ទូលបង្គំក៏ចាប់ផ្ដើមកត់សម្គាល់អំពីទីកន្លែងដែលទូលបង្គំកំពុងនៅ ហើយទូលបង្គំក៏ប្រាថ្នាចង់ប្រាប់អំពីសេចក្ដីប្រាថ្នានានារបស់ទូលបង្គំទៅកាន់អស់អ្នកដែលនឹងធ្វើឲ្យពួកគេសប្បាយចិត្ត ប៉ុន្តែទូលបង្គំមិនអាចធ្វើបានឡើយ! ដ្បិតការប្រាថ្នារបស់ទូលបង្គំគឺនៅក្នុងទូលបង្គំ ហើយពួកគេនៅខាងក្រៅ ដូច្នេះពួកគេមិនមានអំណាចដោយខ្លួនឯងក្នុងការដឹងអំពីអ្វីដែលទូលបង្គំកំពុងគិតបានឡើយ។ ហេតុដូច្នេះហើយបានជាទូលបង្គំបម្រះដៃបម្រះជើង យំ ហើយធ្វើនូវអ្វីដែលទូលបង្គំអាចធ្វើបាន ដើម្បីប្រាប់ពួកគេអំពីអ្វីដែលទូលបង្គំចង់បាន។ តាមពិតទៅ ទូលបង្គំមិនអាចធ្វើឲ្យពួកគេយល់ច្រើនប៉ុន្មាននោះទេ ប៉ុន្តែទូលបង្គំក៏មិនខ្វល់ដែរ។ ប្រសិនបើពួកគេមិនស្ដាប់បង្គាប់ភ្លាមៗ នោះទំនងមកពីពួកគេមិនយល់ ឬក៏ដោយសារអ្វីដែលទូលបង្គំប្រាថ្នាចង់បានគឺមិនល្អសម្រាប់ទូលបង្គំទេ។ ប៉ុន្តែ ទូលបង្គំក៏តែងតែអាក់អន់ចិត្តជាមួយនឹងពួកចាស់ទុំទូលបង្គំដែលពួកគាត់មិនបានចុះចូលជាមួយទូលបង្គំ និងជាមួយនឹងអស់អ្នកដែលមិនបានចាំយាមទូលបង្គំហាក់បីដូចជាអ្នកបម្រើរបស់ទូលបង្គំ ទោះបើពួកគាត់មិនជំពាក់ការបម្រើអ្វីជាមួយនឹងទូលបង្គំក៏ដោយ។ ហើយនៅពេលដែលពួកគេមិនស្ដាប់ នោះទូលបង្គំតែងតែសងសឹកពួកគេតាមរយៈការយំទួញសម្រាប់ខ្លួនឯង។

ទូលបង្គំបានសង្កេតឃើញថា នេះឯងគឺជាអ្វីដែលទារកមាន។ ហើយដោយមិនដឹងខ្លួន ទារកមួយចំនួនដែលទូលបង្គំបានសង្កេតមើលក៏បានបង្ហាញអំពីសណ្ឋានជាទារករបស់ទូលបង្គំល្អប្រសើរជាងម៉ែដោះទូលបង្គំបានពណ៌នាទៅទៀត ដែលគាត់បានដកបទពិសោធន៍អំពីការទាំងនោះជាមួយនឹងទូលបង្គំផ្ទាល់។

៩. ភាពជាទារករបស់ទូលបង្គំបានស្លាប់ទៅជាយូរឆ្នាំមកហើយ ប៉ុន្តែទូលបង្គំនៅបន្តរស់នៅ។ ប៉ុន្តែ ឱព្រះអម្ចាស់អើយ! ទ្រង់មានព្រះជន្មគង់នៅអស់កល្បជានិច្ច ហើយក្នុងទ្រង់ក៏គ្មានអ្វីស្លាប់ដែរ ដ្បិតតាំងពីមុនមានផែនដីនេះ មុនមានរាល់គ្រប់អ្វីៗដែលយើង

ហៅថា «មុន» គឺមានព្រះអង្គរួចស្រេចទៅហើយ ហើយព្រះអង្គជាព្រះជាម្ចាស់ និងជាព្រះអម្ចាស់លើគ្រប់របស់សព្វសារពើផងដែរ។ ព្រះអង្គស្ថិតស្ថេរនៅ ហើយក៏មិនអាចមានការរង្គើយ៉ាងអស់កល្បជានិច្ចបានផងដែរ។ ព្រះអង្គគឺជាបុព្វហេតុដំបូងនៃរាល់របស់ដែលនៅបណ្តោះអាសន្ន។ ព្រះអង្គគឺជាប្រភពដែលមិនបំផ្លាស់បំប្រែនៃរាល់អ្វីៗដែលប្រែប្រួល។ ដូច្នេះ សូមទ្រង់មានព្រះបន្ទូលមកកាន់ទូលបង្គំ ឱព្រះអម្ចាស់ដែលពោរពេញទៅដោយសេចក្តីមេត្តាករុណាអើយ។ ក្នុងក្តីអាណិតអាសូរ សូមទ្រង់មានព្រះបន្ទូលមកកាន់ទូលបង្គំដែលជាមនុស្សដែលគួរឲ្យអាណិត។ សូមទ្រង់មានបន្ទូលមកទូលបង្គំ៖ តើមានពេលវេលាក្នុងជីវិតទូលបង្គំដែលបានកន្លងផុតទៅរួចទៅហើយ មុនពេលដែលទូលបង្គំមានសភាពជាទារកដែរឬទេ? តើកាលនោះជាពេលវេលាដែលទូលបង្គំបានចំណាយក្នុងផ្ទៃអ្នកម្តាយទូលបង្គំមែនឬ? ដ្បិតមានគេបានលើកឡើងអំពីចំណុចដូចនោះមកកាន់ទូលបង្គំ ហើយទូលបង្គំផ្ទាល់ក៏បានឃើញស្ត្រីដែលមានផ្ទៃពោះផងដែរ។ ប៉ុន្តែ ឱព្រះដ៏ជាអំណររបស់ទូលបង្គំអើយ! តើមានអ្វីកើតឡើងមុនកាលមានពេលវេលានៃជីវិតនោះដែរឬទេ? តើទូលបង្គំនៅទីណានៅពេលនោះ ឬក៏ជាបុគ្គលណាម្នាក់ដែរឬទេ? គ្មានអ្នកណាអាចពន្យល់អំពីចំណុចទាំងនេះមកកាន់ទូលបង្គំបានទេ សូម្បីតែឪពុកម្តាយទូលបង្គំក៏មិនអាចដែរ។ ទូលបង្គំមិនអាចសង្កេតមើលបទពិសោធន៍របស់អ្នកដទៃ ហើយទូលបង្គំក៏មិនមានការចងចាំផ្ទាល់ខ្លួនដែរ។ តើព្រះអង្គសើចដាក់ទូលបង្គំទាក់ទងនឹងអ្វីដែលទូលបង្គំកំពុងសួរដែរឬទេ? ឬក៏ថាព្រះអង្គគ្រាន់តែបញ្ជាឲ្យទូលបង្គំសរសើរ ហើយទទួលស្គាល់ព្រះអង្គទាក់ទងទៅនឹងអ្វីដែលទូលបង្គំដឹងមែនឬ?

១០. ឱព្រះអម្ចាស់នៃស្ថានសួគ៌ និងផែនដីអើយ! ទូលបង្គំសូមថ្លែងអំណរអរព្រះគុណដល់ទ្រង់ដោយសរសើរតម្កើងទ្រង់ ទាក់ទងនឹងចំណុចផ្តើមរបស់ទូលបង្គំ និងភាពជាទារករបស់ទូលបង្គំដែលទូលបង្គំមិនចងចាំ។ ដ្បិតព្រះអង្គបានប្រទានឲ្យមនុស្សយើងទទួលបានចំណេះដឹងអំពីខ្លួនឯងតាមរយៈការមើលទារកនានា ហើយឲ្យយើងអាចស្វែងរកបានចំណុចជាច្រើនអំពីខ្លួនឯងតាមរយៈអ្វីដែលស្ត្រីៗនិយាយ។ ប្រាកដណាស់! ទូលបង្គំមានជីវិត សូម្បីតែកាលនៅក្មេងប៉ុណ្ណឹង ហើយខណៈពេលដែលភាពជាទារករបស់ទូលបង្គំឈានដល់ទីបញ្ចប់ នោះទូលបង្គំក៏បានរៀនអំពីចំណុចសម្គាល់មួយចំនួនដែលទូលបង្គំអាចប្រើប្រាស់ក្នុងការប្រាប់អំពីអារម្មណ៍របស់ទូលបង្គំដល់អ្នកដទៃបាន។

ឱព្រះអម្ចាស់អើយ! តើមនុស្សបែបនេះអាចកើតចេញពីអ្នកណាបាន ក្រៅពីព្រះអង្គ? តើមានបុគ្គលណាប្រសព្វល្មមក្នុងការបង្កើតខ្លួនឯងដែរឬទេ? ឬក៏ថា មានប្រភពណាផ្សេងទៀតដែលការមានជីវិតអាចហូរចូលមកក្នុងយើងក្រៅពីព្រះអង្គមែនឬ? ឱព្រះអម្ចាស់អើយ! ទេ! មានតែក្នុងព្រះអង្គដែលជាប្រភព និងជាជីវិតមានការរួបរួមគ្នាបាន។ ដ្បិតព្រះអង្គគឺជាភាវៈ និងជាជីវិតដ៏ឧត្តុង្គឧត្តមផ្ទាល់ជាមួយគ្នាទាំងពីរ។ ព្រះអង្គគង់នៅរហូតអស់កល្បជានិច្ច ហើយក៏គ្មានការប្រែប្រួលដែរ។ ហើយបច្ចុប្បន្នកាលនៃថ្ងៃនេះក៏មិនដែលឈានដល់ទីបញ្ចប់សម្រាប់ព្រះអង្គដែរ។ ទោះជាយ៉ាងណាក្តី ដោយសារព្រះអង្គ រាល់ថ្ងៃក៏ឈានដល់ទីបញ្ចប់សម្រាប់យើង។ ថ្ងៃនីមួយៗរកទីបញ្ចប់របស់វាក្នុងព្រះអង្គ ដ្បិតវានឹងមិនអាចឈានដល់ទីបញ្ចប់បានឡើយ ប្រសិនបើទ្រង់មិនបានបញ្ជាវា។ ហើយដោយសារ «ព្រះជន្មរបស់ព្រះអង្គគ្មានទីបញ្ចប់»[៤] ព្រះជន្មរបស់ព្រះអង្គគឺជាបច្ចុប្បន្នកាលនៃរាល់ថ្ងៃជានិច្ច។ តើប៉ុន្មានថ្ងៃនៃថ្ងៃនានារបស់យើង និងថ្ងៃរបស់ព្ធយុកោរបស់យើងបានកន្លងផុតទៅក្នុង «ថ្ងៃនេះ» របស់ព្រះអង្គ? ប៉ុន្តែ «ព្រះអង្គនៅតែដដែល!»។[៥] ហើយក្នុងចន្លោះរាល់អ្វីៗនៅថ្ងៃស្អែក និងថ្ងៃដែលនឹងមកដល់ និងគ្រប់ចំណុចនៃថ្ងៃម្សិលមិញ និងថ្ងៃដែលបានកន្លងផុតទៅ គឺព្រះអង្គកំពុងតែស្ថិតនៅ។ រាល់គ្រប់អ្វីៗត្រូវបានសម្រេចឡើងក្នុងអំឡុង «ថ្ងៃនេះ» របស់ព្រះអង្គ។ តើចំពោះទូលបង្គំ វាជាអ្វីទៅ ប្រសិនបើបុគ្គលណាម្នាក់មិនយល់អំពីចំណុចនេះ? សូមអនុញ្ញាតឲ្យគាត់នៅបន្តមានអំណរ ហើយបន្តសួរថា «តើនេះជាអ្វីទៅ?» សូមអនុញ្ញាតឲ្យគាត់មានអំណរ ហើយបន្តជ្រើសរើសស្វែងរកព្រះអង្គ ទោះបើគាត់នឹងបរាជ័យក្នុងការរកឃើញចម្លើយក៏ដោយ ជាជាងឲ្យគាត់រកបានចម្លើយ ប៉ុន្តែមិនបានរកឃើញទ្រង់!

៤ ទំនុកតម្កើង ១០២:២៧។
៥ ទំនុកតម្កើង ១០២:២៧។

# ៣

# បទពិសោធន៍នៃការជិតស្លាប់

១៧. កាលទូលបង្គំនៅជាកុមារនៅឡើយ ទូលបង្គំបានឮអំពីសេចក្ដីសន្យានៃជីវិតដ៏នៅអស់កល្បជានិច្ចដែលបានធ្វើឡើងមកកាន់យើងតាមរយៈការបន្ទាបខ្លួននៃព្រះអម្ចាស់ដ៏ជាព្រះនៃយើង។ ព្រះអង្គបានយាងមកលេងយើងពេលយើងកំពុងមានអំនួត។ ទូលបង្គំបានទទួលស្នាមនៃទីសម្គាល់នៃឈើឆ្កាងរបស់ព្រះអង្គ ហើយទូលបង្គំក៏ត្រូវបាន "ប្រឡាក់" ដោយអំបិលរបស់ទ្រង់[១] បន្ទាប់ពីទូលបង្គំបានចេញពីផ្ទៃអ្នកម្ដាយទូលបង្គំមក។ គាត់បានទុកចិត្តលើព្រះអង្គយ៉ាងខ្លាំងក្លា។

ឱព្រះអម្ចាស់អើយ! ទ្រង់បានទតឃើញហើយអំពីកាលមួយដែលទូលបង្គំនៅជា

១ ត្រង់នេះលោកគ្រូ អហ្គុស្ទីន កំពុងតែសំដៅទៅលើប្រពៃណីក្នុងក្រុមជំនុំសម័យដំបូងដែលពួកសង្ឃគូសឈើឆ្កាងលើក្បាលទារកដែលទើបនឹងកើត ហើយដាក់អំបិលក្នុងមាត់របស់ពួកគេដែលជាទីសម្គាល់អំពីការដែលឪពុកម្ដាយថ្វាយទារកនោះទៅកាន់ព្រះអម្ចាស់។

កុមារនៅឡើយ ភ្លាមៗនោះទូលបង្គំបានឈឺក្រពះយ៉ាងខ្លាំង ហើយក៏ជិតស្លាប់ទៀតផង។ ព្រះអង្គទតឃើញ ដ្បិតសូម្បីតែកាលនោះក៏ព្រះគឺជាអង្គដែលបានរក្សាទូលបង្គំផងដែរ និងអំពីរបៀបដ៏មឺងម៉ាត់ជាមួយជំនឿដែលទូលបង្គំបានទាមទារពិធីជ្រមុជទឹកក្នុងព្រះគ្រីស្ទរបស់ព្រះអង្គ ដ្បិតទ្រង់គឺជាព្រះអម្ចាស់ និងជាព្រះជាម្ចាស់របស់ទូលបង្គំ។ ទូលបង្គំទាមទារធ្វើការនោះ ក្នុងនាមជាតួនាទីរបស់អ្នកម្ដាយទូលបង្គំទៅកាន់ព្រះអង្គ និងជាតួនាទីនៃក្រុមជំនុំរបស់ទ្រង់ ដែលជាមាតារបស់យើងទាំងអស់គ្នា។ អ្នកម្ដាយខាងឯសាច់ឈាមរបស់ទូលបង្គំបានភ័យព្រួយយ៉ាងខ្លាំង ដ្បិតដោយចិត្តបរិសុទ្ធ និងជំនឿក្នុងទ្រង់គាត់តែងតែប្រាថ្នាចង់ឲ្យទូលបង្គំទទួលបានជីវិតដ៏នៅអស់កល្បជានិច្ចតាមរយៈសេចក្ដីសង្គ្រោះ។ ឱព្រះអម្ចាស់យេស៊ូវអើយ! គាត់ទំនងនឹងរៀបចំយ៉ាងប្រញាប់ប្រញាល់សម្រាប់ទូលបង្គំក្នុងការទទួលពិធី និងសម្អាតដោយពិធីបង្ហូរព្រះគុណដែលនឹងប្រទានជីវិតពីព្រះអង្គ ប្រសិនបើទូលបង្គំបានលន់តួទៅកាន់ទ្រង់សម្រាប់ជាការអត់ទោសបាប។ ប៉ុន្តែ ទូលបង្គំបានជាសះស្បើយយ៉ាងរហ័សពីការឈឺក្រពះ ដូច្នេះហើយបានជាការជ្រមុជទឹករបស់ទូលបង្គំក៏ត្រូវបានទទួលការពន្យារពេល។ ពួកគេបានពន្យារពេលការសម្អាតរបស់ទូលបង្គំដោយសារពួកគេជឿថាទូលបង្គំនឹងកាន់តែប្រឡូកប្រឡាក់លើសដើម ហើយក៏នឹងកាន់តែពង្រីកពិរុទ្ធភាពរបស់ខ្លួន តាមរយៈការរស់នៅក្នុងជីវិតនៃអំពើបាប បន្ទាប់ពីទទួលពិធីជ្រមុជទឹក។

នៅពេលនោះ នេះឯងគឺជាអ្វីដែលទូលបង្គំជឿជាមួយនឹងអ្នកម្ដាយទូលបង្គំ និងអ្នកផ្ទះទូលបង្គំទាំងមូល លើកលែងតែឪពុកទូលបង្គំ។ ប៉ុន្តែ គាត់មិនបានយកឈ្នះលើឥទ្ធិពលនៃភក្ដីភាពរបស់អ្នកម្ដាយទូលបង្គំទៅកាន់ព្រះអង្គក្នុងទូលបង្គំ ហើយគាត់ក៏មិនបានរារាំងជំនឿរបស់ទូលបង្គំលើព្រះគ្រីស្ទផងដែរ ទោះបើគាត់មិនទាន់ទទួលជឿលើទ្រង់នៅឡើយកាលនោះ។ ឱព្រះជាម្ចាស់អើយ! ដ្បិតវាគឺជាសេចក្ដីប្រាថ្នារបស់អ្នកម្ដាយទូលបង្គំត្រង់ថាឲ្យទូលបង្គំទទួលស្គាល់ថាព្រះអង្គគឺជាព្រះវរបិតានៃទូលបង្គំ ជាជាងទទួលស្គាល់ឪពុកខាងឯសាច់ឈាមរបស់ទូលបង្គំថាជាឪពុកខ្លួន។ ក្នុងចំណុចនេះ ព្រះអង្គបានជួយអ្នកម្ដាយទូលបង្គំក្នុងការយកឈ្នះលើឪពុកទូលបង្គំ ដែលទោះបើលក្ខណសម្បត្តិអ្នកម្ដាយទូលបង្គំល្អជាងឪពុកទូលបង្គំក៏អ្នកម្ដាយទូលបង្គំនៅតែស្ដាប់បង្គាប់។ ក្នុងរបៀបនេះអ្នកម្ដាយទូលបង្គំក៏បានស្ដាប់បង្គាប់ផងដែរ ពីព្រោះនេះហើយគឺជាអ្វីដែលទ្រង់បានបញ្ជា។

១៨. ឱព្រះជាម្ចាស់អើយ! ទូលបង្គំសូមសួរទ្រង់ ហើយសូមប្រាប់ទូលបង្គំផង ប្រសិនបើទ្រង់សព្វព្រះហឫទ័យៈ តើហេតុអ្វីបានជាពិធីជ្រមុជទឹករបស់ទូលបង្គំមានការពន្យារពេលអញ្ចឹង? តើវាពិតជាសម្រាប់ប្រយោជន៍ទូលបង្គំមែនឬត្រង់ថា ការរារាំងក្នុងការប្រព្រឹត្តអំពើបាបក្នុងជីវិតទូលបង្គំមានការបន្ធូរ ដើម្បីឲ្យទូលបង្គំកាន់តែមានសេរីភាពក្នុងការធ្វើបាប? ឬក៏ថា វាគ្មានការបន្ធូរទេ? ប្រសិនបើទេ ចុះហេតុអ្វីបានជាមនុស្សម្នានិយាយថា សូម្បីតែមកដល់សព្វថ្ងៃនេះ «ឲ្យវានៅតែឯងទៅ។ ឲ្យវាធ្វើតាមតែអំពើចិត្តវាចុះ ដ្បិតវាមិនទាន់ទទួលពិធីជ្រមុជទឹកនៅឡើយទេ?»។ ទាក់ទងនឹងសុខភាពខាងឯសាច់ឈាម គ្មាននរណាម្នាក់និយាយថា «ឲ្យវានៅតែឯងទៅ។ ឲ្យវាឈឺលើសដើមចុះ ដ្បិតវាមិនអាចទទួលបានការព្យាបាលទេ!»។ តើវានឹងល្អប្រសើរខ្លាំងប៉ុណ្ណាទៅ បើកាលនោះទូលបង្គំទទួលបានការព្យាបាលទាំងស្រុង? បើដូច្នោះមែន នោះសុខភាពនៃព្រលឹងវិញ្ញាណទូលបង្គំនឹងមានសន្តិភាពក្រោមការការពាររបស់ទ្រង់ជាមិនខាន។ ហើយតាមរយៈការយកចិត្តទុកដាក់ដ៏ប្រុងប្រយ័ត្នពីមិត្តភក្តិទូលបង្គំ និងទូលបង្គំផ្ទាល់ នោះព្រះអង្គនឹងប្រាកដជាបានការពារទូលបង្គំ ហើយជួយទូលបង្គំក្នុងការលូតលាស់ពេញវ័យឡើង។ ប្រាកដណាស់! នេះទំនងជាល្អប្រសើរយ៉ាងខ្លាំងហើយ។ ប៉ុន្តែ មានរលកនៃសេចក្តីល្បួងជាច្រើន ហើយយ៉ាងខ្លាំងផងដែរដែលបានមកគំរាមកំហែងទូលបង្គំ ខណៈពេលដែលទូលបង្គំកំពុងតែធំធាត់ឡើងចេញពីកុមារភាព! អ្នកម្តាយទូលបង្គំបានឃើញអំពីចំណុចនេះជាមុន។ ផ្ទុយទៅវិញ គាត់បានជ្រើសរើសដោយអនុញ្ញាតឲ្យទូលបង្គំប្រឈមមុខនឹងសេចក្តីល្បួង ខណៈពេលដែលដីឥដ្ឋនៅទន់នៅឡើយ ជាជាងប្រថុយឲ្យដីឥដ្ឋដែលត្រូវបានសូន្យឡើងក្នុងរូបអង្គនៃព្រះគ្រីស្ទ។[២]

៣០. ទាំងនេះគឺជាប្រពៃណីក្នុងសម័យដែលទូលបង្គំបានធំធាត់ឡើង ហើយទូលបង្គំក៏ជាកុមារដែលមិនសប្បាយចិត្តដែរ។ ទូលបង្គំមានការភ័យខ្លាចយ៉ាងខ្លាំងក្នុងការនិយាយមិនត្រូវខ្លាំងជាងក្នុងការច្រណែនអស់អ្នកដែលមិនបានធ្វើខុសដូចដែលទូលបង្គំបានធ្វើ។

ឱព្រះជាម្ចាស់អើយ! ទាំងនេះទូលបង្គំសូមប្រកាស ហើយលន់តួទៅកាន់ទ្រង់។ លោកីយ៍នេះកោតសរសើរទូលបង្គំ ដ្បិតទូលបង្គំគិតថា វាផ្តល់កិត្តិយសដល់ទូលបង្គំ

២ ត្រង់នេះលោកគ្រូ អហ្គូស្ទីន កំពុងតែរៀបរាប់អំពីសភាពនៃការមិនទាន់ទទួលបានការបំផ្លាស់បំប្រែរបស់គាត់ ពេលដែលព្រះជាម្ចាស់មិនទាន់បានបំផ្លាស់បំប្រែលោកគ្រូ អហ្គូស្ទីន ឲ្យមានរូបអង្គដូចព្រះគ្រីស្ទ ដូចដែលទ្រង់ធ្វើចំពោះអស់អ្នកដែលបានកើតជាថ្មី (រ៉ូម ៨:២៩)។

ក្នុងការផ្គាប់ចិត្តវា។ ពីព្រោះទូលបង្គំមិនឃើញជង្ហុកដ៏ធំនៃអំពើអាក្រក់ ដែលទូលបង្គំបានធ្លាក់ចូលដោយទូលបង្គំត្រូវបានបោះចោលចេញពីព្រះនេត្ររបស់ទ្រង់។

ដ្បិតចំពោះព្រះនេត្ររបស់ព្រះអង្គ តើឲ្យទូលបង្គំអាចព្រហើនខ្លាំងជាងកម្រិតដែលទូលបង្គំកំពុងតែព្រហើនរួចស្រេចទៅហើយបានដោយរបៀបណាទៅ? ទូលបង្គំថែមទាំងធ្វើឲ្យមនុស្សដូចទូលបង្គំខូចចិត្ត។ ហើយទូលបង្គំបោកបញ្ឆោតគ្រូបង្រៀន ចៅហ្វាយ និងឪពុកម្ដាយទូលបង្គំដោយសារទូលបង្គំស្រឡាញ់ការលេងសើច។ ទូលបង្គំចូលចិត្តមើលការសម្ដែងដ៏ល្ងីល្ងើ ហើយទូលបង្គំក៏មានទឹកចិត្តប្រាថ្នាយ៉ាងខ្លាំងចង់ត្រាប់តាមតួសម្ដែង។ ទូលបង្គំបានលួចស្រា និងម្ហូបរបស់ឪពុកម្ដាយទូលបង្គំ ពេលខ្លះគឺដោយសារទូលបង្គំល្មោភស៊ី ពេលខ្លះគឺគ្រាន់តែ ដើម្បីឲ្យមានអ្វីដោះដូរជាមួយនឹងកុមារឯទៀតៗសម្រាប់ជារបស់លេង ដែលពួកគេបានត្រៀមចិត្តលក់ ទោះបើពួកគេចូលចិត្តរបស់ទាំងនោះដូចទូលបង្គំចូលចិត្តក៏ដោយ។ លើសពីនោះទៅទៀត ក្នុងល្បែងទាំងនេះ ជាទូទៅទូលបង្គំយកឈ្នះតាមរបៀបមិនត្រឹមត្រូវ ពីព្រោះទូលបង្គំចាញ់សេចក្ដីប្រាថ្នាដ៏ឥតប្រយោជន៍ក្នុងការចង់ធ្វើជាមនុស្សទី១។ ប៉ុន្តែ ទូលបង្គំមិនអត់ទ្រាំនឹងបុគ្គលណាដែលមិនប្រព្រឹត្តតាមច្បាប់ឡើយ ទោះបើទូលបង្គំផ្ទាល់មិនប្រព្រឹត្តតាមច្បាប់ក៏ដោយ។ ហើយប្រសិនបើទូលបង្គំចាប់បាននរណាម្នាក់ដែលលេងខូចគេ នោះទូលបង្គំនិងចោទប្រកាន់ពួកគេយ៉ាងខ្លាំង។ ប៉ុន្តែ ប្រសិនបើនរណាម្នាក់ចោទទូលបង្គំថាបានលេងខូចគេ នោះទូលបង្គំនឹងប្រកែកតវ៉ាប្រឆាំងនឹងការចោទប្រកាន់របស់ពួកគេ ជាជាងទទួលស្គាល់កំហុសរបស់ខ្លួន។

តើនេះជាភាពគ្មានកំហុសរបស់កុមារភាពមែនឬ? វាមិនមែនទេ ឱព្រះអម្ចាស់អើយ វាមិនមែនទេ។ ឱព្រះជាម្ចាស់អើយ! ទូលបង្គំអង្វរសូមសេចក្ដីមេត្តាករុណារបស់ទ្រង់ ដ្បិតអំពើបាបដូចនោះក៏កាន់តែទុំជាងមុន ខណៈពេលដែលយើងធំធាត់ឡើង។ អំពើបាបទាស់នឹងគ្រូបង្រៀន និងចៅហ្វាយ ដែលមានរួមដូចជាគ្រាប់សណ្ដែក បាល់ និងចាប បានក្លាយទៅជាអំពើបាបទាស់នឹងរាជរដ្ឋាភិបាល និងស្ដេច ដែលមានរួមដូចជាមាសប្រាក់ ទឹកដី និងអ្នកបម្រើ។ មនុស្សពេញវ័យទទួលទារុណកម្មខ្លាំងជាងគ្រាន់តែការវាយនឹងព្រនង់។ កាលនោះគឺមិនមែនជាអំពើដូចនេះ ប៉ុន្តែផ្ទុយទៅវិញគឺជាការបន្ទាបខ្លួននៃភាពជាកុមារ ដែលទ្រង់ដ៏ជាស្ដេចរបស់យើង ទទួលស្គាល់ថាជាទីសម្គាល់នៃការបន្ទាបខ្លួននៅពេលដែលព្រះអង្គមានព្រះបន្ទូលថា “នគរស្ថានសួគ៌ជារបស់មនុស្សដូច

ក្មេងៗទាំងនេះឯង»។[៣]

៣១. ឱព្រះអម្ចាស់អើយ! ទោះជាយ៉ាងណាក្ដី ទោះបើទ្រង់មិនបានគ្រោងទុកឲ្យទូលបង្គំនៅរស់ដោយឆ្លងកាត់ភាពជាកុមារក៏ដោយ ក៏ព្រះអង្គនៅតែស័ក្ដិសមក្នុងការទទួលការថ្លែងអំណរគុណផងដែរ។ ដ្បិតទ្រង់គឺជាព្រះអាទិករ និងព្រះដែលគ្រងរាជ្យលើចក្រវាល ព្រះអង្គគឺជាព្រះដ៏ឧត្ដុង្គឧត្ដម និងល្អជាងគេបំផុត។ ដ្បិតសូម្បីតែកាលទូលបង្គំនៅជាកុមារក៏ទូលបង្គំមានជីវិត ហើយមានសមត្ថភាពក្នុងការមានអារម្មណ៍។ ទូលបង្គំមានសភាវគតិក្នុងការរក្សាឲ្យខ្លួនឯងមានសុវត្ថិភាព ដែលនោះគឺជាការឆ្លុះបញ្ចាំងរបស់ព្រះជាម្ចាស់ដែលទូលបង្គំទទួលបានជីវិត។[៤] ភាពខាងក្នុងរបស់ទូលបង្គំបានភ្លក់រសជាតិនៃភាពស្មោះត្រង់នៃអ្វីដែលភាពខាងក្រៅរបស់ទូលបង្គំបានកត់សម្គាល់។ ហើយទោះបើក្នុងគំនិតដ៏តូចតាចនេះដែលធ្វើឲ្យទូលបង្គំចាប់អារម្មណ៍ ក៏ទូលបង្គំរៀនចេះអរសប្បាយជាមួយនឹងសេចក្ដីពិត ហើយទូលបង្គំស្អប់ណាស់ពេលគេបោកប្រាស់ទូលបង្គំ។ ព្រះអង្គបានប្រទានដល់ទូលបង្គំឲ្យមានការចងចាំយ៉ាងល្អ ហើយក៏មានភាពពូកែខាងវោហារផងដែរ។ ទូលបង្គំក៏ទទួលបានព្រះពរតាមរយៈមិត្តភក្ដិផងដែរ ហើយទូលបង្គំក៏បានព្យាយាមគេចចេញពីការឈឺចាប់ ទុក្ខព្រួយ និងភាពអវិជ្ជា។

ក្នុងនាមជាស្នាព្រះហស្តដ៏តូចតាច តើទូលបង្គំមិនបានរស់នៅយ៉ាងល្អប្រសើរ ហើយមានជីវិតដែលគួរឲ្យសរសើរមែនឬ? ប៉ុន្តែ ទូលបង្គំមិនអាចទទួលយកផ្នែកណាមួយនៃកិត្តិយសនេះបានទេ ដ្បិតអ្វីទាំងអស់នោះគឺជាអំណោយទានមកពីព្រះជាម្ចាស់នៃទូលបង្គំ! ទូលបង្គំមិនបានផ្ដល់អំណោយទានទាំងនេះដល់ខ្លួនឯងផ្ទាល់ឡើយ។ អំណោយទានរបស់ព្រះអង្គគឺសុទ្ធតែល្អៗ ហើយផលសរុបអំពីវាគឺជារាល់ចំណុចនៃសមត្ថភាពរបស់ទូលបង្គំ។ ដូច្នេះដាច់ខាត ព្រះជាម្ចាស់ដែលបានបង្កើតទូលបង្គំគឺត្រូវតែជាព្រះដ៏ល្អ ហើយរាល់គ្រប់អ្វីៗដែលល្អនៅក្នុងទូលបង្គំគឺជារបស់ទ្រង់។ ហើយទូលបង្គំសូមសរសើរតម្កើងព្រះអង្គសម្រាប់រាល់អំណោយទានដែលល្អដែលទូលបង្គំមាន សូម្បីតែខណៈពេលដែលទូលបង្គំនៅជាកុមារក៏ដោយ។ ប៉ុន្តែ នេះគឺជាអំពើបាបរបស់ទូលបង្គំ៖ ទូលបង្គំបានស្វែងរកភាពអរសប្បាយ កិត្តិយស និងសេចក្ដីពិតក្នុងរបស់សព្វសាររពើរបស់ទ្រង់ ជាជាងក្នុង

---

៣ ម៉ាថាយ ១៩:១៤ (គគខ)។

៤ ត្រង់នេះលោកគ្រូ អហ្គូស្ទីន កំពុងស្វែងយល់អំពីវិសាលភាពនៃភាពជាមនុស្សមានបាបថា តើយើងមានសមត្ថភាពក្នុងការមានចំណែកក្នុងលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ដល់កម្រិតណា។

ទ្រង់ផ្ទាល់។ ហេតុដូច្នេះហើយបានជាទូលបង្គំធ្លាក់ក្នុងទុក្ខព្រួយ មានបញ្ហា និងកំហុសខុសឆ្គង។ ប៉ុន្តែ ទូលបង្គំសូមអរព្រះគុណទ្រង់ដែលទ្រង់គឺជាអំណារ ជាអំនួត ជាទំនុកចិត្ត និងជាព្រះជាម្ចាស់របស់ទូលបង្គំ។ សូមអរព្រះគុណទ្រង់សម្រាប់អំណោយទាននានារបស់ព្រះអង្គ។ ប៉ុន្តែ ព្រះអង្គត្រូវតែរក្សាវាសម្រាប់ទូលបង្គំ ហើយតាមរយៈការដែលព្រះអង្គធ្វើដូច្នោះ នោះទ្រង់ក៏នឹងរក្សាទូលបង្គំ ហើយរាល់ចំណុចទាំងនោះដែលទ្រង់បានប្រទានមកក៏នឹងទទួលបានការអភិវឌ្ឍន៍ និងការពេញខ្នាត។ ហើយទូលបង្គំផ្ទាល់ក៏នឹងនៅជាមួយព្រះអង្គ ដ្បិតព្រះអង្គគឺជាមូលហេតុដែលទូលបង្គំមានជីវិត។

សៀវភៅទី២

# ៤

# ការលួចផ្លែពែរ

១. ឥឡូវទូលបង្គំប្រាថ្នាចង់រម្លឹកអំពីអំពើអាក្រក់ពីអតីតកាលរបស់ទូលបង្គំ និងអំពីភាពពុករលួយខាងឯសាច់ឈាមនៃព្រលឹងទូលបង្គំ—មិនមែនដោយសារទូលបង្គំនៅស្រឡាញ់អំពើបាបទាំងនោះទេ ប៉ុន្តែគឺដើម្បីឲ្យទូលបង្គំស្រឡាញ់ព្រះអង្គដ៏ជាព្រះជាម្ចាស់របស់ទូលបង្គំវិញ។ ទូលបង្គំធ្វើបែបនេះដោយសារទូលបង្គំស្រឡាញ់ការស្រឡាញ់ព្រះអង្គ។ ក្នុងភាពល្វីងជូរចត់ ទូលបង្គំរម្លឹកអំពីផ្លូវដ៏អាក្រក់របស់ទូលបង្គំ ដើម្បីឲ្យព្រះអង្គកាន់តែក្លាយជាភាពផ្អែមល្ហែមចំពោះទូលបង្គំ។ ដ្បិតទ្រង់ជាភាពផ្អែមល្ហែមដែលគ្មានការបោកប្រាស់ទេ!

កាលទូលបង្គំនៅវ័យជំទង់នៅឡើយ ទូលបង្គំប្រាថ្នាចង់ទទួលបានការស្កប់ចិត្តជាមួយអ្វីៗដែលមានក្នុងលោកីយ៍នេះណាស់ ហើយទូលបង្គំក៏មានពេញទៅដោយឈាមរាវដែរ។ ក្នុងព្រះនេត្ររបស់ទ្រង់ ទូលបង្គំបានក្លាយជាពុករលួយ ប៉ុន្តែក្នុងចិត្តគំនិតទូលបង្គំ ទូលបង្គំនៅចូលចិត្តខ្លួនឯង—ហើយទូលបង្គំចង់ផ្គាប់ចិត្តអស់អ្នកដែលនៅជុំវិញទូលបង្គំ។

២. ទូលបង្គំមិនប្រាថ្នាចង់បានអ្វីក្រៅពីការស្រឡាញ់អ្នកដទៃ និងឲ្យអ្នកដទៃស្រឡាញ់ទូលបង្គំឡើយ។ ប៉ុន្តែ សេចក្តីស្រឡាញ់របស់ទូលបង្គំបានឈានហួសពីមិត្តភាព។ ផ្ទុយ

ទៅវិញ ចំហាយនៃតណ្ហាក៏បានពុះកញ្ជ្រោលឡើងចេញពីភាពត្រេកត្រអាលខាងឯសាច់ឈាម ហើយការស្រមៃដ៏ស្រើបស្រាលនៃភាពពេញវ័យ ហើយវាធ្វើឲ្យដួងចិត្តរបស់ទូលបង្គំមានភាពស្រពិចស្រពិលដល់ថ្នាក់ថា ទូលបង្គំលែងមានសមត្ថភាពក្នុងការវែកញែករវាងសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ និងភាពស្រើបស្រាលដែលមិនបរិសុទ្ធ។ ទូលបង្គំត្រូវបានជ្រុលធ្លាក់ចេញពីច្រាំងថ្មដ៏ចោទនៃសេចក្តីប្រាថ្នាដែលមានពេញទៅដោយអំពើបាប ហើយក៏បានធ្លាក់ចូលទៅក្នុងឈូងនៃភាពអាម៉ាស់។ សេចក្តីក្រោធរបស់ទ្រង់ក៏បានធ្លាក់លើទូលបង្គំ ប៉ុន្តែទូលបង្គំមិនបានដឹងទេ។ ទូលបង្គំក៏បានត្រឡប់ជាថ្លង់ ដោយសារសំឡេងច្រាវៗនៃច្រវាក់នៃសេចក្តីស្លាប់ ដែលជាទារុណកម្មសម្រាប់សេចក្តីអំនួតនៃព្រលឹងរបស់ទូលបង្គំ ហើយទូលបង្គំក៏កាន់តែឃ្លាតឆ្ងាយថែមទៀតចេញពីព្រះអង្គ ហើយព្រះអង្គក៏បានអនុញ្ញាតឲ្យទូលបង្គំធ្វើដូចនោះដែរ។ ក្នុងសមុទ្រនៃអំពើផិតក្បត់របស់ទូលបង្គំ ទូលបង្គំក៏ត្រូវបានផាត់ចុះផាត់ឡើង—ហើយទ្រង់ក៏មិនបានមានបន្ទូលអ្វីដែរ។ ពេលវេលាបានកន្លងផុតយូរពេកមុននឹងទូលបង្គំដឹងថា ព្រះអង្គគឺជាអំណរដ៏ពិតរបស់ទូលបង្គំ! កាលនោះព្រះអង្គនៅស្ងាត់ស្ងៀមមិនមានបន្ទូលអ្វីទេ ហើយក្នុងអំនួតរបស់ទូលបង្គំ នោះទូលបង្គំក៏កាន់តែឃ្លាតឆ្ងាយថែមទៀតចេញពីព្រះអង្គបន្តិចម្តងៗ។ ការនោះចេះតែនាំមកនូវការរងទុក្ខ និងទុក្ខព្រួយបន្ថែមទៀតដល់ទូលបង្គំ។

៤. កាលនោះទូលបង្គំជាមនុស្សដ៏ល្ងីល្ងើ ដ្បិតទូលបង្គំបន្តសប្បាយរីករាយក្នុងអំពើអាក្រក់របស់ទូលបង្គំ។ ប៉ុន្តែ ទូលបង្គំមិនបានគេចផុតចេញពីទារុណកម្មរបស់ព្រះអង្គទេ។ ដ្បិតតើមនុស្សដែលតែងនឹងស្លាប់ណាម្នាក់អាចគេចផុតបាន? ព្រះអង្គតែងតែគង់នៅកៀកបង្កើយនឹងទូលបង្គំ ហើយទ្រង់បានពេញដោយសេចក្តីក្រោធដែលមានពេញទៅដោយសេចក្តីមេត្តាករុណាស្របពេលនោះដែរ ទ្រង់តែងតែបន្ថែមរសជាតិល្វីងជូរចត់នៃភាពមិនចេះស្កប់ចិត្តឲ្យចូលទៅសេចក្តីអំណរទទឹងច្បាប់របស់ទូលបង្គំ។ ព្រះអង្គធ្វើបែបនោះ ដើម្បីឲ្យទូលបង្គំអាចនឹងស្វែងរកភាពអរសប្បាយដ៏ពិត ដែលមានសេរីភាពចេញពីការមិនស្កប់ចិត្ត។ ប៉ុន្តែ តើឲ្យទូលបង្គំអាចស្វែងរកភាពអរសប្បាយដូចនោះនៅឯណាបានលើកលែងតែនៅក្នុងទ្រង់ ឱព្រះអម្ចាស់អើយ—គឺមានតែនៅក្នុងទ្រង់ប៉ុណ្ណោះ។ តាមរយៈទុក្ខព្រួយ ព្រះអង្គបង្រៀនយើង។ ព្រះអង្គធ្វើឲ្យយើងត្រូវរបួស ដើម្បីព្យាបាលយើង ហើយទ្រង់សម្លាប់យើង ដើម្បីកុំឲ្យយើងស្លាប់ដោយគ្មានព្រះអង្គ។

៥. កាលទូលបង្គំមានអាយុ១៦ឆ្នាំ ការសិក្សារបស់ទូលបង្គំក៏ត្រូវមានការអាក់ខាន។ ពេលនោះទូលបង្គំទើបតែត្រឡប់មកពី ម៉ាឌូរ៉ា វិញដែលជាទីក្រុងនៅជិតកន្លែងដែលទូលបង្គំបានធំធាត់ឡើង[១]ដែលទូលបង្គំបានទៅសិក្សាវេយ្យាករណ៍ និងវោហារសាស្ត្រ។ ប៉ុន្តែទូលបង្គំត្រឡប់មកផ្ទះវិញ ខណៈពេលដែលឪពុកទូលបង្គំបានសន្សំលុយដែលយើងត្រូវការមាន ដើម្បីបញ្ជូនឲ្យទូលបង្គំទៅសិក្សានៅឯទីក្រុងកាតផេ (Carthage)។

តើទូលបង្គំកំពុងតែប្រាប់ដំណើររឿងនេះទៅកាន់អ្នកណា? មិនមែនទៅកាន់ទ្រង់ដែលជាព្រះជាម្ចាស់នៃទូលបង្គំទេ ប៉ុន្តែទៅកាន់មនុស្សដូចទូលបង្គំក្នុងព្រះវត្តមានរបស់ព្រះអង្គវិញ—គឺទៅកាន់ភាគរយនៃមនុស្សជាតិដ៏តូចមួយដែលទំនងនឹងអានសៀវភៅមួយនេះ។ ហើយទូលបង្គំរៀបរាប់ប្រាប់ផ្នែកនៃដំណើររឿងនៃជីវិតនេះគឺ ដើម្បីឲ្យទូលបង្គំ និងអស់អ្នកដែលនឹងអានពាក្យពេចន៍នៃសៀវភៅនេះទំនងជាយល់អំពីជម្រៅដែលយើងត្រូវស្រែកចេញពីទៅកាន់ព្រះអង្គ។[២] គ្មានអ្វីដែលព្រះអង្គព្រះសណ្ដាប់ឮបានយ៉ាងច្បាស់ជាងដួងចិត្តដែលលន់តួ និងជីវិតដែលស្មោះត្រង់ទេ។

គ្រប់គ្នាសរសើរឪពុករបស់ទូលបង្គំ ពីព្រោះគាត់បានធ្វើលើសពីសមត្ថភាពរបស់គាត់ក្នុងការផ្គត់ផ្គង់ដល់កូនប្រុសរបស់គាត់ឲ្យមានថវិកាគ្រប់គ្រាន់ក្នុងការធ្វើដំណើរដ៏ឆ្ងាយ ដើម្បីបំពេញចំណាប់អារម្មណ៍លើការសិក្សារបស់គាត់។ ដ្បិតអ្នកមានលើសជាងគាត់ទៅទៀតមិនបានធ្វើបែបនោះសម្រាប់កូនៗរបស់ពួកគេទេ។ ទោះជាយ៉ាងណាក្ដីក៏ឪពុករបស់ទូលបង្គំមិនបានរវីរវល់ខ្លួនទាល់តែសោះទាក់ទងត្រង់ថា៖ តើទូលបង្គំកំពុងធ្វើដំណើរដល់ដំណាក់កាលណាឆ្ពោះទៅរកព្រះអង្គ ឬក៏ថាទូលបង្គំកំពុងរស់នៅយ៉ាងបរិសុទ្ធដោយរបៀបណា ពោលគឺគាត់ខ្វល់ខ្វាយតែត្រង់ថា តើទូលបង្គំមានទេពកោសល្យខ្លាំងប៉ុណ្ណាក្នុងវោហារសាស្ត្រ។

៦. កាលទូលបង្គំមានអាយុ១៦ឆ្នាំ ក្នុងអំឡុងពេលនៃឆ្នាំនោះទូលបង្គំបានរស់នៅជាមួយនឹងឪពុកម្ដាយទូលបង្គំ ដោយសារឈប់សម្រាកពីសាលាមួយរយៈ—ទូលបង្គំមានពេលវេលាទំនេរនៅពេលនោះដោយសារឪពុកម្ដាយទូលបង្គំខ្វះខាតផ្នែកថវិកា។ ហើយគុម្ពបន្លានៃភាពត្រេកត្រអាលក៏បានដុះឡើងក្នុងខួរក្បាលរបស់ទូលបង្គំ ហើយក៏គ្មានដៃ

---

១ ប្រមាណជាង ៣២គ.ម ពីស្រុក ធាហ្គាស្តេ (Tagaste) ដែលជាស្រុកកំណើតរបស់លោកគ្រូ អហ្គូស្ទីន។

២ ទំនុកតម្កើង ១៣០:១—និងជាប្រយោគដ៏ចំៗដែលយើងមានពីលោកគ្រូ អហ្គូស្ទីន ទាក់ទងនឹងការជំរុញចិត្ត និងគោលបំណងរបស់គាត់ក្នុងការសរសេរសៀវភៅ “ការលន់តួ” មួយនេះ។

ណាមកដកវាចេញដែរ។ ប្រាកដណាស់! ពេលដែលឪពុកទូលបង្គំបានឃើញទូលបង្គំកំពុងងូតទឹកនាថ្ងៃមួយ ហើយយល់ឃើញថាទូលបង្គំកំពុងតែពេញកំលោះ គាត់ក៏បានប្រាប់អ្នកម្ដាយទូលបង្គំដោយមានអំណរយ៉ាងខ្លាំង ហាក់បីដូចជាថាគាត់កំពុងតែទន្ទឹងរង់ចាំចង់បានចៅៗអញ្ចឹង។ ការពេញចិត្តរបស់គាត់គឺដូចគ្នាទៅនឹងការស្រវឹងស្រា ដែលធ្វើឲ្យលោកីយ៍ភ្លេចអំពីព្រះអង្គ ដែលជាព្រះអាទិករ ហើយស្រឡាញ់អ្វីៗដែលទ្រង់បានបង្កើតជាជាងស្រឡាញ់ទ្រង់ផ្ទាល់។

ប៉ុន្តែ ក្នុងដួងចិត្តអ្នកម្ដាយទូលបង្គំ ទ្រង់បានចាប់ផ្ដើមសាងសង់ព្រះវិហាររបស់ទ្រង់ហើយក៏បានចាក់គ្រឹះនៃភាពបរិសុទ្ធរបស់ទ្រង់ក្នុងការយាងមកគង់នៅរួចស្រេចទៅហើយ។ ហេតុដូច្នេះហើយបានជាគាត់មានការភ្ញាក់ផ្អើលអមជាមួយនឹងភាពភ័យខ្លាចដ៏បរិសុទ្ធ និងការញាប់ញ័រះ ដ្បិតទោះបើថាទូលបង្គំមិនទាន់បានក្លាយជាអ្នកជឿដែលទទួលពិធីជ្រមុជទឹកក៏ដោយ ក៏គាត់មានការភ័យខ្លាចត្រង់ថាទូលបង្គំនឹងបែរខ្នងដាក់ទ្រង់។

៧. វេទនាហើយទូលបង្គំ! ឱព្រះជាម្ចាស់អើយ! តើទូលបង្គំហ៊ានអះអាងថា ទ្រង់នៅស្ងៀមបានដែរឬទេ ខណៈពេលដែលទូលបង្គំកាន់តែឃ្លាតឆ្ងាយចេញថែមទៀតពីព្រះអង្គ? នៅពេលនោះ តើទ្រង់ពិតជាមិនបានមានបន្ទូលអ្វីមកកាន់ទូលបង្គំមែនឬ? ពាក្យពេចន៍របស់អ្នកម្ដាយទូលបង្គំដែលគាត់បាននិយាយមកកាន់ទូលបង្គំ ពិតជាមកពីទ្រង់ ដ្បិតគាត់ជាអ្នកបម្រើដ៏ស្មោះត្រង់របស់ទ្រង់។ ប៉ុន្តែ ពាក្យពេចន៍ទាំងនោះមិនបានជ្រាបចូលដួងចិត្តទូលបង្គំ ដើម្បីធ្វើឲ្យទូលបង្គំដើរតាមទ្រង់ទេ។ ទូលបង្គំចងចាំថា គាត់បានព្រមានទូលបង្គំយ៉ាងម៉ឺងម៉ាត់ថាកុំប្រព្រឹត្តអំពើអសីលធម៌ខាងឯផ្លូវភេទ ហើយលើសពីនោះទៅទៀត គឺកុំឲ្យលួងលោមប្រពន្ធរបស់បុរសម្នាក់ណាផ្សេងទៀតឲ្យសោះ។ ចំពោះទូលបង្គំ ការព្រមានបែបនោះហាក់បីដូចជាមិនជាស្អីសោះ ក្រៅពីការដែលស្ត្រីណាម្នាក់ព្រមានយ៉ាងដូច្នោះជាទូទៅ ហើយទូលបង្គំក៏មានការខ្មាសអៀនក្នុងការស្ដាប់បង្គាប់ផងដែរ។ ទោះជាយ៉ាងណាក្ដី ពាក្យពេចន៍ទាំងនោះគឺមកពីព្រះអង្គ ហើយទូលបង្គំក៏មិនបានដឹងទេ។ ទូលបង្គំបានគិតថា ទ្រង់នៅស្ងៀម ហើយមានតែអ្នកម្ដាយទូលបង្គំទេដែលបាននិយាយ។ ប៉ុន្តែ ទោះជាយ៉ាងណាក្ដី តាមរយៈគាត់គឺព្រះអង្គបានមានបន្ទូល ហើយក្នុងការបដិសេធន៍ការប្រឹក្សាពីគាត់ ពោលគឺទូលបង្គំក៏បានបដិសេធន៍ព្រះអង្គរួចស្រេចទៅហើយដែរ។

៩. ឱព្រះអម្ចាស់អើយ! តាមរយៈក្រឹត្យវិន័យរបស់ទ្រង់ ចោរកម្មត្រូវទទួលការដាក់ទារុណកម្ម ហើយក៏តាមរយៈច្បាប់ដែលត្រូវបានចារក្នុងដួងចិត្តមនុស្សផងដែរ ដែលសូម្បីតែអំពើអាក្រក់ដែលមានឫសគល់ដ៏ជ្រាលជ្រៅខ្លាំងប៉ុណ្ណាក៏មិនអាចលុបបំបាត់ចោលបាន។ ដ្បិតតើចោរណាមួយនឹងអនុញ្ញាតឲ្យចោរណាផ្សេងទៀតលួចពីគាត់? សូម្បីតែចោរដែលជាអ្នកមានក៏នឹងមិនអភ័យទោសដល់ចោរដែលជាអ្នកក្រដែលមកលួចពីគាត់ទោះបើចោរក្រនោះមានតម្រូវការក៏ដោយ។ ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំនៅមានចិត្តប្រាថ្នាចង់ទៅលួច ហើយក៏បានទៅលួច អំពើចោរកម្មមួយនោះកើតឡើងមិនមែនមកពីទូលបង្គំស្រេកឃ្លាន ឬក៏ក្រីក្រនោះទេ តែជាការប្រព្រឹត្តឡើងដោយសារទូលបង្គំមើលងាយលើការប្រព្រឹត្តនូវអ្វីដែលត្រឹមត្រូវ ហើយក៏ដោយសារទូលបង្គំមានចិត្តប្រាថ្នាយ៉ាងខ្លាំងក្នុងការប្រព្រឹត្តអំពើបាប។ ដ្បិតទូលបង្គំបានលួចនូវអ្វីដែលទូលបង្គំមានយ៉ាងគ្រប់គ្រាន់ហើយ ហើយអ្វីដែលទូលបង្គំមាននោះក៏មានគុណភាពល្អប្រសើរជាងផងដែរ។ ទូលបង្គំគ្មានចិត្តប្រាថ្នារីករាយនឹងអ្វីដែលទូលបង្គំបានលួចនោះទេ ប៉ុន្តែគ្រាន់តែមានចិត្តប្រាថ្នាក្នុងការអរសប្បាយនឹងអំពើបាបនៃចោរកម្មផ្ទាល់ប៉ុណ្ណោះ។

មានដើមផ្លែព័រមួយនៅជិតចំការរបស់យើង ដែលសំបូរផ្លែ ដែលតាមពិតទាំងពណ៌សម្រស់ និងរសជាតិរបស់វាក៏មិនគួរឲ្យគយគន់ផង។ នាយប់ជ្រៅមួយ មានយុវជនមួយក្រុម ហើយនិងទូលបង្គំក្នុងចំណោមពួកគេក៏បានទៅអង្រួនដើមនោះ ហើយលួចផ្លែព័រនោះ។ យើងបានយកផ្លែព័រជាច្រើន មិនមែនដើម្បីញ៉ាំដោយខ្លួនឯងនោះទេ ប៉ុន្តែដើម្បីយកទៅឲ្យសត្វជ្រូកស៊ី បន្ទាប់ពីយើងបានសាកល្បងភ្លក់បន្តិចបន្តួចរួចមក។ ការធ្វើបែបនោះបានធ្វើឲ្យយើងសប្បាយណាស់ ពីព្រោះវាជាបម្រាមមិនឲ្យធ្វើ។ នោះគឺជាស្ថានភាពនៃដួងចិត្តទូលបង្គំ ឱព្រះអម្ចាស់អើយ! នោះគឺជាស្ថានភាពនៃដួងចិត្តទូលបង្គំ—ដែលទ្រង់បានអាណិតអាសូរ សូម្បីតែទូលបង្គំនៅក្នុងអន្លង់ដែលគ្មានបាតមួយនោះក៏ដោយ។ ឥឡូវសូមឲ្យដួងចិត្តទូលបង្គំជម្រាបទៅកាន់ទ្រង់អំពីមូលហេតុដែលធ្វើឲ្យទូលបង្គំប្រព្រឹត្តអំពើបាបដែលគ្មានប្រយោជន៍៖ គឺដោយសារទូលបង្គំស្រឡាញ់ការរបិុលរប៉ូចដែលធ្វើឲ្យទូលបង្គំប្រព្រឹត្តការនោះ។ វាគឺជាអំពើអាក្រក់ ហើយទូលបង្គំស្រឡាញ់វាណាស់។ ទូលបង្គំស្រឡាញ់ការហិនវិនាសរបស់ខ្លួនណាស់។ ទូលបង្គំស្រឡាញ់អំពើខុសឆ្គងរបស់ខ្លួនណាស់។ ទូលបង្គំគឺជាព្រលឹងមួយដ៏អាក្រក់ ទូលបង្គំបានធ្លាក់ចេញពីសន្តិភាពក្នុងទ្រង់

ចូលទៅក្នុងការបំផ្លាញចោលផ្ទាល់តែម្ដង មិនស្វែងរកអ្វីចេញពីអំពើអាម៉ាស់លើកលែងតែអំពើអាម៉ាស់ផ្ទាល់។

១៥. «តើឲ្យទូលបង្គំតបស្នងព្រះអម្ចាស់បានដោយរបៀបណាទៅ»[៣] ដ្បិតខណៈពេលដែលការចងចាំរបស់ទូលបង្គំនឹកចាំអំពីសេចក្តីពិតទាំងនេះ នោះក៏ព្រលឹងទូលបង្គំលែងខ្លាចវាទៀតហើយដែរ? ឱព្រះអម្ចាស់អើយ! ទូលបង្គំនឹងស្រឡាញ់ទ្រង់ និងអរព្រះគុណទ្រង់ និងសរសើរតម្កើងព្រះនាមទ្រង់ ពីព្រោះព្រះអង្គបានអត់ទោសឲ្យទូលបង្គំនូវអំពើខិលខូច និងអំពើអាក្រក់ដូចនេះ។ ទូលបង្គំទទួលស្គាល់ថា គឺតាមរយៈព្រះគុណ និងសេចក្តីមេត្តាករុណារបស់ទ្រង់ហើយដែលទ្រង់បានរម្លាយអស់ទាំងអំពើបាបរបស់ទូលបង្គំចោល ហាក់បីដូចជាថាវាជាទឹកកកអញ្ចឹង។ ហើយក៏ដោយសារព្រះគុណរបស់ព្រះជាម្ចាស់ដែរ ដែលទ្រង់បានការពារទូលបង្គំពីការប្រព្រឹត្តអំពើអាក្រក់ណាផ្សេងទៀតដែលទូលបង្គំមិនបានប្រព្រឹត្ត—ដ្បិតតើអ្នកណាអាចនឹងដឹងថាទូលបង្គំនឹងទៅដល់ចំណុចអាក្រក់ណាបាន ព្រោះទូលបង្គំស្រឡាញ់អំពើបាប ពោលគឺស្រឡាញ់ការប្រព្រឹត្តអំពើបាប។ ប៉ុន្តែ ពិតណាស់ រាល់អំពើបាបទូលបង្គំកំពុងលន់តួទៅកាន់ព្រះអង្គព្រះអង្គបានអត់ទោសវារួចហើយ ពោលគឺទាំងអំពើបាបដែលទូលបង្គំបានប្រព្រឹត្តដោយចេតនា និងអំពើបាបដែលទូលបង្គំមិនបានប្រព្រឹត្តដោយសារព្រះអង្គបានគ្រោងទុកមិនឲ្យទូលបង្គំប្រព្រឹត្តឡើង។

តើមានបុគ្គលណាដែលឆ្លុះបញ្ចាំងពីអំពើបាបរបស់ខ្លួនអាចនឹងហ៊ានអះអាងថាគាត់បរិសុទ្ធ ហើយគ្មានអំពើបាបដោយសារការខិតខំប្រឹងប្រែងខ្លួនបាន? ហាក់បីដូចជាថា គាត់ត្រូវការសេចក្តីមេត្តាករុណា និងការអត់ទោសរបស់ព្រះអង្គតិចជាងអ្នកដទៃ? ចំពោះអស់អ្នកដែលទ្រង់បានត្រាស់ហៅ នោះពួកគេក៏បានចៀសចេញពីអំពើបាបដូចដែលទូលបង្គំបានសរសេរចុះនៅត្រង់នេះសម្រាប់ឲ្យពួកគេអាន ដោយសារពួកគេបានស្ដាប់បង្គាប់ព្រះសូរសៀងរបស់ព្រះអង្គ។ ប៉ុន្តែ សូមកុំឲ្យពួកគេសើចចំអកដាក់ទូលបង្គំ—ដ្បិតទូលបង្គំក៏បានទទួលបានការព្យាបាលពីគ្រូពេទ្យដូចពួកគេដែរ ដែលពួកគេបានទទួលជំនួយ ដែលទ្រង់បានការពារពួកគេពីការឈឺថ្កាត់ ឬក៏យ៉ាងហោចណាស់ពីការឈឺថ្កាត់ដ៏ធ្ងន់ធ្ងរដូចទូលបង្គំដែរ។ ហើយដោយសារការនេះ សូមឲ្យពួកគេស្រឡាញ់

៣ ទំនុកតម្កើង ១១៦:១២។

ទ្រង់ដូចទូលបង្គំ—ប្រាកដណាស់ គឺស្រឡាញ់ទ្រង់ខ្លាំងជាង—ដ្បិតពួកគេអាចឃើញថា ព្រះហស្តដែលបានព្យាបាល ហើយស្តារទូលបង្គំចេញពីជំងឺរាតត្បាតនៃអំពើបាបដ៏ធ្ងន់ធ្ងរនេះក៏ជាព្រះហស្តដែលបានការពារពួកគេចេញពីការធ្លាក់ក្នុងការឈឺថ្កាត់នៃជំងឺរាតត្បាតដូចទូលបង្គំដែរ។

១៨. តើនរណាអាចស្រាយចំណងដ៏រញ៉េរញ៉ៃ និងជំពាក់ជំពិនដូចនេះបានទៅហ្ន៎? វាជារឿងមិនស្អាតស្អំ។ ទូលបង្គំស្អប់ណាស់ក្នុងការគិតអំពីវា។ ទូលបង្គំស្អប់ណាស់ក្នុងការសម្លឹងមើលវា។ ប៉ុន្តែ ផ្ទុយទៅវិញ ទូលបង្គំប្រាថ្នាចង់បានព្រះអង្គដ៏ជាសេចក្តីសុចរិតភាពគ្មានទោស និងភាពស្រស់ស្អាត ហើយទ្រង់ពេញទៅដោយព្រះគុណ—ទូលបង្គំប្រាថ្នាចង់បានព្រះអង្គដោយការប្រាថ្នាចង់បានដ៏គ្មានការស្កប់ចិត្តបានសោះ។ ជាមួយព្រះអង្គគឺមានការសម្រាកយ៉ាងល្អឥតខ្ចោះ និងជីវិតដែលមិនប្រែប្រួល។ បុគ្គលណាដែលចូលទៅរកទ្រង់គឺចូលទៅរកអំណរនៃព្រះអម្ចាស់[៤] ហើយក៏នឹងមិនមានការភ័យខ្លាច ហើយក៏នឹងមិនខ្វះនូវចំណុចល្អដែរ។ ឱព្រះជាម្ចាស់អើយ! ប៉ុន្តែ ទូលបង្គំបានបោះបង់ទ្រង់ចោល។ ក្នុងភាពយុវវ័យរបស់ទូលបង្គំ ទូលបង្គំបានចាកចេញឆ្ងាយណាស់ពីព្រះអង្គដ៏ជាព្រះដែលទ្រទ្រង់ដ៏ពិតរបស់ទូលបង្គំ។ ហើយទូលបង្គំក៏បានក្លាយជាដីដែលត្រូវបោះចោល។

---

៤ សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ ម៉ាថាយ ២៥:២១។

# ៨

# ជីវិតនៅឯទីក្រុងកាតេជ

១. ទូលបង្គំបានទៅទីក្រុងកាតេជ ជាកន្លែងដែលមានឆ្នាំងខ្ទះកម្ដៅនៃភាពត្រេកត្រអាលដែលមិនបរិសុទ្ធកំពុងតែពុះកញ្ជ្រោលនៅជុំវិញទូលបង្គំ។ ទូលបង្គំមិនទាន់បានលង់ស្នេហ៍នៅឡើយទេ ប៉ុន្តែទូលបង្គំកំពុងតែលង់ស្នេហ៍ក្នុងគំនិតនៃការលង់ស្នេហ៍។ ហើយអារម្មណ៍នេះដែលថាទូលបង្គំកំពុងខ្វះអ្វីមួយបានធ្វើឲ្យទូលបង្គំស្អប់ខ្លួនឯង ពីព្រោះទូលបង្គំមិនសូវយកចិត្តទុកដាក់ក្នុងការបំពេញតម្រូវការនោះ។ ដូច្នេះ ទូលបង្គំក៏ចាប់ផ្ដើមស្វែងរកអ្វីមួយ ដើម្បីលង់ស្នេហ៍ ដ្បិតទូលបង្គំលង់ស្នេហ៍ជាមួយការលង់ស្នេហ៍។

ទូលបង្គំស្អប់ផ្លូវសុវត្ថិភាពដែលគ្មានអន្ទាក់។ ឱព្រះជាម្ចាស់អើយ! ដ្បិតការស្រេកឃ្លានដ៏ពិតប្រាកដរបស់ទូលបង្គំគឺជាម្ហូបអាហារដែលនឹងផ្គត់ផ្គង់ព្រលឹងទូលបង្គំ ពោលគឺការស្រេកឃ្លានព្រះអង្គ។ ប៉ុន្តែ ទូលបង្គំមិនដឹងអំពីការស្រេកឃ្លាននេះទេ។ ទូលបង្គំមិនមានអារម្មណ៍ថា ស្រេកឃ្លានសម្រាប់ម្ហូបអាហារដែលនឹងមិនខូច។ នេះមិនមែនមកពីទូលបង្គំឆ្អែតរួចទៅហើយនោះទេ ប៉ុន្តែដោយសារពេលដែលទូលបង្គំកាន់តែឃ្លានខ្លាំងនោះទូលបង្គំក៏កាន់តែលែងចង់បរិភោគវា។ មូលហេតុនេះហើយបានជាព្រលឹងទូលបង្គំកាន់តែខ្សោយទៅៗ ហើយមានពេញទៅដោយដំបៅ ហើយវាក៏មើលឆ្វេងមើលស្ដាំ

ដោយចង់ទទួលការលួងលោមពីភាពត្រេកត្រអាល។ ប៉ុន្តែ ភាពត្រេកត្រអាលទាំងនេះដែលទូលបង្គំស្វែងរកមិនមានព្រលឹងនោះទេ ដូច្នេះវាមិនអាចធ្វើជាកម្មវត្ថុនៃសេចក្ដីស្រឡាញ់បានឡើយ។

ចំពោះទូលបង្គំ ការស្រឡាញ់គេ និងការដែលគេស្រឡាញ់វិញ គឺពិតជាផ្អែមណាស់ ហើយវាក៏កាន់តែផ្អែមជាងមុននៅពេលដែលទូលបង្គំរួមភេទជាមួយនឹងបុគ្គលដែលទូលបង្គំស្រឡាញ់។ ដូច្នេះ ទូលបង្គំក៏បានប្រឡូកប្រឡាក់មិត្តភាពជាមួយនឹងភាពកខ្វក់ខាងឯផ្លូវភេទ ហើយទូលបង្គំទម្លាក់ពន្លឺនៃមិត្តភាពជាមួយភាពត្រេកត្រអាលនោះឲ្យទៅជាងងឹតជាមួយនឹងភាពអន្ទិលនៃភាពត្រេកត្រអាល។ ប៉ុន្តែ ទោះបើទូលបង្គំកខ្វក់ និងមិនស្អាតយ៉ាងណាក៏ដោយក៏ទូលបង្គំនៅចង់ (ក្នុងអំនួតយ៉ាងខ្លាំង) ឲ្យអ្នកដទៃគិតថាទូលបង្គំឈ្លាសវៃ និងមានសុជីវធម៌។ ដូច្នេះ ទូលបង្គំដាំដូងធ្លាក់ក្បាលចុះក្នុងសេចក្ដីស្រឡាញ់ដែលទូលបង្គំប្រាថ្នាចង់ទទួលបាន។

ឱព្រះជាម្ចាស់នៃសេចក្ដីមេត្តាករុណារបស់ទូលបង្គំអើយ! ព្រះអង្គបានលាយទ្បំភាពល្វីងជូរចត់ច្រើនណាស់ក្នុងពែងនៃភាពអរសប្បាយមួយនេះ។ ហើយការនេះបង្ហាញអំពីព្រះគុណដ៏ធំធេងរបស់ទ្រង់។ ដ្បិតការស្រឡាញ់របស់ទូលបង្គំបានវិលត្រឡប់មកវិញហើយបានចងជាចំណងជាមួយនឹងទូលបង្គំដោយច្រវាក់នៃចំណង់តណ្ហារបស់វា។ ខណៈពេលដែលទូលបង្គំកំពុងមានអំណរជាមួយវា នោះទូលបង្គំក៏បានជាប់ច្រវាក់នៃបញ្ហា ហើយទទួលទុក្ខទោសពីដែកដែលកំពុងឆេះក្ដៅគគុកដោយភាពច្រណែន ការមានមន្ទិលសង្ស័យ ភាពភ័យខ្លាច កំហឹង និងការឈ្លោះប្រកែក។

២. ការសម្ដែងល្ខោនក៏បានទាក់ទាញចំណាប់អារម្មណ៍ទូលបង្គំដែរ ការសម្ដែងដែលបានបង្ហាញយ៉ាងពេញទីនូវរូបភាពនៃការឈឺចាប់ផ្ទាល់ខ្លួនរបស់ទូលបង្គំគឺជាសាំងដែលបញ្ឆេះភ្លើងលើទូលបង្គំផ្ទាល់។ ហេតុអ្វីបានជាមនុស្សយើងពិបាកចិត្តនៅពេលមើលការសម្ដែងដែលមានទុក្ខព្រួយគួរឲ្យខ្លោចផ្សា និងបទពិសោធន៍នៃការមើលងាយគេ ដែលខ្លួនឯងផ្ទាល់មិនចាំបាច់ឆ្លងកាត់? ពួកគេមើលការសម្ដែង ពីព្រោះពួកគេប្រាថ្នាចង់មានអារម្មណ៍ពិបាកចិត្ត ហើយអារម្មណ៍នៃទុក្ខព្រួយនេះឯងដែលធ្វើឲ្យពួកគេសប្បាយចិត្ត។ នេះពិតជាឆ្កួតភ្លីភ្លើមែន! ដរាបណាបុគ្គលណាម្នាក់កាន់តែមានបទពិសោធន៍ផ្ទាល់ខ្លួនក្នុងការរងទុក្ខ នោះគាត់ក៏កាន់តែអាចចូលតួបានយ៉ាងស្រួលក្នុងការសម្ដែងដែរ។

ប៉ុន្តែ វាចម្លែកត្រង់ថា ហេតុអ្វីនៅពេលដែលបុគ្គលណាម្នាក់រងទុក្ខផ្ទាល់ខ្លួន យើងបែរហៅការនេះថាជា "ទុក្ខវេទនា"។ ហើយពេលដែលគាត់រងទុក្ខ ដោយយល់អំពីអារម្មណ៍អ្នកដទៃ យើងបែរជាហៅវាថា "ការអាណិតអាសូរ" ទៅវិញ។ ប៉ុន្តែ តើនេះជាការអាណិតអាសូរបែបម៉េចដែលកើតចេញពីការមើលការរងទុក្ខដែលជាការសម្តែងដែលស្រមើស្រមៃ និងមិនពិត? គេមិនបានរំពឹងឲ្យអ្នកមើលជួយអ្នកសម្តែងទេ ប៉ុន្តែគ្រាន់តែឲ្យមានទុក្ខព្រួយប៉ុណ្ណោះ។ ហើយពេលគាត់កាន់តែព្រួយបារម្ភ នោះគាត់ក៏កាន់តែកោតសរសើរតួសម្តែងនៃរឿងស្រមើស្រមៃនេះផងដែរ។ ប្រសិនបើតួសម្តែងមានសំណាងអាក្រក់—មិនថាជាប្រវត្តិសាស្ត្រ ឬក៏ការស្រមៃទាំងស្រុងក៏ដោយ—ដោយថាពួកគាត់មិនបានប៉ះពាល់អារម្មណ៍នៃអ្នកមើល នោះអ្នកមើលនឹងស្អប់តួសម្តែង ហើយរអ៊ូរទាំអំពីតួសម្តែងពេលដែលអ្នកមើលចាកចេញ។ ប៉ុន្តែ ប្រសិនបើអ្នកមើលបានទទួលការប៉ះពាល់អារម្មណ៍ពីតួសម្តែងយ៉ាងខ្លាំងតាមរយៈការសម្តែង នោះអ្នកមើលនឹងយកចិត្តទុកដាក់ជាមួយគាត់ ហើយស្រក់ទឹកភ្នែកទាំងមានអំណរ។

៣. តើយើងពិតជាស្រឡាញ់ទឹកភ្នែក និងការរងទុក្ខមែនឬ? ប្រាកដណាស់! មនុស្សគ្រប់រូបប្រាថ្នាចង់អរសប្បាយ។ ប៉ុន្តែ ទោះបើថាគ្មាននរណាម្នាក់មានឆន្ទៈក្នុងការរងទុក្ខក៏ដោយ ក៏យើងនៅតែអាចឯកភាពគ្នាបានថា យើងសុទ្ធតែចង់មានចិត្តអាណិតអាសូរ។ ហេតុដូច្នេះហើយបានជាយើងស្វាគមន៍ទុក្ខព្រួយរបស់អ្នកដទៃ ពីព្រោះបើគ្មានវា នោះយើងក៏មិនមានអ្វី ដើម្បីអាណិតអាសូរផងដែរ។ ការនេះក៏ផុសចេញពីក្បាលទឹកនៃមិត្តភាពដូចគ្នា។ ប៉ុន្តែ តើវាទៅណា? ហើយវាហូរទៅណា? ហេតុអ្វីបានជាវាប្តូរទៅជាក្បាលទឹកនៃជ័រកៅស៊ូដែលពុះកញ្ជ្រោលជាជំនន់នៃភាពត្រេកត្រអាល? វាគួរមានភាពបរិសុទ្ធពីស្ថានសួគ៌ ប៉ុន្តែផ្ទុយទៅវិញវាបែរជាពុករលួយនៅពេលដែលអនុញ្ញាតឲ្យវាជ្រើសរើសផ្លូវដោយខ្លួនឯង។

ដូច្នេះ តើយើងគួរបោះបង់ចោលនូវរាល់អារម្មណ៍អាណិតអាសូរមែនឬ? ទេ! មិនមែនដូច្នោះទេ! ហើយវាក៏មិនមែនជារឿងខុសឆ្គងដែរ ពេលយើងមានអារម្មណ៍អាណិតអាសូរដល់អ្នកដទៃ ដែលកើតចេញពីសេចក្តីស្រឡាញ់។ ប៉ុន្តែ ចូរយើងប្រយ័ត្នអំពីសេចក្តីល្បួងឲ្យទៅប្រព្រឹត្តអំពើដែលមិនបរិសុទ្ធ។ ឱព្រលឹងទូលបង្គំអើយ ចូរយើងមានការប្រុងប្រយ័ត្នទាក់ទងនឹងភាពមិនបរិសុទ្ធ។ ព្រះជាម្ចាស់គឺជាអង្គដែលការពារព្រលឹងទូលបង្គំ

គឺជាព្រះវរបិតានៃពួកឰយុកោរបស់យើង ហើយទ្រង់ស័ក្តិសមនឹងទទួលបានការសរសើរតម្កើង និងការកោតសរសើរពីយើង។

សូម្បីតែមកដល់សព្វថ្ងៃនេះក៏ទូលបង្គំមិនដែលឈប់មានការអាណិតអាសូរដែរ។ ប៉ុន្តែ នៅកាលនោះ ក្នុងរោងល្ខោន ទូលបង្គំបានទទួលភាពរីករាយជាមួយនឹងគូមួយនៅពេលដែលពួកគេកំពុងតែអរសប្បាយក្នុងអំពើបាបជាមួយគ្នាតាមរយៈការសម្តែងដ៏អាសអាភាស ទោះបើថាវាជាការសម្តែងឲ្យជឿក៏ដោយ។ ហើយនៅពេលដែលគូនោះបែកគ្នា ទូលបង្គំក៏ពិបាកចិត្តជាមួយនឹងពួកគាត់ដែរ ហាក់បីដូចជាអាណិតពួកគាត់ តែទោះជាយ៉ាងណាក្តីនៅមានការពេញចិត្តទាំងក្នុងអារម្មណ៍នៃការពិបាកចិត្ត និងអារម្មណ៍នៃការអាណិតអាសូរ។ សព្វថ្ងៃនេះ ទូលបង្គំអាណិតបុគ្គលដែលអរសប្បាយក្នុងអំពើអាក្រក់របស់ខ្លួនខ្លាំងជាងបុគ្គលដែលរាប់ខ្លួនថាជាអកុសល ពីព្រោះគាត់បរាជ័យក្នុងការមិនទទួលបានភាពអរសប្បាយដែលមានគ្រោះថ្នាក់ ឬក៏ការរងទុក្ខនៃការបាត់បង់ភាពអរសប្បាយដ៏វេទនាណាមួយ។ តាមពិតទៅ នេះគឺជាការអាណិតអាសូរដ៏ពិតប្រាកដជាងទុក្ខព្រួយដែលទូលបង្គំមានក្នុងវាដែលនាំឲ្យទូលបង្គំមិនមានការពេញចិត្ត។ ដ្បិតទោះបើថា យើងគួរកោតសរសើរបុគ្គលដែលបង្ហាញពីសេចក្តីស្រឡាញ់ក្នុងការព្រួយបារម្ភជាមួយនឹងបុគ្គលម្នាក់ទៀតដែលមិនអរសប្បាយក៏ដោយ ក៏បុគ្គលដែលមានអំណាចដ៏ពិតនៃការអាណិតអាសូរគួរជ្រើសរើសថា មិនមានអ្វីដែលគួរធ្វើឲ្យគាត់ព្រួយបារម្ភអំពីការនោះនោះទេ ។ ដ្បិតប្រសិនបើឆន្ទៈដ៏ល្អរបស់យើងមានគោលបំណងអាក្រក់ដូចការអាណិតអាសូរក្នុងរោងល្ខោន—ដែលនោះនឹងជាការប្រឆាំងគ្នា—នោះមានន័យថាបុគ្គលដែលអាណិតអាសូរចំពោះបុគ្គលម្នាក់ទៀតនឹងចង់ឲ្យបុគ្គលនោះកាន់តែជួបទុក្ខវេទនាថែមទៀត ដើម្បីឲ្យគាត់អាចកាន់តែអាណិតអាសូរបុគ្គលនោះឲ្យកាន់តែខ្លាំងថែមទៀតបាន។ យើងទំនងជាអាចរាប់ទុក្ខព្រួយនោះថាជាអំពើយុត្តិធម៌បាន ប៉ុន្តែយើងមិនអាចរាប់ថាជាក្តីស្រឡាញ់សម្រាប់វាបានឡើយ។ ឱព្រះអង្គដ៏ជាព្រះជាម្ចាស់ដែលស្រឡាញ់ព្រលឹងវិញ្ញាណអើយ ទ្រង់មានការអាណិតអាសូរដែលបរិសុទ្ធ ហើយពេញទៅដោយសេរីភាពខ្លាំងជាងយើងជាមួយនឹងការលាយឡំការជំរុញចិត្តរបស់យើងទៅទៀត។ ដ្បិតព្រះអង្គមិនដែលមានរបួសដោយសារការទុក្ខព្រួយណាមួយឡើយ។ ឥឡូវ “តើអ្នកណា

មានសមត្ថភាពសម្រាប់កិច្ចការនេះ?»។[១]

៤. ប៉ុន្តែ វាជាចំណុចសម្គាល់នៃអំពើអាក្រក់របស់ទូលបង្គំត្រង់ថា ទូលបង្គំចូលចិត្តព្រួយបារម្ភនៅឯរោងល្ខោន ហើយម្ដងម្កាលទូលបង្គំស្វែងរកឱកាសមានទុក្ខព្រួយលើអ្វីដែលជាការក្លែងក្លាយដែលជាការសម្ដែង។ តួសម្ដែងដែលបំពេញចិត្តទូលបង្គំយ៉ាងខ្លាំង ហើយទាក់ទាញចំណាប់អារម្មណ៍ទូលបង្គំក្នុងការសម្ដែងគឺជាតួអង្គដែលធ្វើឲ្យទូលបង្គំហូរទឹកភ្នែក។ ដូច្នេះហើយបានជាវាមិនមែនជារឿងភ្ញាក់ផ្អើលទេដែលចៀម ដែលមិនសប្បាយចិត្តម្នាក់នេះបានវង្វេងចេញពីហ្វូងរបស់ព្រះអង្គ ហើយមិនចេះអត់ធ្មត់ទាក់ទងនឹងការយកចិត្តទុកដាក់របស់ទ្រង់ បានឆ្លងរោគដ៏គួរឲ្យកាចសាហាវ «រោគ»។[២] នេះគឺជាមូលហេតុនៃសេចក្ដីស្រឡាញ់របស់ទូលបង្គំទាក់ទងទៅនឹងទុក្ខព្រួយបែបនេះ៖ គឺដើម្បីកុំឲ្យទុក្ខព្រួយដ៏ពិតធ្វើឲ្យទូលបង្គំមានរបួសខ្លាំងពេក ដ្បិតទូលបង្គំមិនមានសេចក្ដីប្រាថ្នាក្នុងការឆ្លងកាត់ទុក្ខព្រួយដែលទូលបង្គំចូលចិត្តមើលនៅក្នុងរោងល្ខោនទេ។ ប៉ុន្តែទូលបង្គំចូលចិត្តតែទុក្ខព្រួយបែបជារឿងព្រេង និងរឿងច្នៃប្រឌិតប៉ុណ្ណោះ ដែលរំញោចតែផ្ទៃកលើនៃអារម្មណ៍របស់ទូលបង្គំ។ ទោះជាយ៉ាងណាក្ដី ហាក់បីដូចជាថា ក្រចកម្រាមដៃនោះមានពិស ហើយការអេះនោះក៏បង្កើតឲ្យមានភាពរលាក ការហើម ភាពស្អុយ និងរលួយ។ ជីវិតទូលបង្គំគឺបែបនោះឯង! ប៉ុន្តែ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! តើជីវិតដែលទូលបង្គំរស់នៅពេលនោះពិតជាអាចហៅថាជាជីវិតបានមែនឬ?

៥. ទោះជាយ៉ាងណាក្ដី ក៏សេចក្ដីមេត្តាករុណាដ៏ស្មោះត្រង់របស់ទ្រង់បាននៅអែបលើទូលបង្គំពីចម្ងាយដែរ។ ទូលបង្គំបានបែកយ៉ាងខ្លាំងដោយសារបានប្រព្រឹត្តអំពើអាក្រក់ៗយ៉ាងខ្លាំងជាច្រើន? ដោយសារទូលបង្គំបានបោះបង់ព្រះអង្គចោល ហើយសង្វាតដេញតាមទេវវិជ្ជាដែលជេរប្រមាថ ដែលការនោះបានអូសទម្លាក់ទូលបង្គំចូលក្នុងជង្ហុកនៃការគ្មានជំនឿ។ កាលនោះទូលបង្គំកំពុងបម្រើពួកអារក្ស។ ហើយទង្វើអាក្រក់របស់ទូលបង្គំគឺជាយញ្ញបូជាដែលទូលបង្គំថ្វាយទៅកាន់ពួកវា។ តែទោះជាយ៉ាងណាក្ដី ក្នុងរាល់ចំណុចទាំងនេះ ក៏ព្រះអង្គមិនបានបរាជ័យក្នុងការដាក់វិន័យលើទូលបង្គំដែរ។ មានពេលមួយខណៈពេលដែលគេកំពុងតែប្រារព្ធពិធីមួយចំនួនដ៏ឧឡារិករបស់ព្រះអង្គក្នុងព្រះវិហារ

១ ២កូរិនថូស ២:១៦។

២ ដែលលោកគ្រូ អហ្គូស្ទីន កំពុងតែលើកឡើងត្រង់នេះគឺមិនសំដៅទៅលើរោគាខាងឯសាច់ឈាមនោះទេ ប៉ុន្តែខាងឯព្រលឹងវិញ្ញាណវិញ។

របស់ទ្រង់ ទូលបង្គំហ៊ានមានអារម្មណ៍ស្រើបស្រាលលើស្ត្រីម្នាក់ ហើយមានគម្រោងបំពេញភាពស្រើបស្រាលនោះដែលនាំឲ្យមានសេចក្តីស្លាប់ជាផលផ្លែ។ ទាក់ទងនឹងរឿងនេះព្រះអង្គបានដាក់ទារុណកម្មដែលជាវិន័យដ៏ធ្ងន់ធ្ងរលើទូលបង្គំ ប៉ុន្តែបើប្រៀបធៀបទារុណកម្មរបស់ទ្រង់គឺវាមិនធ្ងន់ធ្ងរស្មើនឹងកំហុសរបស់ទូលបង្គំទេ។ ឱព្រះដ៏ជាសេចក្តីមេត្តាករុណាដ៏ធំធេងរបស់ទូលបង្គំអើយ ទ្រង់ហើយគឺជាទីមាំមួនរបស់ទូលបង្គំចេញពីគ្រោះថ្នាក់ដ៏ធំក្រៃលែងទាំងនោះ ដែលទូលបង្គំបានវង្វេងចូលយ៉ាងពេញទីដោយអំនួតដោយដកខ្លួនចេញកាន់តែឆ្ងាយថែមទៀតពីព្រះអង្គ។ ទូលបង្គំស្រឡាញ់ផ្លូវរបស់ខ្លួនមិនមែនរបស់ព្រះអង្គ។ ទូលបង្គំស្រឡាញ់ «សេរីភាព» ដែលរសាត់ព្រាត់គ្មានទីលំនៅប្រាកដប្រជារបស់ខ្លួន!

៦. ការសិក្សាទាំងនោះដែលទូលបង្គំកំពុងសង្វាតដេញតាម ដែលមនុស្សជាច្រើនគោរព គឺដើម្បីឲ្យបានក្លាយជាអ្នកប្តឹងផ្តល់ក្នុងសាលតុលាការខាងច្បាប់។ ពេលដែលទូលបង្គំកាន់តែកុហក នោះគេក៏កាន់តែកោតសរសើរទូលបង្គំ ដ្បិតមនុស្សយើងខ្វាក់ដល់ថ្នាក់ថា គេក៏សរសើរភាពខ្វាក់របស់ខ្លួនទៀតផង។ ហើយមកដល់ពេលនោះ ទូលបង្គំគឺជាសិស្សដែលជាប់ចំណាត់ថ្នាក់លេខ១ក្នុងថ្នាក់នៃសាលាវោហារសាស្ត្រ ហើយទូលបង្គំពេញចិត្តកិត្តិយសនោះណាស់ ហើយក៏មានអំនួតយ៉ាងខ្លាំង។ ទោះជាយ៉ាងណាក្តី ឱព្រះអម្ចាស់អើយ បើប្រៀបធៀបទៅនឹងសិស្សនានា ទូលបង្គំសុភាពណាស់ ដូចដែលព្រះអង្គបានជ្រាបហើយទូលបង្គំក៏មិនមានចំណែកក្នុងការនិយមបំផ្លាញទ្រព្យជាមួយនឹងអ្នកដែលគេហៅថា «អាបំផ្លាញ»។[៣] ហើយទាក់ទងនឹងឈ្មោះដ៏លីលើមួយនេះ ដែលតាមពិតទៅគឺជាការបម្រើខ្មោចបិសាច មនុស្សម្នាបែរជារាប់វាថាជាកិត្តិយសក្នុងការមានឈ្មោះនេះ។ ទូលបង្គំបានរាប់អានពួកគេ ទោះបើទូលបង្គំអាម៉ាស់ក្នុងការគ្មានចំណែកក្នុងក្រុមជើងកាងរបស់ពួកគេក៏ដោយ។ ប៉ុន្តែ ទូលបង្គំរស់នៅជាមួយពួកគេ ហើយពេលខ្លះទូលបង្គំក៏ចូលចិត្តមិត្តភាពរបស់ពួកគេដែរ ទោះបើទូលបង្គំស្អប់ខ្ពើមទង្វើរបស់ពួកគេក៏ដោយ។ ពួកគេចូលចិត្តធ្វើអំពើញ៉េះញ៉ោះរបិលរប៉ូចលើសិស្សថ្មីៗ ដោយធ្វើបាបពួកគេតាមរយៈការបង្ករឿងដែលមិនគួរធ្វើឡើង ដោយគ្រាន់តែដើម្បីបំពេញចិត្តការលេងកម្សាន្តដ៏អាក្រក់របស់

[៣] នេះគឺជាឈ្មោះក្រុមពួកជើងកាងយុវជនដែលចូលចិត្តបំផ្លាញទ្រព្យនៅឯទីក្រុងកាតាជេ ហើយមើលទៅសមាជិកភាគច្រើននៃក្រុមជើងកាងនោះគឺសុទ្ធតែជាសិស្សានុសិស្សពីសាលារៀននេះ។

ពួកគេ។ គ្មានអ្វីអាចមានលក្ខណៈស្រដៀងជាងទង្វើរបស់ខ្មោចបិសាចដែលពួកយុវជនទាំងនេះព្យាយាមធ្វើ ដើម្បីទាក់ទាញអ្នកដទៃឲ្យប្រព្រឹត្តអំពើអាក្រក់ឡើយ។ ដូច្នេះ តើមានឈ្មោះឯណាទៀតដែលគេអាចចូលមកហៅយ៉ាងត្រឹមត្រូវបានសម្រាប់ពួកក្រុមនេះជាជាងហៅថា «អាបំផ្លាញ»? ដ្បិតវិញ្ញាណអាក្រក់បានបង្វែរពង្វក់ពួកគេពីភាពត្រឹមត្រូវឲ្យក្លាយទៅជាពួកបំផ្លាញរួចស្រេចទៅហើយ ហើយពួកអារក្សក៏តែងតែសើចចំអកដាក់ពួកគេក្នុងលក្ខណៈលាក់បាំង ទោះបើពួកវាជាអ្នកបញ្ចុះបញ្ចូលក៏ដោយ។ ក្នុងរបៀបដូចគ្នា ពួកសិស្សទាំងនេះក៏ចូលចិត្តលេងសើចក្នុងការចំអក និងបោកបញ្ឆោតអ្នកដទៃដែរ។

៧. គឺពេលនោះឯងហើយដែលទូលបង្គំបានសិក្សាសៀវភៅវោហារសាស្ត្រ ដ្បិតទូលបង្គំប្រាថ្នាចង់ក្លាយជាអ្នកនិយាយដ៏ល្បីល្បាញម្នាក់ ទោះបើចេញពីការជំរុញចិត្តដែលគួរឲ្យស្តីបន្ទោសក៏ដោយ៖ ការចូលចិត្តអួតអាង។ ក្នុងរបៀបនៃការសិក្សាទូទៅ ទូលបង្គំក៏បានអានសៀវភៅនិពន្ធដោយលោក សិសារូ ដែលមនុស្សគ្រប់រូបស្ទើរតែកោតសរសើរវោហារសាស្ត្ររបស់គាត់។ សៀវភៅរបស់គាត់មួយក្បាលនេះមានការដាស់តឿនឲ្យរៀនទេវវិជ្ជា ហើយសៀវភៅនោះមានចំណងជើងថា «ហូតធីនស៊ីស»។[៤] ឱព្រះអម្ចាស់អើយ! ប្រាកដណាស់ គឺសៀវភៅនេះហើយដែលបានបំផ្លាស់បំប្រែឥរិយាបថរបស់ទូលបង្គំទាំងស្រុង បង្វែរការអធិស្ឋានរបស់ទូលបង្គំទៅកាន់ព្រះអង្គ ផ្តល់នូវសេចក្តីសង្ឃឹម និងសេចក្តីប្រាថ្នាថ្មីដល់ទូលបង្គំ។ ភ្លាមៗនោះរាល់ក្តីសង្ឃឹមដែលឥតប្រយោជន៍ក៏បានក្លាយជាឥតតម្លៃចំពោះទូលបង្គំ ហើយដោយមានភាពកក់ក្តៅដែលមិនអាចជឿបាន នោះដួងចិត្តរបស់ទូលបង្គំក៏ស្រេកឃ្លានចង់បានប្រាជ្ញាអមតៈ ហើយពេលនោះក៏ចាប់ផ្តើមងើបឡើង ដើម្បីនឹងត្រឡប់ទៅរកទ្រង់វិញ។ វាមិនមែនដើម្បីសំលៀងអណ្តាតទូលបង្គំបន្ថែមទៀតនោះទេ ដែលធ្វើឲ្យទូលបង្គំប្រើប្រាស់សៀវភៅនោះ។ កាលនោះ ទោះបើទូលបង្គំមានអាយុ១៩ឆ្នាំ ហើយឪពុកទូលបង្គំបានស្លាប់អស់រយៈពេល២ឆ្នាំហើយក៏ដោយ។ អ្នកម្តាយទូលបង្គំគឺជាអ្នកផ្គត់ផ្គង់លុយកាក់សម្រាប់ការសិក្សាវោហារសាស្ត្ររបស់ទូលបង្គំ។ រចនាបថនៃសៀវភៅនោះគឺមិនមែនជាអ្វីដែលបញ្ចុះបញ្ចូលទូលបង្គំទេ ប៉ុន្តែគឺអត្ថបទរបស់វាទេតើ។

៨. ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! កាលនោះទូលបង្គំឆេះឆួលយ៉ាងខ្នះខ្នែងណាស់

---

៤ លោក សិសារូ ប្រហែលជាបាននិពន្ធសៀវភៅនេះនៅឆ្នាំ៥០មុនគ.ស. វាគឺជាការតែងសេចក្តីមួយដ៏ល្បីល្បាញនៅសម័យរបស់លោកគ្រូ អហ្គូស្ទីន ប៉ុន្តែមិនមានសេចក្តីចម្លងនៅសល់ដល់សព្វថ្ងៃនេះនោះទេ។ អ្នកនិពន្ធមួយចំនួនទៀតក៏បានលើកឡើងអំពីការតែងសេចក្តីមួយនេះដែរ ប៉ុន្តែបំណែកតូចដែលនៅសល់គឺមានតែនៅក្នុងការនិពន្ធរបស់លោកគ្រូ អហ្គូស្ទីន។

ក្នុងការហោះចេញពីអ្វីៗនៅលើផែនដីនេះ ដើម្បីទៅកាន់ព្រះអង្គ។ ហើយទូលបង្គំក៏មិនដឹងថាព្រះអង្គកំពុងធ្វើការអ្វីខ្លះក្នុងទូលបង្គំទៀតផងនៅកាលនោះ។ ដ្បិតជាមួយព្រះអង្គគឺមានប្រាជ្ញា។ ក្នុងភាសាក្រិក គេហៅការស្រឡាញ់ប្រាជ្ញាថា «ទស្សនវិជ្ជា» ហើយគឺដោយការស្រឡាញ់ទស្សនៈវិជ្ជានេះហើយដែលធ្វើឲ្យទូលបង្គំឆេះឆួល។ មានអ្នកខ្លះបោកប្រាស់អ្នកដទៃតាមរយៈទស្សនៈវិជ្ជា ពីព្រោះទស្សនៈវិជ្ជាមាននាមដែលពេញដោយកិត្តិយស ភាពអស្ចារ្យ និងមន្តស្នេហ៍ ហើយគេប្រើប្រាស់វា ដើម្បីធ្វើឲ្យសេចក្តីដែលខុសឆ្គងរបស់ពួកគេមានភាពទាក់ទាញ។ ហើយស្ទើរតែគ្រប់គ្នាដែលបានធ្វើបែបនោះ មិនថាក្នុងសម័យរបស់លោក ស៊ិសារ៉ូ ឬក៏មុនហ្នឹង គឺត្រូវបានពិនិត្យឃើញ និងចង្អុលបង្ហាញក្នុងសៀវភៅរបស់គាត់។ សៀវភៅនេះបង្ហាញពីតម្លៃនៃការក្រើនរម្លឹកដែលព្រះវិញ្ញាណរបស់ព្រះអង្គបានប្រទាន បានមានព្រះបន្ទូលតាមរយៈអ្នកបម្រើដ៏ល្អ និងពិតរបស់ព្រះអង្គ៖ «ចូរប្រយ័ត្ន ក្រែងមានអ្នកណាម្នាក់ចាប់អ្នករាល់គ្នាជារំពា ដោយប្រើទស្សនៈវិជ្ជា និងពាក្យបោកបញ្ឆោតឥតខ្លឹមសារ តាមទំនៀមទម្លាប់របស់មនុស្ស តាមវិញ្ញាណបឋមសិក្សារបស់លោកីយ៍ គឺមិនតាមព្រះគ្រីស្ទទេ។ ដ្បិតគ្រប់ទាំងសេចក្តីពោរពេញរបស់ព្រះសណ្ឋិតជារូបរាងនៅក្នុងព្រះគ្រីស្ទ»។[៥] ប៉ុន្តែ នៅពេលនោះ ឱពន្លឺនៃដួងចិត្តទូលបង្គំអើយ! ទ្រង់បានជ្រាបហើយថាទូលបង្គំមិនទាន់ស្គាល់ពាក្យពេចន៍របស់ពួកសាវ័កនៅឡើយទេ។ ដូច្នេះ ទូលបង្គំក៏បានទទួលការបំផ្លាស់បំប្រែតាមរយៈការដាស់តឿនរបស់លោក ស៊ិសារ៉ូ យ៉ាងហោចណាស់ដល់ចំណុចថាទូលបង្គំបានទទួលការលើកទឹកចិត្តតាមរយៈវា នឹងទទួលបានការដុតបំភ្លឺ និងការឆេះឆួលឲ្យស្រឡាញ់ ឲ្យស្វែងរក ឲ្យចាប់ឲ្យបាន ឲ្យកាន់ និងឲ្យឱបក្រសោប (មិនមែនគ្រាន់តែទាក់ទងទៅនឹងសាលាទេវវិជ្ជាណាមួយនោះទេ) ប្រាជ្ញាផ្ទាល់តែម្តង មិនថាវានៅទីណាក៏ដោយ។ មានតែចំណុចមួយប៉ុណ្ណោះដែលធ្វើឲ្យភាពឆេះឆួលរបស់ទូលបង្គំមានភាពយឺតយ៉ាវ៖ សៀវភៅនោះមិនបានលើកឡើងអំពីព្រះគ្រីស្ទឡើយ។ ឱព្រះអម្ចាស់អើយ! ដ្បិតតាមរយៈសេចក្តីមេត្តាករុណារបស់ទ្រង់ ទូលបង្គំបានប្តេជ្ញាចិត្តលើភក្តីភាពនៃព្រះនាមរបស់ព្រះអង្គសង្គ្រោះទូលបង្គំ ដែលជាព្រះរាជបុត្រារបស់ព្រះអង្គ មកក្នុងដួងចិត្តដ៏ស្រទន់របស់ទូលបង្គំ សូម្បីតែពេលនៅក្នុងទឹកដោះនៃអ្នកម្តាយទូលបង្គំផង។ ដូច្នេះ អ្វីដែលទូលបង្គំអាន មិនថាវាល្អប្រសើរ ឬក៏មានសេចក្តីពិត

៥ កូឡូស ២:៨-៩។

ខ្លាំងប៉ុណ្ណាក៏ដោយ ក៏វានឹងមិនទាក់ទាញចំណាប់អារម្មណ៍ទូលបង្គំទាំងស្រុងបាននោះទេ ប្រសិនបើវាមិនបានលើកឡើងអំពីព្រះនាមព្រះគ្រីស្ទ។

៩. ដូច្នេះ ទូលបង្គំសម្រេចចិត្តក្នុងការពិនិត្យមើលព្រះបន្ទូលដ៏បរិសុទ្ធរបស់ព្រះអង្គ ដើម្បីឲ្យទូលបង្គំអាចឃើញអំពីសណ្ឋានរបស់វាថាយ៉ាងដូចម្ដេច។ ហើយខណៈពេលដែលទូលបង្គំអាន នោះទូលបង្គំបានសង្កេតឃើញថា មនុស្សមានអំនួតមិនបានគិតថា នេះមាន «ការពិត» នោះទេ ឬក៏ថាវាមានការងាយយល់ចំពោះក្មេងៗផងដែរ។ មនុស្សសាមញ្ញអាចយល់ពាក្យមូលដ្ឋានទាំងនោះបាន ប៉ុន្តែពេលកាន់តែអានឲ្យជ្រាលជ្រៅទៅ នោះនឹងឃើញថា វាគឺជាអាថ៌កំបាំងដែលគួរឲ្យស្ញប់ស្ញែង។ ប៉ុន្តែ នៅពេលនោះ ទូលបង្គំមិនមែនជាបុរសដែលអាចចូលតាមផ្លូវនោះបានទេ ពីព្រោះទូលបង្គំមិនអាចឱនក្បាលទាបល្មម ដើម្បីនឹងចូលឡើយ។ ដ្បិតកាលនោះទូលបង្គំមិនទាន់យល់ព្រះបន្ទូលដូចទូលបង្គំយល់នៅពេលនេះឡើយ។ នៅពេលនោះ ទូលបង្គំបើកមើលព្រះបន្ទូល ចំពោះទូលបង្គំវាហាក់បីដូចជាមិនសមហេតុសមផលបើប្រៀបធៀបជាមួយនឹងពាក្យពេចន៍ដ៏ក្បោះក្បាយរបស់លោក សិសារូ។ ដ្បិតអំនួតដ៏ប៉ោងរបស់ទូលបង្គំបានស្អប់ខ្ពើមស្ដាយដ៏សាមញ្ញនៃព្រះបន្ទូល ហើយទូលបង្គំក៏មិនមានការយល់ដឹងល្មមគ្រប់គ្រាន់ ដើម្បីកាត់ន័យលើអត្ថន័យខាងក្នុងនៅឡើយ។ ពិតណាស់! ព្រះបន្ទូលហាក់បីដូចជាគ្រាន់តែជាពាក្យពេចន៍ដែលជាជំនួយដល់ការលូតលាស់ចំពោះមនុស្សបន្ទាបខ្លួនប៉ុណ្ណោះ ប៉ុន្តែទូលបង្គំស្អប់ត្រង់ថាមិនចង់រាប់ខ្លួនជាមនុស្សតូចតាច ហើយដោយមានពេញទៅដោយអំនួត នោះទូលបង្គំក៏មើលមកខ្លួនឯងថាជាមនុស្សពេញវ័យយ៉ាងពេញទី។

១០. ដូច្នេះ ទូលបង្គំក៏ទទួលបានការជះឥទ្ធិពលពីមនុស្សដែលមានភាពរវើរវាយក្នុងអំនួតរបស់ខ្លួន ការរួមដំណេក និងនិយាយប៉ប៉ាច់ប៉ប៉ោច ហើយមាត់របស់ពួកគេគឺជាអន្ទាក់របស់អារក្ស—អន្ទាក់ដែលធ្វើឡើងដោយលាយឡំជាមួយនឹងការសរសើរព្រះនាមរបស់ព្រះអង្គ និងព្រះនាមរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងអ្នកជំនួយរបស់យើងដែលជាព្រះវិញ្ញាណបរិសុទ្ធ។[៦] ពួកគេបាននិយាយល្អអំពីព្រះអង្គ ប៉ុន្តែការសរសើររបស់ពួកគេ

---

៦ នេះគឺជាសេចក្ដីបង្រៀនរបស់ក្រុមមានិហ្គៀន ដែលជាក្រុមខុសឆ្គងមួយក្នុងនិកាយគ្រីស្ទបរិស័ទ។ លោក ម៉ែនីឡាន មកពីប្រទេសពើស៊ីគឺជាអ្នកបង្កើតក្រុមនេះ (ប្រហែលក្នុងអំឡុងឆ្នាំ២១៦-២៧៧ នៃគ.ស)។ ពួកគេអះអាងថាខ្លួនមានរចនាសម្ព័ន្ធសាសនាដែលមានបែបបទយ៉ាងខ្ពង់ខ្ពស់។ ចំណុចវែកញែកចម្បងរបស់ពួកគេគឺត្រង់ថា ខ្លួនមានគោលការណ៍ទ្វេភាពជាមូលដ្ឋាន និងការបង្រៀនយ៉ាងក្បោះក្បាយអំពីប្រវត្តិនៃការបង្កើតលោក។ ពួកគេបង្រៀនថាសេចក្ដីល្អបានកើតឡើងស្របគ្នាជាមួយនឹងពន្លឺ និងអំពើអាក្រក់ជាមួយនឹងសេចក្ដីងងឹត។ ក្នុងក្រុមនេះមានបែងចែកក្រុមតូចមួយទៀតដែលហៅខ្លួនថា «ពួកឥតខ្ចោះ» ហើយពួកនេះត្រូវតែត្រាប់

គឺគ្រាន់តែជាពាក្យពេចន៍ដែលគ្មានន័យប៉ុណ្ណោះ ដ្បិតបេះដូងរបស់ពួកគេក្លែងក្លាយ។ តែពួកគេនៅបន្តស្រែកថា «សេចក្តីពិតៗ» ហើយតែងតែនិយាយអំពីការនោះមកកាន់ទូលបង្គំ។ ប៉ុន្តែ សេចក្តីពិតមិនមានក្នុងពួកគេឡើយ។ ប្រាកដណាស់! ពួកគេមិនគ្រាន់តែនិយាយខុសឆ្គងអំពីតែព្រះអង្គប៉ុណ្ណោះទេ—ដែលទ្រង់ពិតជាសេចក្តីពិតមែន—ប៉ុន្តែក៏អំពីធាតុដើមមួយចំនួននៃផែនដីនេះដែរ ដែលជាការបង្កើតរបស់ព្រះអង្គ។ ឱព្រះដ៏ល្អសប្បុរសជាងគេអើយ ដែលជាព្រះវរបិតារបស់ទូលបង្គំ និងជាសេចក្តីស្រស់ស្អាតនៃរាល់គ្រប់អ្វីៗដែលស្រស់ស្អាត ពិតណាស់! ទូលបង្គំគួររំលងពួកទស្សនវិទូទាំងនោះផ្ទាល់ សូម្បីតែពេលដែលពួកគេកំពុងតែនិយាយអំពីសេចក្តីពិតទាក់ទងនឹងរបស់សព្វសារពើរបស់ព្រះអង្គដែរ ដើម្បីជាប្រយោជន៍នៃសេចក្តីស្រឡាញ់របស់ព្រះអង្គ។ ឱព្រះដ៏ជាសេចក្តីពិតអើយ! ផ្ទៃក្នុងដ៏ជ្រាលជ្រៅនៃព្រលឹងទូលបង្គំប្រាថ្នាចង់បានព្រះអង្គណាស់នៅពេលដែលជារឿយៗ និងក្នុងរបៀបខុសៗគ្នា ហើយជាច្រើនលើកច្រើនសារ និងក្នុងសៀវភៅជាច្រើនរបស់ក្រុមមានិហ្កៀនបានបញ្ចេញសំឡេងអំពីព្រះនាមរបស់ព្រះអង្គ ប៉ុន្តែវាគ្រាន់តែជាសំឡេងប៉ុណ្ណោះ។ ខណៈពេលដែលទូលបង្គំស្រេកឃ្លានចង់បានព្រះអង្គ ក្នុងចានទាំងនោះដែលគេបានយកមកឲ្យទូលបង្គំគឺមិនមានព្រះអង្គឡើយ ប៉ុន្តែបែរជាមានព្រះអាទិត្យ ព្រះចន្ទ និងរបស់សព្វសារពើដ៏ស្រស់ស្អាតរបស់ទ្រង់ទៅវិញ—ប៉ុន្តែ ទោះជាយ៉ាងណាក្តីគឺមានតែរបស់សព្វសារពើរបស់ព្រះអង្គប៉ុណ្ណោះ មិនមែនមានព្រះអង្គផ្ទាល់នោះទេ ប្រាកដណាស់សូម្បីតែរបស់សព្វសារពើដ៏អស្ចារ្យបំផុតរបស់ព្រះអង្គក៏គ្មានផង។ ដ្បិតព័ន្ធកិច្ចខាងឯព្រលឹងវិញ្ញាណរបស់ព្រះអង្គមានការអស្ចារ្យខ្លាំងជាងរបស់សព្វសារពើនៃសម្ភារៈនិយមទាំងនេះទៅទៀត ទោះបើថាវាបញ្ចេញពន្លឺយ៉ាងចែងចាំងលើផ្ទៃមេឃក៏ដោយ។ ប៉ុន្តែ ពេលនោះទូលបង្គំកំពុងតែស្រេកឃ្លាន មិនមែនសូម្បីតែសម្រាប់របស់សព្វសារពើដ៏អស្ចារ្យបំផុតរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ព្រះអង្គផ្ទាល់ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ ពីព្រោះព្រះអង្គផ្ទាល់គឺជាសេចក្តីពិត «ព្រះអង្គមិនចេះប្រែប្រួល សូម្បីតែស្រមោលនៃការផ្លាស់ប្រែក៏គ្មានដែរ»។[៧] ទោះជាយ៉ាងណាក្តី ក៏ពួកគេនៅតែយកការស្រមើ

---

តាមច្បាប់ដ៏តឹងរឹងនៃការរារាំងខ្លួនមិនឲ្យមានភាពអរសប្បាយ។ ហើយក្រៅពីហ្នឹងគឺមាន «ពួកធម្មតា» ដែលគ្រាប់តាមច្បាប់ពីចម្ងាយនៃគោលលទ្ធិរបស់ពួកល្អឥតខ្ចោះ ប៉ុន្តែមិនមែនជាច្បាប់របស់ខ្លួនឡើយ។ ភាពទាក់ទាញចម្បងរបស់ក្រុមមានិហ្កៀនគឺត្រង់ថាវាហាក់បីដូចជាផ្តល់ជូននូវដំណោះស្រាយយ៉ាងចំៗ គួរឲ្យចាប់អារម្មណ៍ ហើយងាយយល់ទាក់ទងទៅនឹងបញ្ហានៃអំពើអាក្រក់ទាំងក្នុងធម្មជាតិ និងក្នុងបទពិសោធន៍មនុស្សយើងផ្ទាល់។

៧ យ៉ាកុប ១:១៧។

ស្រមៃដ៏ភ្លឺត្រចះត្រចង់ក្នុងចានទាំងនោះមកឲ្យទូលបង្គំដដែល។ ហើយពិតណាស់ វាទំនងជាល្អប្រសើរមែនហើយក្នុងការស្រឡាញ់ព្រះអាទិត្យ ដ្បិតយ៉ាងហោចណាស់វាពិតតាមដែលយើងអាចមើលឃើញមែន។ ហើយដោយសារទូលបង្គំគិតថាភាពរវើរវាយនេះមកពីព្រះអង្គផ្ទាល់ ដូច្នេះទូលបង្គំក៏ទទួលយកវា—មិនមែនដោយភាពឆេះឆួល ដ្បិតរសជាតិដែលមានសល់នៅក្នុងមាត់ទូលបង្គំគឺមិនមែនជារសជាតិនៃសេចក្ដីពិត—ហើយវាក៏មិនអាចបានដូច្នោះបានដែរ ដ្បិតវាមិនមែនមកពីព្រះអង្គ ប៉ុន្តែគ្រាន់តែជាការស្រមើស្រមៃដ៏ឥតប្រយោជន៍ប៉ុណ្ណោះ។ ហើយវាមិនបានផ្គត់ផ្គង់ដល់ទូលបង្គំទេ ប៉ុន្តែបែរជាធ្វើឲ្យទូលបង្គំកាន់តែស្រេកឃ្លានខ្លាំងជាងមុនទៅទៀត។ ម្ហូបអាហារក្នុងសុបិន្តមានសភាពដូចជាម្ហូបអាហារដែលយើងកំពុងតែភ្ញាក់ឡើង ប៉ុន្តែអ្នកដេកមិនបានទទួលការផ្គត់ផ្គង់ទេ ដ្បិតពួកគេកំពុងតែដេក។ ប៉ុន្តែ ភាពស្រមើស្រមៃរបស់ក្រុមមានិហ្កៀនមិនមានលក្ខណៈដូចព្រះអង្គទេ ដូចដែលព្រះអង្គបានមានព្រះបន្ទូលមកកាន់ទូលបង្គំឥឡូវនេះ។ ភាពស្រមើស្រមៃរបស់ក្រុមមានិហ្កៀនគ្រាន់តែជាការធ្វើពុតប៉ុណ្ណោះ។

១១. កាលនោះ តើព្រះអង្គនៅទីណា ហើយថាទ្រង់នៅឆ្ងាយពីទូលបង្គំប៉ុណ្ណា? ពិតណាស់ គឺទូលបង្គំបានវង្វេងចេញនៅយ៉ាងឆ្ងាយពីព្រះអង្គ ហើយទូលបង្គំក៏មិនមានការអនុញ្ញាតឲ្យបរិភោគចំណីដែលទូលបង្គំដាក់ឲ្យសត្វជ្រូកស៊ីទៀតផង។[៨] រឿងមិនពិតរបស់អ្នកជំនាញខាងវេយ្យាករណ៍ និងកវីមានលក្ខណៈល្អប្រសើរជាងក្រុមមានិហ្កៀនទៅទៀត។

ដ្បិតទោះបើទូលបង្គំបានច្រៀងអំពី «ការហោះហើររបស់គ្រូធ្មប់មីដោ (Medea)»[៩] ក៏ទូលបង្គំមិនដែលទទួលជឿអំពីវាដែរ ប៉ុន្តែទូលបង្គំបានជឿអំពីការស្រមើស្រមៃរបស់ក្រុមមានិហ្កៀន។ វេទនាហើយៗ គឺតាមជណ្ដើរនេះឯងដែលទូលបង្គំធ្លាក់ទៅក្នុង «ជម្រៅនៃស្ថានឃុំព្រលឹងមនុស្សស្លាប់»[១០]—ដោយពិបាក និងកំពង់បែកផ្សែង ពីព្រោះទូលបង្គំខ្វះសេចក្ដីពិត សូម្បីតែពេលដែលទូលបង្គំកំពុងតែសង្វាតដេញតាមព្រះអង្គក៏ដោយ ឱព្រះជាម្ចាស់អើយ។ ឥឡូវនេះ ទូលបង្គំសូមលន់តួអំពីការនេះទៅកាន់ព្រះអង្គ ដ្បិតព្រះអង្គបានមានសេចក្ដីមេត្តាករុណាលើទូលបង្គំ ពេលទូលបង្គំមិនទាន់ទាំងបានលន់តួទៅកាន់ព្រះ

៨ លូកា ១៥:១៦។

៩ នេះកំពុងតែសំដៅទៅលើទេវកថាសាស្ត្ររបស់សាសន៍ក្រិកអំពីមេធ្មប់មីដោដែលមាននៅទីក្រុងកូរិនថូសដែលកំពុងតែហោះហើរក្នុងរទេះចម្បាំងដែលទាញទៅដោយសត្វនាគពីរក្បាលដែលមានលក្ខណៈដូចជាសត្វពស់។

១០ សុភាសិត ៩:១៨។

អង្គអំពីវាក៏ដោយ។ ទូលបង្គំក៏សង្វាតតាមរកព្រះអង្គ តែមិនមែនយោងតាមការយល់ដឹងខាងឯគំនិតនោះទេ ប៉ុន្តែគ្រាន់តែតាមរយៈការណែនាំពីញាណខាងឯសាច់ឈាម។ ប៉ុន្តែព្រះអង្គជ្រៅជាងជម្រៅដ៏ជ្រៅបំផុតរបស់ទូលបង្គំទៅទៀត ហើយខ្ពស់ជាងការឈោងដ៏ខ្ពស់របស់ទូលបង្គំទៅទៀត។

១៩. ហើយព្រះអង្គបាន «លាព្រះហស្តចុះពីស្ថានលើ»[១១] ហើយទាញព្រលឹងទូលបង្គំឡើងចេញពីភាពងងឹតដ៏សូន្យឈឹងរបស់ក្រុមមានិហ្កៀន ដោយសារអ្នកម្ដាយទូលបង្គំ ដែលជាអ្នកបម្រើដ៏ស្មោះត្រង់ម្នាក់របស់ទ្រង់ បានយំទៅកាន់ព្រះអង្គជំនួសទូលបង្គំខ្លាំងជាងម្ដាយនានាយំសម្រាប់ការស្លាប់ខាងឯសាច់ឈាមរបស់កូនៗខ្លួនទៅទៀត។ ដ្បិតតាមរយៈពន្លឺនៃជំនឿ និងព្រះវិញ្ញាណគាត់បានទទួលពីព្រះអង្គ នោះអ្នកម្ដាយទូលបង្គំឃើញថាទូលបង្គំស្លាប់ហើយ។ ព្រះអង្គព្រះសណ្ដាប់ឮគាត់ ឱព្រះអម្ចាស់អើយ ព្រះអង្គព្រះសណ្ដាប់ឮគាត់! ព្រះអង្គព្រះសណ្ដាប់ឮគាត់ ហើយក៏មិនបានស្អប់ទឹកភ្នែករបស់គាត់ទេ។ ព្រះអង្គពិតជាបានព្រះសណ្ដាប់ឮគាត់មែន។

ដ្បិតតើឲ្យទូលបង្គំពន្យល់បានដោយរបៀបណាទៅអំពីការយល់សប្ដិដែលទ្រង់បានលួងលោមគាត់ ដើម្បីអនុញ្ញាតឲ្យទូលបង្គំរស់នៅជាមួយគាត់ ដើម្បីឲ្យទូលបង្គំទទួលទានក្នុងផ្ទះដូចគាត់? ដ្បិតគាត់ចាប់ផ្ដើមបដិសេធន៍ទូលបង្គំ ពីព្រោះគាត់ស្អប់ខ្ពើមការជេរប្រមាថនៃកំហុសខុសឆ្គងរបស់ទូលបង្គំ។ ក្នុងសុបិន្តរបស់គាត់ គាត់បានឃើញថាខ្លួនឯងកំពុងឈរលើក្ដាររង្វាស់ឈើមួយ ហើយឃើញយុវជនម្នាក់ដែលមានពន្លឺចាំងលើខ្លួន ដើរមកកាន់គាត់ មានដោយអំណរ ហើយក៏បានញញឹមដាក់គាត់ ខណៈពេលដែលអ្នកម្ដាយទូលបង្គំកំពុងកាន់ទុក្ខ ហើយឱនចុះដោយមានការឈឺចាប់។ ប៉ុន្តែ ពេលយុវជននោះសួរនាំគាត់អំពីមូលហេតុនៃទុក្ខព្រួយរបស់គាត់ និងការយំសោកជាប្រចាំថ្ងៃ (មិនមែនដើម្បីរៀនពីគាត់ ប៉ុន្តែដើម្បីបង្រៀនដល់គាត់ ដែលនោះជាទម្លាប់ក្នុងសុបិន្ត) ហើយពេលគាត់ឆ្លើយថាវាទាក់ទងទៅនឹងភាពហិនវិនាសនៃព្រលឹងរបស់ទូលបង្គំ នោះឯងដែលធ្វើឲ្យគាត់កាន់ទុក្ខ យុវជននោះក៏សូមឲ្យគាត់សម្រាកដោយមានការស្កប់ចិត្ត ហើយប្រាប់គាត់ឲ្យមើល ហើយឃើញថាកន្លែងដែលគាត់កំពុងនៅ នោះទូលបង្គំក៏កំពុងនៅដែរ។ ហើយនៅពេលដែលគាត់មើល នោះគាត់ក៏ឃើញទូលបង្គំកំពុងឈរនៅជិតគាត់លើក្ដារ

១១ ទំនុកតម្កើង ១៤៤:៧។

រង្វាស់ឈើមួយនោះដែរ។

តើឲ្យសុបិន្តនេះមកគាត់បានដោយរបៀបណាទៅ លុះត្រាតែព្រះកាណ៌របស់ព្រះអង្គបានព្រះសណ្ដាប់ដួងចិត្តរបស់គាត់? ឱព្រះដ៏មានពេញទៅដោយអំណាចព្រះចេស្ដាដ៏ល្អអើយ! ព្រះអង្គយកព្រះទ័យទុកដាក់លើយើងគ្រប់ៗរូប ហាក់បីដូចជាព្រះអង្គយកព្រះទ័យទុកដាក់សម្រាប់គាត់តែមួយគត់ ដូច្នេះសម្រាប់ទាំងអស់ហាក់បីដូចជាថាមានតែមនុស្សម្នាក់!

២០. តើអ្វីទៅជាមូលហេតុសម្រាប់អ្វីដែលកើតឡើងជាបន្ទាប់? ពេលដែលគាត់បានប្រាប់ទូលបង្គំអំពីសុបិន្តនោះ ហើយទូលបង្គំបានព្យាយាមកាត់ស្រាយដូចនេះ៖ “ម៉ាក់មិនគួរស្អប់គំនិតដែលថា ថ្ងៃណាមួយម៉ាក់នឹងមានលក្ខណៈដូចកូនទេ” គាត់បានឆ្លើយតបវិញភ្លាមដោយមិនមានភាពអាក់អួលថា “ទេ ដ្បិតមិនបានប្រាប់មកអ្នកម្ដាយថា “កន្លែងដែលគាត់នៅ នោះក៏ជាកន្លែងដែលឯងនឹងទៅដែរ” ប៉ុន្តែ “កន្លែងឯងទៅ នោះគាត់ក៏នឹងទៅដែរ”»។

ឱព្រះអម្ចាស់អើយ! ទូលបង្គំសូមថ្វាយទីបន្ទាល់នេះទៅកាន់ព្រះអង្គ តាមដែលទូលបង្គំអាចនឹករលឹកវាបាន—ហើយទូលបង្គំក៏បានលើកឡើងអំពីចំណុចនេះជាច្រើនលើកច្រើនសារដែរ។ ចម្លើយរបស់ព្រះអង្គដែលទ្រង់បានប្រទានដល់អ្នកម្ដាយទូលបង្គំដែលមានការពិនិត្យមើលយ៉ាងផ្ចិតផ្ចង់គឺត្រង់ចំណុចពិតថា៖ គាត់មិនបានមានស្មារតីបារម្ភទាក់ទងទៅនឹងលទ្ធភាពនៃការកាត់ស្រាយដ៏ខុសឆ្គងរបស់ទូលបង្គំទេ ប៉ុន្តែបានឃើញភ្លាមអំពីអ្វីដែលគួរឃើញ—ហើយនោះក៏ជាអ្វីដែលទូលបង្គំមិនបានឃើញយ៉ាងប្រាកដភ្លាមទាល់តែគាត់បានលើកឡើង—ចម្លើយមួយនោះបានប៉ះពាល់ដល់សង្គមយ៉ាងជ្រាលជ្រៅខ្លាំងជាងសុបិន្តគាត់ទៅទៀត។ ទោះជាយ៉ាងណាក្តី តាមរយៈសុបិន្តមួយនោះ អំណរដែលអ្នកម្ដាយដ៏បរិសុទ្ធរបស់ទូលបង្គំនឹងទទួលបាននៅពេលក្រោយគឺព្រះអង្គបានទាយទុកតាំងពីយូរណាស់ទៅហើយទុកជាការលួងលោមចិត្តដល់គាត់ទាក់ទងនឹងភាពឈឺចាប់នៃបច្ចុប្បន្នកាលរបស់គាត់នៅពេលនោះ។

ប្រមាណជិត៩ឆ្នាំបានកន្លងផុតទៅដែលទូលបង្គំបានដេកក្នុងភក់ដ៏ជ្រាលជ្រៅ និងក្នុងក្ដីងងឹតដ៏ខុសឆ្គងមួយនោះ ទូលបង្គំក៏បានព្យាយាមងើបចេញដែរ ប៉ុន្តែរាល់ពេលដែលទូលបង្គំងើប នោះទូលបង្គំក៏បានធ្លាក់ចុះទៅវិញយ៉ាងជ្រៅជាងមុនលើសដើម។ ប៉ុន្តែ ក្នុង

ពេលទាំងនោះ អ្នកម្ដាយដ៏រឹងមាំ និងបរិសុទ្ធរបស់ទូលបង្គំ—ដែលមានរួមទាំងសេចក្ដីស្រឡាញ់របស់ព្រះអង្គ—ក៏កាន់តែមានសង្ឃឹមជាងមុន ទោះបើគាត់មិនបានឈប់យំ និងកាន់ទុក្ខខ្លះៗក៏ដោយ។ គាត់មិនបានឈប់បារម្ភអំពីទូលបង្គំនៅចំពោះព្រះអង្គ ក្នុងរាល់ពេលដែលគាត់អធិស្ឋានដែរ។ សេចក្ដីអធិស្ឋានរបស់គាត់បានចូលទៅកាន់ព្រះវត្តមានរបស់ព្រះអង្គ ប៉ុន្ដែព្រះអង្គនៅតែអនុញ្ញាតឲ្យទូលបង្គំធ្លាក់ចុះក្នុងសេចក្ដីងងឹតនោះ។

២១. ទូលបង្គំបានរំលងសាច់រឿងជាច្រើនក្នុងការរៀបរាប់មួយនេះ ដោយបន្ដលើកឡើងអំពីចំណុចដែលទូលបង្គំគិតថា សំខាន់ជាងក្នុងការដែលទូលបង្គំលើកមកលន់តួទៅកាន់ព្រះអង្គ—ហើយក៏មានចំណុចជាច្រើនដែលទូលបង្គំបានភ្លេចផងដែរ។ ប៉ុន្ដែព្រះអង្គបានប្រទានចម្លើយមួយផ្សេងទៀតទៅកាន់អ្នកម្ដាយទូលបង្គំ តាមរយៈសង្ឃម្នាក់របស់ព្រះអង្គ ដែលជាអ្នកមើលខុសត្រូវរបស់ព្រះម្នាក់ដែលបានកើតចេញពីព្រះវិហាររបស់ព្រះអង្គ ហើយក៏ចេះព្រះគម្ពីរយ៉ាងខ្លាំងដែរ។ នៅពេលដែលអ្នកម្ដាយបានសូមឲ្យគាត់ឯកភាពវែកញែកជាមួយទូលបង្គំ ដើម្បីបង្ហាញការខុសឆ្គងរបស់ទូលបង្គំ ដើម្បីជួយបង្រៀនឲ្យទូលបង្គំបោះបង់អំពើអាក្រក់ ហើយរៀនអំពើល្អ—ដ្បិតនោះគឺជាទម្លាប់ដែលគាត់ធ្វើនៅពេលដែលគាត់ឃើញថាគេបានត្រៀមខ្លួនក្នុងការទទួល—គាត់បានបដិសេធន៍ដែលប្រកបដោយគតិបណ្ឌិត ដូចដែលទូលបង្គំបានឃើញពេលក្រោយ។ គាត់បានឆ្លើយថាទូលបង្គំរឹងចចេសមិនអាចទទួលការបង្រៀនបានទេ ពេញដោយអំនួតនៃភាពថ្មីចម្លែកនៃសេចក្ដីខុសឆ្គង ហើយថាទូលបង្គំក៏ធ្លាប់បានប្រើប្រាស់ទេពកោសល្យវោហាររបស់ខ្លួនក្នុងការដាក់អន្ទាក់ចាប់បុគ្គលដែលមិនមានបទពិសោធន៍ ដោយប្រើប្រាស់សំណួរដែលមានល្បិច ដូចដែលអ្នកម្ដាយទូលបង្គំផ្ទាល់បានប្រាប់គាត់។ “ទុកគាត់តែឯងសិនទៅ” លោកគ្រូនោះបានលើកឡើង “គ្រាន់តែអធិស្ឋានទៅកាន់ព្រះជាម្ចាស់សម្រាប់គាត់បានហើយ។ តាមរយៈការអានដោយខ្លួនឯង នោះគាត់នឹងឃើញកំហុសខុសឆ្គងរបស់ខ្លួន ហើយនឹងឃើញពីភាពស្អប់ខ្ពើមដ៏ខ្លាំងក្លារបស់ព្រះជាម្ចាស់”។ នៅពេលនោះ គាត់ក៏បន្ដប្រាប់អ្នកម្ដាយទូលបង្គំអំពីខ្លួនឯងផ្ទាល់ថា កាលគាត់នៅជាកុមារ អ្នកម្ដាយដែលមានការយល់ខុសរបស់គាត់ក៏ធ្លាប់ដឹកគាត់ចូលក្រុមមានិហ្កៀនផងដែរ ហើយថាគាត់មិនគ្រាន់ត្រឹមតែបានអានប៉ុណ្ណោះទេ ប៉ុន្ដែក៏ថែមទាំងបានចម្លងស្ទើរតែគ្រប់សៀវភៅរបស់ពួកគេទៀតផង។ ទោះជាយ៉ាងណាក្ដី ដោយគ្មានការវែកញែកពីក្រៅ ឬក៏ភស្ដុតាងពីនរណា

ម្នាក់ គាត់ក៏ចាប់ផ្ដើមឃើញថា ដាច់ខាតត្រូវតែបដិសេធន៍ក្រុមនេះ—ហើយគាត់ក៏បានបដិសេធន៍មែន។ នៅពេលដែលគាត់បានចែកចាយអំពីរឿងនេះ អ្នកម្ដាយទូលបង្គំក៏នៅមិនទាន់មានការពេញចិត្តនៅឡើយ ប៉ុន្តែកាន់តែអង្វរករគាត់លើសដើម ហើយក៏បានបង្ហូរទឹកភ្នែកយ៉ាងខ្លាំង ដោយសូមឲ្យគាត់មកមើល ហើយនិយាយជាមួយនឹងទូលបង្គំ។ ជាចុងក្រោយលោកអ្នកមើលការខុសត្រូវរបស់ព្រះម្នាក់នោះក៏បាននិយាយដោយទើសចិត្តបន្តិចនឹងការទទូចដដែលៗរបស់អ្នកម្ដាយទូលបង្គំ «សូមចេញទៅ! ខណៈពេលដែលនាងបន្តរស់នៅ វាមិនអាចទៅរួចបានទេដែលកូនប្រុសនៃអ្នកម្ដាយដែលបង្ហូរទឹកភ្នែកដូចឯងនឹងវិនាស»។ ដូចដែលគាត់បានប្រាប់ទូលបង្គំជារឿយៗក្រោយមក គាត់ក៏ទទួលយកចម្លើយនេះហាក់បីដូចជាថាវាជាសំឡេងពីស្ថានសួគ៌អញ្ចឹង។

# ៦

# ការវង្វេងដោយហោរាសាស្ត្រ

១. សូមទ្រង់ទ្រង់នឹងទូលបង្គំ ទូលបង្គំសូមអង្វរ ហើយសូមប្រទានព្រះគុណដល់ទូលបង្គំក្នុងការត្រឡប់ក្រោយតាមផ្លូវដដែលក្នុងការចងចាំបច្ចុប្បន្នកាលរបស់ទូលបង្គំដែលមានល្បិចកលក្នុងផ្លូវនៃសេចក្តីខុសឆ្គងពី អតីតកាលរបស់ទូលបង្គំ ហើយអនុញ្ញាតឲ្យទូលបង្គំអាចមានសមត្ថភាពក្នុងការ "ថ្វាយយញ្ញបូជា ជាការអរព្រះ គុណដល់ព្រះ"។[១] បើគ្មានព្រះអង្គ តើទូលបង្គំជាអ្វីទៅ? ដ្បិតបើគ្មានព្រះអង្គ នោះទូលបង្គំជាអ្នកដឹកនាំខ្លួនឯងចូលក្នុងការធ្លាក់ចុះផ្ទាល់។ ឬក៏ថា តើទូលបង្គំជាអ្វីទៅ សូម្បីតែក្នុងសណ្ឋានដ៏ល្អប្រសើរបំផុតរបស់ខ្លួន លើកលែងតែគ្រាន់ជាទារកម្នាក់ ដែលកំពុងបំបៅទឹកដោះ

១ ទំនុកតម្កើង ៥០:១៤។

របស់ទ្រង់ និងញ៉ាំម្ហូបដែលមិនចេះខូចរបស់ទ្រង់?[២] ប្រាកដណាស់! បើគ្រាន់តែគាត់ជាមនុស្ស តើបុគ្គលម្នាក់ជាអ្វីទៅ? ដូច្នេះ សូមអនុញ្ញាតឲ្យមនុស្សថ្មីកច្បាំងដ៏ខ្លាំងពូកែសើចចំអកដាក់យើង ប៉ុន្តែសូមឲ្យយើងដែលជា «មនុស្សក្រីក្រ និងមនុស្សកម្សត់ទុគ៌ត»[៣] លន់តួទៅកាន់ព្រះអង្គចុះ។

២. ក្នុងអំឡុងឆ្នាំទាំងនោះ ទូលបង្គំបានបង្រៀនមុខវិជ្ជាវោហារសាស្ត្រ។ ដោយចាញ់សេចក្តីប្រាថ្នានៃការចង់ទទួលបាន ទូលបង្គំបានលក់ជំនាញនៃការនិយាយស្ដី ដើម្បីយកឈ្នះលើអ្នកដទៃ។ ទោះជាយ៉ាងណាក្តី ឱព្រះអម្ចាស់អើយ ទ្រង់ជ្រាបហើយថាទូលបង្គំចង់បានសិស្សដែលស្មោះត្រង់ (ឬក៏អ្វីដែលអ្នកដទៃបានឲ្យតម្លៃដូចនោះ) ហើយដោយគ្មានល្បិចកលនៃទ្រឹស្ដី ទូលបង្គំបានបង្រៀនសិស្សទាំងនោះរបស់ទូលបង្គំនូវល្បិចកលនៃទ្រឹស្ដី—មិនមែនដើម្បីយកទៅប្រើប្រាស់ទាស់ប្រឆាំងនឹងជីវិតមនុស្សដែលគ្មានទោសនោះទេ ប៉ុន្តែពេលខ្លះដើម្បីសង្គ្រោះជីវិតមនុស្សដែលមានពិរុទ្ធភាពទៅវិញ។

ក្នុងអំឡុងឆ្នាំទាំងនោះ ទូលបង្គំបានមានស្រីកំណាន់ចិត្ត ដែលទូលបង្គំមិនបានចងចំណងអាពាហ៍ពិពាហ៍តាមច្បាប់នៅឡើយ។ គាត់គឺជាស្ត្រីម្នាក់ដែលទូលបង្គំបានជ្រើសរើសដោយគ្មានមូលហេតុពិសេសណាក្រៅពី ដើម្បីបំពេញភាពត្រេកត្រអាលរបស់ទូលបង្គំលើនាងតែប៉ុណ្ណោះ។ ប៉ុន្តែ មានតែគាត់មួយគត់ ហើយទូលបង្គំក៏បានបន្តនៅស្មោះត្រង់ជាមួយនឹងគាត់ដែរ។ ដោយសារទំនាក់ទំនងរបស់ទូលបង្គំជាមួយនឹងគាត់ ទូលបង្គំក៏បានស្វែងរកឃើញថា មានចំណុចខុសគ្នាខ្លាំងណាស់រវាងការចាប់ដៃគ្នាក្នុងជីវិតអាពាហ៍ពិពាហ៍ ដើម្បីបង្កើតជាគ្រួសារ និងការស្ម័គ្រចិត្តនៅជាមួយគ្នាដោយមានមូលដ្ឋាននៃសេចក្តីស្រឡាញ់លើតែទង្វើនៃការរួមភេទខាងឯសាច់ឈាម ហើយតាមរយៈការនោះ ការបង្កើតឲ្យមានកូនគឺជាការទាស់ប្រឆាំងនឹងគោលបំណងរបស់ឪពុកម្ដាយ—ទោះបើថាបន្ទាប់ពីកូនបានកើតមកហើយ យើងមិនអាចធ្វើអ្វីបានទេ ក្រៅពីស្រឡាញ់គាត់។

៣. ទូលបង្គំក៏ចាំអំពីពេលមួយ ដែលទូលបង្គំបានចូលប្រកួតក្នុងការសូត្រកំណាព្យ ហើយមានគ្រូទាយម្នាក់បានសួរបង្គំថា តើទូលបង្គំហ៊ានឲ្យលុយគាត់ប៉ុន្មាន ដើម្បីឲ្យប្រាកដថាទូលបង្គំនឹងឈ្នះ។ ប៉ុន្តែ ទូលបង្គំស្អប់ពិធីអធឹកអធមនោះណាស់[៤] ហើយបាន

---

២ យ៉ូហាន ៦:២៧។

៣ ទំនុកតម្កើង ៧៤:២១។

៤ ពិធីអធឹកអធមរបស់គ្រូទាយមានដូចតទៅ៖ គឺពួកគេត្រូវសម្លាប់សត្វសម្រាប់ទទួលបានសញ្ញាទំនាយជោគជ័យ និងជា

ឆ្លើយតបដូចតទៅ "ទោះបើវង្វាន់គឺជាមាសដែលមិនចេះពុករលួយក៏ខ្ញុំនឹងមិនអនុញ្ញាតឲ្យសម្លាប់អ្វីទេ សូម្បីតែសត្វរុយមួយក្បាល ដើម្បីឲ្យខ្ញុំអាចឈ្នះបានដែរ"។ ដ្បិតគាត់ត្រូវសម្លាប់សត្វធ្វើជាយញ្ញបូជា ដើម្បីអញ្ជើញពួកអារក្សឲ្យមកជួយទូលបង្គំ។ ឱព្រះជាម្ចាស់នៃដួងចិត្តទូលបង្គំអើយ! ទូលបង្គំបានបដិសេធន៍អំពើអាក្រក់នោះ មិនមែនដោយចេញពីការស្រឡាញ់ព្រះអង្គដែលមានភាពបរិសុទ្ធនោះទេ ដ្បិតទូលបង្គំមិនដឹងអំពីរបៀបនៃការស្រឡាញ់ព្រះអង្គឡើយ ពីព្រោះទូលបង្គំមិនទាន់ដឹងអំពីរបៀបនៃការយល់អំពីអ្វីដែលមានសម្រស់ស្រស់ស្អាតលើសពីសាច់ឈាមនៅឡើយទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំមិនអនុញ្ញាតឲ្យមានការធ្វើយញ្ញបូជាទៅកាន់អារក្សសម្រាប់ទូលបង្គំឡើយ ទោះបើកាលនោះទូលបង្គំផ្ទាល់នៅបន្តធ្វើយញ្ញបូជាទៅកាន់អារក្ស ក្នុងរបៀបរបស់ទូលបង្គំផ្ទាល់ទាក់ទងទៅនឹងអបិយជំនឿនៃក្រុមមានិហ្កៀន។

៤. ប៉ុន្តែ ទោះជាយ៉ាងណាក្តី ទូលបង្គំបានទៅសួរនាំពួកអ្នកបោកបញ្ឆោតផ្សេងទៀតដែលគេហៅថា "ពួកហោរាសាស្ត្រ" ដោយគ្មានការស្ទាក់ស្ទើរ ពីព្រោះពួកគេមិនធ្វើយញ្ញបូជា ហើយក៏មិនទូលសុំជំនួយពីពួកអារក្ស ទាក់ទងទៅនឹងការទស្សន៍ទាយរបស់ពួកគេដែរ។ ដាច់ខាត! ទោះជាយ៉ាងណាក្តី គ្រីស្ទបរិស័ទដ៏ពិត ហើយស្មោះត្រង់ត្រូវតែបដិសេធន៍ ហើយថ្កោលទោសលើការប្រព្រឹត្តបែបនេះ។

ការលន់តួទៅកាន់ព្រះអង្គគឺជាការល្អ ចូរទទូចថា "សូមប្រណីសន្តោសទូលបង្គំ សូមប្រោសព្រលឹងទូលបង្គំឲ្យបានជា ដ្បិតទូលបង្គំបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គហើយ"[៥]—មិនមែនកេងប្រវ័ញ្ចសេចក្តីសប្បុរសរបស់ព្រះអង្គទុកជាសិទ្ធិនៃការប្រព្រឹត្តអំពើបាប ប៉ុន្តែដើម្បីឲ្យចងចាំព្រះបន្ទូលរបស់ព្រះអម្ចាស់ "មើល៍ អ្នកបានជាហើយ កុំធ្វើបាបទៀត ក្រែងអ្នកមានសេចក្តីអាក្រក់ជាងមុន"។[៦] ពួកក្រុមហោរាសាស្ត្រព្យាយាមបំផ្លាញសេចក្តីពិតទាំងនេះចោល នៅពេលដែលពួកគេនិយាយថា "អ្នកមិនអាចគេចចេញពីបុព្វហេតុនៃអំពើបាបរបស់ខ្លួនបាន ព្រោះវាមានចំណងចងជាប់នៅលើមេឃ" ហើយ "នេះគឺជាទង្វើរបស់ផ្កាយព្រះសុក្រ (Venus) ឬក៏ផ្កាយព្រះសៅរ៍ (Saturn) ឬក៏ផ្កាយព្រះអង្គារ (Mars)"—ទាំងនេះគឺសម្រាប់ឲ្យមនុស្សដែលមានតែសាច់ឈាម ហើយ

ការផ្តាប់ចិត្តដល់ពួកព្រះនានា។

៥ ទំនុកតម្កើង ៤១:៤។

៦ យ៉ូហាន ៥:១៤។

ពេញទៅដោយភាពពុករលួយនៃអំនួតអាចរាប់ខ្លួនឯងថា គ្មានកំហុសខណៈពេលដែលព្រះអាទិករ និងព្រះដែលរៀបចំផ្ទៃមេឃ ហ្វូងតារាត្រូវទទួលការស្ដីបន្ទោសសម្រាប់បញ្ហារបស់យើងទៅវិញ។ ប៉ុន្ដែ តើអ្នកណាជាព្រះអាទិករមួយនេះ ក្រៅពីព្រះអង្គ ឱព្រះជាម្ចាស់ដ៏ផ្អែមល្ហែម និងជាប្រភពនៃសេចក្ដីសុចរិតរបស់យើងអើយ ហើយព្រះអង្គសងមនុស្សគ្រប់រូបដោយយោងតាមទង្វើរៀងៗខ្លួនហើយទ្រង់ក៏មិនស្អប់ «វិញ្ញាណខ្ទេចខ្ទាំ...ចិត្តខ្ទេចខ្ទាំ»?[៧]

៥. នៅពេលនោះ មានបុរសដ៏ឆ្លាតដែលជាគ្រូពេទ្យដ៏ពូកែ និងល្បីល្បាញម្នាក់។[៨] នៅកាលនោះ គាត់គឺជាអ្នកតំណាងជាតិម្នាក់ ហើយគាត់បានដាក់មកុដលើក្បាលដ៏ឈឺរបស់ទូលបង្គំ ដែលទូលបង្គំបានទទួលដោយសារទូលបង្គំបានឈ្នះក្នុងការប្រកួតវោហារសាស្ត្រ។ ទោះជាយ៉ាងណាក្ដីក៏គាត់មិនបានធ្វើការនោះ ក្នុងនាមជាគ្រូពេទ្យម្នាក់បានដែរ ហើយគាត់ក៏មិនអាចព្យាបាលទូលបង្គំបានឡើយ ដ្បិតមានតែព្រះអង្គមួយគត់ដែលអាចព្យាបាលនូវជំងឺបែបនេះបានដូចដែលទូលបង្គំមាន ពីព្រោះ «ព្រះទ្រង់ប្រឆាំងនឹងមនុស្សមានអំនួត តែទ្រង់ផ្ដល់ព្រះគុណដល់មនុស្សដែលបន្ទាបខ្លួនវិញ»។[៩] ប៉ុន្ដែ ព្រះអង្គក៏បានប្រើប្រាស់ សូម្បីតែបុរសដ៏មានវ័យចំណាស់ម្នាក់នេះ ដើម្បីជួយទូលបង្គំដែរ ហើយព្រះអង្គប្រទានថ្នាំដល់ព្រលឹងរបស់ទូលបង្គំ ដែលវាត្រូវការតាមរយៈបុរសម្នាក់នោះឡើយ។ នៅពេលដែលទូលបង្គំកាន់តែស្គាល់គាត់ជាងមុន នោះទូលបង្គំក៏ធ្លាប់ស្ដាប់ពាក្យពេចន៍របស់គាត់ដោយយកចិត្តទុកដាក់ ទោះបើថាគាត់បាននិយាយក្នុងភាសាដ៏សាមញ្ញៗក៏ដោយ ក៏ការនិយាយស្ដីរបស់គាត់មានពេញទៅដោយភាពឆេះឆួល និងភាពស្មោះត្រង់អស់ពីចិត្តដែរ។ ចេញពីការសន្ទនានានារបស់យើង គាត់បានសង្កេតឃើញថា ទូលបង្គំមានការញៀនក្នុងសៀវភៅហោរាសាស្ត្រ ហើយក្នុងរបៀបដ៏ល្អ គាត់ក៏បានផ្ដល់ការប្រឹក្សាដូចជាឪពុកដល់ទូលបង្គំថាឲ្យបោះបង់វាចោលទៅ ហើយកុំឲ្យចំណាយពេលទំនេរលើសំរាមដូចនោះ ដែលបើផ្ទុយពីនោះគាត់អាចចំណាយទៅលើអ្វីដែលមានប្រយោជន៍វិញ។ គាត់ថាគាត់ផ្ទាល់ កាលគាត់នៅក្មេង ក៏បានសិក្សាហោរាសាស្ត្រដោយមានទស្សនៈចង់ទទួលបានប្រាក់កម្រៃសម្រាប់ការរស់នៅតាមរយៈមុខរបរមួយនេះផងដែរ។ ដោយសារគាត់ធ្លាប់យល់លោក ហិបភូក្រាទីស៍ (Hippocrates) ដូច្នេះគាត់ក៏មានសមត្ថភាពយ៉ាងពេញទី

---

៧ ទំនុកតម្កើង ៥១:១៧។

៨ គាត់មានឈ្មោះថាលោកគ្រូ វិនឌីស៊ិនណូស៍ (Vindicianus)។

៩ យ៉ាកុប ៤:៦ និង១ពេត្រុស ៥:៥។

ក្នុងការយល់អំពីចំណុចនេះបានដែរ។ ទោះជាយ៉ាងណាក្ដី ក៏គាត់បានបោះបង់វាចោល ហើយសិក្សាធ្វើជាឱសថការី ដោយសារឃើញមូលហេតុយ៉ាងសាមញ្ញថា៖ ហោរាសាស្ត្រ គឺជាសេចក្ដីខុសឆ្គងទាំងស្រុង ហើយក្នុងនាមជាបុរសដែលមានអត្តចរិតស្មោះត្រង់គាត់គ្មានឆន្ទៈក្នុងការទទួលបានប្រាក់កម្រៃសម្រាប់ការរស់នៅតាមរយៈការកុហកមនុស្សម្នាឡើយ។ “ប៉ុន្តែក្មួយ” គាត់បានលើកឡើង “មានមុខរបរផ្នែកវោហារសាស្ត្រ ដើម្បីទ្រទ្រង់ខ្លួនឯងបាន។ ដូច្នេះ ការដែលក្មួយកំពុងតែដើរតាមទស្សនៈខុសឆ្គងមួយនេះគឺក្មួយកំពុងតែធ្វើដោយឆន្ទៈសេរី ហើយវាមិនមែនជារឿងចាំបាច់ទេ។ អញ្ចឹង ក្មួយត្រូវតែជឿអ៊ំឲ្យខ្លាំងជាងមុន ដោយសារអ៊ំបានខិតខំព្យាយាមសិក្សាហោរាសាស្ត្រឲ្យបានល្អឥតខ្ចោះ ពីព្រោះអ៊ំប្រាថ្នាចង់ទទួលបានប្រាក់កម្រៃទុកជាការរស់នៅតាមរយៈវា!”។ ពេលដែលទូលបង្គំសួរឲ្យគាត់ដោះស្រាយទាក់ទងទៅនឹងចំណុចជាច្រើនដែលជាការពិត ដែលខាងហោរាសាស្ត្របានទាយទុក គាត់បានឆ្លើយមកកាន់ទូលបង្គំដោយមានហេតុផលល្មមដោយថា ទាំងនោះគឺជាឥទ្ធិពលនៃភ័ព្វសំណាងតែប៉ុណ្ណោះ ដែលកើតឡើងតាមរយៈលំដាប់លំដោយរបស់ធម្មជាតិទាំងស្រុង នោះឯងជាមូលហេតុដែលនាំឲ្យការទាំងនោះកើតឡើង។ ដ្បិតពេលបុរសណាម្នាក់ តាមព្រឹត្តិការណ៍ចៃដន្យ បើកសៀវភៅកំណាព្យកវីណាម្នាក់ ដែលមានឃ្លាស៊ីគ្នាយ៉ាងចំៗទៅនឹងសណ្ឋានបច្ចុប្បន្ននៃអ្នកអាន “មនុស្សយើងមិនគួរឆ្ងល់ទេ” គាត់បានបន្តនិយាយថា “បើដោយអចេតនា បុគ្គលណាម្នាក់បានរកឃើញចម្លើយដោយចៃដន្យដែលស៊ីគ្នាទៅនឹងស្ថានភាពនៃកាលៈទេសៈដែលពួកគេកំពុងតែនៅក្នុងនោះ» (ទោះបើអ្នកច្រៀងបានច្រៀង ហើយមានអត្ថន័យខុសពីអត្ថន័យណាមួយផ្សេងទៀតទាំងស្រុងក៏ដោយ)។

៦. សរុបសេចក្ដីទៅ ពិតណាស់ មិនថាតាមរយៈគាត់ ឬក៏ដោយសារគាត់ គឺព្រះអង្គកំពុងតែមើលថែទូលបង្គំ។ មន្ទិលសង្ស័យដែលទ្រង់បានដាំក្នុងការចងចាំរបស់ទូលបង្គំពេលក្រោយទូលបង្គំក៏ស្វែងយល់បន្ថែមទៀតដោយខ្លួនឯង។ ប៉ុន្តែ នៅពេលនោះ ទាំងអ្នកតំណាងជាតិ និងមិត្តភក្ដិដ៏ស្និទ្ធស្នាលរបស់ទូលបង្គំលោក នេប្រេឌីអស៍ (Nebridius)—ពួកគាត់បានមើលងាយលើមុខរបរនៃការទស្សន៍ទាយ—មិនអាចបញ្ចុះបញ្ចូលឲ្យទូលបង្គំបោះបង់ហោរាសាស្ត្រចោលឡើយ ដោយសារអំណាចនៃអ្នកនិពន្ធសៀវភៅហោរាសាស្ត្របានជះឥទ្ធិពលយ៉ាងខ្លាំងលើទូលបង្គំពោលគឺខ្លាំងជាងពួកគាត់ទៅទៀត។ ហើយ

មកដល់ពេលនេះ ទូលបង្គំមិនទាន់ទទួលបានភស្តុតាងដ៏ពិតប្រាកដនៅឡើយទេ—ដូចដែលទូលបង្គំកំពុងតែសង្ខាតដេញតាម—ដែលមានការបង្ហាញដោយគ្មានមន្ទិលសង្ស័យត្រង់ថា អ្វីដែលអ្នកពិគ្រោះយោបល់បានទាយទុកជាមុនបានកើតឡើងដោយចៃដន្យ ឬក៏ភ័ព្វសំណាង ហើយមិនមែនពីហោរាសាស្ត្រ។

# ៧

# ការស្លាប់របស់មិត្តភក្តិទូលបង្គំ

៧. ក្នុងអំឡុងឆ្នាំទាំងនោះ ពេលទូលបង្គំទើបតែត្រឡប់មកស្រុកកំណើតជាដំបូង ដើម្បីចាប់ផ្ដើមបង្រៀនវោហារសាស្ត្រ ទូលបង្គំក៏មានមិត្តភក្តិដែលស្និទ្ធស្នាលម្នាក់ អ្នកដែលមានវ័យដូចទូលបង្គំ ដែលមានទំនាក់ទំនងជាមួយនឹងទូលបង្គំក្នុងការសិក្សាលើមុខវិជ្ជាដូចគ្នា។ គាត់បានធំធាត់ឡើងជាមួយនឹងទូលបង្គំតាំងពីក្មេង ហើយយើងក៏បានទៅរៀនជាមួយគ្នា ហើយក៏ធ្លាប់លេងជាមួយគ្នាដែរ។ ប៉ុន្តែ គាត់មិនមែនជាមិត្តភក្តិរបស់ទូលបង្គំកាលយើងកំពុងតែធំធាត់ឡើងទេ ហើយក៏មិនបានក្លាយជាមិត្តភក្តិក្នុងអត្ថន័យដ៏ចំៗនៃពាក្យនេះដែរ ដ្បិតមិនអាចមានមិត្តភក្តិដ៏ពិតលើកលែងតែរវាងអស់អ្នកដែលព្រះអង្គផ្គុំជាមួយគ្នា និងអស់អ្នកដែលឱបក្រសោបព្រះអង្គតាមរយៈសេចក្ដីស្រឡាញ់ដែល “ព្រះបានបង្ហូរមកក្នុងចិត្តយើង តាមរយៈព្រះវិញ្ញាណបរិសុទ្ធ ដែលព្រះបានប្រទានមក

យើង»។[១] ទោះជាយ៉ាងណាក្តី នោះក៏ជាមិត្តភាពដ៏ល្អមួយដែរ ដោយសារយើងមានចំណាប់អារម្មណ៍ដូចគ្នា។ ទូលបង្គំក៏បានបង្វែរគាត់ចេញពីជំនឿដ៏ពិតដែរ—ដែលគាត់មិនបានកាន់យ៉ាងខ្ជាប់ខ្ជួន ឬក៏យ៉ាងជ្រាលជ្រៅកាលនៅជាយុវជន—ហើយបង្វែរគាត់ចូលរឿងព្រេងដែលជាអបិយជំនឿ និងគ្រោះថ្នាក់ដែលធ្វើឲ្យអ្នកម្តាយទូលបង្គំមានទុក្ខព្រួយយ៉ាងខ្លាំង។ បុរសម្នាក់នេះបានវង្វេងជាមួយទូលបង្គំក្នុងសេចក្តីខុសឆ្គង ហើយព្រលឹងទូលបង្គំក៏ពឹងផ្អែកលើគាត់ផងដែរ។ ប៉ុន្តែ ព្រះអង្គនៅជិតបង្កើយនឹងអ្នករត់គេចពីទ្រង់—ព្រះអង្គគឺជាព្រះដែលសងសឹក ហើយក៏នៅមានប្រភពនៃសេចក្តីមេត្តាករុណាស្របពេលតែមួយផងដែរ ហើយទ្រង់ក៏បង្វែរយើងឲ្យទៅរកព្រះអង្គវិញក្នុងរបៀបដែលធ្វើឲ្យយើងស្ញប់ស្ញែង។ ព្រះអង្គបានដកបុរសនោះចេញពីជីវិតនេះខណៈពេលដែលគាត់មិនទាន់ទាំងបានធ្វើជាមិត្តភក្តិទូលបង្គំបានមួយឆ្នាំផង។ មកដល់ពេលនោះ ចំពោះទូលបង្គំ មិត្តភាពរបស់យើងគឺមានភាពផ្អែមល្ហែមណាស់ ពោលគឺមានភាពផ្អែមល្ហែមខ្លាំងជាងអ្វីដែលទូលបង្គំធ្លាប់ពិសោធន៍ទៅទៀត។

៨. តើអ្នកណាអាចរៀបរាប់ការសរសើរតម្កើងព្រះជាម្ចាស់បាន[២] សូម្បីតែប្រសិនបើគ្រាន់តែអំពីអស់ទាំងអ្វីៗដែលគាត់ធ្លាប់បានដកពិសោធន៍នៅក្នុងជីវិតគាត់ផ្ទាល់? ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! តើទ្រង់បានធ្វើអ្វីនៅពេលនោះ? យើងមិនអាចស្វែងយល់អំពីជម្រៅនៃការថ្កោលទោសរបស់ទ្រង់បានឡើយ។ ដ្បិតពេលដែលមិត្តភក្តិរបស់ទូលបង្គំកំពុងតែធ្លាក់ខ្លួនឈឺយ៉ាងធ្ងន់ធ្ងរដោយជំងឺគ្រុនក្តៅ ដោយដេកទាំងមិនដឹងខ្លួនក្នុងញើសនៃសេចក្តីស្លាប់ ហើយគ្មានអ្នកណាគិតថាគាត់នឹងជាវិញឡើយ គាត់ក៏ទទួលពិធីជ្រមុជទឹកដោយទាំងមិនដឹងខ្លួនផង។ ហើយនៅកាលនោះ ទូលបង្គំក៏មិនសូវយកចិត្តទុកដាក់ប៉ុន្មានដែរ ដោយសន្មតថាព្រលឹងរបស់គាត់នឹងបន្តទុកនូវអ្វីដែលគាត់បានយកពីទូលបង្គំជាជាងអ្វីដែលគេកំពុងតែធ្វើលើរូបកាយដែលមិនមានស្មារតីរបស់គាត់។ ទោះជាយ៉ាងណាក៏ដោយ ក៏ដំណើររឿងមួយនេះបានប្រែយ៉ាងខុសស្រឡះចេញពីអ្វីដែលយើងបានគិតទាំងស្រុង ដ្បិតគាត់បានជាសះស្បើយ ហើយមានកម្លាំងវិញ។ ភ្លាមៗនោះ ពេលដែលទូលបង្គំអាចនិយាយជាមួយគាត់បាន—នោះទូលបង្គំក៏ព្យាយាមលេងសើចជា

១ រ៉ូម ៥:៥។
២ ទំនុកតម្កើង ១០៦:២។

មួយគាត់ ដោយគិតថាគាត់ក៏នឹងលេងសើចវិញអំពីការជ្រមុជទឹកដែលគាត់បានទទួល ខណៈពេលដែលខួរក្បាល និងស្មារតីរបស់គាត់អសកម្ម ប៉ុន្តែគាត់ក៏ដឹងថានោះក៏ជាអ្វីដែលគាត់បានទទួលដែរ។ ប៉ុន្តែ គាត់បានថយចេញពីទូលបង្គំ ហាក់បីដូចជាថាទូលបង្គំគឺជាខ្មាំងសត្រូវរបស់គាត់ ហើយដោយមានការឆ្លើយតបដែលគួរឲ្យកត់សម្គាល់ និងសេរីភាពដែលមិនគួរនឹងរំពឹងដល់ គាត់ក៏បានស្តីបន្ទោសទូលបង្គំថា ប្រសិនបើទូលបង្គំនៅប្រាថ្នាចង់ធ្វើជាមិត្តភក្តិរបស់គាត់ នោះដាច់ខាតទូលបង្គំត្រូវតែឈប់និយាយលេងសើចអំពីរឿងបែបនោះ។ ដោយមានការច្រទាំ និងការច្របូកច្របល់ នោះទូលបង្គំក៏បានលាក់អារម្មណ៍ខ្លួន រហូតដល់ពេលគាត់ជាសះស្បើយ ហើយឲ្យសុខភាពរបស់គាត់បានល្អប្រសើរជាងមុនគ្រប់គ្រាន់ក្នុងការឲ្យទូលបង្គំអាចជែកញែកអំពីចំណុចនេះឲ្យកាន់តែស៊ីជម្រៅបាន។ ប៉ុន្តែ គាត់ក៏ត្រូវបានដកចេញពីទូលបង្គំ និងភាពភ្លីភ្លើរបស់ទូលបង្គំ ដើម្បីឲ្យនៅដោយមានសុវត្ថិភាពជាមួយនឹងព្រះអង្គ ដើម្បីឲ្យថានៅចុងបញ្ចប់ នោះទូលបង្គំអាចទទួលការលួងលោមបាន។ ពីរបីថ្ងៃក្រោយមក ពេលទូលបង្គំមិននៅជិតគាត់ គ្រុនក្តៅក៏បានកើតឡើងម្តងទៀត ហើយគាត់ក៏ស្លាប់បាត់ទៅ។

៩. តាមរយៈទុក្ខព្រួយមួយនេះ ដួងចិត្តរបស់ទូលបង្គំក៏ឈឺចាប់ឥតឧបមា ហើយទីណាដែលទូលបង្គំមើល នោះទូលបង្គំតែងតែឃើញសេចក្តីស្លាប់នៅទីនោះ។ ស្រុកកំណើតទូលបង្គំក៏បានក្លាយជាបន្ទប់នៃកន្លែងធ្វើទារុណកម្មចំពោះទូលបង្គំ ហើយផ្ទះរបស់ឪពុកទូលបង្គំបានក្លាយជាភាពមិនអរសប្បាយយ៉ាងចម្លែក។ ហើយរាល់អ្វីៗដែលទូលបង្គំបានធ្លាប់ធ្វើជាមួយនឹងគាត់—គឺដោយសារគាត់បានទៅបាត់ហើយ—បានក្លាយជាការធ្វើទុក្ខដ៏គួរឲ្យភ័យខ្លាច។ ភ្នែកទូលបង្គំស្វែងរកគាត់គ្រប់ទីកន្លែង ប៉ុន្តែវាមិនអាចរកឃើញគាត់ឡើយ ហើយទូលបង្គំក៏ស្អប់រាល់គ្រប់កន្លែងផងដែរ ពីព្រោះគាត់មិននៅទីនោះ ពីព្រោះកន្លែងទាំងនោះមិនអាចនិយាយមកទូលបង្គំថា «មើល៍! គាត់កំពុងតែមកហើយ» ដូចដែលវាធ្លាប់ធ្វើពេលគាត់នៅរស់ ប៉ុន្តែអវត្តមាន។ ទូលបង្គំក៏បានសួរព្រលឹងខ្លួនអំពីមូលហេតុដែលធ្វើឲ្យទូលបង្គំបាក់ទឹកចិត្តយ៉ាងខ្លាំង ហើយថាហេតុអ្វីបានជាទូលបង្គំមានអារម្មណ៍ក្តុកក្តួលយ៉ាងខ្លាំងក្រៃលែងម្ល៉េះ។[៣] ប៉ុន្តែ ទូលបង្គំមិនបានឮចម្លើយ

---

៣ ទំនុកតម្កើង ៤២:៥ និង៤៣:៥។

អ្វីសោះ។ ហើយប្រសិនបើទូលបង្គំប្រាប់ព្រលឹងខ្លួនថា «ចូរសង្ឃឹមដល់ព្រះទៅ»[៤] នោះទូលបង្គំនឹងបដិសេធន៍គំនិតនោះទាំងស្រុង ពីព្រោះមិត្តភក្តិដ៏ស្និទ្ធស្នាលនោះដែលទូលបង្គំបានបាត់បង់គឺជាមនុស្សដ៏ពិតប្រាកដ ហើយគាត់ក៏ពិតជាង និងល្អប្រសើរជាងព្រះក្លែងក្លាយដែលទូលបង្គំនឹកស្រមៃចង់ទុកចិត្តលើទៀតផង។ ចំពោះទូលបង្គំ គ្មានអ្វីក្រៅពីទឹកភ្នែកដែលផ្អែមល្ហែមទេ ហើយវាក៏បានយកជំនួសទីកន្លែងនៃមិត្តភក្តិរបស់ទូលបង្គំក្នុងដួងចិត្តទូលបង្គំដែរ។

១០. ប៉ុន្តែឥឡូវនេះ ឱព្រះអម្ចាស់អើយ អ្វីៗទាំងនោះបានកន្លងផុតទៅហើយ ហើយពេលវេលាក៏បានព្យាបាលរបួសទូលបង្គំផងដែរ។ ឱព្រះដ៏ជាសេចក្ដីពិតអើយ! សូមអនុញ្ញាតឲ្យទូលបង្គំរៀនពីព្រះអង្គ ហើយសូមដាក់ត្រចៀកនៃដួងចិត្តរបស់ទូលបង្គំនៅក្បែរព្រះឱស្ឋរបស់ទ្រង់ ដើម្បីឲ្យព្រះអង្គអាចប្រាប់ទូលបង្គំអំពីមូលហេតុដែលការយំសោកគឺជាការដ៏ផ្អែមល្ហែមចំពោះអស់អ្នកដែលមិនអរសប្បាយ។ ទោះបើព្រះអង្គមានព្រះវត្តមាននៅគ្រប់ទីកន្លែងក៏ដោយក៏ថា តើព្រះអង្គបានដកនូវការរងទុក្ខរបស់យើងចេញពីការយកព្រះហឫទ័យទុកដាក់របស់ទ្រង់មែនឬ? តើព្រះអង្គបានតាំងរូបអង្គទ្រង់នៅដាច់ឆ្ងាយពីយើង ខណៈពេលដែលយើងត្រូវបានបោកហើយផាត់ចុះឡើងដោយការរងទុក្ខពីមួយទៅមួយមែនឬ? ទោះជាយ៉ាងណាក្តីយើងក៏នឹងមិនមានសល់សង្ឃឹមទៀតឡើយ ប្រសិនបើការទទូចអង្វរដែលពោរពេញទៅដោយទឹកភ្នែករបស់យើងមិនអាចទៅដល់ព្រះកាណ៌របស់ទ្រង់បាន។ តើផលផ្លែដ៏ផ្អែមល្ហែមបែបនេះត្រូវបានដកចេញពីភាពល្វីងជូរចត់នៃជីវិតដោយរបៀបណាទៅ ពីការថ្ងូរ ការយំ ការដកដង្ហើមធំ និងការកាន់ទុក្ខ? តើសេចក្ដីសង្ឃឹមដែលទ្រង់នឹងព្រះសណ្ដាប់ឮពីយើងនោះធ្វើឲ្យវាផ្អែមមែនឬ? ក្នុងករណីនៃការអធិស្ឋាន ការនេះគឺពិតមែន ដ្បិតក្នុងការអធិស្ឋានគឺមានសេចក្ដីប្រាថ្នាចង់ចូលទៅកាន់ទ្រង់។ ប៉ុន្តែ វាក៏ដូច្នោះដែរ ក្នុងករណីនៃការកាន់ទុក្ខសម្រាប់ការបាត់បង់អ្នកដែលយើងស្រឡាញ់ និងនៅក្នុងការព្រួយបារម្ភបែបនេះដែលបានបំបាក់ទូលបង្គំនៅពេលនោះ? ដ្បិតទូលបង្គំមិនសង្ឃឹមថា គាត់នឹងរស់ពីស្លាប់ឡើងវិញ ឬក៏ថាទូលបង្គំស្វែងរកឃើញការអស្ចារ្យនេះក្នុងរាល់ការស្រក់ទឹកភ្នែករបស់ទូលបង្គំផងដែរ។ ទូលបង្គំគ្រាន់តែកាន់ទុក្ខ និងយំ ដ្បិតទូលបង្គំវេទនា ហើយក៏បានបាត់បង់អំណរទៀតផង។ ឬក៏ថា តើការ

៤ ទំនុកតម្កើង ៤៣:៥។

យំសោកគឺជាភាពល្វីងជូរចត់ដែលនាំឲ្យយើងអរសប្បាយ ពីព្រោះយើងស្អប់អ្វីដែលពីមុនធ្លាប់ធ្វើឲ្យយើងអរសប្បាយមែនឬ?

១១. ប៉ុន្តែ ហេតុអ្វីបានជាទូលបង្គំរៀបរាប់អំពីចំណុចទាំងអស់នេះ? ឥឡូវនេះមិនមែនជាពេលវេលា ដើម្បីសួរសំណួរព្រះអង្គនោះទេ ប៉ុន្តែផ្ទុយទៅវិញគឺជាពេលវេលានៃការលន់តួទៅកាន់ទ្រង់វិញ។ ទូលបង្គំពិតជាមិនសប្បាយចិត្តណាស់ដែរ។ ហើយរាល់ព្រលឹងដែលជាប់ច្រវាក់ទៅនឹងមិត្តភាពនៃអ្វីៗដែលនឹងស្លាប់ទៅក៏ពិតជាអាក្រក់ណាស់ដែរ—ហើយវាក៏នឹងបែកបាក់ពេលដែលវាបាត់បង់របស់ទាំងនោះ ហើយបន្ទាប់មកក៏នឹងយល់អំពីទុក្ខវេទនាដែលវាមាន សូម្បីតែមុនពេលដែលវាបានបាត់បង់ទៀតផង។ ពេលនោះឯងគឺជាពេលវេលាដែលការនោះបានកើតឡើងមកកាន់ទូលបង្គំ។ ទូលបង្គំបានយំសោកយ៉ាងល្វីងជូរចត់ ហើយក៏រកឃើញកន្លែងសម្រាកក្នុងភាពល្វីងជូរចត់ផងដែរ។ ទូលបង្គំមិនសប្បាយចិត្តយ៉ាងខ្លាំងដល់ថ្នាក់ថាទូលបង្គំមានអារម្មណ៍ស្និទ្ធស្នាលជាប់ជាមួយនឹងជីវិតដ៏វេទនារបស់ទូលបង្គំខ្លាំងជាងទូលបង្គំបានមានជាមួយនឹងមិត្តភក្តិរបស់ទូលបង្គំដែលបានស្លាប់ទៅទៀត។ ដ្បិតទោះបើទូលបង្គំចង់ឲ្យវាមានភាពខុសប្លែកក៏ដោយក៏ទូលបង្គំមិនសុខចិត្តជាដាច់ខាតក្នុងការបាត់បង់ភាពវេទនារបស់ខ្លួនជាជាងបាត់បង់គាត់ដែរ។ ប្រាកដណាស់! ទូលបង្គំមានមន្ទិលសង្ស័យត្រង់ថា តើទូលបង្គំហ៊ានស្ម័គ្រចិត្តលះបង់ជីវិតខ្លួន សូម្បីតែសម្រាប់គាត់—ដូចដែលគេបានប្រាប់ (លុះត្រាតែវាជារឿងព្រេង) អំពីមិត្តភាពរវាងលោក អូរីស្ទេស៍ (Orestes) និងលោក ហ្វីឡាដេស៍ (Pylades)។[៥] ពួកគេទាំងពីរនាក់ទំនងជានឹងសប្បាយចិត្តក្នុងការស្លាប់សម្រាប់គ្នាទៅវិញទៅមក ឬក៏ជាមួយគ្នា ពីព្រោះការរស់ដោយគ្មានគ្នាគឺពិបាកជាងការស្លាប់ទៅទៀតចំពោះពួកគេ។ ប៉ុន្តែ មានអារម្មណ៍ដ៏ចម្លែកមួយបានមកគ្របដណ្តប់លើទូលបង្គំ គឺមានលក្ខណៈខុសគ្នាខ្លាំងណាស់ពីរឿងមួយនេះ ដ្បិតទូលបង្គំស្អប់ជីវិត ប៉ុន្តែទូលបង្គំក៏មានការភ័យខ្លាចក្នុងការស្លាប់ដែរ។ ទូលបង្គំគិតថាខណៈពេលដែលទូលបង្គំកាន់តែស្រឡាញ់មិត្តភក្តិទូលបង្គំ នោះទូលបង្គំក៏កាន់តែស្អប់ ហើយមានការភ័យខ្លាចជាងមុន ដែលនោះគឺជាខ្មាំងសត្រូវដ៏ឃោរឃៅខ្លាំងណាស់ គឺសេចក្តីស្លាប់ដែលបានប្លន់គាត់ពីទូលបង្គំ។ ទូល

៥ ត្រង់នេះលោកគ្រូ អហ្គស្ទីន ទំនងជាកំពុងសំដៅទៅលើតួឯកក្នុងរឿងល្ខោនមួយនិពន្ធដោយលោក យូរីភីដេស៍ (Euripedes) នៅឆ្នាំ៤០៨មុនគ.ស.។ លោក ហ្វីឡាដេស៍ បានប្រឆាំងគ្នាយ៉ាងខ្លាំងជាមួយនឹងលោក អូរីស្ទេស៍ ដោយឆ្លងកាត់បញ្ហាជាច្រើនបន្ទាប់ពីលោក អូរីស្ទេស៍ បានសងសឹកឃាតកម្មសម្រាប់ឪពុករបស់គាត់ ដោយសម្លាប់ឃាតករ—ដែលជាអ្នកម្តាយរបស់គាត់។

បង្គំថែមទាំងស្រមៃថាសេចក្ដីស្លាប់នឹងបំផ្លាញមនុស្សទាំងអស់ចោលក្នុងពេលមួយរំពេច ដោយសារវាមានអំណាចដូចនោះលើមិត្តភក្ដិទូលបង្គំ។ នេះគឺជាអ្វីដែលទូលបង្គំចងចាំទាក់ទងទៅនឹងស្ថានភាពនៃគំនិតរបស់ទូលបង្គំនៅពេលនោះ។

ឱព្រះជាម្ចាស់អើយ! សូមសម្លឹងមើលមកក្នុងដួងចិត្តរបស់ទូលបង្គំ។ សូមមើលទូលបង្គំឲ្យជ្រៅ ដ្បិតទូលបង្គំចងចាំអំពីវាយ៉ាងច្បាស់ណាស់ ឱព្រះដ៏ជាសេចក្ដីសង្ឃឹមរបស់ទូលបង្គំអើយ ដែលទ្រង់សម្អាតទូលបង្គំចេញពីភាពមិនស្អាតស្អំនៃការលង់មួយនោះ។ ព្រះអង្គបានបង្វែរភ្នែកទូលបង្គំទៅកាន់ទ្រង់ ហើយក៏បានដកជើងទូលបង្គំចេញពីអន្ទាក់នោះផងដែរ។ ហើយឥឡូវទូលបង្គំស្ញប់ស្ញែងលើអស់អ្នកដែលបន្តរស់នៅ ដោយសារបុគ្គលដែលទូលបង្គំបានស្រឡាញ់ ហាក់បីដូចជាថាគាត់នឹងមិនស្លាប់ ឥឡូវនេះបែរជាស្លាប់បាត់ទៅហើយ។ ហើយទូលបង្គំក៏កាន់តែស្ញប់ស្ញែងត្រង់ថា ទូលបង្គំដែលជាបុគ្គលទីពីរផ្ទាល់ចំពោះគាត់អាចនៅបន្តរស់នៅ ខណៈពេលដែលគាត់បានស្លាប់ទៅបាត់ហើយ។ មានគេនិយាយត្រូវណាស់អំពីមិត្តភក្ដិរបស់ខ្លួនថាជា «មួយចំហៀងទៀតនៃព្រលឹងរបស់ខ្លួន»—ដ្បិតទូលបង្គំមានអារម្មណ៍ថាព្រលឹងរបស់ទូលបង្គំ និងព្រលឹងរបស់គាត់គឺជាព្រលឹងតែមួយក្នុងរូបកាយពីរ។ ជាលទ្ធផល ឥឡូវនេះជីវិតទូលបង្គំគឺជាភាពភ័យខ្លាចក៏ភ័យរន្ធត់ចំពោះទូលបង្គំ ពីព្រោះទូលបង្គំមិនចង់បន្តរស់នៅជាចំហៀងតែម្ខាងផ្ទាល់នោះទេ។ ប៉ុន្តែ វាទំនងមកពីទូលបង្គំខ្លាចស្លាប់ ក្រែងលោបុគ្គលដែលទូលបង្គំធ្លាប់ស្រឡាញ់យ៉ាងខ្លាំងនឹងទំនងជាស្លាប់ទាំងស្រុងតែម្ដង។

១២. ការដែលមិនចេះស្រឡាញ់បុគ្គលណាម្នាក់ក្នុងរបៀបដែលពួកគាត់ស័ក្ដិសមនឹងទទួលគឺជាការល្ងីល្ងើណាស់។ កាលនោះ ទូលបង្គំគឺពិតជាបុរសដ៏ល្ងីល្ងើម្នាក់យ៉ាងខ្លាំងមែន ព្រោះទូលបង្គំរអ៊ូរទាំអំពីអ្វីដែលបុគ្គលទាំងអស់ត្រូវតែឆ្លងកាត់! ទូលបង្គំងប់ងុលខ្លាំងពេកក្នុងអារម្មណ៍នៃភាពឈឺចាប់របស់ទូលបង្គំដល់ថ្នាក់ថាទូលបង្គំមិនអាចសម្រាក ឬក៏ស្ដាប់ការប្រឹក្សាយោបល់ដ៏ល្អដែលអ្នកដទៃបានផ្ដល់ជូនទូលបង្គំទៀតផង។ ទូលបង្គំកំពុងតែអូសបន្លាយនូវព្រលឹងដែលបាក់បែក និងពោរពេញទៅដោយឈាមរបស់ទូលបង្គំ។ ទូលបង្គំអស់កម្លាំងណាស់ក្នុងការអូសវាទៅនេះទៅនោះ ប៉ុន្តែទោះជាយ៉ាងណាក្ដីក៏ទូលបង្គំមិនអាចស្វែងរកទីកន្លែងណាមួយ ដើម្បីដាក់វាចុះបានឡើយ។ ទូលបង្គំមិនអាចរកការសម្រាកបានឡើយមិនថាក្នុងព្រៃព្រឹក្សាដ៏ស្រស់ស្អាត ក្នុងកីឡា ឬក៏ចម្រៀង ក្នុង

សួនច្បារដែលមានក្លិនដ៏ក្រអូប ឬក៏កន្លែងជប់លៀង ក្នុងការសប្បាយក្នុងការរួមភេទ ឬក៏ក្នុងសៀវភៅ និងកំណាព្យផងដែរ។ មើលទៅរាល់អ្វីៗទាំងអស់មានភាពស្រងូតស្រងាត់ សូម្បីតែពន្លឺផ្ទាល់ក៏ដូច្នោះដែរ។ ពេលនោះ ជីវិតគឺគួរឲ្យស្អប់ខ្ពើមណាស់ លើកលែងតែក្នុងការថ្ងូរ និងបង្ហូរទឹកភ្នែករបស់ទូលបង្គំ ដ្បិតមានតែក្នុងចំណុចទាំងនេះឯងទើបទូលបង្គំរកបានការសម្រាកបន្តិចបន្តួច។ ប៉ុន្តែ នៅពេលដែលព្រលឹងទូលបង្គំឈប់យំ នោះក៏មានបន្ទុកដ៏ធ្ងន់នៃភាពវេទនាធ្លាក់លើទូលបង្គំផងដែរ។ ឱព្រះអម្ចាស់អើយ! ទូលបង្គំគួរតែលើកវាទូលទៅកាន់ទ្រង់ ដើម្បីឲ្យព្រះអង្គសម្រាល និងដកវាចេញ។ ទាក់ទងនឹងចំណុចនេះ ទូលបង្គំបានដឹង ប៉ុន្តែទូលបង្គំមិនទាំងមានឆន្ទៈ ឬក៏សមត្ថភាពក្នុងការធ្វើវាឡើយ ជាពិសេសដោយសារក្នុងគំនិតទូលបង្គំអំពីព្រះអង្គ ទ្រង់គឺមិនមែនជាបុគ្គលដ៏ពិតនោះទេ ប៉ុន្តែគ្រាន់តែជាការស្រមើស្រមៃដ៏ឥតប្រយោជន៍ប៉ុណ្ណោះ។ ដូច្នេះ ការកុហករបស់ទូលបង្គំគឺជាព្រះរបស់ទូលបង្គំ។ ប្រសិនបើទូលបង្គំព្យាយាមទម្លាក់ទុក្ខកង្វល់របស់ទូលបង្គំលើភាពស្រមើស្រមៃមួយនេះ ដើម្បីឲ្យទូលបង្គំអាចទទួលបានការសម្រាកនៅទីនោះ នោះទូលបង្គំនឹងធ្លាក់ចូលក្នុងភាពសូន្យ នោះទុក្ខកង្វល់របស់ទូលបង្គំនឹងត្រឡប់មកវិញដោយធ្លាក់លើទូលបង្គំជាថ្មីម្តងទៀតជាមិនខាន។ ទូលបង្គំបានដាក់ខ្លួនក្នុងស្ថានភាពដ៏លំបាក ត្រង់ថាទូលបង្គំមិនអាចបន្តនៅ ឬក៏ចាកចេញបានឡើយ។ ដ្បិតតើឲ្យដួងចិត្តទូលបង្គំអាចទៅឯណាបានក្នុងការរត់គេចចេញពីដួងចិត្តខ្លួនឯង? តើឲ្យទូលបង្គំទៅទីណា ដើម្បីគេចចេញពីខ្លួនឯងបាន? តើឲ្យទូលបង្គំអាចទៅទីណា ហើយមិនឲ្យមានការតាមខ្លួនឯងបាន? ហើយទោះជាយ៉ាងណាក្តីក៏ទូលបង្គំបានរត់ចេញពីស្រុកកំណើតខ្លួន ដើម្បីឲ្យភ្នែកទូលបង្គំដែលតែងតែមើលគាត់មិនសូវឃើញក្នុងទីកន្លែងដែលវាតែងតែឃើញគាត់ទៀត។ ដូច្នេះ ទូលបង្គំក៏បានចាកចេញពីទីក្រុងធាហ្គាស្ទេ ហើយត្រឡប់ទៅទីក្រុងកាតាផេវិញ។

# ៨

# ពេលវេលាមិនចេះឈប់

១៣. ពេលវេលាមិនចេះឈប់ ហើយក៏មិនចេះបន្ថយល្បឿនដែរ ទោះបើថាពេលខ្លះទស្សនៈរបស់យើងគិតថាពេលវេលាធ្វើបែបដូច្នោះមែនក៏ដោយ។ បទពិសោធន៍ទូលបង្គំបានមកដល់ ហើយក៏ត្រឡប់ទៅវិញពីមួយថ្ងៃទៅមួយថ្ងៃ ហើយតាមរយៈការមក និងការទៅវិញ វានាំឲ្យខួរក្បាលទូលបង្គំនឹកចាំអំពីការចងចាំ និងគំនិតនានាជាច្រើនទៀត។ ហើយបន្តិចម្ដងៗ ពេលវេលាក៏បានព្យាបាលរបួសទូលបង្គំ ហើយទូលបង្គំក៏មានសមត្ថភាពក្នុងការដកបទពិសោធន៍ទៅលើអ្វីដែលទូលបង្គំធ្លាប់អរសប្បាយជាមួយនោះសាជាថ្មីម្ដងទៀតបាន។ ប៉ុន្តែ បន្ទាប់ពីទុក្ខព្រួយនោះក៏មានទុក្ខព្រួយផ្សេងៗទៀតបានកើតឡើងផងដែរ មិនមែនទុក្ខព្រួយដូចគ្នាទាំងស្រុងនោះទេ តែគឺជាទុក្ខព្រួយប្រភេទផ្សេងទៀត។ ដ្បិតហេតុអ្វីបានជាទុក្ខព្រួយដំបូងមួយនោះបានជះឥទ្ធិពលយ៉ាងងាយស្រួលម្ល៉េះលើ

ទូលបង្គំ? មូលហេតុគឺដោយសារទូលបង្គំបានចាក់ព្រលឹងខ្លួនចោលលើដី តាមរយៈការស្រឡាញ់បុគ្គលម្នាក់ ហាក់បីដូចជាថាគាត់នឹងមិនដែលស្លាប់ឡើយ។ ប៉ុន្តែ មនុស្សទាំងអស់គ្នាត្រូវតែស្លាប់។ ការលួងលោមពីមិត្តភក្តិរបស់ទូលបង្គំគឺជាអ្វីដែលបានផ្ដល់ជាកម្លាំងចិត្ត និងជាការស្រស់ស្រាយដល់ទូលបង្គំខ្លាំងជាងអ្វីៗផ្សេងទៀត។ ហើយទូលបង្គំបានដាក់ចំណាប់អារម្មណ៍របស់ទូលបង្គំលើពួកគាត់ ជាជាងការស្រឡាញ់ព្រះអង្គ។ នេះគឺជាឧបាយកលដ៏ឃោរឃៅ និងជាការកុហកដ៏ព្រៃផ្សៃ៖ គឺថាការស្រឡាញ់លោកីយ៍នេះអាចផ្ដល់ការស្កប់ស្កល់ចិត្តបាន ហើយការកុហកមួយនេះបានបង្វែរព្រលឹងរបស់មនុស្សឲ្យមានការមិនស្មោះត្រង់ចំពោះព្រះអង្គ។ ហើយនៅពេលដែលមិត្តភក្តិណាម្នាក់របស់ទូលបង្គំស្លាប់ នោះឧបាយកលមួយនេះក៏នឹងមិនស្លាប់ជាមួយគាត់ដែរ។ ហើយជាថ្មីម្ដងទៀតជីវិតទូលបង្គំក៏មានការពឹងលើមិត្តភាពដែលជាមនុស្ស។ យើងតែងតែនិយាយ និងសើចសប្បាយជាមួយគ្នា។ យើងអានសៀវភៅដែលគួរឲ្យចាប់អារម្មណ៍ជាមួយគ្នា។ យើងតែងតែលេងសើចជាមួយគ្នា ហើយពេលខ្លះយើងក៏មានភាពម៉ឺងម៉ាត់ផងដែរ។ យើងតែងតែមិនឯកភាពដោយមិនមានការអន់ចិត្ត។ ពេលខ្លះយើងបង្រៀន ហើយពេលខ្លះទៀតយើងទទួលការបង្រៀន។ យើងតែងតែនឹកនាដល់មិត្តភក្តិដែលអវត្តមាន ហើយស្វាគមន៍ពួកគាត់មកដល់ផ្ទះវិញដោយអំណរ នៅពេលដែលពួកគេត្រឡប់មកវិញ។

ទាំងនេះ និងការបង្ហាញស្រដៀងនោះនៃមិត្តភាពបានកើតចេញពីដួងចិត្តរបស់យើងចំពោះគ្នាទៅវិញទៅមក។ យើងផ្ដល់ការស្រឡាញ់ ហើយក៏ទទួលការស្រឡាញ់វិញផងដែរ។ យើងអាចយល់អំពីគ្នាបានយ៉ាងល្អតាមរយៈនិមិត្តសញ្ញា និងពាក្យសម្ដីរបស់យើង ទឹកមុខក្នុងកែវភ្នែករបស់បុគ្គលណាម្នាក់ និងកាយវិការដ៏រាប់មិនអស់របស់គាត់។ ទាំងនេះគឺជាសាំងដែលរំលាយខួរក្បាលរបស់យើងចោលទាំងអស់គ្នា ហើយចេញពីការមានគ្នាជាច្រើនក៏បង្កើតឲ្យយើងក្លាយជាតែមួយ។

១៤. នេះគឺជាអ្វីដែលយើងស្រឡាញ់ក្នុងមិត្តភក្តិ ហើយយើងស្រឡាញ់វាខ្លាំងណាស់ដល់ថ្នាក់ថាសតិសម្បជញ្ញៈរបស់បុគ្គលម្នាក់នឹងថ្កោលទោសខ្លួនឯងប្រសិនបើគាត់មិនស្រឡាញ់បុគ្គលម្នាក់ទៀតដែលបានស្រឡាញ់គាត់ ឬក៏ឆ្លើយតបក្នុងការស្រឡាញ់ដោយស្រឡាញ់ ដោយមិនស្វែងរកអ្វីពីអ្នកផ្សេងក្រៅពីភស្តុតាងនៃសេចក្ដីស្រឡាញ់របស់គាត់។ នេះគឺជាប្រភពនៃការឈឺចាប់របស់យើងនៅពេលដែលបុគ្គលណាម្នាក់ស្លាប់—ទុក្ខព្រួយ

ដ៏ជ្រាលជ្រៅ ការលង់ក្នុងទឹកភ្នែកនៃដួងចិត្ត រាល់ភាពផ្អែមល្ហែមបានប្រែទៅជាភាពល្វីងជូរចត់។ អារម្មណ៍នៃសេចក្ដីស្លាប់ក្នុងបុគ្គលដែលនៅរស់ ដោយសារការបាត់បង់នៃជីវិតរបស់អ្នកស្លាប់។

មានពរហើយអស់អ្នកណាដែលស្រឡាញ់ព្រះអង្គ និងអស់អ្នកណាដែលស្រឡាញ់មិត្តភក្តិរបស់ខ្លួនក្នុងព្រះអង្គ និងខ្មាំងសត្រូវរបស់គាត់ផងដែរ សម្រាប់ជាប្រយោជន៍របស់ទ្រង់។ មានតែពួកគាត់ទេដែលមិនបានបាត់បង់អ្វីដែលសំខាន់ចំពោះខ្លួន ដ្បិតពួកគេស្រឡាញ់ខ្លួនក្នុងព្រះជាម្ចាស់ ដែលមិនអាចបាត់បង់អ្វីបានឡើយ។ តើអ្នកនោះជាអ្នកណាក្រៅពីព្រះជាម្ចាស់របស់យើង៖ ព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដី ហើយបានបំពេញពួកគេដោយព្រះវត្តមានរបស់ទ្រង់ ពីព្រោះទ្រង់បានបង្កើតពួកគេមកដោយបំពេញពួកគេ? គ្មានបុគ្គលណាអាចបាត់បង់ព្រះអង្គបានឡើយ លើកលែងតែគាត់បោះបង់ទ្រង់ចោលវិញ។ ហើយបុគ្គលដែលបោះបង់ទ្រង់ចោល តើគាត់ទៅទីណា ឬក៏ថាតើគាត់អាចរត់គេចចេញពីសេចក្ដីស្រឡាញ់របស់ទ្រង់បានដោយរបៀបណា លើកលែងតែទៅដល់សេចក្ដីក្រោធរបស់ទ្រង់វិញ? ដ្បិតទីណាដែលគាត់បែរទៅ នោះព្រះអង្គនឹងយកក្រឹត្យវិន័យរបស់ទ្រង់ ដើម្បីមកដាក់ទោសគាត់។ «ក្រឹត្យវិន័យរបស់ព្រះអង្គជាសេចក្ដីពិត»[១] ហើយព្រះអង្គគឺជាសេចក្ដីពិត។

១ ទំនុកតម្កើង ១១៩:១៤២។

# ៩

# ការស្រឡាញ់ភាពស្រស់ស្អាតដ៏តូចទាប

១៥. «ឱព្រះអើយ! សូមនាំយើងខ្ញុំមកវិញ សូមឲ្យព្រះភក្ត្រព្រះអង្គភ្លឺមក នោះយើងខ្ញុំនឹងបានរួចជីវិត!»។[១] ដ្បិតទីកន្លែងណាដែលព្រលឹងរបស់មនុស្សបែរខ្លួនទៅរក លើកលែងតែទៅកាន់ព្រះអង្គ នោះវានឹងជាប់ក្នុងទុក្ខព្រួយជាមិនខាន ទោះបើថាវានៅជុំវិញអ្វីៗដែលស្រស់ស្អាតក៏ដោយ។ ដ្បិតរាល់អ្វីៗដែលស្រស់ស្អាតនឹងមិនអាចគ្រាន់តែកើតឡើងនោះទេ លុះត្រាតែវាមកពីព្រះអង្គ។ រាល់អ្វីៗដែលស្រស់ស្អាតបានកើតឡើង ហើយបន្ទាប់មកវាក៏កន្លងផុតបាត់ទៅដែរ។ ពួកវាធំឡើងយ៉ាងល្អឥតខ្ចោះ ហើយបន្ទាប់មកពួកវាក៏ចាប់ផ្ដើមរួញស្វិត ហើយងាប់ទៅបាត់។ មិនថាគ្រប់គ្នាមានអាយុចាស់នោះទេ ប៉ុន្តែគ្រប់គ្នាស្លាប់។ នេះគឺជារបៀបនៃអ្វីៗទាំងអស់។ នេះគឺជាជីវិតដែលព្រះអង្គបានប្រទាន

១ ទំនុកតម្កើង ៨០:៣។

មកកាន់ពួកគេ។

ឱព្រះជាម្ចាស់ដ៏ជាព្រះអាទិករនៃរាល់អ្វីៗទាំងអស់អើយ! សូមអនុញ្ញាតឲ្យព្រលឹងទូលបង្គំសរសើរតម្កើងទ្រង់ក្នុងរាល់អ្វីៗទាំងអស់នេះ ប៉ុន្តែសូមកុំអនុញ្ញាតឲ្យព្រលឹងទូលបង្គំនៅជាប់ជាមួយនឹងរាល់អ្វីៗទាំងអស់នេះ តាមរយៈការស្រឡាញ់ខាងឯសាច់ឈាមដែលរូបកាយយើងបង្កើតឲ្យឡើយ។ ដ្បិតក្នុងរាល់អ្វីៗទាំងអស់នេះគឺគ្មានកន្លែងសម្រាកដែលយើងអាចរកបាននោះទេ។ ទាំងអស់នេះមិននៅបានយូរឡើយ។ វាតែងតែរត់គេចចេញ ហើយតើនរណាអាចដេញតាមវាដោយប្រើប្រាស់ញាណខាងឯសាច់ឈាមរបស់ខ្លួនបាន? ឬក៏ថា តើនរណាអាចចាប់វាបាន សូម្បីតែពេលវានៅមានវត្តមាននៅឡើយ? ដ្បិតញាណខាងឯសាច់ឈាមរបស់យើងយឺត ដោយសារវាជាញាណខាងឯសាច់ឈាម ហើយក៏មានព្រំដែន។ ញាណខាងឯសាច់ឈាមមានសមត្ថភាពល្មមក្នុងការធ្វើនូវអ្វីដែលទ្រង់បានបង្កើតវាមកឲ្យធ្វើ ប៉ុន្តែវាមិនមានសមត្ថភាពក្នុងការបញ្ឈប់អ្វីក្នុងការបន្តរត់ទៅមុខក្នុងដំណើររបស់វាចាប់តាំងពីដើមចមដែលព្រះជាម្ចាស់បានរៀបចំឲ្យវា ឬក៏បញ្ឈប់នូវអ្វីមួយដែលព្រះជាម្ចាស់បានរៀបចំឲ្យវានោះដែរ។ តាមរយៈព្រះបន្ទូលរបស់ព្រះអង្គ ទ្រង់បានបង្កើតវាឡើង ហើយក្នុងព្រះបន្ទូលរបស់ទ្រង់ពួកវាស្គាល់ព្រំដែនដែលទ្រង់បានរៀបចំឲ្យវា៖ «ឯងនឹងមកបានតែត្រឹមនេះនឹងហួសទៅទៀតមិនបាន [ឡើយ]»។[២]

១៦. ឱព្រលឹងទូលបង្គំអើយ! ចូរកុំល្ងីល្ងើឡើយ ហើយកុំអនុញ្ញាតឲ្យសំឡេងអឺងកងនៃអំនួតរបស់ខ្លួនធ្វើឲ្យត្រចៀកនៃដួងចិត្តធ្ងន់ឡើយ។ សូមយកចិត្តទុកដាក់! ព្រះបន្ទូលផ្ទាល់ហៅឲ្យលោកអ្នកត្រឡប់មកវិញ ហើយជាមួយនឹងទ្រង់មានទីកន្លែងសម្រាកដែលគ្មានការរំខាន។ ដ្បិតទាំងនេះកន្លងផុតទៅ ដើម្បីឲ្យអ្វីផ្សេងទៀតអាចមកជំនួសទីតាំងរបស់ពួកវា។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់សួរថា «តើយើងធ្លាប់រំលងបាត់ទៅបានដែរឬទេ?»។ ឱព្រលឹងទូលបង្គំអើយ! ចូរតាំងទីកន្លែងស្នាក់នៅរបស់ខ្លួនជាមួយនឹងទ្រង់ចុះ។ ចូរផ្ញើរទំនួលខុសត្រូវទាំងអស់ដែលខ្លួនមានទៅកាន់ទ្រង់ចុះ។ ដ្បិតនៅចុងបញ្ចប់ឯងកំពុងតែអស់កម្លាំងទាក់ទងទៅនឹងការបោកបញ្ឆោតហើយ។ ចូរផ្ញើរទំនួលខុសត្រូវទៅកាន់សេចក្តីពិតទាក់ទងទៅនឹងអ្វីដែលឯងទទួលបានពីសេចក្តីពិត នោះឯងនឹងមិនបាត់បង់អ្វីឡើយ។ អ្វីដែលធ្លាប់ពុករលួយនឹងរីកចម្រើនដុះឡើងវិញជាថ្មីម្តងទៀតជាមិន

២ យ៉ូប ៣៨:១១។

ខាន។ រោគារបស់ឯងនឹងទទួលបានការព្យាបាល។ រូបកាយដែលនឹងស្លាប់របស់ឯងនឹងទទួលបានការរចនា នឹងបង្កើតជាថ្មីឡើងវិញ ហើយនិងទទួលបានភាពល្អឥតខ្ចោះជាថ្មីម្តងទៀត។ ហើយអ្វីដែលនឹងខូចទាំងនេះនឹងមិនសែងឯងចុះក្រោមទៅកន្លែងដែលវានឹងទៅពេលដែលវាខូចនោះទេ ប៉ុន្តែនឹងទ្រាំទ្រ ហើយគង់នៅ ហើយឯងនៅជាមួយវានៅចំពោះព្រះជាម្ចាស់ ដែលគង់នៅហើយបន្តនៅយ៉ាងអស់កល្បជានិច្ច។

១៧. ឱព្រលឹងទូលបង្គំអើយ! ហេតុអ្វីបានជាឯងនៅបន្តដើរតាមសេចក្តីប្រាថ្នាខាងឯសាច់ឈាមរបស់ឯងអញ្ចឹង? ផ្ទុយទៅវិញ ចូរអនុញ្ញាតឲ្យវាមានការបំផ្លាស់បំប្រែ ដើម្បីឲ្យវាដើរតាមព្រះជាម្ចាស់។ មិនថាអ្វីក៏ដោយដែលឯងមានអារម្មណ៍តាមរយៈវាគឺតាមពិតទៅវាគ្រាន់តែជាផ្នែកមួយនៃរូបភាពធំប៉ុណ្ណោះ។ ឯងមិនមានការយល់ដឹងគ្រប់ជ្រុងជ្រោយនៃធាតុពិតនោះទេ។ ឯងកំពុងតែទទួលបានភាពអរសប្បាយតាមរយៈអ្វីដែលមិនពេញលេញ។ ប៉ុន្តែ ប្រសិនបើញាណខាងឯសាច់ឈាមរបស់ទូលបង្គំអាចមានសមត្ថភាពក្នុងការយល់អំពីធាតុពិតទាំងមូល—ហើយមិនមែនក្នុងផ្នែកមួយនៃបណ្តាសារ វាគ្រាន់តែបានយល់តែមួយផ្នែកប៉ុណ្ណោះ—នោះឯងទំនងជានឹងប្រាថ្នាចង់ឲ្យអ្វីដែលកំពុងតែមានជីវិតនៅបច្ចុប្បន្នកាលនេះកន្លងផុតទៅ ដើម្បីឲ្យចំណុចទាំងមូលទំនងជានាំឲ្យឯងសប្បាយចិត្តជាងមុន។ ដ្បិតអ្វីដែលយើងនិយាយ នោះលោកអ្នកក៏នឹងឮតែតាមរយៈញាណខាងឯសាច់ឈាមផងដែរ តែទោះជាយ៉ាងណាក្តីក៏លោកអ្នកមិនប្រាថ្នាចង់ឲ្យព្យាង្គទាំងនោះនៅបន្តមាននៅនោះឡើយ។ ផ្ទុយទៅវិញ ឯងបែរជាប្រាថ្នាចង់ឲ្យវាហោះបាត់ទៅ ដើម្បីឲ្យអ្វីផ្សេងៗទៀតទំនងជាអាចតាមវាបាន ហើយអាចឮបានដោយភាពទាំងស្រុង។ នៅពេលណាដែលមានអ្វីមួយផ្គុំគ្នាឡើងដោយមានផ្នែកផ្សេងៗដែលមិនអាចកើតឡើងបានក្នុងពេលតែមួយ នោះទ្រង់ទ្រាយធំនឹងនាំឲ្យមានការអរសប្បាយខ្លាំងជាងផ្នែកនីមួយៗអាចធ្វើបានទៅទៀត ប្រសិនបើយើងគិតអំពីវាដាច់ដោយឡែកពីគ្នា។ ហើយឲ្យកាន់តែល្អប្រសើរជាងផ្នែកនីមួយៗគឺអង្គដែលបានបង្កើតរាល់គ្រប់អ្វីៗទាំងអស់។ ទ្រង់គឺជាព្រះជាម្ចាស់របស់យើង ហើយព្រះអង្គក៏មិនចេះរំលងផុតបាត់ឡើយ ដ្បិតគ្មានអ្វីអាចមកជំនួសទីកន្លែងរបស់ទ្រង់បានទេ។

១៨. ប្រសិនបើវត្ថុខាងឯសាច់ឈាមនាំឲ្យលោកអ្នកអរសប្បាយបាន ចូរសរសើរតម្កើងព្រះជាម្ចាស់សម្រាប់ពួកវាចុះ។ ប៉ុន្តែ សូមបង្វែរសេចក្តីស្រឡាញ់របស់លោកអ្នក

ទៅកាន់ព្រះអាទិករនៃរាល់អ្វីៗទាំងអស់នេះវិញ។ បើមិនដូច្នោះទេ នោះអ្វីៗដែលនាំឲ្យលោកអ្នកអរសប្បាយនឹងមិនបង្កឲ្យលោកអ្នកជាចំណុចសព្វព្រះហឫទ័យទ្រង់ជាមិនខាន។ ប្រសិនបើមនុស្សនាំឲ្យលោកអ្នកអរសប្បាយ ចូរស្រឡាញ់ពួកគេក្នុងព្រះជាម្ចាស់វិញ។ ដ្បិតមនុស្សនិងប្រែប្រួល ហើយស្លាប់បាត់ទៅ លុះត្រាតែពួកគេមានមូលដ្ឋានយ៉ាងរឹងមាំក្នុងព្រះអង្គ។ ដូច្នេះ ចូរស្រឡាញ់ពួកគេក្នុងព្រះអង្គ ហើយនាំទៅកាន់ព្រះជាម្ចាស់នូវមនុស្សជាច្រើនតាមដែលលោកអ្នកអាចធ្វើបានជាមួយនឹងខ្លួន ហើយនិយាយទៅកាន់ពួកគេថា៖ «ចូរឲ្យយើងស្រឡាញ់ទ្រង់ចុះ ដ្បិតទ្រង់ផ្ទាល់គឺជាអង្គដែលបានបង្កើតយើងមក ហើយព្រះអង្គមិននៅឆ្ងាយពីយើងដែរ។ ដ្បិតទ្រង់មិនបានបង្កើតយើងមក ហើយបន្ទាប់មកចាកចេញពីយើងនោះឡើយ។ យើងកើតចេញពីទ្រង់ និងនៅក្នុងទ្រង់។ ចូរមើលព្រះអង្គនៅក្នុងកន្លែងណាដែលមានការស្រឡាញ់សេចក្ដីពិត។ ព្រះអង្គគង់នៅក្នុងចំណុចដ៏ជ្រាលជ្រៅនៃដួងចិត្ត ទោះបើថាដួងចិត្តមួយនោះបានវង្វេងចេញយ៉ាងឆ្ងាយពីព្រះអង្គក៏ដោយ។ ឱជនល្មើសអើយ! ចូរត្រឡប់មកចិត្តរបស់ខ្លួនវិញ ហើយស្វែងរកព្រះអង្គដែលបានបង្កើតលោកអ្នកមកដោយកាន់ឲ្យនៅជាប់។ ចូរឈរនៅជាមួយនឹងទ្រង់ នោះលោកអ្នកនឹងឈរយ៉ាងខ្ជាប់ខ្ជួន។ ចូរសម្រាកក្នុងទ្រង់ នោះលោកអ្នកនឹងបានសម្រាកជាមិនខាន។ ហេតុអ្វីបានជាលោកអ្នកជ្រើសរើសធ្វើដំណើរលើវិថីដ៏ពិបាកនេះ? តើលោកអ្នកកំពុងតែទៅទីណា? សេចក្ដីល្អដែលលោកអ្នកស្រឡាញ់គឺមកពីព្រះអង្គ។ ប៉ុន្តែ សេចក្ដីល្អនោះនឹងប្រែទៅជាភាពល្វីងជូរចត់យ៉ាងត្រឹមត្រូវបាន ប្រសិនបើអ្វីដែលកើតចេញពីព្រះអង្គមិនទទួលបានការស្រឡាញ់ដ៏ត្រឹមត្រូវ ហើយប្រសិនបើលោកអ្នកបោះបង់ទ្រង់ចោល ដើម្បីទៅស្រឡាញ់នូវអ្វីដែលទ្រង់បានបង្កើតវិញ។ ចុះហេតុអ្វីបានជាឯងនៅបន្តវង្វេងចេញកាន់តែឆ្ងាយទៅៗក្នុងផ្លូវដ៏លំបាក និងវេទនានេះ? នៅកន្លែងដែលលោកអ្នកកំពុងតែស្វែងរក គឺគ្មានការសម្រាកទេ។ ចូរស្វែងរកនូវអ្វីដែលលោកអ្នកកំពុងតែស្វែងរក ប៉ុន្តែចូរចងចាំថា វាមិនមែននៅកន្លែងដែលលោកអ្នកកំពុងតែស្វែងរកនោះទេ។ លោកអ្នកស្វែងរកជីវិតដែលពោរពេញដោយព្រះពរក្នុងទឹកដីនៃសេចក្ដីស្លាប់។ វាមិននៅទីនោះទេ។ ដ្បិតតើឲ្យអាចមានជីវិតដែលពោរពេញដោយព្រះពរបានក្នុងទីកន្លែងដែលគ្មានជីវិតផ្ទាល់បានដោយរបៀបណាទៅ?»។

១៩. ប៉ុន្តែ ព្រះនៃជីវិតរបស់យើងបានយាងមកកាន់ផែនដី ហើយយកសេចក្ដីស្លាប់

របស់យើង ហើយក៏បានសម្លាប់វាដោយជីវិតដ៏បរិបូណ៌របស់ទ្រង់ផ្ទាល់។ ហើយដោយសំឡេងផ្គរលាន់ ទ្រង់ត្រាស់ហៅឲ្យយើងត្រឡប់ទៅរកទ្រង់វិញ ក្នុងទីកន្លែងអាថ៌កំបាំងដែលទ្រង់បានចេញពីទីនោះមកយើង—ជាដំបូង ទ្រង់បានយាងចូលផ្ទៃនាងក្រមុំព្រហ្មចារីដែលជាទីកន្លែងសាច់ឈាមដែលនឹងស្លាប់រួមជាមួយនឹងព្រះអង្គ ដើម្បីកុំឲ្យសាច់ឈាមដែលនឹងស្លាប់នឹងបន្តស្លាប់យ៉ាងអស់កល្បជានិច្ច—ហើយក៏យាង «ចេញមកដូចជាកូនកំលោះចេញពីក្រឡាបន្ទំ ក៏ដូចជាមនុស្សខ្លាំងពូកែយាត្រាតាមផ្លូវរបស់ខ្លួនដោយអំណរ»។[៣] ដ្បិតព្រះអង្គមិនបានពន្យារពេលឡើយ ប៉ុន្តែទ្រង់បានរត់លើផែនដីនេះ ស្រែកហៅដោយព្រះបន្ទូល ទង្វើ ការសុគត ព្រះជន្ម ការយាងចុះ និងការយាងឡើងទៅស្ថានសួគ៌វិញ—ស្រែកហៅយ៉ាងឮៗមកកាន់យើង ដើម្បីឲ្យយើងត្រឡប់ទៅរកទ្រង់វិញ។ ហើយព្រះអង្គបានយាងចេញពីកែវភ្នែករបស់យើង ដើម្បីឲ្យយើងអាចត្រឡប់ទៅបេះដូងរបស់យើង ហើយរកទ្រង់នៅទីនោះបាន។ ដ្បិតព្រះអង្គបានចេញពីយើង ប៉ុន្តែមើល៍! ទ្រង់នៅទីនេះ។ ព្រះអង្គមិនអាចនៅជាមួយយើងបានយ៉ាងយូរ ប៉ុន្តែទ្រង់ក៏មិនបានបោះបង់យើងចោលដែរ។ ព្រះអង្គបានត្រឡប់ទៅទីកន្លែងដែលទ្រង់មិនបានធ្លាប់ចាកចេញ ដ្បិត «ពិភពលោកកើតមកដោយសារព្រះអង្គ»។[៤] ក្នុងពិភពលោកនេះមានទ្រង់ ហើយទ្រង់ក៏បានយាងមកកាន់ពិភពលោកនេះផងដែរ ដើម្បីសង្គ្រោះមនុស្សមានបាប។ ព្រលឹងទូលបង្គំលន់តួទៅកាន់ព្រះអង្គ ពីព្រោះទូលបង្គំបានប្រព្រឹត្តអំពើបាបទាស់នឹងទ្រង់ ហើយព្រះអង្គព្យាបាលទូលបង្គំ។ ឱកូនមនុស្សម្នាអើយ! តើឯងនៅបន្តមានបេះដូងយឺតយ៉ាវដល់កាលណាទៀត? សូម្បីតែមកដល់ពេលនេះ បន្ទាប់ពីព្រះនៃជីវិតផ្ទាល់ក៏បានយាងចុះមករកឯង តើឯងនឹងមិនឡើងទៅលើ ហើយមានជីវិតមែនឬ? ប៉ុន្តែ តើឯងនឹងឡើងទៅឯណា ប្រសិនបើឯងបានទៅដល់ផ្នែកដ៏ខ្ពស់បំផុតរួចស្រេចទៅហើយ ហើយក៏បានប្រើប្រាស់មាត់របស់ឯង ដើម្បីទាស់ប្រឆាំងនឹងស្ថានសួគ៌ទៀត? ជាដំបូង ឯងត្រូវចុះសិន ដើម្បីឲ្យឯងអាចឡើងវិញបាន គឺឡើងទៅកាន់ព្រះអង្គ។ ដ្បិតឯងបានធ្លាក់តាមរយៈការព្យាយាមឡើងទៅទាស់ប្រឆាំងនឹងព្រះអង្គ។ ចូរប្រាប់អំពីចំណុចនេះទៅកាន់ព្រលឹងវិញ្ញាណដែលឯងស្រឡាញ់ ដើម្បីឲ្យគេអាចយំនៅឯជ្រលងភ្នំនៃទឹកភ្នែក ហើយតាមរយៈ

៣ ទំនុកតម្កើង ១៩:៥។
៤ យ៉ូហាន ១:១០។

ការនោះ ឯងអាចនាំពួកគេទៅកាន់ព្រះជាម្ចាស់ជាមួយនឹងឯងបាន ពីព្រោះគឺតាមរយៈព្រះវិញ្ញាណរបស់ទ្រង់ដែលឯងបាននិយាយអំពីចំណុចទាំងនោះទៅកាន់ពួកគេ ប្រសិនបើខណៈពេលដែលឯងនិយាយ ឯងបានឆេះឆួលទៅដោយភ្លើងនៃសេចក្ដីស្រឡាញ់។

២០. នៅពេលនោះ ទូលបង្គំមិនបានយល់អ្វីៗទាំងអស់នេះទេ ហើយទូលបង្គំក៏ស្រឡាញ់ភាពស្រស់ស្អាតដ៏អន់ជាងទាំងនោះ ហើយទូលបង្គំក៏បានធ្លាក់ចុះទៅក្នុងជម្រៅនោះទៀតផង។ ហើយទូលបង្គំក៏និយាយទៅកាន់មិត្តភក្ដិទូលបង្គំថា៖ «តើយើងបានស្រឡាញ់អ្វីក្រៅពីអ្វីដែលស្រស់ស្អាតដែរឬទេ? តើអ្វីទៅដែលរាប់ថាស្រស់ស្អាត? តើអ្វីទៅជាភាពស្រស់ស្អាត? តើសម្រស់ជាអ្វី? តើអ្វីទៅទាក់ទាញយើង និងរួបរួមយើងជាមួយនឹងអ្វីៗដែលយើងស្រឡាញ់ ដ្បិតលុះត្រាតែមានភាពស្រទន់ និងភាពស្រស់ស្អាតក្នុងពួកវា នោះពួកវាមិនអាចមានសមត្ថភាពក្នុងការទាក់ទាញយើងទៅកាន់ពួកវាបានឡើយ?» ហើយទូលបង្គំក៏សញ្ជឹងគិតលើចំណុចនេះ ហើយឃើញថាក្នុងវត្ថុទាំងនោះផ្ទាល់គឺមានភាពស្រស់ស្អាតមួយប្រភេទដែលកើតចេញពីការផ្គុំភាពទាំងមូល ហើយក៏មានភាពស្រស់ស្អាតមួយប្រភេទទៀតដែលកើតចេញពីការមានភាពស៊ីគ្នាទៅវិញទៅមក—ដូចជាការព្រមព្រៀងគ្នានៃផ្នែកមួយនៃរូបកាយទៅកាន់ភាពទាំងមូល ឬក៏ស្បែកជើងទៅនឹងជើង។ល។ ហើយគំនិតនេះក៏បានផុសចេញពីខួរក្បាលនៃជម្រៅចិត្តរបស់ទូលបង្គំ ហើយទូលបង្គំក៏បាននិពន្ធសៀវភៅមួយចំនួន—ប្រហែលជាពីរទៅបីក្បាលលើ—«ភាពស្រស់ស្អាត និងភាពស៊ីគ្នា»។[៥] ឱព្រះអម្ចាស់អើយ! ទ្រង់បានជ្រាបអំពីពួកវា ទូលបង្គំបានភ្លេចអំពីឈ្មោះយ៉ាងប្រាកដនៃសៀវភៅនោះ។ ទូលបង្គំមិនមានសៀវភៅនោះទៀតទេ ហើយទូលបង្គំក៏មិនដឹងថា បានបាត់ពួកវាដោយរបៀបណាដែរ។

២១. ឱព្រះដ៏ជាអម្ចាស់ទូលបង្គំអើយ! តើអ្វីទៅបានជំរុញឲ្យទូលបង្គំជូនសៀវភៅទាំងនោះចំពោះ លោក ហៀរអូស៍ ដែលជាវាគ្មិនម្នាក់ពីប្រទេសរ៉ូម ហើយក៏ជាបុរសម្នាក់ដែលទូលបង្គំមិនទាំងដែលជួបផ្ទាល់ ប៉ុន្តែជាបុគ្គលដែលទូលបង្គំបានស្រឡាញ់ ដ្បិតគាត់មានកេរ្តិ៍ឈ្មោះត្រង់ថាគាត់ចូលចិត្តរៀនសូត្រ—ហើយខ្លះទាក់ទងទៅនឹងពាក្យពេចន៍របស់គាត់ដែលទូលបង្គំបានឮដែលធ្វើឲ្យទូលបង្គំសប្បាយចិត្ត? ប៉ុន្តែ គាត់កាន់តែធ្វើឲ្យទូលបង្គំសប្បាយចិត្ត ពីព្រោះគាត់ធ្វើឲ្យអ្នកដទៃសប្បាយចិត្តដែរ ដែលបានកោតសរសើរ

៥ សៀវភៅទាំងនេះបានបាត់បង់រួចទៅហើយ។

គាត់យ៉ាងខ្លាំង ហើយលើកឡើងអំពីភាពអស្ចារ្យរបស់ពួកគេគ្រាន់តែថា អ្នកសាសន៍ស៊ីរីម្នាក់នេះដែលបានសិក្សាវេយ្យាករណ៍ភាសាក្រិកជាដំបូង ឥឡូវក៏បានក្លាយជាអ្នកវាគ្មិនដ៏គួរឲ្យស្ញប់ស្ញែងម្នាក់ក្នុងភាសាឡាតាំងដែរ ហើយក៏ចេះច្រើនក្នុងទស្សនវិជ្ជាទៀតផង។ ដូច្នេះ យើងក៏សរសើរ និងស្រឡាញ់បុគ្គលម្នាក់ដែលយើងមិនបានជួប។ តើការស្រឡាញ់បែបនេះកើតឡើងដោយចូលទៅក្នុងដួងចិត្តអ្នកស្ដាប់ចេញពីមាត់នៃបុគ្គលដែលសរសើរការសរសើររបស់បុគ្គលផ្សេងទៀតមែនឬ? ទេ។ ផ្ទុយទៅវិញ បុគ្គលម្នាក់ចាប់បានផ្កាភ្លើងនៃការស្រឡាញ់ពីបុគ្គលម្នាក់ទៀតដែលស្រឡាញ់។ នេះហើយគឺជាមូលហេតុដែលយើងស្រឡាញ់បុគ្គលដែលទទួលបានការសរសើរនៅពេលដែលគេជឿថា អ្នកសរសើរបានសរសើរដោយកើតចេញពីដួងចិត្តដ៏ស្មោះត្រង់។ នេះមានន័យថា នៅពេលដែលបុគ្គលដែលស្រឡាញ់ គាត់បានសរសើរគាត់។

២២. ឱព្រះជាម្ចាស់អើយ! នោះឯងគឺជាមូលហេតុដែលទូលបង្គំស្រឡាញ់អ្នកដទៃដោយមានមូលដ្ឋានលើយោបល់របស់អ្នកដទៃ មិនមែនលើទ្រង់ ដែលជាបុគ្គលតែមួយអង្គគត់ដែលគ្មានការបោកបញ្ឆោត។ ប៉ុន្តែ ហេតុអ្វីបានជាអារម្មណ៍នេះដែលទូលបង្គំមានសម្រាប់មនុស្សបែបនោះបែរជាទទួលបង្គំមិនមានអារម្មណ៍ដូចនោះចំពោះអ្នកបើកបររទេះចម្បាំងដ៏ឆ្នើម ឬក៏អ្នកប្រមាញ់ប្រយុទ្ធឲ្យគេទស្សនា ដែលមានកេរ្ដិ៍ឈ្មោះយ៉ាងល្បីល្បាញទាំងជិត និងឆ្ងាយ? តាមពិតទៅ ទូលបង្គំពេញចិត្តវាគ្មិនម្នាក់នេះក្នុងរបៀបដែលខុសប្លែកពីនោះ ហើយក៏ក្នុងរបៀបម៉ឺងម៉ាត់ ដូចដែលទូលបង្គំប្រាថ្នាចង់ឲ្យអ្នកដទៃពេញចិត្តនឹងទូលបង្គំដែរ។ ដ្បិតទូលបង្គំមិនចង់ឲ្យពួកគេសរសើរ និងស្រឡាញ់ទូលបង្គំដូចតួល្ខោនទទួលបានការសរសើរ និងការស្រឡាញ់នោះទេ—ទោះបើទូលបង្គំផ្ទាល់សរសើរនិងស្រឡាញ់ពួកគេក៏ដោយ។ ទូលបង្គំចូលចិត្តក្នុងការមិនឲ្យគេស្គាល់ទូលបង្គំ ជាជាងមានភាពល្បីល្បាញដូចពួកគេ ឬក៏ថាឲ្យមានគេស្អប់ទូលបង្គំជាជាងស្រឡាញ់ទូលបង្គំដូចពួកគេដែរ។ តើអ្វីទៅជំរុញឲ្យដួងចិត្តមនុស្សយើងផ្ដល់តម្លៃខុសៗគ្នាទាក់ទងនឹងការស្រឡាញ់? ហេតុអ្វីបានជាទូលបង្គំស្រឡាញ់ជំនាញដែលបុគ្គលម្នាក់ទៀតមាន តែទូលបង្គំស្អប់ជំនាញនោះ ប្រសិនបើទូលបង្គំមាន? ដ្បិតយើងមិនអាចប្រៀបធៀបចំណុចនេះទៅកាន់បុគ្គលម្នាក់ដែលស្រឡាញ់សត្វសេះ ទោះបើគាត់ផ្ទាល់មិនចង់ធ្វើជាសត្វសេះបានទេ។ ព្រោះទាំងតួល្ខោន និងទូលបង្គំ យើងមានលក្ខណៈដូចគ្នាត្រង់ថាយើងជាមនុស្ស។

តើនេះមានន័យថា ទូលបង្គំក៏ស្រឡាញ់អ្វីមួយដែលបុគ្គលម្នាក់ទៀតមាន ដែលទូលបង្គំផ្ទាល់ក៏ជាមនុស្សផងដែរនឹងស្អប់វា ប្រសិនបើទូលបង្គំមានមែនឬ? ភាពជាមនុស្សផ្ទាល់គឺជារឿងអាថ៌កំបាំង។ ឱព្រះអម្ចាស់អើយ! ដ្បិតទ្រង់ដាក់តួលេខទាំងលើសរសៃសក់របស់ពួកគាត់ផ្ទាល់ ហើយវាក៏មិនទាំងជ្រុះទៅលើដីដោយគ្មានព្រះអង្គផង ហើយទោះជាយ៉ាងណាក្តីសរសៃសក់នៅលើក្បាលរបស់គាត់ក៏មានតួលេខយ៉ាងស្រេចជាក់លាក់ជាងការដែលគាត់មានអារម្មណ៍ខុសៗគ្នាក្នុងចិត្តរបស់គាត់ទៀតផង។

២៣. ប៉ុន្តែ ពួកវាគ្មិនទាំងនោះដែលទូលបង្គំកោតសរសើរយ៉ាងខ្លាំងក៏ជាប្រភេទនៃមនុស្សដែលទូលបង្គំប្រាថ្នាចង់ឲ្យខ្លួនឯងក្លាយទៅជាបែបនោះដែរ។ ប៉ុន្តែ វាគឺជាការគិតខុសហើយដែលទូលបង្គំព្យាយាមត្រាប់តាមពួកគាត់ក្នុងជីវិតទូលបង្គំ។ ទូលបង្គំក៏កាន់តែមានអំនួត ហើយទូលបង្គំ «ទាំងត្រូវគ្រប់ទាំងខ្យល់នៃសេចក្តីបង្រៀនផាត់ចុះផាត់ឡើង»[៦] ប៉ុន្តែតាមរយៈការនោះ ព្រះអង្គក៏កំពុងតែតម្រង់ផ្លូវទូលបង្គំ ទោះបើក្នុងរបៀបដ៏គួរឲ្យអាថ៌កំបាំងក៏ដោយ។ ទូលបង្គំដឹងថាទូលបង្គំស្រឡាញ់ពួកវាគ្មិនខ្លាំងជាង ពីព្រោះការស្រឡាញ់នៃអស់អ្នកដែលសរសើរតម្កើងពួកគាត់ គឺខ្លាំងជាងអ្វីដែលពួកវាគ្មិនបានធ្វើផ្ទាល់ខ្លួនដែលគួរឲ្យកោតសរសើរ។ ពីព្រោះប្រសិនបើគេឈប់សរសើរពួកគាត់ ហើយអ្នកសរសើរនោះបែរជាមករិះគន់ពួកគាត់វិញ ហើយបាននិយាយអំពីចំណុចដូចនោះអំពីពួកគាត់ក្នុងសំឡេងបែបស្តីបន្ទោស ឬក៏មិនពេញចិត្ត នោះទូលបង្គំនឹងមិនដែលមានសេចក្តីប្រាថ្នាក្នុងការធ្វើដូចជាពួកគាត់ឡើយ។ ការនេះក៏នឹងមានករណីដូចគ្នា សូម្បីតែទោះបើថាការនិពន្ធរបស់ពួកវាគ្មិនមានលក្ខណៈដូចនោះ មានចំណុចខុសគ្នាតែមួយគត់៖ អ្នកមើលមិនបានសរសើរ។ សូមមើលអំពីរបៀបនៃព្រលឹងមួយដែលកំពុងដេកស្តូកលើដីមិនរើសដោយគ្មានការជួយ ពីព្រោះវាមិនទាន់បានទទួលការទ្រទ្រង់ដ៏ស្ថិតស្ថេរនៃសេចក្តីពិតនៅឡើយ! ដូចដែលខ្យល់នៃសំណោរបានបក់ចេញពីដើមទ្រូងនៃអ្នកដែលប្រកាន់តាមគំនិតផ្ទាល់ខ្លួន នោះព្រលឹងក៏ទទួលការបក់ចុះបក់ឡើងទៅនេះទៅនោះ ដោយជំរុញវាទៅក្រោយ ហើយពន្លឺក៏លែងច្បាស់ ហើយសេចក្តីពិតក៏លែងមើលឃើញដែរ។

២៤. ប៉ុន្តែ ទូលបង្គំមិនទាន់បានឃើញអំពីរបៀបនៅចំណុចចម្បងក្នុងបញ្ហាដ៏ធំនេះ វាពិតជាមានមូលដ្ឋានក្នុងចំណុចពិតដែលថា៖ ព្រះអង្គគឺជាអង្គនៃការដែលបាន

---

៦ អេភេសូរ ៤:១៤។

បង្កើតអ្វីៗទាំងអស់ ឱព្រះដ៏ពេញទៅដោយព្រះចេស្ដាអើយ “ជាព្រះតែមួយព្រះអង្គគត់ដែលធ្វើការដ៏អស្ចារ្យ”។[៧] ដូច្នេះ គំនិតរបស់ទូលបង្គំក៏ដាក់កំណត់តាមរយៈសម្ភារៈទាំងនោះ ហើយទូលបង្គំក៏បានផ្ដល់អត្ថន័យ និងវែកញែកភាពស្រស់ទៅជាពីរប្រភេទ៖ ១. របស់ដែលស្រស់ស្អាតតែឯងផ្ទាល់ ២. របស់ដែលស្រស់ស្អាត ព្រោះវាមានភាពស៊ីគ្នាយ៉ាងពេញលេញទាក់ទងទៅនឹងទំនាក់ទំនងរបស់វាជាមួយនឹងរបស់ផ្សេងៗទៀត។ ទូលបង្គំយកឧទាហរណ៍អាស្រ័យតាមច្បាប់ធម្មជាតិធ្វើជាចំណុចទ្រទ្រង់ការវែកញែកមួយនេះ។ ហើយទូលបង្គំក៏បែរចំណាប់អារម្មណ៍ទៅលើលក្ខណៈខាងឯវិញ្ញាណ ប៉ុន្តែយោបល់ខុសឆ្គងដែលទូលបង្គំប្រកាន់ភ្ជាប់ទាក់ទងទៅនឹងរឿងរ៉ាវខាងឯព្រលឹងវិញ្ញាណបានរារាំងទូលបង្គំពីការឃើញសេចក្ដីពិត។ ទោះបើអំណាចនៃសេចក្ដីពិតផ្ទាល់បានជះឥទ្ធិពលរបស់វាលើការសម្លឹងមើលរបស់ទូលបង្គំក៏ដោយ ក៏ទូលបង្គំបានបង្វែរព្រលឹងដែលកំពុងឈឺចេញពីចំណុចខាងឯព្រលឹងវិញ្ញាណទៅរកចំណុចខាងឯសម្ភារៈនិយមទៅវិញ។ ទូលបង្គំបានពិចារណាមើលលើគុណភាពនៃបន្ទាត់ ពណ៌ និងទម្រង់ ហើយដោយសារព្រលឹងទូលបង្គំមិនអាចមើលឃើញគុណភាពទាំងនោះបាន នោះទូលបង្គំក៏បានធ្វើសេចក្ដីសន្និដ្ឋានលើចំណុចទាំងនោះថា គឺមិនអាចយល់បាននោះទេ។ ទូលបង្គំស្រឡាញ់សន្តិភាពដែលអាចរកឃើញបានក្នុងគុណធម៌ ហើយទូលបង្គំស្អប់ជម្លោះដែលអាចរកឃើញបានក្នុងអំពើអសីលធម៌។ ហេតុដូច្នេះទូលបង្គំក៏ធ្វើសេចក្ដីសន្និដ្ឋានថា៖ ក្នុងគុណធម៌មានភាពរួបរួម ហើយក្នុងអំពើអសីលធម៌មានជម្លោះ។ ចំពោះទូលបង្គំ ការរួបរួមគ្នាហាក់បីដូចជាមាន៖ ព្រលឹងដែលផ្អែកលើហេតុផល លក្ខណៈនៃសេចក្ដីពិត និងចំណុចដ៏ល្អបំផុត។ ប៉ុន្តែ ទូលបង្គំបានស្រមៃថាក្នុងជម្លោះវាហាក់បីដូចជាមានសារធាតុនៃជីវិតដែលមិនសមហេតុសមផល និងប្រភេទណាមួយនៃអង្គភាពដែលជាអំពើអាក្រក់ដែលមានអំណាច។ គំនិតដ៏អាក្រក់បែបនេះគឺមិនគ្រាន់តែជាសារធាតុនោះទេ ប៉ុន្តែហាក់បីដូចជាមានជីវិតក្នុងរបៀបណាមួយដែរ ប៉ុន្តែទោះជាយ៉ាងណាក្តីក៏ទូលបង្គំមិនជឿថា វាកើតចេញពីព្រះអង្គ ឱព្រះជាម្ចាស់ដែលជាប្រភពនៃអ្វីៗទាំងអស់អើយ! ទូលបង្គំហៅភាពរួបរួមគ្នាថា “ឯកអង្គ” (“monad”) ហាក់បីដូចជាថាវាមានព្រលឹងតែគ្មានភេទ។ ទូលបង្គំហៅជម្លោះថា “ទ្វេអង្គ” (“dyad”) ដែលបង្ហាញខ្លួនក្នុងកំហឹងក្នុងទង្វើហិង្សា ក្នុងទង្វើនៃ

៧ ទំនុកតម្កើង ៧២:១៨។

ភាពងប់ងុល និងភាពត្រេកត្រអាល។ ប៉ុន្តែ ទូលបង្គំមិនដឹងអំពីអ្វីដែលទូលបង្គំកំពុងតែនិយាយនោះទេ។ ដ្បិតទូលបង្គំមិនទាន់បានយល់ ហើយក៏មិនដែលទទួលការបង្រៀនថា អំពើអាក្រក់គឺមិនមែនជាសារធាតុទេ ហើយថាព្រលឹងវិញ្ញាណរបស់យើងគឺមិនមែនជាចំណុចល្អឧត្តុង្គឧត្តមដែលមិនមានការប្រែប្រួលដែរ។

២៥. ប្រសិនបើចេញពីព្រលឹងវិញ្ញាណដែលជាកន្លែងដែលអំពើហិង្សា និងទង្វើត្រេកត្រអាលកើតឡើងជាកន្លែងពុករលួយ ហើយប្រសិនបើវាអះអាងផ្ទាល់ដោយបះបោរ នោះសេចក្តីខុសឆ្គង និងយោបល់ខុសឆ្គងក៏បានធ្វើឲ្យជីវិតកខ្វក់ផងដែរ។ នោះឯងគឺជាអ្វីដែលបានកើតឡើងចំពោះទូលបង្គំ ដ្បិតទូលបង្គំល្ងង់ពេកហើយត្រង់ថា៖ ព្រលឹងទូលបង្គំត្រូវទទួលការយល់ដឹងតាមរយៈពន្លឺមួយទៀត ប្រសិនបើចង់ឲ្យវាមានចំណែកជាមួយនឹងសេចក្តីពិត ដោយសារតែឯងវាមិនមែនជាចំណុចស្នូលនៃសេចក្តីពិតទេ។ «ដ្បិតព្រះអង្គអុជប្រទីបទូលបង្គំឲ្យភ្លឺឡើងព្រះយេហូវ៉ាជាព្រះនៃទូលបង្គំ ព្រះអង្គបំភ្លឺសេចក្តីងងឹតរបស់ទូលបង្គំ»[៨] ហើយ «យើងរាល់គ្នាបានទទួលសេចក្តីពោរពេញរបស់ព្រះអង្គ»[៩] ព្រោះ «ពន្លឺដ៏ពិតដែលមកក្នុងលោកីយ៍ គឺជាពន្លឺដែលបំភ្លឺដល់មនុស្សទាំងអស់»[១០] ដ្បិតក្នុងព្រះអង្គ «សូម្បីតែស្រមោលនៃការផ្លាស់ប្រែក៏គ្មានដែរ»។[១១]

២៦. ប៉ុន្តែ ទូលបង្គំក៏រុញទៅកាន់ព្រះអង្គ ហើយព្រះអង្គក៏គាប និងរុញមកទូលបង្គំវិញ ដើម្បីឲ្យទូលបង្គំអាចស្គាល់រសជាតិនៃសេចក្តីស្លាប់ ដ្បិត «ព្រះទ្រង់ប្រឆាំងនឹងមនុស្សមានអំនួត»។[១២] ហើយតើមានអំនួតណាធំជាងអំនួតដែលទូលបង្គំមាន ជាមួយនឹងភាពឆ្កួតលីលាដ៏ចម្លែក ក្នុងការគិតថាទូលបង្គំអាចក្លាយជាព្រះដែលតាមពិតទៅមានតែទ្រង់មួយប៉ុណ្ណោះជាព្រះ? ទូលបង្គំមានការផ្លាស់ប្រែ—ចំពោះទូលបង្គំប៉ុនហ្នឹងគឺល្អមច្បាស់លាស់ហើយ ពីព្រោះទូលបង្គំមានចិត្តប្រាថ្នាចង់មានប្រាជ្ញាដែលកើតចេញពីការប្រាថ្នាចង់បំផ្លាស់ពីអាក្រក់ឲ្យទៅជាល្អ—ប៉ុន្តែទូលបង្គំបែរជាជ្រើសរើសដោយគិតថា ព្រះអង្គមានការបំផ្លាស់បំប្រែមិនមែនទូលបង្គំទេ។ ដោយសារមូលហេតុនេះហើយបានជាព្រះអង្គប្រឆាំងនឹងទូលបង្គំ ហើយជំទាស់នឹងអំនួតដ៏រឹងចចេសរបស់ទូលបង្គំ។ ទូលបង្គំ

៨ ទំនុកតម្កើង ១៨:២៨។
៩ យ៉ូហាន ១:១៦។
១០ យ៉ូហាន ១:៩។
១១ យ៉ាកុប ១:១៧។
១២ យ៉ាកុប ៤:៦ និង ១ពេត្រុស ៥:៥។

មិនបានត្រឡប់ទៅរកព្រះអង្គ ប៉ុន្តែបានបន្តវង្វេងទៅកាន់អ្វីៗដែលមិនមានជីវិត—មិនថាក្នុងព្រះអង្គ ក្នុងទូលបង្គំ ឬក៏ក្នុងរូបកាយ។ សេចក្តីពិតរបស់ទ្រង់មិនបានបង្កើតការគិតរវើរវាយនេះសម្រាប់ទូលបង្គំទេ ប៉ុន្តែគឺវាកើតឡើងចេញពីអំនួតដ៏ឥតប្រយោជន៍នៃសារធាតុខាងឯសម្ភារៈ។ ហើយទូលបង្គំក៏ធ្លាប់សួរកូនៗដ៏ស្មោះត្រង់របស់ព្រះអង្គថា៖ «បើអញ្ចឹង ចុះហេតុអ្វីបានជាព្រលឹងវិញ្ញាណដែលព្រះជាម្ចាស់បានបង្កើតមកធ្វើខុស?» ប៉ុន្តែ ទូលបង្គំមិនដែលអនុញ្ញាតឲ្យនរណាម្នាក់សួរបង្គំថា៖ «ហេតុអ្វីបានជាព្រះជាម្ចាស់ធ្វើខុស?» ទេ។ ទូលបង្គំបែរជាជ្រើសរើសដោយប្រឆាំងថា ទ្រង់មានចំណែកក្នុងការធ្វើខុសទាំងនោះដោយសារវាចាំបាច់ ជាជាងទទួលស្គាល់ថាគឺទូលបង្គំទេតើដែលជាអ្នកផ្លាស់ប្រែ ហើយបានវង្វេងចេញដោយឆន្ទៈសេរីរបស់ខ្លួនឯង ហើយក៏បានធ្លាក់ចុះក្នុងសេចក្តីខុសឆ្គងដែលនោះគឺជាទារុណកម្មចំពោះទូលបង្គំ។

៣០. ហើយតែវាជាប្រយោជន៍ដល់ទូលបង្គំយ៉ាងដូចម្តេចដែលថា ទូលបង្គំអាចអានហើយយកសម្រាប់ខ្លួនឯងនូវរាល់សៀវភៅដែលទូលបង្គំអាចរកបានដែលគេហៅថា «សិល្បៈសេរី» ដែលតាមពិតទៅទូលបង្គំគឺជាទាសករដ៏គ្មានតម្លៃនៃភាពត្រេកត្រអាលដ៏អាក្រក់? ទូលបង្គំស្រឡាញ់ការសិក្សា ប៉ុន្តែមិនដឹងអំពីរបៀបវែកញែកថា អ្វីដែលទូលបង្គំកំពុងតែអានពិត ឬក៏មិនពិតទេ។ ដ្បិតទូលបង្គំបានបែរខ្នងទៅកាន់ពន្លឺ ហើយមុខទូលបង្គំបានបែរទៅរកអ្វីដែលពន្លឺធ្លាក់លើ ដូច្នេះមុខទូលបង្គំដែលកំពុងបែរទៅរកអ្វីដែលពន្លឺបានជះលើ មិនបានទទួលពន្លឺជះលើមុខផ្ទាល់នោះទេ។ មិនថាមុខវិជ្ជាអ្វីក៏ដោយដែលសរសេរអំពីវោហារសាស្ត្រ តក្កវិជ្ជា ធរណីមាត្រ ភ្លេង ឬក៏គណិតវិជ្ជា ទូលបង្គំអាចយល់ទាំងអស់ដោយមិនមានបញ្ហាធំប៉ុន្មានទេ ឬក៏មិនចាំបាច់ឲ្យនរណាម្នាក់មកបង្រៀនទូលបង្គំដែរ។ ឱព្រះអង្គដ៏ជាម្ចាស់ទូលបង្គំអើយ! ទាំងអស់នេះទ្រង់ជ្រាបរួចហើយ ពីព្រោះទាំងភាពរហ័សរហួនក្នុងការយល់ដឹង និងភាពវាងវៃក្នុងការយល់ឃើញគឺជាអំណោយទានរបស់ទ្រង់។ ទោះជាយ៉ាងណាក្តី ទាក់ទងនឹងអំណោយទានទាំងនោះ ទូលបង្គំមិនថ្លែងអំណរអរព្រះគុណទៅកាន់ទ្រង់ឡើយ។ ដូច្នេះ សមត្ថភាពរបស់ទូលបង្គំមិនបានក្លាយជាប្រយោជន៍ដល់ទូលបង្គំទេ ប៉ុន្តែបានក្លាយជាការបាត់បង់ទៅវិញ។ ទូលបង្គំមិនបានប្រើប្រាស់ជំនាញរបស់ទូលបង្គំសម្រាប់ព្រះអង្គឡើយ ប៉ុន្តែបានរត់គេចចេញពីទ្រង់ទៅក្នុងទឹកដីយ៉ាងឆ្ងាយ ដើម្បីប្រើប្រាស់អំណោយទានរបស់ទូលបង្គំ

លើភាពត្រេកត្រអាលរបស់ខ្លួន។[១៣] ហើយតើសមត្ថភាពទាំងនេះនឹងក្លាយជាប្រយោជន៍ដល់ទូលបង្គំយ៉ាងដូចម្ដេចបាន ប្រសិនបើទូលបង្គំមិនប្រើប្រាស់វាសម្រាប់ជាប្រយោជន៍ល្អ? ទូលបង្គំមិនដឹងថាសិល្បៈទាំងនោះមានការយល់ដឹងដ៏ពិបាកនោះទេ សូម្បីតែចំពោះអ្នកដែលសិក្សា និងឆ្លាតវៃ ទាល់តែទូលបង្គំបានព្យាយាមពន្យល់វាទៅកាន់អ្នកដទៃ នោះទើបទូលបង្គំឃើញថា សូម្បីតែអ្នកដែលឆ្លាតជាងគេក៏មានការយឺតយ៉ាវក្នុងការស្ដាប់ទាន់នូវការពន្យល់របស់ទូលបង្គំផងដែរ។

៣១. ប៉ុន្តែ ឱព្រះអង្គដ៏ជាម្ចាស់នៃសេចក្ដីពិតអើយ! តើចំណុចនេះផ្ដល់ជាប្រយោជន៍ដល់ទូលបង្គំយ៉ាងដូចម្ដេច ខណៈពេលដែលទូលបង្គំនៅបន្តគិតថា ព្រះអង្គគឺជារូបកាយដ៏ធំមួយដែលកំពុងជះពន្លឺយ៉ាងចែងចាំង ហើយទូលបង្គំជាចំណែកមួយនៃរូបកាយនោះ? នេះគឺជាភាពរឹងចចេសដ៏ធំមហិមាមែន! ប៉ុន្តែ នោះគឺជារបៀបដែលទូលបង្គំបានគិត។ ឱព្រះជាម្ចាស់អើយ! ទូលបង្គំក៏មិនមានភាពខ្មាសអៀនផងដែរ ក្នុងការលន់តួទូលសូមសេចក្ដីមេត្តាករុណារបស់ទ្រង់មកកាន់ទូលបង្គំក្នុងព្រះវត្តមានរបស់ទ្រង់ ឬក៏ក្នុងការស្រែកហៅរកព្រះអង្គ—ទូលបង្គំក៏មិនមានភាពខ្មាសអៀនខ្លាំងជាងពេលដែលទូលបង្គំមិនបានមានមុខក្រហម ពេលដែលទូលបង្គំបានប្រកាសជាសាធារណៈក្នុងការជេរប្រមាថនៅមុខមនុស្សម្នា ហើយព្រុសទាស់ប្រឆាំងនឹងព្រះអង្គដូចជាឆ្កែ។ តើវាជាប្រយោជន៍ល្អដល់ទូលបង្គំដោយរបៀបណា ខណៈពេលដែលខួរក្បាលដ៏រស់រវើករបស់ទូលបង្គំអាចយល់ការសិក្សាទាំងនោះដោយគ្មានការលំបាក ឬក៏ជំនួយពីគ្រូណាម្នាក់ ស្របពេលនោះទូលបង្គំកំពុងតែធ្លាក់ក្នុងការខុសឆ្គងដ៏ធំក្រៃលែង ហើយក៏កំពុងតែថ្វាយយញ្ញបូជាដ៏គួរឲ្យអាម៉ាស់ស្អប់ខ្ពើមទាស់ប្រឆាំងនឹងព្រះអង្គ? ហើយតើវាពិតជាការមិនពេញចិត្តមែនឬសម្រាប់អស់អ្នកដែលមានខួរក្បាលមិនសូវរហ័សរហួន ដោយសារពួកគេមិនបានរត់ចេញពីព្រះអង្គ ហើយដោយសារពួកគេបានបន្តនៅក្នុងសម្បុកនៃព្រះវិហាររបស់ទ្រង់ ហើយក៏ទទួលបានការផ្គត់ផ្គង់ពេញទៅដោយសុវត្ថិភាពតាមរយៈអាហារនៃជំនឿដ៏ត្រឹមត្រូវ។

ឱព្រះដ៏ជាអម្ចាស់របស់យើងអើយ! សូមអនុញ្ញាតឲ្យយើងមានសង្ឃឹមក្រោមចំអេងស្លាបរបស់ព្រះអង្គ—សូមការពារ និងទ្រទ្រង់ពួកយើង។[១៤] ព្រះអង្គនឹងទ្រទ្រង់យើង

---

១៣ ប្រធានបទនៃរឿងប្រៀបធៀបអំពីកូនពៅវង្វេងក្នុងកណ្ឌគម្ពីរ លូកា ១៥:១៣។

១៤ ទំនុកតម្កើង ១៧:៨។

ខណៈពេលដែលយើងនៅក្មេង ហើយសូម្បីតែនៅពេលដែលយើងចាស់សក់សទៅក៏ព្រះអង្គនឹងនៅបន្តបីយើងផងដែរ។ ទាក់ទងទៅនឹងភាពនឹងនរបស់យើង ពេលដែលវានៅក្នុងទ្រង់ នោះប្រាកដណាស់វានឹងនៅនឹងនរ ប៉ុន្តែពេលដែលវានៅក្នុងខ្លួនឯង នោះវានឹងមិននៅនឹងនរឡើយ។ ចំណុចល្អៗរបស់យើងគឺនៅជាមួយនឹងព្រះអង្គយ៉ាងអស់កល្បជានិច្ច ហើយនៅពេលដែលយើងបែរចេញពីទ្រង់ដោយមានការស្អប់ខ្ពើម នោះយើងនឹងធ្លាក់ក្នុងអំពើអាក្រក់របស់ខ្លួនជាមិនខាន។ ឱព្រះអម្ចាស់អើយ! ឥឡូវនេះ សូមអនុញ្ញាតឲ្យយើងត្រឡប់ទៅរកទ្រង់ ដើម្បីកុំឲ្យយើងវង្វេង ពីព្រោះជាមួយនឹងទ្រង់ នោះអំពើល្អរបស់យើងនឹងបន្តមានដោយគ្មានការបន្ទោស—ដ្បិតចំណុចល្អរបស់យើងគឺព្រះអង្គផ្ទាល់តែម្តង។ ហើយយើងក៏មិនចាំបាច់មានការភ័យខ្លាចត្រង់ថា យើងមិនមានកន្លែងដើម្បីត្រឡប់ទៅវិញដោយសារយើងបានធ្លាក់ចេញពីកន្លែងនោះនោះទេ។ ដ្បិតផ្ទះរបស់យើង—ដែលជាភាពអស់កល្បជានិច្ចរបស់ទ្រង់—និងមិនដែលធ្លាក់បាត់នៅពេលដែលយើងអវត្តមាននោះឡើយ។

សៀវភៅទី៥

# ១០

# ការបាត់បង់សេចក្ដីសង្ឃឹម

១. សូមទទួលការលន់តួនេះ បែបជាយញ្ញបូជាចេញពីបបូរមាត់ទូលបង្គំ ដែលព្រះអង្គបានបង្កើត ដើម្បីសរសើរតម្កើងព្រះនាមទ្រង់។ សូមព្យាបាលគ្រប់ឆ្អឹងឆ្អែងរបស់ទូលបង្គំ ហើយអនុញ្ញាតឲ្យវានិយាយថាៈ «តើមានអ្នកណាដូចព្រះអង្គ?»។[១] នៅពេលដែលទូលបង្គំលន់តួគំនិតនៅក្នុងទូលបង្គំយ៉ាងជ្រៅបំផុតទៅកាន់ព្រះអង្គវាមិនមែនហាក់បីដូចជាថាទ្រង់មិនបានជ្រាបអំពីវាមុននៅឡើយនោះទេ។ ព្រះអង្គទតឃើញដួងចិត្តរបស់មនុស្សគ្រប់គ្នា។ បុគ្គលដែលមានរឿងលាក់កំបាំង ឬក៏ដួងចិត្តរឹងរូសមិនអាចពួនពីទ្រង់បានឡើយ ដ្បិតទ្រង់អាចបន្ទន់វាតាមព្រះហឫទ័យរបស់ទ្រង់បាន។ ប៉ុន្តែ សូមអនុញ្ញាតឲ្យព្រលឹងទូលបង្គំសរសើរព្រះអង្គ ដើម្បីឲ្យវាអាចស្រឡាញ់ទ្រង់ ហើយអនុញ្ញាតឲ្យវារៀបរាប់អំពីក្ដីមេត្តាករុណារបស់ទ្រង់ ដើម្បីឲ្យវាអាចសរសើរទ្រង់បាន។ សូមអនុញ្ញាតឲ្យរបស់សព្វសារពើដែលទ្រង់បានបង្កើតមកសរសើរតម្កើងទ្រង់ដោយឥតឈប់ឈរៈ ព្រលឹងវិញ្ញាណរបស់មនុស្ស តាមរយៈបបូរមាត់ និងសំឡេងរបស់ខ្លួនដោយលើកតម្កើងទ្រង់ពពួកសត្វ និងរាល់អ្វីដែលមានរូបរាងកាយ និងតាមរយៈសំឡេងនៃអស់អ្នកដែលគិត

១ ទំនុកតម្កើង ៣៥:១០។

អំពីពួកវា។ សូមអនុញ្ញាតឲ្យយើងសរសើរតម្កើងទ្រង់ ដើម្បីឲ្យព្រលឹងដ៏ទន់ខ្សោយរបស់យើងអាចនឹងងើបឡើង ហើយធ្វើដំណើរឆ្ពោះទៅរកទ្រង់ ដោយពឹងលើអ្វីដែលទ្រង់បានបង្កើត ដើម្បីជួយយើងទៅរកទ្រង់ ដែលព្រះអង្គបានបង្កើតពួកវាយ៉ាងល្អអស្ចារ្យ។ ជាមួយព្រះអង្គមានការផ្ដល់កម្លាំង និងមានកម្លាំងដ៏ពិត។

២. សូមអនុញ្ញាតឲ្យអ្នកដែលអន្ទះអន្ទែង និងអ្នកដែលមិនសុចរិតរត់ ហើយចាកចេញពីព្រះអង្គចុះ។ ព្រះអង្គទតឃើញពួកគេទាំងពីរ ហើយឃើញស្រមោលពួកគេដែលពួកគេកំពុងតែរត់។ ពួកគេរស់នៅក្នុងភពផែនដីដ៏ស្រស់ស្អាត តែទោះជាយ៉ាងណាក្ដីក៏ពួកគេនៅតែជាមនុស្សដ៏រលួយយ៉ាងខ្លាំងជាងគេបំផុតដែរ។ តើពួកគេបានធ្វើឲ្យព្រះអង្គឈឺចាប់ដោយរបៀបណា? ឬក៏ថាតើពួកគេបានបង្ខូចកេរ្ដិ៍ឈ្មោះសិទ្ធិអំណាចរបស់ទ្រង់ដោយរបៀបណា? អំណាចរបស់ព្រះអង្គពោរពេញទៅដោយយុត្តិធម៌ និងភាពល្អឥតខ្ចោះក្នុងការសោយរាជ្យ ទោះបើដល់ទីបំផុតនៃការបង្កើតក៏ដោយ។ ប្រាកដណាស់! តើឲ្យពួកគេគេចទៅកន្លែងណា ដើម្បីរត់ចេញពីព្រះវត្តមានរបស់ទ្រង់? តើទ្រង់នឹងមិនអាចរកពួកគេឃើញមែនឬ? ប៉ុន្ដែ ពួកគេរត់ចេញ ដើម្បីកុំឲ្យពួកគេឃើញព្រះអង្គ ពីព្រោះពួកគេដឹងថាទ្រង់ទតឃើញពួកគេ។ ប៉ុន្ដែ ព្រះអង្គមិនដែលបោះបង់ចោលអ្វីណាមួយដែលទ្រង់បានបង្កើតនោះទេ។ មនុស្សទុច្ចរិតបានជំពប់ដោយទាស់ប្រឆាំងនឹងទ្រង់ ហើយពួកគេទទួលការពិបាកយ៉ាងត្រឹមត្រូវ ដោយគេចចេញពីភាពស្លូតបូតរបស់ទ្រង់ ហើយរត់បុកភាពយុត្តិធម៌របស់ទ្រង់ ហើយជាចុងក្រោយនឹងដួលក្នុងផ្លូវដ៏ពិបាកនៃជីវិតរបស់ខ្លួន។ ពួកគេមិនដឹងថាទ្រង់គង់នៅគ្រប់ទីកន្លែង ដ្បិតទ្រង់មិនស្ថិតនៅក្រោមព្រំដែននៃការគង់នៅតែមួយកន្លែងទេ។ ព្រះអង្គមកនៅជិតសូម្បីតែចំពោះអស់អ្នកដែលនៅយ៉ាងឆ្ងាយពីទ្រង់ក៏ដោយ។ ដូច្នេះ សូមអនុញ្ញាតឲ្យពួកគេបែរត្រឡប់មកស្វែងរកទ្រង់វិញ ពីព្រោះទោះបើពួកគេបានបោះបង់ចោលព្រះអាទិកររបស់ខ្លួនក៏ដោយក៏ទ្រង់មិនបានបោះបង់របស់សព្វសារពើដែលទ្រង់បានបង្កើតដែរ។ សូមអនុញ្ញាតឲ្យពួកគេបែរត្រឡប់មកស្វែងរកទ្រង់—ដ្បិតទ្រង់គង់នៅក្នុងដួងចិត្តរបស់ពួកគេពោលគឺគង់ក្នុងដួងចិត្តអស់អ្នកដែលលន់តួទៅកាន់ទ្រង់។ សូមអនុញ្ញាតឲ្យពួកគេប្រគល់ជីវិតខ្លួនទៅកាន់ព្រះអង្គ ហើយយំសោកលើព្រះឱរារបស់ទ្រង់ចុះ។ ហើយបន្ទាប់ពីពួកគេបានវង្វេងទាំងអស់កម្លាំង នោះទ្រង់នឹងជូតរាល់

ទឹកភ្នែកចេញពីភ្នែករបស់ពួកគេ។[២] ហើយពួកគេនឹងយំខ្លាំងជាងមុនទៅទៀត ប៉ុន្តែឥឡូវនេះគឺយំដោយសារអំណរ។ ដ្បិតឱព្រះអម្ចាស់អើយ! ទ្រង់គឺមិនមែនជាមនុស្សក្នុងសាច់ឈាមទេ ប៉ុន្តែទ្រង់គឺជាព្រះអម្ចាស់ដែលអត់ទោស ហើយកម្សាន្តចិត្តពួកគេ។ ហើយថាតើទូលបង្គំនៅកន្លែងណាពេលទូលបង្គំកំពុងតែស្វែងរកព្រះអង្គ? គឺទ្រង់នៅទីនោះ នៅមុខទូលបង្គំ ប៉ុន្តែទូលបង្គំបានចេញយ៉ាងឆ្ងាយ សូម្បីតែពីខ្លួនឯងហើយទូលបង្គំក៏មិនអាចរកខ្លួនឯងឃើញបានដែរ អញ្ចឹងតើឲ្យទូលបង្គំរកទ្រង់ឃើញបានដោយរបៀបណាទៅ?

៣. ឥឡូវ សូមអនុញ្ញាតឲ្យទូលបង្គំពណ៌នានៅក្នុងព្រះនេត្ររបស់ព្រះជាម្ចាស់អំពីកាលដែលទូលបង្គំមានអាយុ២៩ឆ្នាំ។ លោក ហ្វូស្ទីស៍ (Faustus) ដែលជាអ្នកដឹកនាំម្នាក់របស់ក្រុមមានិហ្គៀន (Manicheans) ទើបតែមកដល់ទីក្រុងកាតធេ គាត់គឺជាអ្នកដាក់អន្ទាក់ដ៏ឆ្នើមម្នាក់របស់អារក្ស ហើយមានមនុស្សជាច្រើនធ្លាក់ក្នុងអន្ទាក់របស់គាត់តាមរយៈវោហារសាស្ត្រដ៏ពូកែរបស់គាត់។ ទោះបើទូលបង្គំចេះចាប់ផ្ដើមវែកញែករវាងពាក្យពេចន៍នៃវោហារសាស្ត្រ និងពាក្យពេចន៍នៃសេចក្ដីពិតក៏ដោយក៏ទូលបង្គំនៅចូលចិត្តវោហារសាស្ត្ររបស់គាត់ដែលទូលបង្គំចង់រៀនយ៉ាងខ្លាំង។ ទូលបង្គំមិនរវីរវល់នឹងពាក្យពេចន៍របស់លោក ហ្វូស្ទីស៍ ដ៏ល្បីល្បាញម្នាក់នេះដែលគាត់ប្រើប្រាស់ ដើម្បីតុបតែងចានដែលគាត់យកមកជូនទូលបង្គំនោះទេ។

១០. អស់ប្រមាណជាង៩ឆ្នាំ ទូលបង្គំបានស្ដាប់ការបង្រៀនរបស់ក្រុមមានិហ្គៀនដោយមិនមានគំនិតនឹងនរ ទូលបង្គំក៏បានធ្វើជាអ្នកដើរតាមពួកគេ។ ទូលបង្គំបានរំពឹងរង់ចាំការមកដល់របស់លោក ហ្វូស្ទីស៍ យ៉ាងខ្លាំង។ ដ្បិតគ្រប់សមាជិកនៃក្រុមដែលទូលបង្គំបានជួបមិនមានសមត្ថភាពក្នុងការឆ្លើយសំណួរដែលទូលបង្គំបានសួរឡើយ។ ដូច្នេះពួកគេក៏បានសន្យានឹងទូលបង្គំថា បន្ទាប់ពីទូលបង្គំបានសន្ទនាជាមួយនឹងគាត់ នោះរាល់ចំណុចលំបាក និងបញ្ហាធំៗផ្សេងទៀតដែលទូលបង្គំមានជាមួយនឹងពួកគេនឹងមានដំណោះស្រាយយ៉ាងងាយស្រួល ហើយច្បាស់លាស់ទៀតផង។ នៅចុងបញ្ចប់ ពេលគាត់មកដល់ ទូលបង្គំក៏បានឃើញថា គាត់ជាបុរសម្នាក់ដែលមានពាក្យពេចន៍យ៉ាងពីរោះ ដែលនិយាយអំពីចំណុចដូចដែលសមាជិកក្រុមមានិហ្គៀនបាននិយាយ ដោយមានជំនាញ ហើយមិនរដាក់រដុប។ ប៉ុន្តែ តើវោហាររបស់គាត់មានប្រយោជន៍អ្វីដល់ទូល

២ វិវរណៈ ២១:៤។

បង្គំខណៈពេលដែលអ្វីដែលគាត់អាចឲ្យទូលបង្គំបានគឺគ្រាន់តែជាកូនពែងមួយដែលមិនអាចចំអែតភាពស្រេកឃ្លានរបស់ទូលបង្គំបានផង? ត្រចៀកទូលបង្គំបានឆ្អែតហើយអំពីចំណុចបែបនោះ? ការបង្រៀនរបស់ក្រុមមានិហ្គៀនហាក់បីដូចជាមិនមានអ្វីល្អ ឬក៏ពិតជាងមុនដោយគ្រាន់តែថាឥឡូវវាមានការលើកឡើងយ៉ាងល្អប្រសើរជាងមុននោះទេ។ ហើយទូលបង្គំក៏មិនបានគិតថាគាត់ឆ្លាតណាស់ណាដែរ ដោយសារគាត់មានរូបឆោមស្អាត ឬក៏ថាគាត់អាចនិយាយបានយ៉ាងក្បោះក្បាយផងដែរ។ ប្រាកដណាស់! អស់អ្នកដែលបានសរសើរគាត់ក៏មិនមានសមត្ថភាពណាស់ណាក្នុងការវិនិច្ឆ័យដែរ។ ដ្បិតវាគ្រាន់តែថាដោយសារគាត់មានសមត្ថភាពក្នុងទ្រឹស្តី នោះបានជាចំពោះពួកគេ គាត់ហាក់បីដូចជាមានភាពប្រុងប្រយ័ត្ន និងប្រាជ្ញា។ ស្របគ្នាផងដែរ ទូលបង្គំក៏ឃើញថាមនុស្សមួយចំនួនក៏សង្ស័យអំពីចំណុចពិតនៃសេចក្តីបង្រៀននៅពេលដែលគេលើកវាឡើងក្នុងភាសាដែលពីរោះ និងរាបសា។ ប៉ុន្តែ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ ទ្រង់បានបង្រៀនទូលបង្គំរួចស្រេចហើយថាប្រយោគណាមួយពិត ឬក៏មិនពិតគឺមិនអាស្រ័យទៅលើរបៀបនៃការលើកឡើងនោះទេ។ ទូលបង្គំជឿជាក់ថា គឺទ្រង់ហើយដែលបានបង្រៀនចំណុចនេះមកទូលបង្គំ ដ្បិតក្រៅពីព្រះអង្គគ្មានគ្រូនៃសេចក្តីពិតណាទៀតឡើយ មិនថាវាកើតចេញពីប្រភពណាក៏ដោយ។ ព្រះអង្គបានបង្រៀនទូលបង្គំរួចហើយអំពីចំណុចនេះ ហើយព្រះអង្គបានបង្រៀនទូលបង្គំផងដែរថា បើគ្រាន់តែថាដោយសារអ្វីមួយត្រូវបានលើកឡើងដោយបបូរមាត់រដាក់រដុប នោះក៏មិនមែនមានន័យថា យើងគួរថាវាគឺជាសេចក្តីខុសឆ្គងឡើយ។ ជាថ្មីម្តងទៀត ចំណុចណាមួយមិនមែនជាចំណុចពិតអាស្រ័យលើគ្រាន់តែថាគេបានលើកឡើងក្នុងរបៀបមិនល្អនោះដែរ ហើយវាក៏មិនមែនថាវាមិនពិតដោយសារគេបានលើកឡើងក្នុងរបៀបដ៏ល្អប្រសើរផងដែរ។ ប្រាជ្ញា និងចំណុចល្ងីល្ងើគឺប្រៀបដូចជាប្រភេទមុខម្ហូបខុសៗគ្នាអញ្ចឹង។ ម្ហូបខ្លះធ្វើឲ្យរាងកាយធំធាត់ឡើង ហើយម្ហូបខ្លះទៀតមិនដូច្នោះទេ។ ប៉ុន្តែ គេក៏អាចយកម្ហូបទាំងពីរប្រភេទនោះមកដាក់លើចានដែលមានក្បាច់ ឬក៏ចានដែលសាមញ្ញ។ ដូចគ្នាផងដែរ ទាំងប្រាជ្ញា និងសេចក្តីល្ងីល្ងើក៏គេអាចលើកឡើងទាំងក្នុងពាក្យពេចន៍ដ៏សាមញ្ញ ឬក៏ពាក្យពេចន៍ដែលមានពេញទៅដោយវោហារសាស្ត្រដ៏ល្អប្រសើរបានផងដែរ។

១១. ទូលបង្គំបានរំពឹងយ៉ាងយូរចង់ជួបលោក ហ្វ៊ីស្ទឹស៍ យ៉ាងខ្លាំង។ ហើយនៅពេល

ដែលទូលបង្គំបានជួបគាត់ទូលបង្គំក៏ចូលចិត្តអត្តចរិត វោហារសាស្ត្រ និងពាក្យពេចន៍ក្បោះក្បាយដែលគាត់លើកឡើងអំពីគំនិតរបស់គាត់។ ដូច្នេះ ទូលបង្គំក៏មានអំណរ ហើយក៏ចូលរួមជាមួយនឹងអ្នកដទៃក្នុងការកោតសរសើរគាត់។ ប៉ុន្តែ ទូលបង្គំក៏ខកចិត្តផងដែរ ពីព្រោះពេលគាត់កំពុងបង្រៀន ទូលបង្គំមិនមានសិទ្ធិក្នុងការសួរសំណួរដែលទូលបង្គំកំពុងតែឆ្ងល់បានទេ។ ដរាបណាទូលបង្គំបានឃើញឱកាស ទូលបង្គំក៏ទទួលបានការផ្ទង់អារម្មណ៍របស់គាត់ ក្នុងពេលដែលវាមិនមែនជាការរំខានដល់គាត់ ដើម្បីឲ្យគាត់ពិភាក្សាជាមួយនឹងទូលបង្គំ និងមិត្តភក្តិរបស់ទូលបង្គំ។ ហើយពេលដែលទូលបង្គំរៀបរាប់ប្រាប់គាត់អំពីមន្ទិលសង្ស័យរបស់ទូលបង្គំ ភ្លាមនោះទូលបង្គំឃើញថា គាត់មិនចេះអ្វីទេទាក់ទងទៅនឹងសិល្បៈសេរីលើកលែងតែវេយ្យាករណ៍ និងអក្សរសាស្ត្រ ហើយក៏គ្រាន់តែចេះក្នុងកម្រិតដ៏សាមញ្ញផងដែរ។ ទោះជាយ៉ាងណាក្តី គាត់ក៏បានអានសន្ទរកថាមួយចំនួនរបស់លោក ធូលី (Tully) សៀវភៅពីរបីក្បាលរបស់លោក សិននិការ៍ (Seneca) សៀវភៅកវីមួយចំនួនទៀត និងសៀវភៅប៉ុន្មានក្បាលទៀតដែលនិពន្ធដោយក្រុមរបស់គាត់ក្នុងភាសាឡាតាំងដែលមានស្នាដៃល្អ។ អមជាមួយនឹងការរៀនសូត្រដ៏ស្តួចស្តើងមួយនេះ និងការអនុវត្តនិយាយជាប្រចាំ គាត់ក៏ទទួលបានជំនាញនៃវោហារសាស្ត្រដែលបង្ហាញជាភស្តុតាងដែលងាយពេញចិត្តនិងទាក់ទាញអារម្មណ៍ ពីព្រោះវាស្ថិតក្រោមទិសដៅនៃការត្រៀមខ្លួនជាស្រេចនៃការប៉ុនប្រសប់ ព្រមទាំងការឆ្លើយតបដោយសុភាព និងបែបធម្មជាតិ។ ឱព្រះអង្គដ៏ជាម្ចាស់ទូលបង្គំ និងជាព្រះដែលថ្កោលទោសលើសតិសម្បជញ្ញៈរបស់ទូលបង្គំអើយ! តើវាមិនបានកើតឡើងក្នុងរបៀបនេះមែនឬ? ដួងចិត្ត និងការចងចាំរបស់ទូលបង្គំគឺកំពុងតែនៅពីមុខព្រះភ័ក្ត្រព្រះអង្គ ដែលសូម្បីតែនៅពេលនោះទ្រង់ក៏បានណែនាំផ្លូវទូលបង្គំតាមរយៈកម្លាំងអាថ៌កំបាំងនៃអធិបតេយ្យភាពរបស់ព្រះ ហើយទ្រង់ក៏បានបើកសម្តែងចំណុចខុសឆ្គងដ៏អាម៉ាស់នៅពីមុខទូលបង្គំផងដែរ ដើម្បីឲ្យទូលបង្គំអាចនឹងឃើញវា ហើយស្អប់វាទៀតផង។

១២. នៅពេលនោះ ទូលបង្គំឃើញយ៉ាងច្បាស់ថាលោក ហ្វីស្ទីស៍ ខ្វះខាតលើការរៀនសូត្រលើចំណុចទាំងនោះដែលទូលបង្គំធ្លាប់ជឿថាគាត់មានសញ្ញាប័ត្រដែលគួរឲ្យកត់សម្គាល់។ ទូលបង្គំក៏ចាប់ផ្តើមអស់សង្ឃឹមត្រង់ថា គាត់នឹងមានសមត្ថភាពក្នុងការពន្យល់បំភ្លឺរាល់ចំណុចនៃមន្ទិលសង្ស័យដ៏គួរឲ្យពិបាកយល់របស់ទូលបង្គំ—ទោះបើ

ទូលបង្គំយល់ថាចំណុចអវិជ្ជាបែបនេះមិនគួរជះឥទ្ធិពលលើសេចក្តីពិតនៃជំនឿរបស់គាត់ក៏ដោយ ប្រសិនបើគាត់មិនមែនជាអ្នកដើរតាមក្រុមមានិហ្កៀន។ សៀវភៅរបស់ពួកគេមានពេញទៅដោយរឿងល្បើកអំពីផ្ទៃមេឃ ហ្វូងតារា ព្រះអាទិត្យ និងព្រះច័ន្ទ។ ហើយទូលបង្គំក៏ចាប់ផ្តើមឈប់ជឿថា គាត់នឹងមានសមត្ថភាពក្នុងការបើកបង្ហាញឲ្យទូលបង្គំអាចយល់បានយ៉ាងស្កប់ស្កល់ចិត្តអំពីអ្វីដែលទូលបង្គំពិតជាប្រាថ្នាចង់ដឹងយ៉ាងជ្រាលជ្រៅដែរ។ ទូលបង្គំចង់ដឹងថា តើការពន្យល់ដែលមានក្នុងសៀវភៅក្រុមមានិហ្កៀនល្អប្រសើរជាង ឬក៏យ៉ាងហោចណាស់ល្អជាងការពន្យល់លើគណិតវិជ្ជាដែលទូលបង្គំធ្លាប់អានក្នុងសៀវភៅណាផ្សេងទៀតដែរឬទេ? ប៉ុន្តែ ពេលដែលទូលបង្គំស្នើលើប្រធានបទទាំងនេះថាឲ្យយើងពិចារណា ហើយពិភាក្សាគ្នា គាត់ក៏ឆ្លើយតបយ៉ាងសុភាពដោយមិនហ៊ានយល់ព្រមធ្វើការនោះ ដ្បិតគាត់ដឹងថាគាត់មិនមានចំណេះដឹងលើចំណុចទាំងនោះ ហើយក៏មិនខ្មាសក្នុងការប្រាប់ឲ្យទូលបង្គំដឹងផងដែរ។ ដ្បិតគាត់មិនមែនជាបុគ្គលដែលនិយាយច្រើន—ដូចជាបុគ្គលដែលទូលបង្គំបានជួបប្រទះជាច្រើននាក់—ដែលយល់ក្នុងការបង្រៀនទូលបង្គំនូវអ្វីដែលទូលបង្គំចង់ដឹង ហើយបន្ទាប់មកមិននិយាយអ្វីដែលមិនមានប្រយោជន៍ឡើយ។ លោក ហ្វីស្ទីស៍ មានបេះដូង ទោះបើមិនត្រូវនឹងព្រះអង្គ ដែលយ៉ាងហោចណាស់មានការប្រុងប្រយ័ត្ននឹងខ្លួនឯង។ ដោយសារគាត់ដឹងថាខ្លួនខ្វះខាតលើចំណេះដឹងមួយចំនួន ដូច្នេះគាត់ក៏ជ្រើសរើសមិនឲ្យខ្លួនជាប់អន្ទាក់ក្នុងការវែកញែកណាមួយ ដែលគាត់មិនអាចដកខ្លួនចេញឬក៏បញ្ឈប់ការវែកញែកក្នុងលក្ខណៈដ៏ល្អនោះទេ។ ទាក់ទងនឹងចំណុចមួយនេះ ទូលបង្គំក៏កាន់តែចូលចិត្តគាត់ថែមទៀត។ ដ្បិតគំនិតដ៏ឆ្លាតវៃហើយសមរម្យគឺល្អប្រសើរជាងការទទួលបានចំណេះដឹងដែលទូលបង្គំប្រាថ្នាចង់បានទៅទៀត។ ហើយនេះឯងគឺជាឥរិយាបថរបស់គាត់ដែលទូលបង្គំឃើញទាក់ទងទៅនឹងសំណួរពិបាកៗ។

១៣. ចំណង់ចិត្តដ៏ខ្លាំងដែលទូលបង្គំបានជ្រមុជខ្លួនក្នុងសេចក្តីបង្រៀនរបស់ក្រុមមានិហ្កៀនក៏អន់ថយ ហើយទូលបង្គំក៏អស់សង្ឃឹមក្នុងការរៀនបានអ្វីថែមទៀតចេញពីគ្រូនានាដោយសារលោក ហ្វីស្ទីស៍ ដែលជាបុគ្គលដ៏ល្បីល្បាញម្នាក់ក្នុងចំណោមពួកគេមិនអាចឆ្លើយនូវសំណួរដែលទូលបង្គំងឿងឆ្ងល់។ ហេតុដូច្នេះហើយបានជាទូលបង្គំចាប់ផ្តើមចំណាយពេលជាមួយគាត់សិក្សាលើអក្សរសាស្ត្រ (ដែលនោះគឺជាប្រធានបទដែល

គាត់ចូលចិត្តខ្លាំងជាងគេ) ស្របពេលនោះដែរទូលបង្គំក៏បានចាប់ផ្តើមបង្រៀនក្នុងនាមជាគ្រូលើប្រធានបទវោហារសាស្ត្រ ទៅកាន់កូនសិស្សនៅទីក្រុងកាតធេ។ ជាមួយនឹងលោក ហ្វីស្ទីស៍ ទូលបង្គំអាននូវអ្វីដែលគាត់ប្រាថ្នាចង់អាន ឬក៏អ្វីដែលទូលបង្គំគិតថាស័ក្តិសមសម្រាប់បុរសដែលមានចំណេះដឹងដូចគាត់។ ប៉ុន្តែ រាល់ចំណុចខិតខំប្រឹងប្រែងរបស់ទូលបង្គំក្នុងការបន្តដំណើរទៅមុខទៀតជាមួយនឹងក្រុមមានិហ្គៀនក៏បានឈានមកដល់ទីបញ្ចប់តាមរយៈមិត្តភាពរបស់ទូលបង្គំជាមួយនឹងគ្រូម្នាក់នេះ។ ទូលបង្គំមិនបានដកខ្លួនចេញពីពួកគេទាំងស្រុងនោះទេ។ ប៉ុន្តែ ដោយសារទូលបង្គំមិនទាន់បានរកឃើញថាមានអ្វីល្អប្រសើរជាងនោះដូច្នេះទូលបង្គំក៏សម្រេចចិត្តបំពេញចិត្តខ្លួនឯងសម្រាប់ពេលនោះជាមួយនឹងអ្វីដែលទូលបង្គំបានជំពប់លើ ក្រែងលាភសំណាងនឹងបង្ហាញអ្វីល្អប្រសើរជាងនោះមកកាន់ទូលបង្គំ។ ប្រាកដណាស់លោក ហ្វីស្ទីស៍ ដែលបានបោកបញ្ឆោតមនុស្សជាច្រើនក្នុងការស្លាប់របស់ពួកគេ ក៏ចាប់ផ្តើមបាត់បង់ឥទ្ធិពលលើអន្ទាក់ដែលទូលបង្គំបានធ្លាក់ទៅក្នុង មិនថាចេតនា ឬក៏អចេតនាទាំងស្រុងក្តី។ ឱព្រះអម្ចាស់អើយ! ដ្បិតព្រះហស្តរបស់ទ្រង់ ក្នុងការរចនាដ៏លាក់កំបាំងក្នុងការការពារដែលយកចិត្តទុកដាក់ ទ្រង់មិនបានបោះបង់ព្រលឹងទូលបង្គំចោលឡើយ។ ចេញពីឈាមនៃបេះដូងរបស់អ្នកម្តាយទូលបង្គំតាមរយៈទឹកភ្នែកដែលគាត់បានសម្រក់ទាំងយប់ទាំងថ្ងៃ គឺគាត់បានថ្វាយយញ្ញបូជាទៅកាន់ព្រះអង្គសម្រាប់ទូលបង្គំ ហើយក្នុងរបៀបដ៏អស្ចារ្យ ទ្រង់ក៏បានណែនាំផ្លូវទូលបង្គំ។ ដ្បិតគឺព្រះអង្គហើយដែលបាន «តាំងជំហានរបស់មនុស្សឲ្យបានមាំមួនពេលព្រះអង្គសព្វព្រះហឫទ័យនឹងផ្លូវរបស់គេ»។[៣] តើឲ្យយើងអាចទទួលបានសេចក្តីសង្គ្រោះក្រៅពីព្រះហស្តរបស់ទ្រង់ដែលបង្កើតនូវអ្វីជាថ្មីដែលទ្រង់បានបង្កើតរួចស្រេចម្តងហើយបានដោយរបៀបណាទៅ?

---

៣ ទំនុកតម្កើង ៣៧:២៣។

# ១១

# ការរើទៅទីក្រុងរ៉ូម

១៤. ព្រះអង្គបានទាក់ទាញឲ្យទូលបង្គំទៅទីក្រុងរ៉ូម ហើយបង្រៀននៅទីនោះជាជាងបង្រៀននៅទីក្រុងកាតធេ។ ហើយទូលបង្គំនឹងមិនដកចេញការទូលថ្វាយទៅកាន់ព្រះអង្គអំពីរបៀបដែលទ្រង់បានទាក់ទាញឲ្យទូលបង្គំធ្វើបែបហ្នឹងឡើយ។ ពីព្រោះក្នុងចំណុចនេះទូលបង្គំក៏ត្រូវនឹកគិត និងលើកឡើងអំពីព្រះប្រាជ្ញា និងក្តីមេត្តាករុណាដ៏ស្ថិតស្ថេររបស់ព្រះអង្គដែលទ្រង់មានចំពោះទូលបង្គំផងដែរ។ វាពិតជាមិនមែនដោយសារមានប្រាក់ខែច្រើនជាង ឬក៏មានកិត្តិយសខ្ពស់ជាងដែលមិត្តភក្តិទូលបង្គំបានសន្យាមកកាន់ទូលបង្គំថាកំពុងតែរង់ចាំទូលបង្គំនៅឯទីក្រុងរ៉ូមដែលធ្វើឲ្យទូលបង្គំសម្រេចចិត្តទៅទីនោះនោះទេ។ ទោះបើថាចំណុចទាំងនោះបានជះឥទ្ធិពលលើការសម្រេចចិត្តរបស់ទូលបង្គំក៏ដោយ ប៉ុន្តែមូលហេតុចម្បងដែលបណ្តាលឲ្យទូលបង្គំរើទៅនៅទីនោះគឺដោយសារទូលបង្គំបានឮថាសិស្សនៅឯទីក្រុងរ៉ូមខំសិក្សា មានការដាក់វិន័យ និងច្បាប់ខ្លាំងជាងនៅទីក្រុងកាតធេ។ សិស្សានុសិស្សមិនរត់ចូលថ្នាក់រៀនគ្រូដែលពួកគេមិនមានថ្នាក់រៀនជាមួយដោយតាមសន្ទុះចិត្ត ឬក៏ព្រហើននោះទេ។ ហើយពួកគេក៏មិនចូលដោយគ្មានការអនុញ្ញាតពីគ្រូផងដែរ។ នៅឯទីក្រុងកាតធេគឺផ្ទុយពីនេះទាំងស្រុង ពោលគឺមានសេរីភាពដ៏អាម៉ាស់ និងទប់

ពុំបានបែបនេះក្នុងចំណោមពួកសិស្ស។ ពួកសិស្សតែងតែរត់ចូលយ៉ាងឈ្លើយ ហើយឆាឆៅលំដាប់លំដោយដែលគ្រូបានបង្កើតសម្រាប់ជាប្រយោជន៍របស់សិស្សគាត់។ ពួកសិស្សមិនមានសមត្ថភាពក្នុងការយល់ថាអាកប្បកិរិយារបស់ពួកគេ គឺគេមិនអាចទទួលបានទេចំពោះអ្នកផ្សេង ហើយថាជាទូទៅតាមច្បាប់គេអាចដាក់ទារុណកម្មបាន ទោះបើថាតាមប្រពៃណីតាមតំបន់របស់ពួកគេអនុញ្ញាតឲ្យមានអាកប្បកិរិយាទាំងនេះក៏ដោយ។ ហើយប្រាកដណាស់! ប្រពៃណីរបស់ពួកគេដែលអនុញ្ញាតឲ្យមានអាកប្បកិរិយាបែបនោះក៏មិនមានប្រយោជន៍ដែរ ព្រោះវាអនុញ្ញាតឲ្យមនុស្សធ្វើនូវអ្វីដែលព្រះជាម្ចាស់មិនអនុញ្ញាតឲ្យធ្វើ។ ពួកគេគិតថាអាកប្បកិរិយារបស់ពួកគេនឹងមិនធ្វើឲ្យអ្នកដទៃឈឺចាប់ ប៉ុន្តែពួកគេខ្វះទាំងស្រុងតាមរយៈការបាត់បង់ស្មារតីរបស់ពួកគេត្រង់ថា វាកំពុងតែបង្កការឈឺចាប់យ៉ាងខ្លាំងទៅកាន់អស់អ្នកដែលនៅជុំវិញខ្លួន។

កាលទូលបង្គំនៅជាសិស្សនៅឡើយ ទូលបង្គំមិនមានការអនុញ្ញាតឲ្យមានអាកប្បកិរិយាដ៏អាក្រក់ៗបែបនោះទេ ប៉ុន្តែពេលនោះក្នុងនាមជាគ្រូ មានគេជំរុញចិត្តឲ្យទូលបង្គំទ្រទ្រង់អាកប្បកិរិយាដ៏អាក្រក់ក្នុងអ្នកដទៃ។ ហេតុដូច្នេះហើយបានជាទូលបង្គំសប្បាយចិត្តក្នុងការទៅកន្លែងថ្មី កន្លែងដែលអស់អ្នកស្គាល់ទូលបង្គំបានអះអាងមកកាន់ទូលបង្គំថា អាកប្បកិរិយាបែបនោះមិនមានការអនុញ្ញាតនៅទីក្រុងរ៉ូមទេ។ ឱព្រះអម្ចាស់អើយ «ព្រះអង្គជាទីពឹងជ្រករបស់ទូលបង្គំ ជាចំណែករបស់ទូលបង្គំនៅក្នុងទឹកដីរបស់មនុស្សរស់»។[១] ព្រះអង្គសព្វព្រះហឫទ័យឲ្យទូលបង្គំរើចេញពីទីក្រុងកាតធេហើយឲ្យទូលបង្គំបំផ្លាស់បំប្រែចេញពីទម្លាប់លោកីយ៍ ដើម្បីការពារព្រលឹងវិញ្ញាណទូលបង្គំ។ ស្របពេលនោះដែរ ព្រះអង្គបានប្រើប្រាស់មនុស្សនៅជុំវិញទូលបង្គំ ដើម្បីទាក់ទាញទូលបង្គំឲ្យទៅទីក្រុងរ៉ូម និងដើម្បីនាំទូលបង្គំឲ្យចូលផ្លូវត្រឹមត្រូវ ព្រះអង្គនាំទូលបង្គំយ៉ាងអាថ៌កំបាំងតាមរយៈការរឹងក្បាលរបស់ទូលបង្គំ និងតាមរយៈមិត្តភក្តិរបស់ទូលបង្គំ។ អស់អ្នកដែលបានឆាឆៅសន្តិភាពរបស់ទូលបង្គំមានការខ្វាក់តាមរយៈអាកប្បកិរិយាភ្លីភ្លើដ៏អាម៉ាស់ ហើយអស់អ្នកដែលបានបញ្ចុះបញ្ចូលឲ្យទូលបង្គំទៅឯទីក្រុងរ៉ូមក៏មិនមានអ្វីល្អប្រសើរជាងប្រាថ្នាខាងឯលោកីយ៍នេះនោះដែរ។ ហើយដោយសារទូលបង្គំស្អប់ភាពវេទនានៃកន្លែងមួយ ដូច្នេះហើយទូលបង្គំក៏បានស្វែងរកភាពអរសប្បាយដ៏ស្រមើស្រមៃ

១ ទំនុកតម្កើង ១៤២:៥។

ក្នុងកន្លែងមួយទៀត។

១៥. ឱព្រះអម្ចាស់អើយ! ទ្រង់បានជ្រាបហើយអំពីមូលហេតុដែលទូលបង្គំចេញពីទីក្រុងមួយទៅទីក្រុងមួយទៀត។ ប៉ុន្តែ ឱព្រះជាម្ចាស់អើយ ទ្រង់មិនបានបើកសម្តែងអំពីចំណុចនេះមកកាន់ទូលបង្គំ ឬក៏ទៅកាន់អ្នកម្តាយទូលបង្គំទេ ហើយគាត់បានព្រួយបារម្ភយ៉ាងខ្លាំងទាក់ទងទៅនឹងការចាកចេញរបស់ទូលបង្គំ ហើយក៏ថែមទាំងបានតាមទូលបង្គំរហូតទៅដល់សមុទ្រ ដែលជាទីកន្លែងដែលទូលបង្គំនឹងចាកចេញតាមរយៈនាវាដែរ។ គាត់បានឱបទូលបង្គំយ៉ាងជាប់ស្អិត ដោយមានឆន្ទៈទាំងការចងទូលបង្គំទុក ឬក៏ទៅជាមួយទូលបង្គំដែរ ប៉ុន្តែទូលបង្គំបានបោកគាត់ ហើយបានធ្វើពុតដោយនិយាយកុហកថាទូលបង្គំមានមិត្តភក្តិម្នាក់ដែលទូលបង្គំចង់ទៅលេងជាមួយរហូតដល់ពេលគាត់មានអាកាសធាតុអំណោយផលក្នុងការចេញដំណើរ។ ទូលបង្គំបានកុហកអ្នកម្តាយទូលបង្គំដើម្បីឲ្យទូលបង្គំអាចគេចចេញ។ ដ្បិតទាក់ទងនឹងចំណុចនេះ ព្រះអង្គក៏បានអត់ទោសដល់ទូលបង្គំយ៉ាងពេញទៅដោយក្តីមេត្តាករុណាផងដែរ។ ហើយទោះបើថាទូលបង្គំជាមនុស្សល្ងីល្ងើម្នាក់ក៏ដោយក៏ព្រះអង្គនៅតែការពារទូលបង្គំពីទឹកសមុទ្រដែរ។ លើសពីនោះទៅទៀត តាមរយៈទឹកនៃព្រះគុណរបស់ព្រះអង្គ ទ្រង់ក៏បានបន្សុទ្ធទូលបង្គំ។ ហើយទូលបង្គំក៏ទទួលបានកម្លាំងពីទឹកភ្នែកដែលអ្នកម្តាយទូលបង្គំបានសម្រក់ជាប្រចាំថ្ងៃសម្រាប់ទូលបង្គំក្នុងការអធិស្ឋានរបស់គាត់ដែរ។ ហើយដោយសារគាត់បានបដិសេធន៍មិនត្រឡប់ទៅវិញបើគ្មានទូលបង្គំទៅជាមួយ នោះទូលបង្គំក៏បានបញ្ចុះបញ្ចូលគាត់ ឲ្យនៅសម្រាកយប់នោះនៅកន្លែងដ៏ស្ងៀមស្ងាត់មួយជិតនាវារបស់យើង។ នាពេលយប់នោះទូលបង្គំលួចចេញស្ងៀមស្ងាត់ តែគាត់នៅបន្តអធិស្ឋាន និងយំ។ ឱព្រះអម្ចាស់អើយ! តើគាត់បានទូលសូមអ្វីពីទ្រង់ក្នុងការបង្ហូរទឹកភ្នែកនោះ ក្រៅពីការអង្វរករទ្រង់កុំឲ្យទូលបង្គំចេញដំណើរតាមនាវា? ប៉ុន្តែព្រះអង្គ តាមរយៈការប្រឹក្សាដ៏សម្ងាត់របស់ទ្រង់ ហើយនិងការសម្គាល់លើសេចក្តីប្រាថ្នាដ៏ខ្លាំងរបស់គាត់ ទ្រង់មិនបានប្រទាននូវអ្វីដែលគាត់កំពុងតែទូលសូម ដើម្បីប្រទាននូវអ្វីដែលគាត់ទូលសូមពីមុនៗនោះទេ។

ខ្យល់ក៏បក់ ហើយរុញនាវាយើងឃ្លាតចេញពីឆ្នេរទៅ។ ពោរពេញទៅដោយទុក្ខព្រួយអ្នកម្តាយក៏បានទៅកន្លែងនោះនាព្រឹកបន្ទាប់ ហើយមានពេញទៅដោយការត្អូញត្អែរ និងសំឡេងថ្ងូរទៅកាន់ព្រះអង្គ។ ស្របពេលនោះដែរ ព្រះអង្គក៏កំពុងតែប្រើប្រាស់សេចក្តី

ប្រាថ្នារបស់ទូលបង្គំទុកជាយានក្នុងការបញ្ចប់សេចក្តីប្រាថ្នាទាំងនោះ។ ហើយដូចម្តាយគ្រប់ៗរូប អ្នកម្តាយទូលបង្គំស្រឡាញ់ការមានទូលបង្គំនៅជាមួយគាត់ ហើយទំនងជាខ្លាំងជាងម្តាយផ្សេងៗទៀតក៏ថាបាន។ ប៉ុន្តែ គាត់មិនដឹងអំពីអំណរដែលទ្រង់កំពុងតែត្រៀមទុកសម្រាប់គាត់តាមរយៈការចាកចេញរបស់ទូលបង្គំនៅឡើយទេ។ ដោយមិនដឹងអំពីលទ្ធផលនៃអាថ៌កំបាំងនេះ គាត់ក៏មិនបន្តយំ កាន់ទុក្ខ ហើយឃើញក្នុងគាត់អំពីភាពឈឺចាប់នៃមរតកពីនាង អេវ៉ា ដោយស្វែងរកការឈឺចាប់ក្នុងអ្វីដែលគាត់បានបង្កើតមកក្នុងទុក្ខព្រួយ។ ទោះជាយ៉ាងណាក្តី បន្ទាប់ពីគាត់បន្ទោសទូលបង្គំអំពីការកុហក នឹងភាពឃោរឃៅ គាត់ក៏បន្តអធិស្ឋានសម្រាប់ទូលបង្គំ។ គាត់ក៏ត្រឡប់ទៅផ្ទះ ហើយទូលបង្គំក៏ធ្វើដំណើរទៅឯទីក្រុងរ៉ូម។

១៦. នៅទីក្រុងរ៉ូម ទូលបង្គំបានធ្លាក់ខ្លួនឈឺយ៉ាងខ្លាំង ហើយទូលបង្គំក៏ជិតធ្លាក់នរកទៀតផង ទូលបង្គំធូន់ធ្ងរទៅដោយអំពើបាបដ៏អាក្រក់អាក្រីដែលទូលបង្គំបានប្រព្រឹត្តទាស់ប្រឆាំងនឹងព្រះអង្គ ខ្លួនឯង និងអ្នកដទៃ—ដែលមានទាំងច្រវាក់ជាមរតកនៃអំពើបាបដែលយើងទាំងអស់គ្នាស្លាប់ក្នុងលោក អ័ដាម។ ដ្បិតនៅពេលនោះ ព្រះអង្គមិនទាន់បានអត់ទោសបាបទូលបង្គំក្នុងព្រះគ្រីស្ទនៅឡើយ ហើយព្រះគ្រីស្ទក៏មិនទាន់លុបបំបាត់ច្បាប់នៃក្រឹត្យវិន័យចោលដែលមានចែងក្នុងពិធីបង្វូរព្រះគុណនៅឡើយ ដើម្បីឲ្យព្រះអង្គអាចនឹងបង្កើតក្នុងទ្រង់នូវបុរសថ្មីម្នាក់ទៀតជំនួសបុរសទាំងពីរ ហើយចេញពីការនោះបង្កើតឲ្យមានសន្តិភាពបាន។[២] តើឲ្យទ្រង់អាចរំដោះទូលបង្គំតាមរយៈការជាប់ឈើឆ្កាងដែលទូលបង្គំជឿថាមិនមែនជារឿងពិតបានដោយរបៀបណាទៅ? ហើយទូលបង្គំក៏បានជឿថាព្រះយេស៊ូវក៏មិនពិតដែរ។ ព្រលឹងវិញ្ញាណទូលបង្គំបានស្លាប់យ៉ាងខ្លាំងដល់ថ្នាក់ថាចំពោះទូលបង្គំការសុគតរបស់ព្រះអង្គនៅលើឈើឆ្កាងគឺជារឿងក្លែងក្លាយ។ ប៉ុន្តែ ផ្ទុយទៅវិញ គឺការសុគតរបស់ទ្រង់នោះហើយដែលជាការពិត ហើយជីវិតនៃព្រលឹងវិញ្ញាណទូលបង្គំគឺពិតជាក្លែងក្លាយមែន ទោះបើទូលបង្គំមិនបានជឿនៅកាលនោះក៏ដោយ។

កម្តៅនៃគ្រុនក្តៅរបស់ទូលបង្គំក៏កាន់តែកើនឡើង ហើយទូលបង្គំជិតឈានដល់ទីបញ្ចប់ដោយស្លាប់យ៉ាងអស់កល្បជានិច្ច។ ដ្បិតប្រសិនបើទូលបង្គំបានស្លាប់មែននៅកាលនោះ តើទូលបង្គំនឹងទៅទីណាក្រៅពីធ្លាក់ក្នុងទារុណកម្មដ៏ក្តៅដែលអំពើបាបទូលបង្គំ

២ អេភេសូរ ២:១៥។

ស័ក្តិសមនឹងទទួល ពេលវាស់វែងដោយសេចក្តីពិតនៃការត្រួតត្រារបស់ព្រះអង្គ? ទោះបើអ្នកម្តាយទូលបង្គំមិនដឹងអ្វីសោះអំពីរឿងនេះក៏គាត់នៅតែបន្តអធិស្ឋានសម្រាប់ទូលបង្គំពីចម្ងាយដដែល។ ហើយព្រះវត្តមានរបស់ទ្រង់ដែលមានគ្រប់ទីកន្លែងក៏ព្រះសណ្តាប់ឮសេចក្តីអធិស្ឋានរបស់គាត់សម្រាប់ទូលបង្គំ។ ហើយតាមរយៈសេចក្តីស្រឡាញ់ និងសេចក្តីមេត្តាករុណារបស់ព្រះអង្គ នោះទូលបង្គំក៏ទទួលបានសុខភាពទូលបង្គំវិញ ទោះបើដួងចិត្តដែលមិនចេះស្តាប់បង្គាប់របស់ទូលបង្គំនៅមានពេញទៅដោយភាពច្របូកច្របល់ក៏ដោយ។ ក្នុងការប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ខ្លាំងបំផុតនៃសេចក្តីស្លាប់ ទូលបង្គំក៏មិនប្រាថ្នាចង់ទទួលពិធីជ្រមុជទឹកដែរ ដោយនេះអះអាងថា កាលទូលបង្គំនៅកំលោះ ទូលបង្គំស្ថិតក្នុងស្ថានភាពប្រសើរជាងនេះ ពីព្រោះកាលនោះទូលបង្គំបានទាមទារទទួលពិធីជ្រមុជទឹកពីអ្នកម្តាយទូលបង្គំ ដូចដែលទូលបង្គំបានរៀបរាប់រួចហើយ។ ដោយសារបន្ទាប់ពីនោះទូលបង្គំក៏កាន់តែមិនសូវចេះគោរពហើយក៏ថែមទាំងសើចចំអកឡុកឡឺយយ៉ាងខ្លាំងក្រៃលែងលើគោលបំណងទាំងអស់នៃថ្នាំរបស់ព្រះអង្គ ថ្នាំមិនបានអនុញ្ញាតឲ្យទូលបង្គំស្លាប់ទ្វេដង ទោះបើទូលបង្គំជាមនុស្សមានបាបយ៉ាងណាក៏ដោយ។ ប្រសិនបើរបួសនៃសេចក្តីស្លាប់របស់ទូលបង្គំចាក់បេះដូងរបស់អ្នកម្តាយទូលបង្គំ នោះបេះដូងគាត់នឹងមិនអាចទទួលបានការព្យាបាលឡើយ ដ្បិតទូលបង្គំមិនអាចរៀបរាប់យ៉ាងស័ក្តិសមអំពីសេចក្តីស្រឡាញ់ដែលគាត់មានសម្រាប់ទូលបង្គំទេ ឬក៏អំពីការដែលគាត់បានរងទុក្ខការឈឺចាប់យ៉ាងខ្លាំងសម្រាប់ទូលបង្គំខាងឯព្រលឹងជាមួយនឹងការឈឺចាប់ដ៏ខ្លោចផ្សារជាងពេលដែលគាត់បានបង្កើតទូលបង្គំខាងឯសាច់ឈាមទៅទៀត។

១៧. ទូលបង្គំមិនអាចស្រមៃឃើញថា អ្នកម្តាយទូលបង្គំនឹងជាសះស្បើយឡើយ ប្រសិនបើការស្លាប់របស់ទូលបង្គំបានចាក់ក្តីស្រឡាញ់ដ៏ជ្រាលជ្រៅរបស់គាត់ ដោយសារទូលបង្គំនៅក្នុងអំពើបាបនៅឡើយ។ បើដូច្នោះមែន នោះការអធិស្ឋានរបស់គាត់ដែលមិនចេះឈប់ឈរ យ៉ាងអស់ពីចិត្ត និងខ្ជាប់ខ្ជួនទៅកាន់ព្រះអង្គនឹងទៅដល់ទីណាទៅ? មានកន្លែងតែមួយគត់ដែលពួកគេអាចនៅបានគឺជាមួយនឹងព្រះអង្គ។ ប៉ុន្តែ តើឲ្យព្រះអង្គដ៏ជាព្រះដែលមានពេញទៅដោយសេចក្តីមេត្តាករុណាដ៏ធំធេងបំផុតស្អប់ «ចិត្តខ្ទេចខ្ទាំ និងចិត្តសោកស្តាយ»[៣] នៃស្ត្រីមេម៉ាយដ៏បរិសុទ្ធ និងឆ្លាតវៃម្នាក់នោះបានដោយរបៀបណាទៅ?

---

៣ ទំនុកតម្កើង ៥១:១៧។

ដ្បិតគាត់ធ្វើទានឥតឈប់ឈរ មានពេញទៅដោយព្រះគុណ ហើយយកចិត្តទុកដាក់ជាមួយនឹងអ្នកជឿព្រះអង្គ មិនដែលខានក្នុងការទៅលេងព្រះវិហារពីរដងក្នុងមួយថ្ងៃ គឺពេលព្រឹក និងពេលល្ងាច។ គាត់បានទៅព្រះវិហារមិនមែនដើម្បីទៅនិយាយដើមគេដោយឥតប្រយោជន៍ ឬក៏រឿងព្រេងឥតខ្លឹមសាររបស់ស្ត្រីចាស់ៗ ប៉ុន្តែដើម្បីឲ្យគាត់អាចស្ដាប់ព្រះអង្គតាមរយៈការអធិប្បាយនៃព្រះបន្ទូលរបស់ទ្រង់ និងដើម្បីសន្ទនាជាមួយនឹងព្រះអង្គក្នុងការអធិស្ឋានរបស់គាត់។ តើព្រះអង្គនឹងបដិសេធន៍ដោយមិនជួយគាត់បានមែនឬ? ដ្បិតគឺដោយសារព្រះគុណរបស់ទ្រង់ហើយដែលធ្វើឲ្យគាត់ជាស្ត្រីដែលមានលក្ខណៈសម្បត្តិល្អដែលគាត់មាន។ ឬក៏ថាតើព្រះអង្គអាចស្អប់ ឬក៏មើលរំលងទឹកភ្នែកដែលគាត់បានសម្រក ហើយមិនមកជួយគាត់បានដែរឬទេ? ទឹកភ្នែកទាំងនោះដែលគាត់បានប្រើប្រាស់ ដើម្បីទាមទារពីព្រះអង្គ មិនមែនទាមទារសម្រាប់មាស ប្រាក់ ឬក៏អ្វីល្អមួយដែលនៅបណ្ដោះអាសន្ន និងមិននៅស្ថិតស្ថេរទេ ប៉ុន្តែគឺទាមទារឲ្យសង្គ្រោះព្រលឹងវិញ្ញាណរបស់កូនប្រុសគាត់? តើព្រះអង្គនឹងបដិសេធន៍នោះមែនឬ? ទេ! ប្រាកដណាស់! ឱព្រះអម្ចាស់អើយ គឺទ្រង់នៅទីនោះ ហើយក៏ព្រះសណ្ដាប់ឮសេចក្ដីអធិស្ឋានរបស់គាត់ ហើយក៏តែបំពេញផែនការរបស់ទ្រង់ដែលទ្រង់បានគ្រោងទុកពីមុនមក ដើម្បីឲ្យវាបានស្រេច។ ព្រះអង្គទំនងអាចជាបោកប្រាស់គាត់បានក្នុងសុបិនទាំងនោះ និងក្នុងចម្លើយដែលគាត់បានទទួលពីទ្រង់—ខ្លះទូលបង្គំបានលើកឡើងរួចហើយ ហើយខ្លះទៀតមិនបានលើកឡើងទេ—ដែលគាត់បានរក្សាទុកក្នុងដួងចិត្តដ៏ស្មោះត្រង់របស់គាត់ ហើយក៏បានអង្វរករជានិច្ច ខំប្រឹងទូលទៅកាន់ព្រះអង្គហាក់បីដូចជាថាវាជាសេចក្ដីសន្យាផ្ទាល់របស់ទ្រង់ដែលទ្រង់បានដៅត្រា។ ដោយសារ «ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គស្ថិតស្ថេរអស់កល្បជានិច្ច»[៤] នោះព្រះអង្គបានបន្ទាបឋានៈទ្រង់ចំពោះអស់អ្នកដែលជំពាក់ព្រះអង្គដែលទ្រង់បានអភ័យទោសពួកគេតាមរយៈសេចក្ដីសន្យារបស់ទ្រង់។

១៨. ព្រះអង្គបានព្យាបាលទូលបង្គំចេញពីជំងឺខាងឯសាច់ឈាម ដើម្បីឲ្យទូលបង្គំទំនងជារស់នៅសម្រាប់ទ្រង់ ហើយក៏ដើម្បីឲ្យព្រះអង្គប្រទានមកកាន់ទូលបង្គំនូវសុខភាពដ៏ល្អប្រសើរជាងនោះលើសពីជីវិតនេះទៅទៀត។ បន្ទាប់ពីនោះ នៅឯទីក្រុងរ៉ូម ទូលបង្គំក៏

---

៤ ប្រធានបទមួយនេះមាននៅក្នុងកណ្ឌគម្ពីរទំនុកតម្កើង និងខគម្ពីរផ្សេងៗទៀត សូមអានបន្ថែមកណ្ឌគម្ពីរទំនុកតម្កើង ១៣៦។

នៅរាប់អានជាមួយនឹងពួកខុសដែលបោកបញ្ឆោតថា “ពួកបរិសុទ្ធ” ហើយក៏មិនមែនគ្រាន់តែជា “អ្នកស្ដាប់” ម្នាក់របស់គេនោះទេ ដូចបុគ្គលដែលទូលបង្គំបានធ្លាក់ខ្លួនឈឺនៅក្នុងផ្ទះគាត់ ប៉ុន្តែគឺជាមួយអស់អ្នកដែលគេហៅថា “ពួកជ្រើសរើស”។ ទូលបង្គំនៅតែជឿថា “គឺមិនមែនយើងទេដែលជាអ្នកប្រព្រឹត្តអំពើបាប ប៉ុន្តែនិស្ស័យមួយផ្សេងទៀតដែលធ្វើបាបក្នុងយើង”។ ហើយវាក៏បានបំពេញអំនួតរបស់ទូលបង្គំហួសពីការស្ដីបន្ទោស ហើយនៅពេលដែលទូលបង្គំបានប្រព្រឹត្តអ្វីមួយខុសឆ្គង នោះទូលបង្គំមិនបានលន់តួទៅកាន់ព្រះអង្គថាទូលបង្គំបានប្រព្រឹត្តខុសទេ—“សូមប្រណីសន្ដោសទូលបង្គំ សូមប្រោសព្រលឹងទូលបង្គំឲ្យបានជា ដ្បិតទូលបង្គំបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គហើយ”[៥] ហើយទូលបង្គំក៏ចូលចិត្តរកលេសសម្រាប់ព្រលឹងទូលបង្គំ ហើយដោះសារចោទប្រកាន់អ្វីមួយទៀតនៅក្នុងទូលបង្គំវិញ ទោះបើទូលបង្គំមិនដឹងថាជាអ្វីក៏ដោយ។ ប៉ុន្តែប្រាកដណាស់គឺទូលបង្គំ ហើយនឹងអំពើបាបរបស់ទូលបង្គំដែលបានបំបែកទូលបង្គំឲ្យទាស់ប្រឆាំងនឹងខ្លួន។ ដូច្នេះ អំពើបាបនោះក៏កាន់តែមិនអាចទទួលការព្យាបាលបាន ពីព្រោះទូលបង្គំមិនជឿថាខ្លួនឯងគឺជាមនុស្សមានបាបនោះទេ។ ឱព្រះអម្ចាស់អើយ! វាគឺជាអំពើរំលងដ៏អាក្រក់ដែលមិនអាចទទួលយកបាន។ ប៉ុន្តែ ព្រះអង្គមិនទាន់បានដាក់រនាំងការពារមាត់ទូលបង្គំ និងទ្វារលើបបូរមាត់របស់ទូលបង្គំនៅឡើយ ដើម្បីកុំឲ្យចិត្តទូលបង្គំងាយនឹងនិយាយអាក្រក់ និងដើម្បីមានលេសសម្រាប់អំពើបាបជាមួយនឹងមនុស្សដែលប្រព្រឹត្តល្មើស។[៦] ហេតុដូច្នេះហើយបានជាទូលបង្គំបន្តនៅក្នុងក្រុមមានិហៀន ដែលរាប់ខ្លួនថាជា “អ្នកជ្រើសរើស”។

២១. លើសពីនោះទៅទៀតទូលបង្គំក៏ឯកភាពជាមួយនឹងការរិះគន់របស់ពួកគេលើព្រះបន្ទូលរបស់ព្រះអង្គផងដែរ។ ប៉ុន្តែ ទោះជាយ៉ាងណាក្ដី ម្ដងម្កាលក៏ទូលបង្គំប្រាថ្នាចង់និយាយលើប្រធានបទនានាជាមួយនឹងបុគ្គលណាម្នាក់ដែលចេះព្រះគម្ពីរល្អម ដើម្បីល្បងលអំពីអ្វីដែលគាត់គិតអំពីវា។ កាលទូលបង្គំនៅទីក្រុងកាតធេ មានបុរសម្នាក់ឈ្មោះលោក អិលភីឌីអូស៍ (Elpidius) ដែលបាននិយាយទាស់ប្រឆាំងមុខទល់នឹងមុខជាមួយនឹងក្រុមមានិហៀន ហើយគាត់ក៏ចាប់ផ្ដើមធ្វើឲ្យទូលបង្គំចាប់អារម្មណ៍ ពីព្រោះគាត់បានលើកឡើងនូវចំណុចចេញពីព្រះគម្ពីរដែលមានការពិបាកក្នុងការទាស់ប្រឆាំងវិញ ហើយ

៥ ទំនុកតម្កើង ៤១:៤។
៦ ទំនុកតម្កើង ១៤១:៣។

ចំពោះទូលបង្គំ ចម្លើយរបស់ទូលបង្គំគឺហាក់បីដូចជាខ្សោយណាស់។ មានចម្លើយ មួយពួកគេមិននិយាយជាសាធារណៈនោះទេ ប៉ុន្តែបាននិយាយតែជាមួយយើងផ្ទាល់—ពេលដែលពួកគេបានលើកឡើងថា មានអ្នកដែលគេមិនស្គាល់ដែលចង់ភ្ជាប់ក្រឹត្យវិន័យរបស់សាសន៍យូដាជាមួយនឹងជំនឿគ្រីស្ទបរិស័ទបានលូកលាន់លើអត្ថបទនៃព្រះគម្ពីរសញ្ញាថ្មី។ ប៉ុន្តែ ពួកគាត់ផ្ទាល់មិនដែលបង្ហាញអត្ថបទដែលមានគេផ្លាស់ប្តូរពាក្យសោះ។ តាមរយៈការនៅគិតដោយរំពឹងលើអ្វីដែលភ្នែកទូលបង្គំអាចមើលឃើញបាន នោះពួកគាត់មានការគ្រប់គ្រងលើទូលបង្គំក្នុងផ្នែកខ្លះៗ។ ទូលបង្គំមិនអាចដកដង្ហើមនៃសេចក្តីពិតដ៏បរិសុទ្ធ ហើយឥតសៅហ្មងបានឡើយ។

សៀវភៅទី៥

# ១២

# ការរៀនសូត្រពីលោកគ្រូអែមប្រូស៍

២២. ទូលបង្គំបានត្រៀមរួចហើយក្នុងការធ្វើអ្វីដែលទូលបង្គំគ្រោងនឹងធ្វើនៅឯទីក្រុងរ៉ូម គឺ៖ បង្រៀនវោហារសាស្ត្រ។ ជំហានដំបូងគឺនាំមនុស្សពីរបីនាក់មកក្នុងផ្ទះទូលបង្គំ ហើយចាប់ផ្ដើមបង្កើតកេរ្តិ៍ឈ្មោះតាមរយៈពួកគេ។ ប៉ុន្តែ បន្ទាប់មកទូលបង្គំក៏ចាប់ផ្ដើមឃើញថា អំពើល្មើសប្រព្រឹត្តឡើងក្នុងទីក្រុងរ៉ូមគឺមានសភាពខុសគ្នាពីអំពើល្មើសដែលទូលបង្គំធ្លាប់មានបទពិសោធន៍នៅឯប្រទេសអាហ្វ្រិក។ ប្រាកដណាស់! សិស្សានុសិស្សក្មេងៗនៅឯទីក្រុងរ៉ូមមិនបានប្រព្រឹត្តការឆាឆៅដែលគ្មានសណ្ដាប់ធ្នាប់ដូចនៅក្រុងកាតធេទេ។ ប៉ុន្តែ ពេលនោះមិត្តភក្តិទូលបង្គំបានប្រាប់ទូលបង្គំថា សិស្សជាច្រើននៅទីក្រុងរ៉ូមតែងតែមូលគំនិតគ្នា ហើយស្រាប់តែប្តូរទៅរកគ្រូផ្សេងភ្លាមៗ ដើម្បីគេចចេញពីការបង់លុយគ្រូ។ ចិត្ត

ទូលបង្គំស្អប់មនុស្សបែបនោះណាស់ ទោះបើមិនបាន «ស្អប់ពេញទី» ក៏ដោយ។[១] ដ្បិតប្រាកដណាស់ ដោយគ្មានមន្ទិលសង្ស័យ ទូលបង្គំស្អប់ពួកគេខ្លាំង ពីព្រោះពួកគេធ្វើឲ្យទូលបង្គំនឹងរងទុក្ខដោយការវិនិច្ឆ័យទង្វើមិនត្រឹមត្រូវរបស់ពួកគេ។ ទោះជាយ៉ាងណាក្តី មនុស្សបែបនោះគឺពិតជាថោកទាបមែន ពួកគេបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះអង្គ ដ្បិតពួកគេស្រឡាញ់នូវអ្វីដែលនៅបណ្តោះអាសន្ន និងការប្រមូលយកយ៉ាងអាក្រក់ដោយដៃយ៉ាងស្មោកគ្រោកដែលចាប់យករបស់ទាំងនោះ។ គេឱបក្រសោបលោកីយ៍ដែលមិននៅស្ថិតស្ថេរ ហើយស្តីបន្ទោសព្រះអង្គដែលតាមពិតទ្រង់គឺជាអង្គដែលគង់ក្នុងយើង ហើយក៏អញ្ជើញយើងឲ្យវិលត្រឡប់ទៅរកទ្រង់វិញ ហើយព្រះអង្គអត់ឱនទោសព្រលឹងមនុស្សដែលផិតក្បត់ ពេលដែលវាត្រឡប់ទៅរកទ្រង់វិញ។ ឥឡូវ ទូលបង្គំស្អប់មនុស្សមិនស្មោះត្រង់ និងរឹងចចេសបែបនោះណាស់ ប៉ុន្តែទូលបង្គំស្រឡាញ់ពួកគេ ប្រសិនបើពួកគេមានចិត្តចង់ទទួលការណែនាំ ហើយដាក់ចិត្តប្រាថ្នាចង់រៀនជាជាងលុយកាក់ ហើយឲ្យស្រឡាញ់ព្រះអង្គខ្លាំងជាងស្រឡាញ់ការរៀនសូត្រ។ ប៉ុន្តែ នៅកាលនោះសេចក្តីប្រាថ្នាដ៏ខ្លាំងក្លាបំផុតរបស់ទូលបង្គំគឺគិតតែអំពីខ្លួនឯង ហើយមិនចង់រងទុក្ខពីអំពើអាក្រក់ពីពួកគេឡើយ ពោលគឺខ្លាំងជាងចង់ឃើញពួកគេទទួលការបំផ្លាស់បំប្រែសម្រាប់ព្រះនាមរបស់ព្រះអង្គទៅទៀត។

២៣. នៅពេលដែលមានបទបញ្ជាចេញពីរាជរដ្ឋាភិបាលនៃទីក្រុងមីឡាន (Milan) មកកាន់រដ្ឋអំណាចនៅទីក្រុងរ៉ូម ដោយសូមឲ្យពួកគេផ្គត់ផ្គង់គ្រូវោហារសាស្ត្រសម្រាប់ទីក្រុងពួកគេ ហើយចាត់ឲ្យគ្រូទៅដោយប្រើប្រាស់លុយរដ្ឋ នោះទូលបង្គំក៏បានដាក់ពាក្យសម្រាប់ការងារហ្នឹង។ ហើយលោក ស៊ីមម៉ាហ្គូស៍ (Symmachus) ដែលជាអ្នកតំណាងរដ្ឋអំណាច ក៏បានតែងតាំងទូលបង្គំបន្ទាប់ពីគាត់បានល្បងលសមត្ថភាពរបស់ទូលបង្គំតាមរយៈការសាកល្បង។

ហើយនៅពេលដែលទូលបង្គំមកដល់ទីក្រុងមីឡាន នោះទូលបង្គំក៏ជួបលោកគ្រូអែមប្រូស៍ (Ambrose) ដែលជាគ្រូគង្វាល ដែលមានភាពល្បីល្បាញទូទាំងពិភពលោកថាជាបុរសដ៏ល្អម្នាក់ ហើយក៏ជាបុគ្គលដែលមានភក្តីភាពបែបជាអ្នកបម្រើរបស់ព្រះអង្គយ៉ាងខ្លាំង។ នៅពេលនោះសេចក្តីអធិប្បាយដ៏ក្បោះក្បាយរបស់គាត់បានផ្គត់ផ្គង់ដល់

១ ទំនុកតម្កើង ១៣៩:២២។

វាស្ត្ររបស់ទ្រង់នូវម្សៀនៃស្រូវសាលីរបស់ទ្រង់ ភាពអរសប្បាយនៃប្រេងរបស់ទ្រង់ និងភាពរីករាយដ៏ភ្ញាក់ខ្លួននៃស្រារបស់ព្រះអង្គ។[២] ទ្រង់បាននាំទូលបង្គំទៅគាត់ដោយទូលបង្គំមិនដឹងខ្លួន ដើម្បីឲ្យគាត់អាចនាំទូលបង្គំទៅទ្រង់ដោយដឹងខ្លួន។ អ្នកសំណព្វរបស់ព្រះម្នាក់នោះក៏បានទទួលទូលបង្គំហាក់បីដូចជាឪពុកទទួល ហើយស្វាគមន៍ទូលបង្គំដូចដែលអ្នកមើលការខុសត្រូវដ៏ល្អម្នាក់គួរធ្វើ។ ហើយប្រាកដណាស់! ទូលបង្គំក៏ចាប់ផ្តើមស្រឡាញ់គាត់ ជាដំបូងមិនមែនក្នុងនាមជាគ្រូនៃសេចក្តីពិតនោះទេ ដ្បិតទូលបង្គំអស់សង្ឃឹមទាំងស្រុងហើយទាក់ទងនឹងការរកសេចក្តីពិតក្នុងព្រះវិហាររបស់ទ្រង់—ប៉ុន្តែស្រឡាញ់ក្នុងនាមជាបុរសដែលមានការរាក់ទាក់។ ហើយទូលបង្គំក៏បានស្តាប់គាត់ដោយយកចិត្តទុកដាក់—ទោះបើទូលបង្គំមិនមានហេតុផលត្រឹមត្រូវ—ខណៈពេលដែលគាត់អធិប្បាយទៅកាន់មនុស្សម្នា។ កាលនោះទូលបង្គំកំពុងតែព្យាយាមស្វែងយល់ថា តើវោហារសាស្ត្រដ៏ក្បោះក្បាយរបស់គាត់មានភាពស៊ីគ្នាជាមួយនឹងកេរ្តិ៍ឈ្មោះរបស់គាត់ឬទេ ហើយថាតើវាហូរជ្រៅ ឬរាក់ជាងអ្វីដែលអ្នកដទៃបានលើកឡើងដែរឬទេ។ ហេតុដូច្នេះហើយបានជាទូលបង្គំស្តាប់ពាក្យពេចន៍របស់គាត់ដោយយកចិត្តទុកដាក់ ប៉ុន្តែទាក់ទងនឹងប្រធានបទរបស់គាត់ ទូលបង្គំគ្រាន់តែជាអ្នកស្តាប់ដែលធ្វេសប្រហែស ហើយមើលងាយទៀតផង។ ទូលបង្គំពេញចិត្តនឹងភាពទាក់ទាញនៃពាក្យពេចន៍របស់គាត់ ដែលពោរពេញទៅដោយបញ្ញវន្ត ទោះបើមិនសូវរីករាយ ហើយស្រួលស្តាប់ជាងរបៀបរបស់លោក ហ្វីស្ទឹស៍ ក៏ដោយ។ ទោះជាយ៉ាងណាក្តី ទាក់ទងនឹងប្រធានបទ មិនអាចមានការប្រៀបធៀបឡើយ ដ្បិតលោក ហ្វីស្ទឹស៍ កំពុងតែវង្វេងក្នុងការបោកបញ្ឆោតរបស់ក្រុមម៉ានិហ្គៀន ខណៈពេលដែលការបង្រៀនរបស់លោកគ្រូគង្វាល អែមប្រូស៍ ដែលជាអ្នកមើលខុសត្រូវ គឺអំពីសេចក្តីសង្គ្រោះដ៏ត្រឹមត្រូវ។ ប៉ុន្តែ «ការសង្គ្រោះស្ថិតនៅឆ្ងាយពីមនុស្សអាក្រក់»[៣] ហើយនោះជាការពិតចំពោះទូលបង្គំ ពេលទូលបង្គំកំពុងឈរនៅមុខគាត់។ ទោះជាយ៉ាងណាក្តីក៏ទូលបង្គំកំពុងតែខិតចូលជាងមុនបន្តិចម្តងៗដោយមិនទាំងដឹងខ្លួនទៀតផង។

២៤. ទោះបើទូលបង្គំមិនបានយកចិត្តទុកដាក់ទៅនឹងអ្វីដែលគាត់បានលើកឡើង ប៉ុន្តែដើម្បីគ្រាន់តែឲ្យឮអំពីរបៀបដែលគាត់បាននិយាយក៏ដោយ ក៏ការយកចិត្តទុកដាក់

---

២ ទំនុកតម្កើង ៤:៧; ៤៥:៧; ១០៤:១៥។

៣ ទំនុកតម្កើង ១១៩:១៥៥។

ដ៏ទទេសូន្យនេះនឹងនៅបន្តជាគោលបំណងចម្បងរបស់ទូលបង្គំដរាបណាទូលបង្គំគ្មានសង្ឃឹមក្នុងការស្វែងរកផ្លូវដ៏ច្បាស់លាស់ពីមនុស្សទៅកាន់ព្រះអង្គ។ ទោះជាយ៉ាងណាក្ដី អមជាមួយនឹងវោហារសាស្ត្រដ៏ក្បោះក្បាយដែលទូលបង្គំពេញចិត្ត នោះគំនិតដែលទូលបង្គំបានមើលរំលងក៏បានចូលមកក្នុងខួរក្បាលទូលបង្គំដែរ ដ្បិតទូលបង្គំមិនអាចបំបែកវាបានឡើយ។ ហើយខណៈពេលដែលទូលបង្គំបានបើកចិត្តទទួលស្គាល់អំពីជំនាញនៃការនិយាយស្ដីរបស់គាត់ នោះទូលបង្គំក៏ចាប់ផ្ដើមដឹងបន្តិចម្ដងៗអំពីសេចក្ដីពិតដែលគាត់កំពុងបង្រៀន។ ជាដំបូង ចំពោះទូលបង្គំ គំនិតរបស់គាត់ហាក់បីដូចជាអាចការពារបាន ហើយទោះបើពីមុនទូលបង្គំគិតថាគោលលទ្ធិនៃជំនឿគ្រីស្ទបរិស័ទមិនអាចតតាំងនឹងការរែកញែកដ៏មានអំណាចរបស់ក្រុមម៉ានិហៀនបានក៏ដោយ ក៏ឥឡូវនេះទូលបង្គំយល់ថា វាអាចអះអាងដោយគ្មានការច្របូកច្របល់យល់ច្រឡំគ្នាទេ។ ការនេះគឺពិតជាច្បាស់លាស់ណាស់ ជាពិសេសបន្ទាប់ពីទូលបង្គំបានឮពីរទៅបីដងនៃការពន្យល់អំពីព្រះគម្ពីរសញ្ញាចាស់បែបប្រៀបធៀប—ដែលពីមុនៗនៅពេលដែលទូលបង្គំកាត់ស្រាយវាដោយចំៗគឺវា “បានសម្លាប់” ទូលបង្គំខាងឯព្រលឹងវិញ្ញាណវិញ។[៤] ទោះជាយ៉ាងណាក្ដី នៅពេលដែលទូលបង្គំទទួលបានការពន្យល់លើបទគម្ពីរជាច្រើនក្នុងកណ្ឌគម្ពីរទាំងនោះ ទូលបង្គំក៏ចាប់ផ្ដើមឃើញកំហុសក្នុងភាពអស់សង្ឃឹមរបស់ទូលបង្គំដោយជឿជាក់ថាមិនអាចមានការឆ្លើយតបទៅកាន់អស់អ្នកដែលស្អប់ ហើយសើចចំអកលើកណ្ឌគម្ពីរក្រឹត្យវិន័យ និងកណ្ឌគម្ពីរពួកហោរាបានទៀតទេ។ ប៉ុន្តែ ទូលបង្គំក៏មិនទាន់បានឃើញថា នេះជាមូលហេតុគ្រប់គ្រាន់ក្នុងការដើរតាមគោលជំនឿគ្រីស្ទបរិស័ទនេះដោយគ្រាន់តែសម្អាងថារបៀបនៃការកាត់ស្រាយរបស់ព្រះគម្ពីររបស់ពួកគេគឺសម្លឹងមើលតែបុគ្គលដែលអាចឆ្លើយជំទាស់ដោយគ្មានភាពពុំសមហេតុសមផល។ ហើយទូលបង្គំក៏មិនទាន់ឃើញថាអ្វីដែលទូលបង្គំធ្លាប់បានឮពីមុននេះ ឥឡូវនេះគួរទទួលការថ្កោលទោសផងដែរ ពីព្រោះទាំងសងខាងមានការការពារស្មើគ្នាក្នុងយោបល់ទូលបង្គំ។ ដូច្នេះ ចំពោះទូលបង្គំ គោលជំនឿដែលត្រឹមត្រូវហាក់បីដូចជាមិនទាន់ទទួលបានការចាញ់ទាំងស្រុង ប៉ុន្តែក៏មិនទាន់ទទួលបានជ័យជម្នះទាំងស្រុងនៅឡើយដែរ។

២៥. ប៉ុន្តែ ពេលនោះទូលបង្គំបានមូលគំនិតខ្លួនឯងយ៉ាងខ្លាំងថា តើមានមធ្យោបាយ

---

៤ សូមអានបន្ថែមក្នុងកណ្ឌគម្ពីរ ២កូរិនថូស ៣:៦។

ណាដែលអាចទៅរួចបានទេក្នុងការបង្ហាញថាក្រុមមានិហ្គៀនគឺជាក្រុមខុសឆ្គង។ ប្រសិនបើទូលបង្គំអាចស្រមើស្រមៃអំពីធាតុពិតខាងឯវិញ្ញាណបាន នោះទីមាំមួនរបស់ពួកគេនឹងដួលរលំ ហើយក៏ត្រូវបានបោះបង់ចោលចេញពីគំនិតរបស់ទូលបង្គំជាមិនខាន។ ប៉ុន្តែ ទូលបង្គំមិនអាច។ ទោះជាយ៉ាងណាក្តី ទាក់ទងនឹងរូបកាយសម្ភារៈនិយមនៃផែនដីនេះ និងធម្មជាតិទាំងមូល—ហើយពេលនោះដោយសារទូលបង្គំមានសមត្ថភាពក្នុងការគិត និងប្រៀបធៀបរឿងដូចបែបនោះជាងមុន—ដូច្នេះ ទូលបង្គំក៏បានសម្រេចចិត្តថាទស្សនវិទូភាគច្រើនប្រកាន់ខ្ជាប់តាមជម្រើសនៃទស្សនៈត្រឹមត្រូវជាងក្រុមមានិហ្គៀន។ ដូច្នេះ តាមរយៈរបៀបដែលទូលបង្គំបានគិតដែលទស្សនវិទូ បានប្រើប្រាស់ នោះទូលបង្គំក៏ឈានដល់ការសន្និដ្ឋានថាទូលបង្គំត្រូវតែចាកចេញពីក្រុមមានិហ្គៀន។ ទូលបង្គំបានសម្រេចចិត្តថា ទូលបង្គំមិនអាចនៅបន្តក្នុងក្រុមនេះបានទៀតទេ ពីព្រោះទូលបង្គំចូលចិត្តទស្សនវិទូមួយចំនួនទៀតជាងពួកគេ។ ប៉ុន្តែ ទូលបង្គំក៏បានបដិសេធន៍ក្នុងការដាក់ការព្យាបាលនៃព្រលឹងដ៏ទន់ខ្សោយរបស់ទូលបង្គំចំពោះពួកទស្សនវិទូទាំងនោះ ពីព្រោះពួកគេគ្មានព្រះនាមនៃការសង្គ្រោះរបស់ព្រះគ្រីស្ទឡើយ។ ហេតុដូច្នេះ ទូលបង្គំក៏សម្រេចចិត្តយ៉ាងម៉ឺងម៉ាត់ថាធ្វើជាអ្នករៀនសូត្រក្នុងក្រុមជំនុំ—ដែលឪពុកម្តាយទូលបង្គំបានប្រាថ្នាយ៉ាងខ្លាំងក្នុងការឃើញទូលបង្គំធ្វើ—រហូតដល់ទូលបង្គំឃើញយ៉ាងច្បាស់លាស់នូវពន្លឺដែលណែនាំផ្លូវទូលបង្គំ។

# ១៣

# អ្នកម្តាយទូលបង្គំនៅឯទីក្រុងមីឡាន

១. ឱព្រះដ៏ជាសេចក្តីសង្ឃឹមរបស់ទូលបង្គំតាំងពីទូលបង្គំនៅជាក្មេងនៅឡើយអើយ![1] តើព្រះអង្គនៅឯណាពេលនោះ ហើយតើទ្រង់បានដកអង្គទ្រង់ចេញពីទូលបង្គំនៅពេលណា?[2] ដ្បិតតើព្រះអង្គមិនបានបង្កើតទូលបង្គំ ហើយធ្វើឲ្យទូលបង្គំមានភាពឧត្តុង្គឧត្តមខ្ពស់ជាងពួកសត្វ ហើយមានប្រាជ្ញាខ្លាំងជាងបក្សាបក្សីមែនឬ? តែទោះជាយ៉ាងណាក្តី ក៏ទូលបង្គំបានវង្វេងក្នុងសេចក្តីងងឹត និងផ្លូវដ៏រអិលដែរ។ ទូលបង្គំបានស្វែងរកព្រះអង្គក្រៅពីខ្លួនឯង។ ហេតុដូច្នេះហើយបានជាទូលបង្គំមិនបានស្វែងរកព្រះដ៏ជាម្ចាស់នៃដួងចិត្តទូលបង្គំឃើញ។ ទូលបង្គំបានចុះទៅក្នុងជម្រៅទឹកនៃសមុទ្រ ហើយក៏បានបាត់បង់

១ ទំនុកតម្កើង ៧១:៥។
២ ទំនុកតម្កើង ១០:១។

ជំនឿ ថែមទាំងអស់សង្ឃឹមត្រង់ថា ខ្លួននឹងមិនដែលរកឃើញសេចក្តីពិតបាន។

មកដល់ពេលនេះ បន្ទាប់ពីអ្នកម្តាយទូលបង្គំបានប្រមូលផ្តុំភាពក្លាហាន គាត់ក៏បាន។ មករកទូលបង្គំ ហើយថែមទាំងបានឆ្លងកាត់នូវរាល់គ្រោះថ្នាក់ក្នុងការធ្វើដំណើរដោយមានសន្តិភាពក្នុងព្រះអង្គ។ ដ្បិតក្នុងគ្រោះថ្នាក់នៃការធ្វើដំណើរគាត់បានលួងលោមពួកនាវិក—ទោះបើថាជាទូទៅអ្នកធ្វើដំណើរដែលមិនមានបទពិសោធន៍ចេញពីការលួងលោមតាមរយៈនាវិកពេលដែលពួកគេភ័យខ្លាច—ហើយគាត់ក៏បានធានាទៅកាន់ពួកគេថា ពួកគេនឹងទៅដល់ទីកន្លែងដោយមានសុខសុវត្ថិភាព ពីព្រោះព្រះអង្គបានធានាមកកាន់គាត់អំពីការនេះនៅក្នុងការបើកសម្តែង។

ពេលអ្នកម្តាយបានរកឃើញទូលបង្គំក្នុងស្ថានភាពដ៏ពេញទៅដោយគ្រោះថ្នាក់នៃការបាក់ទឹកចិត្ត ដ្បិតទូលបង្គំបានអស់សង្ឃឹមទាំងស្រុងហើយថា ខ្លួននឹងមិនអាចរកឃើញសេចក្តីពិតបានឡើយ។ ប៉ុន្តែ នៅពេលដែលទូលបង្គំបានប្រាប់គាត់ថា ឥឡូវនេះទូលបង្គំលែងដើរតាមពួកក្រុមមានិហ្កៀនទៀតហើយ (ទោះបើមិនទាន់ជាគ្រីស្ទបរិស័ទដ៏ពិតក៏ដោយ) នោះគាត់ក៏មិនបានលោតកញ្ឆេងពេញដោយអំណរហាក់បីដូចជាថា នេះគឺជារឿងដែលមិនអាចរំពឹងទុកបានឡើយ។ ដ្បិតគាត់បានទទួលការធានាអះអាងអំពីចំណុចនៃស្ថានភាពដ៏អាក្រក់របស់ទូលបង្គំនោះរួចទៅហើយ ហើយគាត់បានកាន់ទុក្ខសម្រាប់ទូលបង្គំហាក់បីដូចជាថាទូលបង្គំបានស្លាប់ហើយ ប៉ុន្តែក៏ដូចជាថាបុគ្គលម្នាក់ដែលនឹងទទួលបានការមានជីវិតឡើងវិញតាមរយៈព្រះអង្គផងដែរ។ គាត់ក៏បានបីទូលបង្គំទៅព្រះអង្គតាមរយៈការអធិស្ឋានរបស់គាត់ ដើម្បីឲ្យព្រះអង្គអាចមានព្រះបន្ទូលមកកាន់កូននៃស្ត្រីមេម៉ាយម្នាក់នេះ «អ្នកកំលោះអើយ! ខ្ញុំបង្គាប់អ្នកថា ចូរក្រោកឡើង!»[៣] ហើយបន្ទាប់មកកូននេះនឹងមានជីវិតវិញ ហើយចាប់ផ្តើមនិយាយ ហើយព្រះអង្គក៏នឹងយកកូននេះឲ្យអ្នកម្តាយរបស់គាត់វិញ។

ដូច្នេះ គាត់ក៏មិនបានបង្ហាញអំណរយ៉ាងខ្លាំង ពេលដែលគាត់ឮថា ចំណុចដ៏ធំនៃអ្វីដែលគាត់បានអធិស្ឋានជាប្រចាំថ្ងៃទូលសូមឲ្យព្រះអង្គធ្វើ គឺពិតជាបានកើតឡើងរួចស្រេចទៅហើយ—ត្រង់ថាទោះបើទូលបង្គំមិនទាន់បានយល់អំពីសេចក្តីពិតក៏ដោយ ក៏យ៉ាងហោចណាស់ទូលបង្គំបានទទួលការសង្គ្រោះចេញពីភាពខុសឆ្គងដែរ។ ផ្ទុយទៅ

៣ លូកា ៧:១១-១៧។

វិញ គាត់បានមានទំនុកចិត្តយ៉ាងពេញទីថា ព្រះអង្គដែលបានសន្យានូវភាពទាំងស្រុងទៅកាន់គាត់ក៏នឹងប្រទានអ្វីផ្សេងៗទៀតផងដែរ។ ដូច្នេះ ដោយនៅយ៉ាងស្ងៀម ហើយមានចិត្តពេញទៅដោយទំនុកចិត្ត គាត់ក៏បានឆ្លើយតបមកកាន់ទូលបង្គំថា គាត់ជឿជាក់ថាក្នុងព្រះគ្រីស្ទ មុននឹងគាត់ស្លាប់ទៅ នោះគាត់នឹងឃើញទូលបង្គំទទួលយកជំនឿដ៏ពិត។ ហើយគាត់ក៏មិនបានថាអ្វីច្រើនទៀត ក្រៅពីនេះមកកាន់ទូលបង្គំឡើយ។ ប៉ុន្តែ ឱប្រភពនៃសេចក្ដីមេត្តាករុណាអើយ! ទៅកាន់ព្រះអង្គ គាត់បានបន្តបញ្ចេញសំណូមពរអធិស្ឋានម្ដងហើយម្ដងទៀត ដែលពោរពេញទៅដោយទឹកភ្នែកត្រង់ថា ឲ្យព្រះអង្គឆាប់ជួយទូលបង្គំ ហើយបំភ្លឺភ្នែកទូលបង្គំចេញពីភាពងងឹត ហើយគាត់ក៏កាន់តែទៅព្រះវិហារយ៉ាងជាប់លាប់ ហើយទុកពាក្យរបស់លោកគ្រូគង្វាល អែមប្រូស៍ យ៉ាងជាប់លាប់ ខណៈពេលដែលគាត់អធិស្ឋានឲ្យប្រភពទឹកហូរចេញពីជីវិតដ៏នៅអស់កល្បជានិច្ច។[៤] ដ្បិតគាត់ស្រឡាញ់លោកគ្រូនោះ ហាក់បីដូចជាទេវតាម្នាក់របស់ព្រះជាម្ចាស់អញ្ចឹង ដោយសារគាត់បានដឹងថាគឺតាមរយៈការជះឥទ្ធិពលរបស់គាត់នោះឯង ដែលបាននាំឲ្យទូលបង្គំមកដល់ស្ថានភាពដែលមិននឹងនរ ដោយមានមន្ទិលសង្ស័យដែលទូលបង្គំកំពុងតែមានឥឡូវនេះ។ តាមរយៈការនេះ គាត់បានទទួលជឿយ៉ាងពេញលេញថា ទូលបង្គំនឹងជាពីការឈឺ ទោះបើថាទូលបង្គំនឹងត្រូវឆ្លងកាត់កាលៈទេសៈដ៏គួរឲ្យលំបាកជាមុនសិន ដូចជាពេលដែលគ្រូពេទ្យបានពណ៌នាអំពីការឡើងកំដៅពីជំងឺគ្រុនក្ដៅរបស់ទូលបង្គំមុនពេលវាជា។

២. មានពេលមួយអ្នកម្ដាយទូលបង្គំបានយកតង្វាយជាបបរ នំប៉័ង និងស្រាទៅកាន់ទីអាសនៈនៅឯព្រះវិហារដែលគេបានសាងសង់ឡើងទុកជាការចងចាំអំពីពួកមរណសាក្សី (ដូចដែលគាត់បានធ្វើជាច្រើនលើកច្រើនសានៅឯប្រទេសអាហ្វ្រិក)—ប៉ុន្តែ ឥឡូវនេះ អ្នកយាមទ្វារបានហាមឃាត់មិនឲ្យធ្វើនៅឯព្រះវិហារទេ។ ហើយពេលដែលគាត់ដឹងថាគឺលោកគ្រូគង្វាល ដែលជាអ្នកហាមមិនឲ្យធ្វើការនោះ គាត់ក៏បានចុះចូល ហើយស្ដាប់បង្គាប់ពេញទៅដោយមេត្រីភាព ដល់ថ្នាក់ថាទូលបង្គំផ្ទាល់ក៏មានការស្ញប់ស្ញែងអំពីភាពរហ័សរហួននៃរបៀបដែលគាត់បានបដិសេធន៍ប្រពៃណីរបស់ខ្លួនចោល ជាជាងសួរសំណួរដេញដោលអំពីការហាមប្រាមនោះ។ គាត់មិនដែលញៀនក្នុងការផឹកស្រានោះទេ។ ហើយការស្រឡាញ់ស្រាក៏មិនបានបង្កឲ្យគាត់ស្អប់សេចក្ដីពិតផងដែរ ដូចដែលបានកើតឡើង

៤ យ៉ូហាន ៤:១៤។

ចំពោះមនុស្សជាច្រើន ដែលបដិសេធន៍ការបង្រៀនត្រឹមត្រូវដូចអ្នកប្រមឹកស្រោបដិសេធន៍ស្រាដែលលាយទឹក។ គាត់តែងតែមានទម្លាប់ក្នុងការយកម្ហូបអាហារពីមហាស្របក្នុងកញ្ជើរ ដើម្បីភ្លក់ខ្លួនឯងសិន ហើយបន្ទាប់មកក៏ឲ្យទាំងអស់ដល់អ្នកដទៃ។ គាត់មិនដែលអនុញ្ញាតឲ្យខ្លួនហូបស្រាលើសជាងមួយកូនពែងដ៏តូចនោះទេ ដែលលាយតាមចំណូលចិត្តនៃរសជាតិរបស់គាត់ដែលមិនអាចធ្វើឲ្យគាត់ស្រវឹងបាន។ ហើយប្រសិនបើមានការរម្លឹកខួបជាច្រើនអំពីពួកបរិសុទ្ធដែលបានចាកចេញទៅដែលស័ក្តិសមផ្តល់កិត្តិយសក្នុងរបៀបដូចៗគ្នា នោះគាត់នឹងកាន់កូនពែងស្រាតូចនោះដើរជាមួយគាត់ ដែលគាត់បានលាយទឹកយ៉ាងច្រើន ហើយក៏ថែមទាំងមានកំដៅយ៉ាងក្តៅអ៊ុនៗដោយសារកាន់យូរ។ គាត់តែងតែក្រេបបន្តិចៗជាមួយនឹងមិត្តភក្តិរបស់គាត់ដែលគាត់កំពុងតែចំណាយពេលជាមួយគ្នា។ សេចក្តីប្រាថ្នារបស់គាត់គឺដើម្បីបង្ហាញការគោរព មិនមែនស្វែងរកភាពអរសប្បាយនោះទេ។

ប៉ុន្តែ ពេលដែលគាត់ដឹងថា គ្រូអធិប្បាយដ៏ល្បីល្បាញ និងគ្រូគង្វាលដែលកោតខ្លាចព្រះជាម្ចាស់មួយនោះបានហាមមិនឲ្យធ្វើទម្លាប់ទាំងនោះ សូម្បីតែចំពោះអស់អ្នកដែលហូបតែបន្តិចបន្តួច ដើម្បីកុំឲ្យវាក្លាយទៅជាឱកាសសម្រាប់អស់អ្នកដែលផឹករហូតដល់ស្រវឹងជោគខ្លួន នោះគាត់ក៏បានស្ម័គ្រចិត្តក្នុងការបញ្ឈប់ទំនៀមទម្លាប់នេះ ពីព្រោះបុណ្យខួបរម្លឹកទាំងនោះមានលក្ខណៈស្រដៀងគ្នាពេកជាមួយនឹងការប្រារព្ធដែលពេញដោយអបិយជំនឿរបស់សាសនាផ្សេងៗ។ ដូច្នេះ ជាជាងយកកញ្ជើរពេញទៅដោយម្ហូបអាហារ និងគ្រឿងផឹក គាត់បានរៀនយកដួងចិត្តពេញទៅដោយការអធិស្ឋានទៅការរម្លឹកខួបសម្រាប់ពួកមរណសាក្សីទាំងនោះវិញ ដែលនោះគឺជាការដ៏បរិសុទ្ធខ្លាំងជាងអំណោយទានទាំងនេះទៅទៀត។ ហើយក្នុងរបៀបនេះ គាត់ក៏មានសមត្ថភាពក្នុងការកាន់តែជួយអ្នកក្រីក្រថែមទៀតដែរ។

ប៉ុន្តែ ទោះជាយ៉ាងណាក្តី ឱព្រះអង្គដ៏ជាម្ចាស់នៃទូលបង្គំអើយ ចំពោះទូលបង្គំវាហាក់បីដូចជាថា អ្នកម្តាយទូលបង្គំនឹងទំនងជាមិនបដិសេធន៍យ៉ាងងាយស្រួលនូវទម្លាប់មួយនេះ ប្រសិនបើមានគ្រូណាផ្សេងទៀតជាអ្នកហាម ដែលគាត់មិនបានស្រឡាញ់ដូចដែលគាត់ស្រឡាញ់លោកគ្រូគង្វាល អំមប្រូស៍។ ដ្បិតចេញពីការបារម្ភរបស់គាត់សម្រាប់សេចក្តីសង្គ្រោះរបស់ទូលបង្គំ គាត់បានស្រឡាញ់លោកគ្រូគង្វាលនោះយ៉ាងខ្លាំង ហើយលោក

គ្រូគង្វាលនោះក៏បានស្រឡាញ់គាត់យ៉ាងពិតប្រាកដដែរ ពីព្រោះអ្នកម្ដាយទូលបង្គំមានជីវិត និងព្រលឹងវិញ្ញាណដ៏ស្មោះត្រង់។ នៅពេលដែលលោកគ្រូគង្វាល អែមប្រូស៍ ជួបទូលបង្គំ គាត់តែងតែសរសើរអ្នកម្ដាយទូលបង្គំ ដោយបង្ហាញអំណរសាទរដល់ទូលបង្គំថាទូលបង្គំមានអ្នកម្ដាយដ៏ល្អ—ទាំងមិនដឹងថាទូលបង្គំជាកូនបែបម៉េចចំពោះអ្នកម្ដាយផង៖ ទូលបង្គំគឺជាមនុស្សដែលចេះតែសង្ស័យលើចំណុចទាំងអស់នេះ ហើយជឿថាវាមិនអាចទៅរួចទេក្នុងការស្វែងរកផ្លូវនៃជីវិតដ៏ពិតបាន។

៣. ប៉ុន្តែ ទោះបើខួរក្បាលទូលបង្គំមានពេញទៅដោយសំណួរ ហើយទូលបង្គំក៏ប្រាថ្នាចង់រកបានចម្លើយទាក់ទងទៅនឹងមន្ទិលសង្ស័យរបស់ទូលបង្គំក៏ដោយ ក៏ទូលបង្គំមិនបានអធិស្ឋានដោយយកចិត្តទុកដាក់ទៅកាន់ព្រះអង្គឲ្យជួយទូលបង្គំដែរ។ ទូលបង្គំថែមទាំងគិតថាលោកគ្រូគង្វាល អែមប្រូស៍ គឺគ្រាន់តែជាបុរសដែលសប្បាយចិត្តម្នាក់ប៉ុណ្ណោះ យ៉ាងហោចណាស់ចេញពីទស្សនៈនៃលោកីយ៍ ដោយសារមនុស្សសំខាន់ៗជាច្រើនបានផ្ដល់កិត្តិយសយ៉ាងខ្ពង់ខ្ពស់ដល់គាត់។ មានតែភាពនៅលីវរបស់គាត់តែមួយទេដែលចំពោះទូលបង្គំមើលទៅហាក់បីដូចជារបៀបនៃការរស់នៅដែលមិនសប្បាយ។ ប៉ុន្តែមានចំណុចខ្លះៗអំពីគាត់ដែលទូលបង្គំមិនយល់។ ទូលបង្គំមិនយល់អំពីសេចក្ដីសង្ឃឹមដែលគាត់ឲ្យតម្លៃលើ ឬក៏ថាតើគាត់ជំទាស់នឹងការតយុទ្ធអ្វីទាក់ទងនឹងការល្បួងដោយសារឋានៈដ៏ខ្ពស់របស់គាត់។ ទូលបង្គំក៏មិនយល់ថា តើគាត់ទទួលបានការលួងលោមពីទីណានៅពេលដែលគាត់មានការលំបាក ឬក៏ថាតើគាត់មានអំណរបែបដូចម្ដេចដែលកើតចេញពីការផ្គត់ផ្គង់នំបុ័ងរបស់ទ្រង់។

គាត់ក៏មិនដឹងអំពីការអន់ចិត្តរបស់ទូលបង្គំ ឬក៏កាលៈទេសៈដ៏ពេញទៅដោយគ្រោះថ្នាក់ដែលទូលបង្គំកំពុងតែនៅដែរ។ គាត់រវល់ខ្លាំងណាស់ ដោយសារមានមនុស្សម្នាជាច្រើនបានមករកជំនួយពីគាត់ ហេតុដូច្នេះហើយបានជាទូលបង្គំមិនអាចទៅសន្ទនាឲ្យស៊ីជម្រៅជាមួយនឹងគាត់ដូចដែលទូលបង្គំប្រាថ្នា។ ហើយនៅពេលគាត់មិនជួបជាមួយនឹងមនុស្ស—ដែលតាមពិតទៅមិនមានពេលយូរប៉ុន្មានទេ—នោះគាត់ក៏បានសម្រាកដោយសារគាត់ត្រូវការ ដើម្បីបរិភោគអាហារ ឬក៏អានសៀវភៅ។

ហើយពេលដែលគាត់អានដោយស្ងៀមស្ងាត់ ភ្នែករបស់គាត់ក៏មើលលើទំព័រ ហើយចិត្តរបស់គាត់ក៏ស្វែងយល់អត្ថន័យ។ ជាទូទៅ នៅពេលដែលយើងចូលមកក្នុងបន្ទប់

គាត់—ដ្បិតគ្មាននរណាមានការហាមប្រាមមិនឲ្យចូលនោះទេ—នោះយើងនឹងឃើញគាត់អានមកកាន់ខ្លួនឯងដូចនោះ។ បន្ទាប់ពីយើងបានអង្គុយចាំយ៉ាងយូរ ហើយស្ងាត់ស្ងៀម (ដ្បិតតើនរណាហ៊ានរំខានបុគ្គលដែលកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាដូចនោះ?) នោះយើងតែងតែចាកចេញ ដោយទទួលស្គាល់ថា គាត់គ្មានបំណងចង់ឲ្យយើងរំខានគាត់ទេ។ មិនថាគាត់មានហេតុផលអ្វីក៏ដោយទាក់ទងនឹងការអានដោយយកចិត្តទុកដាក់របស់គាត់ គឺគ្មានមន្ទិលសង្ស័យទេត្រង់ថាវាគឺជាហេតុផលដ៏ល្អ។

៤. ប៉ុន្តែ តាមពិតទៅ ទូលបង្គំមិនមានឱកាសក្នុងការសួរនូវសំណួរដែលទូលបង្គំចង់សួរគាត់សោះ លុះត្រាតែវាជារឿងមួយដែលអាចដោះស្រាយបានយ៉ាងរហ័ស។ ជារៀងរាល់ថ្ងៃនៃព្រះអម្ចាស់ ទូលបង្គំបានស្ដាប់គាត់ «កាត់ស្រាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ»[៥] ក្នុងចំណោមមនុស្សដែលស្ដាប់។ ហើយទូលបង្គំក៏កាន់តែជឿជាក់ថា រាល់ចំណងនៃឧបាយកលមួលបង្កាច់ដែលពួកមានិហៀនបានបង្កើតឡើង ដើម្បីបោកបញ្ឆោតទាស់ប្រឆាំងនឹងព្រះគម្ពីរគឺអាចទទួលការដោះស្រាយបាន។

ឆាប់ៗនេះ ទូលបង្គំក៏យល់ប្រយោគថា ព្រះអង្គបានបង្កើតយកមកក្នុងរូបអង្គទ្រង់ ហើយអ្នកដែលដើរតាមព្រះអង្គ—ដែលព្រះអង្គបានបង្កើតជាថ្មីតាមរយៈក្រុមជំនុំ និងព្រះគុណ—មិនបានយល់ប្រយោគនោះទេ ហាក់បីដូចជាថាពួកគេជឿ ហើយក៏ស្រមៃថា ព្រះអង្គគ្រាន់តែមានលក្ខណៈជារូបរាងមនុស្សប៉ុណ្ណោះ។ ហើយទូលបង្គំក៏មានពេញទៅដោយអំណរ និងមុខក្រហមពេញដោយភាពអាម៉ាស់ត្រង់ថា អស់ជាច្រើនឆ្នាំនេះទូលបង្គំបានវាយប្រហារ មិនមែនក្រុមជំនុំពិត ប៉ុន្តែក្រុមជំនុំដែលពួកក្រុមមានិហៀនបានបង្កើតឡើងទេតើ។ ឱព្រះអង្គដ៏ខ្ពង់ខ្ពស់អើយ! ដ្បិតទ្រង់គង់នៅយ៉ាងជិតបង្កើយ យ៉ាងអាថ៌កំបាំង និងពេញទៅដោយព្រះវត្តមាន។ ព្រះអង្គមិនមានអវយវៈនៃរូបរាងកាយនោះទេ ប៉ុន្តែទ្រង់ក៏គង់នៅគ្រប់ទីកន្លែង ហើយក៏គ្មានកន្លែងមួយណាដែលទ្រង់មិនអាចនៅបានដែរ។ ព្រះអង្គបានបង្កើតមនុស្សយើងមកក្នុងរូបអង្គទ្រង់ ហើយមនុស្សយើងរស់នៅក្នុងលំហអាកាសពីក្បាលដល់ចុងជើង។

---

៥ ២ធីម៉ូថេ ២:១៥។

សៀវភៅទី៦

# ១៤

# អំណរដែលមិនពិត

៦. ពេលនោះទូលបង្គំចូលចិត្តសិក្សាកណ្ឌក្រឹត្យវិន័យ និងកណ្ឌពួកហោរាក្នុងព្រះបន្ទូល។ ទូលបង្គំលែងសង្ស័យលើបទគម្ពីរណាទៀតហើយ។ ហើយទូលបង្គំក៏ឈប់គិតថា អ្វីៗដែលទូលបង្គំអានមិនសមហេតុផល ដូចដែលទូលបង្គំបានគិតនៅអតីតកាលទេ។ ដ្បិតទូលបង្គំធ្លាប់មើលងាយពួកបរិសុទ្ធរបស់ព្រះអង្គ ដោយសារទូលបង្គំបានគិតថាពួកគាត់ជឿលើអ្វីដែលមើលទៅគួរឲ្យអស់សំណើច ប៉ុន្តែតាមពិតទៅពួកគាត់ផ្ទាល់មិនជឿដូចដែលទូលបង្គំបានគិតនោះទេ។ ហើយទូលបង្គំក៏ចូលចិត្តស្ដាប់លោកគ្រូគង្វាល អែមប្រូស៍អធិប្បាយទៅកាន់មនុស្សម្នាដែរ។ ហើយទូលបង្គំស្ដាប់នៅពេលដែលគាត់លើកឡើងខគម្ពីរមួយនេះម្ដងហើយម្ដងទៀតថា ជាមូលដ្ឋាននៃគោលការណ៍ចម្បងនៃការកាត់ស្រាយ «អក្សរនាំឲ្យស្លាប់ តែព្រះវិញ្ញាណ ប្រទានឲ្យមានជីវិត»។[១] នៅពេលដែលគាត់អធិប្បាយគាត់តែងតែដកចេញនូវការអាថ៌កំបាំង ហើយក៏បង្ហាញអំពីអត្ថន័យនៃខគម្ពីរនោះខាងឯព្រលឹងវិញ្ញាណ គឺជាខគម្ពីរដែលហាក់បីដូចជាសេចក្ដីបង្រៀនចចេសបើយើងយល់អត្ថន័យចំៗ។ គ្មានអ្វីក្នុងសេចក្ដីបង្រៀនរបស់គាត់ដែលធ្វើឲ្យទូលបង្គំអន់ចិត្តនោះទេ ទោះ

១ ២កូរិនថូស ៣:៦។

បើទូលបង្គំមិនបានដឹងយ៉ាងពិតប្រាកដនៅឡើយថា អ្វីៗដែលគាត់កំពុងតែបង្រៀនជាការពិត ឬក៏មិនពិតក៏ដោយ។ ដូច្នេះ ទូលបង្គំក៏មិនបាននិយាយថាទូលបង្គំឯកភាពជាមួយនឹងអ្វីដែលគាត់បានបង្រៀនដែរ ដោយខ្លាចថាខ្លួននឹងធ្លាក់ក្នុងសេចក្តីបង្រៀនខុសឆ្គងជាថ្មីម្តងទៀត។

ប៉ុន្តែ ទូលបង្គំកំពុងតែទទួលការច្របាច់កចង់ស្លាប់តាមរយៈការមិនដឹងយ៉ាងពិតប្រាកដ។ ដ្បិតទូលបង្គំចង់ដឹងយ៉ាងប្រាកដអំពីអ្វីៗដែលមើលមិនឃើញ ដូចដែលទូលបង្គំដឹងថាទូលបង្គំដឹងថា ៧ + ៣ = ១០។ ទូលបង្គំមិនមានការវង្វេងវង្វាន់ ដូចជាការជឿថាទូលបង្គំមិនអាចយល់គណិតវិជ្ជាដ៏សាមញ្ញបានទេ ប៉ុន្តែសេចក្តីប្រាថ្នារបស់ទូលបង្គំគឺចង់ឲ្យយល់គ្រប់អ្វីៗដូចជាគណិតវិជ្ជាដែរ ទោះបើថាវាជាវត្ថុខាងឯសាច់ឈាមក៏ដោយ សូម្បីតែវាមិននៅមុខទូលបង្គំក៏ដោយ ឬក៏ជាវត្ថុខាងឯព្រលឹងវិញ្ញាណ ដែលទូលបង្គំមិនដឹងអំពីរបៀបនៃការយល់លក្ខណៈរបស់វា លើកលែងតែតាមលក្ខណៈបែបជាខាងឯសាច់ឈាម។

ពេលនោះប្រសិនបើទូលបង្គំអាចទទួលជឿបាន នោះទូលបង្គំនឹងទំនងជាទទួលបានការព្យាបាល ហើយនៅមានការបន្សុទ្ធខាងឯវិញ្ញាណរបស់ទូលបង្គំ នោះក្នុងរបៀបមួយចំនួនវាក៏ទំនងជានាំទូលបង្គំទៅកាន់សេចក្តីពិតរបស់ព្រះអង្គ ដែលគង់នៅជានិច្ច ហើយមិនចេះបរាជ័យផងដែរ។ ប៉ុន្តែ ដូចបុរសម្នាក់ដែលធ្លាប់បានទទួលបទពិសោធន៍ពីគ្រូពេទ្យមិនល្អម្នាក់ នោះគាត់ក៏នឹងមានការភ័យខ្លាចក្នុងការទុកចិត្តគ្រូពេទ្យដ៏ល្អផ្សេងៗទៀត វាក៏ដូចនោះដែរទាក់ទងទៅនឹងសុខភាពខាងឯព្រលឹងវិញ្ញាណរបស់ទូលបង្គំដែលនឹងមិនអាចទទួលបានការព្យាបាល លុះត្រាតែតាមរយៈការជឿ។ ប៉ុន្តែ ដោយសារទូលបង្គំខ្លាចធ្លាក់ចូលទៅក្នុងការជឿសេចក្តីខុសឆ្គងជាថ្មីម្តងទៀត នោះវាក៏បដិសេធន៍ក្នុងការទទួលការព្យាបាល ហើយក៏បដិសេធន៍ព្រះហស្តរបស់ទ្រង់ដែរ។

៧. ទោះជាយ៉ាងណាក្តី ចាប់ពីពេលនោះទៅមុខ ក៏ទូលបង្គំចាប់ផ្តើមចូលចិត្តសេចក្តីបង្រៀនរបស់គ្រីស្ទបរិស័ទដែរ។ ទូលបង្គំមានអារម្មណ៍ថា ពួកគេចេះដាក់ខ្លួន ហើយស្មោះត្រង់ខ្លាំងជាងពួកក្រុមមានិហ្កៀន។ ដ្បិតទោះបើថា គ្រីស្ទបរិស័ទបង្គាប់ឲ្យជឿលើចំណុចមួយចំនួនដែលពួកគាត់មិនអាចផ្តល់ជាភស្តុតាងបាន នេះគឺគ្រាន់តែដោយសារពួកគាត់អាចផ្តល់ជាភស្តុតាងបាន ប៉ុន្តែមិនមែនថាមនុស្សគ្រប់រូបអាចយល់បានទេ ឬក៏ដោយសារ

តាមពិតទៅមិនមានភស្តុតាងដែលអាចមើលឃើញបាន ដើម្បីយកមកចង្អុលបង្ហាញ។ នេះគឺជារបៀបដ៏ល្អប្រសើរខ្លាំងជាងពួកក្រុមមានិហ្គៀនទៅទៀត ដែលពួកគាត់សើចចំអកលើជំនឿដ៏សាមញ្ញរបស់សមាជិកថ្មី សន្សំភ្លាមៗអំពីចំណេះដឹងដែលពួកគាត់គ្រាន់តែបង្ខំឲ្យពួកគេជឿលើរឿងព្រេង និងមិនសមហេតុសមផល ពីព្រោះមូលហេតុដ៏ចម្បងនោះគឺថា៖ ពួកគាត់មិនមានសមត្ថភាពក្នុងការផ្ដល់ជាភស្តុតាងឡើយ។ បន្ទាប់ពីនោះ ឱព្រះអម្ចាស់អើយ! ដោយអមជាមួយនឹងព្រះហស្តដ៏ថ្នមៗ ដែលពេញទៅដោយសេចក្ដីមេត្តាករុណារបស់ទ្រង់ ដែលកំពុងទាញ និងធ្វើឲ្យចិត្តទូលបង្គំនៅស្ងៀម នោះព្រះអង្គក៏ចាប់ផ្ដើមយកឈ្នះលើទូលបង្គំបន្តិចម្ដងៗហើយ។ ដ្បិតទូលបង្គំបានគិតអំពីចំណុចជាច្រើនដែលទូលបង្គំទទួលជឿដោយមិនបានឃើញ ដែលមានដូចជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រខាងឯលោកីយ៍ និងទីកន្លែង និងទីក្រុងដែលទូលបង្គំមិនដែលធ្លាប់ឃើញ នោះទូលបង្គំនឹងឃើញថា មានចំណុចជាច្រើនដែលទូលបង្គំទទួលជឿដោយរំពឹងតែលើសម្ដីរបស់មិត្តភក្តិទូលបង្គំ ឬក៏គ្រូពេទ្យ ឬក៏បុគ្គលណាម្នាក់ក៏ថាបាន។ ហើយយើងត្រូវតែជឿដោយរំពឹងលើពាក្យពេចន៍របស់អ្នកដទៃ បើមិនដូច្នោះទេ នោះយើងក៏នឹងមិនអាចសម្រេចអ្វីបានក្នុងជីវិតនេះបានឡើយ។ ជាចុងក្រោយ ទូលបង្គំក៏មានការភ្ញាក់ផ្អើលអំពីចំណុចដែលទូលបង្គំជឿជាក់ថា ឪពុកម្ដាយរបស់ទូលបង្គំគឺពិតជាឪពុកម្ដាយរបស់ទូលបង្គំមែន ទោះបើទូលបង្គំគ្រាន់តែដឹងអំពីចំណុចនេះដោយរំពឹងលើពាក្យពេចន៍របស់អ្នកដទៃក៏ដោយ។ តាមរយៈការគិតអំពីចំណុចនេះ នោះព្រះអង្គក៏បានយកឈ្នះលើទូលបង្គំត្រង់ថា ទូលបង្គំមិនគួររកចំណុចខុសឆ្គងជាមួយនឹងអស់អ្នកដែលជឿលើព្រះបន្ទូលរបស់ទ្រង់ឡើយ—ដែលព្រះអង្គបានបង្កើតស្ទើរតែគ្រប់ជាតិសាសន៍ដែលមានអំណាចយ៉ាងអស្ចារ្យ—ប៉ុន្តែទូលបង្គំគួរតែចាប់ចំណុចខុសឆ្គងលើអស់អ្នកដែលមិនជឿលើព្រះបន្ទូលរបស់ទ្រង់វិញ។ លើសពីនោះទៅទៀត ព្រះអង្គក៏បានយកឈ្នះលើទូលបង្គំត្រង់ថា ទូលបង្គំមិនគួរផ្ដោតអារម្មណ៍លើមនុស្សទាំងនោះដែលសួរទូលបង្គំថា៖ «តើឯងដឹងដោយរបៀបណាថា ព្រះបន្ទូលទាំងនេះត្រូវបានឲ្យមកមនុស្សលោកតាមរយៈព្រលឹងវិញ្ញាណនៃព្រះដ៏ពិតតែមួយ?»។ ដ្បិតនេះគឺជាចំណុចដ៏សំខាន់បំផុតក្នុងការជឿ ដោយសារគ្មានការវាយប្រហារជាសំណួរដែលជេរប្រមាថដូចនេះដែលទូលបង្គំបានអាននៅក្នុងសៀវភៅដែលប្រឆាំងនឹងខ្លួនឯង ហើយចេញមកដោយពួកទស្សនៈវិទូ ពោលគឺវាមិនអាចដកទូលបង្គំចេញពីការជឿថា ព្រះអង្គ

ពិតជាមានព្រះជន្មមែន ហើយថាព្រះអង្គក៏កំពុងតែសោយរាជ្យលើមនុស្សលោកផងដែរ។

៨. ទូលបង្គំជឿប៉ុណ្ណឹង ទោះបើពេលខ្លះតិចជាងនោះ ឬក៏ច្រើនជាងហ្នឹង។ ប៉ុន្តែទូលបង្គំតែងតែជឿលើចំណុចទាំងពីរនេះគឺថា៖ ពិតជាមានព្រះមែន ហើយព្រះអង្គយកព្រះហឫទ័យទុកដាក់ជាមួយនឹងយើងដែរ[២] ទោះបើទូលបង្គំមិនដឹងថា គួរគិតយ៉ាងម៉េចអំពីសារធាតុផ្សំរបស់ទ្រង់ និងថាតើផ្លូវមួយណានាំទៅ (ឬក៏នាំត្រឡប់ទៅ) ព្រះអង្គវិញក៏ដោយ។ ពីព្រោះយើងខ្សោយពេកណាស់ក្នុងការស្វែងរកសេចក្តីពិតដោយរំពឹងតែលើតក្កវិជ្ជា ពោលគឺយើងត្រូវការអំណាចនៃព្រះគម្ពីរបរិសុទ្ធ ហើយនៅពេលនោះទូលបង្គំក៏ចាប់ផ្តើមជឿថា ព្រះអង្គនឹងមិន (មិនថាក្នុងកាលៈទេសៈណាក៏ដោយ) ប្រទានអំណាចដ៏ខ្ពង់ខ្ពស់ទៅកាន់ព្រះបន្ទូលនោះទេ លុះត្រាតែព្រះអង្គសព្វព្រះហឫទ័យឲ្យយើងស្គាល់ព្រះអង្គដោយជំនឿតាមរយៈព្រះបន្ទូល គឺឲ្យតាមរយៈព្រះបន្ទូលនោះឯង។ ដ្បិតទាក់ទងទៅនឹងបទគម្ពីរទាំងនោះនៅក្នុងព្រះគម្ពីរ ដែលពេលនោះហាក់បីដូចជាមិនមានភាពស៊ីគ្នា ហើយធ្វើឲ្យទូលបង្គំអន់ចិត្ត ឥឡូវនេះដោយសារទូលបង្គំបានឮគេពន្យល់ពីរបីដងដែលមានហេតុផល នោះទូលបង្គំក៏ឃើញថា យើងអាចរកដំណោះស្រាយសម្រាប់វាបានតាមរយៈការកាត់ស្រាយខាងឯព្រលឹងវិញ្ញាណប៉ុណ្ណោះ។ ចំពោះទូលបង្គំ អំណាចនៃព្រះបន្ទូលហាក់បីដូចជាកាន់តែមានភាពឧត្តម ហើយស័ក្តិសមសម្រាប់ជំនឿដែលមិនអាចរង្គើបាន ទោះបើគ្រប់គ្នាអាចអានបានក៏ដោយ ក៏វានៅតែបន្សល់ទុកភាពឧត្តុង្គឧត្តមដ៏ពេញទីនៃប្រាជ្ញាដ៏អាថ៌កំបាំងក្នុងការយល់ដឹងដ៏ជ្រាលជ្រៅខាងឯព្រលឹងវិញ្ញាណដែរ។ ទោះបើភាសា និងរបៀបសរសេរមានភាពសាមញ្ញក៏ដោយ វាក៏ទាមទារឲ្យមានការផ្ចង់ចិត្តយ៉ាងខ្លាំងសូម្បីតែចេញពីអស់អ្នកដែលមានគំនិតដោយម៉ត់ចត់បំផុតដែរ។ នេះដើម្បីទំនងជាការនាំផ្លូវក្នុងបរិបទដ៏តូចៗនោះទៅកាន់ព្រះអង្គ តែទោះជាយ៉ាងណាក្តីក៏គួរមានករណីជាច្រើនទៀតដែលប្រសិនបើមិនមានអំណាចដ៏អួតអាង ដែលបានដាក់អន្ទាក់លើមនុស្សជាច្រើនតាមរយៈការបន្ទាបខ្លួនដ៏បរិសុទ្ធរបស់វា។ ទូលបង្គំបន្តឆ្លុះបញ្ចាំងលើចំណុចទាំងអស់នោះ ហើយព្រះអង្គក៏បានគង់ជាមួយនឹងទូលបង្គំផងក៏ដោយ។ ទូលបង្គំបានដកដង្ហើមធំៗ ហើយព្រះអង្គក៏បានព្រះសណ្តាប់ឮទូលបង្គំដែរ។ ទូលបង្គំបានរារែក ហើយទ្រង់ក៏បានដឹកនាំផ្លូវទូលបង្គំ។ ទូលបង្គំបានធ្វើដំណើរដោយគ្មានទិសដៅលើផែន

២ ហេព្រើរ ១១:៦

ដីនេះ ហើយព្រះអង្គក៏មិនបានបោះបង់ទូលបង្គំចោលដែរ។

៩. ពេលនោះទូលបង្គំនៅចង់ទទួលបានកិត្តិយស លុយកាក់ និងជីវិតអាពាហ៍ពិពាហ៍ ហើយទ្រង់ក៏បានសើចចំអកដាក់ទូលបង្គំ។ ក្នុងការសង្វាតដេញតាមសេចក្ដីប៉ងប្រាថ្នាទាំងអស់នោះ ទូលបង្គំក៏បានប្រឈមមុខនឹងការលំបាកដ៏ជូរចត់ ដែលតាមរយៈការទាំងនោះ គឺព្រះអង្គបង្ហាញព្រះគុណរបស់ទ្រង់ក្នុងការមិនអនុញ្ញាតឲ្យទូលបង្គំពេញចិត្តនឹងអ្វីក្រៅពីទ្រង់។ ឱព្រះអម្ចាស់អើយ! សូមទតមើលដួងចិត្តទូលបង្គំ ដ្បិតទ្រង់បានជំរុញឲ្យទូលបង្គំនឹកគិតអំពីចំណុចទាំងនេះ ហើយលន់តួទៅកាន់ទ្រង់។ ឥឡូវនេះ សូមអនុញ្ញាតឲ្យព្រលឹងទូលបង្គំតោងទ្រង់ ពីព្រោះទ្រង់បានរំដោះទូលបង្គំចេញពីជ័រដ៏ជាប់ស្អិតជិតនឹងស្លាប់។

ទូលបង្គំពិតជាវេទនាមែននៅពេលនោះ! ហើយព្រះអង្គបានឆ្កឹះឆ្កៀលរបួសដ៏ឈឺចាប់នៃព្រលឹងរបស់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចបោះបង់គ្រប់អ្វីៗទាំងអស់ចោល ហើយត្រឡប់ទៅរកទ្រង់វិញ—ព្រះអង្គគង់នៅលើគ្រប់អ្វីៗទាំងអស់ ហើយបើគ្មានទ្រង់ នោះគ្រប់អ្វីៗទាំងអស់ក៏នឹងមិនអាចមានបានដែរ—ដើម្បីឲ្យទូលបង្គំអាចនឹងបំផ្លាស់បំប្រែ ហើយទទួលបានការព្យាបាល។ ពេលនោះ ទូលបង្គំពិតជាវេទនាមែន ហើយព្រះអង្គបានដាក់ពិន័យទូលបង្គំ ដើម្បីឲ្យទូលបង្គំដឹងអំពីភាពវេទនារបស់ខ្លួនបាន។ ទូលបង្គំចាំអំពីរឿងនៃថ្ងៃដែលទូលបង្គំកំពុងរៀបចំធ្វើសេចក្ដីថ្លែងអំពីមហារាជ។ ក្នុងការថ្លែងនោះ ទូលបង្គំត្រូវលើកឡើងអំពីការកុហកជាច្រើន ហើយអស់អ្នកដែលដឹងថា ទូលបង្គំកំពុងតែកុហកក៏ត្រូវតែអបអរសាទរជាមួយនឹងការកុហកនោះ។ ចិត្តទូលបង្គំក៏មានការបារម្ភ និងមិនស្រួលព្រោះមានអារម្មណ៍ពិរុទ្ធភាព។ ដ្បិតកាលទូលបង្គំកំពុងដើរលើផ្លូវមួយនៅទីក្រុងមីឡាន ទូលបង្គំក៏បានឃើញអ្នកសុំទានដ៏ក្រខ្សត់ម្នាក់ដែលកំពុងរីករាយ ហើយសើចសប្បាយ (តែទូលបង្គំជឿថាគាត់បានឆ្អែតពេញពោះហើយ)។ ទូលបង្គំក៏បានដកដង្ហើមធំៗ ហើយនិយាយទៅកាន់មិត្តភក្ដិនៅជុំវិញទូលបង្គំអំពីទុក្ខកង្វល់ជាច្រើនដែលកើតចេញពីភាពលីលារបស់ពួកយើង ពីព្រោះមិនថាយើងខិតខំប្រឹងប្រែងខ្លាំងប៉ុណ្ណាក៏ដោយ ក៏យើងនៅតែមានចិត្តប្រាថ្នាចង់បាននូវសេចក្ដីអរសប្បាយដែលអ្នកសុំទានម្នាក់នោះបានឈានទៅដល់នៅមុខយើងដដែល។ តែក៏នៅមានការធ្វើឲ្យព្រួយបារម្ភត្រង់ថា យើងទំនងនឹងមិនអាចទទួលវាបាន។ ដ្បិតអ្វីដែលគាត់ទទួលបានតាមរយៈលុយតិចតួចនោះ ដែលគាត់ទទួលបានតាមរយៈការសុំទាននោះ ទូលបង្គំកំពុងរៀបចំផែនការតាមរយៈការវេទនា

និងការធ្វើការដ៏ស្មុគស្មាញជាច្រើន—និយាយឲ្យចំទៅគឺអំណរនៃការអរសប្បាយដែលកំពុងកន្លងផុតទៅ។ ពិតណាស់! គាត់មិនបានទទួលអំណរដ៏ពិតទេ ប៉ុន្តែស្របពេលនោះដែរ អមគ្នាជាមួយនឹងសេចក្តីប៉ងប្រាថ្នាទាំងអស់របស់ទូលបង្គំ គឺទូលបង្គំកំពុងតែស្វែងរកអំណរដែលកាន់តែមិនពិតជាងគាត់ទៅទៀត។ ទោះជាយ៉ាងណាក្តី គាត់កំពុងតែមានអំណរ ហើយទូលបង្គំមានទុក្ខព្រួយ។ គាត់មិនមានការព្រួយបារម្ភ ហើយទូលបង្គំមានការថប់ចិត្តបារម្ភជាច្រើន។ ពេលនោះ ប្រសិនបើមានបុគ្គលណាម្នាក់មកសួរបង្គំថា តើទូលបង្គំចង់សប្បាយចិត្ត ឬក៏ព្រួយបារម្ភ នោះទូលបង្គំនឹងឆ្លើយថា «សប្បាយចិត្ត»។ ជាថ្មីម្តងទៀត ប្រសិនបើមានបុគ្គលណាម្នាក់បានសួរទូលបង្គំថា តើទូលបង្គំចង់មានលក្ខណៈដូចជាអ្នកសុំទាន ឬក៏មានលក្ខណៈដូចដែលទូលបង្គំកំពុងតែមាននៅពេលនេះ នោះទូលបង្គំនឹងជ្រើសរើសថា មានលក្ខណៈដូចដែលទូលបង្គំបានមានជាមិនខាន ទោះបីទូលបង្គំមានពេញទៅដោយទុក្ខកង្វល់ និងទុក្ខព្រួយក៏ដោយ។ ប៉ុន្តែ តើនេះមិនមែនជាការជ្រើសរើសដែលមិនពិតមែនឬ? តើយើងអាចប្រៀបធៀបជីវិតទាំងពីរនេះបានទេ? តាមពិតទៅ ទូលបង្គំមិនគួរជ្រើសរើសយកខ្លួនឯងលើការជ្រើសរើសគាត់ដោយព្រោះទូលបង្គំបានរៀនសូត្រច្រើនជាងគាត់នោះទេ ដ្បិតទូលបង្គំមិនបានទទួលបានការដ៏អស្ចារ្យចេញពីការរៀនសូត្ររបស់ទូលបង្គំឡើយ។ ប៉ុន្តែ ផ្ទុយពីនោះ ទូលបង្គំបែរជាស្វែងរករបៀបនៃការបង្ហាញជំនាញរបស់ទូលបង្គំ ដើម្បីធ្វើឲ្យអ្នកដទៃសប្បាយចិត្តទៅវិញ—ហើយនេះមិនមែនជាការបង្រៀនដល់អ្នកដទៃនោះទេ ប៉ុន្តែគឺគ្រាន់តែធ្វើឲ្យពួកគាត់សប្បាយចិត្តតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយបានជាព្រះអង្គបំបាក់ឆ្អឹងរបស់ទូលបង្គំដោយព្រនង់នៃការណែនាំរបស់ទ្រង់។

១០. យើងត្រូវតែមានការប្រុងប្រយ័ត្នជាមួយនឹងអស់អ្នកដែលនឹងនិយាយថា៖ «អ្វីដែលពិតជាសំខាន់នោះគឺមូលហេតុដែលធ្វើឲ្យបុគ្គលនោះអរសប្បាយ។ អ្នកសុំទានមានអំណរក្នុងភាពស្រវឹងរបស់គាត់ ហើយរីឯអ្នកវិញ អ្នកចង់មានអំណរក្នុងសិរីល្អ។» ឱព្រះអម្ចាស់អើយ! សិរីល្អអ្វីទៅ? សិរីល្អប្រភេទមិនមាននៅក្នុងព្រះអង្គ ដ្បិតដូចដែលអ្នកសុំទានដែលស្រវឹងមិនមានអំណរដ៏ពិត នោះទូលបង្គំក៏មិនមានសិរីល្អដ៏ពិតដែរ។ គាត់នឹងស្វាងពីភាពស្រវឹងរបស់គាត់នៅយប់នោះ ប៉ុន្តែទូលបង្គំបានដេកជាច្រើនយប់ហើយភ្ញាក់ឡើងវិញជាមួយវាដដែល ហើយទូលបង្គំនឹងដេកជាមួយវា ហើយភ្ញាក់ឡើង

វិញជាមួយវាម្តងទៀត ទូលបង្គំមិនដឹងថានឹងត្រូវមានប៉ុន្មានដងទៀតទេ។ វាពិតជាមានភាពខុសគ្នាមែនត្រង់ថា បុគ្គលណាម្នាក់ទទួលបានអំណររបស់គាត់ដោយរំពឹងលើវត្ថុដែលគាត់កំពុងរំពឹងលើ។ ទូលបង្គំដឹងថានេះគឺជាការពិត ហើយទូលបង្គំក៏ដឹងផងដែរថា អំណរនៃសេចក្តីសង្ឃឹមដ៏ស្មោះត្រង់គឺមិនអាចប្រៀបជាមួយបាន ហួសទៅនឹងអំនួតបែបនេះនោះទេ។ ទោះជាយ៉ាងណាក្តី ស្របពេលនោះដែរ អ្នកសុំទានម្នាក់នោះគឺលើសជាងទូលបង្គំហើយ ដ្បិតគាត់ពិតជាបុរសដែលកំពុងតែសប្បាយចិត្តមែន—មិនមែនគ្រាន់តែដោយសារមកពីគាត់កំពុងតែជាប់ក្នុងភាពដ៏សប្បាយរបស់គាត់ ខណៈពេលដែលទូលបង្គំកំពុងតែរហែកខ្ទេចខ្ទីជាមួយនឹងការយកចិត្តទុកដាក់នោះទេ ប៉ុន្តែគឺដោយសារគាត់បានទទួលទានស្រា ហើយក៏កំពុងតែជូនពរដល់អស់អ្នកដែលកំពុងដើរកាត់គាត់ ខណៈពេលដែលទូលបង្គំកំពុងតែដើរតាមសេចក្តីប៉ងប្រាថ្នានៃអំនួតតាមរយៈការកុហករបស់ទូលបង្គំ។ ដោយទទួលបានឥទ្ធិពលបែបនេះ នោះទូលបង្គំក៏បាននិយាយទៅកាន់មិត្តភក្តិទូលបង្គំ ហើយភ្លាមនោះទូលបង្គំក៏ឃើញអំពីរបៀបដែលពួកគាត់ឆ្លើយតប ពោលគឺឆ្លើយតបស្ទើរតែដូចទូលបង្គំទាំងស្រុង។ ហើយទូលបង្គំក៏ឃើញថា ស្ថានភាពរបស់ទូលបង្គំគឺមិនអាចទទួលយកបានទេ។ ទូលបង្គំក៏បារម្ភ ហើយក៏ធ្វើឲ្យទុក្ខកង្វល់របស់ទូលបង្គំក្លាយជាទ្វេដង។ ហើយបើមានភាពចម្រុងចម្រើនណាមួយកាត់ផ្លូវទូលបង្គំ នោះទូលបង្គំមានការស្អប់ក្នុងការចាប់យកវា ដ្បិតស្ទើរតែរាល់ពេលមុនទូលបង្គំអាចចាប់វាបាន នោះវាតែងតែហោះបាត់ទៅ។

១៨. ហើយជាពិសេសទូលបង្គំឆ្ងល់ ពេលទូលបង្គំចងចាំអំពីពេលវេលាដែលបានកន្លងផុតជាច្រើនឆ្នាំហើយកាលពីទូលបង្គំមានអាយុ១៩ឆ្នាំ ដែលពេលនោះគឺជាគ្រាដំបូងដែលទូលបង្គំបានលង់ស្នេហ៍ក្នុងប្រាជ្ញា ហើយក៏បានប្តេជ្ញាចិត្តថា ពេលដែលទូលបង្គំអាចធ្វើបាន នោះទូលបង្គំនឹងស្វែងរកប្រាជ្ញា ហើយនឹងបោះបង់រាល់ក្តីសង្ឃឹមដែលគ្មានប្រយោជន៍ទាំងអស់ចោល និងទស្សនៈខុសឆ្គងឆ្កួតនៃសេចក្តីប៉ងប្រាថ្នាដ៏អត់ប្រយោជន៍។ កាលនោះ ទូលបង្គំជិតមានអាយុ៣០ឆ្នាំ ហើយនៅតែបន្តជាប់យ៉ាងខ្លាំងក្នុងភក់ដដែល នៅតែបន្តលោភលន់ក្នុងការអរសប្បាយជាមួយនឹងអ្វីដែលជាទ្រព្យសម្បត្តិបណ្តោះអាសន្ននៅបច្ចុប្បន្នកាលនោះ ដែលវាតែងតែហោះចេញទៅ ហើយធ្វើឲ្យស្មារតីទូលបង្គំមិននឹងនរ។ ហើយទូលបង្គំនៅបន្តតែនិយាយថា “ថ្ងៃស្អែកទូលបង្គំនឹងរកវាបាន

ហើយ។ វានឹងក្លាយជារឿងសាមញ្ញ ហើយទូលបង្គំនឹងឃើញវា។ លោក ហ្វីស្ទីស៍ នឹងមក ហើយពន្យល់គ្រប់ចំណុច។» ឬក៏ទូលបង្គំនឹងនិយាយថា៖ «ឱអ្នកប្រាជ្ញដែលជំនាញក្នុងមុខវិជ្ជាសិក្សាអើយ! តើមិនមានភាពប្រាកដប្រជាដែលមនុស្សអាចចាប់បានយកមកធ្វើជាការនាំផ្លូវក្នុងជីវិតរបស់គាត់មែនឬ? ទេ! សូមអនុញ្ញាតឲ្យយើងបន្តស្វែងរកដោយយកចិត្តទុកដាក់ថែមទៀត ហើយសូមអនុញ្ញាតកុំឲ្យយើងអស់សង្ឃឹមឡើយ។ មើល៍! ចំណុចនៅក្នុងសៀវភៅនានានៃព្រះវិហារដែលពីមុនហាក់បីដូចជាមិនសមហេតុសមផលចំពោះយើង ឥឡូវនេះមិនមែនជាបញ្ហាទៀតទេ ពីព្រោះបើមិនដូច្នោះទេនោះវានឹងមិនសមហេតុសមផល ប្រសិនបើយើងមិនកាត់ស្រាយដោយស្មោះត្រង់។ ខ្លួននឹងដាក់ជើងលើជណ្ដើរ កាលដែលទូលបង្គំនៅជាកុមារឪពុកម្ដាយទូលបង្គំបានដាក់ទូលបង្គំលើទាល់តែទូលបង្គំយល់សេចក្ដីពិតយ៉ាងច្បាស់លាស់ដែលខ្លួនកំពុងតែស្វែងរក។ ប៉ុន្តែ តើនៅទីណា និងនៅពេលណាដែលខ្លួននឹងអាចរកវាបាន? លោកគ្រូគង្វាល អែមប្រូស៍ មិនមានពេលវេលាទំនេរទេ—យើងក៏មិនមានពេលវេលាទំនេរ ដើម្បីអានសៀវភៅដែរ។ តើឲ្យយើងទៅរកសៀវភៅនៅឯណា? តើនៅកន្លែងណា ឬក៏ឲ្យខ្លួនទៅរកវាបានដោយរបៀបណា? ឲ្យខ្លួនទៅខ្ចីវាពីនរណា? សូមអនុញ្ញាតឲ្យខ្លួនដាក់កាលវិភាគក្នុងថ្ងៃរបស់ខ្លួន ហើយញែកម៉ោងណាមួយសម្រាប់សុខភាពខាងឯព្រលឹងវិញ្ញាណ។ សេចក្ដីសង្ឃឹមដ៏អស្ចារ្យបានលេចឡើងនៅក្នុងយើង ពីព្រោះជំនឿខាងឯគ្រីស្ទសាសនាមិនបង្រៀននូវអ្វីដែលយើងគិតថាវាបង្រៀននោះទេ ហើយយើងក៏មិនអាចប្រកាន់វាដោយមានជោគជ័យបានដែរ។ គ្រូបង្រៀនប្រកាន់ខ្ជាប់លើចំណុចជំរុញត្រង់ជំនឿថា ព្រះជាម្ចាស់មានព្រំដែនតាមរយៈរូបរាងនៃរូបកាយរបស់មនុស្សយើង។ ហើយថាខ្លួនគួរសង្ស័យដោយ "គោះ" ដើម្បីឲ្យរាល់គ្រប់អ្វីៗទាំងអស់ "បើកបង្ហាញ" មកកាន់ខ្លួនមែនឬ? ពេលព្រឹកខ្លួនចំណាយពេលនោះជាមួយនឹងពួកសិស្សរបស់ខ្លួន តើឲ្យខ្លួនគួរចំណាយពេលវេលានៅសល់ដោយរបៀបណា? ហេតុអ្វីមិនធ្វើការនេះ? ប៉ុន្តែ ក្រៅពីនោះ តើឲ្យខ្លួនទៅលេងសិស្សដែលមានឥទ្ធិពលរបស់ខ្លួននៅពេលណា ដែលខ្លួនត្រូវការឲ្យគាត់ចូលចិត្តខ្លួន? តើឲ្យខ្លួនរៀបចំមេរៀនដែលខ្លួនលក់ក្នុងថ្នាក់រៀននៅពេលណា? តើឲ្យខ្លួនទៅដើរលេងដើម្បីសម្រាកខួរក្បាលពីការងារដ៏ស្មុគស្មាញនៅពេលណា?»

២០. ខណៈពេលដែលទូលបង្គំកំពុងនិយាយអំពីចំណុចទាំងនោះ ខ្យល់នៃយោបល់

នានាក៏បានបុកពីនេះទៅនោះលើដួងចិត្តរបស់ទូលបង្គំដោយផាត់ចុះផាត់ឡើង។ ពេលវេលាកំពុងតែរត់គេចចេញ។ ទូលបង្គំក៏ពន្យារពេលនៃការកែប្រែចិត្តទទួលជឿទៅលើព្រះអម្ចាស់។ ទូលបង្គំបានពន្យារពេលក្នុងការមានជីវិតក្នុងព្រះអង្គពីមួយថ្ងៃហើយទៅមួយថ្ងៃទៀត ប៉ុន្តែទូលបង្គំមិនអាចពន្យារពេលនៃការស្លាប់ជារៀងរាល់ថ្ងៃក្នុងខ្លួនឯងទៀតបានឡើយ។ ទូលបង្គំប្រាថ្នាចង់មានជីវិតដ៏អរសប្បាយ ប៉ុន្តែទូលបង្គំនៅភ័យខ្លាចក្នុងការស្វែងរកវាក្នុងកន្លែងស្នាក់នៅរបស់វាផ្ទាល់ ហេតុដូច្នេះហើយបានជាទូលបង្គំបានរត់គេចចេញពីវា ខណៈពេលដែលទូលបង្គំកំពុងតែស្វែងរកវា។ ទូលបង្គំបានគិតថាទូលបង្គំនឹងទំនងជាវេទនាហើយ ប្រសិនបើទូលបង្គំមិនទទួលបានការឱបក្រសោបដ៏ស្និទ្ធស្នាលពីមនុស្សស្រី ហើយទូលបង្គំមិនដែលគិតអំពីថ្នាំនៃសេចក្តីមេត្តាករុណារបស់ទូលបង្គំដែលទ្រង់បានប្រទានមកសម្រាប់ជាការព្យាបាលជំងឺមួយនេះឡើយ ដ្បិតទូលបង្គំមិនដែលសាកល្បងទេ។ ទាក់ទងនឹងភាពបរិសុទ្ធខាងផ្លូវភេទ ទូលបង្គំគិតថា វាអាស្រ័យទៅលើកម្លាំងរបស់បុគ្គលផ្ទាល់ ទោះបើទូលបង្គំមិនបានរកឃើញកម្លាំងណាស្អីនៅក្នុងខ្លួនឯងក៏ដោយ ដ្បិតក្នុងភាពល្ងីល្ងើរបស់ទូលបង្គំ ទូលបង្គំមិនដឹងអំពីអ្វីដែលសរសេរចុះ «បើព្រះជាម្ចាស់មិនប្រោសប្រទានទេនោះ ខ្ញុំពុំអាចទទួលព្រះប្រាជ្ញាញាណបានឡើយ»[៣] ប្រាកដណាស់! ព្រះអង្គទំនងជាប្រទានឲ្យ ប្រសិនបើទូលបង្គំបានទូលសូមពីព្រះអង្គដោយសំឡេងថ្ងូរចេញពីដួងចិត្ត ហើយប្រសិនបើទូលបង្គំបានផ្ទេរភាពខ្វល់ខ្វាយរបស់ទូលបង្គំទៅកាន់ព្រះអង្គដោយមានជំនឿយ៉ាងរឹងមាំ។

៣ ព្រះប្រាជ្ញាញាណ ៨:២១។ ខណៈពេលដែលលោកគ្រូ អហ្គស្ទីន បានហៅទុតិយកណ្ឌមួយចំនួនថាជាព្រះគម្ពីរ ក៏មើលទៅគាត់មិនដែលជឿថា កណ្ឌដែលគេបានរាប់ចូលជាព្រះគម្ពីរមានអំណាចស្មើគ្នាទេ ប៉ុន្តែផ្ទុយទៅវិញគឺថា ក្នុងចំណោមកណ្ឌទាំងនោះមានកម្រិតនៃអំណាចខុសៗគ្នា។ កណ្ឌដែលគេបានទទួលស្គាល់ជាទូទៅថាជាព្រះបន្ទូលដែលមានអំណាច និងកណ្ឌដែលមិនមាន។ ក្នុងក្រុមជំនុំសកល គេមិនដែលទទួលស្គាល់ទុតិយកណ្ឌនោះទេ។ ទាក់ទងនឹងចំណុចលោកគ្រូ អហ្គស្ទីន បានសរសេរថា៖ អ្នកកាត់ស្រាយដ៏ជំនាញបំផុតលើការនិពន្ធដ៏បរិសុទ្ធគឺជាអ្នកដែលបានអានទាំងអស់ និងចងចាំនៅក្នុងគំនិតរបស់ខ្លួន ទោះបើថាមិនទាន់មានការយល់ដឹងយ៉ាងពេញទីក៏ដោយ ក៏យ៉ាងហោចណាស់មានចំណេះដឹងដូចដែលការអានបានផ្តល់—ក្នុងចំណោមទាំងនោះ យ៉ាងហោចណាស់គឺកណ្ឌដែលគេបានរាប់ថាជាព្រះគម្ពីរ។ ដ្បិតគាត់នឹងអានកណ្ឌផ្សេងៗដោយមានសន្តិភាពយ៉ាងខ្លាំង ពេលសាងសង់ជំនឿនៃសេចក្តីពិត ដើម្បីកុំឲ្យវាយកជាកម្មសិទ្ធិគោលដំបូងលើខួរក្បាលទន់ខ្សោយ ឬក៏បន្លំ និងបោកប្រាស់ដោយសេចក្តីខុសឆ្គងដែលពេញទៅដោយគ្រោះថ្នាក់ និងបំពេញជាមួយនឹងការរើសអើងដោយខគម្ពីរផ្ទុយគ្នាពីការយល់ដឹងត្រឹមត្រូវ។ ទាក់ទងទៅនឹងព្រះគម្ពីរ គាត់ត្រូវតែត្រាប់តាមយោបល់នៃក្រុមជំនុំសកល ហើយពិតណាស់ក្នុងចំណោមនេះ គឺត្រូវឲ្យតម្លៃខ្ពស់ទៅលើអស់អ្នកដែលគេបានរាប់ថាស័ក្តិសមក្នុងការអង្គុយនៅកន្លែងរបស់ពួកសាវ័ក និងការទទួលយកសំបុត្រ។ ដោយហេតុនេះ ក្នុងចំណោមកណ្ឌនៃព្រះគម្ពីរ គាត់ត្រូវតែវាយតម្លៃដោយយោងទៅតាមស្តង់ដារដូចតទៅ៖ ជ្រើសរើសយកនូវកណ្ឌគម្ពីរដែលក្រុមជំនុំសកលបានទទួលយកលើកណ្ឌគម្ពីរដែលពួកគេមិនបានទទួលយក។ ជាថ្មីម្តងទៀត៖ ក្នុងចំណោមទាំងនោះ គឺកណ្ឌដែលគ្រប់គ្នាមិនបានទទួលយក គាត់នឹងជ្រើសរើសយកកណ្ឌគម្ពីរដែលមនុស្សជាច្រើនបានទទួលយក និងកណ្ឌគម្ពីរដែលមានអំណាចខ្លាំងក្លាជាង ពោលគឺមិនត្រូវជ្រើសរើសយកកណ្ឌគម្ពីរដែលមានភាគរយមនុស្សតិចយក ហើយក៏ថែមទាំងមិនសូវមានអំណាចផងដែរ (គោលជំនឿគ្រីស្ទបរិស័ទ សៀវភៅទី២, ជំពូកទី៨ ក្នុងឆ្នាំ៣៩៧ នៃគ.ស.)។

# ១៥

# ភាពជាទាសករក្នុងអំណរខាងឯផ្លូវភេទ

២១. តាមពិតទៅ គឺតាមរយៈលោក អាលីពីស៍ ដែលជាមិត្តភក្តិទូលបង្គំទេដែលបានហាមឃាត់ទូលបង្គំក្នុងការរៀបអាពាហ៍ពិពាហ៍ ដោយលើកទឹកចិត្តថា ប្រសិនបើទូលបង្គំរៀបការ នោះទូលបង្គំនឹងមិនមានសមត្ថភាពទៀត ដើម្បីឲ្យយើងរស់នៅជាមួយគ្នា និងលែងមានពេលវេលាដែលគ្មានការឆាឆៅក្នុងការយើងតាមស្រឡាញ់ប្រាជ្ញាដូចដែលយើងបានប្រាថ្នាចង់ធ្វើផងដែរ។ ដ្បិតគាត់មានភាពបរិសុទ្ធក្នុងដំណាក់ការយ៉ាងខ្ពង់ខ្ពស់ ហើយលើសពីនោះគឺដោយសារកាលគាត់នៅក្មេង គាត់បានរួមភេទជាច្រើនដងក្រៅជីវិតអាពាហ៍ពិពាហ៍ ប៉ុន្តែមិនបានបន្តទៅមុខទៀត។ ផ្ទុយទៅវិញ ដោយសារគាត់មានអារម្មណ៍ទុក្ខព្រួយ និងស្អប់វា នោះគាត់បានរស់នៅចាប់តាំងពីពេលនោះរហូតដល់ឥឡូវដោយមានភាពបរិសុទ្ធខាងឯផ្លូវភេទ។ ទូលបង្គំបានលើកឡើងដោយជំទាស់

នឹងគាត់អំពីគំរូនៃមនុស្សប្រុសដែលបានរៀបការ ហើយនៅអាចធ្វើជាអ្នកស្រឡាញ់ប្រាជ្ញាបាន ដែលជាមនុស្សគាប់ព្រះហឫទ័យនឹងព្រះជាម្ចាស់ ហើយនៅបន្តមានភាពស្មោះត្រង់ និងក្ដីស្រឡាញ់ចំពោះមិត្តភក្ដិរបស់ខ្លួនបាន។ ទូលបង្គំធ្លាក់ឆ្ងាយណាស់ចេញពីពួកគេក្នុងភាពបរិសុទ្ធខាងឯព្រលឹងវិញ្ញាណ ហើយមានភាពរីករាយជាមួយនឹងជំងឺខាងឯសាច់ឈាមរបស់ទូលបង្គំ និងភាពផ្អែមល្ហែមដែលធ្វើឲ្យវាស្លាប់ នោះទូលបង្គំក៏បន្តអូសជាប់ច្រវាក់ទៀត ដោយមានភាពភ័យខ្លាចក្នុងការទទួលបានសេរីភាព។ ដូច្នេះទូលបង្គំក៏បដិសេធន៍ការប្រឹក្សាដ៏ពេញដោយប្រាជ្ញារបស់គាត់ ហាក់ដូចជាដៃដែលនឹងរំដោះទូលបង្គំពីច្រវាក់របស់ទូលបង្គំនឹងកាន់តែធ្វើឲ្យរបួសទូលបង្គំឈឺខ្លាំងថែមទៀត។

២២. លោក អាលីពឹស៍ បានឆ្ងល់ថា ហេតុអ្វីបានទូលបង្គំ ដែលជាបុគ្គលម្នាក់ដែលគាត់បានចាត់ទុកថា ខ្ពង់ខ្ពស់គួរជាប់យ៉ាងខ្លាំងក្នុងការសង្វាតដេញតាមភាពអរសប្បាយហាក់បីដូចជាថា ហេតុអ្វីបានជាទូលបង្គំមិនអាចរស់នៅដោយមិនចាំបាច់រួមភេទបានរាល់ពេលដែលយើងនិយាយអំពីប្រធានបទមួយនេះ? ហើយពេលដែលទូលបង្គំប្រកែកដោយការពារសំណួរចោទប្រកាន់របស់គាត់ត្រង់ថា ភាពអរសប្បាយដែលបានកើតឡើងយ៉ាងលឿនក្នុងលក្ខណៈលួចលាក់ខាងឯផ្លូវភេទដែលគាត់បានធ្លាប់ទទួលបទពិសោធន៍ហើយឥឡូវនេះទំនងទាំងជាមិនចងចាំបានផង ហេតុដូច្នេះហើយបានជាគាត់អាចបំភ្លេចវាបានយ៉ាងស្រួលត្រង់ថា យើងមិនគួរយកវាមកប្រៀបធៀបជាមួយនឹងទំនាក់ទំនងដែលនៅយូរអង្វែងជាមួយនឹងស្ត្រីណាម្នាក់បានទេ ហើយថាប្រសិនបើចំណងអាពាហ៍ពិពាហ៍ដែលពោរពេញទៅដោយកិត្តិយសត្រូវបានបន្ថែមចូលទៅក្នុងទំនាក់ទំនងដ៏យូរអង្វែងវែងមួយនេះ នោះគាត់ក៏មិនគួរមានការភ្ញាក់ផ្អើលដែរ ប្រសិនបើទូលបង្គំមិនមានសមត្ថភាពក្នុងការមិនចុះចូលបាន។ នៅពេលដែលទូលបង្គំជជែកវែកញែកបែបនេះ នោះគាត់ក៏មានចិត្តប្រាថ្នាចង់រៀបការដែរ នេះមិនមែនមកពីគាត់ចាញ់ភាពត្រេកត្រអាលក្នុងភាពអរសប្បាយខាងផ្លូវភេទទេ ប៉ុន្តែមកពីគាត់មានការងឿងឆ្ងល់។ ដ្បិតទោះបើគាត់បានគិតថា មើលទៅហាក់បីដូចជាទូលបង្គំកំពុងតែសប្បាយ នោះគាត់បាននិយាយថាគាត់ចង់ដឹង៖ តើហេតុអ្វីបានជាទូលបង្គំរាប់ថាការរួមភេទមានតម្លៃយ៉ាងខ្លាំងដូចនេះត្រង់ថា ទូលបង្គំមានអារម្មណ៍ថាប្រសិនបើគ្មានវា នោះជីវិតទូលបង្គំក៏គ្មានតម្លៃក្នុងការបន្តរស់នៅដែរ ជីវិតទូលបង្គំហាក់បីដូចជាកំពុងតែទទួលទារុណកម្មថែមទៀតផង។ ដ្បិតបុគ្គលដែលមិន

ជាប់ច្រវាក់មានការភ្ញាក់ផ្អើលចំពោះភាពជាទាសកររបស់ទូលបង្គំ ហើយភាពភ្ញាក់ផ្អើលមួយនេះបានដាស់សេចក្តីប្រាថ្នារបស់គាត់ក្នុងការចង់ដកបទពិសោធន៍ ហើយចេញពីនោះគាត់ក៏នឹងទំនងជាបន្តទៅមុខទៀតដោយទទួលបទពិសោធន៍ដោយខ្លួនឯងផ្ទាល់ ហើយបន្ទាប់មកគាត់ទំនងប្រហែលជានឹងធ្លាក់ចុះក្នុងភាពជាទាសករនោះផ្ទាល់តែម្តង ដែលគាត់បានមានការភ្ញាក់ផ្អើលក្នុងទូលបង្គំ ដោយសារគាត់បានត្រៀមខ្លួនរួចស្រេចទៅហើយក្នុងការឈានចូលទៅក្នុងការ «ចុះសញ្ញានឹងសេចក្តីស្លាប់»[១] ដ្បិត «បុគ្គលដែលស្រឡាញ់គ្រោះថ្នាក់នឹងធ្លាក់ចូលជាមិនខាន»។[២]

អ្វីដែលបង្កបញ្ហាដល់ទូលបង្គំជាងគេ ហើយអ្វីដែលធ្វើឲ្យទូលបង្គំបានក្លាយជាទាសកររបស់វារួចទៅហើយនោះគឺៈ ទម្លាប់នៃការព្យាយាមបំពេញភាពត្រេកត្រអាលដែលមិនអាចបំពេញបាន។ ប៉ុន្តែលោក អាលីពីស៍ ជិតក្លាយជាទាសករដោយសារគាត់គ្រាន់តែមានភាពងឿងឆ្ងល់។ នេះគឺជាស្ថានភាពដែលយើងកំពុងរស់នៅក្នុងរហូតដល់ព្រះអង្គដែលជាព្រះដ៏ឧត្តមឧត្តមបានមានសេចក្តីមេត្តាករុណាលើទុក្ខវេទនារបស់យើង ហើយបានយាងមកសង្គ្រោះយើងក្នុងរបៀបដ៏អស្ចារ្យ និងលាក់កំបាំងទៀតផង។ ព្រះអង្គមិនដែលបោះបង់ភាពថោកទាបរបស់យើងចោលទេ។

២៣. គ្រួសារទូលបង្គំបានព្យាយាមយ៉ាងសកម្មក្នុងការបង្ខំឲ្យទូលបង្គំរៀបការ។ ទូលបង្គំក៏បានស្នើ ហើយក៏បានភ្ជាប់ពាក្យ។ ហើយអ្នកម្តាយទូលបង្គំបានធ្វើ តាមដែលគាត់អាចធ្វើបាន ក្នុងការជួយទាក់ទងទៅនឹងរឿងមួយនេះ។ ដ្បិតគាត់បានសង្ឃឹមថា បន្ទាប់ពីទូលបង្គំបានរៀបការហើយ នោះទូលបង្គំនឹងទំនងជាទទួលបានការលាងជម្រះយ៉ាងស្អាតក្នុងទឹកនៃសេចក្តីសង្គ្រោះនៃការជ្រមុជទឹក។ ទោះជាយ៉ាងណាក្តី (ដោយអាស្រ័យលើសំណូមពររបស់ទូលបង្គំ និងកម្លាំងជំរុញរបស់គាត់ផ្ទាល់) នៅពេលដែលគាត់អំពាវនាវជាប្រចាំថ្ងៃយ៉ាងខ្លាំងទៅកាន់ព្រះអង្គដោយមានសម្រែកយំចេញពីដួងចិត្តផ្ទាល់ត្រង់ថាៈ ឲ្យព្រះអង្គបើកសម្តែងតាមរយៈសុបិន្តឲ្យគាត់ឃើញអំពីជីវិតអាពាហ៍ពិពាហ៍នៅឯថ្ងៃអនាគតរបស់ទូលបង្គំ ប៉ុន្តែព្រះអង្គមិនបានធ្វើការនោះទេ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏គាត់បានឃើញចំណុចមិនសូវច្បាស់ និងចម្លែកមួយចំនួន ដែលការនោះគឺជាការកើត

---

១ អេសាយ ២៨:១៥។
២ ព្រះសិរ៉ាក ៣:២៦។

ឡើងចេញពីគំនិតរបស់មនុស្សយើង ដែលផ្តោតទៅលើវាខ្លាំងពេក ហើយទាក់ទងនឹងចំណុចទាំងអស់នោះ គាត់ក៏បានសន្មតថាវាទាក់ទងជាមួយនឹងទូលបង្គំ។ ហើយគាត់បានប្រាប់ទូលបង្គំអំពីវា តែមិនមានទំនុកចិត្តដូចដែលគាត់ធ្លាប់មានទេ នៅពេលដែលព្រះអង្គបានបើកសម្តែងឲ្យគាត់ឃើញអ្វីមួយនោះទេ។ ដ្បិតគាត់តែងតែលើកឡើងថាគាត់អាចវែកញែកវាបាន តាមរយៈអារម្មណ៍ណាមួយដែលគាត់មិនអាចពណ៌នាបានរវាងការបើកសម្តែងរបស់ព្រះអង្គ និងសុបិន្តរបស់គាត់ផ្ទាល់។ ទោះជាយ៉ាងណាក្តី ផែនការក៏បន្តទៅមុខទៀត ការភ្ជាប់ពាក្យក៏បានកើតឡើងជាមួយនឹងស្ត្រីម្នាក់ ដែលនៅកាលនោះគាត់មិនទាន់ដល់អាយុរៀបការ—ពោលគឺខ្វះពីរឆ្នាំទៀត។[៣] ហើយដោយសារទូលបង្គំពេញចិត្តនឹងគាត់ខ្លះដែរ នោះទូលបង្គំក៏ឯកភាពថានឹងចាំនាង។

២៥. ស្របពេលនោះដែរអំពើបាបរបស់ទូលបង្គំក៏កាន់តែកើនឡើងៗ។ ស្ត្រីដែលទូលបង្គំកំពុងតែរស់នៅជាមួយក៏ត្រូវបានដកចេញពីទូលបង្គំ ពីព្រោះគាត់គឺជាឧបសគ្គចំពោះអាពាហ៍ពិពាហ៍របស់ទូលបង្គំ ហើយបេះដូងទូលបង្គំដែលបានភ្ជាប់ជាមួយនឹងគាត់ក៏ត្រូវបានរហែកចេញ ហើយត្រូវរងរបួសរហូតដល់វាហូរឈាម។ គាត់ក៏បានត្រឡប់ទៅទ្វីបអាហ្វ្រិកវិញ គាត់បានស្បថថានឹងមិនប្រគល់ខ្លួនទៅកាន់បុរសណាផ្សេងទៀតទេ ហើយក៏បានទុកកូនជាមួយនឹងទូលបង្គំដែលយើងបានមានជាមួយគ្នា។ ប៉ុន្តែ ទូលបង្គំមិនសប្បាយចិត្ត ហើយខ្សោយជាងគាត់ ហើយក៏មិនអាចរង់ចាំទាល់តែគ្រប់ពីរឆ្នាំទៀតមុនទូលបង្គំទទួលបានកូនក្រមុំទូលបង្គំទេ។ ហេតុដូច្នេះ ដោយសារទូលបង្គំមិនមែនជាអ្នកស្រឡាញ់ជីវិតអាពាហ៍ពិពាហ៍ដូចដែលទូលបង្គំជាទាសករនៃភាពត្រេកត្រអាល នោះទូលបង្គំក៏ទៅយកស្ត្រីកំណាន់ម្នាក់ផ្សេងទៀត—ដែលមិនមែនជាប្រពន្ធ។ ដូច្នេះ ក្នុងចំណងនៃទម្លាប់ដែលនៅជាប់លាប់ នោះជំងឺរាតត្បាតនៃព្រលឹងវិញ្ញាណរបស់ទូលបង្គំក៏មានការបណ្តោយឲ្យធ្វើតាមចិត្ត ហើយបន្តពេញទៅដោយកម្លាំងខ្លាំង ឬក៏ថាថែមទាំងកើតលើសដើមទៅទៀត។ ប្រាកដណាស់! របួសរបស់ទូលបង្គំក៏មិនទទួលបានការព្យាបាល ដែលបានកើតឡើងតាមរយៈស្ត្រីកំណាន់មុនរបស់ទូលបង្គំចេញដែរ។ វាគ្រាន់តែលែងឈឺចាប់ ហើយមានសំឡេងងូងៗ ហើយក៏ចាប់ផ្តើមឆ្លងយ៉ាងអាក្រក់ ហើយក៏កាន់តែមានគ្រោះថ្នាក់ជាងមុន ពីព្រោះឥឡូវវាមិនសូវឈឺចាប់ដូចមុន។

---

៣ នៅពេលនោះ១២ឆ្នាំគឺជាអាយុដ៏តិចបំផុត ដែលបុគ្គលណាម្នាក់អាចរៀបការស្របច្បាប់បាន។

២៦. ព្រះអង្គស័ក្តិសមនឹងទទួលការសរសើរតម្កើង ហើយស័ក្តិសមនឹងទទួលសិរីល្អ ឱព្រះដ៏ជាប្រភពនៃសេចក្ដីមេត្តាករុណាអើយ! ទូលបង្គំកាន់តែវេទនាជាងមុន ហើយព្រះអង្គក៏កាន់តែយាងមកជិតជាងមុន។ ព្រះហស្តស្តាំរបស់ទ្រង់បានត្រៀមរួចស្រេចទៅហើយ ក្នុងការដកទូលបង្គំចេញពីភក់ ដើម្បីលាងសម្អាតទូលបង្គំ ប៉ុន្តែទូលបង្គំមិនបានដឹងអំពីការនេះនោះទេ។ ហើយក៏គ្មានអ្វីមួយបានហៅទូលបង្គំឲ្យត្រឡប់ចេញពីការលោតចូលយ៉ាងជ្រាលជ្រៅក្នុងភាពអរសប្បាយខាងឯសាច់ឈាមផងដែរ លើកលែងតែភាពភ័យខ្លាចនៃការស្លាប់ និងការថ្កោលទោសនៅឯអនាគតរបស់ទ្រង់ ដែលសូម្បីតែក្នុងការវារនៃយោបល់របស់ទូលបង្គំក៏មិនដែលថយចេញពីគំនិតទូលបង្គំដែរ។

ពេលនោះ ទូលបង្គំពិតជាកំពុងដើរក្នុងផ្លូវដ៏វៀចវេរមែន! វេទនាហើយព្រលឹងដ៏ល្ងីល្ងើ និងរឹងរូសដែលសង្ឃឹមថាវានឹងរកបានអ្វីល្អប្រសើរជាងតាមរយៈការបោះបង់ព្រះអង្គចោល! វាបក់ចុះបក់ឡើង ហើយប្រែទៅនេះប្រែទៅនោះ—ប៉ុន្តែ គ្រែរឹងណាស់ ហើយមានតែព្រះអង្គមួយគត់ដែលប្រទានការសម្រាកដល់វាបាន។ ព្រះអង្គគង់នៅជិត ហើយព្រះអង្គរំដោះយើងចេញពីភាពវេទនានៃការវង្វេងរបស់យើង ហើយក៏បង្កើតយើងក្នុងផ្លូវរបស់ទ្រង់ ហើយក៏លួងលោមយើងដោយមានព្រះបន្ទូលថា "ចូរបន្តរត់ចុះ! យើងបានបង្កើតឯង ហើយយើងនឹងទ្រទ្រង់ឯង យើងនឹងកាន់ឯង ហើយក៏នឹងសង្គ្រោះឯងដែរ"។[៤]

---

៤ ១កូរិនថូស ៩:២៤ និងអេសាយ ៤៦:៤។

# ១៦

# ការតស៊ូរបស់ទូលបង្គំក្នុងការយល់អំពីព្រះជាម្ចាស់

១. ឥឡូវទូលបង្គំបានធំធាត់ជាបុរសពេញវ័យហើយ អំពើអាក្រក់ និងភាពអាម៉ាស់ពីមុនៗរបស់ទូលបង្គំកាលនៅជានៅយុវជនគឺនៅពីក្រោយទូលបង្គំ។ ឱព្រះជាម្ចាស់អើយ! ទូលបង្គំលែងគិតថាព្រះអង្គមានលក្ខណៈរូបរាងដូចជាមនុស្សទៀតហើយ។ ទូលបង្គំគេចចេញពីកំហុសខុសឆ្គងនេះនៅពេលដែលទូលបង្គំបានចាប់ផ្តើមសិក្សាទស្សនវិជ្ជា។ ទូលបង្គំបានមានអំណរក្នុងការរកឃើញសេចក្តីពិតមួយនេះក្នុងជំនឿពីអ្នកម្តាយខាងឯព្រលឹងវិញ្ញាណរបស់យើង គឺក្រុមជំនុំរបស់ទ្រង់។ ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំមិនដឹងអំពីរបៀបនៃការយល់អំពីព្រះអង្គដែរ។ ទូលបង្គំបានប្រាថ្នាចង់ស្គាល់ព្រះអង្គដែលជាព្រះពេញទៅដោយអធិបតេយ្យភាព និងក៏ជាព្រះដ៏ពិតតែមួយគត់ ប៉ុន្តែទូលបង្គំគ្រាន់តែជាមនុស្ស ហើយក៏ជាមនុស្សដែលមានបាបផងដែរ។

ក្នុងជម្រៅចិត្តទូលបង្គំ ទូលបង្គំបានដឹងថាទ្រង់មិនមានភាពពុករលួយ មិនអាចរំលោភបំពានលើបាន ហើយក៏មិនផ្លាស់ប្តូរដែរ។ ច្បាស់ណាស់! ភាពពុករលួយមានភាពតូចតាចជាងភាពមិនពុករលួយ។ ការរំលោភបំពានមានភាពតូចតាចជាងការមិនរំលោភបំពាន។ ការបំផ្លាស់បំប្រែមានភាពតូចតាចជាងការមិនបំផ្លាស់បំប្រែ។ ទូលបង្គំអាចឃើញអំពីចំណុចនេះដោយគ្មានមន្ទិលសង្ស័យ ទោះបើទូលបង្គំមិនដឹងអំពីមូលហេតុក៏ដោយ។

២. ឱព្រះដែលជាជីវិតនៃជីវិតរបស់ទូលបង្គំអើយ! ទូលបង្គំបានស្រមៃថា ទ្រង់មានពាសពេញលើផ្ទៃអាកាស ដោយជ្រាបចូលក្នុងភពផែនដីទាំងមូលផង។ ព្រះអង្គឈោងទៅដល់គ្រប់ទិសទី គ្មានដែនកំណត់ ហើយក៏ធំមហិមាទៀតផង។ ព្រះអង្គគង់នៅលើផែនដី នៅឯស្ថានសួគ៌ និងនៅក្នុងគ្រប់អ្វីៗទាំងអស់។ ប៉ុន្តែ ពួកវាមានព្រំដែនក្នុងព្រះអង្គ ខណៈពេលដែលព្រះអង្គគ្មានព្រំដែនទាល់តែសោះ។ ព្រះអង្គប្រៀបដូចជាពន្លឺនៃព្រះអាទិត្យ។ ពន្លឺព្រះអាទិត្យមិនបំបែកបំបាក់ ឬក៏ធ្វើឲ្យខ្យល់ផ្ទុះនោះទេ ប៉ុន្តែវាជ្រាបចូលក្នុងទាំងស្រុងតែម្តង។ ក្នុងរបៀបដូចគ្នានោះដែរ ទូលបង្គំក៏នឹកស្រមៃថា ព្រះអង្គបានជ្រាបចូលខ្យល់ សមុទ្រ ផ្ទៃមេឃ និងផែនដី។ ទាំងអស់បើកទៅកាន់ព្រះអង្គ ហើយក៏ត្រៀមជាស្រេចក្នុងការទទួលព្រះអង្គ។ នេះគឺជាអ្វីដែលទូលបង្គំធ្លាប់បានជឿ។ ប៉ុន្តែ វាមិនពិតទេ។

ដ្បិតប្រសិនបើវាពិតមែន នោះទ្រង់ទ្រាយធំនៃផែនដីក៏នឹងប្រាកដជាមានចំណែកដ៏ធំនៃព្រះអង្គជាមិនខាន។ ទ្រង់ទ្រាយតូច និងមានភាគតូច។ ទាំងអស់នឹងមានពេញទៅដោយព្រះអង្គ ដោយអាស្រ័យទៅលើទំហំរបស់វា។ ដូច្នេះសត្វដំរីនឹងមានផ្នែកធំរបស់ព្រះអង្គជាងសត្វចាប។ ព្រះអង្គនឹងត្រូវបានបើកបង្ហាញនៅលើផែនដីនេះក្នុងវត្ថុជាច្រើនដោយអាស្រ័យទៅលើទំហំរបស់វា ធំទៅធំ ហើយតូចទៅតូច។

ប៉ុន្តែ នេះមិនដូចទ្រង់នោះទេ។ ទោះបើថា នៅពេលនោះព្រះអង្គមិនទាន់បានបំភ្លឺភាពងងឹតរបស់ទូលបង្គំក៏ដោយ។

៤. ប៉ុន្តែ ទោះជាយ៉ាងណាក្តី ក៏នៅមានបញ្ហាមួយដែលបានមកអំពល់ទុក្ខទូលបង្គំ។ ឱព្រះអម្ចាស់ និងព្រះជាម្ចាស់អើយ! ទូលបង្គំបានដឹងយ៉ាងប្រាកដថាគឺទ្រង់ហើយដែលជាអង្គបានបង្កើតព្រលឹង និងរូបកាយយើង និងរបស់សព្វសារពើ និងរាល់អ្វីៗទាំងអស់ ហើយទូលបង្គំក៏ដឹងថាព្រះអង្គគ្មានការបំផ្លាស់បំប្រែ ហើយក៏គ្មានការប្រឡាក់ដែរ។ ប៉ុន្តែ ទូលបង្គំមិនអាចយល់អំពីបុព្វហេតុនៃអំពើអាក្រក់សោះ។

ទូលបង្គំត្រូវតែវិភាគលើបញ្ហាមួយនេះដោយមិនជំទាស់លើលក្ខណៈសម្បត្តិដែលគ្មានការបំផ្លាស់បំប្រែរបស់ព្រះជាម្ចាស់។ បើមិនដូច្នោះទេ នោះទូលបង្គំនឹងក្លាយជាអំពើអាក្រក់ផ្ទាល់ដែលទូលបង្គំកំពុងតែវិភាគជាមិនខាន។

ដោយមានគំនិតស្ងៀមស្ងាត់ ទូលបង្គំក៏ស្វែងរកចម្លើយ។ ឥឡូវ ទូលបង្គំមានទំនុកចិត្តថាគំនិតរបស់ពួកក្រុមមានិហ្គៀនគឺជាគំនិតខុសឆ្គង។ ពួកគេស្វែងរកចម្លើយចេញពីប្រភពនៃអំពើអាក្រក់ដោយមានដួងចិត្តដែលពេញទៅដោយអំនួតដ៏អាក្រក់ៗ។ ពួកគេចូលចិត្តនិយាយអំពីលក្ខណៈសម្បត្តិរបស់ទ្រង់ថា អនុញ្ញាតឲ្យមានអំពើអាក្រក់ ជាជាងលើកឡើងអំពីលក្ខណៈសម្បត្តិដ៏អាក្រក់របស់ខ្លួនគេផ្ទាល់។

៥. បន្ទាប់មក ទូលបង្គំផ្តោតលើការយល់ថា សេចក្តីបង្រៀននៃឆន្ទៈសេរីរបស់យើងគឺជាបុព្វហេតុដ៏ពិតនៃអំពើអាក្រក់។ ដូច្នេះ ជាផលកម្មយើងក៏រងទុក្ខដែរ។ នេះគឺជាសេចក្តីយុត្តិធម៌ និងការថ្កោលទោសរបស់ព្រះអង្គចំពោះយើង។

ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំនៅមិនយល់អំពីវា។ គំនិតរបស់ទូលបង្គំបានព្យាយាមឡើងចេញពីរណ្តៅមួយនោះ ប៉ុន្តែទូលបង្គំបានធ្លាក់ចូលវាជាថ្មីម្តងហើយម្តងទៀត។ ចំណុចមួយដែលចង្អុលបង្ហាញទូលបង្គំទៅកាន់ពន្លឺរបស់ព្រះអង្គគឺចំណេះដឹងដែលទូលបង្គំមានថាទូលបង្គំមានទាំងជីវិត និងឆន្ទៈ។ ដូច្នេះ ទោះបើថាទូលបង្គំមានឆន្ទៈ ឬក៏មិនមានឆន្ទៈក្នុងការប្រព្រឹត្តទង្វើណាមួយ នោះទូលបង្គំអាចឃើញថាឆន្ទៈរបស់ទូលបង្គំគឺជាប្រភពនៃអំពើបាបរបស់ទូលបង្គំដែរ។

នៅពេលដែលទូលបង្គំប្រព្រឹត្តប្រឆាំងនឹងឆន្ទៈរបស់ទូលបង្គំ គឺមិនមែនជាទូលបង្គំទេដែលកំពុងតែប្រព្រឹត្ត។ ផ្ទុយទៅវិញ ទូលបង្គំកំពុងតែទទួលការប្រព្រឹត្តលើ។ ទូលបង្គំមិនបានទទួលស្គាល់ថា ទង្វើទាំងនេះគឺជាកំហុសរបស់ទូលបង្គំ ប៉ុន្តែគឺជាការដាក់ទណ្ឌកម្មពីព្រះអង្គវិញ។ ហើយភ្លាមនោះទូលបង្គំក៏លន់តួថាទណ្ឌកម្មរបស់ទូលបង្គំគឺមិនមែនមិនយុត្តិធម៌នោះទេ ដ្បិតព្រះអង្គយុត្តិធម៌រហូត។

ប៉ុន្តែ តើអ្នកណាដាក់គំនិតនេះក្នុងទូលបង្គំ? តើអ្នកណាដាំក្នុងទូលបង្គំនូវឫសដ៏ល្វីងមួយនេះ? តើទូលបង្គំមិនមែនជាស្នាព្រះហស្តនៃព្រះដ៏ពេញទៅដោយសេចក្តីមេត្តាករុណាយ៉ាងល្អឥតខ្ចោះមែនឬ? តើគួរបន្ទោសអារក្សមែនឬ? ហើយតើអ្នកណាជាអ្នកបង្កើតអារក្ស? ឬក៏ថា ប្រហែលវាធ្លាប់ជាទេវតាដ៏ល្អដែលបានក្លាយជាអាក្រក់តាមរយៈ

ឆន្ទៈដ៏អាក្រក់របស់វាផ្ទាល់ តើឆន្ទៈដ៏អាក្រក់បែបនោះបានលេចឡើងដោយរបៀបណាទៅ? តើវាមិនមែនជាទេវតាល្អដែលព្រះជាម្ចាស់ដ៏ល្អបានបង្កើតវាមែនឬ?

ជាថ្មីម្ដងទៀត សំណួរទាំងអស់នេះបានទម្លាក់ទូលបង្គំចូលក្នុងរណ្ដៅនៃការយល់ច្រឡំ។ ប៉ុន្តែ ទូលបង្គំមិនបានធ្លាក់ចូលនរកនៃការខុសឆ្គងដែលជាទីកន្លែងមនុស្សឈប់អះអាងអំពីទ្រង់។ ទូលបង្គំមិនជឿថា ព្រះអង្គគឺជាអង្គដែលយើងត្រូវបន្ទោសទាក់ទងនឹងអំពើអាក្រក់ទេ។ ផ្ទុយទៅវិញ យើងទេគឺជាអ្នកត្រូវទទួលការបន្ទោសក្នុងនាមជាអ្នកប្រព្រឹត្តអំពើអាក្រក់ទេតើ។

៦. ទោះបើទូលបង្គំមានការតយុទ្ធនេះក៏ដោយ ក៏ទូលបង្គំនៅដឹងថា ភាពមិនពុករលួយនៅល្អប្រសើរជាងភាពពុករលួយដែរ។ ទូលបង្គំស្គាល់ច្បាស់ណាស់អំពីសេចក្ដីពិតមួយនេះ។ មិនថាព្រះអង្គមានលក្ខណៈបែបណាក៏ដោយ ក៏ទូលបង្គំនៅដឹងថា ដាច់ខាត! ទ្រង់មិនអាចមានភាពពុករលួយបានទេ។

ទូលបង្គំបានសន្មតថា គ្មានអ្នកណាអាចគិតអំពីអ្វីដែលល្អ ឬក៏ខ្ពស់ជាងព្រះអង្គបានឡើយ ដ្បិតព្រះអង្គគឺល្អ ហើយខ្ពង់ខ្ពស់ជាងគេបំផុត។ ប្រសិនបើព្រះអង្គមានភាពពុករលួយ នោះទូលបង្គំនឹងមានសមត្ថភាពក្នុងការគិតថា មានអ្វីផ្សេងទៀតល្អប្រសើរជាងទ្រង់។ ដូច្នេះ ពេលដែលទូលបង្គំឃើញថា ភាពមិនពុករលួយល្អប្រសើរជាងភាពពុករលួយ នោះទូលបង្គំក៏ឃើញអំពីទីកន្លែងដែលទូលបង្គំត្រូវតែស្វែងរកព្រះអង្គ និងអំពីទីកន្លែងដែលទូលបង្គំគួរមើលក្នុងការស្វែងរកប្រភពនៃអំពើអាក្រក់ដែរ។ ទូលបង្គំគួររកវាក្នុងភាពពុករលួយដែលគ្មានសមត្ថភាពក្នុងការធ្វើឲ្យព្រះអង្គពុករលួយដែរ។ ដ្បិតវាពិតប្រាកដណាស់ត្រង់ថា ភាពពុករលួយមិនមានសមត្ថភាពក្នុងការធ្វើឲ្យព្រះរបស់យើងពុករលួយបាននោះទេ ពីព្រោះព្រះអង្គជាព្រះរបស់យើង ហើយអ្វីដែលព្រះអង្គបានគ្រោងទុកគឺសុទ្ធតែល្អ ហើយព្រះអង្គផ្ទាល់ក៏ល្អដែរ។ ប៉ុន្តែ ការក្លាយជាពុករលួយមិនល្អទេ។ ឱព្រះអម្ចាស់អើយ! ទ្រង់គ្មានការបង្ខំឲ្យធ្វើអ្វីទាស់ប្រឆាំងនឹងព្រះហឫទ័យរបស់ទ្រង់ឡើយ ដោយសារព្រះហឫទ័យរបស់ព្រះអង្គមិនធំជាងអំណាចរបស់ព្រះអង្គទេ។ ហើយតើមានអ្វីអាចធ្វើឲ្យព្រះអង្គមានការភ្ញាក់ផ្អើលបាន ដោយសារព្រះអង្គជ្រាបរាល់គ្រប់អ្វីៗទាំងអស់ហើយ? ហើយថា តើយើងគួរនិយាយអ្វីបន្ថែមទៀតអំពីមូលហេតុដែលថាព្រះជាម្ចាស់មិនអាចពុករលួយបានឡើយ? ពីព្រោះប្រសិនបើព្រះជាម្ចាស់អាចពុករលួយបាន នោះ

ទ្រង់មិនអាចធ្វើជាព្រះបានទេ។

# ១៧

# ការស្វែងយល់អំពីបុព្វហេតុនៃអំពើអាក្រក់

៧. ហើយទូលបង្គំក៏បានបន្តស្វែងរកបុព្វហេតុនៃអំពើអាក្រក់។ ប៉ុន្តែ វិធីសាស្ត្ររបស់ទូលបង្គំផ្ទាល់មិនត្រឹមត្រូវ ហើយទូលបង្គំក៏មិនអាចឃើញកំហុសរបស់ខ្លួនដែរ។

ទូលបង្គំបានគិតអំពីការបង្កបង្កើតរបស់សព្វសារពើទាំងអស់ក្នុងកែវភ្នែកនៃគំនិតរបស់ទូលបង្គំ៖ រាល់អ្វីដែលយើងឃើញអំពីផែនដី សមុទ្រ ខ្យល់ ផ្កាយ ដើមឈើ និងសត្វនានា។ និងអ្វីៗដែលយើងមិនឃើញ៖ លំហអាកាសនៃផ្ទៃមេឃខាងលើ ពួកទេវតា និងរបស់សព្វសារពើខាងឯវិញ្ញាណ។ ហើយទូលបង្គំក៏បាននឹកគិតក្នុងគំនិតរបស់ទូលបង្គំអំពីការបង្កើតរបស់ព្រះអង្គ ហាក់បីដូចជាថាជាដុំដ៏ធំមួយ ដែលមានរួមទាំងរូបរាងកាយគ្រប់ប្រភេទជាច្រើន—ខ្លះគឺរូបកាយផ្ទាល់ ហើយខ្លះទៀតទូលបង្គំគិតថាដូចជាវិញ្ញាណ។ ទូលបង្គំបានស្រមៃថាដុំនេះធំណាស់—ពិតណាស់មិនមែនក្នុងរង្វាស់ដ៏ពេញរបស់វាទេ ដ្បិត

នេះទូលបង្គំមិនអាចស្គាល់បានទេ—ប៉ុន្តែ ធំតាមដែលទូលបង្គំអាចគិតដល់ តែនៅមានដែនកំណត់នូវរាល់គ្រប់ជ្រុងជ្រោយនៅឡើយ។ ឱព្រះអម្ចាស់អើយ! ប៉ុន្តែ ចំពោះទ្រង់ទូលបង្គំបានស្រមៃថា ព្រះអង្គបានហ៊ុមព័ទ្ធដុំនោះនៅគ្រប់ជ្រុង ហើយជ្រាបចូលវា តែនៅគ្មានព្រំដែនក្នុងគ្រប់ទិសទី—ហាក់បីដូចជាថាជាសមុទ្រនៅគ្រប់ទីកន្លែង ហើយគ្រប់ទីកន្លែងតាមរយៈលំហដែលមិនអាចវាស់វែងបាន គឺគ្មានអ្វីទេក្រៅពីសមុទ្រដែលគ្មានព្រំដែន។

ដូច្នេះ ទូលបង្គំក៏គិតថារបស់សព្វសារពើដែលព្រះអង្គបានបង្កើតមកផ្ទាល់មានព្រំដែន មានពេញទៅដោយព្រះអង្គ ដែលគ្មានព្រំដែន។ ហើយទូលបង្គំក៏លើកឡើងថា «ចូរមើលអ្វីៗដែលព្រះអង្គបានបង្កើត!»។ ព្រះអង្គល្អ មានពេញទៅដោយព្រះចេស្ដា ហើយក៏ល្អប្រសើរដែលមិនអាចប្រៀបផ្ទឹមបានជាមួយនឹងស្នាព្រះហស្ដទាំងអស់របស់ទ្រង់ទៀតផង។ ប៉ុន្តែ ព្រះដ៏ល្អក៏បានបង្កើតរាល់គ្រប់អ្វីៗបានយ៉ាងល្អផងដែរ។ ដូច្នេះ តើអំពើអាក្រក់នៅឯណា តើវាមកពីណា ហើយតើវាបានចូលមកដោយរបៀបណា? តើវាមានឫស និងគ្រាប់ពូជដោយរបៀបណា? តែវាគ្មានរូបរាងទាល់តែសោះបានឬ? ដូច្នេះ ហេតុអ្វីបានជាយើងខ្លាច ហើយគេចចេញពីអ្វីដែលគ្មានរូបរាងអញ្ចឹង? ឬក៏ថា ប្រសិនបើយើងខ្លាចវាដោយគ្មានតម្រូវការ នោះប្រាកដណាស់ ការភ័យខ្លាចមួយនេះគឺអាក្រក់តាមរយៈដួងចិត្តដែលវាបានចាក់ ហើយធ្វើបាបដោយគ្មានការចាំបាច់—ហើយពិតណាស់គឺ ជាអំពើអាក្រក់ដ៏ធំជាងនោះដោយសារយើងមិនមានអ្វីពិតក្នុងការភ័យខ្លាច តែបែរជាភ័យខ្លាច។ ដូច្នេះ ទំនងជាមានអំពើអាក្រក់ដែលយើងភ័យខ្លាច ឬក៏ទង្វើនៃការភ័យខ្លាចគឺជាអំពើអាក្រក់ផ្ទាល់។ ប៉ុន្តែ សំណួរនៅមាន តើវាមកពីណា ដោយសារព្រះជាម្ចាស់ល្អ ហើយអ្វីៗដែលព្រះអង្គបានបង្កើតមកក៏ល្អដែរ? ពិតណាស់! ទ្រង់ក៏ខ្ពង់ខ្ពស់ឧត្ដម ហើយល្អប្រសើរជាងគេ ហើយក៏បានបង្កើតរបស់ទាំងនេះដែលល្អចាញ់ទ្រង់ដែរ។ ប៉ុន្តែ ទាំងព្រះអាទិករ និងអ្វីៗដែលត្រូវបានបង្កើតមកល្អ។ ដូច្នេះ តើអំពើអាក្រក់កើតចេញពីណា? តើមានសារធាតុអាក្រក់ណាមួយចេញពីអ្វីដែលទ្រង់បានបង្កើតមក ហើយធ្វើ និងគ្រោងវាឡើង ប៉ុន្តែបានទុកអ្វីមួយចោលក្នុងរបស់សព្វសារពើរបស់ព្រះអង្គដែលទ្រង់មិនបានប្ដូរឲ្យទៅជាល្អមែនឬ? ប៉ុន្តែ ហេតុអ្វីបានវាដូច្នោះ? ប្រសិនបើព្រះអង្គមានពេញទៅដោយអំណាចមែន តើទ្រង់មិនមានអំណាចក្នុងការបំផ្លាស់បំប្រែទាំងអស់ ដើម្បីកុំឲ្យមានសល់អំពើអាក្រក់មែនឬ? ហើយប្រសិនបើនេះពិតមែន អញ្ចឹងហេតុអ្វីបានជាព្រះអង្គបង្កើតចេញ

ពីសារធាតុដូចនោះ? ហេតុអ្វីបានជាទ្រង់មិនបំផ្លាញវាចោលតាមរយៈអំណាចព្រះចេស្ដាដ៏ខ្លាំងក្លាដូចនោះរបស់ព្រះអង្គ? តើអាចមានអំពើអាក្រក់ទាស់ប្រឆាំងនឹងព្រះហឫទ័យរបស់ទ្រង់ដែរឬទេ? តើព្រះដែលមានពេញទៅដោយព្រះចេស្ដានឹងមិនជ្រើសរើសបំផ្លាញចោលសារធាតុនៃអំពើអាក្រក់នេះ ហើយបន្តមានព្រះជន្មតែឯកអង្គ—ទ្រង់ល្អឥតខ្ចោះពិត មានពេញទៅដោយអធិបតេយ្យភាព ហើយក៏ជាព្រះដ៏ល្អដែលគ្មានទីបញ្ចប់? ឬក៏ថា ប្រសិនបើវាមិនល្អដែលទ្រង់ជាព្រះដ៏ល្អមិនគួរធ្វើជាអង្គដែលគ្រោង ហើយបង្កើតនូវអ្វីដែលល្អ ចុះហេតុអ្វីបានជាសារធាតុដ៏អាក្រក់នោះមិនទទួលបានការដកចេញ ហើយបំផ្លាញឲ្យសូន្យសុងតែម្ដង ដើម្បីឲ្យព្រះអង្គបង្កើតសារធាតុល្អ ដែលចេញពីនោះទ្រង់អាចប្រើប្រាស់ក្នុងការបង្កើតរាល់គ្រប់អ្វីៗទាំងអស់? ដ្បិតព្រះអង្គមិនអាចមានពេញទៅដោយអំណាចព្រះចេស្ដាបានឡើយ ប្រសិនបើទ្រង់គ្មានសមត្ថភាពក្នុងការបង្កើតនូវអ្វីដែលល្អដោយមិនទទួលជំនួយពីសារធាតុដែលអាក្រក់ដែលទ្រង់មិនបានបង្កើតវាមកផ្ទាល់តែឯង!

បញ្ហាទាំងនេះបង្កឲ្យដួងចិត្តរបស់ទូលបង្គំមានរឿងមិនសប្បាយចិត្ត។ ទូលបង្គំមានភាពភ័យខ្លាចដោយបារម្ភថា ខ្លួននឹងស្លាប់មុនទូលបង្គំស្វែងរកឃើញសេចក្ដីពិត។ ទោះជាយ៉ាងណាក្ដី ជំនឿនៃព្រះគ្រីស្ទរបស់ព្រះអង្គដែលជាព្រះអម្ចាស់ និងព្រះអង្គសង្គ្រោះរបស់ទូលបង្គំក៏បានបង្រៀនដល់ទូលបង្គំ តាមរយៈក្រុមជំនុំរបស់ទ្រង់ ក៏នៅបានផ្ដល់សន្តិភាពដល់ទូលបង្គំដែរ។ ទេវវិទ្យារបស់ទូលបង្គំនៅត្រូវការការថែរក្សា និងការណែនាំ ប៉ុន្តែចិត្តគំនិតរបស់ទូលបង្គំមិនបានបោះបង់ជំនឿចោលឡើយ។ ផ្ទុយទៅវិញ ទូលបង្គំក៏បានផឹកពីវាថែមទៀតជាប្រចាំថ្ងៃ។

# ១៨

# របៀបនៃការដែលទូលបង្គំបដិសេធហោរាសាស្ត្រ

៨. មកដល់ពេលនោះ ទូលបង្គំបានបដិសេធទំនាយខុសឆ្គង និងគំនិតឡប់សតិនៃហោរាសាស្ត្រ។ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! ចេញពីជម្រៅនៃព្រលឹងវិញ្ញាណរបស់ទូលបង្គំ សូមមានសេចក្ដីមេត្តាករុណាខណៈពេលដែលទូលបង្គំលន់តួអំពីចំណុចនេះទៅកាន់ទ្រង់។ ព្រះអង្គផ្ទាល់បានកែតម្រង់ភាពរឹងចចេសរបស់ទូលបង្គំទាស់ប្រឆាំងនឹងលោក វិនឌីស៊ិនណូស៍ (Vindicianus) ដែលឆ្លាតវៃ ហើយមានវ័យចាស់ និងលោកនេប្រេឌីអស៍ ដ៏ឆ្នើម។ លោក វិនឌីស៊ិនណូស៍ បានកែតម្រង់ដោយបង្ខំ ខណៈពេលដែលលោក នេប្រេឌីអស៍ បានកែតម្រង់បន្តិចម្ដងៗ ប៉ុន្តែជាញឹកញាប់។ ពួកគេបានប្រាប់ទូលបង្គំថា យើងមិនអាចមើលអនាគតឃើញបានទេ។ ពួកគេបានអះអាងថា ពួកហោរាសាស្ត្របានបោកប្រាស់មនុស្សជាច្រើនដោយប្រើប្រាស់ភាពចៃដន្យទាំងស្រុង។ ពួកហោរាសាស្ត្រ

ធ្វើការទាយជាច្រើន ដូច្នេះ មិនយូរមិនឆាប់ នោះការទាយមួយចំនួននឹងប្រាកដជាកើតឡើងមែនបាន។ ពួកគេជំពប់លើសេចក្តីពិតតាមរយៈការទាយដែលរាប់មិនអស់។

ដើម្បីកែតម្រង់គំនិតទូលបង្គំ ទ្រង់ក៏បានប្រទានមិត្តម្នាក់មកកាន់ទូលបង្គំដែលទៅសួរនាំពួកហោរាសាស្ត្រដោយសារគាត់មានចិត្តនឹកឆ្ងល់។ គាត់មិនសូវស្គាល់ការនិពន្ធរបស់ពួកគេ ប៉ុន្តែគាត់ចេះច្រើនណាស់ ពីព្រោះគាត់បានឮអំពីអ្វីដែលឪពុករបស់គាត់បានបង្រៀន។ គាត់នឹងមិនអាចដឹងថា យោបល់របស់គាត់បានបំផ្លាស់បំប្រែទស្សនៈរបស់ទូលបង្គំលើហោរាសាស្ត្រដល់កម្រិតណាបានទេ។

គាត់ឈ្មោះលោក ហ្វើរមីនីស៍ (Firminus)។ គាត់បានទទួលការសិក្សាផ្នែកសិល្បៈសេរី ហើយក៏មានបទពិសោធន៍យ៉ាងល្អក្នុងវោហារសាស្ត្រដែរ។ ដោយសារទូលបង្គំជាមនុស្សដែលជាទីស្រឡាញ់ម្នាក់របស់គាត់ នោះមានថ្ងៃមួយគាត់ក៏បានសួរទូលបង្គំអំពីយោបល់មួយចំនួន ទាក់ទងទៅនឹងកាលៈទេសៈរបស់គាត់។ សេចក្តីសង្ឃឹមខាងឯលោកីយ៍របស់គាត់បានមានសន្ទុះឡើង ពីព្រោះការទស្សន៍ទាយរបស់គាត់។ ទូលបង្គំបានចាប់ផ្តើមចូលខាងទស្សនៈរបស់លោក នេប្រេឌីអស៍ ទាក់ទងទៅនឹងហោរាសាស្ត្រ។ ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំបានឯកភាពក្នុងការវែកញែកប្រធានបទនេះ ហើយចែកចាយអំពីទស្សនៈមិនប្រាកដប្រជារបស់ទូលបង្គំដែរ។ ទូលបង្គំបានបន្ថែមថា ទូលបង្គំជិតបានទទួលស្គាល់យ៉ាងពេញទីហើយថាហោរាសាស្ត្រឥតប្រយោជន៍ ហើយជាការអស់សំណើចដ៏ភ្លីភ្លើផងដែរ។

គាត់បានប្រាប់ទូលបង្គំអំពីឪពុករបស់គាត់ ដែលបានមានចំណាប់អារម្មណ៍យ៉ាងខ្លាំងក្នុងសៀវភៅរបស់ពួកហោរាសាស្ត្រ។ ឪពុករបស់គាត់ក៏មានមិត្តភក្តិម្នាក់ដែលមានចំណាប់អារម្មណ៍យ៉ាងខ្លាំងដូចគាត់ដែរ។ ជាមួយគ្នា ពួកគាត់ក៏បានសិក្សា ហើយវែកញែក។ ចំណុចនេះក៏បានបន្ថែមភ្លើងនៃភាពឆេះឆួលសម្រាប់ភាពភ្លីភ្លើរបស់ពួកគាត់ដែរ។ ពួកគាត់ថែមទាំងពិនិត្យមើលពេលដែលសត្វដ៏ភ្លីភ្លើរបស់គាត់បង្កើតកូន ហើយកត់សម្គាល់ទុកអំពីទីតាំងនៃហ្វូងតារា។ ពួកគាត់ធ្វើបែបនេះ ដើម្បីប្រមូលព័ត៌មានថ្មីៗសម្រាប់បុព្វបទវិទ្យាសាស្ត្រនេះ។

លើសពីនោះទៅទៀត ឪពុករបស់គាត់ធ្លាប់ប្រាប់គាត់អំពីពេលវេលាដែលម្តាយរបស់គាត់កំពុងតែពរពោះគាត់ ខណៈពេលដែលមិត្តភក្តិស្រីម្នាក់របស់គាត់ដែលជាអ្នកបម្រើក៏

កំពុងតែពរពោះដែរ។ អ្នកបម្រើម្នាក់នោះមិនទាំងអាចលាក់រឿងនេះពីចៅហ្វាយរបស់គាត់បានផង ដោយសារគាត់កត់សម្គាល់យ៉ាងលម្អិតទាក់ទងទៅនឹងការបង្កើតកូន សូម្បីតែឆ្កែរបស់គាត់ក៏គាត់កត់សម្គាល់ដែរ។

ក្រោមការពិនិត្យយ៉ាងយកចិត្តទុកដាក់ ប្រពន្ធរបស់គាត់ និងអ្នកបម្រើក៏បានសម្រាលកូនក្នុងពេលតែមួយដែរ។ ដោយមានការគណនាយ៉ាងផ្ចិតផ្ចង់ រហូតដល់ត្រូវនឹងនាទី ទាំងកូនប្រុសរបស់គាត់ និងកូនរបស់អ្នកបម្រើវ័យក្មេងនោះក៏មានការទស្សន៍ទាយដូចគ្នាទាំងស្រុង។ នៅពេលដែលស្ត្រីទាំងពីរនាក់កំពុងតែឆ្លងទន្លេ ពួកគាត់ក៏បានផ្ញើសារទៅកាន់ផ្ទះស្ត្រីទៅវិញទៅមក ទាក់ទងទៅនឹងអ្វីដែលកំពុងតែកើតឡើង។ ពួកគាត់មានអ្នកនាំសារត្រៀមខ្លួនជាស្រេចក្នុងការនាំព័ត៌មានភ្លាមៗអំពីការសម្រាលកូនយ៉ាងលម្អិត។ លោក ហ្វៀរមីនីស៍ បានព័ត៌មានថា អ្នកនាំសារបានជួបគ្នាចំពាក់កណ្ដាលផ្លូវរវាងផ្ទះទាំងពីរ។ ទាំងពីរនាក់មិនអាចមើលឃើញចំណុចខុសប្លែកណាមួយក្នុងទីតាំងផ្កាយ ឬក៏ព័ត៌មានលម្អិតណាឡើយ។

ទោះជាយ៉ាងណាក៏ដោយក៏លោក ហ្វៀរមីនីស៍ បានកើតក្នុងគ្រួសារដ៏ធូរធារមួយ ហើយដើរក្នុងគន្លងផ្លូវនៃភាពចម្រុងចម្រើនក្នុងលោកីយ៍នេះ។ គាត់កាន់តែមានជាងមុន ហើយក៏ទទួលបានកិត្តិយសជាច្រើនទៀតផង។ ស្របគ្នានោះដែរ អ្នកបម្រើក៏នៅបន្តបម្រើចៅហ្វាយរបស់ខ្លួន។ ក្រោមនឹមនៃកាលៈទេសៈរបស់គាត់ គឺគ្មានការសម្រាកទេ។ លោក ហ្វៀរមីនីស៍ បានឃើញអំពីការនេះ ពីព្រោះគាត់ស្គាល់អ្នកបម្រើម្នាក់នោះ។

៩. បន្ទាប់ពីបានឮ ហើយជឿអំពីចំណុចទាំងអស់នោះ ពីមិត្តភក្តិម្នាក់ដែលអាចទុកចិត្តបាន នោះការប្រឆាំងក្នុងការបដិសេធន៍ហោរាសាស្ត្ររបស់ទូលបង្គំក៏បានរលាយបាត់ទៅ។ បន្ទាប់មក ភ្លាមៗនោះទូលបង្គំក៏ព្យាយាមសង្គ្រោះលោក ហ្វៀរមីនីស៍ ចេញពីអបិយជំនឿរបស់គាត់ដែរ។ ទូលបង្គំបានប្រាប់គាត់ថាប្រសិនបើទូលបង្គំកាត់ស្រាយស្មោះត្រង់អំពីហោរាសាស្ត្ររបស់គាត់ នោះទូលបង្គំនឹងទាយអំពីរឿងដែលងាយមើលឃើញបានជាមិនខាន។ ទូលបង្គំអាចទាយអំពីឋានៈខ្ពង់ខ្ពស់របស់ឪពុកម្ដាយក្នុងចំណោមអ្នកជិតខាងរបស់ពួកគេ គ្រួសារល្អប្រពៃមួយក្នុងទីក្រុងរបស់ពួកគេ កំណើតដ៏អស្ចារ្យ និងការអប់រំសិល្បៈសេរីដ៏ល្អមួយផងដែរ។ ប៉ុន្តែ ប្រសិនបើអ្នកបម្រើមួយនោះបានមករកទូលបង្គំទាក់ទងនឹងហោរាសាស្ត្ររបស់គាត់ នោះទូលបង្គំនឹងទាយថាគាត់នឹងមាន

កំណើតតូចតាច នឹងជីវិតដែលមានពេញទៅដោយបញ្ហា។ ទូលបង្គំនឹងទាយរាល់គ្រប់អ្វីៗខុសគ្នាទាំងស្រុង ហើយផ្ទុយគ្នាពីដំបូង។ ក្នុងករណីនេះ ដើម្បីនិយាយសេចក្ដីពិតដូចគ្នានឹងហោរាសាស្ត្រ នោះទូលបង្គំត្រូវទាយប្រឆាំងគ្នា។ នេះមានន័យថា សេចក្ដីពិតណាដែលទូលបង្គំទាយទុកគឺមិនមែនតាមរយៈជំនាញខាងហោរាសាស្ត្រនោះទេ ប៉ុន្តែគឺជារឿងចៃដន្យ។ ដូចគ្នាផងដែរ ការទាយខុសឆ្គងណាមួយក៏មិនមែនកើតឡើងមកពីការខ្វះជំនាញនោះទេ ប៉ុន្តែកើតឡើងពីការចៃដន្យនៃការមិនត្រឹមត្រូវ។

១០. ដូច្នេះ នោះក៏មានបង្អួចមួយបើកក្នុងភាពងងឹតរបស់ទូលបង្គំ។ ទូលបង្គំក៏ចាប់ផ្ដើមគិតអំពីលទ្ធផលផ្សេងៗ។ ចុះបើទូលបង្គំស្គាល់មនុស្សភ្លីភ្លើណាម្នាក់ដែលជឿអំពីអបិយជំនឿនេះ? ហើយចុះបើទូលបង្គំចង់វាយប្រហារ និងធ្វើឲ្យគំនិតរបស់គាត់ច្របូកច្របល់? នោះក៏ទំនងជាប្រកែកថាលោក ហ្វើរមីនីស៍ បានផ្ដល់ព័ត៌មានមិនត្រឹមត្រូវដល់ទូលបង្គំហើយ។ ឬក៏គាត់ទំនងនឹងថា ឪពុករបស់គាត់មិនបានផ្ដល់ព័ត៌មានត្រឹមត្រូវដល់គាត់។

ដូច្នេះ ទូលបង្គំក៏បានគិតអំពីមនុស្សដែលបានកើតជាកូនភ្លោះ។ ជាទូទៅ ពួកគាត់ចេញពីផ្ទៃពោះម្ដាយក្នុងពេលដែលមិនសូវឆ្ងាយពីគ្នាប៉ុន្មានទេ ក្នុងចន្លោះពេលដ៏តូចមួយ។ អ្នកហោរាសាស្ត្រទំនងជានិយាយថា លក្ខណៈបែបនេះទាក់ទងទៅនឹងចន្លោះពេលវេលាគឺសំខាន់។ ខណៈពេលដែលគាត់ព្យាយាមទាយ គាត់ទំនងជាអះអាងថា ទាំងភ្នែកមនុស្ស និងតារាងរបស់ហោរាសាស្ត្រមិនអាចពណ៌នាអំពីចំណុចសំខាន់នៃភាពលម្អិតនេះបានឡើយ។

ប៉ុន្តែ ការទាយទាំងនោះមិនអាចពិតបានទេ។ ប្រសិនបើគាត់មើលហោរាសាស្ត្រដូចគ្នានោះ នោះគាត់នឹងទាយអំពីអនាគតដូចគ្នាសម្រាប់លោក អេសាវ និងលោក យ៉ាកុបដែរ។[១] តែយើងដឹងថា អនាគតរបស់ពួកគាត់មិនបានកើតឡើងដូចគ្នានោះទេ។ ដូច្នេះគាត់គឺជាមនុស្សកុហក។ ប្រសិនបើគាត់និយាយសេចក្ដីពិត នោះដាច់ខាតគាត់ត្រូវកាត់ស្រាយការទាយខុសៗគ្នាសម្រាប់ហោរាសាស្ត្រតែមួយ។ ប៉ុន្តែ នេះនឹងមានន័យថា ការទាយដ៏ពិតរបស់គាត់គឺអាស្រ័យទៅលើភាពចៃដន្យ មិនមែនលើជំនាញនោះទេ។

ឱព្រះអម្ចាស់អើយ! ទ្រង់គឺជាព្រះដែលសុចរិតជាងគេបង្អស់ ហើយមានពេញទៅ

---

១ លោកុប្បត្តិ ២៥:២១-៣៣:២០។

ដោយអធិបតេយ្យភាពនៃចក្រវាលនេះ ហើយព្រះអង្គធ្វើព័ន្ធកិច្ចតាមរយៈព្រះហឫទ័យលាក់បាំងរបស់ទ្រង់។ ទោះបើថាពួកហោរាសាស្ត្រ ឬក៏អ្នកសួរដឹង ឬក៏មិនដឹង នោះអ្នកសួរទំនងជាឮអ្វីដែលគាត់ចង់ឮ។ នេះគឺយោងទៅតាមគុណសម្បត្តិលាក់កំបាំងនៃព្រលឹងរបស់គាត់ និងជម្រៅនៃសេចក្ដីថ្កោលទោសដ៏យុត្តិធម៌របស់ព្រះអង្គ។ ដូច្នេះ កុំឲ្យនរណាម្នាក់និយាយទៅកាន់ព្រះជាម្ចាស់ថា «តើនេះជាអ្វី?» ឬក៏ «តើនោះជាអ្វី?»។ កុំឲ្យគាត់និយាយក្នុងរបៀបនេះ ដ្បិតគាត់គ្រាន់តែជាមនុស្ស។

១១. ឱព្រះដ៏ជាជំនួយរបស់ទូលបង្គំអើយ! មកដល់ពេលនេះព្រះអង្គបានរំដោះទូលបង្គំចេញពីច្រវាក់ទាំងនោះហើយ។

# ១៩

# ការយល់អំពីប្រភពនៃអំពើអាក្រក់

ទោះបើជាយ៉ាងណាក៏ដោយ ក៏ទូលបង្គំនៅសួរ “តើអ្វីទៅជាប្រភពនៃអំពើអាក្រក់?” ប៉ុន្តែ ទូលបង្គំមិនបានរកឃើញចម្លើយទេ។ ព្រះអង្គមិនបានអនុញ្ញាតឲ្យគំនិតមិនស្ថិតស្ថេររបស់ទូលបង្គំនាំទូលបង្គំចេញពីជំនឿដែលទូលបង្គំបានប្រកាន់ខ្ជាប់តាមទេ។ ទូលបង្គំនៅជឿថា ព្រះអង្គមានព្រះជន្ម។ ទូលបង្គំបានជឿថា ព្រះអង្គគ្មានការបំផ្លាស់បំប្រែ។ ទូលបង្គំបានជឿថា ព្រះអង្គមើលថែមនុស្សយើង ហើយក៏នឹងថ្កោលទោសពួកគេគ្រប់គ្នាដែរ។ ទូលបង្គំបានជឿថា ព្រះអង្គបានរៀបចំផ្លូវនៃសេចក្តីសង្គ្រោះសម្រាប់មនុស្សយើងដែលនាំទៅកាន់ជីវិតបន្ទាប់ពីស្លាប់។ ព្រះអង្គបានធ្វើការនេះតាមរយៈព្រះរាជបុត្រារបស់ទ្រង់ គឺព្រះយេស៊ូវគ្រីស្ទដែលជាព្រះអម្ចាស់របស់យើង និងតាមរយៈព្រះបន្ទូលដែលក្រុមជំនុំរបស់ព្រះអង្គបានលើកទឹកចិត្តឲ្យទូលបង្គំអាន។

ដូច្នេះ ដោយមានជំនឿយ៉ាងប្រាកដប្រជាបែបនេះក្នុងគំនិតរបស់ទូលបង្គំនោះទូលបង្គំក៏បានសួរដោយយកចិត្តទុកដាក់ថា៖ «តើអ្វីទៅជាប្រភពនៃអំពើអាក្រក់?»។ អំឡុងពេលនោះ បេះដូងដែលអស់កម្លាំងរបស់ទូលបង្គំបានរងទុក្ខយ៉ាងខ្លាំងក្លា! ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! ការថ្ងូចថ្ងូរយ៉ាងខ្លាំង! ទោះជាយ៉ាងណាក្តី ក៏ព្រះកាណ៌របស់ព្រះអង្គបានបើកសម្រាប់ទូលបង្គំ ហើយទូលបង្គំក៏មិនបានដឹងអំពីការនោះដែរ។ ទូលបង្គំក៏បាននៅស្ងៀម ហើយក៏បានខំស្វែងរកយ៉ាងខ្លាំង ហើយការពិបាកចិត្តដែលនៅស្ងៀមស្ងាត់នៃព្រលឹងទូលបង្គំក៏បានទទូចអង្វរយ៉ាងឮៗសម្រាប់សេចក្តីមេត្តាករុណា។ មានតែព្រះអង្គមួយគត់ដែលជ្រាបអំពីអ្វីដែលទូលបង្គំបានរងទុក្ខ។ ចំពោះពួកមិត្តភក្តិដ៏សិទ្ធិស្នាលរបស់ទូលបង្គំ ទូលបង្គំអាចពណ៌នាបានតែមួយភាគរយនៃការនោះក្នុងពាក្យពេចន៍ប៉ុណ្ណោះ! តើឲ្យទូលបង្គំអាចប្រាប់អំពីបញ្ហាខាងឯព្រលឹងរបស់ទូលបង្គំទៅកាន់ពួកគាត់បានដោយរបៀបណា ខណៈពេលដែលទាំងពេលវេលា និងពាក្យពេចន៍មិនល្មមគ្រប់គ្រាន់ផង? ព្រះអង្គបានព្រះសណ្តាប់យ៉ាងយកចិត្តទុកដាក់នូវគ្រប់សំណួរផ្សេងៗរបស់ទូលបង្គំ។ ទាំងអស់នោះ ទូលបង្គំបានស្រែកយំក្នុងទុក្ខលំបាកនៃបេះដូងរបស់ទូលបង្គំ។ ប៉ុន្តែ អំនួតរបស់ទូលបង្គំដែលកំពុងតែធំធាត់ឡើងក៏បានបំបែកទូលបង្គំចេញពីព្រះអង្គ ហើយមុខហើមរបស់ទូលបង្គំក៏បានធ្វើឲ្យភ្នែកទូលបង្គំខ្វាក់ដែរ។

១២. ឱព្រះអម្ចាស់អើយ! ព្រះអង្គនៅតែដដែលយ៉ាងអស់កល្បជានិច្ច ប៉ុន្តែទ្រង់មិននៅខ្ញាល់នឹងយើងជារៀងរហូតទេ។ ព្រះអង្គមានសេចក្តីមេត្តាករុណាលើដី និងផេះរបស់យើង។[១] ក្នុងព្រះនេត្ររបស់ទ្រង់ ទ្រង់សព្វព្រះហឫទ័យក្នុងការកែតម្រង់ភាពពុករលួយរបស់ទូលបង្គំ។ តាមរយៈការចាក់ចុចពីខាងក្នុង ព្រះអង្គបានបន្តឆាឆាវទូលបង្គំ ដើម្បីកុំឲ្យទូលបង្គំអាចសម្រាកបាន លុះត្រាតែទូលបង្គំមានភាពច្បាស់លាស់អំពីព្រះអង្គនៅខាងក្នុងទូលបង្គំសិន។ តាមរយៈការព្យាបាលនៃព្រះហស្តលាក់បាំងរបស់ព្រះអង្គ នោះការហើមរបស់ទូលបង្គំក៏បានអន់ថយចុះ។ ភ្នែកដែលងងឹត និងមានទ្រង់ទ្រាយដ៏អាក្រក់នៃគំនិតរបស់ទូលបង្គំក៏មានសុខភាពល្អឡើងវិញ។ ការនេះបានកើតឡើងពីមួយថ្ងៃទៅមួយថ្ងៃតាមរយៈប្រេងព្យាបាលដ៏ឈឺចាប់នៃការបន្ទាបខ្លួនដែលមានទុក្ខព្រួយ។

១៣. ជាដំបូង ព្រះអង្គបានធ្វើឲ្យទូលបង្គំឃើញអំពីរបៀបដែលទ្រង់ «ប្រឆាំងនឹង

១ ទំនុកតម្កើង ១០៣:៩-១៤។

មនុស្សមានអំនួត តែទ្រង់ផ្តល់ព្រះគុណដល់មនុស្សដែលបន្ទាបខ្លួនវិញ»។[២] តាមរយៈសេចក្តីមេត្តាករុណារបស់ទ្រង់ ព្រះអង្គបានបើកសម្តែងមកកាន់មនុស្សយើងនូវរបៀបនៃការបន្ទាបខ្លួននៅពេលដែល «ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម ហើយគង់នៅក្នុងចំណោមយើង»។[៣] ព្រះអង្គបានប្រទានមកកាន់ទូលបង្គំនូវសៀវភៅរបស់ក្រុមផ្លាតូនិយមប៉ុន្មានក្បាល ដែលបានបកប្រែពីភាសាក្រិកមកជាភាសាឡាតាំង។ ពួកវាបានមកដល់ទូលបង្គំតាមរយៈបុរសម្នាក់ដែលមានពេញទៅដោយអំនួតដ៏គួរឲ្យស្អប់ខ្ពើម។ ក្នុងសៀវភៅទាំងនេះ ទូលបង្គំបានឃើញសេចក្តីពិតស្រដៀងគ្នាដែលមានក្នុងព្រះបន្ទូល ទោះបើមិនមែនក្នុងពាក្យពេចន៍ដូចគ្នាទាំងស្រុងក៏ដោយ។ ទូលបង្គំបានឃើញថា «កាលដើមដំបូងមានព្រះបន្ទូល ព្រះបន្ទូលគង់នៅជាមួយព្រះ ហើយព្រះបន្ទូលនោះឯងជាព្រះ។ ព្រះអង្គគង់នៅជាមួយព្រះតាំងពីដំបូង គ្រប់របស់ទាំងអស់បានកើតមកដោយសារព្រះអង្គ ហើយគ្មានអ្វីណាមួយកើតមកក្រៅពីព្រះអង្គឡើយ។ នៅក្នុងព្រះអង្គ អ្វីៗដែលបានកើតមកមានជីវិត ហើយជីវិតនោះជាពន្លឺនៃមនុស្សលោក។ ពន្លឺនោះក៏ភ្លឺមកក្នុងសេចក្តីងងឹត តែសេចក្តីងងឹតមិនយល់ដល់ពន្លឺទេ»។ ទោះបើទូលបង្គំក៏បានអានផងដែរថាព្រលឹងរបស់មនុស្ស «ធ្វើបន្ទាល់ពីពន្លឺ» តែព្រលឹងរបស់មនុស្ស «មិនមែនជាពន្លឺ» ទេ។ ប៉ុន្តែ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយសារទ្រង់ជាព្រះ នោះទ្រង់គឺជា «ពន្លឺដ៏ពិត...ដែលបំភ្លឺដល់មនុស្សទាំងអស់» ហើយ «ព្រះអង្គបានយាងមកគង់នៅដែនដី។ ព្រះអង្គបានគង់នៅក្នុងពិភពលោក ហើយពិភពលោកកើតមកដោយសារព្រះអង្គ តែប្រជារាស្ត្រព្រះអង្គមិនបានទទួលព្រះអង្គឡើយ»។[៤] ទូលបង្គំបានឃើញអំពីចំណុចទាំងនេះក្នុងការនិពន្ធរបស់ក្រុមផ្លាតូនិយម។

ប៉ុន្តែ សៀវភៅនោះមិនបាននិយាយថា «ព្រះអង្គបានយាងមកគង់នៅទឹកដីរបស់ព្រះអង្គ តែប្រជារាស្ត្រព្រះអង្គមិនបានទទួលព្រះអង្គឡើយ។ ប៉ុន្តែ អស់អ្នកដែលទទួលព្រះអង្គ គឺអស់អ្នកដែលជឿដល់ព្រះនាមព្រះអង្គ ព្រះអង្គប្រទានអំណាច ឲ្យបានត្រឡប់ជាកូនព្រះ»។[៥]

១៤. សៀវភៅនោះបានលើកឡើងថា ព្រះជាម្ចាស់ដែលជាព្រះបន្ទូលបាន «កើតមក

---

២ យ៉ាកុប ៤:៦។

៣ យ៉ូហាន ១:១៤។

៤ លោកគ្រូ អហ្គូស្ទីន បានលាយឡំសម្រង់សម្តីក្នុងកណ្ឌគម្ពីរ យ៉ូហាន ១:១-១០ ជាមួយនឹងសៀវភៅទី៥នៃ *«អិនណាត»* *(“Ennead”)*។

៥ យ៉ូហាន ១:១១-១២។

មិនមែនពីឈាម ពីប្រាថ្នាខាងរូបសាច់ ឬពីចំណង់របស់មនុស្សឡើយ គឺកើតមកពីព្រះវិញ»។[៦] ប៉ុន្តែ ពួកក្រុមផ្លាតូនិយមមិនបាននិយាយថា «ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម ហើយគង់នៅក្នុងចំណោមយើង»។[៧]

ក្នុងរបៀបខុសៗគ្នា និងជាច្រើនប្រភេទ សៀវភៅទាំងនោះបានបង្រៀនថាព្រះរាជបុត្រា «បានប្រសូតមកក្នុងលក្ខណៈជាព្រះ»។ ព្រះអង្គមានលក្ខណៈដូចគ្នា ប៉ុន្តែទ្រង់ «មិនបានរាប់ឋានៈដែលស្មើនឹងព្រះនោះ ទុកជាសេចក្ដីដែលគួរកាន់ខ្ជាប់ឡើយ»។[៨]

ទោះជាយ៉ាងណាក្ដីក៏សៀវភៅទាំងនោះមិនបានបង្រៀនថា «ព្រះអង្គបានលះបង់អង្គទ្រង់ មកយកសភាពជាអ្នកបម្រើវិញ ព្រមទាំងប្រសូតមកមានសភាពជាមនុស្សផង។ ដោយឃើញព្រះអង្គមានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបអង្គទ្រង់ ទាំងចុះចូលស្ដាប់បង្គាប់ រហូតដល់ទីមរណៈ គឺព្រះអង្គទទួលសុគតជាប់លើឈើឆ្កាងផង។ ដោយហេតុនោះបានជាព្រះបានលើកទ្រង់ឡើងយ៉ាងខ្ពស់» ពីការសុគត «ហើយបានប្រទានឲ្យមាននាមដ៏ប្រសើរ លើសជាងអស់ទាំងនាម ដើម្បីពេលណាឮព្រះនាមព្រះយេស៊ូវ នោះគ្រប់ទាំងជង្គង់នៅស្ថានសួគ៌ នៅផែនដី និងនៅក្រោមដីត្រូវលុតចុះ ហើយឲ្យគ្រប់ទាំងអណ្ដាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ សម្រាប់ជាសិរីល្អដល់ព្រះជាព្រះវរបិតា»។[៩]

ក្រុមផ្លាតូនិយមបានសរសេរថា តាំងពីមុនពេលគឺមុនពេលមានពេលវេលាទៅទៀត គឺព្រះរាជបុត្រាតែមួយអង្គគត់របស់ទ្រង់មិនមានការបំផ្លាស់បំប្រែ ហើយក៏មានភាពអស់កល្បជានិច្ចជាមួយនឹងព្រះអង្គដែរ។ ក្នុងភាពពេញបរិបូណ៌របស់ទ្រង់ ព្រលឹងទាំងអស់អាចទទួលបានពរ។ តាមរយៈការមានចំណែកក្នុងប្រាជ្ញាមួយនោះ នោះព្រលឹងទាំងអស់នឹងទទួលបានការស្ដារឡើងវិញ ដើម្បីឲ្យមានប្រាជ្ញាបាន។

ប៉ុន្តែ ក្រុមផ្លាតូនិយមមិនបាននិយាយថា «លុះដល់កំណត់ហើយ ព្រះគ្រីស្ទបានសុគតជំនួសមនុស្សទមិឡល្មើស»។ ពួកគេមិនបានសរសេរថាព្រះអង្គ «មិនបានសំចៃទុកព្រះរាជបុត្រាព្រះអង្គផ្ទាល់ គឺបានលះបង់ព្រះរាជបុត្រាសម្រាប់យើងរាល់គ្នា»។[១០] «ព្រះអង្គបានលាក់សេចក្ដីទាំងនេះនឹងពួកអ្នកប្រាជ្ញ និងពួកឈ្លាសវៃ តែបានសម្ដែង

៦ យ៉ូហាន ១:១៣។
៧ យ៉ូហាន ១:១៤។
៨ ភីលីព ២:៦។
៩ ភីលីព ២:៧-១១។
១០ រ៉ូម ៥:៦; ៨:៣២។

ឲ្យពួកកូនក្មេងយល់វិញ»។[១១] ព្រះអង្គបានសន្យាថាឲ្យមានការសម្រាកចំពោះ «អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់» ពីព្រោះព្រះអង្គ «ស្លូត ហើយមានចិត្តសុភាព»។[១២] «ព្រះអង្គនាំមនុស្សសុភាពឲ្យប្រព្រឹត្តតាមមាគ៌ាដ៏ត្រឹមត្រូវហើយបង្រៀនមនុស្សរាបសារឲ្យស្គាល់ផ្លូវរបស់ព្រះអង្គ»។[១៣] ទ្រង់ «ទតមើលទុក្ខវេទនា និងការនឿយព្រួយរបស់ទូលបង្គំ ហើយសូមអត់ទោសអំពើបាបទាំងប៉ុន្មានរបស់ទូលបង្គំផង»។[១៤] ប៉ុន្តែ ពួកមានអំនួត គឺអស់អ្នកដែលដើរក្នុងវិថីដ៏ខ្ពង់ខ្ពស់ក្នុងការគិតថា ខ្លួនមានចំណេះដឹងយ៉ាងខ្ពង់ខ្ពស់ នឹងមិនអាចឮព្រះអង្គមានព្រះបន្ទូលថា «ចូរយកនឹមរបស់ខ្ញុំដាក់លើអ្នករាល់គ្នា ហើយរៀនពីខ្ញុំទៅ នោះអ្នករាល់គ្នានឹងបានសេចក្តីសម្រាកដល់ព្រលឹង ដ្បិតខ្ញុំស្លូត ហើយមានចិត្តសុភាព»។[១៥] ដ្បិតទោះបើពួកគាត់បានស្គាល់ព្រះជាម្ចាស់ក៏ដោយ ក៏ពួកគាត់នឹងមិនថ្វាយព្រះកិត្តិយសដល់ទ្រង់ក្នុងនាមជាព្រះ ឬក៏ថ្លែងអំណរអរព្រះគុណដល់ព្រះអង្គដែរ។ ប៉ុន្តែពួកគេបែរជាមានគំនិតឥតប្រយោជន៍ ហើយចិត្តល្ងង់ខ្លៅរបស់គេ ក៏ត្រឡប់ជាងងឹត។ ដោយអះអាងថា ខ្លួនមានប្រាជ្ញា ដូច្នេះពួកគេក៏បានក្លាយជាមនុស្សល្ងង់ខ្លៅទៅវិញ។[១៦]

១៥. ទូលបង្គំក៏បានអានក្នុងការនិពន្ធរបស់ក្រុមផ្លាតូនិយមដែលថា «គេបានប្តូរសិរីល្អរបស់ព្រះដែលមិនចេះខូច យករូបសំណាក មើលទៅដូចជាមនុស្សដែលតែងតែស្លាប់ ឬដូចជាសត្វស្លាប សត្វជើងបួន និងសត្វលូនវារជំនួសវិញ»។[១៧] ពួកគេបានប្តូរព្រះអង្គយកជំនួសម្ហូបពីប្រទេសអេស៊ីព្ទ ដែលលោក អេសាវ បានលក់សិទ្ធិជាកូនច្បងរបស់គាត់។ រាស្ត្រដំបូងរបស់ព្រះអង្គបានថ្វាយបង្គំក្បាលសត្វជាជាងព្រះអង្គ។ ពួកគេបានបង្វែរដួងចិត្តរបស់ខ្លួនត្រឡប់ទៅកាន់ប្រទេសអេស៊ីព្ទវិញ។ មនុស្សដែលព្រះអង្គបានបង្កើតក្នុងរូបអង្គទ្រង់ ប៉ុន្តែពួកគេបែរជាក្រាបថ្វាយបង្គំរូបសត្វគោដែលស៊ីស្មៅទៅវិញ។ ទូលបង្គំបានឃើញចំណុចទាំងនេះក្នុងសៀវភៅរបស់ពួកគេ ប៉ុន្តែទូលបង្គំមិនបានទទួលយកវាទាំងស្រុងឡើយ។

ឱព្រះអម្ចាស់អើយ! ទ្រង់សព្វព្រះហឫទ័យក្នុងការដកចេញឋានៈទាបរបស់លោក

---

១១ លូកា ១០:២១។
១២ ម៉ាថាយ ១១:២៨, ២៩។
១៣ ទំនុកតម្កើង ២៥:៩។
១៤ ទំនុកតម្កើង. ២៥:១៨។
១៥ ម៉ាថាយ ១១:២៩។
១៦ រ៉ូម ១:២១។
១៧ រ៉ូម ១:២៣។

យ៉ាកុប ដើម្បីឲ្យ «កូនច្បងនឹងបម្រើកូនប្អូន» វិញ។[១៨] ដូចគ្នាផងដែរ ព្រះអង្គក៏បានត្រាស់ហៅពួកសាសន៍ដទៃឲ្យក្លាយជាមរតករបស់ទ្រង់។ ហើយទូលបង្គំក៏ពេញចិត្តយ៉ាងខ្លាំងក្នុងការទទួលបានមាសដែលទ្រង់បានប្រាប់ពួករាស្ត្ររបស់ទ្រង់ឲ្យយកពីពួកអេស៊ីព្ទដែរ។ ដ្បិតទីណាដែលមានមាស ទីនោះជាកម្មសិទ្ធិរបស់ទ្រង់។[១៩] តាមរយៈសាវ័ករបស់ទ្រង់ ព្រះអង្គបានប្រាប់ពួកអ្នកនៅក្រុងអាថែនថា «នៅក្នុងព្រះអង្គ យើងរស់នៅ មានចលនា ហើយមានជីវិតជាមនុស្ស» ដូចដែលសាសនាក្លែងក្លាយមួយចំនួនបានលើកឡើង។[២០] ហើយសៀវភៅរបស់ក្រុមផ្លាតូនិយមទាំងនេះក៏បានបូកពីទីក្រុងអាថែនដែរ។ ប៉ុន្តែ ទូលបង្គំមិនបានដាក់ផ្ចត់គំនិតរបស់ទូលបង្គំលើរូបព្រះដែលធ្វើពីមាសពីប្រទេសអេស៊ីព្ទទាំងនេះឡើយ។ ពួកគេ «បានប្តូរសេចក្តីពិតអំពីព្រះ យកសេចក្តីភូតភរ ហើយថ្វាយបង្គំ និងគោរពបម្រើរបស់ដែលកើតមក ជាជាងព្រះដែលបង្កើតរបស់ទាំងនោះ»។[២១]

១៦. ឱព្រះដ៏ជាសេចក្តីពិតយ៉ាងអស់កល្បជានិច្ច ជាសេចក្តីស្រឡាញ់ដ៏ពិត និងជាអង្គដែលទទួលសេចក្តីស្រឡាញ់យ៉ាងអស់កល្បជានិច្ចអើយ! ទ្រង់គឺជាព្រះជាម្ចាស់របស់ទូលបង្គំ។ ចំពោះព្រះអង្គ ទូលបង្គំដកដង្ហើមធំៗ ទាំងយប់ទាំងថ្ងៃ។ កាលទូលបង្គំបានស្គាល់ព្រះអង្គជាដំបូង ទ្រង់បានលើកទូលបង្គំឡើង ដើម្បីឲ្យឃើញថាមានអ្វីមើល។ ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំមិនមានសមត្ថភាពក្នុងការមើលឃើញវាដែរ។ ព្រះអង្គបានយកឈ្នះលើការទន់ខ្សោយនៃការមើលឃើញរបស់ទូលបង្គំ។ ពន្លឺរស្មីដ៏ចែងចាំងរបស់ព្រះអង្គបានជះពន្លឺលើទូលបង្គំហើយទូលបង្គំក៏បានយកដោយក្តីស្រឡាញ់ និងការភ័យខ្លាច។ ទូលបង្គំក៏យល់ឃើញថា ទូលបង្គំបាននៅឆ្ងាយណាស់ពីព្រះអង្គ ពោលគឺនៅក្នុងទឹកដីដ៏ចម្លែកទាំងស្រុង។ វាហាក់បីដូចជាថា ទូលបង្គំបានឮព្រះសូរសៀងរបស់ព្រះអង្គពីខាងលើថា៖ «យើងគឺជាអាហារសម្រាប់មនុស្សខ្លាំង។ ចូរធំឡើង ហើយឯងនឹងបរិភោគយើង។ ប៉ុន្តែ ឯងមិនបំផ្លាស់បំប្រែយើងក្នុងរបៀបដែលម្ហូបក្លាយជាផ្នែកមួយក្នុងឯងឡើយ។ ផ្ទុយទៅវិញ ឯងនឹងក្លាយដូចជារូបអង្គយើង»។ ទូលបង្គំក៏យល់ឃើញថា ព្រះអង្គប្រដៅមនុស្សសម្រាប់អំពើបាបរបស់គាត់ ហើយដូចជាសត្វពីងពាង នោះព្រះអង្គក៏

---

១៨ លោកុប្បត្តិ ២៥:២៣។

១៩ និក្ខមនំ ១២:៣៥, ៣៦។

២០ កិច្ចការ ១៧:២៨។

២១ រ៉ូម ១:២៥។

ស៊ីព្រលឹងរបស់វា។[២២] ហើយទូលបង្គំក៏លើកឡើងថា «សេចក្ដីពិតមិនបានសាយភាយពាសពេញលំហអាកាសទេ។ វាមិននៅអស់កល្បជានិច្ច ហើយក៏នៅអស់កល្បជានិច្ចដែរ។ ដូច្នេះ តើសេចក្ដីពិតមិនមែនជាអ្វីមែនឬ?»។ បន្ទាប់មក ព្រះអង្គក៏បានស្រែកដាក់ទូលបង្គំពីចម្ងាយថា «យើងជាព្រះដ៏ជាព្រះ»។[២៣] ហើយទូលបង្គំក៏បានឮព្រះអង្គក្នុងដួងចិត្តទូលបង្គំ។ មិនមានកន្លែងសម្រាប់មន្ទិលសង្ស័យទៀតទេ។ ទូលបង្គំទំនងជាអាចនៅមានមន្ទិលសង្ស័យថា ទូលបង្គំពិតជាមានជីវិតមែន ជាជាងមានមន្ទិលសង្ស័យថាពិតជាមានសេចក្ដីពិតមែន។ នេះគឺជាការលើកឡើងថាសេចក្ដីពិតផ្ទាល់ «បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ ហើយយល់បាន តាមរយៈអ្វីៗដែលព្រះអង្គបង្កើតមកដែរ»។[២៤]

១៨. ដូច្នេះ ចំពោះទូលបង្គំ វាក៏បានច្បាស់លាស់យ៉ាងខ្លាំងថា គ្រប់អ្វីៗគឺល្អ សូម្បីតែថាទោះបើវាបានក្លាយជាពុករលួយក៏ដោយ។ ប្រសិនបើថា អ្វីមួយល្អយ៉ាងខ្ពង់ខ្ពស់ ឬក៏ថាវាមិនល្អទាល់តែសោះ នោះក៏វាមិនអាចធ្លាក់ទៅក្នុងការពុករលួយបានដែរ។ ប្រសិនបើវាជាអ្វីដែលល្អយ៉ាងខ្ពង់ខ្ពស់ នោះវាមិនអាចពុករលួយបានឡើយ។ ប្រសិនបើវាមិនមានអ្វីល្អនៅក្នុងវាទេ នោះក៏មិនអាចមានអ្វីមួយមកធ្វើឲ្យវាពុករលួយបានដែរ។ ភាពពុករលួយត្រូវតែធ្វើឲ្យមានការខូចខាត ប៉ុន្តែវាមិនធ្វើឲ្យមានការខូចខាតបានឡើយ ប្រសិនបើគ្មានអ្វីល្អក្នុងការដកចេញបាន។ ដូច្នេះ ទំនងជាអាចថា មិនមានការខូចខាតក្នុងភាពពុករលួយ ឬក៏ថាប្រាកដណាស់អ្វីៗដែលមានការពុករលួយគឺធ្លាប់ជាល្អ។ ប៉ុន្តែ ប្រសិនបើដកនូវអ្វីដែលល្អទាំងអស់ចេញ នោះវានឹងលែងមានជីវិតទៀតហើយ។ ដ្បិតប្រសិនបើមានអ្វីដែលស៊ាំនឹងភាពពុករលួយ នោះដាច់ខាតវាត្រូវតែខ្ពង់ខ្ពស់ហើយ។ យោងតាមអត្ថន័យ វាមិនអាចមានភាពពុករលួយយ៉ាងអស់កល្បជានិច្ចបានទេ។ ដូច្នេះ វាគឺជារឿងដ៏គួរឲ្យអស់សំណើចណាស់ក្នុងការវែកញែកថា ប្រសិនបើយើងដកនូវអ្វីដែលល្អចេញទាំងអស់ពីអ្វីមួយ នោះនឹងធ្វើឲ្យវាមានភាពខ្ពង់ខ្ពស់ឡើង។ បើយើងយកអ្វីៗទាំងអស់ដែលល្អចេញ នោះវានឹងក្លាយជាសូន្យជាមិនខាន។ ហេតុដូច្នេះ ដរាបណាវានៅមានជីវិត នោះវានៅល្អនៅឡើយ។ សរុបសេចក្ដីទៅ រាល់អ្វីៗដែលមានជីវិត ដាច់ខាតវាត្រូវតែល្អ។

ទូលបង្គំកំពុងតែស្វែងរកប្រភពនៃអំពើអាក្រក់។ ដាច់ខាត! អំពើអាក្រក់មិនមាន

២២ ទំនុកតម្កើង ៣៩:១១។ ក្នុងការបកប្រែព្រះគម្ពីរក្នុងភាសាឡាតាំង គេបានបកប្រែពាក្យ «សត្វខ្មួត» ថាជា «សត្វពីងពាង»។

២៣ និក្ខមនំ ៣:១៤ (ពគប)។

២៤ រ៉ូម ១:២០។

សារធាតុទេ ដ្បិតបើអំពើអាក្រក់ជាសារធាតុ នោះដាច់ខាតវាត្រូវតែជាអ្វីដែលល្អ។ ប្រសិនបើអំពើអាក្រក់ជាសារធាតុដែលមិនអាចក្លាយជាពុករលួយបាន នោះវាក៏ជាអ្វីដែលល្អយ៉ាងខ្ពង់ខ្ពស់ដែរ។ ហើយប្រសិនបើវាជាសារធាតុដែលអាចពុករលួយបាន នោះវាក៏មិនអាចក្លាយជាពុករលួយបានដែរ លុះត្រាតែវាល្អសិន។ ដូច្នេះ ទូលបង្គំក៏បានយល់យ៉ាងច្បាស់លាស់ថា ព្រះអង្គបានបង្កើតរាល់គ្រប់អ្វីៗល្អ ហើយគ្រប់សារធាតុទាំងអស់គឺត្រូវបានបង្កើតឡើងតាមរយៈព្រះអង្គ។ ដោយសាររាល់គ្រប់អ្វីៗមិនត្រូវបានបង្កើតឡើងដោយមានភាពស្មើគ្នា នោះតែឯងវានៅល្អ ហើយពេលដែលយើងផ្សំរាល់គ្រប់អ្វីៗទាំងអស់ នោះវាក៏ល្អប្រពៃឡើងដែរ។ ដ្បិតព្រះជាម្ចាស់របស់យើងបានបង្កើតរាល់គ្រប់អ្វីៗបានយ៉ាងល្អប្រពៃ។

២៤. ដូច្នេះ ទូលបង្គំក៏ស្វែងរករបៀបមួយចំនួនក្នុងការទទួលបានកម្លាំងល្មម ដើម្បីមានអំណរក្នុងព្រះអង្គ។ ប៉ុន្តែ ទូលបង្គំមិនបានរកឃើញទាល់តែទូលបង្គំទទួលស្គាល់ «អ្នកកណ្តាលតែមួយ រវាងព្រះនឹងមនុស្ស គឺព្រះគ្រីស្ទយេស៊ូវ ដែលជាមនុស្ស»។[២៥] ទ្រង់គឺជា «ព្រះដែលខ្ពស់លើសទាំងអស់ មានព្រះពរអស់កល្បជានិច្ច»[២៦] ដែលបានយាងមកត្រាស់ហៅ ហើយមានបន្ទូលថា «ខ្ញុំជាផ្លូវ ជាសេចក្តីពិត និងជាជីវិត»។[២៧] ហើយព្រះអង្គក៏បានលាយចូលក្នុងភាពជាសាច់ឈាមរបស់យើងនូវម្ហូបពីស្ថានសួគ៌ដែលទូលបង្គំមិនមានសមត្ថភាពក្នុងការទទួលយក។ ដ្បិត «ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម»[២៨] ដើម្បីឲ្យប្រាជ្ញារបស់ព្រះអង្គអាចក្លាយជាទឹកដោះសម្រាប់យើងក្នុងភាពមិនពេញវ័យរបស់យើង។ ទោះជាយ៉ាងណាក្តីក៏ទូលបង្គំមិនមានការបន្ទាបខ្លួនល្មមគ្រប់គ្រាន់ក្នុងការឱបក្រសោបការបន្ទាបខ្លួនរបស់ព្រះយេស៊ូវដែរ។

២៥. ទូលបង្គំគ្រាន់តែរាប់ព្រះអម្ចាស់យេស៊ូវគ្រីស្ទថាជាបុរសដែលមានប្រាជ្ញាដ៏ខ្ពង់ខ្ពស់បំផុតដែលគ្មានមនុស្សណាផ្សេងអាចយកមកប្រៀបផ្ទឹមបានដែរ។ ទូលបង្គំរាប់ការដែលព្រះអង្គបានប្រសូតមកពីនាងក្រមុំព្រហ្មចារី ដែលនោះជារឿងដ៏អស្ចារ្យថា វាគ្រាន់តែជាគំរូនៃការប្រមាថអ្វីៗនៅលើលោកនេះ ដើម្បីទទួលបានភាពអមតៈតែប៉ុណ្ណោះ។

---

២៥ ១ធីម៉ូថេ ២:៥។

២៦ រ៉ូម ៩:៥។

២៧ យ៉ូហាន ១៤:៦។

២៨ យ៉ូហាន ១:១៤។

ដោយសារចំណុចនេះ និងការដែលព្រះអង្គយកព្រះហឫទ័យទុកដាក់សម្រាប់យើង នោះទូលបង្គំក៏មានអារម្មណ៍ថាទ្រង់ស័ក្តិសមក្នុងការមានអំណាចយ៉ាងខ្លាំងក្លាក្នុងនាមជាអ្នកដឹកនាំ។ ប៉ុន្តែ ទូលបង្គំមិនអាចចាប់ផ្តើមយល់អំពីចំណុចអាថ៌កំបាំងក្នុងឃ្លា “ព្រះបន្ទូលបានត្រឡប់ជាសាច់ឈាម”។ ទូលបង្គំបានរៀន តាមរយៈសៀវភៅដែលគេបានឲ្យយើងថាព្រះអង្គបានសោយ ផ្ទំ យាង មានអំណរ មានការសោកស្តាយ និងមានការសន្ទនាគ្នា។ ទូលបង្គំបានស្វែងរកឃើញថា សាច់ឈាមរបស់ព្រះអង្គមានភាពជាប់គ្នាជាមួយនឹងព្រះបន្ទូលរបស់ទ្រង់ ប៉ុន្តែក៏មានភាពជាប់គ្នាជាមួយនឹងព្រលឹង និងសាច់ឈាមរបស់មនុស្សផងដែរ។ គ្រប់គ្នាដឹងអំពីចំណុចនេះ ប្រសិនបើគេដឹងថា ព្រះបន្ទូលរបស់ទ្រង់មិនអាចមានការប្រែប្រួលបាន។ មកដល់ពេលនេះ ទូលបង្គំក៏បានដឹងអំពីចំណុចនេះផងដែរ តាមដែលទូលបង្គំអាចមានសមត្ថភាព ហើយទូលបង្គំក៏គ្មានមន្ទិលសង្ស័យទាល់តែសោះ។ ព្រលឹង និងគំនិតដែលមានការផ្លាស់ប្រែមានលក្ខណៈសម្បត្តិមួយចំនួន។ ពេលខ្លះ វានឹងរើរូបកាយវា ហើយពេលខ្លះវានឹងមិនរើ។ ពេលខ្លះ វានឹងបង្ហាញពីអារម្មណ៍ ហើយពេលខ្លះវានឹងមិនបង្ហាញ។ ពេលខ្លះ វានឹងបង្ហាញសញ្ញាសម្គាល់បែបជាពាក្យពេចន៍ដែលមានប្រាជ្ញា ហើយពេលខ្លះវានឹងនៅស្ងៀម។ ប្រសិនបើព័ត៌មានលម្អិតទាំងនេះដែលបានសរសេរចុះអំពីព្រះយេស៊ូវមិនត្រឹមត្រូវ នោះរាល់ចំណុចផ្សេងៗក៏ទំនងមិនត្រឹមត្រូវដែរ ហើយក៏នឹងគ្មានជំនឿដែលសង្គ្រោះមនុស្សលោកបានឡើយ។

ប៉ុន្តែ ដោយសារព្រះបន្ទូលពិត នោះទូលបង្គំក៏ទទួលស្គាល់ថា បុរសដ៏ល្អឥតខ្ចោះគឺមានក្នុងព្រះគ្រីស្ទ។ ព្រះអង្គមិនគ្រាន់តែមានរូបកាយក្នុងមនុស្សប៉ុណ្ណោះទេ ហើយព្រះអង្គក៏មិនមែនជារូបកាយ និងព្រលឹងដែលមិនមានគំនិតផងដែរ ប៉ុន្តែទ្រង់គឺជាបុរសពេញលេញ។ ហើយទូលបង្គំក៏បានជឿជាក់ថា ទ្រង់មានភាពឧត្តុង្គឧត្តមខ្ពស់ជាងអ្នកផ្សេងទាំងអស់ មិនមែនមកពីដោយសារព្រះអង្គគឺជាសេចក្តីពិតក្នុងរូបរាងជាមនុស្សទេ ប៉ុន្តែដោយសារទូលបង្គំជឿជាក់ថា ក្នុងទ្រង់ភាពជាមនុស្សបានឈានទៅដល់ភាពល្អឥតខ្ចោះ ហើយដោយសារព្រះអង្គមានចំណែកដ៏ធំក្នុងព្រះប្រាជ្ញារបស់ព្រះដែរ។

២៦. តាមរយៈការអានសៀវភៅរបស់ក្រុមផ្លាតូនិយម នោះទូលបង្គំបានទទួលការបង្រៀនឲ្យស្វែងរកសេចក្តីពិតក្នុងអ្វីដែលមិនមានរូបរាង។ ហើយទូលបង្គំក៏បានឃើញអំពីរបៀបនៃនិស្ស័យជាព្រះរបស់ព្រះអង្គ ដែលទោះបើជាគេមើលមិនឃើញគឺត្រូវបាន

យល់យ៉ាងច្បាស់លាស់តាមរយៈអ្វីៗដែលព្រះអង្គបង្កើតមក។[២៩] ហើយទោះបើការដែលទូលបង្គំនៅប្រាថ្នាចង់ដឹងបន្ថែមទៀតបានមានការរារាំង នោះទូលបង្គំមានការយល់ដឹងដែលពុំអាចយល់ឃើញច្បាស់អំពីអ្វីដែលគំនិតទូលបង្គំមានភាពស្រអាប់ខ្លាំងពេកក្នុងការឃើញឲ្យបានច្បាស់លាស់។ ទូលបង្គំបានមានភាពប្រាកដប្រជាថា ពិតជាមានព្រះអង្គមែន ហើយក៏គ្មានព្រំដែនដែរ។ ទូលបង្គំបានជឿជាក់ថា ព្រះអង្គពិតជាមានព្រះជន្ម ហើយថាព្រះអង្គក៏គង់នៅដដែល ហើយក៏មិនចេះប្រែប្រួលឡើយ។ ហើយថាគ្រប់អ្វីៗទាំងអស់មានជីវិតក្នុងព្រះអង្គ ដែលនោះបានបង្ហាញជាភស្តុតាងក្នុងចំណុចពិតថាពួកវាមានជីវិតមែន។

ទូលបង្គំប្រាកដយ៉ាងច្បាស់លើចំណុចទាំងនេះ ប៉ុន្តែទូលបង្គំខ្សោយពេកក្នុងការមានអំណរក្នុងទ្រង់។ ទូលបង្គំបាននិយាយប៉ប៉ាច់ប៉ប៉ោចហាក់បីដូចជាទូលបង្គំជាអ្នកជំនាញ។ ហើយប្រសិនបើទូលបង្គំមិនបានស្វែងរកផ្លូវរបស់ព្រះអង្គក្នុងព្រះគ្រីស្ទទេ ដែលជាព្រះអង្គសង្គ្រោះរបស់យើង នោះចំណេះដឹងរបស់ទូលបង្គំនឹងមិនមែនជាការណែនាំទេ ប៉ុន្តែជាការបំផ្លិចបំផ្លាញវិញ។ ទូលបង្គំចង់ឲ្យគេឃើញថា ទូលបង្គំមានប្រាជ្ញាអញ្ចឹងពេលគេមើលទូលបង្គំ។ ហើយអំនួតនេះគឺជាការដាក់ទោសរបស់ទូលបង្គំ។ ទូលបង្គំគួរតែមានការប្រែចិត្តទាក់ទងទៅនឹងភាពល្ងង់ខ្លៅរបស់ទូលបង្គំ ប៉ុន្តែផ្ទុយទៅវិញទូលបង្គំបែរជាបំប៉ោងខ្លួនដោយចំណេះដឹង។ ដ្បិតតើសេចក្តីស្រឡាញ់ដែលបានសង់លើមូលដ្ឋានគ្រឹះនៃការបន្ទាបខ្លួននោះមកពីណា ក្រៅពីព្រះយេស៊ូវគ្រីស្ទ? តើសៀវភៅរបស់ក្រុមផ្លាតូនិយមទាំងនេះបានបង្រៀនទូលបង្គំអំពីចំណុចនេះដោយរបៀបណា? ឥឡូវទូលបង្គំជឿថា គឺព្រះហឫទ័យរបស់ព្រះអង្គហើយដែលបណ្តាលឲ្យទូលបង្គំបានសិក្សាចេញពីសៀវភៅរបស់ពួកក្រុមផ្លាតូនិយមមុនទូលបង្គំសិក្សាយ៉ាងជ្រាលជ្រៅនូវព្រះបន្ទូលរបស់ព្រះអង្គ ដើម្បីឲ្យទូលបង្គំចាំអំពីទីកន្លែងដែលពួកគេបានចោលទូលបង្គំ។ ដើម្បីឲ្យពេលក្រោយទូលបង្គំអាចមានសមត្ថភាពឃើញយ៉ាងច្បាស់អំពីចំណុចខុសគ្នារវាងសៀវភៅទស្សនវិជ្ជាដែលព្យាយាមនាំអ្នកអានក្នុងភាពខ្វាក់ទៅកាន់គោលដៅដោយមិនស្គាល់ផ្លូវនៃការទៅដល់ទីកន្លែងនោះ និងព្រះបន្ទូលរបស់ព្រះអង្គដែលនាំអ្នកអាននៅលើផ្លូវដ៏ពិតទៅកាន់គេហដ្ឋានដែលមានពេញទៅដោយព្រះពរនៃស្ថានសួគ៌វិញ។

---

២៩ រ៉ូម ១:២០។

២៧. ដូច្នេះ ដោយមានដៃដែលចង់ ទូលបង្គំក៏អានការសរសេរដ៏បរិសុទ្ធនៃព្រះវិញ្ញាណរបស់ទ្រង់ ជាពិសេសការសរសេររបស់សាវ័ក ប៉ុល។ ជាដំបូង ទូលបង្គំបានគិតថាពេលខ្លះគាត់បានសរសេរទាស់នឹងគ្នា។ ទូលបង្គំបានគិតថា ការបង្រៀនរបស់គាត់មិនបានឯកភាពជាមួយនឹងពាក្យពេចន៍នៃក្រឹត្យវិន័យ និងពួកហោរាទេ។ ប៉ុន្តែ ពេលនោះរាល់មន្ទិលសង្ស័យទាំងនោះបានបាត់អស់ទៅហើយ។ ទូលបង្គំឃើញថា ពាក្យពេចន៍ដ៏បរិសុទ្ធទាំងនោះមានមុខតែមួយ ហើយទូលបង្គំក៏រៀនមានអំណរដោយញាប់ញ័រផងដែរ។

បុគ្គលម្នាក់ទំនងជាអាច «ត្រេកអរនឹងក្រឹត្យវិន័យរបស់ព្រះ...នៅក្នុងអវយវៈ» ប៉ុន្តែបន្ទាប់មកគាត់ក៏បានឃើញ «នៅក្នុងអវយវៈ...ដែលច្បាំងនឹងច្បាប់នៃគំនិត...ទាំងធ្វើឲ្យ...ជាប់នៅក្រោមច្បាប់របស់បាប ដែលនៅក្នុងអវយវៈ»។[៣០] តើគាត់អាចធ្វើអ្វីបាន? ឱព្រះអម្ចាស់អើយ! ទ្រង់សុចរិត ប៉ុន្តែយើងបានប្រព្រឹត្តអំពើបាប និងអំពើអាក្រក់។ យើងបានរស់នៅជាមួយនឹងអំពើអាក្រក់។ ព្រះហស្តរបស់ទ្រង់បានចាប់ផ្តើមមានភាពធ្ងន់ធ្ងរនៅលើយើង។ ដោយសារភាពយុត្តិធម៌របស់ព្រះអង្គ ទ្រង់ក៏បានផ្តល់យើងទៅកាន់សាតាំងមានបាបពីបុរាណនោះ គឺម្ចាស់នៃសេចក្តីស្លាប់។ ឆន្ទៈរបស់វាមិនបានបន្តនៅក្នុងសេចក្តីពិតរបស់ទ្រង់ ដូច្នេះវាក៏លួងលោមឆន្ទៈរបស់យើងឲ្យក្លាយដូចជាឆន្ទៈរបស់វាដែរ។ «ខ្ញុំនេះជាមនុស្សវេទនាណាស់! តើអ្នកណានឹងជួយខ្ញុំឲ្យរួចពីរូបកាយដែលតែងតែស្លាប់នេះបាន?»។[៣១]

ប៉ុន្តែ អក្សរសរសេរទាស់ប្រឆាំងនឹងយើងត្រូវបានលុបចេញដោយព្រះគុណរបស់ព្រះអង្គតាមរយៈព្រះយេស៊ូវគ្រីស្ទដែលជាព្រះអម្ចាស់របស់យើងហើយ។ ព្រះអង្គបានបង្កើតទ្រង់មក ព្រះអង្គមានសភាពស្មើគ្នាជាមួយនឹងទ្រង់តាំងពីអស់កល្បជានិច្ច គឺមុនអស់ទាំងកិច្ចការរបស់ព្រះអង្គពីបុរាណ។[៣២] ម្ចាស់នៃសេចក្តីស្លាប់នៃលោកីយ៍នេះមិនបានរកឃើញមូលហេតុស័ក្តិសមសម្រាប់ការសុគតរបស់ទ្រង់ឡើយ។ ទោះជាយ៉ាងណាក្តី

៣០ រ៉ូម ៧:២២-២៣។

៣១ រ៉ូម ៧:២៤-២៥។

៣២ សុភាសិត ៨:២២; កូឡុស ១:១៥។ នៅត្រង់នេះ លោកគ្រូ អហ្គស្ទីន ភ្ជាប់រូបភាពនៃប្រាជ្ញាក្នុងកណ្ឌគម្ពីរសុភាសិតជាមួយនឹងរូបភាពនៃព្រះបន្ទូលក្នុងការចាប់ផ្តើមនៃដំណឹងល្អរបស់សាវ័ក យ៉ូហាន។ ប៉ុន្តែលោកគ្រូ អហ្គស្ទីន មានការប្រុងប្រយ័ត្នយ៉ាងខ្លាំងក្នុងការអះអាងអំពីភាពដ៏នៅអស់កល្បជានិច្ចស្មើគ្នា និងលក្ខណៈដូចគ្នារបស់ព្រះយេស៊ូវក្នុងការបង្កើតរបស់ព្រះអង្គ ហើយគាត់ក៏បានលើកឡើងផងដែរថាព្រះយេស៊ូវមានព្រះជន្មដ៏នៅអស់កល្បជានិច្ចស្មើគ្នាជាមួយនឹងព្រះជាម្ចាស់។ ហេតុដូច្នេះ ព្រះអង្គមិនមែនជាចំណែកមួយនៃការបង្កើតនោះទេ ប៉ុន្តែគឺជាព្រះដ៏ពិត។ ការបង្រៀនខុសឆ្គងរបស់លោក អើរីអ៊ីស៍ បានអះអាងថាព្រះយេស៊ូវគឺជារបស់សព្វសារពើមួយដែលព្រះជាម្ចាស់បានបង្កើតមក។ ប៉ុន្តែ ត្រង់នេះលោកគ្រូ អហ្គស្ទីន បានបដិសេធន៍យ៉ាងច្បាស់លាស់ថាសេចក្តីបង្រៀននេះគឺជាការខុសឆ្គង។

ក៏វានៅសម្លាប់ព្រះអង្គដែរ។ ហើយសេចក្តីដែលកត់ទុកនៃបំណុលដែលទាស់នឹងយើងក៏ត្រូវបានលុបចោល។[៣៣]

ការនិពន្ធរបស់ក្រុមផ្លាតូនិយមមិនបានលើកឡើងអំពីចំណុចនេះទាល់តែសោះ។ ទំព័រនានានៃសៀវភៅរបស់ពួកគេមិនមានការលើកឡើងអំពីប្រភេទនៃភាពបរិសុទ្ធ ទឹកភ្នែកនៃការលន់តួ ឬក៏យញ្ញបូជារបស់ទ្រង់ឡើយ។ ពួកគេមិនមានវិញ្ញាណដែលមានបញ្ហា វិញ្ញាណខ្ទេចខ្ទាំ និងចិត្តសោកស្តាយ ឬក៏សេចក្តីសង្គ្រោះនៃរាស្ត្ររបស់ទ្រង់ទេ។ ពួកគេមិនបានលើកឡើងអំពីទីក្រុងនៃការធ្វើជាកូនចិញ្ចឹមរបស់យើង សេចក្តីស្មោះត្រង់របស់ព្រះវិញ្ញាណបរិសុទ្ធ និងពែងនៃការប្រោសលោះរបស់យើង។ ក្នុងសៀវភៅរបស់ពួកគេ គ្មាននរណាច្រៀងថា៖ «ព្រលឹងខ្ញុំរង់ចាំព្រះតែមួយព្រះអង្គដោយស្ងៀមស្ងាត់ ការសង្គ្រោះរបស់ខ្ញុំក៏មកតែពីព្រះអង្គដែរ។ ព្រះអង្គតែមួយប៉ុណ្ណោះដែលជាថ្មដា និងជាព្រះសង្គ្រោះខ្ញុំជាបន្ទាយរបស់ខ្ញុំ ខ្ញុំនឹងមិនត្រូវរង្គើជាខ្លាំងឡើយ»។[៣៤] ក្នុងសៀវភៅទាំងនោះ គ្មាននរណាឮគាត់ស្រែកថា «អស់អ្នកដែលនឿយព្រួយ ហើយផ្ទុកធ្ងន់អើយ! ចូរមករកខ្ញុំចុះ»។[៣៥] ពួកគេបានមើលងាយសេចក្តីបង្រៀនរបស់ទ្រង់ ពីព្រោះព្រះអង្គ «ស្លូត ហើយមានចិត្តសុភាព»។[៣៦] ដ្បិតព្រះអង្គបាន «លាក់សេចក្តីទាំងនេះពីពួកអ្នកប្រាជ្ញ និងពួកអ្នកចេះដឹង តែបានសម្តែងសេចក្តីទាំងនោះឲ្យពួកកូនក្មេងយល់វិញ»។[៣៧]

ទូលបង្គំបានអានការសរសេររបស់សាវ័កដ៏ «តូចជាងគេ» នោះ ហើយក៏បានពិចារណារាល់អ្វីៗទាំងអស់របស់ទ្រង់ដោយមានភាពញាប់ញ័រ។[៣៨] ហើយគំនិតទាំងនេះក៏បានលង់មកក្នុងចិត្តរបស់ទូលបង្គំដោយមានការស្រឡាំងកាំងយ៉ាងអស្ចារ្យ។

៣៣ កូឡូស ១:១៤។
៣៤ ទំនុកតម្កើង ៦២:១-២, ៥-៦។
៣៥ ម៉ាថាយ ១១:២៨។
៣៦ ម៉ាថាយ ១១:២៩។
៣៧ ម៉ាថាយ ១១:២៥។
៣៨ ១កូរិនថូស ១៥:៩។

សៀវភៅទី៨

# ២០

# ការតយុទ្ធជាមួយនឹងសេចក្ដីប្រាថ្នាពីរយ៉ាង

១. ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! សូមអនុញ្ញាតឲ្យទូលបង្គំចងចាំដោយមានដួងចិត្តនៃការអរព្រះគុណ ហើយលន់តួទៅកាន់ព្រះអង្គអំពីសេចក្ដីមេត្តាករុណារបស់ទ្រង់ចំពោះទូលបង្គំ។ សូមឲ្យឆ្អឹងទូលបង្គំជ្រាបចូលទៅដោយសេចក្ដីស្រឡាញ់របស់ទ្រង់។ ហើយឲ្យពួកគេនិយាយថា «ឱព្រះយេហូវ៉ាអើយ តើមានអ្នកណាដូចព្រះអង្គ? ។[1] ព្រះអង្គបានបំបាក់ឆ្អឹងទូលបង្គំឲ្យទៅជាបំណែកតូចៗ។ ទូលបង្គំនឹងថ្វាយយញ្ញបូជានៃការអរព្រះគុណដល់ព្រះអង្គ»។[2] ហើយទូលបង្គំនឹងប្រកាសអំពីរបៀបដែលព្រះអង្គបានបំបាក់ឆ្អឹងរបស់ទូលបង្គំ។ ហើយនៅពេលអស់អ្នកដែលថ្វាយបង្គំទ្រង់ឮអំពីចំណុចទាំងនេះ នោះ

១ ទំនុកតម្កើង ៣៥:១០។

២ ទំនុកតម្កើង ១១៦:១៦, ១៧។

ពួកគេនឹងលើកឡើងថាៈ «ឱព្រះយេហូវ៉ា ជាព្រះអម្ចាស់នៃយើងខ្ញុំអើយ ព្រះនាមរបស់ព្រះអង្គថ្កុំថ្កើងរុងរឿងពាសពេញលើផែនដីទាំងមូល! ព្រះអង្គបានតម្កល់សិរីល្អរបស់ព្រះអង្គនៅលើផ្ទៃមេឃ»។[៣]

ព្រះបន្ទូលរបស់ទ្រង់បានជាប់យ៉ាងស្អិតក្នុងដួងចិត្តរបស់ទូលបង្គំ។ ហើយព្រះអង្គបានរុំព័ទ្ធទូលបង្គំពីគ្រប់ជ្រុងជ្រោយ។ ឥឡូវ ទូលបង្គំប្រាកដយ៉ាងច្បាស់អំពីព្រះជន្មដ៏អស់កល្បជានិច្ចរបស់ទ្រង់ ទោះបើទូលបង្គំបាន «មើលឃើញបែបស្រអាប់ ដូចជាមើលក្នុងកញ្ចក់»។[៤] ឥឡូវ ព្រះអង្គបានដកចេញនូវរាល់មន្ទិលសង្ស័យរបស់ទូលបង្គំទាំងអស់។ ហើយទូលបង្គំក៏បានដឹងយ៉ាងប្រាកដថា មានសារធាតុដែលមិនអាចពុករលួយបាន ដែលនោះគឺជាប្រភពនៃរាល់សារធាតុទាំងអស់ដែលបានកើតចេញមក។ ទូលបង្គំក៏កាន់តែលែងប្រាថ្នាអំពីភាពប្រាកដប្រជានៃព្រះជន្មរបស់ព្រះអង្គ ប៉ុន្តែឥឡូវនេះចំណុចដ៏សំខាន់បំផុតចំពោះទូលបង្គំគឺឲ្យខ្លួននៅកាន់តែខ្ជាប់ខ្ជួនក្នុងទ្រង់។

ប៉ុន្តែ ទាក់ទងទៅនឹងភាពបណ្ដោះអាសន្ននៃជីវិតរបស់ទូលបង្គំ រាល់គ្រប់អ្វីៗលែងប្រាកដប្រជាទៀតហើយ។ ចិត្តទូលបង្គំត្រូវការទទួលការសម្អាតចេញពីដំបែរចាស់។ ទូលបង្គំមានចំណាប់អារម្មណ៍ទៅ «ផ្លូវ» និងព្រះអង្គសង្គ្រោះ ប៉ុន្តែនៅស្ទាក់ស្ទើរក្នុងការឆ្លងកាត់ទ្វារតូច។ ព្រះអង្គបានដាក់ក្នុងចិត្តរបស់ទូលបង្គំឲ្យទៅលេងលោកគ្រូ សិមភ្លីស៊ីអន្ទស៍។ ទូលបង្គំបានជឿថា គាត់គឺជាអ្នកបម្រើដ៏ស្មោះត្រង់ម្នាក់របស់ទ្រង់។ ទូលបង្គំក៏បានឮផងដែរថា តាំងពីគាត់នៅក្មេងគឺគាត់បានប្ដេជ្ញាក្នុងការរស់នៅសម្រាប់ព្រះអង្គ។ មកដល់ពេលនោះ គាត់ជាមនុស្សចាស់ហើយ។ ចំពោះទូលបង្គំ មើលទៅគាត់ហាក់បីដូចជាពេញទៅដោយប្រាជ្ញា ហើយគាត់ក៏ពិតជាមានប្រាជ្ញាមែន។ ទូលបង្គំចង់ឲ្យគាត់ប្រាប់ទូលបង្គំថាតើទូលបង្គំគួរធ្វើអ្វីក្នុងជីវិតទូលបង្គំ។

២. ទូលបង្គំមិនមានការពេញចិត្តនឹងជីវិតទូលបង្គំដែលកំពុងតែរស់នៅក្នុងលោកីយ៍នេះ។ ទូលបង្គំក៏លែងរំភើបអំពីសិរីល្អ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនដែរ។ ព្រោះវាគឺជាបន្ទុកដ៏គួរឲ្យភ័យព្រួយក្នុងការបន្តរស់នៅដោយមានចំណុចទាំងនោះគ្រប់គ្រងពីលើ។ វាមិនអាចប្រៀបផ្ទឹមបានជាមួយនឹងភាពផ្អែមល្ហែម និងភាពស្រស់ស្អាតនៃព្រះដំណាក់របស់

---

៣ ទំនុកតម្កើង ៨:១។
៤ ១កូរិនថូស ១៣:១២។

ព្រះអង្គ ដែលទូលបង្គំស្រឡាញ់បានឡើយ។ សិរីល្អ និងទ្រព្យសម្បត្តិផ្ទាល់ខ្លួនលែងធ្វើឲ្យទូលបង្គំសប្បាយចិត្តទៀតហើយ។ ប៉ុន្តែ ទូលបង្គំនៅជាប់ចំណងនៃភាពត្រេកត្រអាលយ៉ាងស្អិតដែលទូលបង្គំមានសម្រាប់ស្ត្រីម្នាក់។ សាវ័ក ប៉ុល មិនបានហាមមិនឲ្យទូលបង្គំរៀបការនោះទេ ទោះបើថាគាត់បានលើកទឹកចិត្តឲ្យទូលបង្គំធ្វើនូវអ្វីដែលល្អប្រសើរជាងនេះក៏ដោយ។ ដ្បិតគាត់បានប្រាថ្នាយ៉ាងស្មោះត្រង់ថាឲ្យបុរសគ្រប់រូបនៅលីវដូចគាត់។

ប៉ុន្តែ ទូលបង្គំខ្សោយ ហើយក៏បានជ្រើសរើសផ្លូវដ៏ងាយស្រួលជាង។ ហើយទាក់ទងនឹងមូលហេតុតែមួយគត់នេះ នោះជីវិតខាងក្នុងទាំងមូលរបស់ទូលបង្គំក៏មានភាពចលាចល ហើយក៏គ្មានកម្លាំងក្នុងការសម្រេចចិត្តដែរ។ អ្នកនៅជុំវិញទូលបង្គំក៏បានបង្ខំឲ្យទូលបង្គំរៀបការ ទោះបើទូលបង្គំមិនសុខចិត្តក៏ដោយ។ ទូលបង្គំបានឮពីព្រះបន្ទូលនៃសេចក្ដីពិតថា «មានមនុស្សកម្រៀវដែលអ្នកដទៃបានក្រៀវ ហើយមានមនុស្សកម្រៀវដែលបានក្រៀវដោយខ្លួនឯង ដោយព្រោះព្រះរាជ្យនៃស្ថានសួគ៌»[៥] ប៉ុន្តែ ព្រះអង្គបានមានព្រះបន្ទូលថា «អ្នកណាដែលអាចទទួលសេចក្ដីនេះបាន ចូរទទួលចុះ»។

ប៉ុន្តែ ទូលបង្គំបានក្លាយជាមនុស្សអាក្រក់ដូចពួកទាំងនោះដែល «ដ្បិតទោះជាគេបានស្គាល់ព្រះ ក៏គេមិនបានតម្កើងព្រះអង្គជាព្រះ ឬអរព្រះគុណព្រះអង្គដែរ»។[៦] ទោះជាយ៉ាងណាក្ដី ព្រះហស្តស្ដាំរបស់ទ្រង់ក៏កាន់ទ្រទូលបង្គំឡើងហើយដាក់ទូលបង្គំនៅកន្លែងដែលទូលបង្គំទំនងជាអាចជាសះស្បើយវិញបាន។ ព្រះអង្គបានមានព្រះបន្ទូលទៅកាន់មនុស្សលោកថា «មើល៍! សេចក្ដីកោតខ្លាចដល់ព្រះអម្ចាស់នោះហើយជាប្រាជ្ញា»[៧] និង «កុំឲ្យមើលខ្លួនថាមានប្រាជ្ញាឡើយ»[៨] ពីព្រោះ «គេអួតអាងថាខ្លួនមានប្រាជ្ញា តែគេបែរជាល្ងីល្ងើ»។[៩] ទូលបង្គំបានរកឃើញពេជ្រមួយគ្រាប់ដ៏មានតម្លៃ។ ទូលបង្គំត្រូវការលក់នូវរាល់គ្រប់អ្វីៗដែលទូលបង្គំមាន ដើម្បីទិញវា។ ប៉ុន្តែ ទូលបង្គំមានការស្ទាក់ស្ទើរ។

៣. ដូច្នេះ ទូលបង្គំក៏បានទៅរកលោកគ្រូ សិមភ្លីស៊ីអន្ទស៍ ដែលជាឪពុកខាងឯព្រលឹងវិញ្ញាណរបស់លោកគ្រូគង្វាល អែមប្រូស៍ ដែលលោកគ្រូ អែមប្រូស៍ ពិតជាបានស្រឡាញ់គាត់ដូចជាឪពុករបស់គាត់មែន។ ទូលបង្គំបានពណ៌នាទៅកាន់គាត់នូវរាល់ចំណុច

៥ ម៉ាថាយ ១៩:១២។
៦ រ៉ូម ១:២១។
៧ យ៉ូប ២៨:២៨។
៨ សុភាសិត ៣:៧។
៩ រ៉ូម ១:២២។

ច្របូកច្របល់នៃការវង្វេងរបស់ទូលបង្គំ។ ហើយនៅពេលដែលទូលបង្គំលើកឡើងទៅកាន់គាត់ថាទូលបង្គំបានអានសៀវភៅមួយចំនួនរបស់ក្រុមផ្លាតូនិយម នោះលោកគ្រូ សិមភ្លីស៊ីអន្នស៍ ក៏បានអបអរសាទរមកកាន់ទូលបង្គំថា ទូលបង្គំមិនបានធ្លាក់ទៅក្នុងការសរសេររបស់ទស្សនវិទូដទៃ ដែលពួកវាមានពេញទៅដោយគំនិតខុសឆ្គងដែលធ្វើឲ្យសេចក្តីពិតមានភាពស្រអាប់ «តាមវិញ្ញាណបឋមរបស់លោកីយ៍»[១០] ស្របពេលដែលក្រុមផ្លាតូនិយម នូវរាល់ចំណុចបែបនោះវិថីរបស់វានាំទៅកាន់ការជឿលើព្រះជាម្ចាស់ និងព្រះបន្ទូលរបស់ទ្រង់។

បន្ទាប់មកលោកគ្រូ សិមភ្លីស៊ីអន្នស៍ បានលើកទឹកចិត្តឲ្យទូលបង្គំមានការបន្ទាបខ្លួនដូចជាព្រះគ្រីស្ទ។ ការបន្ទាបខ្លួនគឺជាចំណុចដែលមានការលាក់បាំងពីអ្នកឆ្លាត ប៉ុន្តែមានការបើកសម្តែងទៅកាន់កូនក្មេងតូចៗ។ គាត់បានប្រាប់ទូលបង្គំអំពីលោកគ្រូ វិខទូរីនូស៍ ដែលជាបុគ្គលដែលគាត់បានស្គាល់យ៉ាងច្បាស់ពេលគាត់រស់នៅទីក្រុងរ៉ូម។ ហើយទូលបង្គំជួយមិនបានទេ ប៉ុន្តែគឺត្រូវតែលើកឡើងអំពីការដែលគាត់បានប្រាប់ទូលបង្គំអំពីលោកគ្រូ វិខទូរីនូស៍ ទៅកាន់ព្រះអង្គ។ ដ្បិតវាមាននូវភស្តុតាងដ៏ពេញដោយសិរីរុងរឿងនៃព្រះគុណរបស់ព្រះអង្គ ដែលទូលបង្គំត្រូវតែប្រកាសទៅកាន់ទ្រង់។ លោកគ្រូ វិខទូរីនូស៍ គឺជាបុរសដ៏ចាស់ម្នាក់ដែលបានរៀនសូត្រយ៉ាងជ្រាលជ្រៅ ហើយក៏មានជំនាញក្នុងរាល់សិល្បៈសេរីដែរ។ គាត់បានអាន រិះគន់ និងពន្យល់នូវការនិពន្ធជាច្រើនរបស់ទស្សនវិទូនានា។ ហើយគាត់ក៏ជាគ្រូនៃសមាជិកព្រឹទ្ធសភាដ៏អស្ចារ្យជាច្រើននាក់ផងដែរ។ ពួកគេបានគោរពគាត់យ៉ាងខ្លាំងដល់ថ្នាក់ថាពួកគេបានធ្វើរូបចម្លាក់អំពីគាត់នៅទីប្រជុំជននៅឯទីក្រុងរ៉ូម ដើម្បីជារង្វាន់ដល់គាត់—ដែលនោះគឺជាអ្វីដែលមនុស្សគ្រប់រូបសរសើរថាជាការផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត។ នៅក្នុងទីកន្លែងដែលសូម្បីតែមនុស្សដែលមិនកាន់សាសនាក៏ស្រឡាញ់ឋានៈរបស់គាត់ដោយមានកិត្តិយសដ៏ខ្ពស់។ បុរសដែលមានវ័យចំណាស់ ហើយពេញទៅដោយបទពិសោធន៍ម្នាក់នេះ គឺជាមនុស្សដែលបានថ្វាយបង្គំរូបព្រះស្ទើរតែពេញមួយជីវិតរបស់គាត់។ ទោះជាយ៉ាងណាក៏ដោយក៏គាត់មិនមានភាពអាម៉ាស់ក្នុងការក្លាយជាអ្នកបម្រើរបស់ព្រះគ្រីស្ទរបស់ទ្រង់ដែរ និងជាទារកនៅឯកន្លែងទឹកផុសរបស់ទ្រង់ ព្រមទាំងឱនក្បាលគាត់ទៅកាន់នឹមនៃការបន្ទាបខ្លួន និងការ

១០ កូឡុស ២:៨។

ចុះចូលថ្វាសរបស់គាត់ទៅកាន់ភាពអាម៉ាស់នៃឈើឆ្កាង។

៤. ឱព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់ «ឱព្រះយេហូវ៉ាអើយ! សូមផ្អៀងផ្ទៃមេឃ ហើយយាងចុះមក! សូមពាល់ភ្នំទាំងប៉ុន្មាន ដើម្បីឲ្យមានផ្សែងហុយឡើង!»។[១១] តើព្រះអង្គបានយាងចូលទៅក្នុងដួងចិត្តរបស់លោកគ្រូ វិខទូរីនូស៍ ដោយរបៀបណា? លោកគ្រូសិមភ្លីស៊ីអន្ទស៍ បានលើកឡើងថាលោកគ្រូ វិខទូរីនូស៍ បានធ្លាប់អានព្រះបន្ទូលដ៏បរិសុទ្ធយ៉ាងល្អិតល្អន់ ហើយក៏បានសិក្សានូវការនិពន្ធរបស់គ្រីស្ទបរិស័ទមួយចំនួនក្នុងរបៀបដែលមានការយកចិត្តទុកដាក់ និងចេតនាដែរ។ លោកគ្រូ វិខទូរីនូស៍ បានប្រាប់លោកគ្រូសិមភ្លីស៊ីអន្ទស៍ យ៉ាងអាថ៌កំបាំងក្នុងនាមជាមិត្តភក្តិថា «ឯងត្រូវតែដឹងថា ខ្ញុំគឺជាគ្រីស្ទបរិស័ទ»។ ហើយលោកគ្រូ សិមភ្លីស៊ីអន្ទស៍ បានឆ្លើយតបវិញថា «គ្នានឹងមិនជឿទេ ហើយក៏នឹងមិនរាប់ឯងក្នុងចំណោមគ្រីស្ទបរិស័ទដែរ ទាល់តែគ្នាឃើញឯងចូលទៅក្នុងក្រុមជំនុំរបស់ព្រះគ្រីស្ទសិន»។ បន្ទាប់មកលោកគ្រូ វិខទូរីនូស៍ បានសួរលោកគ្រូ សិមភ្លីស៊ីអន្ទស៍ដោយមានការលេងសើចថា «ចុះបើអញ្ចឹង តើអគារមែនឬដែលធ្វើឲ្យមនុស្សក្លាយជាគ្រីស្ទបរិស័ទ?»។ លោកគ្រូ វិខទូរីនូស៍ បានធ្លាប់លើកឡើងជាញឹកញាប់ថា គាត់គឺជាគ្រីស្ទបរិស័ទរួចស្រេចទៅហើយ ហើយលោកគ្រូ សិមភ្លីស៊ីអន្ទស៍ ក៏តែងតែឆ្លើយដដែលៗទៅគាត់។ ហើយលោកគ្រូ វិខទូរីនូស៍ ក៏នឹងលើកឡើងអំពីរឿងកំប្លែងរបស់គាត់អំពីអគារម្តងទៀតដែរ។ លោកគ្រូ វិខទូរីនូស៍ មានការខ្លាចក្នុងការធ្វើឲ្យមិត្តភក្តិរបស់គាត់ដែលជាអ្នកថ្វាយបង្គំពួកអារក្សពេញដោយអំនួតអន់ចិត្ត។ គាត់ខ្លាចថា ប្រសិនបើគាត់ធ្វើឲ្យមិត្តភក្តិរបស់គាត់អន់ចិត្ត នោះព្យុះនៃការស្អប់ខ្ពើមនឹងធ្លាក់មកលើគាត់ជាមិនខាន។

ប៉ុន្តែ ខណៈពេលដែលគាត់អានដោយប្រិតប្រៀង នោះគាត់ក៏កាន់តែចាប់ផ្តើមមានភាពក្លាហានឡើងៗ។ គាត់ខ្លាចថា ព្រះគ្រីស្ទនឹងបដិសេធន៍គាត់នៅចំពោះមុខពួកទេវតាដ៏បរិសុទ្ធ ប្រសិនបើគាត់មានភាពអាម៉ាស់ក្នុងការទទួលស្គាល់ព្រះអង្គនៅចំពោះមុខមនុស្សលោក។ ដូច្នេះ គាត់ក៏មានអារម្មណ៍ពិរុទ្ធភាព ដោយសារគាត់មានភាពអាម៉ាស់ទាក់ទងទៅនឹងពិធីបង្ហូរព្រះគុណនៃការបន្ទាបខ្លួននៃព្រះបន្ទូលរបស់ព្រះអង្គ ខណៈពេលដែលគាត់មិនមានភាពអាម៉ាស់ក្នុងការមានចំណែកក្នុងពិធីរបស់ពួកអារក្សដ៏ពេញដោយអំនួត។ គាត់ក៏ចាប់ផ្តើមមានភាពអាម៉ាស់ទាក់ទងទៅនឹងពិធីសាសនាដ៏គ្មានន័យ

១១ ទំនុកតម្កើង ១៤៤:៥។

ទាំងនោះ ហើយក៏ចាប់ផ្ដើមមានអារម្មណ៍នៃការគោរពសេចក្ដីពិត។ ភ្លាមៗនោះ ហើយដោយគ្មានការរំពឹងទុកជាមុនគាត់ក៏បាននិយាយទៅកាន់លោកគ្រូ សិមភ្លីស៊ីអន្នស៍ ថា "តោះ! ចូរយើងនាំគ្នាទៅក្រុមជំនុំ គ្នាចង់ក្លាយជាគ្រីស្ទបរិស័ទ"។ បន្ទាប់មកលោកគ្រូ សិមភ្លីស៊ីអន្នស៍ ក៏បានទៅជាមួយគាត់ភ្លាម ដោយមិនអាចលាក់អំណររបស់គាត់បាន។ គេក៏បានដាក់គាត់ចូលពិធីបង្ហូរព្រះគុណដំបូងនៃការណែនាំ។ ហើយមិនយូរប៉ុន្មាន គាត់ក៏បានចុះឈ្មោះ ដើម្បីឲ្យគាត់អាចទទួលពិធីជ្រមុជទឹកនៃការកើតជាថ្មី។ មកដល់ចំណុចនេះ រាល់បុគ្គលនៅក្នុងទីក្រុងរ៉ូមក៏មានការភ្ញាក់ផ្អើល ហើយក្រុមជំនុំក៏មានពេញទៅដោយអំណរដែរ។ ពេលពួកមានអំនួតឃើញ នោះពួកគេក៏មានពេញទៅដោយកំហឹង។ ពួកគេបានសង្កៀតធ្មេញដាក់គាត់ ហើយក៏បានរលាយបាត់ទៅ! ប៉ុន្តែ ព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់គឺជាសេចក្ដីសង្ឃឹមនៃអ្នកបម្រើរបស់ទ្រង់ ហើយគាត់ក៏មិនអើពើនឹងការឥតប្រយោជន៍ និងការកុហកដ៏រវើរវាយរបស់ពួកគេដែរ។

៥. ជាចុងក្រោយ វេលាក៏បានមកដល់ក្នុងការឲ្យគាត់អះអាងជាសាធារណៈអំពីជំនឿរបស់គាត់ (ដ្បិតនៅទីក្រុងរ៉ូម វាគឺជាទំនៀមទម្លាប់ចំពោះអស់អ្នកដែលរៀបចំនឹងឈានចូលព្រះគុណរបស់ទ្រង់ ក្នុងការឲ្យគាត់ប្រកាសជាសាធារណៈនៃការសូត្រពីការចងចាំពាក្យពេចន៍)។ ក្នុងករណីរបស់លោកគ្រូ វិខទូរីនូស៍ ពួកចាស់ទុំនៃក្រុមជំនុំបានផ្ដល់ឱកាសដល់គាត់ក្នុងការធ្វើការប្រកាសបែបជាសម្ងាត់ ដ្បិតនោះគឺជាទំនៀមទម្លាប់សម្រាប់អស់អ្នកដែលទំនងជាមានការភ័យខ្លាចដោយសារការខ្មាសអៀន។ ប៉ុន្តែលោកគ្រូ វិខទូរីនូស៍ បានជ្រើសរើសធ្វើការប្រកាសអំពីសេចក្ដីសង្គ្រោះរបស់គាត់នៅចំពោះមុខក្រុមជំនុំដ៏បរិសុទ្ធទាំងមូល។ ដ្បិតគ្មានសេចក្ដីសង្គ្រោះក្នុងវោហារសាស្ត្រដែលគាត់ធ្លាប់បង្រៀនពីមុនទេ ទោះជាយ៉ាងណាក៏ដោយ ក៏គាត់បានប្រកាសជាសាធារណៈដែរ។ ដូច្នេះ ហើយបានជាគាត់មិនមានការភ័យខ្លាចក្នុងការលើកឡើងអំពីព្រះបន្ទូលរបស់ទ្រង់នៅចំពោះមុខកូនចៀមរបស់ព្រះអង្គ ពីព្រោះពីមុនគាត់មិនមានការភ័យខ្លាចក្នុងការប្រកាសពាក្យពេចន៍ផ្ទាល់ខ្លួនរបស់គាត់នៅចំពោះមុខមហាជនជាច្រើនឡើយ។

ដូច្នេះ ពេលដែលគាត់ដើរឡើងទៅលើឆាក ដើម្បីធ្វើការប្រកាស នោះក៏មានមនុស្សជាច្រើនបានស្គាល់គាត់ ពួកគេក៏បានខ្សឹបខ្សៀវឈ្មោះរបស់គាត់ដាក់គ្នាទៅវិញទៅមក ក្នុងសំឡេងនៃការអបអរសាទរ។ ហើយតើមានអ្នកណាក្នុងចំណោមអ្នកចូលរួមមិនស្គាល់

គាត់ដែរឬទេ? ហើយក៏ចាប់ផ្តើមមានការបញ្ចេញសូរខ្សឹបៗលើបបូរមាត់នៃអ្នកចូលរួមដែលកំពុងមានអំណរថា៖ «រិខទូរីនូស៍! រិខទូរីនូស៍!»។ បន្ទាប់មក ភ្លាមៗនោះពួកគេក៏បាននៅស្ងៀម ដើម្បីឲ្យខ្លួនអាចស្តាប់គាត់ឮ។ គាត់ក៏បានប្រកាសជំនឿពិតដោយមានភាពក្លាហានដ៏ល្អក្រៃលែង។ ហើយពិតណាស់! ការប្រកាសរបស់គាត់ក៏បានជ្រាបចូលក្នុងដួងចិត្តនៃអស់អ្នកដែលកំពុងស្តាប់ដែរ។ ហើយពួកគេក៏បានទទួលយកគាត់ដោយសេចក្តីស្រឡាញ់ និងសូរសំឡេងទះដៃដែលពេញដោយអំណរ។

៦. ឱព្រះជាម្ចាស់ដ៏ជាព្រះនៃសេចក្តីសប្បុរសអើយ! តើមានអ្វីធ្វើឲ្យមនុស្សយើងមានអំណរខ្លាំងជាង ក្រៅពីពេលដែលមនុស្សម្នាក់ទទួលជឿ ដែលពួកគេគិតថាគ្មានសង្ឃឹមក្នុងការទទួលបានសេចក្តីសង្គ្រោះទេ ជាជាងគេមានអំណរនៅពេលដែលបុគ្គលដែលគេគិតថាមានសង្ឃឹម ឬក៏មិនដែលស្ថិតនៅគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរ? ទ្រង់ក៏ជាព្រះវរបិតាដែលមានពេញទៅដោយសេចក្តីមេត្តាករុណាដែរ ហើយព្រះអង្គមានអំណរខ្លាំង «ដោយសារមនុស្សបាបតែម្នាក់ដែលប្រែចិត្ត ជាងមនុស្សសុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការប្រែចិត្ត»។[១២] ហើយយើងក៏ស្តាប់ដោយមានអំណរយ៉ាងក្រៃលែងផងដែររាល់ពេលណាដែលយើងឮថាចៀមដែលបានបាត់បង់គឺត្រូវបាននាំត្រឡប់មកវិញនៅលើស្មានៃអ្នកគង្វាល។ សូម្បីតែពួកទេវតាដែលនៅឯស្ថានសួគ៌ក៏មានអំណរដែរនៅពេលដែលបុគ្គលណាម្នាក់កែប្រែចិត្ត។ ដូចពេលដែលយើងឮរឿងនៃរបៀបដែលគេបានរកឃើញកាក់ប្រាក់ឡើងវិញ ហើយដាក់វាចូលទៅក្នុងឃ្លាំង។ ហើយស្ត្រីដែលបានរកវាឃើញក៏អរសប្បាយជាមួយនឹងមិត្តភក្តិ និងអ្នកជិតខាងរបស់គាត់។[១៣] ទឹកភ្នែកនៃអំណរក៏ហូរចុះមកពេលយើងឮអំពីកូនប្រុសប្អូន (កូនពៅវង្វេង) ដែល «បានស្លាប់ ឥឡូវរស់ឡើងវិញ ក៏បាត់ទៅ តែបានឃើញវិញហើយ»។[១៤] ដ្បិតគឺព្រះអង្គហើយដែលអរសប្បាយជាមួយនឹងយើង និងជាមួយនឹងពួកទេវតារបស់ទ្រង់ដែលជាពួកបរិសុទ្ធក្នុងសេចក្តីស្រឡាញ់ដ៏បរិសុទ្ធ។ ដ្បិតទ្រង់នៅតែដដែល ពីព្រោះទ្រង់ជ្រាបនូវរាល់អ្វីៗទាំងអស់។ ទោះបើអ្វីៗទាំងអស់ដែលមិនតែងតែនៅដដែល។

៩. ឱព្រះអម្ចាស់អើយ! សូមយាងមក ធ្វើឲ្យយើងមានចលនា ហើយត្រាស់ហៅយើង

---

១២ លូកា ១៥:៧។

១៣ លូកា ១៥។

១៤ លូកា ១៥:២៤។

ឲ្យត្រឡប់ទៅវិញផង។ សូមធ្វើឲ្យភាពឆេះឆួលរបស់យើងលូតលាស់ឡើង ហើយទាញចំណាប់អារម្មណ៍របស់យើងទៅកាន់ព្រះអង្គវិញ។ សូមធ្វើឲ្យបេះដូងរបស់យើងមានចលនា ហើយសូមព្រះអង្គកាន់តែមានភាពផ្អែមល្ហែមចំពោះយើង ដើម្បីឲ្យយើងអាចស្រឡាញ់ទ្រង់ ហើយរត់ទៅរកទ្រង់បាន។ តើមិនមានមនុស្សជាច្រើនជាងហ្នឹងដែលបានត្រឡប់មករកព្រះអង្គវិញដោយចេញពីអន្លង់នៃសេចក្ដីងងឹតដ៏ជ្រៅជាងលោកគ្រូវិខទូរីនូស៍ មែនឬ? តើមានអ្នកណាទៅជិតព្រះអង្គ ពីព្រោះពន្លឺរបស់ទ្រង់បានជះលើពួកគេ ដោយផ្ដល់អំណាចដល់ពួកគេឲ្យក្លាយជាកូនៗរបស់ទ្រង់? ប៉ុន្តែ ប្រសិនបើពួកគេមិនសូវល្បីល្បាញ នោះសូម្បីតែអស់អ្នកដែលស្គាល់ពួកគាត់មិនសូវជាអរសប្បាយប៉ុន្មានសម្រាប់ពួកគេដែរ។ ដ្បិតពេលមនុស្សជាច្រើនអរសប្បាយជាមួយគ្នានូវអំណររបស់អ្នកណាម្នាក់ និងមានភាពពេញលេញជាងមុន ពីព្រោះអំណររបស់ពួកគេពង្រីកខ្លាំងជាងមុន តាមរយៈអំណរនៃអស់អ្នកដែលនៅជុំវិញពួកគេ។ ហើយអស់អ្នកដែលល្បីល្បាញក៏មានឥទ្ធិពលលើមនុស្សជាច្រើន និងលើសេចក្ដីសង្គ្រោះរបស់មនុស្សជាច្រើនដែរ។ ដូច្នេះ សូម្បីតែអស់អ្នកដែលបានជឿពីមុនៗ នោះពួកគេក៏មានអំណរយ៉ាងខ្លាំងលើពួកគេដែរ ពីព្រោះពួកគេមិនគ្រាន់តែមានអំណររបស់ពួកគេតែឯងនោះទេ។ ប៉ុន្តែ នៅកន្លែងថ្វាយបង្គំរបស់ទ្រង់ យើងមិនគួរស្វាគមន៍ពួកអ្នកមានខ្លាំងជាងពួកអ្នកក្រនោះទេ ឬក៏ពួកអភិជនលើអ្នកផ្សេងៗនោះដែរ ដ្បិត «ព្រះបានជ្រើសរើសអ្វីដែលល្ងីល្ងើក្នុងលោកនេះ ដើម្បីធ្វើឲ្យអ្នកប្រាជ្ញមានសេចក្ដីខ្មាស ព្រះបានជ្រើសរើសអ្វីដែលខ្សោយក្នុងលោកនេះ ដើម្បីធ្វើឲ្យពួកខ្លាំងពូកែមានសេចក្ដីខ្មាស ព្រះបានជ្រើសរើសអ្វីដែលទាបថោក និងអ្វីដែលគេមើលងាយនៅលោកីយ៍នេះ អ្វីៗដែលគ្មាន ដើម្បីធ្វើឲ្យអ្វីៗដែលមានទៅជាអសារឥតការ»។[១៥] សូម្បីតែ «ក្នុងបណ្ដាពួកសាវ័កនោះខ្ញុំជាអ្នកតូចជាងគេ» ដែលតាមរយៈគាត់ព្រះអង្គបាននិពន្ធពាក្យពេចន៍ទាំងនេះ។

ខ្មាំងសត្រូវរបស់យើងទទួលបទពិសោធន៍នៃការចាញ់យ៉ាងខ្លាំងពេលវាបាត់បង់ការចាប់លើបុគ្គលណាដែលវាបានចាប់លើ។ ប៉ុន្តែ ខ្មាំងសត្រូវរបស់យើងគ្រប់គ្រងលើពួកមានអំនួតងាយស្រួលជាង ពីព្រោះពួកគេចាប់អារម្មណ៍លើឋានៈរបស់ខ្លួន និងតាមរយៈការជះឥទ្ធិពលរបស់ពួកគេ នោះវាក៏កាន់តែគ្រប់គ្រងលើមនុស្សច្រើនជាងមុនបាន

---

១៥ ១កូរិនថូស ១:២៧-២៨។

ដែរ។ ដូច្នេះ ការដែលលោកគ្រូ វិខទូរីនូស៍ ក្លាយជាគ្រីស្ទបរិស័ទគឺជារឿងដ៏សំខាន់មួយ។ ដួងចិត្តរបស់លោកគ្រូ វិខទូរីនូស៍ គឺជាទីមាំមួនមួយរបស់អារក្ស ហើយវាក៏បានប្រើប្រាស់ពាក្យពេចន៍របស់គាត់ ដើម្បីបោកបញ្ឆោតមនុស្សជាច្រើននាក់ដែរ។ ប៉ុន្តែ ឥឡូវនេះកូនៗរបស់ព្រះអង្គមានមូលហេតុដ៏ល្អ ដើម្បីមានអំណរជាមួយនឹងការអរសប្បាយដ៏អស្ចារ្យ។ ពីព្រោះស្តេចរបស់យើងបានចងមនុស្សពូកែហើយ។ ហើយកូនៗរបស់ព្រះអង្គបានឃើញនូវរាល់ចំណុចដែលកំពុងតែត្រូវបានដកចេញពីគាត់ ដើម្បីសម្អាតគាត់ ហើយធ្វើឲ្យគាត់ស័ក្តិសមសម្រាប់ព្រះកិត្តិយសរបស់ព្រះអង្គ «ដែលបានរៀបចំជាស្រេច សម្រាប់ការល្អគ្រប់ជំពូក»។[១៦]

១០. នៅពេលលោកគ្រូ សិមភ្លីស៊ីអន្ទស៍ ដែលជាអ្នកបម្រើរបស់ព្រះអង្គបានប្រាប់ទូលបង្គំអំពីរឿងរបស់លោកគ្រូ វិខទូរីនូស៍ នោះទូលបង្គំមានចិត្តចង់ក្លាយដូចជាគាត់យ៉ាងខ្លាំងណាស់។ ប្រាកដណាស់! ទូលបង្គំជឿថា នេះគឺជាគោលបំណងរបស់លោកគ្រូ សិមភ្លីស៊ីអន្ទស៍ ក្នុងការប្រាប់រឿងនេះមកកាន់ទូលបង្គំ។ ហើយគាត់បន្តប្រាប់ទូលបង្គំអំពីអំឡុងពេលនៃសម័យរបស់អធិរាជ ជូលាន ដែលពេលនោះគេបានចេញច្បាប់ហាមមិនឲ្យគ្រីស្ទបរិស័ទបង្រៀនអក្សរសាស្ត្រ ឬក៏វោហារសាស្ត្រ។ ហើយគាត់បានប្រាប់ទូលបង្គំអំពីរបៀបដែលលោកគ្រូ វិខទូរីនូស៍ បានទទួលយកច្បាប់ដោយស្ម័គ្រចិត្ត ហើយជ្រើសរើសបោះបង់ចោល «សាលានៃពាក្យពេចន៍» របស់គាត់ជាជាងព្រះបន្ទូលរបស់ទ្រង់។ ចំពោះទូលបង្គំ មើលទៅហាក់បីដូចជាគាត់មិនសូវក្លាហានប៉ុន្មានទេ ប៉ុន្តែវាគឺជារឿងដ៏សំណាងណាស់ដែលគាត់បានរកឃើញមូលហេតុក្នុងការប្រគល់ពេលវេលាទាំងអស់របស់គាត់ទៅកាន់ព្រះអង្គ។ ដ្បិតនេះគឺជាអ្វីដែលទូលបង្គំប្រាថ្នាចង់ធ្វើ។ ប៉ុន្តែ ទូលបង្គំនៅជាប់ចំណងច្រវាក់ដែកនៃឆន្ទៈរបស់ខ្លួននៅឡើយ។ សាតាំងបានចាប់យកឆន្ទៈរបស់ទូលបង្គំ ហើយបានធ្វើវាឲ្យក្លាយជាច្រវាក់ហើយក៏បានចងទូលបង្គំយ៉ាងជាប់ជាមួយវាដែរ។ ពីព្រោះចេញពីឆន្ទៈចចេសរឹងរូសរបស់បុគ្គលណាមួយគឺភាពត្រេកត្រអាល ហើយការប្រព្រឹត្តតាមភាពត្រេកត្រអាលបង្កើតចេញជាទម្លាប់ ហើយក៏មានការងាយស្រួលក្នុងការក្លាយជាអ្វីដែលចាំបាច់។ «ការភ្ជាប់គ្នានោះ» ដែលបង្កើតឡើងជាមួយគ្នា (នេះហើយគឺជាមូលហេតុដែលទូលបង្គំហៅវាថាជា «ច្រវាក់») បានផ្ទុកទូលបង្គំក្នុងភាពជាទាសករ។

១៦ ២ធីម៉ូថេ ២:២១។

ប៉ុន្តែ ឆន្ទៈថ្មីដែលបានចាប់ផ្ដើមដុះឡើងក្នុងទូលបង្គំមានការប្រាថ្នាចង់ថ្វាយបង្គំព្រះអង្គដោយមានសេរីភាព និងមានអំណរក្នុងទ្រង់។ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! មានតែទ្រង់ហើយដែលជាអំណរដែលនៅស្ថិតស្ថេរ។ ប៉ុន្តែ ព្រះអង្គមិនទាន់យកឈ្នះលើឆន្ទៈមុនៗរបស់ទូលបង្គំនៅឡើយទេ ដែលបានក្លាយជាខ្លាំងជាងមុន ពីព្រោះទូលបង្គំមានប្រវត្តិនៃការបំពេញវាអស់ជាច្រើនឆ្នាំ។ ដូច្នេះ ឆន្ទៈទាំងពីររបស់ទូលបង្គំ ទាំងចាស់ និងថ្មីក៏មានការប្រជែងគ្នានៅខាងក្នុងទូលបង្គំ។ ហើយការប្រជែងគ្នារបស់ពួកវាក៏បានហែកបំបែកព្រលឹងរបស់ទូលបង្គំដែរ។

១១. នេះគឺជារបៀបដែលទូលបង្គំបានឈានទៅដល់ការយល់ដឹងនូវអ្វីដែលទូលបង្គំបានអានចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ទូលបង្គំ៖ «សេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាម តែងតែទាស់នឹងព្រះវិញ្ញាណ ហើយសេចក្ដីប៉ងប្រាថ្នារបស់ព្រះវិញ្ញាណ ក៏ទាស់នឹងសាច់ឈាមដែរ ព្រោះទាំងពីរនេះប្រឆាំងគ្នា»។[១៧] ទូលបង្គំពិតជាប្រាថ្នាចង់បានផ្លូវទាំងពីរមែន។ ហើយទោះជាយ៉ាងណាក៏ដោយក៏ទូលបង្គំមានទំនួលខុសត្រូវសម្រាប់ចំណុចពិតនៃទម្លាប់របស់ទូលបង្គំដែលបានក្លាយជាខ្មាំងសត្រូវដ៏ជូរចត់ដែរ។ ពីព្រោះទូលបង្គំបានមានឆន្ទៈក្នុងការទៅធ្វើ ឲ្យខ្លួនក្លាយជាអ្វីដែលទូលបង្គំមិនមានឆន្ទៈចង់ឃើញខ្លួនឯងបានក្លាយទៅជាដូចនោះដែរ។

តើអ្នកណាអាចរអ៊ូរទាំយ៉ាងត្រឹមត្រូវបានអំពីការដាក់ទារុណកម្មដ៏យុត្តិធម៌ដែលដេញតាមមនុស្សមានបាប? ទូលបង្គំមិនអាចបន្តប្រើប្រាស់លេសដែលទូលបង្គំមានការស្ទាក់ស្ទើរក្នុងការលះបង់លោកីយ៍នេះចោល ហើយបម្រើព្រះអង្គទៀតទេ ពីព្រោះទូលបង្គំមិនមានការប្រាកដប្រជាអំពីសេចក្ដីពិត។ ដ្បិតឥឡូវនេះ ទូលបង្គំមានភាពប្រាកដប្រជាអំពីសេចក្ដីពិតហើយ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ក៏ទូលបង្គំនៅជាប់នឹងលោកីយ៍ ហើយបដិសេធន៍ក្នុងការធ្វើជាទាហានរបស់ទ្រង់ដែរ។ ហើយទូលបង្គំមានការភ័យខ្លាចក្នុងការមានសេរីភាពរួចចេញពីគ្រប់អន្ទាក់ ពេលដែលតាមពិតទៅទូលបង្គំគួរមានការភ័យខ្លាចក្នុងការជាប់អន្ទាក់ទៅវិញទេ។

១២. គំនិតរបស់ទូលបង្គំអំពីព្រះអង្គគឺប្រៀបដូចជាការខិតខំប្រឹងប្រែងរបស់អ្នកដែលប្រាថ្នាចង់ភ្ញាក់ឡើងអញ្ចឹង ប៉ុន្តែគឺជាអស់អ្នកដែលភាពងុយងោកបានយកឈ្នះ

១៧ កាឡាទី ៥:១៧។

លើ ហើយក៏បានគេងលក់យ៉ាងស្រួលទៅវិញ។ ទោះបើគ្មានបុគ្គលណាប្រាថ្នាចង់ដេកជារៀងរហូតក៏ដោយ ក៏វាជាការងាយស្រួលណាស់សម្រាប់ឲ្យបុគ្គលណាម្នាក់បន្តក្នុងភាពងងុយរបស់គាត់ ប្រសិនបើគាត់អស់កម្លាំងខាងឯសាច់ឈាម។ ហើយបុគ្គលនោះក៏សប្បាយចិត្តក្នុងការបន្តដេក ទោះបើគាត់ដឹងថាពេលវេលាបានមកដល់ហើយក្នុងការឲ្យគាត់ងើបក៏ដោយ។ ក្នុងរបៀបដូចគ្នា នោះទូលបង្គំក៏ប្រាកដយ៉ាងច្បាស់ថា វាគឺជាការដ៏ល្អប្រសើរយ៉ាងខ្លាំងណាស់ក្នុងការដែលទូលបង្គំប្រគល់ខ្លួនទូលបង្គំទៅកាន់ការស្រឡាញ់របស់ព្រះអង្គ ជាជាងការបន្តចូលទៅក្នុងភាពជាទាសករនៃភាពត្រេកត្រអាលរបស់ខ្លួន។ សេចក្ដីស្រឡាញ់របស់ព្រះអង្គធ្វើឲ្យទូលបង្គំស្កប់ស្កល់ចិត្ត ហើយក៏យកឈ្នះលើទូលបង្គំដែរ។ ប៉ុន្តែ ភាពត្រេកត្រអាលរបស់ទូលបង្គំធ្វើឲ្យទូលបង្គំសប្បាយ ហើយវាក៏ចាប់ទូលបង្គំធ្វើជាទាសករផងដែរ។ ហើយទូលបង្គំក៏មិនបានឆ្លើយតប នៅពេលដែលព្រះអង្គមានព្រះបន្ទូលមកកាន់ទូលបង្គំថា៖ «អ្នកដែលដេកលក់អើយ ចូរភ្ញាក់ឡើង ចូរក្រោកពីពួកមនុស្សស្លាប់ឡើង នោះព្រះគ្រីស្ទនឹងចាំងពន្លឺមកលើអ្នក»។[១៨]

ទោះបើព្រះអង្គបានបង្ហាញទូលបង្គំក្នុងគ្រប់ផ្លូវថា ព្រះបន្ទូលរបស់ទ្រង់ពិត ហើយទោះបើសេចក្ដីពិតបានធ្វើឲ្យទូលបង្គំទទួលជឿយ៉ាងស៊ប់ក៏ដោយ នោះទូលបង្គំក៏មិនមានការឆ្លើយតបអ្វីក្រៅពីថា៖ «ជិតហើយៗ សូមគ្រាន់តែទុកទូលបង្គំចោលតែមួយភ្លែតទៀតសិនចុះ»។ ប៉ុន្តែឃ្លា «ជិតហើយៗ» គឺមិនសំដៅទៅលើពេលវេលាបច្ចុប្បន្នទេ ហើយ «សូមគ្រាន់តែទុកទូលបង្គំចោលតែមួយភ្លែតទៀតសិនចុះ» ក៏បានពន្យារយ៉ាងយូរដែរ។ ក្នុងភាពឥតប្រយោជន៍ ទូលបង្គំ «បានត្រេកអរក្នុងក្រឹត្យវិន័យរបស់ព្រះអង្គតែខាងក្នុង» ខណៈពេលដែល «ក្រឹត្យវិន័យមួយផ្សេងទៀត ក្នុងអវយវៈរបស់ទូលបង្គំ កំពុងតែធ្វើសង្គ្រាមទាស់ប្រឆាំងនឹងគំនិតរបស់ទូលបង្គំ ហើយនាំឲ្យទូលបង្គំធ្លាក់ក្នុងភាពជាឈ្លើយទៅកាន់ក្រឹត្យវិន័យនៃអំពើបាបដែលនៅក្នុងអវយវៈរបស់ទូលបង្គំ»។ ដ្បិតក្រឹត្យវិន័យនៃអំពើបាបគឺជាអំពើរំលោភបំពាននៃទំនៀមទម្លាប់ ដែលតាមរយៈនោះ វាចាប់យកគំនិត ហើយឃាត់ទុក សូម្បីពេលដែលទាស់នឹងឆន្ទៈរបស់វាផ្ទាល់ក៏ដោយ។ ទោះជាយ៉ាងណាក្ដីក៏វាស័ក្តិសមក្នុងការឲ្យគេចាប់យក ពីព្រោះវាបានធ្លាក់ចូលក្នុងទំនៀមទម្លាប់ដោយស្ម័គ្រចិត្ត។ «ខ្ញុំនេះជាមនុស្សវេទនាណាស់! តើអ្នកណានឹងជួយខ្ញុំឲ្យរួចពី

១៨ អេភេសូរ ៥:១៤។

រូបកាយដែលតែងតែស្លាប់នេះបាន?»។ គ្មានអ្វីក្រៅពីព្រះគុណរបស់ព្រះអង្គតាមរយៈ
ព្រះយេស៊ូវគ្រីស្ទដែលជាព្រះអង្គសង្គ្រោះរបស់យើងឡើយ។[១៩]

---

១៩ រ៉ូម ៧:២២-២៥។

# ៣១

# សេចក្តីសង្គ្រោះ

១៣. ឱព្រះអម្ចាស់អើយ! ទ្រង់គឺជាជំនួយ និងជាព្រះអង្គប្រោសលោះរបស់ទូលបង្គំ។ ឥឡូវ ទូលបង្គំនឹងប្រកាស ហើយលន់តួក្នុងព្រះនាមរបស់ព្រះអង្គអំពីរបៀបដែលទ្រង់បានរំដោះទូលបង្គំចេញពីច្រវាក់នៃការប្រាថ្នាខាងឯផ្លូវភេទដែលទូលបង្គំបានជាប់ចំណងយ៉ាងខ្លាំង នឹងចេញពីភាពជាទាសករនៃលោកីយ៍ខាងឯទង្វើ។ ជារៀងរាល់ថ្ងៃការបារម្ភរបស់ទូលបង្គំក៏បានកើនឡើងៗ ខណៈពេលដែលទូលបង្គំបន្តរស់នៅជាធម្មតា។ ហើយពីមួយថ្ងៃទៅមួយថ្ងៃ ទូលបង្គំក៏កាន់តែចង់បានព្រះអង្គ។ ទូលបង្គំចូលរួមនៅក្នុងក្រុមជំនុំរបស់ព្រះអង្គដរាបណាទូលបង្គំមិនសូវរវល់ពេកជាមួយនឹងការងារ។ លោក អាលីពីស៍ បាននៅជាមួយទូលបង្គំ ហើយគាត់មិនមានការងារធ្វើទេបន្ទាប់ពីគាត់បានបម្រើជាចៅក្រមអស់រយៈពេលបីអាណត្តិ។ ពេលនោះគាត់កំពុងរង់ចាំអតិថិជនផ្ទាល់ខ្លួនដែលគាត់អាចលក់ការប្រឹក្សាខាងឯផ្លូវច្បាប់របស់គាត់ ដូចដែលទូលបង្គំកំពុងលក់សិល្បៈនៃវោហារសាស្ត្រសាធារណៈដែរ។

១៤. មានថ្ងៃមួយ លោក ភូនទីស៊ីអានូស៍ ក៏បានមកលេង ហើយជួបលោក អាលីពីស៍ និងទូលបង្គំនៅឯផ្ទះរបស់យើង។ គាត់ជាអ្នកមកពីស្រុកកំណើតដូចយើងពីប្រទេស

អាហ្វ្រិក ហើយគាត់ក៏មានឋានៈខ្ពស់ខាងតុលាការរបស់អភិរាជដែរ។ ទូលបង្គំមិនចាំយ៉ាងច្បាស់ថា តើគាត់ចង់បានអ្វីពីយើងនោះទេ។ ប៉ុន្តែ ខណៈពេលដែលយើងអង្គុយចុះ ជជែកគ្នា នោះគាត់ក៏កត់សម្គាល់អំពីសៀវភៅមួយក្បាលនៅលើតុរបស់យើង។ គាត់ក៏យកវាមកបើកមើល ហើយផ្ទុយពីការរំពឹងរបស់គាត់ គាត់ក៏ឃើញសំបុត្ររបស់សាវ័កប៉ុល។ ពីព្រោះដាដំបូងគាត់បានគិតថា វាទំនងជាសៀវភៅវោហារសាស្ត្រដ៏នឿយហត់មួយរបស់ទូលបង្គំ។ បន្ទាប់មក គាត់ក៏មើលមកកាន់ទូលបង្គំដោយញញឹម ហើយលើកឡើងអំពីការពេញចិត្តរបស់គាត់។ គាត់ពិតជាគ្រីស្ទបរិស័ទដ៏ពិតមែន។ ហើយជារឿយៗគាត់ក៏ឱនក្រាបខ្លួនចុះនៅមុខព្រះភ័ក្ត្ររបស់ព្រះអង្គ ដែលជាព្រះជាម្ចាស់របស់យើង ក្នុងក្រុមជំនុំដោយអធិស្ឋានជារៀងរាល់ថ្ងៃជាប្រចាំ។ ពេលទូលបង្គំបានលើកឡើងថាទូលបង្គំបានចំណាយពេលជាច្រើនក្នុងការសិក្សាព្រះបន្ទូលទាំងនេះ នោះគាត់ក៏បានប្រាប់ទូលបង្គំអំពីលោក អែនថូនី ដែលជាតាបសម្នាក់ពីប្រទេសអេស៊ីព្ទ។ គាត់គឺជាបុគ្គលដ៏ល្បីល្បាញយ៉ាងខ្លាំងម្នាក់ក្នុងចំណោមអ្នកបម្រើនានារបស់ព្រះអង្គ។ ប៉ុន្តែ នៅពេលនោះទូលបង្គំមិនស្គាល់គាត់ទេ។ នៅពេលដែលលោក ភូនទីស៊ីអានូស៍ ឃើញថាទូលបង្គំមិនស្គាល់គាត់ នោះគាត់ក៏ប្រាប់យើងបន្ថែមទៀតអំពីគាត់ ដោយរ៉ាយរ៉ាប់ប្រាប់យើងអំពីដំណើររឿងដ៏ឧត្តុង្គឧត្តមរបស់បុរសនេះ។ យើងពិតជាមានការស្ញប់ស្ញែងមែនក្នុងការឮអំពីព័ន្ធកិច្ចដ៏អស្ចារ្យរបស់ព្រះអង្គដែលត្រូវបានបង្ហាញឡើងយ៉ាងពេញទីក្នុងពេលវេលាដែលបានកន្លងផុតទៅថ្មីៗនេះ។ សូម្បីតែតាមរយៈបទពិសោធន៍របស់យើងក្នុងជំនឿ និងក្រុមជំនុំដ៏ពិត។ យើងមានការភ្ញាក់ផ្អើលដោយសារចំណុចដ៏អស្ចារ្យទាំងនេះ ហើយលើសពីនោះគឺថាយើងមិនដែលធ្លាប់ឮអំពីវាពីមុនសោះ។

១៦. ខណៈពេលដែលគាត់កំពុងនិយាយ។ ឱព្រះអម្ចាស់អើយ! ទ្រង់បានបង្វែរចំណាប់អារម្មណ៍របស់ទូលបង្គំមកកាន់ទូលបង្គំផ្ទាល់។ ហើយព្រះអង្គបានដាក់ទូលបង្គំមុខទល់នឹងមុខជាមួយនឹងខ្លួនឯង ដើម្បីឲ្យទូលបង្គំអាចទំនងជាឃើញថាខ្លួនមានភាពអាក្រក់ខ្លាំងប៉ុណ្ណាខាងឯព្រលឹងវិញ្ញាណ អំពីរបៀបមិនស្មោះត្រង់ និងភាពស្មោកគ្រោកដែលមានពេញទៅដោយការឈឺចាប់ និងដំបៅជាច្រើន។ ហើយទូលបង្គំក៏មើលមកកាន់ខ្លួនឯង ហើយក៏ស្អប់ខ្លួនឯងដែរ។ ប៉ុន្តែ គ្មានកន្លែងណាដែលអាចឲ្យទូលបង្គំពួនពីខ្លួនឯងបានឡើយ។ ទោះបើទូលបង្គំបានព្យាយាមមើលចេញពីខ្លួនឯងក៏ដោយ។ រឿងរបស់

លោក ភូនទីស៊ីអានូស៍ ក៏បន្តទៅមុខទៀត។ ហើយព្រះអង្គក៏បានបោះទូលបង្គំនៅមុខភ្នែកខ្លួនឯង ដើម្បីឲ្យទូលបង្គំអាចរកឃើញថាខ្លួនមានអំពើបាប ហើយស្អប់វា។ ទូលបង្គំបានស្គាល់អំពើបាបរបស់ខ្លួន ប៉ុន្តែទូលបង្គំបានធ្វើពុតហាក់បីដូចជាថាខ្លួនមិនស្គាល់។ ទូលបង្គំបានបដិសេធន៍ដោយមិនទទួលស្គាល់អំពីអំពើអាក្រក់របស់ខ្លួន ហើយក៏បានព្យាយាមបំភ្លេចវាចោលដែរ។

១៧. ប៉ុន្តែ ពេលនោះ ខណៈពេលដែលទូលបង្គំកាន់តែឮអំពីអស់អ្នកដែលស្រឡាញ់ព្រះអង្គនោះទូលបង្គំក៏កាន់តែចាប់ផ្ដើមស្អប់ខ្លួនឯង ពេលប្រៀបធៀបខ្លួនឯងជាមួយនឹងពួកគេ។ ប្រមាណជាង១២ឆ្នាំបានកន្លងផុតទៅហើយ ការទូលបង្គំមានអាយុ១៩ឆ្នាំ តាំងពីពេលដែលទូលបង្គំអានសៀវភៅ «ហរ្ទិនស៊ីណូស៍» របស់លោកគ្រូ ស៊ិសារ៉ូ។ ហើយវាក៏បានបណ្ដាលឲ្យទូលបង្គំចង់ប្រាថ្នាបានប្រាជ្ញា។ ប៉ុន្តែ សូម្បីតែមកដល់ពេលនោះក៏ទូលបង្គំនៅបន្តពន្យារខ្លួនក្នុងការប្ដេជ្ញាខ្លួន ដើម្បីស្វះស្វែងរកប្រាជ្ញារបស់ព្រះអង្គ ពីព្រោះទូលបង្គំមិនទាន់ចង់បោះបង់ចោលភាពអរសប្បាយរបស់លោកីយ៍នេះនៅឡើយ។ ប៉ុន្តែទូលបង្គំគួរតែជ្រើសរើសយក ការស្វែងរកប្រាជ្ញាក្នុងការប្រៀបធៀបទៅនឹងការមានទ្រព្យសម្បត្តិទាំងអស់ និងនគរនៃលោកីយ៍នេះ។ ទូលបង្គំគួរជ្រើសរើសយកការស្វែងរកប្រាជ្ញាលើសជាងការអរសប្បាយខាងឯផ្លូវភេទដែលទូលបង្គំអាចទទួលបានពេលណាក៏បាន។ ប៉ុន្តែ ទូលបង្គំជាបុរសវ័យក្មេងម្នាក់ដែលមិនសប្បាយចិត្ត។ គ្មានសង្ឃឹមសូម្បីតែតាំងពីពេលនៅក្មេង កាលនោះបង្គំបានទូលសូមព្រះអង្គឲ្យទូលបង្គំមានភាពបរិសុទ្ធខាងឯផ្លូវភេទ ហើយក៏បានអធិស្ឋានថា៖ «សូមប្រទានឲ្យទូលបង្គំមានសេរីភាពពីការញៀននឹងការរួមភេទ ហើយឲ្យមានការគ្រប់គ្រងលើខ្លួនឯង ប៉ុន្តែមិនមែនឥឡូវនេះទេ»។ ពីព្រោះទូលបង្គំខ្លាចថា ព្រះអង្គនឹងទំនងជាព្រះសណ្ដាប់ឮសេចក្ដីអធិស្ឋានរបស់ទូលបង្គំលឿនពេក ហើយថាព្រះអង្គនឹងទំនងជាព្យាបាលជំងឺនៃភាពត្រេកត្រអាលរបស់ទូលបង្គំលឿនពេក ដែលទូលបង្គំបានប្រាថ្នាចង់ផ្គត់ផ្គង់វាជាជាងការកាត់ផ្ដាច់វាចោល។

១៨. ពិតណាស់! ជម្រៅនៅខាងក្នុងទូលបង្គំមានការច្របូកច្របល់។ ខណៈពេលដែលលោក ភូនទីស៊ីអានូស៍ កំពុងប្រាប់អំពីរឿងរបស់គាត់ នោះទូលបង្គំក៏មានពេញទៅដោយភាពអាម៉ាស់។ ហើយពេលដែលគាត់បញ្ចប់រឿងរបស់គាត់ គាត់ក៏បានសម្រេចការងារដែលគាត់បានមកធ្វើ ហើយក៏បានចាកចេញបាត់ទៅ។ ហើយបន្ទាប់មកទូលបង្គំក៏

ចាប់ផ្តើមសួរសំណួរខ្លួនឯង តើមានអ្វីខូចក្នុងទូលបង្គំ? តើអ្វីទៅក្នុងទូលបង្គំដែលពិតជារាំងទូលបង្គំពីការដើរតាមព្រះអង្គ?» ទោះជាយ៉ាងណាក៏ដោយ ក៏ព្រលឹងរបស់ទូលបង្គំនៅតែដកថយចេញ។ វាក៏បានបដិសេធន៍ ហើយក៏មិនព្រមមានការខិតខំប្រឹងប្រែងផងដែរ។ ការពិភាក្សាទាំងអស់ត្រូវបានលើកឡើងមក ដើម្បីជជែកវែកញែកនឹងការដើរតាមព្រះអង្គ ប៉ុន្តែវាក៏ទាស់ប្រឆាំងទាំងអស់។ ទោះជាយ៉ាងណាក៏ដោយក៏វានៅតយុទ្ធ ដោយមានការភ័យខ្លាចថានឹងត្រូវកាត់ចេញពីទម្លាប់ខាងឯផ្លូវភេទចោល។ ទម្លាប់ដែលកំពុងបង្កឲ្យព្រលឹងទូលបង្គំខ្ទះខ្ទាយរហូតដល់ស្លាប់។

១៩. ខណៈពេលដែលការតយុទ្ធដ៏ធំនេះកំពុងតែកើតឡើងក្នុងដួងចិត្តរបស់ទូលបង្គំនោះទូលបង្គំក៏ទៅរកលោក អាលីពីស៍ យ៉ាងលឿន ហើយស្រែកថា៖ «តើមានអ្វីខូចក្នុងយើង? តើនេះជាអ្វី? តើឯងបានឮរឿងដែរឬទេ? មនុស្សអវិជ្ជាកំពុងតែដើរតាមសេចក្តីពិតហើយក៏កំពុងទទួលបានស្ថានសួគ៌។ ហើយយើង ដោយមានការរៀនសូត្រជាច្រើន យើងមិនមានភាពក្លាហានល្មមគ្រប់គ្រាន់ ដើម្បីស្គាល់សេចក្តីពិត។ បើគ្រាន់តែដោយសារអ្នកដទៃបានទៅពីមុនយើង នោះតើយើងមានការអាម៉ាស់ក្នុងការដើរតាមដែរមែនឬ? ផ្ទុយពីនោះ តើយើងមិនគួរមានការអាម៉ាស់ ដោយសារយើងមិនបានព្យាយាមដើរតាមទេឬ?»។ ទូលបង្គំបាននិយាយដោយមិនបានគិតជាមុន ប៉ុន្តែចេញពីភាពរំភើបរបស់ទូលបង្គំ នោះឯងគឺជាអ្វីដែលទូលបង្គំបាននិយាយទៅកាន់គាត់។ ហើយគាត់ក៏បានមើលមកកាន់ទូលបង្គំក្នុងភាពស្ងៀមស្ងាត់ដោយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ដ្បិតអ្វីដែលខ្ញុំបានលើកឡើងគឺចម្លែកណាស់។ ភាសាទឹកមុខ ភ្នែក និងសំណេរនៃសំឡេងរបស់ទូលបង្គំបានលើកឡើងយ៉ាងច្បាស់ជាងអ្វីដែលទូលបង្គំបាននិយាយទៅទៀត។

មានសួនច្បារតូចមួយជាប់នឹងផ្ទះដែលយើងរស់នៅ។ ខ្យល់បក់បោកនៅក្នុងដួងចិត្តរបស់ទូលបង្គំបានបណ្តាលឲ្យទូលបង្គំចេញទៅសួនច្បារនោះ ដែលទំនងជានឹងមិនមានអ្នកណាមកឆាឆៅការតយុទ្ធដ៏ឆេះឆួលដែលទូលបង្គំកំពុងតែប្រឈមមុខជាមួយនឹងខ្លួនឯងនោះទេ។ នៅទីនោះ ទូលបង្គំអាចនៅតែឯង រហូតដល់ទូលបង្គំឈានដល់ការធ្វើសេចក្តីសន្និដ្ឋាន។ ហើយព្រះអង្គបានជ្រាបហើយអំពីសេចក្តីសន្និដ្ឋាននោះ ទោះបើទូលបង្គំមិនទាន់ដឹង។ ទូលបង្គំកំពុងតែឆ្កួតជាមួយនឹងការភ្លីភ្លើដែលនឹងនាំឲ្យទូលបង្គំជាលា។ ទូលបង្គំកំពុងតែស្លាប់ក្នុងសេចក្តីស្លាប់ដែលនាំឲ្យទូលបង្គំមានជីវិត។

ទូលបង្គំស្គាល់អំពើអាក្រក់ដែលមានក្នុងខ្លួន ប៉ុន្តែ ទូលបង្គំមិនស្គាល់សេចក្ដីល្អដែលព្រះអង្គហៀបនឹងបង្កើតក្នុងទូលបង្គំទេ។

ទូលបង្គំក៏បានរត់ទៅក្នុងសួនច្បារ។ លោក អាលីពីស៍ បានតាមពីក្រោយទូលបង្គំ។ ហើយវត្តមានរបស់គាត់មិនមែនជាការឆាឆៅចំពោះការនៅតែឯងរបស់ទូលបង្គំទេ។ ដ្បិតតើឲ្យគាត់អាចចោលទូលបង្គំក្នុងស្ថានភាពបែបនោះបានដោយរបៀបណា? យើងអង្គុយចុះជាមួយគ្នាយ៉ាងឆ្ងាយតាមដែលអាចធ្វើបានពីផ្ទះរបស់យើង។ ទូលបង្គំមានទុក្ខកង្វល់យ៉ាងខ្លាំងក្នុងព្រលឹង ខឹងខ្លួនឯងដែលមិនបានឈានចូលការតាំងសេចក្ដីសញ្ញាជាមួយនឹងព្រះអង្គ។ ព្រលឹងទូលបង្គំក៏ស្រែកយំថាទូលបង្គំគួរតែចូល។ ផ្លូវទៅដល់ទីនោះគឺមិនមែនតាមរយៈនាវា រទេះ ឬក៏ការដើរនោះទេ។ ពិតណាស់! ដំណើរមិនឆ្ងាយដូចការឆ្ងាយពីចម្ងាយពីផ្ទះរបស់ទូលបង្គំមកកន្លែងដែលទូលបង្គំកំពុងអង្គុយនោះឡើយ។ មានចំណុចដ៏ចាំបាច់តែមួយគត់ក្នុងការឈានទៅដល់ទីកន្លែងនោះ គឺការស្ម័គ្រចិត្តចេញទៅ។ ប៉ុន្តែដាច់ខាត! វាត្រូវតែជាឆន្ទៈដ៏ខ្លាំង និងតែមួយ មិនមែនការភ្ញាក់ផ្អើល ឬក៏ការទៅផ្លូវនេះ ឬផ្លូវនោះនោះទេ។

២២. ខណៈពេលដែលទូលបង្គំកំពុងវែកញែកថា តើគួរបម្រើព្រះអម្ចាស់ដែលជាព្រះជាម្ចាស់របស់ទូលបង្គំឥឡូវនេះ ដូចដែលទូលបង្គំបានមានគោលបំណងចង់ធ្វើតាំងពីយូរមកម្ល៉េះ ក្នុងពេលតែមួយទូលបង្គំក៏មាន និងក៏មិនមានឆន្ទៈធ្វើផងដែរ។ ទូលបង្គំមានឆន្ទៈទាំងស្រុង ហើយក៏មិនមានឆន្ទៈទាំងស្រុងផងដែរ។ ហេតុដូច្នេះ ទូលបង្គំក៏ស្ថិតក្នុងការធ្វើសង្គ្រាមជាមួយនឹងខ្លួនឯង ហើយក៏បានហែកបំបែកខ្លួនឯងទៀតផង។ ហើយការមិនឯកភាពដ៏ឃោរឃៅនេះក៏កំពុងតែជំទាស់នឹងឆន្ទៈរបស់ទូលបង្គំដែរ។ ទោះជាយ៉ាងណាក៏ដោយក៏នេះមិនមែនជាការបើកសម្តែងអំពីឆន្ទៈរបស់បុគ្គលណាម្នាក់ផ្សេងទៀតនៅក្នុងឆន្ទៈរបស់ទូលបង្គំដែរ ផ្ទុយទៅវិញ វាគឺជាទារុណកម្មនៃការរងទុក្ខតាមរយៈគំនិតរបស់ទូលបង្គំផ្ទាល់។ ហើយវាក៏មិនមែនទូលបង្គំទេដែលបាននាំមកនូវការដាក់ទោសនេះ ប៉ុន្តែគឺអំពើបាបដែលមានក្នុងទូលបង្គំទៅវិញ។ ទារុណកម្មនៃអំពើបាបដែលលោក អ័ដាម បានជ្រើសរើសដោយសេរី ហើយទូលបង្គំក៏ជាកូនម្នាក់របស់លោក អ័ដាម ដែរ។

២៥. ទូលបង្គំឈឺចុកចាប់ដល់ក្រពះ ហើយក៏ទទួលបានការធ្វើទុក្ខ។ ទូលបង្គំក៏បានបន្ទោសខ្លួនឯងយ៉ាងខ្លាំងជាងដែលធ្លាប់ធ្វើពីមុនៗទៅទៀត។ ទូលបង្គំកំពុងតែរមៀល

ហើយបែរទៅនេះទៅនោះក្នុងច្រវាក់របស់ទូលបង្គំរហូតដល់វាដាច់ទាំងស្រុង។ វាក្រុងទូលបង្គំបានតែបន្តិចទេ ប៉ុន្តែទូលបង្គំបន្តស្ថិតនៅក្នុងការក្រុងរបស់វានៅឡើយ។ ប៉ុន្តែ ឱព្រះអម្ចាស់អើយ! ព្រះអង្គបានសង្កត់ចំណុចដ៏ជ្រៅបំផុតនៃដួងចិត្តរបស់ទូលបង្គំដោយក្ដីមេត្តាករុណាយ៉ាងធ្ងន់ធ្ងររបស់ទ្រង់។ តាមរយៈការចម្រើនការភ័យខ្លាចរបស់ទូលបង្គំ និងភាពអាម៉ាស ដើម្បីការពារទូលបង្គំពីការបាត់បង់ការប្ដេជ្ញាចិត្តក្នុងការប្រឆាំងនឹងសេចក្ដីប្រាថ្នាខាងឯលោកីយ៍របស់ទូលបង្គំ។ ព្រះអង្គបានធ្វើបែបនោះ ដើម្បីឲ្យទូលបង្គំខិតខំព្យាយាម និងដើម្បីឲ្យចំណងចុងក្រោយដ៏តូចបំផុតនៃច្រវាក់របស់ទូលបង្គំបានដាច់ចេញ។

ទូលបង្គំបាននៅបន្តនិយាយមកកាន់ខ្លួនឯងថា៖ «ឥឡូវនេះគឺជាពេលវេលា។ ឥឡូវនេះគឺជាពេលវេលា»។ ហើយខណៈពេលដែលទូលបង្គំបាននិយាយដូច្នោះ នោះទូលបង្គំបានឈានចូលក្នុងដំណើរការនៃការធ្វើការសម្រេចចិត្តយ៉ាងមុឺងម៉ាត់រួចហើយ។ ទូលបង្គំបានជិតធ្វើការសម្រេចចិត្តយ៉ាងខ្លាំង ប៉ុន្តែបន្ទាប់មកទូលបង្គំមិនបានធ្វើសោះ។ ទោះជាយ៉ាងណាក្តីក៏ទូលបង្គំមិនបានធ្លាក់ចូលស្ថានភាពចាស់របស់ទូលបង្គំដែរ ប៉ុន្តែបានឈរនៅម្ខាងអស់មួយរយៈ ហើយក៏បានព្យាយាមដកដង្ហើមជាថ្មីម្ដងទៀត។ បន្ទាប់មកទូលបង្គំក៏បានព្យាយាមម្ដងទៀត ហើយទូលបង្គំក៏ជិតឈានដល់គោលបំណងរបស់ខ្លួនដែរ។ ទោះជាយ៉ាងណាក៏ដោយក៏ទូលបង្គំមិនបានឈានដល់ ឬក៏ចាប់យកគោលដៅនោះបានដែរ។ ពីព្រោះទូលបង្គំមានការស្ទាក់ស្ទើរក្នុងការឲ្យសេចក្ដីស្លាប់ស្លាប់ក្នុងទូលបង្គំ ដើម្បីឲ្យជីវិតរស់ក្នុងទូលបង្គំ។ ហើយរបៀបអាក្រក់ដែលទូលបង្គំមានទម្លាប់ជាមួយវាក៏ខ្លាំងក្នុងទូលបង្គំជាងរបៀបដែលទូលបង្គំមិនទាន់បានសាកល្បង។ ខណៈពេលដែលទូលបង្គំកាន់តែឈានជិតដល់ចំណុចដែលទូលបង្គំនឹងប្រែទៅជាមនុស្សថ្មី នោះវាក៏កាន់តែធ្វើឲ្យទូលបង្គំមានការភ័យខ្លាចក្នុងចិត្តទូលបង្គំជាងមុនដែរ។ ទោះជាយ៉ាងណាក៏ដោយក៏វាមិនបានបណ្ដាលឲ្យទូលបង្គំបែរចេញពីទូលបង្គំដែរ ប៉ុន្តែវាគ្រាន់តែក្រុងទូលបង្គំក្នុងការថប់បារម្ភប៉ុណ្ណោះ។

២៦. តាមពិតទៅ ទូលបង្គំនៅមានចំណាប់អារម្មណ៍ជាមួយនឹងអំពើបាបដែលទូលបង្គំនៅស្រឡាញ់ ដែលជាអំពើបាបដែលមានពេញទៅដោយភាពឥតប្រយោជន៍ដ៏ឥតប្រយោជន៍។ ពួកវាបានព្យាយាមទាញទូលបង្គំចូលភាពត្រេកត្រអាលខាងឯសាច់ឈាម។ ហើយបានបន្តខ្សឹបខ្សៀវមកកាន់ទូលបង្គំថា៖ «តើលោកនឹងចេញពីពួកយើងមែនឬ? តើ

លោកនឹងចេញពីពួកយើងជារៀងរហូតមែនឬ? តើលោកមិនដឹងទេថា ពេលលោកចាកចេញពីយើង នោះលោកមិនអាចបកត្រឡប់មករកយើងវិញបានទេ?»។ ពួកគេបានបន្តនិយាយដូចនោះមកកាន់ទូលបង្គំ ហើយលើកជាសំណើមកកាន់ទូលបង្គំថាឲ្យធ្វើនេះ ឬធ្វើនោះ។ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! តើពួកគេកំពុងតែលើកជាសំណើអ្វីទៅ? សូមអនុញ្ញាតឲ្យសេចក្ដីមេត្តាករុណារបស់ព្រះអង្គការពារព្រលឹងនៃអ្នកបម្រើរបស់ទ្រង់ ពីអំពើអសីលធម៌ និងភាពអាម៉ាស់ដែលពួកគេបានលើកឡើង! ទូលបង្គំមិនសូវជាបានឮពួកគេនោះទេ ពីព្រោះពួកគេមិនបានបង្ហាញខ្លួនជាសាធារណៈមកកាន់ទូលបង្គំឡើយ។ ប៉ុន្តែ ពួកគេបាននិយាយយ៉ាងខ្សឹបៗមកកាន់ទូលបង្គំ ហាក់បីដូចជាថា ពួកគេបាននៅពីក្រោយទូលបង្គំអញ្ចឹង។ ពួកគេបានទាញទូលបង្គំយ៉ាងសម្ងាត់ ពេលទូលបង្គំបានដើរចេញ ហើយព្យាយាមធ្វើឲ្យទូលបង្គំមើលក្រោយទៅកាន់ពួកគេវិញ។ ពួកគេបានព្យាយាមកាន់ទូលបង្គំ។ ហើយទូលបង្គំមានការស្ទាក់ស្ទើរក្នុងការដោះលែងខ្លួនចេញពីពួកគេ ហើយបដិសេធន៍ពួកគេទាំងស្រុង ហើយលោតទៅកន្លែងដែលព្រះអង្គកំពុងតែត្រាស់ហៅទូលបង្គំឲ្យទៅ។ ដ្បិតទម្លាប់ដែលទូលបង្គំមិនអាចគ្រប់គ្រងលើបានកំពុងតែនិយាយមកកាន់ទូលបង្គំថា៖ «តើឯងគិតថាឯងអាចបន្តរស់នៅដោយគ្មានពួកគេបានមែនឬ?»

២៧. ប៉ុន្តែ បន្ទាប់មកសំឡេងនៃទម្លាប់ពុតិចៗណាស់។ ទូលបង្គំនៅខ្លាចនៅឡើយក្នុងការទៅទីកន្លែងដែលទូលបង្គំបានដាក់ភ្នែកលើថាទៅ។ ហើយខណៈពេលដែលទូលបង្គំឈរនៅក្បែររបាំងដោយមានការញាប់ញ័រ នៅម្ខាងទៀត នោះទូលបង្គំអាចឃើញភាពស្រស់ស្អាតបរិសុទ្ធរបស់ប្រាជ្ញា ដែលកំពុងស្រែកហៅឲ្យទូលបង្គំឆ្លងទៅ ហើយកុំឲ្យមានការស្ទាក់ស្ទើរទៀត។ ប៉ុន្តែ ទូលបង្គំនៅខ្លាចក្នុងការឈានទៅមុខ។ ប្រាជ្ញាបានទាញដៃដ៏បរិសុទ្ធ ដើម្បីទទួល និងឱបទូលបង្គំ ដែលមានពេញទៅដោយគំរូល្អៗជាច្រើន។ មានមនុស្សវ័យក្មេងជាច្រើននាក់ទាំងប្រុសទាំងស្រី អាយុខុសៗគ្នា មេម៉ាយ និងពោះម៉ាយចាស់ៗ និងស្ត្រីៗព្រហ្មចារី ហើយប្រាជ្ញាផ្ទាល់កំពុងតែនៅក្នុងចំណោមពួកគេ។ មិនមែនជាស្ត្រីអា ប៉ុន្តែជាម្ដាយដែលមានកូនៗជាច្រើននាក់។ អំណររបស់នាងគឺមកពីព្រះអម្ចាស់ដែលជាព្រះស្វាមីរបស់នាង។ ហើយប្រាជ្ញាក៏បានញញឹមដាក់ទូលបង្គំដោយមានការញញឹមដែលជំទាស់ហាក់បីដូចជាថា៖ «តើលោកមិនអាចធ្វើនូវអ្វីដែលបុរស និងស្ត្រីវ័យក្មេងទាំងនេះបានធ្វើហើយមែនឬ? តើលោកគិតថា ពួកគេបានធ្វើការនោះដោយខ្លួនឯង

ដោយមិនមានជំនួយពីព្រះអម្ចាស់ដែលជាព្រះជាម្ចាស់របស់ពួកគេមែនឬ? ព្រះអម្ចាស់ដែលជាព្រះជាម្ចាស់របស់ពួកគេបានឲ្យពួកគេមកកាន់យើង។ ហេតុអ្វីបានជាលោកពឹងលើកម្លាំងរបស់ខ្លួនឯងផ្ទាល់ ហើយចេញពីការនោះមិនមានលទ្ធភាពក្នុងការឈរ? ចូរបោះខ្លួនលោកលើទ្រង់ចុះ ហើយកុំភ័យខ្លាចឡើយ។ ព្រះអង្គនឹងមិនងាកចេញ ដើម្បីឲ្យលោកធ្លាក់ចុះទេ។ ចូរបោះខ្លួនលោកលើទ្រង់ដោយកុំភ័យខ្លាច ដ្បិតព្រះអង្គនឹងចាប់លោក ហើយនិងព្យាបាលលោក»។ ហើយទូលបង្គំក៏មានពេញទៅដោយភាពអាម៉ាស់ពីព្រោះទូលបង្គំបានបន្តស្តាប់ «ភាពឥតប្រយោជន៍» ទាំងនោះ ហើយក៏មានការស្ទាក់ស្ទើរ។ ជាថ្មីម្តងទៀត ប្រាជ្ញាក៏បាននិយាយមកកាន់ទូលបង្គំថា៖ «ចូរឈប់ស្តាប់ភាពខ្សឹបខ្សៀវដែលមិនស្អាតទាំងនោះរបស់លោក ដើម្បីឲ្យពួកវាងាប់ទៅបាន។ ពួកគេកំពុងតែប្រាប់លោកអំពីការអរសប្បាយផ្សេងៗដ៏អស្ចារ្យ ប៉ុន្តែមិនមែនយកតាមក្រឹត្យវិន័យនៃព្រះអម្ចាស់ដែលជាព្រះជាម្ចាស់របស់លោកទេ»។

ការតយុទ្ធនេះដែលកំពុងតែកើតឡើងក្នុងដួងចិត្តរបស់ទូលបង្គំគឺមិនមែនជាអ្វី ក្រៅពីការប្រកួតប្រជែងរវាងខ្លួនឯងទាស់នឹងខ្លួនឯងទេ។ ហើយលោក អាលីពីស៍ បានឈរនៅក្បែរទូលបង្គំ ហើយបានចាំយ៉ាងស្ងៀម ដើម្បីមើលលទ្ធផលនៃភាពក្តុកក្តួលដ៏ចម្លែករបស់ទូលបង្គំ។

២៨. ទូលបង្គំក៏ឈានដល់ពេលវេលានៃការឆ្លុះបញ្ចាំងយ៉ាងជ្រាលជ្រៅលើខ្លួនឯង ហើយក៏បានដកចេញនូវអាថ៌កំបាំងដ៏ងងឹតៗមួយចំនួនចេញពីព្រលឹងរបស់ខ្លួន។ ភាពវេទនាទាំងអស់របស់ទូលបង្គំក៏បានគរឡើងនៅពីមុខភ្នែកនៃដួងចិត្តរបស់ទូលបង្គំ។ ហើយព្យុះដ៏កំណាចមួយក៏កំពុងតែកើតឡើង ដែលហែហមជាមួយនឹងភ្លៀងដ៏សាហាវនៃទឹកភ្នែក។ ទូលបង្គំក៏បានចុះចូលទាំងស្រុង ហើយក៏បានចាប់ផ្តើមយំ និងកាន់ទុក្ខ។ ទូលបង្គំក៏ចេញពីវត្តមានរបស់លោក អាលីពីស៍។ ពីព្រោះទូលបង្គំមានអារម្មណ៍ថា ការនៅតែឯងគឺជាអ្វីដែលស័ក្តិសមពេលដែលទូលបង្គំកំពុងតែយំ។ ទូលបង្គំបានចេញឆ្ងាយល្មម ដល់ថ្នាក់ទូលបង្គំមិនមានអារម្មណ៍អំពីវត្តមានរបស់គាត់ ដើម្បីកុំឲ្យគាត់ធ្វើឲ្យទូលបង្គំបែកស្មារតី។ នោះគឺជាអ្វីដែលទូលបង្គំមានអារម្មណ៍នៅកាលនោះ ហើយគាត់ក៏យល់ដែរ។ ទូលបង្គំគិតថា ទូលបង្គំទំនងជាបាននិយាយអ្វីមួយ មុនទូលបង្គំបានចាប់ផ្តើមធ្វើការលន់តួ។ គាត់យល់ពីចំណុចនោះចេញពីសំណេរនៃសំឡេងរបស់ទូលបង្គំ។ ពីព្រោះ

ទូលបង្គំក៏បានចាប់ផ្ដើមអួលដើមទ្រូងដោយសារការយំហើយ។ ហេតុដូច្នេះហើយបានជាគាត់បន្តនៅកន្លែងដែលយើងបានអង្គុយជាមួយគ្នាពីមុន ដោយមានការភ្ញាក់ផ្អើលយ៉ាងខ្លាំងក្លា។ ទូលបង្គំក៏បានទម្លាក់ខ្លួនចុះក្រោមដើមល្វាមួយ ដោយមិនដឹងថាទូលបង្គំបានទៅដល់ទីនោះ ហើយទឹកភ្នែករបស់ទូលបង្គំក៏បានចាប់ផ្ដើមហូរយ៉ាងសេរី។ ចរន្តទឹកភ្នែករបស់ទូលបង្គំក៏បានហូរយ៉ាងលឿន ដែលនោះគឺជាយញ្ញបូជាចំពោះព្រះអង្គដែលទ្រង់ទទួលយក។ ហើយពិតណាស់! ជាមួយនឹងពាក្យពេចន៍ទាំងនេះ និងនៅក្នុងស្ថានភាពនោះ ទូលបង្គំក៏ស្រែកយំទៅកាន់ព្រះអង្គថា៖ «ឱព្រះយេហូវ៉ាអើយ! តើដល់កាលណាទៀត? តើព្រះហឫទ័យប្រចណ្ឌរបស់ព្រះអង្គនៅតែឆេះដូចភ្លើងទៀតឬ? សូមកុំនឹកចាំអំពើទុច្ចរិត ដែលយើងខ្ញុំធ្វើពីដើមឡើយ»។[១] ដ្បិតទូលបង្គំមានអារម្មណ៍ថា ទូលបង្គំស្ថិតនៅក្រោមភាពជាឈ្លើយរបស់ពួកវានៅឡើយ។ ទូលបង្គំក៏ធ្វើសម្រែកយំដែលពេញទៅដោយទុក្ខព្រួយនេះឡើង៖ «តើដល់កាលណាទៀត? តើដល់កាលណាទៀត? ថ្ងៃស្អែក និងថ្ងៃបន្ទាប់ពីថ្ងៃនេះមែនឬ? ហេតុអ្វីបានជាមិនឥឡូវនេះ? ហេតុអ្វីបានជាមិនកម្ចាត់ចោលជីវិតមិនបរិសុទ្ធរបស់ខ្លួននៅវេលាម៉ោងនេះភ្លាមអញ្ចឹង?»។

២៩. ទូលបង្គំបានលើកឡើងអំពីចំណុចទាំងនោះ ហើយក៏កំពុងតែយំដោយមានកំហុសឆ្គងយ៉ាងអាក្រក់ក្នុងដួងចិត្តរបស់ខ្លួន ហើយភ្លាមនោះទូលបង្គំក៏ឮសំឡេងរបស់ក្មេងប្រុស ឬក៏ក្មេងស្រីម្នាក់។ ទូលបង្គំមិនប្រាកដថាមួយណានោះទេ។ សំឡេងនោះចេញមកពីផ្ទះអ្នកជិតខាង។ សូត្រឃ្លានេះម្ដងហើយម្ដងទៀត៖ «យកវាឡើង ហើយអានវាចុះ! យកវាឡើង ហើយអានវាចុះ!»។[២] ភ្លាមៗនោះទូលបង្គំក៏ឈប់យំ ហើយក៏បានចាប់ផ្ដើមឆ្ងល់ថា តើឃ្លានេះគឺជាផ្នែកមួយនៃល្បែងក្មេងៗលេងមែនឬ។ ប៉ុន្តែ ទូលបង្គំមិនបានចាំថា វាជាឃ្លាដែលទូលបង្គំធ្លាប់ឮពីមុននោះទេ។ ដូច្នេះ ទូលបង្គំក៏ទប់ទឹកភ្នែក ហើយងើបឈរឡើង។ ហើយទូលបង្គំមិនអាចគិតអំពីអ្វីផ្សេងទៀត ក្រៅពីការជឿថា នេះគឺជាបញ្ជាពីព្រះជាម្ចាស់ឲ្យបើកព្រះគម្ពីរ ហើយអាន។ ជាពិសេសអត្ថបទដំបូងដែលទូលបង្គំទំនងជារកឃើញ។ ដ្បិតទូលបង្គំបានឮអំពីលោក អែនថូនី ដែលបានចូលទៅក្នុងក្រុមជំនុំដោយចៃដន្យ ខណៈពេលដែលគេកំពុងតែអានអំពីដំណឹងល្អ។[៣] ហើយគាត់ក៏បានទទួលការ

---

១ ទំនុកតម្កើង ៦:៣; ៧៩:៥, ៨។

២ នេះគឺជាឃ្លាដ៏ល្បីមួយ "Tolle, lege; tolle, lege"។

៣ ទំនងលោក ភូនទីស៊ីអានូស៍ បានប្រាប់អំពីរឿងនេះក្នុងការសន្ទនាពីមុនរបស់ពួកគេ។

ដាស់តឿននោះហាក់បីដូចជាថាអ្វីដែលកំពុងអាននោះគឺជាការនិយាយមកកាន់គាត់ផ្ទាល់៖ «បើអ្នកចង់ឲ្យបានគ្រប់លក្ខណ៍ ចូរទៅលក់ទ្រព្យសម្បត្តិរបស់អ្នក ហើយយកលុយទៅចែកឲ្យអ្នកក្រទៅ នោះអ្នកនឹងមានទ្រព្យសម្បត្តិនៅស្ថានសួគ៌ រួចហើយមកតាមខ្ញុំ»។[៤] តាមរយៈការប្រកាសដ៏ល្អពិសេសនោះ គាត់ក៏បានទទួលជឿព្រះអង្គភ្លាម។

ទូលបង្គំក៏ត្រឡប់ទៅបង់អង្គុយដែលលោក អាលីពីស៍ កំពុងអង្គុយភ្លាម។ ដ្បិតទូលបង្គំបានទុកព្រះគម្ពីរសាវ័កនៅកន្លែងនោះពីមុន។ ទូលបង្គំក៏យកវា ហើយបើកវា ហើយក្នុងភាពស្ងៀមស្ងាត់ក៏អាននូវកថាខណ្ឌដែលភ្នែកទូលបង្គំបានឃើញមុនគេបង្អស់។ ទីនោះមានសរសេរដូចតទៅ៖ «មិនមែនដោយស៊ីផឹក លេងល្បែង ឬមានស្រីញី ឬដោយឈ្លោះប្រកែក និងឈ្នានីស នោះឡើយ។ ផ្ទុយទៅវិញ ត្រូវប្រដាប់ខ្លួនដោយព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយកុំបំពេញតាមសេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាមឡើយ»។[៥] ទូលបង្គំមិនចង់អានទៅមុខទៀត ហើយទូលបង្គំក៏មិនចាំបាច់ដែរ។ ពីព្រោះជាមួយនឹងពាក្យចុងក្រោយនៃប្រយោគ នោះក៏ហាក់បីដូចជាមានពន្លឺក្នុងលក្ខណៈដ៏ពិសេសមួយបានជ្រាបចូលដួងចិត្តរបស់ទូលបង្គំ ដែលមានពេញទៅដោយភាពប្រាកដប្រជា។ ហើយភ្លាមៗនោះ រាល់ភាពស្រងេះស្រងោចនៃមន្ទិលសង្ស័យក៏បានរលាយបាត់ទៅ។

៣០. បន្ទាប់ពីទូលបង្គំបានអាន នោះទូលបង្គំក៏បានប្រើម្រាមដៃ ឬក៏អ្វីមួយ ដើម្បីសម្គាល់ចំណាំកន្លែង ហើយបន្ទាប់មកក៏បានបិទព្រះគម្ពីរ។ ហើយទូលបង្គំក៏បានចាប់ផ្ដើមដោយមានការបង្ហាញទឹកមុខដែលពេញទៅដោយសន្តិភាពក្នុងការប្រាប់លោក អាលីពីស៍ អំពីអ្វីៗទាំងអស់ដែលទើបតែបានកើតឡើង។ ហើយគាត់ក៏បើកចិត្ត ហើយប្រាប់ទូលបង្គំអំពីអ្វីដែលកំពុងតែកើតឡើងនៅក្នុងខ្លួនគាត់ផងដែរ។ ចំណុចដែលទូលបង្គំមិនដែលធ្លាប់ដឹងសោះ។ គាត់ក៏បានចង់ឃើញថាទូលបង្គំទើបតែអានអ្វី។ ទូលបង្គំក៏បង្ហាញគាត់ ហើយគាត់ក៏អានលើសជាងអ្វីដែលទូលបង្គំបានអានទៅទៀត។ ទូលបង្គំមិនបានដឹងថា កថាខណ្ឌបន្ទាប់និយាយអំពីអ្វីទេ។ ប៉ុន្តែ បានលើកឡើងអំពីចំណុចនេះ៖ «ចូរទទួលអ្នកណាដែលខ្សោយខាងជំនឿ»។[៦] លោក អាលីពីស៍ បានយកពាក្យពេចន៍នោះមកអនុវត្តនៅក្នុងខ្លួនឯងផ្ទាល់ ហើយក៏បានប្រាប់ទូលបង្គំអំពីពាក្យពេចន៍នៃការ

---

៤ ម៉ាថាយ ១៩:២១។

៥ រ៉ូម ១៣:១៣។

៦ រ៉ូម ១៤:១។

លើកទឹកចិត្តនេះដែលបានផ្តល់កម្លាំងដល់គាត់។ ហើយដោយគ្មានការស្ទាក់ស្ទើរ គាត់ក៏បានចូលរួមជាមួយនឹងទូលបង្គំដោយមានការប្តេជ្ញាចិត្តទាំងស្រុង។

បន្ទាប់មក យើងក៏នាំគ្នាទៅជួបអ្នកម្តាយរបស់ទូលបង្គំ ហើយបានប្រាប់គាត់អំពីអ្វីដែលបានកើតឡើង។ គាត់ក៏មានពេញទៅដោយអំណរ។ យើងបានប្រាប់គាត់អំពីរបៀបដែលវាបានកើតឡើង។ គាត់បានលោតឡើងដោយមានពេញទៅដោយអំណរដែលមានជ័យជម្នះ ហើយក៏បានថ្លែងការអរព្រះគុណទៅកាន់ព្រះអង្គដែរ។ តាមរយៈការមានប្រសាសន៍ថាព្រះអង្គ «អាចនឹងធ្វើហួសសន្ធឹក លើសជាងអ្វីៗដែលយើងសូម ឬគិត ដោយព្រះចេស្តាដែលធ្វើការនៅក្នុងយើង»។[៧] ដ្បិតគាត់ឃើញថា ព្រះអង្គបានប្រទានទៅកាន់គាត់លើសជាងអ្វីដែលគាត់បានទទូចសូមក្នុងរាល់ចំណុចដែលគួរឲ្យអាណិតអាសូរ និងការកាន់ទុក្ខដែលបានធ្លាក់ចុះ។ ព្រះអង្គបាននាំឲ្យទូលបង្គំទទួលជឿ ដើម្បីកុំឲ្យទូលបង្គំស្វែងរកប្រពន្ធ ឬក៏ក្តីសង្ឃឹមរបស់លោកីយ៍នេះណាផ្សេងទៀត។ ប៉ុន្តែ ព្រះអង្គបានដាក់ជើងរបស់ទូលបង្គំយ៉ាងមាំលើខ្សែរង្វាស់នៃជំនឿ ដែលទ្រង់បានបើកសម្តែងទៅកាន់អ្នកម្តាយទូលបង្គំជាច្រើនឆ្នាំមុននោះក្នុងការសុបិនរបស់គាត់អំពីទូលបង្គំ។ ហើយព្រះអង្គបានបង្វែរទុក្ខព្រួយរបស់គាត់ឲ្យក្លាយទៅជាអំណរច្រើនជាងគាត់អាចហ៊ានសង្ឃឹមថានឹងមានបានទៅទៀត។ អំណរដែលជាទីស្រឡាញ់ដ៏ជ្រាលជ្រៅ និងបរិសុទ្ធលើសជាងគាត់ធ្លាប់ប្រាថ្នាថាគាត់នឹងមានពីមុនៗតាមរយៈកូនចៅរបស់ទូលបង្គំ។

៧ អេភេសូរ ៣:២០។

សៀវភៅទី៩

# ២៣

# ការលូតលាស់ខាងឯជំនឿ

១. «ឱព្រះយេហូវ៉ាអើយ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ ទូលបង្គំជាអ្នកបម្រើរបស់ព្រះអង្គ កូនរបស់ស្ត្រីដែល ជាអ្នកបម្រើរបស់ព្រះអង្គ។ ព្រះអង្គបានស្រាយចំណងរបស់ទូលបង្គំហើយ»។[១] សូមអនុញ្ញាតឲ្យដួងចិត្ត និងអណ្ដាតរបស់ទូលបង្គំសរសើរតម្កើងព្រះអង្គ ហើយសូមអនុញ្ញាតឲ្យឆ្អឹងទាំងអស់របស់ទូលបង្គំលើកឡើងថា «ឱព្រះអម្ចាស់អើយ! តើមានព្រះណាដូចព្រះអង្គ?»[២] សូមអនុញ្ញាតឲ្យពួកគេនិយាយមក ហើយឆ្លើយមកពីទូលបង្គំ ហើយលើកឡើងមកកាន់ព្រលឹងទូលបង្គំថា «យើងជាព្រះសង្គ្រោះអ្នក!»។[៣]

តើទូលបង្គំជាអ្នកណា ហើយតើអ្វីទៅជាលក្ខណៈរបស់ទូលបង្គំ? តើមានអំពើអាក្រក់ណាដែលមិនមានក្នុងទូលបង្គំ និងក្នុងទង្វើរបស់ទូលបង្គំ ឬក៏ថាប្រសិនបើមិនមានក្នុងទង្វើរបស់ទូលបង្គំ គឺមានក្នុងសម្ដីរបស់ទូលបង្គំ ឬក៏ថាប្រសិនបើមិនមានក្នុងសម្ដីរបស់ទូលបង្គំ គឺមានក្នុងឆន្ទៈរបស់ទូលបង្គំ? ប៉ុន្តែ ឱព្រះអម្ចាស់អើយ! ព្រះអង្គសប្បុរស ហើយមានពេញទៅដោយសេចក្ដីមេត្តាករុណា ហើយព្រះហស្តស្ដាំរបស់ទ្រង់ក៏បានឈោង

១ ទំនុកតម្កើង ១១៦:១៦, ១៧។
២ និក្ខមនំ ១៥:១១។
៣ ទំនុកតម្កើង ៣៥:៣។

ចូលក្នុងជម្រៅនៃសេចក្ដីស្លាប់របស់ទូលបង្គំ ហើយក៏បានចាកចេញនូវភាពពុករលួយទាំងអស់ចេញពីជម្រៅបាតនៃដួងចិត្តរបស់ទូលបង្គំ។ ហើយនេះគឺជាលទ្ធផល៖ ទូលបង្គំមិនមានឆន្ទៈក្នុងការធ្វើនូវអ្វីដែលទូលបង្គំមានឆន្ទៈធ្វើ ប៉ុន្តែបានចាប់ផ្ដើមមានឆន្ទៈធ្វើនូវអ្វីដែលព្រះអង្គសព្វព្រះហឫទ័យវិញ។

ប៉ុន្តែ តើឆន្ទៈសេរីរបស់ទូលបង្គំនៅឯណាក្នុងអំឡុងឆ្នាំ [នៃការបះបោរ] ទាំងអស់នោះ? ឱព្រះគ្រីស្ទយេស៊ូវអើយ! ហើយតើចេញពីជម្រៅណាដែលទូលបង្គំបានទទួលការត្រាស់ហៅឲ្យទូលបង្គំចុះចូលក្រោម «នឹមងាយ» ស្រួលរបស់ព្រះអង្គ ហើយឲ្យស្មារបស់ទូលបង្គំចុះចូលក្រោម «បន្ទុកស្រួល» របស់ព្រះអង្គ «ឱថ្មដា និងជាអ្នកប្រោសលោះនៃទូលបង្គំអើយ!»។[៤] ការនេះក៏បានក្លាយជាផ្អែមល្ហែមភ្លាមៗដល់ទូលបង្គំក្នុងការមិនមានភាពអរសប្បាយដ៏ល្ងីល្ងើដែលទូលបង្គំធ្លាប់សប្បាយជាមួយពីមុន! ហើយឥឡូវនេះទូលបង្គំក៏មានអំណរក្នុងការបោះបង់ចោលនូវអ្វីដែលពីមុនទូលបង្គំធ្លាប់បានមានការភ័យខ្លាចក្នុងការបាត់បង់។ ឱភាពផ្អែមល្ហែមដ៏ពិត និងខ្ពង់ខ្ពស់អើយ! ដ្បិតគឺព្រះអង្គហើយដែលបានបោះបង់សេចក្ដីប្រាថ្នាទាំងនោះរបស់ទូលបង្គំចោល។ ព្រះអង្គបានបោះបង់វាចោល ហើយព្រះអង្គផ្ទាល់ក៏បានយកកន្លែងរបស់វា—ផ្អែមលើសជាងភាពអរសប្បាយទាំងអស់ ទោះបើមិនទៅកាន់សាច់ឈាម ភ្លឺខ្លាំងជាងពន្លឺទាំងអស់ ប៉ុន្តែមានរបាំងលើសជាងអាថ៌កំបាំងទាំងអស់ មានការលើកតម្កើងខ្ពង់ខ្ពស់ហួសកិត្តិយសទាំងអស់ ប៉ុន្តែមិនមែនចំពោះអស់អ្នកដែលគិតខ្ពស់អំពីខ្លួន។ ព្រលឹងរបស់ទូលបង្គំមានសេរីភាពចេញពីការកកេរនៃការខ្វាយខ្វល់នៃការស្វែងរក និងការទទួលបាន នៃការនឿលក្នុងភក់ និងការអេះភាពរមាស់នៃភាពត្រេកត្រអាលទៀតហើយ។ ឱព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់នៃទូលបង្គំអើយ! ទូលបង្គំក៏បានបាននិយាយប៉ប៉ាច់ប៉ប៉ោចដូចជាកូនក្មេងម្នាក់ទៅកាន់ព្រះអង្គ—ពន្លឺរបស់ទូលបង្គំ ទ្រព្យសម្បត្តិរបស់ទូលបង្គំ និងសេចក្ដីសង្គ្រោះរបស់ទូលបង្គំ។

២. ហើយវាក៏ហាក់បីដូចជាត្រឹមត្រូវចំពោះទូលបង្គំដែរ ក្នុងព្រះនេត្ររបស់ព្រះអង្គ គឺថាមិនឲ្យឈប់ពីកន្លែងការងារភ្លាមៗ ប៉ុន្តែឲ្យដកខ្លួនចេញដោយស្ងៀមស្ងាត់ ដើម្បីកុំឲ្យបុរសវ័យក្មេងដែលមិនយកចិត្តទុកដាក់អំពីក្រឹត្យវិន័យ និងសន្តិភាពរបស់ព្រះអង្គ ប៉ុន្តែមានពេញទៅដោយភាពភូតភរដោយល្ងីល្ងើមកទិញពាក្យពេចន៍ដែលជាអាវុធពីទូលបង្គំ

៤ ម៉ាថាយ ១១:២៨-៣០; ទំនុកតម្កើង ១៩:១៤។

សម្រាប់ភាពក្ដៅក្រហាយរបស់ពួកគេ។ អរព្រះគុណព្រះអង្គ! សល់ប្រមាណតែពីរបីថ្ងៃទៀតទេមុនមកដល់ "ថ្ងៃឈប់សម្រាកសម្រាប់ធ្វើស្រាទំពាំងបាយជូរ"។[៥] ហើយទូលបង្គំក៏បានប្ដេជ្ញាចិត្តថានឹងទ្រទ្រាំជាមួយវាសិន ដើម្បីឲ្យទូលបង្គំអាចលាចេញក្នុងពេលវេលាដោយត្រឹមត្រូវ ហើយលែងលក់សេវាកម្មរបស់ទូលបង្គំ ដ្បិតទូលបង្គំជាកម្មសិទ្ធិរបស់ព្រះអង្គ។

ផែនការរបស់ទូលបង្គំគឺស្គាល់ព្រះអង្គ ប៉ុន្តែលើកលែងតែចំពោះមិត្តភក្តិរបស់ទូលបង្គំ គឺមិនមានអ្នកដទៃដឹងទេ។ ដ្បិតយើងបានឯកភាពហើយថាយើងមិនគួរប្រកាសវាជាសាធារណៈ។

៣. ព្រះអង្គបានចាក់ទម្លុះបេះដូងយើងដោយសេចក្តីស្រឡាញ់របស់ទ្រង់ ហើយយើងក៏បីត្រកងព្រះបន្ទូលរបស់ព្រះអង្គ ហាក់បីដូចជាថា ព្រះបន្ទូលបានចាក់ចូលសរីរាង្គកាយដ៏សំខាន់ៗរបស់យើង។ គំរូនៃអ្នកបម្រើនានារបស់ព្រះអង្គដែលទ្រង់បានបំផ្លាស់បំប្រែពីខ្មៅទៅស ពីស្លាប់ទៅរស់ក៏បានជ្រាបចូលមកក្នុងចំណុចស្នូលនៃគំនិតរបស់យើង បញ្ឆេះនិងដុតអារម្មណ៍ក្រៀមស្វិតស្រពោនរបស់យើង ដើម្បីកុំឲ្យយើងធ្លាក់ចូលរណ្ដៅដែលជ្រៅវិញ។ ហើយពួកគេក៏បានជំរុញចិត្តយើងយ៉ាងខ្លាំង ដើម្បីឲ្យគ្រប់ខ្យល់ដង្ហើមនៃអណ្ដាតដែលភូតភររបស់អ្នកដែលបោះបង់យើងមកបក់ភ្លើង មិនមែនពន្លត់វាចោលនោះទេ។

៤. នៅរដូវក្ដៅនោះ សួតរបស់ទូលបង្គំក៏បានខ្សោយដោយសារនិយាយច្រើនពេក។ ការដកដង្ហើមក៏ពិបាក ការឈឺចុកចាប់ក្នុងដើមទ្រូងទូលបង្គំបានបង្ហាញថាសួតរបស់ទូលបង្គំបានកើតរោគ ហើយក៏ខ្សោយដោយសារនិយាយឮៗពេក ឬក៏និយាយយូរពេក។ ជាដំបូងកាលនោះក៏បានក្លាយជាការពិបាកចំពោះទូលបង្គំ ដ្បិតវាបានបង្ខំឲ្យទូលបង្គំបញ្ឈប់ការបង្រៀនដោយចាំបាច់។ ប្រសិនបើទូលបង្គំចង់ជា ហើយមានកម្លាំងដូចមុន នោះទូលបង្គំត្រូវសម្រាកពីការបង្រៀនមួយរយៈសិន។ ប៉ុន្តែ ក្នុងរំពេចដែលសេចក្តីប្រាថ្នាឲ្យនៅស្ងៀមដែលទូលបង្គំចាប់ផ្តើមស្គាល់ថាទ្រង់គឺជាព្រះអម្ចាស់[៦] បានភ្ញាក់ឡើង ហើយទូលបង្គំទទួលបានការអះអាង នោះឱព្រះជាម្ចាស់អើយ ទ្រង់ជ្រាបហើយថា ទូលបង្គំក៏ចាប់ផ្តើមមានអំណរត្រង់ថាទូលបង្គំមានលេសនេះត្រៀមរួចស្រេចទៅហើយ—មិនមែនជាការក្លែងក្លាយផងដែរ—ដែលទំនងជាអាចបន្ថយការមិនសប្បាយចិត្តចំពោះអស់អ្នក

៥ នេះគឺជារដូវកាលនៃការសម្រាកជាតិដែលមានការចាប់ផ្តើមចេញពីខែ សីហា ដល់ពាក់កណ្តាលខែ តុលា។

៦ ទំនុកតម្កើង ៤៦:១០។

ដែលទាក់ទងនឹងសេរីភាពសម្រាប់កូនខ្លួនប្រាថ្នាមិនឲ្យទូលបង្គំមានសេរីភាពផ្ទាល់ខ្លួន។

បន្ទាប់មក ក្នុងការមានចិត្តពេញដោយអំណរ នោះទូលបង្គំក៏ទ្រាំទ្រហូតដល់ពេលវេលាកន្លងផុតទៅ—ទំនងជា២០ថ្ងៃ—ទោះជាយ៉ាងណាក៏ដោយក៏ទូលបង្គំមានការប្រឹងប្រែងក្នុងការបន្តទៅមុខជាមួយនឹងវាដែរ ដ្បិតភាពលោភលន់ដែលជួយទ្រទ្រង់ការលំបាកបានបាត់អស់ហើយ ហើយទូលបង្គំទំនងជាពិបាកចិត្តយ៉ាងខ្លាំង ប្រសិនបើទីតាំងនៃភាពលោភលន់មិនត្រូវបានដកចេញតាមរយៈការអត់ធ្មត់ក្នុងដួងចិត្តទូលបង្គំទេ។

៧. នៅទីបញ្ចប់ ថ្ងៃដែលទូលបង្គំនឹងពិតជាទទួលបានការលាចេញពីការធ្វើគ្រូវោហារសាស្ត្រក៏បានមកដល់។ ហើយវាក៏ចប់ទៅ។ ហើយព្រះអង្គបានរំដោះអណ្ដាតរបស់ទូលបង្គំដូចដែលទ្រង់បានរំដោះដួងចិត្តរបស់ទូលបង្គំរួចដែរ។ ទូលបង្គំបានថ្វាយព្រះពរទៅកាន់ព្រះអង្គដោយមានអំណរយ៉ាងពេញចឹង។ បន្ទាប់មក ទូលបង្គំក៏ត្រឡប់ទៅផ្ទះវិញជាមួយនឹងមិត្តភក្តិ។ សៀវភៅទូលបង្គំធ្វើជាសាក្សីអំពីអ្វីដែលទូលបង្គំបានធ្វើក្នុងការនិពន្ធ ដែលឥឡូវនេះទូលបង្គំសង្ឃឹមថាមានភក្តីភាពចំពោះការបម្រើព្រះអង្គ។ ទោះបើថាក្នុងថ្ងៃសម្រាកនេះវាហាក់បីដូចជាថាទូលបង្គំនៅបន្តមិនមានដង្ហើមដោយសារការខិតខំប្រឹងប្រែងក្នុងសាលានៃអំនួត។ ទាំងនេះគឺជាសៀវភៅនានាដែលទូលបង្គំបានឆ្លើយឆ្លងក្នុងការជជែកវែកញែកជាមួយនឹងមិត្តភក្តិរបស់ទូលបង្គំ ហើយក្នុងពាក្យពេចន៍ទាំងនោះគឺនៅចំពោះព្រះភ័ក្ត្រទ្រង់តែមួយអង្គគត់។

តើមានពេលណាដែលជាពេលវេលាល្មមគ្រប់គ្រាន់ក្នុងការរៀបរាប់អំពីព្រះពរដ៏អស្ចារ្យទាំងអស់របស់ទ្រង់ដែលទ្រង់បានប្រទានមកកាន់យើងនៅពេលនោះ ប៉ុន្តែទូលបង្គំនឹងបន្តក្នុងដំណើររឿង ហើយរៀបរាប់អំពីសេចក្តីមេត្តាករុណាដ៏ល្អអស្ចារ្យខ្លាំងជាងនេះទៅទៀត? ឱព្រះអម្ចាស់អើយ! ដ្បិតការចងចាំរបស់ទូលបង្គំរម្លឹកវាមកកាន់ទូលបង្គំ ហើយវាគឺជាការដ៏សប្បាយណាស់ក្នុងការដែលទូលបង្គំរៀបរាប់អំពីវាទៅកាន់ព្រះអង្គ។ ការលើកទឹកចិត្តពីខាងក្នុងតាមរយៈព្រះអង្គបានធ្វើឲ្យទូលបង្គំចុះចូល ហើយព្រះអង្គក៏បាននាំទូលបង្គំទៅកន្លែងទាប ឈូសឆាយយ៉ាងរាបនូវភ្នំ និងកូនភ្នំនៃគំនិតរបស់ទូលបង្គំ តម្រង់ការវៀចវេររបស់ទូលបង្គំ នឹងធ្វើឲ្យផ្លូវទ្រេតទ្រោតរបស់ទូលបង្គំរលោង។

៨. ឱព្រះដ៏ជាម្ចាស់នៃទូលបង្គំអើយ! ទូលបង្គំបានស្រែកទៅកាន់ព្រះអង្គ ពេលទូលបង្គំអានទំនុកតម្កើងនិពន្ធដោយស្តេច ដាវីឌ៖ ទំនុកនៃជំនឿ និងចម្រៀងនៃភក្តីភាព

ដែលមិនឲ្យមានកន្លែងសម្រាប់អំនួតលូតលាស់ឡើងឡើយ! ទូលបង្គំនៅខ្ចីនៅឡើយ ក្នុងសេចក្ដីស្រឡាញ់ដ៏ពិតរបស់ទ្រង់ ជាអ្នករៀនដែលកំពុងសម្រាកនៅផ្ទះជាមួយនឹង លោក អាលីពឹស៍ ដែលជាអ្នករៀនដូចទូលបង្គំដែរ។ អ្នកម្ដាយទូលបង្គំក៏នៅជាមួយនឹង យើងដែរ—ដោយមានរូបរាងជាស្ត្រី ប៉ុន្តែមានភាពស្មោះត្រង់របស់មនុស្សប្រុស មាន សន្តិភាពយ៉ាងចាស់ទុំ និងភាពពេញវ័យនៃការស្រឡាញ់របស់អ្នកម្ដាយ និងភក្ដីភាព របស់គ្រីស្ទបរិស័ទ។ ក្នុងចម្រៀងទាំងនោះ ទូលបង្គំបានស្រែកទៅកាន់ព្រះអង្គនៅស្ថាន លើ ហើយទូលបង្គំក៏មានភាពឆេះឆួលយ៉ាងខ្លាំងទៅកាន់ព្រះអង្គតាមរយៈវាផងដែរ! ទូលបង្គំមានការឆេះឆួលក្នុងការច្រៀងវា ប្រសិនបើអាច គឺទៅកាន់ពិភពលោកទាំងមូល ដោយទាស់ប្រឆាំងនឹងអំនួតនៃមនុស្សជាតិទាំងឡាយ។ ហើយប្រាកដណាស់! ក៏មាន ការច្រៀងពេញពិភពលោកផងដែរ ហើយគ្មានបុគ្គលណាអាចលាក់ខ្លួនពីកម្ដៅរបស់ព្រះ អង្គបានឡើយ។ ទូលបង្គំមានការសោកស្ដាយ និងខឹងយ៉ាងខ្លាំងដោយមានភាពល្វីងជូរ ចត់ទៅកាន់ពួកក្រុមមានិហ្កៀន! ប៉ុន្តែ ទូលបង្គំក៏អាណិតពួកគេដែរ ដ្បិតពួកគេមិនស្គាល់ ពិធីបង្គ្រព្រះគុណទាំងនោះ គឺថ្នាំទាំងនោះ—ហើយពួកគេខឹងយ៉ាងឆ្កួតលេលាប្រឆាំងនឹង ការព្យាបាលដែលទំនងនឹងអាចធ្វើឲ្យពួកគេលែងឆ្កួត! ទូលបង្គំបានប្រាថ្នាចង់ឲ្យពួកគេ នៅក្បែរការនោះហើយ—ដោយទូលបង្គំមិនដឹងខ្លួន—ពួកគេអាចឃើញមុខរបស់ទូលបង្គំ ហើយឮពាក្យពេចន៍របស់ទូលបង្គំ កាលក្នុងពេលសម្រាក ទូលបង្គំបានមើលកណ្ឌគម្ពីរ ទំនុកតម្កើងជំពូក៤ដោយយកចិត្តទុកដាក់។ ហើយទោះបើទូលបង្គំប្រាថ្នាថាចង់ឲ្យគេ ឃើញអំពីរបៀបដែលកណ្ឌគម្ពីរទំនុកតម្កើងនោះបានជះឥទ្ធិពលលើទូលបង្គំ។ «ឱព្រះ នៃសេចក្ដីសុចរិតរបស់ទូលបង្គំអើយ ពេលទូលបង្គំអំពាវនាវ សូមមានព្រះបន្ទូលឆ្លើយ មកទូលបង្គំផង! ពេលទូលបង្គំមានសេចក្ដីតានតឹង ព្រះអង្គប្រទានឲ្យទូលបង្គំបាន ស្បើយ។ សូមប្រណីសន្ដោសទូលបង្គំ ហើយសូមព្រះសណ្ដាប់សេចក្ដីអធិស្ឋានរបស់ ទូលបង្គំផង»។[៧] ទូលបង្គំប្រាថ្នាចង់ឲ្យពួកគេបានឮនូវអ្វីដែលទូលបង្គំបានលើកឡើង ក្នុងនោះពាក្យពេចន៍នៃការពន្យល់ទាំងនោះ—ដោយមិនឲ្យទូលបង្គំដឹងថាពួកគេបាន ឮ ដើម្បីកុំឲ្យពួកគេគិតថាទូលបង្គំកំពុងនិយាយសម្រាប់តែប្រយោជន៍ពួកគេ។ ប្រាកដ ណាស់! ដ្បិតទូលបង្គំនឹងមិនទំនងជាលើកនូវចំណុចដដែលដូចៗគ្នា ឬក៏ក្នុងរបៀប

---

៧ ទំនុកតម្កើង ៤:១។

ដូចៗគ្នា ប្រសិនបើទូលបង្គំបានដឹងថាពួកគេកំពុងតែស្ដាប់។ ហើយប្រសិនបើទូលបង្គំបាននិយាយដោយដឹងថាពួកគេកំពុងតែស្ដាប់ នោះពាក្យពេចន៍របស់ទូលបង្គំនឹងទំនងជាមិនមានអត្ថន័យដូចអ្វីដែលទូលបង្គំមានអត្ថន័យចំពោះពួកគេទេ ខណៈពេលដែលវាមានអត្ថន័យចំពោះទូលបង្គំពេលទូលបង្គំបានលើកឡើងតាមរយៈ និងសម្រាប់ខ្លួនផ្ទាល់ចំពោះព្រះអង្គ ដែលកើតចេញពីការស្រឡាញ់ដ៏សម្ងាត់នៃព្រលឹងទូលបង្គំ។

៩. ឱព្រះវរបិតាអើយ! ទូលបង្គំញាប់ញ័រដោយភ័យខ្លាច ហើយមានភាពកក់ក្ដៅដោយមានសង្ឃឹម និងមានអំណរក្នុងសេចក្ដីមេត្តាករុណារបស់ទ្រង់។ ហើយអារម្មណ៍ទាំងអស់នេះក៏បានបើកបង្ហាញឡើងក្នុងភ្នែក និងសំឡេងរបស់ទូលបង្គំ ពេលដែលព្រះវិញ្ញាណដ៏ល្អរបស់ទ្រង់បានបែរមកយើង ហើយមានបន្ទូលថា «ឱពួកមនុស្សជាតិអើយ តើអ្នករាល់គ្នាជាន់ឈ្លីកិត្តិយសខ្ញុំដល់កាលណាទៀត? តើអ្នករាល់គ្នាស្រឡាញ់ភាពឥតប្រយោជន៍ ហើយសង្វាតដេញតាមការកុហកភូតភរ ដល់កាលណាទៀត?»។[៨] ដ្បិតទូលបង្គំបានស្រឡាញ់ភាពឥតប្រយោជន៍ ហើយសង្វាតដេញតាមការកុហក។ ឱព្រះអម្ចាស់អើយ! ព្រះអង្គក៏បានលើកតម្កើងព្រះដ៏បរិសុទ្ធរបស់ទ្រង់ដោយប្រោសទ្រង់ពីការសុគត ដាក់ទ្រង់នៅខាងស្ដាំព្រះហស្តរបស់ព្រះអង្គ ហើយចេញពីនោះព្រះអង្គនឹងចាត់ពីស្ថានខ្ពស់នូវ «ព្រះជាជំនួយ...គឺជាព្រះវិញ្ញាណនៃសេចក្ដីពិត» ដែលទ្រង់បានសន្យា។[៩] ព្រះអង្គបានចាត់ទ្រង់មកហើយ តែទូលបង្គំមិនបានដឹងអំពីការនោះ។ ព្រះអង្គបានចាត់ទ្រង់មក ពីព្រោះទ្រង់បានទទួលការលើកតម្កើង មានព្រះជន្មរស់ពីការសុគត ហើយយាងទៅកាន់ស្ថានសួគ៌វិញ។ ដ្បិតរហូតដល់ពេលនោះ «ព្រះវិញ្ញាណបរិសុទ្ធមិនទាន់យាងមក ដោយព្រោះព្រះយេស៊ូវមិនទាន់បានតម្កើងឡើងនៅឡើយ»។[១០] ហើយហោរាក៏បានស្រែកឡើងថា «តើអ្នករាល់គ្នានៅមានចិត្តយឺតយ៉ាវដល់កាលណាទៀត? តើអ្នករាល់គ្នានៅស្រឡាញ់ការឥតប្រយោជន៍ ហើយសង្វាតដេញតាមការកុហកដល់កាលណាទៀត? ចូរឲ្យយល់ចំណុចនេះ គឺថាព្រះអម្ចាស់បានលើកតម្កើងព្រះដ៏បរិសុទ្ធរបស់ទ្រង់ហើយ»។ ព្រះអង្គបានស្រែកថា «តើដល់កាលណាទៀត?»។ ព្រះអង្គបានស្រែកថា «ចូរឲ្យយល់ចំណុចនេះ» ហើយទូលបង្គំ—ដែលបានស្រឡាញ់ភាពឥតប្រយោជន៍

៨ ទំនុកតម្កើង ៤:២។

៩ យ៉ូហាន ១៤:១៦, ១៧។

១០ យ៉ូហាន ៧:៣៩។

ហើយសង្វាតដេញតាមការកុហកភូតភរជាច្រើនឆ្នាំ—បានឮ និងញាប់ញ័រ ពីព្រោះពាក្យពេចន៍ទាំងនេះត្រូវបាននិយាយទៅកាន់បុគ្គលដែលមានលក្ខណៈដូចទូលបង្គំផ្ទាល់ធ្លាប់មានពីមុន។ ដ្បិតក្នុងការបោកប្រាស់ទាំងនោះដែលទូលបង្គំធ្លាប់បានកាន់ហាក់បីដូចជាសេចក្ដីពិតគឺជាភាពឥតប្រយោជន៍ ហើយសង្វាតដេញតាមការកុហកភូតភរ ។ ហើយទូលបង្គំក៏បាននិយាយអំពីចំណុចជាច្រើនយ៉ាងឮៗ និងម៉ឺងម៉ាត់—ក្នុងទុក្ខព្រួយនៃការចងចាំរបស់ទូលបង្គំ—ដែលទូលបង្គំប្រាថ្នាចង់ឲ្យពួកគាត់បានឮ ដែលនៅ "ស្រឡាញ់ភាពឥតប្រយោជន៍ និងសង្វាតដេញតាមការកុហកភូតភរ"។ ទំនងពួកគាត់អាចនឹងព្រួយបារម្ភ ហើយបានឆ្លួតសេចក្ដីខុសឆ្គងរបស់ខ្លួនចេញ នោះព្រះអង្គនឹងបានឮពួកគេនៅពេលដែលពួកគេស្រែកទៅកាន់ទ្រង់ ដ្បិតតាមរយៈការសុគតដ៏ពិតខាងឯសាច់ឈាមរបស់ព្រះគ្រីស្ទ នោះព្រះអង្គបានសុគតសម្រាប់យើង ហើយឥឡូវនេះទ្រង់កំពុងតែទទូចអង្វរសម្រាប់យើងទៅកាន់ព្រះអង្គ។

១០. ទូលបង្គំបន្តអានទៅមុខទៀត "ចូរខឹងចុះ តែកុំឲ្យធ្វើបាប" ឡើយ។[១១] ឱព្រះដ៏ជាម្ចាស់ទូលបង្គំអើយ! ទូលបង្គំពិតជាទទួលបានការប៉ះពាល់យ៉ាងខ្លាំងមែន។ ដ្បិតពេលនោះទូលបង្គំបានរៀនចេះខឹងជាមួយនឹងខ្លួនឯងទាក់ទងនឹងអ្វីៗពីអតីតកាល ដើម្បីឲ្យថានៅអនាគតទូលបង្គំមិនប្រព្រឹត្តអំពើបាបទៀត។ ប្រាកដណាស់! ការខឹងដោយមានបុព្វហេតុល្អ ដ្បិតមិនមែនមានជាតិសាសន៍ណាមួយផ្សេងទៀតចេញពីភាពងងឹតបានប្រព្រឹត្តអំពើបាបសម្រាប់ទូលបង្គំទេ—ដូចដែលពួកគេបានអះអាងហើយថាពួកគេមិនខឹងជាមួយនឹងខ្លួនឯងឡើយ ហើយពួកគេក៏បានសន្សំទុកសម្រាប់ខ្លួនឯងនូវសេចក្ដីក្រោធដែលគួរឲ្យកោតខ្លាចទាស់នឹងថ្ងៃនៃសេចក្ដីក្រោធ និងការបើកសម្ដែងនូវការថ្កោលទោសដ៏យុត្តិធម៌របស់ទ្រង់ដែរ។ ហើយក៏មិនរាប់នូវចំណុចល្អៗដែលទូលបង្គំបានឃើញឥឡូវនេះខាងក្រៅខ្លួនឯង ហើយយើងក៏មិនអាចឃើញវាដោយភ្នែកខាងឯសាច់ឈាមក្នុងពន្លឺនៃព្រះអាទិត្យលើផែនដីនេះបានដែរ។ ដ្បិតអស់អ្នកដែលមានអំណរដែលកើតចេញពីខាងក្រៅខ្លួនឯងក៏ងាយនឹងលង់ទៅក្នុងភាពទទេ ឲ្យធ្លាក់ចេញលើរបស់ដែលអាចមើលឃើញ ហើយនៅជាបណ្ដោះអាសន្ន ថយក្នុងគំនិតនៃការអត់ឃ្លានរបស់ពួកគេ នោះពួកគេនឹងលិតស្រមោលរបស់ខ្លួនឯងផ្ទាល់។ ប្រសិនបើពួកគេគ្រាន់តែចាប់ផ្ដើមនឿយហត់

១១ អេភេសូរ ៤:២៦។

ជាមួយនឹងការស្រេកឃ្លានរបស់ខ្លួន ហើយដោយព្រោះនិយាយថា “តើអ្នកណាបង្ហាញឲ្យយើងឃើញសេចក្តីល្អ?”។[១២] នោះយើងនឹងឆ្លើយ ហើយពួកគេនឹងឮថា “ឱព្រះអម្ចាស់អើយ! សូមផ្តល់នូវជីវិតនៃពន្លឺនៃព្រះភ័ក្ត្ររបស់ទ្រង់លើមុខរបស់យើង!”។ ដ្បិតយើងមិនមែនជាពន្លឺនោះដែលបើកបំភ្លឺមនុស្សគ្រប់ៗរូបនោះទេ ប៉ុន្តែយើងទទួលបានការបើកបំភ្លឺតាមរយៈព្រះអង្គ ដើម្បីឲ្យយើងដែលពីមុនធ្លាប់រស់នៅក្នុងភាពងងឹតអាចឥឡូវមកធ្វើជាពន្លឺក្នុងទ្រង់បាន។ បើពួកគាត់គ្រាន់តែឃើញពន្លឺដ៏ពិតនៅខាងក្នុងដែលទូលបង្គំធ្លាប់បានឃើញ! ទូលបង្គំបានសង្កៀតធ្មេញ ពីព្រោះទូលបង្គំមិនអាចបង្ហាញទៅកាន់ពួកគេបានលុះត្រាតែពួកគេនាំចិត្តរបស់ពួកគេមកកាន់ទូលបង្គំក្នុងភ្នែករបស់ខ្លួនសិន—ភ្នែកដែលសម្លឹងមើលដោយគ្មានទិសដៅ—ហើយនិយាយថា “តើអ្នកណាបង្ហាញឲ្យយើងឃើញសេចក្តីល្អ?”។ ប៉ុន្តែ សូម្បីតែនៅទីនោះ ក្នុងបន្ទប់ផ្ទាល់ខ្លួននៃព្រលឹងរបស់ទូលបង្គំ—ដែលជាកន្លែងដែលទូលបង្គំកំពុងតែខឹងនឹងខ្លួនឯង ជាកន្លែងដែលទូលបង្គំបានទទួលការចាក់ពីខាងក្នុង ជាកន្លែងដែលទូលបង្គំបានថ្វាយយញ្ញបូជារបស់ទូលបង្គំ ដោយកំពុងសម្លាប់មនុស្សចាស់របស់ទូលបង្គំចោល ហើយសង្ឃឹមក្នុងទ្រង់ជាមួយនឹងការប្តេជ្ញាចិត្តថ្មីនៃជីវិតថ្មីជាមួយនឹងទំនុកចិត្តរបស់ទូលបង្គំដែលទូលបង្គំបានដាក់ទៅលើទ្រង់—សូម្បីតែនៅទីនោះក៏ព្រះអង្គបានចាប់ផ្តើមមានភាពផ្អែមល្ហែមមកកាន់ទូលបង្គំដែរ ហើយ “បានដាក់អំណរក្នុងចិត្តទូលបង្គំច្រើនជាង”។[១៣] ដូច្នេះ ខណៈពេលដែលទូលបង្គំអានចំណុចទាំងនេះ នោះទូលបង្គំក៏បានស្រែកឮៗ ហើយក៏យល់អំពីអត្ថន័យខាងក្នុងរបស់វា។ ហើយទូលបង្គំក៏លែងមានសេចក្តីប្រាថ្នាចង់ក្លាយជាអ្នកមានសម្បត្តិច្រើន ដ្បិតទូលបង្គំមាន ក្នុងភាពដ៏សាមញ្ញអស់កល្បជានិច្ចរបស់ទ្រង់ “ស្រូវ ទឹកទំពាំងបាយជូរ និងប្រេងឯទៀត”។[១៤]

១១. ទូលបង្គំអានឧបន្ទាប់ ហើយដោយមានសម្រែកយ៉ាងខ្លាំងចេញពីបេះដូងរបស់ទូលបង្គំដោយលើកឡើងថា “ឱ! ក្នុងភាពសុខសាន្តដូចគ្នា!”។ សូមមើលអំពីរបៀបដែលគាត់លើកឡើង “ទូលបង្គំនឹងសម្រាកកាយ ហើយដេកលក់” ។[១៥] ដ្បិតតើអ្នកណានឹងមកឈរជំទាស់ជាមួយនឹងយើងនៅពេលដែលសេចក្តីពិតនៃការលើកឡើងនេះ ដែល

១២ ទំនុកតម្កើង ៤:៦។
១៣ ទំនុកតម្កើង ៤:៧។
១៤ ទំនុកតម្កើង ៤:៧។
១៥ ទំនុកតម្កើង ៤:៨។

បានសរសេរចុះ បានបើកបង្ហាញយ៉ាងច្បាស់លាស់៖ «ជ័យជម្នះបានលេបសេចក្តីស្លាប់បាត់ហើយ»។[១៦] ប្រាកដណាស់! ដ្បិតព្រះអង្គដែលមិនចេះប្រែប្រួល ព្រះអង្គនៅដដែលហើយក្នុងទ្រង់មានការសម្រាក ហើយការភ្លេចទុក្ខព្រួយទាំងអស់ដែរ។ ឱព្រះអម្ចាស់អើយ! គ្មាននរណាក្រៅពីព្រះអង្គឡើយ ហើយយើងក៏មិនគួរខំប្រឹងធ្វើការសម្រាប់របស់ជាច្រើនផ្សេងទៀតដែលមិនមែនព្រះអង្គ ដ្បិតមានតែទ្រង់ ដែលធ្វើឲ្យទូលបង្គំនៅក្នុងសេចក្តីសង្ឃឹមបាន។

ទូលបង្គំអានចំណុចទាំងអស់នោះ ហើយក៏ទទួលបានការឆេះឆួល—ប៉ុន្តែ ទូលបង្គំនៅមិនអាចរកឃើញនូវអ្វីដែលគួរធ្វើជាមួយនឹងពួកមានិហ្កៀនដែលថ្លង់ ហើយស្លាប់ដែលទូលបង្គំផ្ទាល់ក៏ជាសមាជិកម្នាក់ដែរ។ ដ្បិតទូលបង្គំជាអ្នកជេរប្រមាថដ៏ខ្វាក់ និងល្ងីងជូរចត់ម្នាក់ដែលប្រឆាំងនឹងការនិពន្ធទាំងអស់ ដែលមានការគ្របដណ្តប់ទៅដោយទឹកឃ្មុំពីស្ថានសួគ៌ ហើយមានការចែងចាំងទៅដោយពន្លឺរបស់ទ្រង់។ ហើយទូលបង្គំក៏មានការសោកស្តាយយ៉ាងខ្លាំងតាមរយៈខ្ទាំងសត្រូវនានានៃព្រះបន្ទូលនេះ។

---

១៦ ១កូរិនថូស ១៥:៥៤។

សៀវភៅទី៩

# ២៣

# ពិធីជ្រមុជទឹក

១៣. ពេលការសម្រាកបានឈានដល់ទីបញ្ចប់ នោះទូលបង្គំក៏ដាក់ពាក្យឈប់ដោយប្រាប់អ្នកទីក្រុងមីឡាន ដើម្បីឲ្យពួកគេអាចផ្ដល់អ្នកប្រាជ្ញរបស់ខ្លួនម្នាក់ទៀតក្នុងការធ្វើពាណិជ្ជករលក់ពាក្យ។ ទូលបង្គំបានផ្ដល់មូលហេតុផ្ទាល់ខ្លួនក្នុងការប្ដេជ្ញាចិត្តបែបនេះ ដើម្បីបម្រើព្រះអង្គ និងដោយសារការខ្វះសមត្ថភាពរបស់ទូលបង្គំក្នុងការងារ ពីព្រោះទូលបង្គំពិបាកដកដង្ហើម ហើយដើមទ្រូងនៅឈឺ។

ហើយទូលបង្គំក៏បានផ្ញើសំបុត្រជម្រាបដល់អ្នកមើលខុសត្រូវរបស់ព្រះអង្គ គឺលោកគ្រូ អែមប្រូស៍ ដែលជាបុរសបរិសុទ្ធ ដោយប្រាប់គាត់អំពីកំហុសខុសឆ្គងមុនៗរបស់ទូលបង្គំ និងអំពីការប្ដេជ្ញាចិត្តបច្ចុប្បន្ននេះរបស់ទូលបង្គំដែរ។ ហើយទូលបង្គំក៏សូមប្រឹក្សាពីគាត់ទាក់ទងទៅនឹងកណ្ឌគម្ពីរមួយណារបស់ព្រះអង្គដែលល្អបំផុតសម្រាប់ទូលបង្គំក្នុងការអាន ដើម្បីឲ្យទូលបង្គំអាចកាន់តែត្រៀមខ្លួនបានខ្លាំងជាងមុន ហើយស័ក្តិសមក្នុងការទទួលព្រះគុណដ៏អស្ចារ្យ។ គាត់បានផ្ដល់យោបល់ឲ្យអានកណ្ឌគម្ពីរ អេសាយ។ ហើយទូលបង្គំជឿថា នេះគឺដោយសារហោរា អេសាយ ផ្ដល់ជាប្រផ្នូលបានយ៉ាងល្អច្បាស់លាស់ខ្លាំងជាងហោរានានាអំពីដំណឹងល្អ និងការត្រាស់ហៅសាសន៍ដទៃ។ ប៉ុន្តែ ដោយសារ

ទូលបង្គំមិនអាចយល់ផ្នែកដំបូងបាន ហើយដោយសារទូលបង្គំបានស្រមៃថាផ្នែកបន្តបន្ទាប់នៃសៀវភៅក៏ដូចនោះដែរ ដូច្នេះទូលបង្គំក៏ទុកកណ្ឌគម្ពីរនោះចោលមួយរយៈសិន ដោយមានបំណងចិត្តចង់ចាប់ផ្តើមអានជាថ្មីម្តងទៀតនៅពេលក្រោយ នៅពេលទូលបង្គំមានជំនាញល្អជាងមុនក្នុងការយល់នូវព្រះបន្ទូលរបស់ព្រះអម្ចាស់នៃយើង។

១៤. នៅពេលដែលវេលាបានមកដល់ឲ្យទូលបង្គំក្នុងការចុះឈ្មោះសម្រាប់ពិធីបុណ្យជ្រមុជទឹក នោះយើងក៏ចាកចេញពីតំបន់ជនបទ ហើយត្រឡប់មកទីក្រុងមីឡានវិញ។ យើងបានយក អាឌីអូដាទឹស៍ ជាមួយយើង ដែលជាកូនប្រុសរបស់ទូលបង្គំខាងឯសាច់ឈាម ជាកូននៃអំពើបាបរបស់ទូលបង្គំ។ ព្រះអង្គបានធ្វើឲ្យគាត់ក្លាយជាក្មេងប្រុសដែលមានកិត្តិយសម្នាក់។ គាត់មិនទាន់មានអាយុប៉ុន្មាន១៥ឆ្នាំទេ ប៉ុន្តែចំណេះដឹងរបស់គាត់មានច្រើនជាងបុរសដែលបានរៀនសូត្រដោយយកចិត្តទុកដាក់ទៅទៀត។ ឱព្រះអម្ចាស់ដែលជាព្រះជាម្ចាស់នៃទូលបង្គំអើយ! ទូលបង្គំសូមរៀបរាប់អំពីអំណោយទាននានារបស់ទ្រង់ ដែលជាព្រះអាទិករនៃរាល់អ្វីៗទាំងអស់ ព្រះអង្គមានអំណាចក្នុងការកែច្នៃកន្លែងខូចទ្រង់ទ្រាយរបស់យើងបាន—ទូលបង្គំសូមរៀបរាប់អំពីអំណោយទានរបស់ទ្រង់ទៅកាន់ទ្រង់។ ទូលបង្គំមានសៀវភៅមួយក្បាលដែលមានចំណងជើងថា «គ្រូ» គឺជាការសន្ទនារវាង អាឌីអូដាទឹស៍ និងទូលបង្គំ។ ហើយព្រះអង្គជ្រាបអំពីគំនិតរបស់គាត់ ដែលមាននៅក្នុងនោះ ក្នុងនាមជាតួឯករួមម្នាក់ក្នុងការសន្ទនាដែលមានការសរសេរចុះក្នុងសៀវភៅនោះ ទោះបើថានៅកាលនោះគាត់ទើបតែមានអាយុ១៦ឆ្នាំនៅឡើយ។ ទូលបង្គំក៏ឃើញអំណោយទានជាច្រើនផ្សេងទៀតក្នុងគាត់ផងដែរ។ ទេពកោសល្យរបស់គាត់គឺជាប្រភពនៃការភ្ញាក់ផ្អើលចំពោះទូលបង្គំ។ ហើយតើមាននរណា ក្រៅពីព្រះអង្គដែលបានធ្វើការអស្ចារ្យទាំងនោះ? ហើយព្រះអង្គក៏បានដកជីវិតរបស់គាត់ឆាប់រហ័សចេញពីផែនដីនេះ ហើយសូម្បីតែឥឡូវនេះក៏ទូលបង្គំគិតអំពីគាត់ក្នុងខួរក្បាលទូលបង្គំដោយមានញាណនៃសន្តិភាព ពីព្រោះទូលបង្គំមិនមានការភ័យខ្លាចអ្វីទេទាក់ទងទៅហ្នឹងកុមារភាព និងភាពជាយុវ័យរបស់គាត់ ព្រមទាំងវិជ្ជាជីវៈទាំងមូលរបស់គាត់ដែរ។ យើងរាប់គាត់រួមដូចជាគូកន ហាក់បីដូចជាថាគាត់មានអាយុស្មើហ្នឹងយើងផ្ទាល់ ដើម្បីឲ្យមានការរៀនជាមួយយើងក្នុងការធ្វើជាសិស្សរបស់ព្រះអង្គ។ ដូច្នេះ យើងក៏ទទួលពិធីជ្រមុជទឹក ហើយភាពខ្វល់ខ្វាយអំពីជីវិតនេះដែលយើងធ្លាប់រស់នៅក្នុងពីមុនក៏បានចាកចេញពីយើង។

១៦. ឱព្រះជាម្ចាស់អើយ! ទូលបង្គំសូមថ្លែងអំណរអរព្រះគុណទៅកាន់ព្រះអង្គ។ តើចេញពីទីណា ហើយសំដៅទៅទីណា ដែលព្រះអង្គកំពុងតែនាំការចងចាំរបស់ទូលបង្គំ ដែលទូលបង្គំរៀបរាប់អំពីចំណុចដូចនេះទៅកាន់ទ្រង់។ ដ្បិតទោះបើថាព្រឹត្តិការណ៍ទាំងនេះពិតជាអស្ចារ្យក៏ដោយក៏ទូលបង្គំស្ទើរតែភ្លេចក្នុងការរាប់វាបញ្ចូលដែរ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលរសជាតិផ្អែមនៃក្រមួនរបស់ទ្រង់កាន់តែមានក្លិនក្រអូប នោះទូលបង្គំក៏មិនបានរត់ដេញតាមព្រះអង្គ។[១] ដូច្នេះ ទូលបង្គំក៏កាន់តែយំយ៉ាងខ្លាំងជាងមុន ខណៈពេលដែលទូលបង្គំបានស្ដាប់ទំនុករបស់ទ្រង់ បន្ទាប់ពីបានស្រេកឃ្លានយ៉ាងខ្លាំងតាមទ្រង់យ៉ាងយូរ។ ហើយមកដល់ពេលនេះទូលបង្គំក៏អាចដកដង្ហើមតាមដែលអាចធ្វើបានក្នុងការអនុញ្ញាតពីទំហំក្នុងផ្ទះស្បូវនេះរបស់យើង ពោលគឺរូបកាយលើផែនដីនេះរបស់យើង។[២]

---

១ បទចម្រៀងសាឡូម៉ូន ១:៣, ៤។

២ អេសាយ ៤០:៦; ១ពេត្រុស ១:២៤៖ «មនុស្សជាតិទាំងឡាយប្រៀបដូចជាស្មៅ»។

# ៣៤

# មរណភាពរបស់អ្នកម្ដាយទូលបង្គំ

១៧. ឱព្រះជាម្ចាស់អើយ សូមទទួលការលន់តួរបស់ទូលបង្គំ និងការអរព្រះគុណសម្រាប់នូវអ្វីៗដែលរាប់មិនអស់ទាក់ទងនឹងអ្វីដែលទូលបង្គំមិនបានលើកឡើង។

ប៉ុន្ដែ ទូលបង្គំនឹងមិនដកចេញនូវអ្វីដែលខួរក្បាលទូលបង្គំបានរម្លឹកឡើងវិញអំពីមរណភាពរបស់អ្នកម្ដាយទូលបង្គំ ដែលជាអ្នកបម្រើរបស់ទ្រង់នោះទេ។ អ្នកម្ដាយទូលបង្គំបានបង្កើតទូលបង្គំក្នុងសាច់ឈាមនេះ ដើម្បីឲ្យទូលបង្គំកើតមកក្នុងពន្លឺនៃផែនដីនេះ។ គាត់បានបង្កើតទូលបង្គំក្នុងដួងចិត្តគាត់ ដើម្បីឲ្យទូលបង្គំអាចកើតជាថ្មីក្នុងជីវិតដ៏នៅអស់កល្បជានិច្ច។ ទូលបង្គំនឹងមិននិយាយរៀបរាប់អំពីអំណោយទានរបស់គាត់ឡើយ ប៉ុន្ដែអំពីអំណោយទានរបស់ព្រះអង្គក្នុងគាត់វិញ។ គាត់មិនបានបង្កើតខ្លួនឯងឬក៏បង្ហាត់បង្រៀនខ្លួនឯងទេ។ ព្រះអង្គគឺជាអង្គដែលបានបង្កើតគាត់។ ឪពុកម្ដាយគាត់

មិនដឹងថា នឹងមានបុគ្គលបែបម៉េចដែលនឹងកើតចេញពីពួកគាត់ឡើយ។ គឺជំបងរបស់ព្រះគ្រីស្ទ និងការណែនាំពីព្រះរាជបុត្រារបស់ទ្រង់តែមួយគត់ដែលបានបង្ហាត់បង្រៀនគាត់ក្នុងការកោតខ្លាចព្រះអង្គ ក្នុងផ្ទះនៃសមាជិកដ៏ស្មោះត្រង់នៃក្រុមជំនុំរបស់ទ្រង់។

អ្នកម្ដាយទូលបង្គំមិនសូវអះអាងថា ការបង្ហាត់បង្រៀនដ៏ល្អរបស់គាត់គឺកើតចេញពីការយកចិត្តទុកដាក់ពីម្ដាយរបស់គាត់ប៉ុន្មានទេ។ ប៉ុន្តែ ផ្ទុយទៅវិញ គឺពីអ្នកបម្រើដែលមានវ័យចំណាស់ម្នាក់ ដែលបានមើលថែឪពុករបស់គាត់កាលគាត់នៅជាទារក។ អ្នកបម្រើម្នាក់នោះក៏ថែមទាំងឲ្យគាត់ជិះលើករបស់គាត់ ដូចជាពេលដែលក្មេងស្រីម្នាក់ពទារកម្នាក់ទៀតតូចជាងខ្លួនបន្តិចអញ្ចឹង។ ដោយសារគាត់បានបម្រើជាយូរឆ្នាំ មានវ័យចំណាស់ និងមានលក្ខណសម្បត្តិដ៏ល្អជាច្រើន ដូច្នេះអ្នកដឹកនាំផ្ទះដែលជាគ្រីស្ទបរិស័ទនោះក៏បានគោរពគាត់យ៉ាងខ្លាំង។ គាត់បានទទួលទំនួលខុសត្រូវក្នុងការមើលថែកូនស្រីៗរបស់មេផ្ទះនោះ ហើយគាត់ក៏បានបំពេញភារកិច្ចនោះដោយយកចិត្តទុកដាក់។ គាត់បានបង្រៀនពួកគេដោយមានការដាក់វិន័យយ៉ាងម៉ឺងម៉ាត់។ ហើយពេលចាំបាច់ គាត់ក៏បានគ្រប់គ្រងពួកគេដោយមានការណែនាំដោយបរិសុទ្ធយ៉ាងតឹងរ៉ឹង។ គាត់មិនអនុញ្ញាតឲ្យកូនស្រីៗញ៉ាំអ្វីតាមតែចិត្តនោះទេ ទោះបើពេលដែលពួកគេស្រេកឃ្លានយ៉ាងខ្លាំងប៉ុណ្ណាក៏ដោយ ហើយសូម្បីតែពេលបរិភោគម្ហូបអាហារជាមួយនឹងឪពុកម្ដាយ ក៏នៅមានការគ្រប់គ្រងយ៉ាងតឹងរ៉ឹងផងដែរ។ មូលហេតុគឺពីព្រោះគាត់កំពុងតែការពារទាស់ប្រឆាំងនឹងវប្បធម៌ដ៏អាក្រក់ ហើយផ្ដល់ប្រឹក្សាដែលមានសីលធម៌បែបនេះ «ពេលស្រេក កូនៗចង់ញ៉ាំទឹក។ នេះព្រោះកូនៗមានវ័យក្មេងពេកក្នុងការផឹកស្រា។ ថ្ងៃមួយកូនៗនឹងរៀបការ ហើយនឹងមានបន្ទប់ទុកដាក់ស្រាជាមិនខាន។ ពេលនោះកូនៗនឹងមានអារម្មណ៍ចង់ផឹកអ្វីផ្សេងទៀត។ កាលដល់ពេលនោះ នោះកូនៗនឹងមានទម្លាប់ល្អក្នុងការមិនចុះចូលនឹងអារម្មណ៍ស្រេកឃ្លានរបស់ខ្លួន។» តាមរយៈយុទ្ធសាស្ត្របែបនេះ និងតាមរយៈអំណាចរបស់គាត់ គាត់ក៏បានរារាំងក្មេងៗពីការបំពេញការប្រាថ្នារបស់ពួកគេ ថែមទាំងដាក់កម្រិតលើការស្រេករបស់ពួកគេទៀតផង ដើម្បីកុំឲ្យកូនៗចង់បាននូវអ្វីដែលគេមិនគួរមាន។

១៨. ទោះជាយ៉ាងណាក្ដី អ្នកបម្រើម្នាក់នេះរបស់ព្រះអង្គបានលន់តួចំពោះទូលបង្គំដែលជាកូនប្រុសរបស់គាត់ថា គាត់ក៏បានចាប់ផ្ដើមចូលចិត្តស្រាដែរ។ ឪពុកម្ដាយគាត់គិតថា គាត់គឺជាស្ត្រីដែលមិនចូលចិត្តស្រា ដូច្នេះហើយបានជាពួកគាត់ចូលចិត្តប្រើឲ្យ

គាត់ចុះទៅយកស្រានៅបន្ទប់ទុកស្រា។ ប៉ុន្តែ មុនគាត់ចាក់ស្រាចូលដប គាត់តែងតែយកកូនពែងដាក់ក្រោមកន្លែងបើក ហើយភ្លក់ស្រានោះនៅលើបបូរមាត់របស់គាត់ ពោលគឺភ្លក់យូរជាងគាត់គួរអនុញ្ញាត។ គាត់មិនបានធ្វើបែបនោះ ពីព្រោះគាត់ចូលចិត្តស្រានោះទេ ប៉ុន្តែជាការបង្ហាញអំពីភាពភ្លើតភ្លើននៃយុវវ័យ។ មនុស្សវ័យចំណាស់ៗនៅជុំវិញគាត់តែងតែនិយាយផាដាក់ភាពជាក្មេងឈាមរាវ និងការអរសប្បាយនៃភាពជាយុវជននេះ។ ដូច្នេះ គាត់ក៏បន្ថែមស្រាបន្តិចម្តងៗថែមទៀតជារៀងរាល់ថ្ងៃ ដ្បិតបុគ្គលដែលមិនស្តាប់រឿងតូចតាចក៏នឹងដួលពីបន្តិចនៅខាងនេះ បន្តិចនៅខាងនោះជាមិនខាន។ គាត់ក៏បានរអិលចូលទម្លាប់នោះ ហើយក៏ថែមទាំងចូលចិត្តបង្ហើយស្រាដែលមាននៅក្នុងកូនពែងនោះ ដែលស្ទើរតែជិតពេញតែម្តង។

តើអ្នកបម្រើដែលមានវ័យចំណាស់ ហើយពេញទៅដោយប្រាជ្ញា ដែលអមដោយការគ្រប់គ្រងយ៉ាងតានតឹងនោះនៅឯណានៅពេលនោះ? ឱព្រះអម្ចាស់អើយ! តើមានអ្វីអាចព្យាបាលជំងឺលាក់បាំងរបស់យើងបានទេ ប្រសិនបើថ្នាំរបស់ព្រះអង្គមិនបានមើលថែយើង? ទោះបើឪពុកម្ដាយ និងម៉ែដោះមិនមានវត្តមានក៏ព្រះអង្គនៅមានព្រះវត្តមានដែរ។ ព្រះអង្គគឺជាព្រះអាទិករ ជាព្រះដែលត្រាស់ហៅ និងប្រើប្រាស់មនុស្សដែលទ្រង់បានដាក់នៅលើយើង ដើម្បីជាប្រយោជន៍សម្រាប់សេចក្តីសង្គ្រោះរបស់យើង។ ឱព្រះជាម្ចាស់អើយ! តើព្រះអង្គបានធ្វើអ្វីនៅពេលនោះ? តើព្រះអង្គបានព្យាបាលគាត់ដោយរបៀបណា? តើទ្រង់បានធ្វើឲ្យគាត់ល្អទាំងស្រុងវិញដោយរបៀបណា?

ព្រះអង្គបានប្រើប្រាស់ព្រលឹងរបស់ស្ត្រីម្នាក់ទៀត ដោយមានការស្តីបន្ទោសយ៉ាងឈឺចាប់ និងពិបាកទទួលយក ប្រៀបដូចជាកូនកាំបិតវះកាត់ដែលមានមុខពីរដែលទ្រង់មានក្នុងកាបូបលាក់បាំងរបស់ទ្រង់។ ដោយគ្រាន់តែមួយឆ្នូត នោះព្រះអង្គបានវះរបួសដែលងាយឆ្លងនោះបាន។ មានបាវបម្រើស្រីម្នាក់ដែលពេលខ្លះចុះទៅកន្លែងយកស្រាជាមួយគាត់ ហើយឈ្លោះគ្នាពេលដែលពួកគាត់នៅតែឯង។ នាងបានលើកឡើងអំពីអំពើបាបមួយនេះ ហើយបានស្តីបន្ទោសយ៉ាងឈឺចាប់ដោយហៅគាត់ថា "នាងប្រមឹក"។ សម្តីឡកឡឺយនោះបានធ្វើឲ្យអ្នកម្តាយទូលបង្គំឈឺចាប់ គាត់ក៏ឃើញភាពថោកទាបរបស់ខ្លួន ហើយភ្លាមៗនោះក៏រាប់ថាវាខុសឆ្គង ក៏បោះបង់វាចោលតែម្តង។

ដូចដែលការអួតបញ្ចោររបស់ពួកម៉ាកធ្វើឲ្យមានការពុករលួយ នោះជាទូទៅសម្តី

ឡុកឡឺយរបស់ខ្មាំងសត្រូវក៏មានការណែនាំផងដែរ។ អ្នកបម្រើស្រីម្នាក់នោះចង់ធ្វើឲ្យថៅហ្វាយស្រីរបស់គាត់ខឹង មិនមែនចង់ព្យាបាលគាត់ទេ។ នោះឯងជាមូលហេតុដែលនាងបាននិយាយនៅពេលដែលពួកគាត់នៅតែឯង។ ឬក៏ទំនងមកពីការឈ្លោះប្រកែករបស់ពួកគាត់កើតឡើងតែនៅក្នុងពេលវេលា និងទីកន្លែងនោះក៏មិនដឹង ឬក៏ទំនងមកពីនាងខ្លាចថានឹងទទួលទារុណកម្មដោយមិនបានប្រាប់នរណាអំពីរឿងនោះទាន់ពេល។

ប៉ុន្តែទ្រង់ ឱព្រះអម្ចាស់ ដែលជាអង្គសោយរាជ្យលើផ្ទៃមេឃ និងផែនដី ដែលជាអង្គបំផ្លាស់បំប្រែទឹកជំនន់ដ៏ជោរជន់ និងគ្រប់គ្រងលើរលកដ៏វិលវល់នៃពេលវេលាសម្រាប់គោលបំណងរបស់ទ្រង់ គឺព្រះអង្គហើយដែលបានព្យាបាលបុគ្គលមួយតាមរយៈកំហុសរបស់បុគ្គលម្នាក់ទៀត។ ព្រះអង្គធ្វើបែបនេះ ដើម្បីកុំឲ្យមានបុគ្គលណាម្នាក់អះអាងថា ចិត្តដែលទទួលបានការបំផ្លាស់បំប្រែគឺជាការកើតឡើងចេញពីអំណាចរបស់ខ្លួន ឬក៏ទទួលជឿថា បុគ្គលណាម្នាក់ទៀតអាចទទួលបានការបំផ្លាស់បំប្រែតាមរយៈពាក្យសម្ដីរបស់ខ្លួន។

១៩. គាត់ធំធាត់ឡើងដោយមានការដាក់ខ្លួន ការមិនស្រវឹងស្រា និងការចុះចូលចំពោះឪពុកម្ដាយរបស់គាត់តាមរយៈព្រះអង្គ មិនមែនតាមរយៈឪពុកម្ដាយរបស់គាត់ចំពោះព្រះអង្គ។ ពេលគាត់ពេញវ័យរៀបការ ឪពុកម្ដាយគាត់ក៏រៀបការឲ្យគាត់។ គាត់ក៏បានបម្រើប្ដីរបស់គាត់ដូចជាលោកម្ចាស់។ គាត់ខំប្រឹងយ៉ាងខ្លាំងក្នុងការបញ្ចុះបញ្ចូលឲ្យប្ដីគាត់ទទួលជឿទ្រង់។ ព្រះអង្គបាននាំគាត់ឲ្យមានការឯកភាពដែលចេះចុះចូល ហើយឲ្យប្ដីសរសើរគាត់ ហើយគាត់បានប្រកាសអំពីព្រះអង្គតាមរយៈឥរិយាបថរបស់គាត់។ គាត់ទ្រាំទ្រដោយមានការអត់ធ្មត់ទាក់ទងនឹងអំពើផិតក្បត់របស់ប្ដីគាត់ ហើយក៏មិនដែលទាស់ប្រឆាំងឈ្លោះប្រកែកជាមួយគាត់អំពីប្រធានបទនេះទៀតផង។ គាត់បន្តរង់ចាំសេចក្ដីមេត្តាករុណារបស់ព្រះអង្គលើប្ដីរបស់គាត់រហូតដល់គាត់ទំនងជានឹងក្លាយជាមនុស្សបរិសុទ្ធតាមរយៈជំនឿលើព្រះអង្គ។

ទោះបើប្ដីរបស់គាត់មានចិត្តសប្បុរសដ៏ពិតក៏ដោយ ក៏ប្ដីរបស់គាត់មានអំពើហិង្សាក្នុងកំហឹងរបស់គាត់ដែរ។ គាត់បានរៀនថា ពេលដែលប្ដីកំពុងខឹង គាត់មិនគួរទៅតយុទ្ធក្នុងពាក្យសម្ដី ឬក៏ឥរិយាបថឡើយ។ ដូច្នេះ ទាល់តែពេលប្ដីរបស់គាត់មានអារម្មណ៍ស្ងប់ស្ងាត់ ហើយអ្នកម្ដាយទូលបង្គំឃើញថាមានពេលវេលាដ៏ត្រឹមត្រូវ នោះទើបគាត់ចូលទៅពន្យល់អំពីទង្វើរបស់គាត់ដែលទំនងជាបានធ្វើឲ្យប្ដីរបស់គាត់មានឥរិយាបថមិនសមហេតុសម

ផល។ ជាលទ្ធផល ខណៈពេលដែលប្រពន្ធជាច្រើននាក់ ដែលមានប្ដីដែលស្លូតបូតជាង មានការបង្ហាញអំពីការធ្វើបាបខាងឯសាច់ឈាមដូចជាការជាំមុខ ហើយនៅពេលដែលពួកគេទម្លាក់កំហុសលើប្ដីខ្លួនដោយមានការនិយាយលួចលាក់ ក៏គាត់ស្ដីឲ្យពួកគេដែលនិយាយបែបនោះផងដែរ។ គាត់បានព្រមានពួកគេ ទោះបើក្នុងរបៀបនិយាយលេងសើច ដោយថាតាមរយៈពាក្យសម្បថក្នុងជីវិតអាពាហ៍ពិពាហ៍របស់ពួកគេ នោះពួកគេបានក្លាយជាអ្នកបម្រើរបស់ប្ដីហើយ។ ដោយមានគំនិតបែបនោះ នោះអ្នកបម្រើមិនគួរទាស់ប្រឆាំងនឹងលោកម្ចាស់របស់ខ្លួនឡើយ។

ពួកគេដឹងអំពីការទ្រាំទ្ររបស់គាត់ គឺថាប្ដីរបស់គាត់ងាយច្រឡោត ហើយខឹង។ ហើយពួកគេក៏មានការភ្ញាក់ផ្អើលត្រង់ថា មិនមានការនិយាយដើម ឬក៏ចំណុចសម្គាល់ដែលថាលោក ផាទ្រីស៊ីអូស៍ ធ្លាប់វាយគាត់ ឬក៏ថាធ្លាប់មានការឈ្លោះប្រកែកគ្នានៅក្នុងផ្ទះ សូម្បីតែមួយថ្ងៃក៏មិនដែលឮផង។ នៅពេលដែលពួកគេលួចសួរគាត់ដោយស្ងាត់ៗអំពីរឿងនេះ គាត់ក៏បានបង្រៀនពួកគេអំពីច្បាប់នៃការធ្វើជាអ្នកបម្រើ។ មានអ្នកខ្លះមើល ហើយត្រាប់តាមដូចជាប្រាជ្ញា ហើយក៏មានអំណរ។ ប៉ុន្តែ ក៏មានអ្នកខ្លះទៀតមិនបានមើល ហើយត្រាប់តាម ហើយថែមទាំងធ្វើឲ្យសាំចិត្ត និងទទួលការសំឡុតចិត្តទៀតផង។[១]

២០. ដំបូង ម្ដាយក្មេករបស់អ្នកម្ដាយទូលបង្គំមិនចូលចិត្តគាត់ទេ ព្រោះមានអ្នកបម្រើមួយចំនួនបាននិយាយដើមយ៉ាងអាក្រក់អំពីគាត់។ ប៉ុន្តែ សូម្បីតែម្ដាយក្មេករបស់គាត់ក៏ចូលចិត្តគាត់តាមរយៈឥរិយាបថនៃការចុះចូល និងការទ្រាំទ្ររបស់គាត់បែបនេះ។ ម្ដាយក្មេកគាត់បានប្រាប់កូនប្រុសគាត់ថា អ្នកបម្រើទាំងនោះបានព្យាយាមបំផ្លាញសន្តិភាពរវាងគាត់ និងកូនប្រសាររបស់គាត់ ហើយគាត់ថែមទាំងអង្វរឲ្យកូនប្រុសគាត់ដាក់ទារុណកម្មលើអ្នកបម្រើទាំងនោះដែរ។ គេក៏បានវាយអ្នកបម្រើទាំងនោះ ហើយម្ដាយក្មេកក៏ថែមទាំងគំរាមថា គាត់នឹងដាក់ទោសអស់អ្នកណាដែលព្យាយាមអែបអបនឹងគាត់ដោយប្រើប្រាស់ការនិយាយដើមបង្ខូចកូនប្រសាររបស់គាត់។ បន្ទាប់ពីនោះ គ្មានអ្នកណាហ៊ានទេ ហើយស្ត្រីទាំងពីរនាក់ក៏បានរស់នៅជាមួយគ្នាដោយមានសុច្ឆន្ទៈ និងមិត្តភាពល្អ។

[១] ព្រះគម្ពីរមិនអភ័យទោសការធ្វើបាបពីដៃគូជីវិតនោះទេ តាមពិតទៅគឺផ្ទុយពីនេះទាំងស្រុង គឺព្រះគម្ពីរបានថ្កោលទោសអំពើបែបនោះ (សុភាសិត ៦:១៦-១៩; កូឡូស ៣:១៩; ១ពេត្រុស ៣:៧)។ ត្រង់នេះលោកគ្រូ អហ្គូស្ទីន កំពុងតែនិយាយអំពីរបៀបដែលអ្នកម្ដាយរបស់គាត់ ដែលបានរៀបការជាមួយនឹងអ្នកមិនជឿ អាកប្បកិរិយាស្លូតបូត និងការចុះចូលជាទូទៅនឹងបង្វែរកំហឹង (សុភាសិត ១៥:១)។ ប៉ុន្តែ ប្រសិនបើដៃគូជីវិតរបស់លោកអ្នកកំពុងតែធ្វើបាបលោកអ្នក នោះសូមមេត្តារកជំនួយពីអស់អ្នកដែលនៅជុំវិញលោកអ្នកដែលលោកអ្នកគោរព និងពីអាជ្ញាធរចុះ។

២១. ឱព្រះជាម្ចាស់ដ៏ជាក្ដីមេត្តាករុណារបស់ទូលបង្គំអើយ ព្រះអង្គបានប្រទានអំណោយទានដ៏អស្ចារ្យមួយទៀតទៅកាន់អ្នកបម្រើស្ត្រីដ៏ល្អរបស់ទ្រង់ដែរ។ គឺថាគាត់បានបង្ហាញឥរិយាបថជាអ្នករក្សាសន្តិភាពនៅពេលណាដែលគាត់អាចធ្វើបាន។ ពេលខ្លះអណ្ដាតនៃមិត្តភក្តិចូលចិត្តនិយាយដើមយ៉ាងអាក្រក់អាក្រីអំពីខ្មាំងសត្រូវ។ នៅពេលដែលគាត់ឮពាក្យពេចន៍ដ៏ល្វីងជូរចត់នៃការនិយាយដើម ឬក៏ការមិនឯកភាពគ្នា នោះគាត់នឹងមិននិយាយអ្វីតបទៅនឹងបុគ្គលម្នាក់នោះទេ លុះត្រាតែវានឹងជួយឲ្យមានការផ្សះផ្សា។

មើលទៅ នេះទំនងជារឿងតូចតាច។ ប៉ុន្តែ ជាការដ៏គួរឲ្យសោកស្ដាយ ដោយសារមេរោគដ៏អាក្រក់នៃអំពើបាប ទូលបង្គំក៏បានឮមនុស្សដែលរាប់មិនអស់បានលើកឡើងម្ដងទៀតអំពីពាក្យពេចន៍នៃកំហឹងរបស់បុគ្គលណាម្នាក់ផ្សេងទៀតដែរ។ ហើយអាក្រក់ជាងនោះទៅទៀត គឺពួកគេបានថែមរបោយលើអ្វីដែលមិនទាំងបានលើកឡើងផង។ វាមិនល្អមគ្រប់គ្រាន់ទេសម្រាប់បុគ្គលដែលមានទឹកចិត្តល្អក្នុងការចៀសចេញពីការឈ្លោះប្រកែកគ្នាឲ្យកាន់តែខ្លាំងជាងមុន ដោយពាក្យពេចន៍អាក្រក់ៗ។ ពួកគេក៏គួរព្យាយាមដោះស្រាយបញ្ហាដោយប្រើពាក្យពេចន៍ដែលមានសន្តានចិត្តល្អវិញ។ អ្នកម្ដាយទូលបង្គំគឺជាបុគ្គលបែបនោះ។ គឺព្រះអង្គហើយ ដែលជាអ្នកណែនាំយ៉ាងកៀកបង្កើយនឹងគាត់ ដែលបានបង្រៀនគាត់ក្នុងសាលានៃដួងចិត្តគាត់។

២២. នៅទីបំផុត ខណៈពេលដែលប្ដីរបស់គាត់ឈានដល់គ្រាចុងក្រោយនៃពេលវេលាលើផែនដីនេះ គាត់ក៏បានយកឈ្នះលើប្ដីរបស់គាត់សម្រាប់ព្រះអង្គ។ ដូច្នេះ គាត់លែងមានការរអ៊ូរទាំទាក់ទងនឹងភាពអត់ធ្មត់លើការមិនស្មោះត្រង់របស់ប្ដីគាត់ ដ្បិតឥឡូវប្ដីរបស់គាត់បានក្លាយជាអ្នកស្មោះត្រង់ម្នាក់ហើយ។

អ្នកម្ដាយទូលបង្គំក៏ជាអ្នកបម្រើម្នាក់នៃអ្នកបម្រើនានារបស់ព្រះអង្គដែរ។ អស់អ្នកដែលស្គាល់គាត់ក៏សរសើរព្រះអង្គ ថ្វាយព្រះកិត្តិយសដល់ទ្រង់ និងស្រឡាញ់ទ្រង់យ៉ាងខ្លាំងតាមរយៈគាត់ផងដែរ។ ពួកគេឃើញព្រះវត្តមានរបស់ទ្រង់ក្នុងដួងចិត្តរបស់គាត់តាមរយៈការធ្វើបន្ទាល់អំពីទ្រង់ និងផលផ្លែនៃជីវិតដ៏បរិសុទ្ធរបស់គាត់។ គាត់បានធ្វើជាប្រពន្ធតែម្នាក់ចំពោះប្ដីតែមួយ បានផ្ដល់កិត្តិយសដល់ឪពុកម្ដាយគាត់ បានណែនាំអ្នកផ្ទះរបស់គាត់ក្នុងផ្លូវនៃការកោតខ្លាចព្រះ។ អ្នកផ្សេងក៏ស្គាល់គាត់តាមរយៈទង្វើល្អៗរបស់គាត់ ហើយក៏ខិតខំប្រឹងប្រែងយ៉ាងប្រយ័ត្នទាក់ទងនឹងការចិញ្ចឹមបីបាច់ថែរក្សាកូនៗដោយពុំ

ឲ្យងាកបែរចេញពីព្រះអង្គ។ ជាចុងក្រោយ ឱព្រះអម្ចាស់អើយ ដោយសារទ្រង់អនុញ្ញាតឲ្យអ្នកបម្រើរបស់ទ្រង់និយាយ គឺថាគាត់បានបង្ហាញភក្ដីភាពយ៉ាងជ្រាលជ្រៅតាមរយៈការមើលថែរាស្ត្ររបស់ទ្រង់ដែលគាត់ស្គាល់ ប្រៀបដូចជាម្ដាយចំពោះយើងទាំងអស់គ្នា ទោះបើគាត់បានបម្រើ ប្រៀបដូចជាកូនស្រីចំពោះយើងទាំងអស់គ្នាក៏ដោយ។

២៣. ថ្ងៃដែលម្ដាយទូលបង្គំត្រូវលាចាកចេញពីជីវិតនេះបានឈានមកដល់ ជាថ្ងៃដែលមានតែទ្រង់មួយអង្គជ្រាប ហើយក៏មានពេលដែលគាត់ និងទូលបង្គំបាននៅតែពីរនាក់។ ទូលបង្គំជឿជាក់ថា តាមរយៈផ្លូវដ៏អាថ៌កំបាំងរបស់ទ្រង់គឺទ្រង់បានរៀបចំពេលវេលានោះ។ កាលនោះ យើងកំពុងផ្អែកលើបង្អួចដែលមើលឃើញសួនច្បារនៅផ្ទះយើងនៅឯទីក្រុង អូស្ទៀ (Ostia)។ យើងបានដកខ្លួនចេញពីហ្វូងមនុស្ស ដើម្បីសម្រាក ដោយសារយើងទើបតែធ្វើដំណើរមកពីផ្លូវឆ្ងាយ។

យើងទាំងពីរនាក់កំពុងតែមានការសន្ទនាយ៉ាងរាក់ទាក់ ហើយ «ភ្លេចសេចក្ដីទាំងប៉ុន្មានដែលកន្លងទៅហើយ ក៏ខំមមុលឈោងទៅរកអ្វីៗខាងមុខទៀត»។[២] ក្នុងព្រះវត្តមាននៃសេចក្ដីពិត គឺព្រះអង្គផ្ទាល់ យើងកំពុងតែពិភាក្សាគ្នាអំពីលក្ខណៈសម្បត្តិនៃជីវិតដ៏នៅអស់កល្បជានិច្ចសម្រាប់ពួកបរិសុទ្ធទាក់ទងនឹង «អ្វីដែលភ្នែកមិនដែលឃើញ ត្រចៀកមិនដែលឮ ហើយចិត្តមនុស្សមិនដែលនឹកដល់»។[៣] មាត់នៃដួងចិត្តរបស់យើងក៏បានបើកចំហ ហើយស្រេកទឹកពីស្ថានសួគ៌ដែលមានប្រភពពីព្រះអង្គ៖ «ប្រភពទឹកនៃជីវិត»[៤] ហើយក៏ចង់ទទួលបានការប្រោះព៌ទឹកនោះ ដើម្បីឲ្យយល់ តាមដែលអាចធ្វើបាន លើសេចក្ដីពិតមួយចំនួននៃអាថ៌កំបាំងដ៏អស្ចារ្យនេះ។

២៤. ការសន្ទនារបស់យើងបានឈានដល់ចំណុចត្រង់ថា សូម្បីតែញាណដ៏ខ្លាំងបំផុតខាងឯសាច់ឈាម និងពន្លឺខែខាងឯសម្ភារៈនិយមដ៏ខ្លាំងក្លាបំផុតក៏មិនស័ក្ដិសមនឹងយកមកប្រៀបផ្ទឹមជាមួយនឹងភាពផ្អែមល្ហែមនៃជីវិតដ៏នៅអស់កល្បជានិច្ចដែលនឹងមកដល់បានដែរ។ យើងក៏មានភាពស្ញប់ស្ញែងលើរបស់សព្វសារពើដែលព្រះអង្គបានបង្កើត ហើយមិនយូរមិនឆាប់រំលងវត្ថុខាងឯសម្ភារៈនិយមទាំងអស់ សូម្បីតែស្ថានសួគ៌ដែលជាកន្លែងរបស់ព្រះអាទិត្យ ព្រះចន្ទ និងផ្កាយដែលចាំងពន្លឺលើផែនដី។ ទោះជា

២ ភីលីព ៣:១៣។
៣ ១កូរិនថូស ២:៩។
៤ ទំនុកតម្កើង ៣៦:៩។

យ៉ាងណាក្តីក្នុងចិត្តគំនិតយើង យើងក៏បានហើរកាន់តែខ្ពស់ឡើងៗ ដោយនិយាយរៀបរាប់ និងស្រឡាញ់ពេញចិត្តលើអ្វីដែលទ្រង់បានបង្កើតមកដែរ។

យើងបាននិយាយ ហើយក៏បានដេញចាប់ប្រាជ្ញា ហើយក៏បានប៉ះវាយ៉ាងតិចតួចតាមរយៈការខិតខំប្រឹងប្រែងយ៉ាងអស់ពីចិត្តរបស់យើង។ យើងក៏បានដកដង្ហើមធំ ហើយក៏ទុកផលដំបូងនៃវិញ្ញាណឲ្យជាប់ជាមួយនឹងភាពដ៏សប្បាយនោះ។ យើងក៏ត្រឡប់មកឯសំឡេងនៃមាត់របស់យើង ដែលជាកន្លែងចាប់ផ្តើម និងបញ្ចប់ពាក្យពេចន៍។ ប៉ុន្តែ ការនេះមិនដូចព្រះបន្ទូលរបស់ទ្រង់ទេ គឺព្រះអម្ចាស់យើង ព្រះអង្គនៅដោយមិនចម្រើនវ័យចំណាស់ ហើយក៏ថែមទាំងធ្វើឲ្យគ្រប់អ្វីៗទាំងអស់ថ្មីទៀតផង។

២៦. បន្ទាប់មក អ្នកម្តាយទូលបង្គំបានមានប្រសាសន៍ដូចតទៅ៖ «កូនម្តាយអើយ! ឥឡូវម្តាយលែងអរសប្បាយនឹងអ្វីទៀតហើយក្នុងជីវិតនេះ។ ក្តីសង្ឃឹមនានារបស់ម្តាយក្នុងលោកីយ៍នេះគឺត្រូវបានស្កប់ចិត្តហើយ។ គ្មានអ្វីដែលត្រូវចង់បានទៀតទេ។ តើហេតុអ្វីបានជាម្តាយនៅទីនេះ? ពិតណាស់មានរឿងមួយដែលម្តាយសង្ឃឹមចង់ឃើញក្នុងជីវិតនេះ ហើយរឿងនោះគឺឲ្យឃើញកូនក្លាយជាគ្រីស្ទបរិស័ទដ៏ពិតមុនម្តាយស្លាប់ទៅ។ ព្រះជាម្ចាស់របស់ម្តាយបានឆ្លើយតបលើសជាងសេចក្តីសប្បុរសចំពោះម្តាយហើយ។ ឥឡូវម្តាយឃើញថាកូនបានក្លាយជាអ្នកបម្រើរបស់ទ្រង់ ហើយក៏បានបដិសេធរាល់ចំណុចអរសប្បាយលើលោកនេះផងដែរ។ នៅទីនេះ តើនៅមានអ្វីដែលម្តាយអាចធ្វើបានទៀត?»។

២៧. ទូលបង្គំមិនចាំអំពីរបៀបដែលទូលបង្គំឆ្លើយតបទៅកាន់អ្នកម្តាយទូលបង្គំវិញអំពីចំណុចនេះនោះទេ។ មិនបានប្រមាណប្រាំថ្ងៃក្រោយមកគាត់ក៏បានគ្រុនក្តៅ។ ថ្ងៃមួយខណៈពេលដែលគាត់កំពុងឈឺ គាត់ក៏បានដួល ហើយសន្លប់មួយភ្លែតដែរ។ ប្អូនប្រុសរបស់ទូលបង្គំ និងទូលបង្គំក៏បានរត់ទៅជួយគាត់។ មិនយូរប៉ុន្មាន គាត់ក៏បានដឹងខ្លួនវិញ ហើយមើលមកយើងខណៈពេលដែលយើងកំពុងឈរក្បែរគាត់។ គាត់បានសួរថា «តើមុនហ្នឹងម្តាយនៅឯណា?»។ គាត់បានខំមើលយើងយ៉ាងខ្លាំង និយាយមិនចេញក្នុងទុក្ខព្រួយ ហើយលើកឡើងថា «កូននឹងកប់ម្តាយនៅកន្លែងនេះ»។ ទូលបង្គំនៅយ៉ាងស្ងៀម ហើយទប់អារម្មណ៍ដោយមិនយំ ខណៈពេលដែលប្អូនប្រុសរបស់ទូលបង្គំលើកឡើងអំពីសេចក្តីប្រាថ្នាត្រង់ថា គាត់មិនចង់ឃើញអ្នកម្តាយស្លាប់នៅស្រុកក្រៅឡើយ ប៉ុន្តែនៅស្រុកខ្លួនវិញ។ ពេលដែលគាត់ឮចំណុចនោះ គាត់ក៏បានសម្លឹងមើលប្អូនប្រុសទូលបង្គំចំនឹង

ភ្នែក ហើយមុខរបស់គាត់ក៏បានបង្ហាញពីភាពព្រួយបារម្ភ ពីព្រោះប្អូនប្រុសរបស់ទូលបង្គំខ្វល់ខ្វាយពីអ្វីដែលទាក់ទងនឹងលោកីយ៍នេះ។ បន្ទាប់មក គាត់ក៏បានបែរមកមើលទូលបង្គំ ហើយលើកឡើងថា «ចូរមើលអំពីរបៀបដែលប្អូនប្រុសកូននិយាយ»។ ហើយគាត់ក៏បាននិយាយមកកាន់ពួកយើងថា «កប់សពអ្នកម្ដាយទូលបង្គំនៅទីណាក៏បាន ចូរកុំឲ្យវាធ្វើឲ្យកូនព្រួយបារម្ភឲ្យសោះ។ ម្ដាយសូមឲ្យតែកូនៗនឹកចាំអំពីម្ដាយនៅឯអាសនារបស់ព្រះអម្ចាស់ និងនៅទីណាដែលកូនទៅ»។ ហើយបន្ទាប់ពីគាត់បានចែកចាយអំពីសេចក្ដីប្រាថ្នារបស់គាត់ក្នុងលក្ខណៈដ៏ល្អបំផុតដែលគាត់អាចធ្វើបាន គាត់ក៏បាននៅស្ងៀម មានពេញទៅដោយភាពឈឺចាប់ដែលកើតចេញពីជំងឺរបស់គាត់។

២៨. ឱព្រះដែលមិនអាចមើលឃើញអើយ! ខណៈពេលដែលទូលបង្គំបានគិតអំពីអំណោយទានរបស់ព្រះអង្គ ដែលទ្រង់បានដាំក្នុងដួងចិត្តនៃអស់អ្នកដែលស្មោះត្រង់ ហើយចេញពីនោះ វាក៏បានបង្កើតផលផ្លែដ៏ល្អៗ នោះទូលបង្គំមានអំណរ ហើយក៏អរព្រះគុណព្រះអង្គផងដែរ។ ទូលបង្គំចាំថាពីមុនអ្នកម្ដាយរបស់ទូលបង្គំតែងតែខ្វល់ខ្វាយខ្លាំងណាស់អំពីទីកន្លែងកប់សពរបស់គាត់។ គាត់បានផ្ដត់ផ្ដង់ ហើយរៀបចំកន្លែងមួយសម្រាប់គាត់នៅក្បែរសពរបស់ប្ដីគាត់។ ដោយសារពួកគាត់បានរស់នៅជាមួយគ្នាដោយមានសុភមង្គល ដូច្នេះគាត់តែងតែប្រាថ្នាចង់បន្ថែមចំណុចចុងក្រោយនេះទៅក្នុងសុភមង្គលមួយនោះ។ ចិត្តគំនិតរបស់មនុស្សយើងគ្មានសមត្ថភាពក្នុងការយល់អំពីចំណុចពាក់ព័ន្ធនឹងព្រះជាម្ចាស់ទេ។ គាត់ចង់ឲ្យអ្នកដទៃសរសើរអំពីរបៀប បន្ទាប់ពីគាត់បានធ្វើដំណើរធម្មយាត្រាហួសសមុទ្រ ដូចដែលគាត់ទាំងពីរនាក់បានរួមគ្នាលើផែនដីនេះ នោះគាត់ក៏នឹងរួបរួមគ្នាក្នុងផ្នូរផងដែរ។

ទូលបង្គំមិនដឹងអំពីពេលវេលា តាមរយៈសេចក្ដីសប្បុរសដ៏បរិបូណ៌របស់ព្រះ ដែលគំនិតឥតប្រយោជន៍នេះបានចាប់ផ្ដើមរសាត់ចេញពីដួងចិត្តរបស់គាត់ទេ។ ពេលនោះទូលបង្គំភ្ញាក់ផ្អើលយ៉ាងខ្លាំង និងពេញដោយអំណរអំពីអ្វីដែលគាត់ទើបតែបានប្រាប់មកកាន់ទូលបង្គំ។ ពិតណាស់! ក្នុងការសន្ទនារបស់យើងនៅឯមាត់បង្អួច គាត់បានបង្ហាញអំពីសេចក្ដីប្រាថ្នាដែលថាគាត់មិនខ្វល់បើជាគាត់មិនស្លាប់នៅឯស្រុករបស់គាត់ នៅពេលដែលគាត់លើកឡើងថា «នៅទីនេះ តើនៅមានអ្វីដែលអ្នកម្ដាយអាចធ្វើបានទៀតទៅ?»។ ក្រោយមក ទូលបង្គំបានឮអំពីការដែលគាត់បាននិយាយស្ដីជាមួយនឹង

មិត្តភក្តិរបស់ទូលបង្គំមួយចំនួន ខណៈពេលដែលយើងនៅទីក្រុងអូស្លៀ។ ដោយមានទំនុកចិត្តបែបជាម្ដាយ គាត់បានប្រាប់ពួកគេអំពីភាពសម្ផប់របស់គាត់សម្រាប់ជីវិតនេះ និងអំពីព្រះពរនៃការស្លាប់។ តាមរយៈភាពក្លាហានដែលព្រះអង្គបានប្រទានមកកាន់អ្នកម្ដាយទូលបង្គំ ការនោះបានធ្វើឲ្យពួកគាត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង។ ពួកគាត់បានសួរអ្នកម្ដាយទូលបង្គំថា តើលោកអ៊ំមានភាពភ័យខ្លាចដែរឬទេ ទាក់ទងនឹងការដែលគេនឹងកប់សពរបស់អ្នកមីងយ៉ាងឆ្ងាយពីស្រុកកំណើតរបស់ខ្លួន? អ្នកម្ដាយទូលបង្គំបានឆ្លើយដូចតទៅ៖ គ្មានអ្វីឆ្ងាយពីព្រះជាម្ចាស់ទេ។ អ៊ំមិនខ្លាចទេ។ នៅគ្រាចុងក្រោយ ព្រះអង្គនឹងស្គាល់ទីកន្លែងដែលគេនិងបញ្ចុះសព ទ្រង់នឹងលើកអ៊ំពីស្លាប់ឡើងវិញ។ ហើយនៅថ្ងៃទី៩ បន្ទាប់ពីគាត់បានធ្លាក់ខ្លួនឈឺ គាត់មានអាយុ៥៦ឆ្នាំ (ហើយទូលបង្គំមានអាយុ៣៣ឆ្នាំ) ព្រលឹងដ៏ស្មោះត្រង់ និងពេញដោយភក្តីភាពមួយនោះក៏បានទទួលសេរីភាពចេញពីរូបកាយនេះទៅ។

២៩. ទូលបង្គំក៏បានបិទភ្នែកគាត់ ហើយការសោកស្ដាយធំធេងមួយក៏បានហូរកាត់ដួងចិត្តទូលបង្គំ ហើយក៏បានក្លាយទៅជាទឹកភ្នែកដែលស្រក់ចុះមក។ ប៉ុន្តែ ខួរក្បាលទូលបង្គំបង្ខំភ្នែកទូលបង្គំឲ្យឈប់យំ ហើយការកាន់ទុក្ខរបស់ទូលបង្គំបានបង្កឲ្យទូលបង្គំញ័រខ្លួន។ ពេលដែលគាត់ដកដង្ហើមចុងក្រោយរបស់គាត់ភ្លាម នោះកុមារ អាឌីអូដាទឹស៍ ក៏ស្រែកយំ ហើយយើងបានបញ្ឈប់គាត់ ហើយគាត់ក៏បាននៅស្ងៀម។ ដូចគ្នាផងដែរ អារម្មណ៍ដូចជាកូនក្មេងរបស់ទូលបង្គំក៏ព្យាយាមរកផ្លូវគេចចេញក្នុងការសម្រក់ទឹកភ្នែកតាមរយៈសំឡេងបេះដូងដ៏នៅយុវ័យដែរ។ ទូលបង្គំបានទប់អារម្មណ៍យ៉ាងស្ងៀមស្ងាត់។ យើងបានពិចារណាថា ការអបអរសាទរសេចក្ដីស្លាប់មួយនេះដោយការយំ និងការថ្ងូរគឺមិនមែនជារឿងត្រឹមត្រូវទេ។ ការកាន់ទុក្ខបែបនេះគឺសម្រាប់តែអស់អ្នកដែលបានស្លាប់ដោយមិនមានភាពអរសប្បាយ ហើយគឺពិតជាបានស្លាប់មែនតែប៉ុណ្ណោះ។ ប៉ុន្តែ គាត់មិនបានស្លាប់ដោយមិនអរសប្បាយនោះទេ ហើយគាត់ក៏មិនបានពិតជាស្លាប់មែនដែរ។ យើងដឹងអំពីចំណុចនេះយ៉ាងប្រាកដ។ យើងបានឃើញជីវិតដ៏ល្អរបស់គាត់ «ជំនឿដ៏ស្មោះត្រង់» របស់គាត់[៥] និងភស្តុតាងដ៏ច្បាស់លាស់នានាផ្សេងទៀតរបស់គាត់។

៣០. ជីវិតដ៏មានតម្លៃ និងផ្អែមល្ហែមមួយនេះជាមួយនឹងគាត់ក៏បានបែកបាក់ភ្លាមៗ។

៥ ១ធីម៉ូថេ ១:៥។

តើអ្វីទៅបានធ្វើឲ្យទូលបង្គំឈឺចិត្តយ៉ាងខ្លាំង លើកលែងតែរបួសដ៏ថ្មីមួយនេះ? ទូលបង្គំបានពេញទៅដោយអំណរ ព្រោះអ្នកម្ដាយទូលបង្គំបានធ្វើទីបន្ទាល់អំពីទូលបង្គំដោយសរសើរទូលបង្គំមុនគាត់ស្លាប់ដោយថា ទូលបង្គំជាកូនដែលមានទំនួលខុសត្រូវ ហើយសប្បុរស។ ដោយមានពេញទៅដោយសេចក្ដីស្រឡាញ់ គាត់បានរៀបរាប់អំពីការដែលគាត់នឹងនឹកចាំថា ទូលបង្គំមិនដែលប្រើប្រាស់ពាក្យពេចន៍គំរោះគំរើយ ឬក៏រិះគន់គាត់ឡើយ។ ឱព្រះដ៏ជាព្រះអាទិកររបស់យើងអើយ! តើកិត្តិយសដែលទូលបង្គំផ្ដល់ដល់គាត់ អាចប្រៀបធៀបទៅនឹងអ្វីដែលគាត់បានធ្វើសម្រាប់ទូលបង្គំបានដោយរបៀបណា? ដោយគ្មានការលួងលោមដ៏ល្អរបស់គាត់ នោះទូលបង្គំមិនមានអ្វីនៅសល់ទេ។ ព្រលឹងទូលបង្គំក៏បានកាន់ទុក្ខ ហើយជីវិតទូលបង្គំ ដែលមានរួមទាំងជីវិតរបស់អ្នកម្ដាយទូលបង្គំ និងទូលបង្គំក៏ត្រូវបានបែកគ្នាទៅ។

៣១. ពេលដែលយើងបានលួងឲ្យកុមារនោះឈប់យំ នោះលោក អីវូឌីអូស៍ (Evodius) ក៏បានចាប់ផ្ដើមច្រៀងចេញពីកណ្ឌគម្ពីរទំនុកតម្កើង “ទូលបង្គំនឹងច្រៀងអំពីព្រះហឫទ័យសប្បុរស និងយុត្តិធម៌ ឱព្រះយេហូវ៉ាអើយ ទូលបង្គំនឹងច្រៀងសរសើរព្រះអង្គ” (គកស)។[៦] គ្រួសារទាំងមូលក៏ចូលរួមច្រៀង ហើយដោយឮនូវអ្វីដែលយើងកំពុងតែធ្វើ បងប្អូនប្រុសស្រីជាច្រើននាក់ទៀតក៏បានមកជួបជុំគ្នាផងដែរ។ ខណៈពេលដែលមានអ្នកខ្លះជួយរៀបចំសម្រាប់ពិធីបុណ្យសពតាមបែបបទប្រពៃណី ទូលបង្គំបានសន្ទនាយ៉ាងសុភាពរាបសារនៅឯបន្ទប់មួយទៀតក្នុងផ្ទះជាមួយនឹងអស់អ្នកដែលបានគិតថា ទូលបង្គំមិនគួរនៅតែឯងឡើយ។ តាមរយៈសេចក្ដីពិតដែលជាថ្នាំ ទូលបង្គំក៏ទទួលបានការធូរស្បើយពីទារុណកម្មដែលមានតែទ្រង់មួយអង្គគត់ជ្រាបអំពីចំណុចនោះ។ ពួកគាត់មិនដឹងឡើយ។ ពួកគាត់ស្ដាប់ទូលបង្គំយ៉ាងយកចិត្តទុកដាក់ ហើយគិតថាទូលបង្គំគ្មានការឈឺចាប់ឡើយ។ ប៉ុន្តែក្នុងព្រះកាណ៌របស់ព្រះអង្គ ដែលពួកគាត់មិនអាចស្ដាប់ឮបាន ទូលបង្គំបានរិះគន់ខ្លួនឯងទាក់ទងនឹងអារម្មណ៍ដ៏ទន់ខ្សោយរបស់ខ្លួន ហើយថែមទាំងទប់ភាពជន់ជោរនៃការកាន់ទុក្ខ។ ទូលបង្គំបានចុះចូលនឹងឆន្ទៈរបស់ខ្លួនឯងម្ដងម្កាលដែរ ហើយបន្ទាប់មកក៏បានវាយប្រហារវាជាថ្មីម្ដងទៀត។ ទូលបង្គំដឹងអំពីអ្វីដែលទូលបង្គំលាក់នៅក្នុងដួងចិត្តរបស់ខ្លួន ហើយទូលបង្គំក៏មិនបានអនុញ្ញាតឲ្យខ្លួនស្រែកយំ ឬក៏សូម្បីតែបំផ្លាស់បំប្រែទឹកមុខ

៦ ទំនុកតម្កើង ១០១:១។

ក៏ដោយ។ ទូលបង្គំធុញទ្រាន់ខ្លាំងណាស់ដែលអារម្មណ៍ខាងឯសាច់ឈាមទាំងនេះមានអំណាចយ៉ាងខ្លាំងលើទូលបង្គំ ទោះបើថាសេចក្ដីស្លាប់គឺគ្រាន់តែជាផ្នែកមួយនៃលក្ខណៈធម្មជាតិដែលកើតមានឡើងចំពោះមនុស្សយើងទាំងអស់គ្នាតាមពេលវេលាកំណត់ និងវាសនាក៏ដោយ។ ដូច្នេះ ក្នុងទុក្ខព្រួយថ្មីមួយនេះ ដែលទូលបង្គំកំពុងតែកាន់ទុក្ខព្រួយអំពីការទុក្ខព្រួយរបស់ទូលបង្គំ វាបានធ្វើឲ្យទូលបង្គំរងទុក្ខក្នុងការសោកស្ដាយជាទ្វេដង។

៣២. ពេលគេយកសពចេញ យើងបានត្រឡប់មកវិញដោយមិនយំសោក។ ក្នុងសេចក្ដីអធិស្ឋានដែលយើងបានទូលថ្វាយទៅកាន់ព្រះអង្គ នៅពេលដែលយើងថ្វាយយញ្ញបូជានៃការសង្គ្រោះរបស់យើងទៅកាន់ទ្រង់ សម្រាប់អ្នកម្ដាយទូលបង្គំក៏ទូលបង្គំមិនបានយំដែរ។ ហើយមុនពេលគេបញ្ចុះសពគាត់ គេយកសពគាត់ដាក់ក្បែរផ្នូរជាមុនសិន ព្រោះនោះជាប្រពៃណី ក៏កាលនោះក្នុងសេចក្ដីអធិស្ឋានរបស់ទូលបង្គំក៏ទូលបង្គំមិនបានយំផងដែរ។ ប៉ុន្តែ ទូលបង្គំបានលាក់បាំងការគ្រាំគ្រាចិត្តដ៏ខ្លាំងក្លានោះពេញមួយថ្ងៃ ដោយមិនឲ្យមានអ្នកណាដឹងឡើយ។ ដោយសារចិត្តគំនិតទូលបង្គំពេញទៅដោយទុក្ខកង្វល់ នោះហើយបានជាទូលបង្គំទូលអង្វរព្រះអង្គ តាមដែលទូលបង្គំអាចធ្វើទៅបាន ដោយសូមឲ្យព្រះអង្គព្យាបាលការរងទុក្ខរបស់ទូលបង្គំ ប៉ុន្តែទ្រង់មិនបានធ្វើឡើយ។ ឥឡូវ ទូលបង្គំក៏ជឿថា ទ្រង់កំពុងតែកែមេរៀនមួយនោះក្នុងការចងចាំរបស់ទូលបង្គំ ដើម្បីឲ្យចំណងនៃទំនាក់ទំនងមានអំណាចលើមិត្តភាព សូម្បីតែលើខួរក្បាលដែលលែងរស់ដោយចាញ់ការបោកបញ្ឆោតដែរ។

ទូលបង្គំបានឮថាពាក្យឡាតាំងសម្រាប់ការងូតទឹក [“ប៊ិលនីអូម” “balneum”] គឺជាពាក្យកម្ចីពីភាសាក្រិក “ប៊ិលឡានីអូន” (“balaneion”) ព្រោះវាលាងសម្អាតទុក្ខកង្វល់ចេញពីខួរក្បាល។ ដូច្នេះ ទូលបង្គំគិតថា ទូលបង្គំគួរទៅងូតទឹក។ ឥឡូវ ទូលបង្គំលន់តួចំពោះសេចក្ដីមេត្តាករុណារបស់ព្រះអង្គ “ឱព្រះអង្គដ៏ជាឪពុករបស់ក្មេងកំព្រា”[៧] ទូលបង្គំក៏បានងូតទឹក ហើយក៏គ្មានអារម្មណ៍ខុសប្លែកពីមុនៗឡើយ។ ភាពល្វីងជូរចត់នៃការកាន់ទុក្ខរបស់ទូលបង្គំមិនទទួលបានការលាងជម្រះចេញពីដួងចិត្តទូលបង្គំទេ។ ប៉ុន្តែ ទូលបង្គំក៏បានចូលគេង ហើយនៅពេលដែលទូលបង្គំភ្ញាក់ពីគេងឡើងវិញ គឺទូលបង្គំបានឃើញថា ការកាន់ទុក្ខរបស់ទូលបង្គំក៏បានទទួលការធូរស្រាលយ៉ាងខ្លាំង។ ខណៈពេលដែល

៧ ទំនុកតម្កើង ៦៨:៥។

ទូលបង្គំកំពុងតែដេកនៅលើគ្រែ ទូលបង្គំក៏បាននឹកចាំអំពីសម្រង់សម្ដីដ៏ពិតរបស់លោកគ្រូគង្វាល អែមប្រូស៍។ ព្រះអង្គពិតជា៖

«ព្រះអាទិករនៃយើងទាំងអស់គ្នាអើយ!
ព្រះដែលដឹកនាំហ្វូងតារាវិថី
ព្រះដែលបំពាក់ថ្ងៃដោយពន្លឺដ៏គួរឲ្យស្រឡាញ់
ព្រះដែលប្រទានដំណេកដ៏ពេញដោយព្រះគុណនៅពេលយប់៖
ព្រះគុណរបស់ព្រះអង្គព្យាបាលដៃជើងដ៏នឿយហត់របស់យើង
ហើយដូចពីមុនគឺ ព្រះអង្គប្រទានកម្លាំងសម្រាប់ធ្វើការ
ហើយបន្ធូរការកាន់ទុក្ខនៃខួរក្បាលដែលនឿយហត់
ចេញពីការឈឺចាប់ដ៏ជ្រាលជ្រៅដែលវាជួបប្រទះ»។[៨]

៣៣. បន្ទាប់មក ទូលបង្គំក៏នឹកចាំអំពីរឿងចាស់ៗម្ដងបន្តិចៗអំពីអ្នកបម្រើរបស់ព្រះអង្គ អំពីភក្តីភាពរបស់គាត់ចំពោះព្រះអង្គ និងការមើលថែដ៏ទន់ភ្លន់បរិសុទ្ធរបស់គាត់ចំពោះយើង ដែលភ្លាមៗនោះត្រូវបានដកចេញពីយើង។ ហើយវាក៏ជាការធូរស្បើយសម្រាប់ទូលបង្គំក្នុងការយំក្នុងព្រះវត្តមានរបស់ព្រះអង្គសម្រាប់គាត់ និងសម្រាប់ទូលបង្គំ អំពីគាត់ និងអំពីទូលបង្គំដែរ។ ទូលបង្គំក៏បណ្ដោយទឹកភ្នែកទូលបង្គំឲ្យមានសេរីភាព ដែលទូលបង្គំបានលាក់ ដើម្បីឲ្យវាហូរតាមចិត្ត ដោយលាតត្រដាងវាដូចជាខ្នើយក្រោមដួងចិត្តទូលបង្គំ។ ហើយដួងចិត្តទូលបង្គំក៏ទទួលបានការសម្រាក។ ព្រះអង្គកំពុងតែព្រះសណ្ដាប់ទូលបង្គំដោយយកព្រះទ័យទុកដាក់ គឺមិនដូចមនុស្សដែលនឹងសើចចំអកដាក់ទូលបង្គំ ដោយសារទូលបង្គំយំសោកនោះទេ។ ឱព្រះអម្ចាស់អើយ! ឥឡូវក្នុងការសរសេរកំណត់ហេតុទូលបង្គំ ទូលបង្គំសូមលន់តួទៅកាន់ទ្រង់! អស់អ្នកណាដែលប្រាថ្នា សូមអាន ហើយវិនិច្ឆ័យតាមចិត្តគាត់ចង់ធ្វើចុះ។ ប្រសិនបើបុគ្គលណាម្នាក់សន្និដ្ឋានថា ទូលបង្គំបានប្រព្រឹត្តអំពើបាបក្នុងការយំសោកអស់រយៈពេលប្រមាណមួយម៉ោងសម្រាប់អ្នកម្ដាយទូលបង្គំ ព្រះអង្គអើយសូមកុំឲ្យគេសើចចំអកដាក់ទូលបង្គំឡើយ។ អ្នកម្ដាយមួយនេះ ដែលឥឡូវនេះចំពោះមុខទូលបង្គំ គាត់បានស្លាប់ទៅហើយ ក៏បានយំសោកអស់ជា

៨ លោក Sir Tobie Matthew គឺជាអ្នកបកប្រែសម្រង់សម្ដីនេះដំបូងគេក្នុងភាសាអង់គ្លេស ហើយឥឡូវយើងបានកែសម្រួលសម្រាប់ភាសាខ្មែរ។

ច្រើនឆ្នាំសម្រាប់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចនឹងរស់នៅក្នុងព្រះនេត្ររបស់ព្រះអង្គ។ ប៉ុន្តែ ប្រសិនបើបុគ្គលម្នាក់នោះជាមនុស្សដែលមានពេញទៅដោយសេចក្ដីស្រឡាញ់ដ៏បរិបូណ៌ សូមអនុញ្ញាតឲ្យគាត់យំសម្រាប់អំពើបាបរបស់ទូលបង្គំទាស់នឹងព្រះអង្គចុះ ឱព្រះវរបិតានៃយើងរាល់គ្នា ដែលជាបងប្អូននៃព្រះគ្រីស្ទរបស់ទ្រង់។

៣៤. ឥឡូវនេះ ដួងចិត្តរបស់ទូលបង្គំទទួលបានការព្យាបាលពីរបួសមួយនេះហើយ។ ដូច្នេះ ឱព្រះដ៏ជាព្រះជាម្ចាស់របស់យើងអើយ! ជំនួសអ្នកបម្រើរបស់ព្រះអង្គ ទូលបង្គំសូមសម្រក់ទឹកភ្នែកដែលមានលក្ខណៈខុសប្លែកពីមុនទៅកាន់ព្រះអង្គ។ វាហូរចេញពីព្រលឹងបាក់បែកតាមរយៈការគិតអំពីគ្រោះថ្នាក់នៃរាល់ព្រលឹងទាំងអស់ដែលបានស្លាប់ក្នុងលោកអ័ដាម។ សូម្បីតែមុនគាត់ទទួលបានសេរីភាពចេញពីរូបកាយនេះ ក៏គាត់ «បានមានជីវិត» ក្នុងព្រះគ្រីស្ទហើយដែរ[៩] ហើយចាប់តាំងពីពេលនោះគាត់ក៏សរសើរតម្កើងព្រះនាមរបស់ទ្រង់តាមរយៈជំនឿ និងជីវិតរស់នៅជាប្រចាំថ្ងៃរបស់គាត់ផងដែរ។ ទោះជាយ៉ាងណាក្ដីក៏ទូលបង្គំនឹងមិនអះអាងថា ចាប់តាំងពីពេលដែលទ្រង់បានបង្កើតគាត់ជាថ្មីក្នុងពិធីជ្រមុជទឹកក៏គាត់មិនដែលនិយាយអ្វីទាស់ប្រឆាំងនឹងបញ្ញត្តិរបស់ទ្រង់ឡើយ។ ហើយព្រះរាជបុត្រារបស់ព្រះអង្គដែលជាសេចក្ដីពិត ទ្រង់បានប្រកាសថា អស់អ្នកណាដែលនិយាយ "«អាឆ្កួត» នោះនឹងត្រូវធ្លាក់ទៅក្នុងភ្លើងនរក"។[១០] ប្រសិនបើគ្មានសេចក្ដីមេត្តាករុណាពីព្រះអង្គ នោះសូម្បីតែមនុស្សដែលគេកោតសរសើរក៏នឹងហិនវិនាសនៅចំពោះរាជបល្ល័ង្កនៃការកាត់ទោសរបស់ទ្រង់ដែរ។ ប៉ុន្តែ ដោយសារព្រះអង្គមានពេញទៅដោយក្ដីមេត្តាករុណាពេលទូទាត់អំពើបាបយើង នោះយើងសង្ឃឹមដោយមានទំនុកចិត្តថានឹងមានកន្លែងឈរក្នុងព្រះវត្តមានរបស់ព្រះអង្គ។ ប្រសិនបើបុគ្គលណាម្នាក់រៀបរាប់ពីទង្វើល្អរបស់គាត់ទៅកាន់ព្រះអង្គ គឺគាត់គ្រាន់តែកំពុងរៀបរាប់អំពីអំណោយទានដ៏ល្អៗដែលទ្រង់បានប្រទានទៅគាត់តែប៉ុណ្ណោះ។ អូ! ប្រសិនបើមនុស្សដឹងថាខ្លួនគ្រាន់តែជាមនុស្ស នោះ «អ្នកណាដែលអួត» គឺនឹង «អួតពីព្រះអម្ចាស់» ជាមិនខាន![១១]

៣៥. ឱព្រះនៃដួងចិត្តទូលបង្គំ និងជាព្រះដែលទូលបង្គំសរសើរតម្កើង ហើយក៏ជាព្រះនៃជីវិតទូលបង្គំអើយ! សម្រាប់មួយរយៈនេះទូលបង្គំនឹងភ្លេចអំពីទង្វើល្អៗរបស់គាត់

៩ ១កូរិនថូស ១៥:២២។
១០ ម៉ាថាយ ៥:២២។
១១ ២កូរិនថូស ១០:១៧។

ដែលទូលបង្គំអរព្រះគុណទ្រង់យ៉ាងពេញដោយអំណរ ហើយក៏បានអធិស្ឋានសម្រាប់អំពើបាបរបស់អ្នកម្ដាយទូលបង្គំផងដែរ។ សូមព្រះសណ្ដាប់ទូលបង្គំតាមរយៈអង្គដែលត្រូវបានគេឆ្កាងលើដើមឈើ ដ៏ជាគ្រូពេទ្យព្យាបាលសម្រាប់របួសរបស់យើង ហើយក៏ជាអង្គដែលកំពុងគង់នៅខាងស្ដាំព្រះហស្តព្រះអង្គ ហើយក៏កំពុង «អង្វរជំនួសយើងរាល់គ្នា»។[១២] ទូលបង្គំដឹងថាគាត់បានប្រព្រឹត្តដោយមានក្ដីមេត្តាករុណា ហើយចេញពីដួងចិត្តរបស់គាត់ គាត់ក៏បានអត់ទោសដល់អស់អ្នកដែលបានប្រព្រឹត្តខុសនឹងគាត់ផងដែរ។[១៣] ទូលបង្គំក៏អង្វរព្រះអង្គឲ្យអត់ទោសនូវរាល់កំហុសរបស់គាត់ផងដែរ ទាក់ទងនឹងអ្វីដែលគាត់ទំនងជាបានប្រព្រឹត្តក្នុងអំឡុងឆ្នាំជាច្រើនកន្លងមកបន្ទាប់ពីគាត់បានទទួលពិធីជ្រមុជទឹកសម្រាប់សេចក្ដីសង្គ្រោះរបស់គាត់។ សូមអត់ទោសឲ្យគាត់ ឱព្រះអម្ចាស់អើយ! សូមអត់ទោសឲ្យគាត់ ទូលបង្គំសូមអង្វរ។ «សូមកុំឲ្យកើតក្ដីក្ដាំនឹង» គាត់ឡើយ។[១៤] សូមឲ្យក្ដីមេត្តាករុណារបស់ទ្រង់ថ្កុំថ្កើងឡើងលើសពីសេចក្ដីយុត្តិធម៌របស់ព្រះអង្គម្ចាស់ចុះ។ ដ្បិតព្រះបន្ទូលរបស់ព្រះអង្គពិត ហើយព្រះអង្គបានសន្យាថានឹងមានក្ដីមេត្តាករុណាចំពោះអស់អ្នកដែលមានក្ដីមេត្តាករុណាផងដែរ។ «មានពរហើយ អស់អ្នកដែលមានចិត្តមេត្តាករុណា ដ្បិតអ្នកទាំងនោះនឹងបានព្រះហឫទ័យមេត្តាករុណាវិញ»។[១៥] នេះគឺជាអំណោយទានរបស់ព្រះអង្គ។ ដ្បិតព្រះអង្គបានមានព្រះបន្ទូលថា «"យើងនឹងមេត្តាករុណាដល់អ្នកណាដែលយើងមេត្តាករុណា ហើយយើងនឹងក្ដួលអាណិត ដល់អ្នកណាដែលយើងក្ដួលអាណិត"»។[១៦]

៣៦. ប្រាកដណាស់! ទូលបង្គំជឿជាក់ថា ទ្រង់បានធ្វើនូវអ្វីដែលទូលបង្គំកំពុងតែទូលសូមពីទ្រង់រួចស្រេចទៅហើយ។ ទោះជាយ៉ាងណាក្ដី «ឱព្រះយេហូវ៉ាអើយ សូមទទួលតង្វាយស្ម័គ្រចិត្តរបស់ទូលបង្គំ»[១៧] ដ្បិតពេលគាត់ជិតស្លាប់ អ្នកម្ដាយទូលបង្គំមិនបានស្នើសុំឲ្យយើងរុំសពរបស់គាត់ក្នុងលក្ខណៈដ៏ស្អាតអស្ចារ្យ ឬក៏អប់សពកុំឲ្យស្អុយរលួយជាមួយនឹងគ្រឿងទេសនោះឡើយ។ ហើយគាត់ក៏មិនខ្វល់ថាមានមុខម៉ុងដ៏ស្រស់ស្អាត

---

១២ រ៉ូម ៨:៣៤។
១៣ ម៉ាថាយ ៦:១២។
១៤ ទំនុកតម្កើង ១៤៣:២។
១៥ ម៉ាថាយ ៥:៧។
១៦ រ៉ូម ៩:១៥។
១៧ ទំនុកតម្កើង ១១៩:១០៨។

ប៉ុណ្ណោះទេ ក៏ថែមទាំងមិនខ្វល់ថាគេនឹងមិនយកសពគាត់ទៅកប់នៅឯស្រុកកំណើតខ្លួនទៀតផង។ ទាក់ទងនឹងរឿងទាំងនេះ គាត់មិនបានបន្សល់ទុកការណែនាំនោះទេ។ អ្នកម្ដាយទូលបង្គំគ្រាន់តែចង់ឲ្យយើងចាំឈ្មោះរបស់គាត់នៅឯអាសនារបស់ទ្រង់តែប៉ុណ្ណោះ ដែលជាទីកន្លែងគាត់បានបម្រើព្រះអង្គដោយគ្មានថ្ងៃរំលងមួយសោះឡើយ។ គាត់ដឹងថាទីនោះគឺជាកន្លែងប្រារព្ធពិធីលៀងព្រះអម្ចាស់ ហើយក៏ជាទីកន្លែងដែលព្រះអង្គបានលុបចេញនូវការសរសេរចុះជំទាស់នឹងយើងដែរ។ ខ្មាំងសត្រូវក៏បានចាញ់ ខណៈពេលដែលវាទាស់ប្រឆាំងនឹងកំហុសរបស់យើង ហើយស្វែងរករបៀប ដើម្បីនឹងចោទប្រកាន់យើង ប៉ុន្តែមិនអាចរកអ្វីបាននៅក្នុងព្រះអង្គឡើយ ដែលក្នុងទ្រង់យើងទទួលបានជ័យជម្នះហើយ។

តើអ្នកណានឹងប្រគល់ព្រះលោហិតដែលគ្មានកំហុសឲ្យព្រះអង្គវិញ? តើអ្នកណានឹងសងព្រះអង្គវិញសម្រាប់តម្លៃដែលទ្រង់បានទិញយើង ហើយអាចយកយើងចេញពីទ្រង់បាន? ហេតុដូច្នេះ អ្នកបម្រើរបស់ព្រះអង្គក៏បានជាប់ព្រលឹងរបស់គាត់តាមរយៈចំណងនៃជំនឿជាមួយនឹងពិធីបង្ហូរព្រះគុណនៃសេចក្ដីប្រោសលោះដែលយើងបានទទួល។ សូមកុំអនុញ្ញាតឲ្យមានអ្វីបំបែកគាត់ចេញពីការការពាររបស់ព្រះអង្គឡើយ។ សូមកុំឲ្យ “សត្វសិង្ហ” ឬក៏ “សត្វនាគ” រារាំងផ្លូវរបស់គាត់ មិនថាតាមរយៈការបង្ខំ ឬក៏ការបញ្ឆោតឡើយ។ គាត់នឹងមិនអះអាងថាគាត់មិនជំពាក់អ្វីទេ (ដែលនាំឲ្យអ្នកបញ្ឆោតដ៏ឆ្លាតម្នាក់នោះមកឆបោក ឬក៏បោកប្រាស់គាត់នោះឡើយ) តែផ្ទុយទៅវិញគាត់នៅឆ្លើយថា អំពើបាបរបស់គាត់ត្រូវបានទទួលបានការអត់ទោសរួចស្រេចទៅហើយ។ ពួកគេបានទទួលការអត់ទោសពីព្រះអង្គដែលគ្មានអ្នកណាអាចសងតម្លៃដែលទ្រង់បានបង់ ទោះបើទ្រង់មិនជំពាក់អ្វីនឹងយើងទាល់តែសោះក៏ដោយ។

៣៧. ដូច្នេះ សូមអនុញ្ញាតឲ្យគាត់សម្រាកក្នុងសន្តិភាពជាមួយនឹងប្ដីរបស់គាត់ដែលគាត់បានស្ដាប់បង្គាប់ដោយមានការអត់ធ្មត់ ហើយក៏បាននាំផលផ្លែមកកាន់ព្រះអង្គត្រង់ថាគាត់បាននាំឲ្យប្ដីរបស់គាត់ទទួលជឿទ្រង់។ មុន និងក្រោយប្ដីគាត់ អ្នកម្ដាយទូលបង្គំមិនបានរៀបការជាមួយនឹងអ្នកណាផ្សេងទៀតទេ។ ឱព្រះអង្គដ៏ជាម្ចាស់ទូលបង្គំអើយ! សូមជំរុញចិត្តអ្នកបម្រើរបស់ព្រះអង្គដែលជាបងប្អូនប្រុសស្រីរបស់ទូលបង្គំ ជាបុត្រាបុត្រីរបស់ទ្រង់ ជាចៅហ្វាយរបស់ទូលបង្គំដែលទូលបង្គំកំពុងតែបម្រើជាមួយនឹងសំឡេង បេះដូង និងការនិពន្ធរបស់ទូលបង្គំ។ សូមឲ្យអស់អ្នកណាដែលទំនងនឹងអានការលន់តួមួយ

នេះនៅឯអាសនារបស់ព្រះអង្គចាំអំពីអ្នកម្ដាយទូលបង្គំលោកស្រី ម៉ូនីកា ដែលជាអ្នកបម្រើស្ដ្រីរបស់ព្រះអង្គ នឹងចាំអំពីលោកឪពុកទូលបង្គំ ផាទ្រីសូស៍ ដែលធ្លាប់ជាប្ដីរបស់គាត់។ ព្រះអង្គបានបង្កើតទូលបង្គំក្នុងជីវិតនេះ តាមរយៈសាច់ឈាមរបស់ពួកគាត់។ ដោយមានការស្រឡាញ់ដែលស្មោះត្រង់ សូមឲ្យពួកគេចងចាំអំពីឪពុកម្ដាយទូលបង្គំក្នុងជីវិតដ៏បណ្ដោះអាសន្នមួយនេះ។ សូមឲ្យពួកគេចងចាំអំពីបងប្អូនប្រុសស្រីរបស់ទូលបង្គំក្រោមព្រះអង្គដ៏ជាព្រះវរបិតានៃក្រុមជំនុំ។ សូមឲ្យពួកគេចងចាំអំពីជនរួមជាតិតែមួយជាមួយនឹងទូលបង្គំក្នុងទីក្រុងយេរូសាឡឹមដ៏នៅអស់កល្បជានិច្ច ដ្បិតនៅកន្លែងនោះរាស្ដ្ររបស់ព្រះអង្គបានដកដង្ហើមធំយ៉ាងធូរស្បើយ ក្នុងដំណើរធម្មយាត្រារបស់ពួកគេពីកំណើតរហូតដល់ពួកគេត្រឡប់ទៅវិញ។ ហើយដើម្បីបំពេញនូវអ្វីដែលអ្នកម្ដាយទូលបង្គំប្រាថ្នាចង់បានពីទូលបង្គំឲ្យលើសនោះតាមរយៈសេចក្ដីអធិស្ឋានរបស់មនុស្សម្នាជាច្រើននាក់ទៀត ដែលនឹងកើតឡើងសម្រាប់គាត់តាមរយៈការលន់តួទាំងនេះ ជាជាងគ្រាន់តែតាមរយៈការអធិស្ឋានរបស់ទូលបង្គំតែឯង។[១៨]

---

១៨ នៅពេលនោះ ក្នុងប្រវត្តិសាស្ត្រក្រុមជំនុំ វាគឺជាប្រពៃណីទេក្នុងការដែលអ្នកជឿអធិស្ឋានសម្រាប់អ្នកដែលបានស្លាប់ហើយ។ ដើម្បីរៀនបន្ថែមទៀតសូមចូលទៅកាន់គេហទំព័រ៖ https://plovpit.com/pray-after-death។

# ២៥

# ភាពអស្ចារ្យនៃការចងចាំ

១. ឱព្រះអង្គដែលជ្រាបនូវគ្រប់អ្វីៗនៃទូលបង្គំអើយ! សូមអនុញ្ញាតឲ្យទូលបង្គំស្គាល់ទ្រង់។ សូមអនុញ្ញាតឲ្យទូលបង្គំស្គាល់ព្រះអង្គដូចដែលព្រះអង្គស្គាល់ទូលបង្គំ។[១] ឱព្រះដ៏ជាកម្លាំងនៃព្រលឹងទូលបង្គំអើយ! សូមយាងចូលមក ហើយរៀបចំព្រលឹងទូលបង្គំសម្រាប់ព្រះអង្គផ្ទាល់ ដើម្បីឲ្យព្រះអង្គអាចទទួលវាបាន ហើយកាន់វាដោយ «ឥតប្រឡាក់ ឥតជ្រួញ»។[២] នេះគឺជាសេចក្តីសង្ឃឹមរបស់ទូលបង្គំ ហេតុដូច្នេះហើយបានជាទូលបង្គំបាននិយាយឡើង។ ហើយក្នុងសេចក្តីសង្ឃឹមនេះ ទូលបង្គំមានអំណរ រាល់ពេលដែលទូលបង្គំមានអំណរយ៉ាងត្រឹមត្រូវ។ ប៉ុន្តែ ទាក់ទងទៅនឹងចំណុចផ្សេងៗទៀតនៃជីវិតនេះ ជារឿយៗអ្វីដែលយើងកាន់ទុក្ខខ្លាំងជាងគេបំផុតតាមពិតទៅគឺជាចំណុចដែលយើងគួរកាន់ទុក្ខតិចជាងគេបំផុត។ ហើយចំណុចដែលយើងមិនគួរកាន់ទុក្ខតាមពិតទៅគឺជាចំណុចដែលយើងគួរតែកាន់ទុក្ខខ្លាំងជាងគេបំផុត។ ដ្បិត «មើល៍! ព្រះអង្គសព្វព្រះហឫទ័យនឹងសេចក្តីពិត»[៣] ហើយ «អ្នកណាដែលប្រព្រឹត្តតាមសេចក្តីពិតវិញ តែងចូលមករកពន្លឺ»។[៤]

---

១ ១កូរិនថូស ១៣:១២។

២ អេភេសូរ ៥:២៧។

៣ ទំនុកតម្កើង ៥១:៦។

៤ យ៉ូហាន ៣:២១។

នេះគឺជាអ្វីដែលទូលបង្គំប្រាថ្នាចង់ធ្វើតាមរយៈការលន់តួក្នុងដួងចិត្តរបស់ទូលបង្គំចំពោះព្រះអង្គ និងក្នុងការសរសេររបស់ទូលបង្គំនៅចំពោះសាក្សីជាច្រើន។

២. ឱព្រះអម្ចាស់អើយ! តើទូលបង្គំមានអ្វីក្នុងទូលបង្គំដែលអាចមានការលាក់បាំងពីព្រះអង្គបាន ដែលនៅចំពោះព្រះនេត្ររបស់ព្រះអង្គសតិសម្បជញ្ញៈដ៏ជ្រាលជ្រៅរបស់មនុស្សយើងគឺត្រូវបានបើកសម្តែងឡើងយ៉ាងពេញទី ទោះបើថាទូលបង្គំមិនមានឆន្ទៈក្នុងការលន់តួទៅកាន់ព្រះអង្គក៏ដោយ? ដ្បិតប្រសិនបើទូលបង្គំមិនលន់តួទៅកាន់ព្រះអង្គ នោះទូលបង្គំកំពុងតែលាក់ព្រះអង្គពីខ្លួនឯងហើយ មិនមែនលាក់ខ្លួនឯងពីព្រះអង្គទេ។ ប៉ុន្តែ ដោយសារការថ្ងូររបស់ទូលបង្គំគឺជាសាក្សីនៃសេចក្តីពិតត្រង់ថា ទូលបង្គំមិនបានស្កប់ចិត្តជាមួយនឹងខ្លួនឯង នោះព្រះអង្គក៏បានជះពន្លឺរបស់ទ្រង់ ហើយធ្វើឲ្យទូលបង្គំស្កប់ចិត្ត។ ព្រះអង្គគួរឲ្យស្រឡាញ់ និងគួរឲ្យប្រាថ្នាចង់បានណាស់។ ពេលដែលទូលបង្គំគិតអំពីស្ថានភាពរបស់ខ្លួន នោះទូលបង្គំមានពេញទៅដោយភាពអាម៉ាស់។ ទូលបង្គំបោះបង់ខ្លួនឯងចោល ហើយជ្រើសរើសយកព្រះអង្គវិញ។ ដ្បិតទូលបង្គំមិនទាំងអាចផ្គាប់ចិត្តព្រះអង្គ ឬក៏ខ្លួនឯងផ្ទាល់លើកលែងតែក្នុងទ្រង់បានផង។ ហេតុដូច្នេះ ឱព្រះអម្ចាស់អើយ! ចំពោះទ្រង់ទូលបង្គំនៅអាក្រាត មិនថាទូលបង្គំជាអ្នកណាក៏ដោយ ហើយទូលបង្គំក៏បានធ្លាប់លើកឡើងអំពីអត្ថប្រយោជន៍នៃការលន់តួទៅកាន់ព្រះអង្គរួចហើយដែរ។ ទូលបង្គំមិនប្រព្រឹត្តការនោះឡើងដោយប្រើប្រាស់ពាក្យពេចន៍ ឬសំឡេងដែលសាច់ឈាមយើងបង្កើតឡើងនោះទេ ប៉ុន្តែគឺប្រើប្រាស់ពាក្យពេចន៍ចេញពីព្រលឹង ហើយនិងប្រើប្រាស់សំឡេងនៃគំនិតរបស់ទូលបង្គំ ដែលព្រះកាណ៌របស់ព្រះអង្គព្រះសណ្តាប់ឮបាន។ ដ្បិតពេលដែលទូលបង្គំនៅអាក្រក់ ការលន់តួទៅកាន់ព្រះអង្គមិនមានន័យអ្វីទាបជាងការធ្វើឲ្យខ្លួនឯងមិនស្កប់ចិត្តនោះទេ។ ប៉ុន្តែ ពេលទូលបង្គំពិតជាដើរតាមព្រះអង្គមែន នោះទូលបង្គំក៏មិនបានរាប់ការល្អនោះថាកើតឡើងចេញពីខ្លួនឯងនោះដែរ ពីព្រោះឱព្រះអម្ចាស់អើយទ្រង់ប្រទានពរដល់ពួកសុចរិត ប៉ុន្តែជាដំបូងទ្រង់រាប់ពួកគេថាជាមនុស្សសុចរិតមុនសិនខណៈពេលដែលពួកគេនៅជាមនុស្សមានបាបនៅឡើយ។ ដូច្នេះ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! ទូលបង្គំបានលន់តួទៅកាន់ព្រះអង្គក្នុងរបៀបដ៏ស្ងៀមស្ងាត់នៅចំពោះព្រះភ័ក្ត្ររបស់ទ្រង់—ប៉ុន្តែមិនមែនក្នុងលក្ខណៈដ៏ស្ងប់ស្ងាត់។ ទាក់ទងទៅនឹងសំឡេងគឺវានៅស្ងៀមស្ងាត់ទេតើ។ ប៉ុន្តែ ក្នុងសុច្ឆន្ទៈដ៏ខ្លាំងរបស់វានោះគឺបានស្រែកយំយ៉ាងឮ។ ដ្បិតទូលបង្គំ

ក៏មិនបញ្ចេញសំឡេងអំពីអ្វីដែលស្ដាប់ទៅហាក់បីដូចជាត្រឹមត្រូវនៅចំពោះមនុស្សម្នាផង ដែរ ដែលព្រះអង្គមិនធ្លាប់ឮពីទូលបង្គំពីមុន ហើយព្រះអង្គក៏មិនឮអ្វីពីទូលបង្គំដែលទ្រង់ មិនធ្លាប់បានមានព្រះបន្ទូលពីមុនមកទូលបង្គំឡើយ។

៣. ប្រសិនបើមានមនុស្សឮការលន់តួរបស់ទូលបង្គំ តើទូលបង្គំបារម្ភអំពីអ្វី? ពួក គាត់មិនមែនជាអ្នកដែលនឹងព្យាបាលរាល់ជំងឺរបស់ទូលបង្គំទេ។ មនុស្សមានការងឿង ឆ្ងល់ក្នុងការដឹងអំពីជីវិតរបស់អ្នកដទៃ ប៉ុន្តែមានការយឺតយ៉ាវក្នុងការកែតម្រង់ជីវិតរបស់ ខ្លួន។ ហេតុអ្វីបានជាពួកគាត់ចាប់អារម្មណ៍ក្នុងការឮចេញពីទូលបង្គំអំពីទូលបង្គំ ខណៈ ពេលដែលពួកគេមិនមានចិត្តចង់ឮពីទ្រង់ ទាក់ទងទៅនឹងចំណុចថា តើពួកគេជាមនុស្ស បែបម៉េច? ហើយតើឲ្យពួកគេដឹងដោយរបៀបណា ពេលដែលពួកគេឮអំពីអ្វីដែលទូលបង្គំ និយាយអំពីខ្លួនឯងត្រង់ថា តើទូលបង្គំកំពុងតែនិយាយអំពីការពិតដែរឬក៏អត់ ដោយសារ គ្មានមនុស្សណាដឹងអំពីអ្វីក្នុងបុគ្គលណាម្នាក់ទៀត «ក្រៅពីវិញ្ញាណអ្នកនោះដែលនៅក្នុង ខ្លួន?»។[៥] ប៉ុន្តែ ប្រសិនបើពួកគាត់ត្រូវបានឮពីព្រះអង្គអំពីអ្វីទាក់ទងទៅនឹងពួកគាត់ នោះ ពួកគាត់នឹងមិនអាចនិយាយថា «ព្រះអម្ចាស់កំពុងតែកុហក» បានទេ។ ដ្បិតការឮពីព្រះ អង្គអំពីពួកគាត់គឺជាការស្គាល់អំពីខ្លួនឯង។ ហើយតើបុគ្គលណាដែលស្គាល់ខ្លួនឯងនឹង និយាយថា «នេះគឺជាការកុហក» លុះត្រាតែគាត់ផ្ទាល់កំពុងតែកុហក។ ប៉ុន្តែដោយសារ «សេចក្ដីស្រឡាញ់...ជឿទាំងអស់»[៦]—យ៉ាងហោចណាស់ក្នុងចំណោមអស់អ្នកដែលមាន ចំណងជាមួយគ្នាក្នុងការស្រឡាញ់—នោះទូលបង្គំសូមលន់តួទៅកាន់ទ្រង់ ឱព្រះអម្ចាស់ អើយ! ដើម្បីឲ្យមនុស្សអាចឮបាន។ ដ្បិតប្រសិនបើទូលបង្គំមិនអាចផ្ដល់ជាភស្ដុតាងដល់ ពួកគេថា អ្វីដែលទូលបង្គំកំពុងតែលន់តួនេះគឺជាសេចក្ដីពិត នោះត្រចៀករបស់អ្នកដែល បើកឡើងដោយក្ដីស្រឡាញ់នឹងជឿអំពីអ្វីដែលទូលបង្គំបានលើកឡើងជាមិនខាន។

៤. ប៉ុន្តែ ឱព្រះអង្គដែលជាគ្រូពេទ្យខាងឯព្រលឹងវិញ្ញាណរបស់ទូលបង្គំអើយ! តើទ្រង់ នឹងបើកបង្ហាញឲ្យទូលបង្គំឃើញយ៉ាងច្បាស់ថា តើទូលបង្គំនឹងទទួលបានអត្ថប្រយោជន៍ អ្វីចេញពីការធ្វើបែបនេះដែរឬទេ? ដ្បិតពេលដែលគេអាន ហើយឮការលន់តួនៃអំពើបាប ពីអតីតកាលរបស់ទូលបង្គំ (ដែលព្រះអង្គបាន «អត់ទោស និងគ្របបាំង»)[៧] នោះវាទំនង

៥ ១កូរិនថូស ២:១១។
៦ ១កូរិនថូស ១៣:៧។
៧ ទំនុកតម្កើង ៣២:១។

ជានឹងប៉ះពាល់ដួងចិត្តអ្នកស្ដាប់ ដើម្បីឲ្យពួកគាត់ឈប់ដេកក្នុងភាពអស់សង្ឃឹម ហើយនិយាយថា «ខ្ញុំមិនអាច»។ ប៉ុន្តែ ផ្ទុយពីនោះប្រហែលជាពួកគេនឹងភ្ញាក់ឡើងក្នុងសេចក្ដីស្រឡាញ់នៃសេចក្ដីមេត្តា និងភាពផ្អែមល្ហែមនៃព្រះគុណរបស់ព្រះអង្គវិញ។ គឺតាមរយៈព្រះគុណរបស់ព្រះអង្គហើយ ដែលយើងជាមនុស្សខ្សោយត្រូវបានក្លាយជាអ្នកខ្លាំង បើយើងដឹងអំពីភាពទន់ខ្សោយរបស់ខ្លួនឯង។ ហើយតាមរយៈការស្ដាប់ការលន់តួរបស់ទូលបង្គំក៏នឹងធ្វើឲ្យអ្នកស្ដាប់មានចិត្តសប្បាយ ជាពិសេសអស់អ្នកដែលស្រឡាញ់ព្រះអង្គ ដ្បិតពួកគេនឹងឮអំពីកំហុសខុសឆ្គងពីអតីតកាល ដែលទូលបង្គំធ្លាប់ធ្លាក់ជាប់ក្នុងនោះ តែឥឡូវនេះបានមានសេរីភាពចេញពីពួកវាហើយ។

៨. ឱព្រះអម្ចាស់អើយ! ទូលបង្គំគ្មានមន្ទិលសង្ស័យទេអំពីសេចក្ដីស្រឡាញ់របស់ទូលបង្គំចំពោះព្រះអង្គ ប៉ុន្តែមានភាពប្រាកដប្រជាទាំងស្រុងក្នុងសតិសម្បជញ្ញៈរបស់ទូលបង្គំ។ ព្រះអង្គបានធ្វើឲ្យចិត្តទូលបង្គំស្រឡាញ់ទ្រង់យ៉ាងខ្លាំងដោយព្រះបន្ទូលរបស់ទ្រង់ ហើយទូលបង្គំក៏បានស្រឡាញ់ព្រះអង្គមែន។ សូម្បីតែផ្ទៃមេឃ និងផែនដី និងរាល់អ្វីៗដែលនៅក្នុងវា—នៅគ្រប់ទិសទីវាប្រាប់ឲ្យទូលបង្គំស្រឡាញ់ព្រះអង្គ ហើយពួកវាក៏មិនដែលឈប់ប្រាប់អំពីចំណុចនេះទៅកាន់គ្រប់មនុស្សផងដែរ «ដូច្នេះ គេមិនអាចដោះសាបានឡើយ»។[៨] លើសពីនោះទៅទៀត ព្រះអង្គនឹងមានសេចក្ដីមេត្តាករុណាយ៉ាងជ្រាលជ្រៅចំពោះអស់អ្នកដែលព្រះអង្គសព្វព្រះហឫទ័យមានសេចក្ដីមេត្តាករុណា និងក្ដួលអាណិតដល់អ្នកណាដែលទ្រង់ក្ដួលអាណិតដែរ។[៩] ដ្បិតបើមិនដូច្នោះទេ នោះទាំងផ្ទៃមេឃ និងផែនដីនឹងប្រាប់អំពីការសរសើរតម្កើងរបស់ទ្រង់យ៉ាងសាយភាយដល់ត្រចៀកថ្លង់ជាមិនខាន។

ប៉ុន្តែ តើអ្វីទៅដែលទូលបង្គំស្រឡាញ់អំពីការស្រឡាញ់ព្រះអង្គ? មិនមែនភាពសង្ហាខាងឯសាច់ឈាម ភាពរុងរឿងនៃពេលវេលា ឬក៏ភាពចែងចាំងនៃពន្លឺទេ—ដែលមានភាពរាក់ទាក់ដល់ភ្នែកយើងមែន—ហើយក៏មិនមែនភាពពីរោះផ្អែមល្ហែមនៃបទចម្រៀងដែលមានច្រើនប្រភេទ ហើយក៏មិនមែនភាពក្រអូបនៃផ្កា ក្រមួន និងគ្រឿងទេស មិនមែននំម៉ាណា និងទឹកឃ្មុំ ឬក៏ដៃជើងដែលឱបគ្នាក្នុងការស្រឡាញ់ខាងឯសាច់ឈាមដែរ—ទាំងនេះគឺ

៨ រ៉ូម ១:២០។
៩ រ៉ូម ៩:១៥។

មិនមែនជាអ្វីដែលទូលបង្គំស្រឡាញ់ ពេលដែលទូលបង្គំស្រឡាញ់ព្រះជាម្ចាស់របស់ទូលបង្គំទេ។ ទោះជាយ៉ាងណាក្តី ពិតណាស់ទូលបង្គំក៏ស្រឡាញ់ប្រភេទនៃពន្លឺមួយចំនួន និងសំឡេង និងក្លិនក្រអូប និងម្ហូប ហើយក៏ឱបក្រសោបក្នុងការស្រឡាញ់ព្រះជាម្ចាស់របស់ទូលបង្គំដែរ ព្រះអង្គគឺជាពន្លឺ សំឡេង ក្លិន ម្ហូប និងការឱបក្រសោបនៃភាពជាមនុស្សខាងក្នុងរបស់ទូលបង្គំ—ដែលជាទីកន្លែងនៃពន្លឺនោះបានចែងចាំងក្នុងព្រលឹងរបស់ទូលបង្គំដែលគ្មានកន្លែងណាផ្សេងអាចផ្ទុកបាន ជាកន្លែងដែលពេលវេលាមិនអាចឆក់យកសំឡេងដែលគួរឲ្យស្រឡាញ់បាន ជាកន្លែងដែលគ្មានខ្យល់អាចបក់ក្លិនក្រអូបឲ្យរសាត់បាន ជាកន្លែងដែលការបរិភោគមិនអាចបន្ថយម្ហូបដែលផ្គត់ផ្គង់ចុះបាន និងជាកន្លែងដែលការឱបក្រសោបមិនអាចមានភាពឆ្អែតឆ្អន់ក្នុងការញែកបំបែកបាន។ នេះគឺជាអ្វីដែលទូលបង្គំស្រឡាញ់ ជាពេលដែលទូលបង្គំស្រឡាញ់ព្រះជាម្ចាស់របស់ទូលបង្គំ។

៩. ហើយតើអ្វីទៅជាព្រះជាម្ចាស់នេះអើយ? ទូលបង្គំបានសួរផែនដី ហើយវាក៏បានឆ្លើយតបដូចតទៅ «ខ្ញុំមិនមែនជាព្រះអង្គទេ» ហើយរាល់គ្រប់អ្វីៗលើផែនដីក៏បាននិយាយដូចនោះផងដែរ។ ទូលបង្គំបានសួរសមុទ្រ និងជម្រៅ និងអ្វីៗដែលលូនវារ ហើយពួកវាបានឆ្លើយតបថា «ពួកយើងមិនមែនជាព្រះរបស់លោកទេ។ សូមស្វែងរកនៅខាងលើយើង»។ ទូលបង្គំបានសួរខ្យល់ដែលកំពុងតែរសាត់ ហើរលើអាកាស និងអ្វីៗដែលនៅក្នុងវាក៏បានឆ្លើយតបថា៖ «ខ្ញុំមិនមែនជាព្រះជាម្ចាស់ទេ»។ ទូលបង្គំបានសួរផ្ទៃមេឃ ព្រះអាទិត្យ ព្រះចន្ទ និងដួងតារា ហើយពួកវាក៏បានឆ្លើយថា «យើងក៏មិនមែនជាព្រះដែលលោកកំពុងតែស្វែងរកដែរ»។ ហើយទូលបង្គំក៏ឆ្លើយតបចំពោះអ្វីៗទាំងអស់នោះដែលនៅខាងក្រៅស្ថានភាពទូលបង្គំវិញថា៖ «ពួកឯងបានប្រាប់ខ្ញុំថា ពួកឯងមិនមែនជាព្រះរបស់ខ្ញុំ។ សូមប្រាប់ខ្ញុំចំណុចមួយចំនួនអំពីទ្រង់»។ ហើយដោយមានសំឡេងយ៉ាងខ្លាំង ពួកគេក៏បានស្រែកឡើងថា «ព្រះអង្គបានបង្កើតយើងមក»។ សំណួររបស់ទូលបង្គំបានលេចឡើងចេញពីការសង្កេតមើលពួកវា ហើយការឆ្លើយតបរបស់ពួកវាក៏បានលេចឡើងតាមរយៈភាពស្រស់ស្អាតនៃលំដាប់លំដោយរបស់ពួកវាដែរ។ ហើយទូលបង្គំក៏បង្វែរគំនិតរបស់ទូលបង្គំមកក្នុង ហើយនិយាយទៅកាន់ខ្លួនឯងថា «តើឯងជាអ្នកណា?»។ ហើយទូលបង្គំក៏បានឆ្លើយតបថា «ជាមនុស្ស»។ ដ្បិតមើល៍! ក្នុងទូលបង្គំគឺមានទាំងរូបកាយ និងព្រលឹងវិញ្ញាណ មួយនៅខាងក្រៅ ហើយមួយទៀតនៅខាងក្នុង។ តើក្នុងមួយណាដែលទូលបង្គំ

គួរស្វែងរកព្រះជាម្ចាស់របស់ទូលបង្គំ ដែលជាអង្គដែលទូលបង្គំបានស្វែងរកដោយរូបកាយរបស់ទូលបង្គំពីផែនដីដល់ផ្ទៃមេឃ ឆ្ងាយតាមដែលទូលបង្គំមានសមត្ថភាពក្នុងការផ្ញើតាមរយៈអ្នកនាំសារទាំងនោះ—ធ្នឹមនៃកែវភ្នែកទូលបង្គំមែនឬ? ប៉ុន្តែ ផ្នែកខាងក្នុងគឺជាផ្នែកដ៏ល្អជាង ដ្បិតគឺទៅកាន់វា ដែលទាំងពីរគឺជាអ្នកត្រួតត្រា និងអ្នកកាត់ក្តី អ្នកនាំសារនៃញាណទាំងអស់នេះបានផ្តល់ចម្លើយនៃផ្ទៃមេឃ និងផែនដី និងរាល់អ្វីៗដែលវាមាន ដោយលើកឡើងថា «យើងមិនមែនជាព្រះទេ ប៉ុន្តែព្រះអង្គគឺជាអង្គដែលបានបង្កើតយើងមក»។ មនុស្សខាងក្នុងរបស់ទូលបង្គំដឹងអំពីចំណុចទាំងអស់នេះតាមរយៈព័ន្ធកិច្ចនៃមនុស្សខាងក្រៅរបស់ទូលបង្គំ ហើយទូលបង្គំ ដែលជាមនុស្សខាងក្នុងដឹងអំពីចំណុចទាំងនេះ—ទូលបង្គំ ដែលជាព្រលឹង តាមរយៈញាណនៃរូបកាយរបស់ទូលបង្គំ។ ទូលបង្គំបានសួរផែនដីទាំងមូលអំពីព្រះជាម្ចាស់នៃទូលបង្គំ ហើយវាបានឆ្លើយថា «ខ្ញុំមិនមែនជាព្រះអង្គទេ ប៉ុន្តែព្រះអង្គជាអង្គដែលបានបង្កើតខ្ញុំមក»។

១០. តើនេះមិនមែនជាភាពស្រស់ស្អាតខាងឯរូបរាងដែលអាចមើលឃើញចំពោះញាណទាំងមូលដែលមិនខូចមែនឬ? ចុះហេតុអ្វីបានវាមិននិយាយដូចៗគ្នាចំពោះអ្វីទាំងអស់? សត្វ (ទាំងតូច និងធំ) ឃើញប៉ុន្តែវាមិនមានសមត្ថភាពក្នុងការដកយកអត្ថន័យរបស់វា ពីព្រោះញាណរបស់វាមិនមានការឧបត្ថម្ភក្នុងការយល់ដែលអនុញ្ញាតឲ្យវាថ្កោលទោសលើភស្តុតាងដែលញាណរបស់វាផ្តល់ព័ត៌មានឲ្យទេ។ ប៉ុន្តែ មនុស្សយើងអាចដកស្រង់បាន ដើម្បីឲ្យ «និស្ស័យជាព្រះរបស់ព្រះអង្គ…នោះក៏បានបង្ហាញឲ្យឃើញច្បាស់…តាមរយៈអ្វីៗដែលព្រះអង្គបង្កើតមកដែរ»។[១០] ប៉ុន្តែ មនុស្សស្រឡាញ់អ្វីដែលព្រះអង្គបានបង្កើតខ្លាំងពេក។ ពួកគេបានធ្លាក់ក្នុងការចុះចូលក្រោមវា ហើយក្នុងនាមជាអ្នកចុះចូលក៏មិនអាចមានសមត្ថភាពក្នុងការថ្កោលទោសបានផងដែរ។ អ្វីៗដែលត្រូវបានបង្កើតមកមិនមានសមត្ថភាពក្នុងការឆ្លើយតបអ្នកសួរសំណួរពួកគេ លុះត្រាតែពួកគេអាចធ្វើការកាត់ទោសដែលសមហេតុផលបាន។ របស់សព្វសារពើទាំងនេះនឹងមិនអាចបំផ្លាស់បំប្រែសំឡេងរបស់វាបានឡើយ—ត្រង់ថា៖ ភាពស្រស់ស្អាតនៃរូបរាងរបស់ពួកវា—ប្រសិនបើបុគ្គលម្នាក់គ្រាន់តែឃើញអ្វីដែលបុគ្គលម្នាក់ទៀតអាចឃើញទាំងសាកសួរសំណួរដូច្នេះលោកីយ៍នេះហាក់បីដូចជាមានរបៀបមួយចំពោះបុគ្គលម្នាក់ ហើយរបៀបមួយទៀត

១០ រ៉ូម ១:២០។

ចំពោះបុគ្គលម្នាក់ទៀត។ វាបង្ហាញចេញក្នុងរបៀបដូចគ្នាចំពោះទាំងពីរ ប៉ុន្តែវាថ្លង់ចំពោះម្នាក់នេះ ហើយវានិយាយចំពោះម្នាក់នោះ។ ប្រាកដណាស់! តាមពិតទៅវានិយាយទៅកាន់ទាំងអស់ ប៉ុន្តែចំពោះអ្នកដែលប្រៀបធៀបសំឡេងដែលទទួលបានពីក្រៅជាមួយនឹងសេចក្ដីពិតដែលយល់បានពីខាងក្នុងបានប៉ុណ្ណោះ។ ដ្បិតសេចក្ដីពិតបាននិយាយមកកាន់ខ្ញុំថា "ផ្ទៃមេឃ ផែនដី និងអ្នកណាផ្សេងទៀតគឺមិនមែនជាព្រះរបស់លោកទេ"។ ស្ថានភាពផ្ទាល់របស់ពួកគេប្រាប់អំពីចំណុចនេះទៅកាន់បុគ្គលដែលកំពុងមើលពួកគេ។ "ពួកគេត្រូវបានបង្កើតឡើង តូចៗជាងក្នុងផ្នែកទាំងមូល"។ ឥឡូវនេះ ឱព្រលឹងទូលបង្គំអើយ! ឯងគឺជាចំណុចល្អប្រសើរជាងរបស់ខ្ញុំ ហើយចំពោះឯងខ្ញុំចង់និយាយ ដោយសារឯងធ្វើឲ្យរូបរាងទាំងមូលមានចលនានៃរាងកាយរបស់ឯង ដោយផ្ដល់ជីវិត ខណៈពេលដែលគ្មានរូបកាយណាអាចបង្កើតឲ្យមានជីវិតក្នុងរូបកាយណាមួយផ្សេងទៀតបាន។ ប៉ុន្តែ ព្រះជាម្ចាស់របស់ឯងគឺជាជីវិតនៃជីវិតរបស់ឯង។

១៥. ឱព្រះជាម្ចាស់ទូលបង្គំអើយ អំណាចនៃការចងចាំនេះពិតជាអស្ចារ្យមែន អស្ចារ្យយ៉ាងខ្លាំងណាស់—ការចងចាំជាបន្ទប់ដ៏ធំ និងគ្មានព្រំដែននៅខាងក្នុង។ តើអ្នកណាអាចវាស់វែងជម្រៅរបស់វាបាន? ទោះជាយ៉ាងណាក្ដី វាគឺជាអំណាចនៃគំនិតរបស់ទូលបង្គំ ហើយវាក៏ជាកម្មសិទ្ធិនៃលក្ខណៈរបស់ទូលបង្គំផងដែរ។ ប៉ុន្តែ ទូលបង្គំផ្ទាល់ក៏មិនអាចយល់នូវរាល់គ្រប់ចំណុចរបស់ខ្លួនឯងបានដែរ។ ដូច្នេះ គំនិតគឺតូចពេកហើយក្នុងការផ្ទុកខ្លួនឯងបាន។ ប៉ុន្តែ តើចំណុចនោះអាចនៅទីណាដែលវាមិនអាចផ្ទុកបាន? តើវានៅខាងក្រៅ ហើយមិននៅក្នុងខ្លួនឯងមែនឬ? ដូច្នេះ តើឲ្យយើងមានលក្ខណៈបែបនោះបានដោយរបៀបណា ដែលគំនិតមិនអាចយល់អំពីខ្លួនឯងបាន? មានចំណុចមួយដ៏អស្ចារ្យកើតឡើងក្នុងទូលបង្គំ ហើយការភ្ញាក់ផ្អើលក៏ចាប់ទូលបង្គំជាប់។ មនុស្សយើងចេញទៅមើលភាពអស្ចារ្យនៃកម្ពស់នៃភ្នំនានា និងរលកដ៏ធំនៃសមុទ្រមហាសាគរការដែលទន្លេហូរយ៉ាងខ្លាំង ភាពធំក្រៃលែងនៃសមុទ្រមហាសាគរ និងតារាវិថី ប៉ុន្តែពួកគេមិនយកចិត្តទុកដាក់ដោយភ្ញាក់ផ្អើលមើលមកកាន់ខ្លួនឯងនោះទេ។ ហើយពួកគេមិនបានឆ្ងល់ត្រង់ថា ពេលដែលទូលបង្គំកំពុងនិយាយអំពីចំណុចទាំងអស់នេះ នោះទូលបង្គំមិនបានមើលពួកគេដោយប្រើប្រាស់ភ្នែករបស់ទូលបង្គំនោះទេ—ប៉ុន្តែ ទោះបើជាយ៉ាងណាក្ដី ក៏ទូលបង្គំមិនអាចនិយាយអំពីពួកគេបានដែរ លុះត្រាតែទូលបង្គំមើលមកកាន់

ខាងក្នុងខ្លួនឯងសិនក្នុងការចងចាំរបស់ទូលបង្គំ៖ ភ្នំទាំងនោះ និងរលក និងទន្លេ និងផ្កាយដែលទូលបង្គំធ្លាប់បានឃើញ ព្រមទាំងសមុទ្រដែលទូលបង្គំជឿថាមាន។ ប៉ុន្តែពេលទូលបង្គំឃើញវានៅខាងក្រៅទូលបង្គំ នោះទូលបង្គំក៏មិនបានយកវាចូលមកក្នុងទូលបង្គំតាមរយៈការឃើញវាផងដែរ ហើយអ្វីៗទាំងនោះក៏មិនមាននៅក្នុងទូលបង្គំផងដែរ ប៉ុន្តែគ្រាន់តែជារូបភាពរបស់ពួកវាប៉ុណ្ណោះ។ ហើយទោះជាយ៉ាងណាក្តី ក៏ទូលបង្គំនៅដឹងថា តាមរយៈការដកបទពិសោធន៍នីមួយៗក្នុងញាណខាងឯសាច់ឈាម វាបានធ្វើឲ្យទូលបង្គំមានចំណាប់អារម្មណ៍យ៉ាងខ្លាំង។

១៧. ប៉ុន្តែ នៅពេលទូលបង្គំឮថាមានសំណួរបីប្រភេទ—“តើវត្ថុនេះពិត? តើវាជាអ្វី? ហើយតើវាមានប្រភេទជាអ្វី?”—ពិតប្រាកដណាស់ ទូលបង្គំបានរក្សាទុករូបរាងនៃសំឡេងនៃការដែលពាក្យពេចន៍នោះមាន ហើយទូលបង្គំក៏ដឹងថាសំឡេងនោះបានធ្វើដំណើរឆ្លងកាត់ខ្យល់អាកាសដោយមានជាសំណោរ ហើយឥឡូវនេះវាលែងរស់នៅទៀតហើយ។ ប៉ុន្តែ អ្វីទាំងនេះដែលតំណាងដោយសំឡេងនោះទូលបង្គំមិនដែលអាចឈោងចាប់វាបានតាមរយៈញាណនៃរូបកាយណាមួយរបស់ទូលបង្គំទេ ហើយក៏មិនដែលឃើញវាលើកលែងតែតាមរយៈគំនិតរបស់ទូលបង្គំដែរ។ ហើយអ្វីដែលទូលបង្គំរក្សាទុកក្នុងការចង់ចាំរបស់ទូលបង្គំគឺមិនមែនសញ្ញារបស់ពួកវាទេ ប៉ុន្តែគឺអ្វីដែលវាសម្គាល់ឲ្យ។

តើវាបានចូលមកក្នុងទូលបង្គំដោយរបៀបណា សូមអនុញ្ញាតឲ្យបុគ្គលណាដែលអាចប្រាប់បានប្រាប់ចុះ។ ដ្បិតទូលបង្គំបានត្រួតពិនិត្យរាល់គ្រប់ចំណុចនៃសាច់ឈាមរបស់ទូលបង្គំហើយ ប៉ុន្តែទូលបង្គំមិនអាចរកឃើញទ្វារដែលវាបានប្រើប្រាស់ក្នុងការចូលមកនោះទេ។ ដ្បិតភ្នែកបាននិយាយថា “ប្រសិនបើវាជាពណ៌ នោះយើងជាអ្នករាយការណ៍អំពីការនោះ”។ ត្រចៀកថា “ប្រសិនបើវាបានបញ្ចេញសំឡេង នោះយើងក៏បានកត់សម្គាល់អំពីការនោះដែរ”។ រន្ធច្រមុះថា “ប្រសិនបើវាជាក្លិន នោះវាត្រូវតែឆ្លងកាត់ពួកយើងសិន”។ ញាណនៃការភ្លក់រសជាតិនិយាយថា “បើវាគ្មានរសជាតិ កុំមកសួរខ្ញុំអំពីវាអី”។ ញាណនៃការប៉ះនិយាយថា “បើវាគ្មានដុំខាងឯសាច់ឈាម នោះខ្ញុំក៏មិនបានប៉ះវាដែរ ហើយបើខ្ញុំមិនដែលប៉ះវា នោះខ្ញុំក៏មិនដែលរាយការណ៍អំពីវាដែរ”។

តើពីរចំណុចណា ឬក៏ដោយរបៀបណាដែលទាំងអស់នេះបានចូលមកក្នុងការចងចាំរបស់ទូលបង្គំ? ទូលបង្គំមិនដឹងទេ។ ដ្បិតពេលទូលបង្គំរៀនអំពីវាពេលដំបូង គឺវាមិន

មែនមកពីទូលបង្គំជឿវាដោយរំពឹងលើគំនិតរបស់បុគ្គលម្នាក់ទៀតនោះទេ ប៉ុន្តែទូលបង្គំបានស្គាល់វាផ្ទាល់ ហើយទូលបង្គំក៏បានឃើញថាវាពិត ហើយក៏បានយកវាមកទុកក្នុងគំនិតរបស់ទូលបង្គំដែរ ហើយរក្សាវានៅកន្លែងដែលទូលបង្គំអាចនឹងទៅរកវាឃើញវិញបាននៅពេលដែលទូលបង្គំចង់ទៅរកវា។ វាក៏មាន សូម្បីតែមុនពេលដែលទូលបង្គំបានរៀនអំពីវាទៅទៀត ប៉ុន្តែវាមិនបានមាននៅក្នុងការចងចាំរបស់ទូលបង្គំទេ។ អញ្ចឹង តើវានៅទីណាទៅ? នៅពេលដែលគេនិយាយអំពីវា តើទូលបង្គំមានគំនិតអំពីវាដោយរបៀបណាដោយលើកឡើងថា «ពិតណាស់ គឺវាពិតមែន» លុះត្រាតែវាមាននៅក្នុងការចងចាំនោះរួចជាស្រេចហើយ ទោះបើនៅយ៉ាងឆ្ងាយ ហើយមានការលាក់បាំង ដូចដែលថាវាកំពុងតែនៅក្នុងរូងល្អាងលាក់កំបាំង ដោយថាលុះត្រាតែមានគេទាញវាចេញតាមរយៈការបង្រៀនរបស់បុគ្គលណាម្នាក់ នោះទូលបង្គំទំនងជានឹងមិនដែលអាចមានសមត្ថភាពក្នុងការគិតអំពីវាទាល់តែសោះមែនឬ?

១៩. ការចងចាំក៏មានរួមទាំងគោលការណ៍ និងច្បាប់ដែលគ្មានតួលេខ ទាក់ទងទៅនឹងលេខ និងការវាស់វែង។ ទាំងនេះគ្មានការទាក់ទាញចំណាប់អារម្មណ៍ក្នុងការចងចាំតាមរយៈញាណខាងឯសាច់ឈាមនោះទេ ពីព្រោះវាមិនមានទាំងពណ៌ សំឡេង រសជាតិ ឬក៏ញាណនៃការប៉ះពាល់ឡើយ។ ទូលបង្គំបានឮសំឡេងនៃពាក្យពេចន៍ទាំងនេះតាមរយៈអ្វីៗដែលវាសម្គាល់ឲ្យពេលដែលគេឡើងមកវែកញែកៈ ប៉ុន្តែសំឡេងគឺជារឿងតែមួយប៉ុណ្ណោះ ហើយវត្ថុផ្ទាល់គឺជារឿងមួយទៀត។ ដ្បិតសំឡេងគឺជារឿងមួយក្នុងភាសាក្រិក ហើយក៏ជារឿងមួយទៀតក្នុងភាសាឡាតាំង ប៉ុន្តែវត្ថុផ្ទាល់គឺមិនពាក់ព័ន្ធទៅនឹងក្រិកឬក៏ឡាតាំង ឬក៏ភាសាណាផ្សេងនោះទេ។ ទូលបង្គំធ្លាប់ឃើញខ្សែរបស់ពួកសិប្បករ គឺត្រង់ស្អាតដូចជាសម្បុកពីងពាង ប៉ុន្តែទាក់ទងទៅនឹងគណិតវិទ្យា ខ្សែគឺមិនដូចគ្នានោះទេ។ វាមិនមែនជារូបភាពដូចអ្វីដែលភ្នែកនៃរូបកាយរបស់ទូលបង្គំបានបង្ហាញឲ្យទូលបង្គំឃើញនោះទេ។ បុគ្គលដែលស្គាល់វាគឺស្គាល់ដោយមិនបាច់កោះហៅវត្ថុនោះឡើងខាងឯសាច់ឈាមផ្ទាល់នោះទេ ប៉ុន្តែផ្ទុយពីនោះគ្រាន់តែវែកញែកវាក្នុងខ្លួនឯងផ្ទាល់។ ទូលបង្គំធ្លាប់បានគិតដោយប្រើប្រាស់ញាណទាំងអស់នៃរូបកាយរបស់ទូលបង្គំ ទាក់ទងទៅនឹងតួលេខដែលយើងប្រើប្រាស់ក្នុងការរាប់ ប៉ុន្តែតួលេខដែលយើងរាប់គឺមានភាពខុសគ្នាឆ្ងាយណាស់ពីវត្ថុទាំងនោះ។ វាមិនមែនជារូបភាពនៃរបស់ទាំងនោះទេ តែវាគឺជា

វាផ្ទាល់តែម្តង។ សូមឲ្យបុគ្គលដែលមិនអាចឃើញចំណុចទាំងនេះសើចចំអកដាក់ទូលបង្គំ ដោយសារទូលបង្គំលើកឡើងអំពីវាចុះ ហើយទូលបង្គំនឹងអាណិតគាត់ខណៈពេលដែលគាត់កំពុងតែសើចចំអកដាក់ទូលបង្គំ។

២០. ទាំងអស់នេះទូលបង្គំមាននៅក្នុងការចងចាំរបស់ទូលបង្គំ ហើយទូលបង្គំចាំអំពីរបៀបដែលទូលបង្គំបានរៀនអំពីពួកវា។ ទូលបង្គំក៏ចាំបានអំពីចំណុចជាច្រើនដែលទូលបង្គំបានឮដែលជាការខុសឆ្គងទាស់ប្រឆាំងនឹងពួកវា ប៉ុន្តែទូលបង្គំពិតជាមិនបានចាំអំពីវាមែន ទោះបើចំណុចទាំងនោះខុសឆ្គងមែន។ ហើយទូលបង្គំក៏ចាំអំពីការដែលទូលបង្គំបានវែកញែករវាងវត្ថុពិត និងវត្ថុមិនពិត ហើយឥឡូវនេះទូលបង្គំឃើញថា វាជារឿងមួយទេក្នុងការវែកញែកចំណុចទាំងអស់នេះ ហើយគឺជារឿងមួយទៀតក្នុងការចាំថា ទូលបង្គំពិតជាបានវែកញែកអំពីពួកវាមែន ពេលដែលទូលបង្គំបានគិតអំពីពួកវា។ កាលនោះទូលបង្គំចាំថា៖ ជារឿយៗទូលបង្គំក៏បានយល់អំពីចំណុចទាំងនោះ ហើយឥឡូវនេះទូលបង្គំក៏បានរក្សាវាទុកក្នុងការចងចាំរបស់ទូលបង្គំអំពីអ្វីដែលទូលបង្គំបានវែកញែក ហើយយល់អំពីវា ដើម្បីឲ្យពេលក្រោយទូលបង្គំអាចចងចាំវាដូចដែលទូលបង្គំបានយល់អំពីវាដូចពេលឥឡូវនេះផងដែរ។ ដូច្នេះ ទូលបង្គំចាំថាទូលបង្គំបានចាំ ដើម្បីឲ្យថាពេលក្រោយប្រសិនបើទូលបង្គំរម្លឹកវាក្នុងគំនិត ដែលពីមុនទូលបង្គំមានសមត្ថភាពក្នុងការចាំអំពីចំណុចទាំងនោះ នោះវានឹងកើតឡើងតាមរយៈអំណាចនៃការចងចាំដែលទូលបង្គំអាចកោះហៅវាមកបាន—ពោលគឺនឹងនឹកឃើញវាមកវិញបាន។

២១. ការចងចាំដូចនេះក៏មានរួមទាំងអារម្មណ៍នៃគំនិតរបស់ទូលបង្គំដែរ មិនមែនក្នុងរបៀបដែលគំនិតបានដកពិសោធន៍លើវានោះទេ ប៉ុន្តែខុសប្លែកគ្នាពីនោះយ៉ាងខ្លាំងដោយយោងលើអំណាចដ៏ចម្លែកនៃការចងចាំ។ ដ្បិតដោយមិនមានអំណរឥឡូវនេះ ក៏ទូលបង្គំនៅអាចចាំថាធ្លាប់មានពេលមុនទូលបង្គំមានអំណរដែរ ហើយដោយមិនបាច់មានការមិនសប្បាយចិត្តឥឡូវនេះ ក៏ទូលបង្គំនៅអាចរម្លឹកអំពីការមិនសប្បាយចិត្តពីអតីតកាលរបស់ទូលបង្គំបានមែនដែរ។ ទូលបង្គំនៅអាចចាំអំពីការភ័យខ្លាចពីអតីតកាលដោយមិនចាំបាច់ភ័យខ្លាចឥឡូវនេះ នឹងចាំអំពីការប្រាថ្នាពីមុនៗដោយមិនចាំបាច់ប្រាថ្នាឥឡូវនេះ។ ជាថ្មីម្តងទៀត ការផ្ទុយគ្នាក៏អាចកើតឡើងបានដែរ។ ពេលខ្លះពេលដែលទូលបង្គំមានអំណរ នោះទូលបង្គំក៏ចាំអំពីការមិនសប្បាយចិត្តដែលបានកើតពីអតីតកាលដែរ

ហើយពេលទូលបង្គំមិនសប្បាយចិត្ត នោះទូលបង្គំក៏ចាំអំពីការមានអំណរពីអតីតកាលរបស់ទូលបង្គំដែរ។

នេះមិនមែនជាអ្វីដែលយើងគួរភ្ញាក់ផ្អើលទេ ទាក់ទងទៅនឹងរូបកាយ ដ្បិតគំនិតគឺជារឿងមួយ ហើយរូបកាយគឺជារឿងមួយទៀត។ ដូច្នេះ ប្រសិនបើពេលខ្លះទូលបង្គំសប្បាយចិត្ត ហើយទូលបង្គំនឹកចាំអំពីការឈឺចាប់ខាងឯរូបកាយពីអតីតកាលមួយចំនួន នោះវាគឺមិនមែនជារឿងចម្លែកទេ។ ប៉ុន្តែ សូម្បីតែខណៈពេលដែលការចងចាំនេះកំពុងតែដកពិសោធន៍ ក៏វាមានភាពដូចគ្នាជាមួយនឹងគំនិត—ដូចដែលយើងប្រាប់បុគ្គលណាម្នាក់ឲ្យនឹកចាំអំពីអ្វីដែលយើងនិយាយ «សូមប្រាកដថាឲ្យលោកអ្នកចងចាំអំពីចំណុចនេះក្នុងគំនិត» ហើយពេលដែលយើងភ្លេចចំណុចណាមួយ នោះយើងនិយាយថា «វាមិនបានចូលមកក្នុងគំនិតរបស់ខ្ញុំទេ» ឬក៏ថា «វាបានរំលងគំនិតខ្ញុំហើយ»។ ដូច្នេះ យើងក៏ហៅការចងចាំផ្ទាល់ថាជាគំនិត។

ដោយសារវាដូច្នោះមែន តើវាកើតឡើងដោយរបៀបណាដែលថា ពេលដែលទូលបង្គំកំពុងតែមានអំណរ ស្របពេលនោះទូលបង្គំក៏ចងចាំអំពីការឈឺចាប់ពីអតីតកាលដែរ? ដូច្នេះ គំនិតមានអំណរ ហើយការចងចាំមានការឈឺចាប់ ហើយគំនិតក៏មានអំណរចេញពីអំណរដែលវាកំពុងតែនៅក្នុង តែការចងចាំមិនពិបាកចិត្តពីការមិនសប្បាយចិត្តដែលវាធ្លាប់នៅក្នុង។ តើវាអាចទៅរួចទេដែលថា គំនិតមិនមែនជាម្ចាស់នៃការចងចាំ? តើអ្នកណានឹងហ៊ានថាដូច្នោះ? យើងអាចនិយាយថា គ្មានមន្ទិលសង្ស័យទេដែលថាការចងចាំប្រៀបដូចជាក្បាលពោះនៃគំនិត៖ ហើយអំណរ និងការមិនសប្បាយចិត្តគឺប្រៀបដូចជាម្ហូបដែលផ្អែម និងល្វីង ត្រង់ថាពេលដែលវាបានចូលទៅក្នុងការចងចាំ នោះវាហាក់បីដូចជាថាវាបានឆ្លងកាត់ពោះ ដែលនៅទីនោះវាអាចរក្សាទុកបាន ប៉ុន្តែមិនអាចមានការភ្លក់បានទៀតឡើយ។ ការប្រៀបប្រដូចបែបនេះគឺពិតជាការអស់សំណើចមែន ប៉ុន្តែតាមពិតទៅវាមិនមែនដូច្នោះទាំងស្រុងនោះទេ។

២២. ប៉ុន្តែ វាចេញពីការចងចាំរបស់ទូលបង្គំហ្នឹងហើយដែលទូលបង្គំបានបង្កើតមកនៅពេលដែលទូលបង្គំថាមានអារម្មណ៍ជាមូលដ្ឋានគោល៤ប្រភេទនៃគំនិត៖ សេចក្តីប្រាថ្នា អំណរ ភាពភ័យខ្លាច និងការបារម្ភ។ មិនថាទូលបង្គំទំនងជាបានវិភាគដោយប្រភេទណាក៏ដោយទាក់ទងទៅនឹងចំណុចនេះ ដោយបែងចែកចំណុចនីមួយៗទៅជា

ប្រភេទដោយឡែកៗពីគ្នា នោះទូលបង្គំនៅអាចរកឃើញអំពីអ្វីដែលទូលបង្គំកំពុងតែនិយាយនៅក្នុងការចងចាំរបស់ទូលបង្គំបាន ហើយវាគឺចេញពីការចងចាំរបស់ទូលបង្គំ ហើយដែលទូលបង្គំបានស្រង់វាចេញ។ ប៉ុន្តែ ទូលបង្គំក៏មិនមានការប៉ះពាល់ចេញពីអារម្មណ៍ទាំងនោះ ពេលដែលទូលបង្គំដកវាចេញពីគំនិតរបស់ទូលបង្គំតាមរយៈការចងចាំវានោះទេ។ លើសពីនោះទៅទៀត មុនពេលដែលទូលបង្គំរម្លឹកអំពីពួកវា និងគិតអំពីពួកវា នោះពួកវាក៏មាននៅក្នុងការចងចាំរបស់ទូលបង្គំជាស្រេចហើយ ហើយនេះឯងគឺជារបៀបដែលមានការចងចាំអំពីពួកវាបាន។ ដូច្នេះ ទំនងដូចទៅនឹងអាហារដែលបានលេចចេញពីពោះតាមរយៈការសញ្ជឹងគិតដូចជាគោទំពាអៀង ដូចគ្នាផងដែរចំណុចទាំងអស់នេះគឺត្រូវបានដកចេញឡើងពីការចងចាំតាមរយៈការរម្លឹក។ ប៉ុន្តែ បើដូច្នោះមែន ហេតុអ្វីបានជាបុគ្គលម្នាក់ដែលមិនកំពុងគិតអំពីអារម្មណ៍ក៏បែរជាកំពុងរម្លឹកអំពីពួកវាក៏មានអារម្មណ៍ក្នុងមាត់របស់គាត់នៃការទំពាអៀងនៃភាពផ្អែមល្ហែមនៃអំណរ ឬក៏ភាពល្វីងនៃការមិនសប្បាយចិត្តទៅវិញ? តើការប្រៀបធៀបមិនមានភាពដូចគ្នាទាំងស្រុងក្នុងចំណុចនេះ ពីព្រោះវាមិនមានភាពពេញទីក្នុងរាល់ចំណុចមែនឬ? ដ្បិតតើអ្នកណានឹងនិយាយដោយសេរីអំពីប្រធានបទទាំងនេះ ប្រសិនបើជារឿយៗយើងប្រើប្រាស់ពាក្យមិនសប្បាយចិត្ត និងភាពភ័យខ្លាច នោះយើងគួរមានការបង្ខំឲ្យមិនសប្បាយចិត្ត ឬក៏ឲ្យមានការភ័យខ្លាច? ហើយទោះជាយ៉ាងណាក្តីក៏យើងមិនអាចនិយាយអំពីវាបាន ប្រសិនបើយើងមិនអាចរកវាឃើញបាននៅក្នុងការចងចាំរបស់យើង មិនមែនគ្រាន់តែដូចជាសំឡេងនៃឈ្មោះ ហាក់បីដូចជាថារូបរាងរបស់វាមានការចាប់អារម្មណ៍លើវាតាមរយៈញាណខាងឯសាច់ឈាម ប៉ុន្តែក៏ពាក់ព័ន្ធទៅនឹងគំនិតនៃចំណុចទាំងនោះផ្ទាល់—ដែលយើងមិនបានទទួលបានតាមរយៈទ្វារនៃសាច់ឈាម ប៉ុន្តែគឺគំនិតផ្ទាល់បានស្គាល់វាតាមរយៈការមានបទពិសោធន៍អំពីវាក្នុងការឆេះឆួលរបស់វា ហើយក៏បានផ្តល់ជាទំនួលខុសត្រូវទៅកាន់ការចងចាំ ឬក៏បើមិនដូច្នោះនោះការចងចាំផ្ទាល់បានទទួលវាដោយគ្មានការផ្តល់ជាទំនួលខុសត្រូវដល់វា។

២៤. ពេលដែលទូលបង្គំលើកឡើងអំពីការភ្លេចភ្លាំង ហើយយល់អំពីអ្វីដែលទូលបង្គំចង់មានន័យទាក់ទងនឹងវា តើទូលបង្គំមានការយល់ដឹងអំពីវាបានយ៉ាងដូចម្តេចបានប្រសិនបើទូលបង្គំមិនបានចងចាំវាមែនដោយរបៀបណាទៅហ្ន៎? ហើយប្រសិនបើ

ទូលបង្គំមិនលើកឡើងដោយសំដៅទៅលើសំឡេងនៃការភ្លេចភ្លាំង ប៉ុន្តែសំដៅលើអ្វីមួយនោះដែលពាក្យពេចន៍នោះសម្គាល់ឲ្យ តើឲ្យទូលបង្គំអាចដឹងថាសំឡេងនោះសម្គាល់ឲ្យអ្វីបានប្រសិនបើទូលបង្គំបានភ្លេចថាការភ្លេចភ្លាំងនោះមានន័យអ្វី? ដូច្នេះ នៅពេលដែលទូលបង្គំចាំអំពីការចងចាំ នោះការចងចាំនឹងមានវត្តមានផ្ទាល់តាមរយៈវាផ្ទាល់។ ប៉ុន្តែ នៅពេលដែលទូលបង្គំចងចាំអំពីការភ្លេចភ្លាំង នោះទាំងការចងចាំ និងការភ្លេចភ្លាំងក៏មានវត្តមានក្នុងពេលតែមួយ—ពោលគឺការចងចាំដែលទូលបង្គំបានចាំអំពីការភ្លេចភ្លាំងដែលទូលបង្គំបានចាំវិញ។ ប៉ុន្តែ តើអ្វីទៅជាការភ្លេចភ្លាំង ក្រៅពីការគ្មានការចងចាំ? ដូច្នេះ តើវាមានវត្តមានក្នុងការចងចាំរបស់ទូលបង្គំយ៉ាងដូចម្ដេចទៅ ពេលដែលវាគ្រប់គ្រងលើគំនិតរបស់ទូលបង្គំនូវអ្វីដែលទូលបង្គំមិនអាចចងចាំបាន? ប៉ុន្តែ ប្រសិនបើអ្វីដែលយើងចាំយើងបានរក្សាទុកនៅក្នុងការចងចាំរបស់យើង ហើយប្រសិនបើ លុះត្រាតែយើងចង់ចាំការភ្លេចភ្លាំង នោះយើងមិនអាចដឹងអំពីអ្វីដែលជាទីសម្គាល់តាមរយៈពាក្យពេចន៍ពេលដែលយើងឮវានោះទេ—នោះមានន័យថា ការភ្លេចភ្លាំងគឺមានបន្សល់ទុកនៅក្នុងការចងចាំ។ វាមានវត្តមាន ដើម្បីកុំឲ្យយើងភ្លេចវា ប៉ុន្តែដោយសារវាមានវត្តមាន នោះយើងក៏ភ្លេចមែនដែរ។

ចេញពីចំណុចនេះ យើងគួរយល់ថាពេលដែលយើងចាំការភ្លេចភ្លាំង នោះមិនមែនមកពីវាមានវត្តមាននៅក្នុងការចងចាំតាមរយៈវាផ្ទាល់នោះទេ ប៉ុន្តែគឺថាតាមរយៈរូបរាងរបស់វា ពីព្រោះបើការភ្លេចភ្លាំងមានវត្តមានតាមរយៈវាផ្ទាល់ នោះវានឹងមិននាំយើងទៅដល់ការចងចាំបានទេឡើយ ប៉ុន្តែគ្រាន់តែជាការភ្លេចប៉ុណ្ណោះ។ ឥឡូវ តើនឹងមានអ្នកណានឹងបកស្រាយការនេះនៅថ្ងៃណាមួយដែរឬទេ? តើមានអ្នកណាអាចយល់អំពីរបៀបនេះបានដែរឬទេ?

២៦. ការចងចាំពិតជាមានអំណាចខ្លាំងមែន។ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! វាពិតជាគួរឲ្យភ្ញាក់ផ្អើលណាស់ ជាការដ៏ម៉ត់ចត់ និងពហុភាពដែលគ្មានទីបញ្ចប់! ហើយនេះឯងគឺជាគំនិត ហើយនេះក៏ជាទូលបង្គំផ្ទាល់ដែរ។ បើអញ្ចឹង ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! តើទូលបង្គំជាអ្វីទៅ? តើទូលបង្គំមានលក្ខណៈជាអ្វី? ជាជីវិតផ្សេងៗគ្នា ហើយមានច្រើនប្រភេទ ហើយក៏ធំទៅក្រៃលែងខ្លាំងដែរ។ មើល៍! ក្នុងបន្ទប់ និងរូងភ្នំដែលមិនអាចរាប់អស់បាន ក្នុងទីវាល បន្ទប់ និងគុហាធំៗនៃការចងចាំរបស់ទូលបង្គំដែលមិន

អាចរាប់អស់បាន គឺពេញដោយការមិនមានរង្វាស់នៃការដាក់តួលេខប្រភេទណាបាន នៃចំណុចទាំងនោះឡើយ—មានវត្ថុមាននៅទីនោះតាមរយៈរូបភាពដូចជារូបកាយទាំងអស់ ឬក៏មានវត្ថុមានក្នុងចំណុចទាំងនោះផ្ទាល់ដូចដែលគំនិតរបស់យើងមានដែរ។ ក៏តាមរយៈការសម្គាល់ ឬក៏ការសង្កេតដូចដែលអារម្មណ៍របស់យើងមានការចងចាំមានដែរ ដូចដែលគំនិតមានអារម្មណ៍ថាវាក៏មាន ដែលការចងចាំបានរក្សាទុកទោះបើគំនិតមានអារម្មណ៍ថាវាលែងមានទៀតក៏ដោយ ដរាបណានៅមានអ្វីៗនោះនៅក្នុងការចងចាំ នោះវាក៏នៅក្នុងគំនិតផងដែរ—តាមរយៈទាំងអស់នេះ ទូលបង្គំរត់ និងហោះទៅវិញទៅមក។ ទូលបង្គំជ្រៀតចូលវាពីខាងនេះ និងពីខាងនោះយ៉ាងឆ្ងាយតាមដែលទូលបង្គំអាចចូលទៅបាន តែវាគ្មានទីបញ្ចប់ទេ។

ដូច្នេះ ការចងចាំពិតជាមានអំណាចខ្លាំងមែន ហើយអំណាចក្នុងជីវិតមនុស្សក៏ពិតជាអស្ចារ្យមែន ទោះបើជាជីវិតមិនអមតៈក៏ដោយ! ឱព្រះជាម្ចាស់ដ៏ជាជីវិតពិតរបស់ទូលបង្គំអើយ! ដូច្នេះ តើទូលបង្គំគួរធ្វើអ្វីទៅ? ទូលបង្គំក៏នឹងទៅហួស សូម្បីតែលើសអំណាចរបស់ទូលបង្គំមួយនេះដែលហៅថាការចងចាំ—ទូលបង្គំនឹងទៅហួសវា ដើម្បីឲ្យទូលបង្គំអាចទៅដល់ព្រះអង្គ ឱពន្លឺដ៏គួរឲ្យស្រឡាញ់អើយ! ហើយតើព្រះអង្គកំពុងមានព្រះបន្ទូលអ្វីមកកាន់ទូលបង្គំ? មើល៍! ទូលបង្គំហោះទៅកាន់ព្រះអង្គតាមរយៈគំនិតរបស់ទូលបង្គំ ហើយព្រះអង្គគង់នៅពីលើទូលបង្គំ។ ទូលបង្គំក៏នឹងទៅលើសអំណាចរបស់ទូលបង្គំមួយនេះដែលហៅថាការចងចាំ ដោយប្រាថ្នាឈោងចាប់ព្រះអង្គនៅទីកន្លែងដែលព្រះអង្គកំពុងគង់នៅ ហើយចង់ឱបក្រសោបព្រះអង្គនៅកន្លែងដែលអាចឱបក្រសោបព្រះអង្គបាន។ ដ្បិតសូម្បីតែសត្វ និងបក្សាបក្សីក៏មានការចងចាំដែរ ព្រោះបើមិនដូច្នោះទេ នោះពួកវានឹងមិនអាចរកទីជម្រក ឬក៏សម្បុករបស់វាម្តងទៀតបានឡើយ ហើយក៏មិនអាចបង្ហាញអ្វីជាច្រើនទៀតដែលពួកវាមាន ឬក៏ប្រព្រឹត្តទម្លាប់ដដែលៗ។ ប្រាកដណាស់! ពួកវាមិនទាំងអាចបំពេញទម្លាប់របស់ខ្លួនបាន លើកលែងតែតាមរយៈការចងចាំរបស់ពួកវា។ ដូច្នេះ ទូលបង្គំនឹងទៅហួស សូម្បីតែការចងចាំរបស់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចឈោងទៅដល់ព្រះអង្គដែលជាអង្គដែលបានវែកញែកទូលបង្គំដាច់ស្រេចចេញពីសត្វជើងបួន និងបក្សាបក្សីនៅលើអាកាសដែលការនេះនឹងធ្វើឲ្យទូលបង្គំឆ្លាតវាងវៃជាងរបស់សព្វសារពើផ្សេងៗទៀត។ ហេតុដូច្នេះហើយ ទូលបង្គំនឹងទៅហួសការចងចាំ។ ប៉ុន្តែ តើទូល

បង្គំរកឃើញព្រះអង្គនៅកន្លែងណាបាន ទ្រង់គឺជាអង្គដែលល្អពិតមែន ហើយក៏ជាភាពផ្អែមល្ហែមដែលនៅស្ថិតស្ថេរដែរ? ប៉ុន្តែ តើទូលបង្គំនឹងរកឃើញព្រះអង្គនៅកន្លែងណា? ប្រសិនបើទូលបង្គំរកព្រះអង្គឃើញដោយមិនមានការចងចាំ នោះទូលបង្គំនឹងមិនមានការចងចាំទេ។ ហើយថាតើទូលបង្គំអាចរកឃើញព្រះអង្គបានដោយរបៀបណាទៅបាន ប្រសិនបើទូលបង្គំមិនទាំងអាចចាំព្រះអង្គបានផង?

២៧. ដ្បិតស្ត្រីដែលបានបាត់កាក់ដ៏តូចរបស់គាត់[១១] ហើយស្វែងរកវាដោយប្រើពន្លឺ ក៏នឹងមិនអាចរកវាឃើញបានដែរ លុះត្រាតែគាត់បានចងចាំវា។ ដ្បិតពេលដែលគាត់រកវាឃើញ តើគាត់អាចដឹងបានដោយរបៀបណាថា នេះគឺជាកាក់ដូចគ្នាតែមួយ ប្រសិនបើគាត់មិនបានចងចាំវា? ទូលបង្គំចាំអំពីការបាត់បង់ និងការរកឃើញរបស់ជាច្រើន ហើយទូលបង្គំបានរៀនអំពីចំណុចនេះចេញពីការដកបទពិសោធន៍ត្រង់ថា ពេលទូលបង្គំកំពុងស្វែងរករបស់ណាមួយ ក៏បានសួរថា៖ «តើនេះមែនឬ? ឬក៏នោះទេអី?»។ ទូលបង្គំបានឆ្លើយថា «ទេ!» រហូតដល់នៅចុងបញ្ចប់ទូលបង្គំក៏បានឃើញនូវអ្វីដែលទូលបង្គំកំពុងតែស្វែងរក។ ប៉ុន្តែ ប្រសិនបើទូលបង្គំមិនបានចងចាំអំពីវាទេ—មិនថាអ្វីក៏ដោយ—ទោះបើទូលបង្គំបានឃើញវា នោះក៏ទូលបង្គំនឹងមិនអាចរកវាឃើញបានដែរ ពីព្រោះទូលបង្គំមិនបានស្គាល់វា។ ហើយនេះក៏តែងតែជារបៀបក្នុងពេលដែលយើងកំពុងតែស្វែងរកអ្វីមួយ ហើយរកឃើញអ្វីដែលបានបាត់បង់។ ទោះជាយ៉ាងណាក្តី ប្រសិនបើយើងបានបាត់បង់អ្វីមួយពីការមើលឃើញដោយចេញពីអចេតនា—មិនមែនពីការចងចាំ ហាក់បីដូចជារូបកាយមួយដែលអាចមើលឃើញបាន—នោះរូបភាពរបស់វានៅមាននៅក្នុងនៅឡើយទេ ហើយយើងនឹងបន្តស្វែងរកវារហូតដល់យើងឃើញវាផ្ទាល់វិញ។ ហើយនៅពេលដែលយើងរកវាឃើញ នោះយើងនឹងស្គាល់វាតាមរយៈរូបរាងដែលវាមាននៅខាងក្នុង។ ហើយយើងក៏មិនអាចថា យើងបានរកឃើញអ្វីដែលយើងបាត់បង់ លុះត្រាតែយើងអាចស្គាល់វាបានដែរ ហើយយើងក៏មិនអាចស្គាល់វាបាន លុះត្រាតែយើងចងចាំអំពីវាដែរ។ ប៉ុន្តែ ស្របពេលនោះដែរ អ្វីដែលបានបាត់បង់ពីការមើលឃើញក៏មានបន្សល់ទុកនៅក្នុងការចងចាំ។

២៨. ប៉ុន្តែ តើមានអ្វីកើតឡើងនៅពេលដែលការចងចាំផ្ទាល់បានបាត់បង់អ្វីមួយ ដូចពេលដែលយើងភ្លេចអ្វីមួយ ហើយព្យាយាមរម្លឹកវាវិញ? តើយើងទៅរកវានៅទីណា ក្រៅពី

---

១១ លូកា ១៥:៨-១០។

ក្នុងការចងចាំផ្ទាល់តែម្តង? ហើយក្នុងការចងចាំរបស់យើង ប្រសិនបើវាកើតឡើងដោយចៃដន្យត្រង់ថា ចំណុចមួយបានលើកឡើងជំនួសចំណុចមួយទៀត នោះយើងនឹងបដិសេធរហូតដល់យើងជួបនូវអ្វីដែលយើងកំពុងតែស្វែងរក។ ហើយពេលដែលយើងឃើញនូវអ្វីដែលយើងកំពុងតែស្វែងរក នោះយើងនឹងស្គាល់ថាវាពិតជាវាមែន។ ប៉ុន្តែ យើងមិនអាចធ្វើបែបនេះបានឡើយ លុះត្រាតែយើងស្គាល់វាសិន ហើយយើងក៏មិនអាចស្គាល់បានលុះត្រាតែយើងចងចាំអំពីវាដែរ។ ទោះជាយ៉ាងណាក្តី យើងក៏ពិតជាបានភ្លេចវាមែន។

ទំនងចំណុចទាំងមូលពិតជាមិនបានរអិលចេញពីការចងចាំរបស់យើងមែន ប៉ុន្តែមានផ្នែកមួយនៅសល់តាមរយៈផ្នែកដទៃដែលបានបាត់បង់ដែលយើងកំពុងតែស្វែងរក ពីព្រោះការចងចាំបានកត់សម្គាល់ថា វាមិនអាចដំណើរការបានយ៉ាងងាយស្រួលទេ ហើយក៏កំពុងតែមានភាពពិការក្នុងការដំណើរការនៃទម្លាប់របស់វាដែរ។ ហេតុដូច្នេះ វាក៏ទាមទារការស្តារឡើងវិញនូវអ្វីដែលបានបាត់បង់។

ឧទាហរណ៍៖ ប្រសិនបើយើងឃើញ ឬគិតអំពីបុគ្គលណាម្នាក់ដែលយើងស្គាល់ ហើយបានភ្លេចឈ្មោះរបស់គាត់ ដោយកំពុងព្យាយាមរម្លឹកខ្លួនឯង—បើមានអ្វីផ្សេងទៀតបង្ហាញជាវត្តមាន នោះយើងមិនអាចទាញវាបញ្ចូលក្នុងការព្យាយាមចងចាំបានទេ ពីព្រោះវាមិនមែនជាទម្លាប់នៃការគិតក្នុងការរាប់អានជាមួយនឹងគាត់ឡើយ។ នោះជាលទ្ធផល យើងនឹងបដិសេធវារហូតទាល់តែមានអ្វីមួយបានផុសឡើងនៅក្នុងគំនិតរបស់យើង ដែលចំណេះដឹងរបស់យើងអាចដឹងយ៉ាងត្រឹមត្រូវថា វាគឺជាអ្វីដែលយើងកំពុងតែស្វែងរក ឬក៏ជាអ្វីដែលយើងស្គាល់មែន។ ហើយតើឈ្មោះនោះត្រឡប់មកវិញពីកន្លែងណា លើកលែងតែពីការចងចាំផ្ទាល់តែម្តង? ដ្បិតសូម្បីពេលដែលយើងស្គាល់វាតាមរយៈការដែលបុគ្គលណាផ្សេងរម្លឹកយើងអំពីវា ក៏វានៅតែកើតចេញពីការចងចាំផងដែរ ដ្បិតយើងមិនជឿថាវាកើតឡើងពីអ្វីថ្មីទេ។ ប៉ុន្តែ ពេលដែលយើងរម្លឹកអំពីវា នោះយើងទទួលស្គាល់ថា អ្វីដែលបាននិយាយឡើងគឺត្រឹមត្រូវ។ ប៉ុន្តែ ប្រសិនបើឈ្មោះនោះត្រូវបានដកចេញដែលស្រង់ចេញពីគំនិត នោះយើងមិនមានសមត្ថភាពក្នុងការនឹកចាំវាឡើងវិញបានឡើយ សូម្បីតែពេលដែលយើងទទួលបានការរម្លឹកពីអ្នកដទៃក៏ដោយ។ ដ្បិតយើងមិនអាចភ្លេចអ្វីបានទាំងស្រុងឡើយ ប្រសិនបើយើងអាចចាំថាយើងបានភ្លេចវាក៏ដោយ។ ដ្បិតទាក់ទងទៅនឹងការភ្លេចភ្លាំង បុគ្គលម្នាក់មិនអាចភ្លេចទាំងស្រុងបានឡើយ

សូម្បីតែការស្វែងរកវាក៏យើងមិនមានសមត្ថភាពក្នុងការធ្វើបានផងដែរ។

# ២៦

# ការស្វែងរកជីវិតដ៏អរសប្បាយ

២៩. ឱព្រះអម្ចាស់អើយ! តើឲ្យទូលបង្គំស្វែងរកទ្រង់ដោយរបៀបណា? ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! ពេលទូលបង្គំស្វែងរកព្រះអង្គ ទូលបង្គំស្វែងរកជីវិតដ៏អរសប្បាយ ទូលបង្គំនឹងស្វែងរកព្រះអង្គ ដើម្បីឲ្យព្រលឹងទូលបង្គំអាចមានជីវិតបាន។[១] ដ្បិតរូបកាយទូលបង្គំមានជីវិតតាមរយៈព្រលឹងទូលបង្គំ ហើយព្រលឹងទូលបង្គំមានជីវិតតាមរយៈព្រះអង្គ។ ដូច្នេះ តើឲ្យទូលបង្គំស្វែងរកជីវិតដ៏អរសប្បាយបានដោយរបៀបណា ដោយសារសេចក្តីអរសប្បាយគឺមិនមែនជារបស់ទូលបង្គំ លុះត្រាតែទូលបង្គំអាចនិយាយថា «វាគ្រប់គ្រាន់ហើយ។ នេះគឺជាវាមែន»។ តើទូលបង្គំស្វែងរកវាដោយរបៀបណា? តើតាមរយៈការចងចាំ ហាក់បីដូចជាទូលបង្គំបានភ្លេចវា ហើយនៅដឹងថាទូលបង្គំបានភ្លេចវាមែនឬ? តើ

១ អេសាយ ៥៥:៣។

ទូលបង្គំនៅស្វែងរកវា ដោយមានចិត្តចង់រៀនអំពីវា ហាក់បីដូចជាថាវាជាអ្វីមួយដែលទូលបង្គំមិនទាន់ដឹងមែនឬ ដែលទូលបង្គំមិនដែលដឹង ឬក៏បានភ្លេចវាទាំងស្រុង សូម្បីតែមិនអាចចងចាំថាទូលបង្គំបានភ្លេចវា? តើការមានជីវិតអរសប្បាយមិនមែនជាអ្វីដែលគ្រប់គ្នាប្រាថ្នាចង់បាន ហើយតើមានបុគ្គលណាម្នាក់មិនប្រាថ្នាចង់បានវាដែរឬទេ? ប៉ុន្តែតើពួកគាត់មានចំណេះដឹងអំពីវាពីណា ដែលថាពួកគាត់គួរប្រាថ្នាចង់បានវា? តើពួកគាត់បានឃើញវានៅកន្លែងណាដែលពួកគាត់គួរស្រឡាញ់វាដូច្នោះ? វាពិតក្នុងរបៀបណាមួយមែនដែលយើងមានចំណេះដឹងនេះ។ ប៉ុន្តែ ទូលបង្គំមិនដឹងថា យើងបានវាដោយរបៀបណាដែរឬទេ។

ប្រាកដណាស់! គឺមានអត្ថន័យដែលថា ពេលដែលបុគ្គលណាទទួលបានសេចក្ដីប្រាថ្នារបស់គាត់ នោះគាត់សប្បាយមែន។ ហើយក៏មានអ្នកខ្លះដែលសប្បាយក្នុងក្ដីសង្ឃឹម។ ពួកគាត់ទាំងនេះសប្បាយយ៉ាងអន់ជាងអស់អ្នកដែលពិតជាសប្បាយមែន ទោះជាយ៉ាងណាក្ដីក៏ពួកគាត់នៅល្អប្រសើរជាងអស់អ្នកដែលមិនសប្បាយក្នុងជីវិត ឬក៏ក្នុងក្ដីសង្ឃឹមដែរ។ ប៉ុន្តែ សូម្បីតែពួកទាំងនេះ ប្រសិនបើពួកគាត់មិនស្គាល់ការអរសប្បាយក្នុងកម្រិតណាមួយ ក៏នឹងមិនអាចប្រាថ្នាចង់អរសប្បាយបានផងដែរ។ ហើយទោះជាយ៉ាងណាក៏ដោយក៏ប្រាកដណាស់ពួកគាត់ក៏ពិតជាបានប្រាថ្នាដូចនោះមែន។ ទូលបង្គំមិនដឹងពីរបៀបដែលពួកគាត់ស្គាល់ការអរសប្បាយនោះទេ ប៉ុន្តែពួកគាត់មានវាតាមរយៈចំណេះដឹងមួយប្រភេទដែលទូលបង្គំមិនស្គាល់ ដ្បិតទូលបង្គំសង្ស័យយ៉ាងខ្លាំងណាស់ថា វាមាននៅក្នុងការចងចាំ។ ដ្បិតបើវាមាននៅទីនោះមែន នោះនឹងមានន័យថា យើងធ្លាប់អរសប្បាយពីមុនហើយ—ត្រង់ថា៖ យើងនីមួយៗផ្ទាល់ ឬក៏យើងទាំងអស់គ្នាក្នុងបុរសដំបូងដែលបានប្រព្រឹត្តអំពើបាប ហើយក្នុងគាត់យើងទាំងអស់គ្នាក៏បានស្លាប់ ហើយចេញពីគាត់យើងក៏បានកើតក្នុងភាពវេទនាដែរ។ ទាក់ទងនឹងរបៀបនេះបានកើតឡើង ឥឡូវនេះទូលបង្គំមិនសួរទៀតឡើយ។ ប៉ុន្តែ ទូលបង្គំចង់សួរថា តើជីវិតអរសប្បាយមាននៅក្នុងការចងចាំមែនឬ? ដ្បិតបើយើងមិនដឹងអំពីវា នោះយើងក៏នឹងមិនគួរស្រឡាញ់វាដែរ។ យើងឮឈ្មោះរបស់វា ហើយយើងទាំងអស់គ្នាក៏ទទួលស្គាល់ថាយើងចង់បានវា ដ្បិតយើងមិនអរសប្បាយជាមួយនឹងតែឈ្មោះរបស់វាប៉ុណ្ណោះទេ។ ដ្បិតពេលសាសន៍ក្រិកឮពាក្យ “អរសប្បាយ” ក្នុងភាសាឡាតាំង នោះគាត់នឹងមិនមានអារម្មណ៍សប្បាយ

ទេ ដ្បិតគាត់មិនដឹងថាគេបាននិយាយអ្វីឡើយ។ ប៉ុន្តែ យើងក៏នឹងអរសប្បាយដូចដែលគាត់នឹងអរសប្បាយ ប្រសិនបើគាត់ឮគេនិយាយក្នុងភាសាក្រិក ពីព្រោះចំណុចនេះផ្ទាល់គឺមិនមែនជាភាសាក្រិក ឬក៏ភាសាឡាតាំងនោះទេ។ សាសន៍ក្រិក សាសន៍ឡាតាំង និងមនុស្សគ្រប់ជាតិសាសន៍ក្នុងគ្រប់ភាសាប្រាថ្នាចង់ទទួលបានការអរសប្បាយនេះយ៉ាងពេញទី។ មនុស្សគ្រប់រូបស្គាល់ការអរសប្បាយ។ ហើយប្រសិនបើមានសំឡេងតែមួយអាចសួរមនុស្សទាំងអស់ថា តើពួកគាត់ប្រាថ្នាចង់អរសប្បាយដែរឬទេ នោះគ្មានមន្ទិលសង្ស័យទេត្រង់ថា ពួកគាត់នឹងឆ្លើយថាពួកគាត់ចង់។ ហើយនេះក៏មិនអាចទៅរួចបានដែរ លុះត្រាតែចំណុចនោះផ្ទាល់ ដែលយើងហៅថា «ការអរសប្បាយ» មានរួចស្រេចទៅហើយក្នុងការចងចាំ។

៣១. តើនៅទីណា និងពេលណាដែលទូលបង្គំធ្លាប់មានបទពិសោធន៍ក្នុងស្ថានភាពនៃការអរសប្បាយដែលពេញទៅដោយពរជ័យ ដែលទូលបង្គំអាចរម្លឹកមកក្នុងគំនិតហើយស្រឡាញ់វា ហើយប្រាថ្នាចង់បានវា? មិនមានតែទូលបង្គំតែឯងផ្ទាល់ ឬក៏មនុស្សពីរបីនាក់ប៉ុណ្ណោះទេដែលប្រាថ្នាចង់អរសប្បាយ ប៉ុន្តែគ្រប់គ្នាតែម្តង។ លុះត្រាតែយើងស្គាល់សេចក្តីអរសប្បាយតាមរយៈចំណេះដឹងដែលពិតប្រាកដ នោះយើងក៏មិនប្រាថ្នាចង់បានវាដោយមានឆន្ទៈយ៉ាងប្រាកដប្រជាបានផងដែរ។ សូមមើលឧទាហរណ៍នេះ៖ ប្រសិនបើមានគេសួរបុរសពីរនាក់ថា តើពួកគាត់ប្រាថ្នាចង់ធ្វើជាទាហានដែរឬទេ នោះម្នាក់ទំនងនឹងឆ្លើយថាគាត់ចង់ ហើយម្នាក់ទៀតទំនងនឹងឆ្លើយថាគាត់មិនចង់ទេ។ ប៉ុន្តែប្រសិនបើគេសួរពួកគាត់ថា តើពួកគាត់ប្រាថ្នាចង់អរសប្បាយដែរឬទេ នោះទាំងពីរនាក់នឹងឆ្លើយដោយមិនស្ទាក់ស្ទើរថា ពួកគាត់ចង់ជាមិនខាន។ ប៉ុន្តែ បុរសទីមួយនឹងទំនងជាប្រាថ្នាចង់ធ្វើជាទាហាន ហើយបុរសម្នាក់ទៀតនឹងទំនងជាមិនប្រាថ្នាចង់ធ្វើ ទាំងពីរនាក់គឺគ្មានការជំរុញណា ក្រៅពីការអរសប្បាយទេ។ តើអាចទេថា ទំនងម្នាក់បានអំណរក្នុងការនោះ ហើយម្នាក់ទៀតបានអំណរក្នុងការនេះ? ដូច្នេះ ពួកគាត់ឯកភាពក្នុងការប្រាថ្នាចង់បានសេចក្តីអរសប្បាយដូចដែលពួកគាត់ក៏នឹងឯកភាពប្រសិនបើគេសួរក្នុងការប្រាថ្នាចង់បានអំណរ? តើអំណរនេះគឺជាអ្វីដែលគេហៅថាជាជីវិតដ៏អរសប្បាយមែនឬ? ទោះបីបុគ្គលម្នាក់អាចជ្រើសរើសអំណររបស់គាត់ក្នុងរបៀបនោះ ហើយម្នាក់ទៀតក្នុងរបៀបនេះ នោះក៏ទាំងអស់គ្នានៅមានគោលបំណងតែមួយដែលពួកគេកំពុងតែព្យាយាមទទួលបាន៖

និយាយឲ្យចំទៅ គឺការមានអំណរ។ គ្មានបុគ្គលណាអាចនិយាយថា គាត់មិនដែលមានបទពិសោធន៍ជាមួយនឹងអំណរទេ ហេតុដូច្នេះយើងអាចរកឃើញបាននៅក្នុងការចងចាំ ហើយគេក៏ស្គាល់វាពេលណាដែលគេឮឃ្លា "ជីវិតដ៏អរសប្បាយ"។

៣២. ឱព្រះអម្ចាស់អើយ! សូមហាម ដោយដាក់វាឲ្យឆ្ងាយពីដួងចិត្តនៃអ្នកបម្រើរបស់ព្រះអង្គ ដែលទូលបង្គំកំពុងតែលន់តួទៅកាន់ទ្រង់—សូមឲ្យ វានៅឆ្ងាយពីទូលបង្គំដោយកុំឲ្យទូលបង្គំគិតថាខ្លួនឯងអរសប្បាយដោយសារមានផ្នែកណាមួយ ឬក៏ផ្នែកទាំងមូលនៃអំណរ។ ដ្បិតមានអំណរដែលមិនប្រទានដល់ពួកអាក្រក់ ប៉ុន្តែដល់តែអស់អ្នកដែលថ្វាយបង្គំព្រះអង្គដោយមានចិត្តដឹងគុណ—ហើយព្រះអង្គផ្ទាល់គឺជាអំណរនេះ។ ជីវិតដ៏អរសប្បាយនេះគឺ៖ ការមានអំណរទៅកាន់ព្រះអង្គ ក្នុងព្រះអង្គ និងសម្រាប់ព្រះអង្គ។ គឺនេះហើយ ហើយក៏គ្មានអ្វីក្រៅពីហ្នឹងដែរ។ ប៉ុន្តែ ចំពោះអស់អ្នកដែលគិតថា មានប្រភពអំណរផ្សេងនឹងសង្វាតដេញតាមអំណរនានា ដែលមិនមែនជាអំណរដ៏ពិតនោះទេ។

៣៣. ប៉ុន្តែ តើអស់អ្នកដែលនិយាយថា ខ្លួនចង់មានជីវិតដ៏អរសប្បាយពិតជាមិនប្រាថ្នាចង់អរសប្បាយមែនឬ ពីព្រោះពួកគេមិនមានចិត្តចង់រកអំណរក្នុងព្រះអង្គ? ដ្បិតជីវិតដែលអរសប្បាយរកឃើញតែនៅក្នុងព្រះអង្គតែមួយគត់។ ឬក៏ថា ផ្ទុយទៅវិញមនុស្សគ្រប់រូបពិតជាប្រាថ្នាការនេះមែន ប៉ុន្តែគឺពីព្រោះ "សេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាម តែងតែទាស់នឹងព្រះវិញ្ញាណ" ដែលថាពួកវា "ក៏រាំងរាអ្នករាល់គ្នាមិនឲ្យធ្វើការ ដែលអ្នករាល់គ្នាចង់ធ្វើទៅកើត"[២] ដូច្នេះមនុស្សទាំងនេះធ្វើបានតែអ្វីដែលពួកគេអាចធ្វើបាន ហើយស្កប់ចិត្តតែប៉ុណ្ណឹង? ដ្បិតមនុស្សមិនចង់ធ្វើអ្វីដែលពួកគេមិនអាចធ្វើជាបន្ទាន់គ្រប់គ្រាន់ល្មមក្នុងការធ្វើឲ្យពួកគេមានលទ្ធភាពធ្វើវាឡើយ។

ឥឡូវ ទូលបង្គំសួរមនុស្សទាំងអស់ថា តើពួកគាត់ចង់មានអំណរក្នុងសេចក្ដីពិត ឬក៏ក្នុងសេចក្ដីខុសឆ្គង។ ពួកគាត់នឹងឆ្លើយតបដោយគ្មានការស្ទាក់ស្ទើរថា "ក្នុងសេចក្ដីពិត" គឺពួកគេក៏ប្រាថ្នាចង់អរសប្បាយ។ ដ្បិតជីវិតដ៏សប្បាយគឺជាអំណរក្នុងសេចក្ដីពិត។ ហើយនេះគឺជាអំណរក្នុងព្រះអង្គ ដែលជាសេចក្ដីពិត ឱព្រះជាម្ចាស់នៃពន្លឺទូលបង្គំអើយ "ព្រះអង្គជាជំនួយ និងជាព្រះនៃខ្ញុំ"។[៣] គ្រប់គ្នាប្រាថ្នាចង់បានជីវិតដ៏សប្បាយនេះ។ គ្រប់

---

២ កាឡាទី ៥:១៧។

៣ ទំនុកតម្កើង ៤២:១១។

គ្នាប្រាថ្នាចង់បានជីវិតនេះដែលជាជីវិតដ៏សប្បាយតែមួយគត់៖ អំណរក្នុងសេចក្តីពិត។

ទូលបង្គំធ្លាប់ជួបមនុស្សជាច្រើនដែលប្រាថ្នាចង់ទៅបោកប្រាស់អ្នកដទៃ ប៉ុន្តែមិនដែលជួបបុគ្គលណាចង់ប្រាថ្នាឲ្យអ្នកផ្សេងមកបោកប្រាស់គាត់ឡើយ។[៤] ដូច្នេះ តើពួកគាត់ស្គាល់អំពីជីវិតដ៏សប្បាយនេះពីកន្លែងណា លើកលែងតែពីការដែលពួកគាត់ស្គាល់ថាអ្វីជាសេចក្តីពិត? ដ្បិតពួកគាត់ក៏ស្រឡាញ់សេចក្តីពិតផងដែរ ដោយសារពួកគាត់មិនចង់ឲ្យអ្នកដទៃមកបោកប្រាស់គាត់។ ហើយពេលដែលពួកគាត់ស្រឡាញ់ជីវិតដ៏សប្បាយដែលគ្មានអ្វីក្រៅពីអំណរក្នុងសេចក្តីពិត នោះមានន័យថា ពួកគាត់ក៏ស្រឡាញ់សេចក្តីពិតដែរ។ ហើយទោះជាយ៉ាងណាក្តីក៏ពួកគាត់នឹងមិនស្រឡាញ់វាផងដែរ ប្រសិនបើមិនមានចំណេះដឹងអំពីវានៅក្នុងការចងចាំ។

អញ្ចឹង ហេតុអ្វីបានជាពួកគាត់មិនអរសប្បាយក្នុងវា? ហេតុអ្វីបានជាពួកគាត់មិនសប្បាយ? ពីព្រោះពួកគាត់ខ្វល់ខ្វាយខ្លាំងពេកជាមួយនឹងអ្វីដែលធ្វើឲ្យពួកគាត់កាន់តែវេទនា ជាជាងជាមួយនឹងអ្វីដែលធ្វើឲ្យពួកគាត់សប្បាយ។ អំពីអ្វីៗដែលពួកគាត់ចាំបានតិចណាស់។ ប៉ុន្តែ នៅមានពន្លឺបន្តិចនៅក្នុងមនុស្សយើង។ សូមអនុញ្ញាតឲ្យពួកគាត់ដើរ—សូមអនុញ្ញាតឲ្យពួកគាត់ដើរក្នុងវា បើមិនដូច្នោះទេ នោះសេចក្តីងងឹតនឹងយកឈ្នះលើពួកគេជាមិនខាន។

៣៤. ចុះហេតុអ្វីបានជាសេចក្តីពិតបង្កើតឲ្យមានភាពស្អប់ខ្ពើម ហើយហេតុអ្វីបានជាអ្នកបម្រើរបស់ព្រះអង្គដែលប្រកាសអំពីសេចក្តីពិតបានក្លាយជាសត្រូវចំពោះពួកគេដែលស្រឡាញ់ជីវិតដ៏សប្បាយដែរ ដែលជាអំណរក្នុងសេចក្តីពិត—ប្រហែលមកពីពួកគេស្រឡាញ់អ្វីផ្សេងទៀតក្រៅពីសេចក្តីពិត ហើយប្រាថ្នាថាឲ្យអ្វីដែលពួកគេស្រឡាញ់នោះជាសេចក្តីពិតទៅវិញ។ ដោយសារមនុស្សយើងមិនមានឆន្ទៈក្នុងការឲ្យគេមកបោកប្រាស់ នោះពួកគេក៏មិនមានឆន្ទៈក្នុងការទទួលស្គាល់ថា ពួកគេក៏ត្រូវបានគេបោកប្រាស់រួចស្រេចទៅហើយដែរ។ ដូច្នេះ ពួកគាត់ក៏ស្អប់សេចក្តីពិតជំនួសអ្វីដែលពួកគាត់ស្រឡាញ់ក្រៅពីសេចក្តីពិតផ្ទាល់។ ពួកគេស្រឡាញ់សេចក្តីពិតនៅពេលដែលសេចក្តីពិតឯកភាពជាមួយនឹងពួកគេ ហើយស្អប់សេចក្តីពិតនៅពេលដែលសេចក្តីពិតស្តីបន្ទោសឲ្យពួកគេ។ ហើយដោយសារពួកគាត់មិនមានឆន្ទៈក្នុងការឲ្យអ្នកដទៃមកបោកប្រាស់ ប៉ុន្តែចង់

៤ ទំនុកតម្កើង ៤២:១១។

ទៅបោកប្រាស់អ្នកដទៃវិញ នោះពួកគេស្រឡាញ់សេចក្តីពិតនៅពេលដែលសេចក្តីពិតបង្ហាញខ្លួន ហើយស្អប់សេចក្តីពិតនៅពេលដែលសេចក្តីពិតបង្ហាញថាពួកគាត់ខុស។ ដោយសារការនេះ នោះសេចក្តីពិតនឹងសងសឹកអស់អ្នកដែលមិនមានឆន្ទៈក្នុងការបើកបង្ហាញដោយបើកបង្ហាញទាស់នឹងឆន្ទៈរបស់ពួកគេ។ ប៉ុន្តែ សេចក្តីពិតក៏នឹងមិនអនុញ្ញាតឲ្យពួកគេឃើញខ្លួនដែរ។

ពិតប្រាកដណាស់ៗ៖ គំនិតរបស់មនុស្សយើងខ្វាក់ ហើយឈើយ៉ាងខ្លាំង អាក្រក់ ហើយមានអាកប្បកិរិយាមិនល្អ ដោយប្រាថ្នាចង់នៅបន្តលាក់ខ្លួន ប៉ុន្តែមិនប្រាថ្នាចង់ឲ្យមានអ្វីផ្សេងទៀតលាក់ខ្លួនពីវាឡើយ។ ហើយទោះជាយ៉ាងណាក្តី ចំណុចផ្ទុយក៏កើតឡើង—គំនិតផ្ទាល់ក៏មិនមានការលាក់បាំងពីសេចក្តីពិត ប៉ុន្តែសេចក្តីពិតមានការលាក់បាំងពីវាវិញ។ ហើយសូម្បីតែដូច្នោះមែន ទាក់ទងទៅនឹងភាពអាក្រក់ទាំងអស់របស់វា ក៏វានៅពេញចិត្តក្នុងការមានអំណរក្នុងសេចក្តីពិត ជាជាងក្នុងសេចក្តីខុសឆ្គងដោយដឹងខ្លួន។ ដូច្នេះ វានឹងអរសប្បាយបានតែក្នុងករណីពេលដែលគ្មានការឆោឆៅ ហើយវារកឃើញអំណរក្នុងសេចក្តីពិតតែមួយគត់ដែលជាប្រភពនៃសេចក្តីពិតទាំងអស់ផ្សេងទៀត។

# ២៧

# ព្រះអង្គគឺជាសេចក្ដីមេត្តាករុណា

៣៥. មើល៍! ឱព្រះអម្ចាស់អើយ! ទូលបង្គំបានស្រាវជ្រាវក្នុងការចងចាំរបស់ទូលបង្គំក្នុងច្រើនកន្លែង ដើម្បីស្វែងរកព្រះអង្គ។ ហើយក្នុងទាំងអស់នោះក៏ទូលបង្គំមិនទាន់បានរកឃើញព្រះអង្គដែរ។ ហើយទូលបង្គំក៏មិនទាន់បានរកឃើញអ្វីអំពីទ្រង់ លើកលែងតែអ្វីដែលទូលបង្គំបានទុកក្នុងការចងចាំរបស់ទូលបង្គំពីពេលវេលាដែលទូលបង្គំបានរៀនអំពីព្រះអង្គ។ ដ្បិតទីណាដែលទូលបង្គំបានរកឃើញសេចក្ដីពិត នោះទូលបង្គំក៏បានរកឃើញព្រះជាម្ចាស់នៃទូលបង្គំដែលជាសេចក្ដីពិតផ្ទាល់ដែរ។ ចាប់តាំងពីពេលដែលទូលបង្គំបានរៀនអំពីចំណុចនេះ នោះទូលបង្គំក៏មិនបានភ្លេចវាដែរ។ ដូច្នេះចាប់តាំងពីពេលដែលទូលបង្គំបានរៀនអំពីព្រះអង្គ នោះព្រះអង្គក៏បានគង់នៅក្នុងការចងចាំរបស់ទូលបង្គំ ហើយគឺនៅទីនោះឯងដែលទូលបង្គំរកឃើញព្រះអង្គនៅពេលដែលទូលបង្គំស្រែក

ហៅទ្រង់តាមរយៈការចងចាំ ហើយមានអំណរក្នុងទ្រង់។ ទាំងនេះគឺជាការអរសប្បាយដ៏បរិសុទ្ធរបស់ទូលបង្គំ ដែលព្រះអង្គបានដាក់លើទូលបង្គំក្នុងសេចក្ដីមេត្តាករុណារបស់ទ្រង់ ដោយភាពសន្ដោសនឹងភាពក្រីក្ររបស់ទូលបង្គំ។

៣៩. វេទនាហើយទូលបង្គំ! ឱព្រះអម្ចាស់អើយ! សូមអាណិតទូលបង្គំ។ ភាពទុក្ខព្រួយដ៏អាក្រក់របស់ទូលបង្គំប្រឆាំងជាមួយនឹងអំណរដ៏ល្អរបស់ទូលបង្គំ ហើយថាជ័យជម្នះនឹងធ្លាក់ទៅខាងណា នោះទូលបង្គំមិនដឹងទេ។ វេទនាហើយទូលបង្គំ! មើល៍! ទូលបង្គំមិនលាក់របួសទូលបង្គំទេ។ ព្រះអង្គជាគ្រូពេទ្យ ហើយទូលបង្គំគឺជាបុរសដែលកំពុងឈឺ ព្រះអង្គគឺជាសេចក្ដីមេត្តាករុណា ហើយទូលបង្គំត្រូវការសេចក្ដីមេត្តាករុណា។ តើជីវិតរបស់មនុស្សយើងនៅលើលោកនេះមិនមែនជាជីវិតដែលមានពេញទៅដោយទុក្ខកង្វល់មែនឬ? តើមានបុគ្គលណាដែលចង់ជួបទុក្ខលំបាក និងការល្បួងលដែរឬទេ? ព្រះអង្គបានបង្គាប់ឲ្យយើងអត់ធ្មត់នឹងទុក្ខលំបាក និងការល្បួងល ប៉ុន្តែមិនបានបង្គាប់ឲ្យយើងស្រឡាញ់ទុក្ខលំបាក និងការល្បួងលទេ។ ដ្បិតគ្មានបុគ្គលណាស្រឡាញ់អ្វីដែលគាត់កំពុងតែអត់ធ្មត់ជាមួយនោះទេ ទោះបើថាគាត់ស្រឡាញ់ការអត់ធ្មត់នោះក៏ដោយ។ ទោះជាយ៉ាងណាក្ដី សូម្បីបើថាគាត់មានអំណរក្នុងការអត់ធ្មត់ក៏ដោយ ក៏គាត់នឹងពេញចិត្តក្នុងការគ្មានអ្វីឲ្យគាត់អត់ធ្មត់ជាមួយខ្លាំងជាងដែរ។ ក្នុងការលំបាក ទូលបង្គំប្រាថ្នាចង់បានភាពចម្រុងចម្រើន ហើយក្នុងភាពចម្រុងចម្រើន ទូលបង្គំខ្លាចការលំបាក។ ដូច្នេះ តើមានចំណុចកណ្ដាលដែរឬទេ រវាងចំណុចទាំងពីរនេះ ដែលជាកន្លែងដែលមនុស្សយើងមិនមានជីវិតលំបាក? មានភាពវេទនាក្នុងភាពចម្រុងចម្រើនលើផែនដីនេះ។ មានភាពវេទនាក្នុងការភ័យខ្លាចទាក់ទងនឹងរឿងអកុសល។ មានភាពវេទនាក្នុងអំណរដែលចេះខូច។ មានភាពវេទនាក្នុងការលំបាកលើផែនដីនេះ—ភាពវេទនាទីពីរ និងទីបីដែលកើតចេញពីការប្រាថ្នាចង់មានភាពចម្រុងចម្រើន—ពីព្រោះភាពវេទនាផ្ទាល់គឺជាអ្វីដែលពិបាកក្នុងការទ្រាំទ្រ ហើយវាក៏បំផ្លាញការអត់ធ្មត់ចោលផងដែរ។ តើជីវិតរបស់មនុស្សយើងនៅលើលោកនេះមិនមែនជាជីវិតដែលមានពេញទៅដោយការរងទុក្ខឥតល្ហែមែនឬ?

៤០. សេចក្ដីសង្ឃឹមរបស់ទូលបង្គំទាំងស្រុងគឺនៅក្នុងសេចក្ដីមេត្តាករុណាដ៏ធំមហិមារបស់ព្រះអង្គ ហើយគឺនៅក្នុងតែចំណុចនោះតែមួយគត់។ សូមបញ្ជានូវអ្វីដែលទ្រង់សព្វព្រះហឫទ័យ ប៉ុន្តែសូមប្រទាននូវអ្វីដែលទ្រង់បញ្ជា។ ព្រះអង្គបានបញ្ជាឲ្យយើងមានភាព

បរិសុទ្ធខាងឯផ្លូវភេទ ហើយនៅពេលដែលទូលបង្គំដឹង ដូចដែលគេបានលើកឡើងគឺថា គ្មានបុគ្គលណាអាចមានភាពបរិសុទ្ធខាងឯផ្លូវភេទបានឡើយ លុះត្រាតែព្រះជាម្ចាស់ប្រទានដល់គាត់ នោះក៏សូម្បីតែនៅក្នុងចំណុចនេះក៏ជាប្រាជ្ញាក្នុងការដឹងថាវាជាអំណោយទានរបស់នរណាផងដែរ។ ដ្បិតតាមរយៈភាពបរិសុទ្ធខាងឯផ្លូវភេទ យើងបានជាប់ចំណង ហើយក៏ត្រូវបាននាំមកវិញជាមួយគ្នាក្នុងព្រះអង្គ ដែលថាពីមុនយើងត្រូវបានបែកខ្ញាយពីគ្នាក្នុងចំណោមមនុស្សជាច្រើន។ ដ្បិតបុគ្គលដែលស្រឡាញ់ព្រះអង្គតិចពេកគឺជាបុគ្គលដែលស្រឡាញ់ទ្រង់អមជាមួយនឹងអ្វីមួយផ្សេងទៀតដែលគាត់មិនស្រឡាញ់សម្រាប់ជាប្រយោជន៍របស់ព្រះអង្គ ឱព្រះដ៏ជាសេចក្ដីស្រឡាញ់អើយ ព្រះអង្គនៅឆេះយ៉ាងអស់កល្បជានិច្ច ហើយក៏មិនចេះឆ្អែតឆ្អន់ផងដែរ។ ឱព្រះជាម្ចាស់ដ៏ជាព្រះនៃសេចក្ដីស្រឡាញ់អើយ! សូមបញ្ឆេះដួងចិត្តទូលបង្គំដោយភ្លើង។ ព្រះអង្គបញ្ជាឲ្យមានភាពបរិសុទ្ធខាងឯផ្លូវភេទ ដូច្នេះសូមបញ្ជានូវអ្វីដែលទ្រង់សព្វព្រះហឫទ័យ ប៉ុន្តែសូមប្រទាននូវអ្វីដែលទ្រង់បញ្ជា។

៤១. ពិតណាស់! ព្រះអង្គបានបញ្ជាឲ្យទូលបង្គំរារាំងខ្លួនពី «សេចក្ដីប៉ងប្រាថ្នារបស់សាច់ឈាម សេចក្ដីប៉ងប្រាថ្នារបស់ភ្នែក និងអំនួតរបស់ជីវិត»។[១] ព្រះអង្គបានបញ្ជាទូលបង្គំឲ្យរារាំងខ្លួនពីទំនាក់ទំនងខាងឯផ្លូវភេទ ក្រៅពីចំណងអាពាហ៍ពិពាហ៍។ ហើយទាក់ទងទៅនឹងជីវិតអាពាហ៍ពិពាហ៍ផ្ទាល់ ព្រះអង្គបានផ្ដល់ជាការប្រឹក្សានូវអ្វីដែលល្អប្រសើរជាងអ្វីដែលទ្រង់អនុញ្ញាតទៅទៀត។ ហើយដោយសារព្រះអង្គគឺជាអង្គដែលបានប្រទាន នោះវាក៏បានសម្រេចដែរ—ពោលគឺសូម្បីតែតាំងពីមុនទូលបង្គំបានក្លាយជាអ្នកបម្រើព័ន្ធកិច្ចរបស់ទ្រង់ទៅទៀត។ ប៉ុន្តែ នៅមានក្នុងការចងចាំរបស់ទូលបង្គំ—ដែលប្រធានបទនោះ ទូលបង្គំបានលើកឡើងជាច្រើនលើកច្រើនសាអំពីវា—គឺរូបភាពនៃរឿងរ៉ាវដូចជាទម្លាប់របស់ទូលបង្គំបាននៅជាប់ក្នុងនោះ។ ចំណុចទាំងនោះបានរត់មកចូលក្នុងគំនិតរបស់ទូលបង្គំ នៅពេលដែលទូលបង្គំកំពុងតែភ្ញាក់ ហើយវាក៏មិនបានយកឈ្នះលើទូលបង្គំដែរ ប៉ុន្តែក្នុងការគេងវាបានរត់ចូលមក មិនមែនគ្រាន់តែដើម្បីផ្ដល់ជាភាពត្រេកត្រអាលតែប៉ុណ្ណោះទេ ប៉ុន្តែវាក៏ទទួលបានការចុះចូល ហើយការដែលស្ទើរតែសម្រេចទង្វើទាំងស្រុងផ្ទាល់តែម្ដងទៀតផង។ ពិតណាស់! គំនិតនៃរូបភាពបានយកឈ្នះដល់កម្រិតខ្លះៗ (ទាំងខាងព្រលឹង និងខាងឯសាច់ឈាមរបស់ទូលបង្គំ) គឺថាគំនិតបាន

១ ១យ៉ូហាន ២:១៦។

បញ្ចុះបញ្ចូលទូលបង្គំ ពេលដែលទូលបង្គំកំពុងតែគេងដល់ថ្នាក់ថា ចំណុចពិតនឹងមិនអាចធ្វើឡើងបាននៅពេលដែលទូលបង្គំកំពុងតែភ្ញាក់ឡើង។ ឱព្រះដ៏ជាអម្ចាស់នៃទូលបង្គំអើយ! តើពេលនោះទូលបង្គំមិនមែនជាទូលបង្គំមែនឬ? ហើយថា តើមានពេលខុសគ្នាមែនឬ រវាងពេលដែលទូលបង្គំនៅភ្ញាក់នៅឡើយ និងពេលដែលទូលបង្គំកំពុងតែឆ្លងកាត់ពីការកំពុងតែភ្ញាក់ហើយចូលទៅគេងវិញ ឬក៏ត្រឡប់ពីការគេងដោយភ្ញាក់ឡើងវិញ?

ដូច្នេះ តើអំណាចនៃការគិតគូរនៅឯណាដែលទាស់ប្រឆាំងនឹងការលើកឡើងបែបនេះពេលដែលទូលបង្គំភ្ញាក់ឡើង? ដ្បិតពេលទូលបង្គំភ្ញាក់ឡើង សូម្បីបើថាចំណុចនោះផ្ទាល់ត្រូវបានបង្ហំមកលើទូលបង្គំ នោះទូលបង្គំនឹងតយុទ្ធ! តើការគិតគូរលែងមានទៀតនៅពេលដែលយើងបិទភ្នែកមែនឬ? តើការគិតគូរបានចូលដេកជាមួយនឹងញាណខាងឯរូបកាយមែនឬ? ប៉ុន្តែ ក្នុងករណីនេះ តើវាកើតឡើងដោយរបៀបណា ពេលដែលយើងកំពុងតែគេងជារឿយៗយើងក៏តយុទ្ធផងដែរ ហើយក៏មិនបានចុះចូលនឹងការល្បួងលោមបែបនោះ? ទោះជាយ៉ាងណាក្តី ក៏យ៉ាងហោចណាស់នៅមានចំណុចខុសគ្នាប៉ុននេះ៖ ពេលដែលវាកើតឡើងក្នុងសុបិន ពេលដែលយើងភ្ញាក់ឡើង នោះសតិសម្បជញ្ញៈរបស់យើងក៏បានផ្តល់សន្តិភាពដល់យើងយ៉ាងឆាប់រហ័សដែរ។ ហើយគឺតាមរយៈចំណុចខុសគ្នាមួយនេះ (រវាងការកំពុងតែគេង និងពេលភ្ញាក់) ដែលយើងឃើញថា វាគឺមិនមែនជាយើងទេដែលបានប្រព្រឹត្តវា ខណៈពេលដែលយើងនៅមានអារម្មណ៍អាក់អន់ស្រពន់ចិត្តត្រង់ថា ក្នុងរបៀបណាមួយគឺវាបានកើតឡើងក្នុងយើង។

៤២. ឱព្រះដែលពេញទៅដោយព្រះចេស្តាអើយ! តើព្រះហស្តរបស់ទ្រង់មិនអាចព្យាបាលនូវរាល់ជំងឺនៃព្រលឹងវិញ្ញាណទូលបង្គំ តាមរយៈព្រះគុណដ៏ធំក្រៃលែងមហិមាវាស់វែងមិនបានយ៉ាងបរិបូណ៌របស់ព្រះអង្គ ក្នុងការកម្ទេចចោល សូម្បីតែទង្វើនៃភាពត្រេកត្រអាលក្នុងការគេងរបស់ទូលបង្គំមែនឬ? ឱព្រះអម្ចាស់អើយ! ទ្រង់នឹងចម្រើនអំណោយទានរបស់ទ្រង់ក្នុងទូលបង្គំបន្ថែមទៀត ដើម្បីឲ្យព្រលឹងទូលបង្គំទំនងជាទៅតាមទូលបង្គំទៅកាន់ទ្រង់ ដកខ្លួនចេញពីការជំស្អិតនៃភាពត្រេកត្រអាល ដើម្បីកុំឲ្យវានៅទាស់ប្រឆាំងជាមួយខ្លួនឯង សូម្បីតែក្នុងសុបិន។ ដើម្បីកុំឲ្យវាទាំងប្រព្រឹត្ត ឬក៏ចុះចូលក្នុងភាពពុករលួយដ៏គួរឲ្យស្អប់ខ្ពើមនេះបាន ដែលកើតឡើងតាមរយៈការឃើញរូបភាពអាសអាភាស ហើយជាលទ្ធផលក៏បានបញ្ចេញជាឧស្ម័នខាងឯសាច់ឈាម។ ដ្បិតវាមិនមែនជារឿងអស្ចារ្យទេ

សម្រាប់ព្រះដ៏ពេញទៅដោយព្រះចេស្តា ព្រះអង្គ «អាចនឹងធ្វើហួសសន្ធឹក លើសជាងអ្វីៗ ដែលយើងសូម ឬគិត» បាន។[២] ក្នុងការនាំវាឲ្យកើតឡើងដោយមិនមានឥទ្ធិពល—មិនមែនសូម្បីតែក្នុងការងក់ព្រះកេស ដើម្បីរារាំងនោះទេ—មានលទ្ធភាពក្នុងការបំពេញតាមអារម្មណ៍នៃបុគ្គលដែលបរិសុទ្ធ សូម្បីតែពេលដែលគាត់កំពុងតែគេងក៏ដោយ។ ការនេះក៏អាចកើតឡើង មិនមែនគ្រាន់តែក្នុងជីវិតនេះនោះទេ ប៉ុន្តែសូម្បីតែពេលដែលទូលបង្គំមានអាយុប៉ុណ្ណឹងក្នុងបច្ចុប្បន្នកាលនេះក៏បានដែរ។ ប៉ុន្តែ ក្នុងស្ថានភាពដែលទូលបង្គំកំពុងតែស្ថិតនៅក្នុងរបៀបដ៏អាក្រក់នេះ ក៏ទូលបង្គំលន់តួទៅកាន់ព្រះអម្ចាស់ដ៏ជាព្រះដ៏ល្អរបស់ទូលបង្គំ ដោយអំណរអមជាមួយនឹងការញាប់ញ័រក្នុងអ្វីដែលទ្រង់បានប្រទានមកកាន់ទូលបង្គំដែរ ហើយក៏បានកាន់ទុក្ខក្នុងខ្លួនឯងសម្រាប់អ្វីដែលទូលបង្គំមិនទាន់ល្អឥតខ្ចោះនៅឡើយ។ ទូលបង្គំជឿទុកចិត្តថាព្រះអង្គនឹងធ្វើឲ្យទូលបង្គំបានល្អឥតខ្ចោះក្នុងសេចក្តីមេត្តាករុណារបស់ទ្រង់ រហូតដល់ចំណុចកំពូលនៃសន្តិភាពដែលទាំងមនុស្សខាងក្នុង និងមនុស្សខាងក្រៅរបស់ទូលបង្គំនឹងមាននៅជាមួយនឹងព្រះអង្គ នៅពេលដែលសេចក្តីស្លាប់ត្រូវបានលេបទាំងមូលក្នុងជ័យជម្នះ។[៣]

៤៥. ទូលបង្គំឮព្រះសូរសៀងនៃព្រះជាម្ចាស់ទូលបង្គំកំពុងតែបញ្ជាៈ «ចូរអ្នករាល់គ្នាប្រយ័ត្នខ្លួន ក្រែងចិត្តអ្នករាល់គ្នាកំពុងតែផ្ទុកដោយសេចក្តីវក់នឹងការស៊ីផឹក»។[៤] ការផឹកស៊ីស្រវឹងគឺនៅឆ្ងាយណាស់ពីទូលបង្គំ។ សេចក្តីមេត្តាករុណារបស់ព្រះអង្គនឹងបន្តដោយមិនអនុញ្ញាតឲ្យវាមកចូលជិតទូលបង្គំ។ ប៉ុន្តែ ពេលខ្លះ «សេចក្តីវក់នឹងការស៊ីផឹក» បានលបលូនចូលមកលើអ្នកបម្រើរបស់ព្រះអង្គ។ សូមព្រះអង្គបង្ហាញសេចក្តីមេត្តាករុណាដើម្បីឲ្យវានៅឆ្ងាយពីទូលបង្គំ។ ដ្បិតគ្មានបុគ្គលណាអាចគ្រប់គ្រងលើខ្លួនឯងបាន លុះត្រាតែព្រះអង្គប្រទានឲ្យគាត់ធ្វើបាន។ ព្រះអង្គបានប្រទានមកយើងនូវអ្វីៗដែលយើងបានអធិស្ឋានជាច្រើនពីព្រះអង្គ រួមទាំងរឿងដ៏ល្អៗជាច្រើនទៀតដែលយើងបានទទួលមុនយើងបានទូលសូមតាមរយៈការអធិស្ឋានសម្រាប់វាទៅទៀត យើងបានទទួលពីព្រះអង្គ ដើម្បីឲ្យយើងទំនងជាអាចនឹងដឹងពេលក្រោយថាយើងបានទទួលវាពីព្រះអង្គ។ ទូលបង្គំមិនដែលជាមនុស្សប្រមឹកនោះទេ ប៉ុន្តែទូលបង្គំស្គាល់អ្នកប្រមឹកជាច្រើនដែលព្រះអង្គ

---

២ អេភេសូរ ៣:២០។

៣ ១កូរិនថូស ១៥:៥៤។

៤ លូកា ២១:៣៤។

បានបំផ្លាស់បំប្រែឲ្យគាត់ឈប់ផឹករហូតដល់ស្រវឹង។ ហើយព្រះអង្គជាអង្គដែលបានធ្វើព័ន្ធកិច្ចក្នុងការរារាំងមិនឲ្យមនុស្សមួយចំនួនបានក្លាយទៅជាអ្នកប្រមឹក—ហើយដូចគ្នាផងដែរ ក៏តាមរយៈព្រះអង្គដែលអស់អ្នកដែលធ្លាប់ជាអ្នកប្រមឹកក៏លែងក្លាយជាអ្នកប្រមឹកទៀត។ ហើយដូចគ្នាផងដែរ គឺពីព្រះអង្គដែលអ្នកទាំងពីរអាចនឹងដឹងថា ខ្លួនមានសភាពមកពីណា។

ទូលបង្គំក៏បានឮព្រះសូរសៀងមួយទៀតរបស់ព្រះអង្គ៖ «កុំត្រាប់តាមភាពត្រេកត្រអាលរបស់ខ្លួន ហើយរារាំងខ្លួនពីភាពអរសប្បាយចុះ»។ ហើយក៏តាមរយៈព្រះគុណរបស់ព្រះអង្គផងដែរដែលទូលបង្គំបានឮសម្រង់សម្ដីមួយនេះដែលតាមរយៈវាទូលបង្គំក៏ទទួលបានភាពកក់ក្ដៅយ៉ាងខ្លាំង៖ «បើយើងមិនបរិភោគ ក៏មិនខាតអ្វី ហើយបើយើងបរិភោគក៏មិនចំណេញអ្វីដែរ»។[៥] នេះគឺដើម្បីនិយាយថា ការបរិភោគនឹងមិនបង្កឲ្យទូលបង្គំមានជាងមុន ឬក៏ការឃាត់ខ្លួនឯងនឹងរារាំងទូលបង្គំពីភាពវេទនាឡើយ។ ទូលបង្គំក៏បានឮសំឡេងមួយទៀតថា៖ «ដ្បិតខ្ញុំបានរៀនឲ្យចេះស្កប់ចិត្តចំពោះអ្វីដែលខ្ញុំមាន។ ខ្ញុំធ្លាប់ទ្រាំក្នុងការចង្អៀតចង្អល់ ហើយក៏ធ្លាប់មានសេចក្ដីរីករាយដែរ...ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទចម្រើនកម្លាំងដល់ខ្ញុំ»។[៦] ត្រង់នេះទាហាននៃកងទ័ពស្ថានសួគ៌និយាយ មិនមែនគ្រាន់តែជាប្រភេទដីធម្មតាដូចយើងនោះទេ។ ឱព្រះអម្ចាស់អើយ! ប៉ុន្តែ សូមចងចាំថា «យើងគ្រាន់តែជាធូលីដីប៉ុណ្ណោះ»[៧] ហើយថាព្រះអង្គបានបង្កើតមនុស្សយើងចេញពីធូលីដី[៨] ហើយថាគាត់ «ក៏បាត់ទៅ តែបានឃើញវិញ»។[៩] ពិតណាស់! សាវ័កប៉ុល គាត់មិនអាចធ្វើទាំងអស់នេះតាមរយៈអំណាចរបស់គាត់ផ្ទាល់បាននោះទេ។ គាត់ក៏ត្រូវបានបង្កើតឡើងដូចដីនោះដែរ—គាត់គឺជាបុគ្គលដែលទូលបង្គំស្រឡាញ់យ៉ាងខ្លាំង ហើយគាត់ក៏បាននិយាយនូវចំណុចទាំងនេះតាមរយៈការបណ្ដាលឲ្យតែងពីព្រះជាម្ចាស់ផ្ទាល់ផងដែរ៖ «ខ្ញុំអាច» គាត់បានលើកឡើងថា «នឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទចម្រើនកម្លាំងដល់ខ្ញុំ»។ សូមប្រទានកម្លាំងដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គំអាចនឹងមានសមត្ថភាពផងដែរ។ សូមប្រទាននូវអ្វីដែលទ្រង់បញ្ជា ហើយបញ្ជានូវអ្វីដែលទ្រង់

៥ ១កូរិនថូស ៨:៨។
៦ ភីលីព ៤:១១-១៣។
៧ ទំនុកតម្កើង ១០៣:១៤។
៨ លោកុប្បត្តិ ៣:១៩។
៩ លូកា ១៥:២៤។

សព្វព្រះហឫទ័យ។ សាវ័ក ប៉ុល ប្រកាសថាគាត់បានទទួលអំណោយទាននៃព្រះគុណ ហើយពេលដែលគាត់ថ្វាយសិរីល្អ គឺគាត់ថ្វាយសិរីល្អក្នុងព្រះអម្ចាស់។ ទូលបង្គំក៏បានឮសំឡេងមួយទៀតនៃការអធិស្ឋានដែលថាឲ្យគាត់អាចនឹងទំនងជាទទួលបាន៖ «សូមដកចេញពីទូលបង្គំ» គាត់បានលើកឡើងថា «ភាពអាត្មានិយមនៃពោះ»។ ឱព្រះដ៏បរិសុទ្ធនៃទូលបង្គំអើយ! ហើយចេញពីការនេះ វាហាក់បីដូចជាថា ព្រះអង្គពិតជាបានប្រទានមែន នៅពេលដែលព្រះអង្គបង្គាប់ឲ្យអ្វីដែលត្រូវធ្វើបានសម្រេចឡើង។

៤៦. ឱព្រះវរបិតាដ៏ល្អអើយ! ព្រះអង្គបានបង្រៀនទូលបង្គំថា «គ្រប់ទាំងអស់ជាស្អាតបរិសុទ្ធ ដល់អ្នកណាដែលស្អាតបរិសុទ្ធ»[១០] ប៉ុន្តែ «ចំពោះអ្នកណាដែលបរិភោគធ្វើឲ្យអ្នកដទៃជំពប់ដួល អ្នកនោះបែរជាអាក្រក់វិញ»[១១] ហើយថា «អ្វីៗទាំងអស់ដែលព្រះបានបង្កើតមក សុទ្ធតែល្អទាំងអស់ ហើយមិនត្រូវចោលមួយណាឡើយ ឲ្យគ្រាន់តែទទួលដោយអរព្រះគុណប៉ុណ្ណោះ»។[១២] ហើយថា «មិនមែនចំណីអាហារទេដែលធ្វើឲ្យយើងខិតចូលជិតព្រះ»[១៣] ហើយក៏ «កុំឲ្យអ្នកណាម្នាក់និន្ទាអ្នករាល់គ្នា អំពីរឿងចំណីអាហារ ភេសជ្ជៈ...នោះឡើយ»។[១៤] «អ្នកដែលបរិភោគ មិនត្រូវមើលងាយអ្នកដែលមិនបរិភោគឡើយ ហើយអ្នកដែលមិនបរិភោគ ក៏មិនត្រូវថ្កោលទោសអ្នកដែលបរិភោគដែរ»។[១៥] ទូលបង្គំបានរៀនអំពីចំណុចទាំងអស់នេះ ទូលបង្គំសូមអរព្រះគុណ និងសរសើរតម្កើងដល់ព្រះអង្គ ដែលជាព្រះជាម្ចាស់ និងជាចៅហ្វាយរបស់ទូលបង្គំ។ ព្រះបន្ទូលរបស់ទ្រង់បានចូលត្រចៀកទូលបង្គំ ហើយក៏បានបើកបំភ្លឺដួងចិត្តរបស់ទូលបង្គំ។ សូមរំដោះទូលបង្គំចេញពីរាល់សេចក្តីល្បួង!

ទូលបង្គំមិនខ្លាចទេ ទាក់ទងទៅនឹងសាច់មិនស្អាត ប៉ុន្តែខ្លាចភាពមិនស្អាតនៃការស្រេកឃ្លានដែលមិនមានការគ្រប់គ្រងលើបាន។ ទូលបង្គំដឹងថា ព្រះអង្គបានអនុញ្ញាតឲ្យលោក ណូអេ បរិភោគនូវរាល់ប្រភេទសាច់ដែលល្អសម្រាប់ជាអាហារ ហើយថាហោរាអេលីយ៉ា ក៏បានបរិភោគសាច់ដែរ ហើយថាលោក យ៉ូហាន ក៏មិនបានប្រឡាក់តាមរយៈសត្វដែលមានជីវិត (នេះសំដៅទៅលើសត្វកណ្តូប) ដែលគាត់បានបរិភោគ។ ហើយ

---

១០ ទីតុស ១:១៥។
១១ រ៉ូម ១៤:២០។
១២ ១ធីម៉ូថេ ៤:៤។
១៣ ១កូរិនថូស ៨:៨។
១៤ កូឡុស ២:១៦។
១៥ រ៉ូម ១៤:៣។

ទូលបង្គំក៏ដឹងថាលោក អេសាវ ក៏បានចាញ់បោកភាពស្រេកឃ្លានរបស់គាត់ដោយសំឡក្រហម ហើយថាស្តេច ដាវីឌ ក៏បានបន្ទោសខ្លួនឯងទាក់ទងទៅនឹងការប្រាថ្នាចង់បានទឹក ហើយថាស្តេចរបស់យើងក៏ត្រូវល្បួង មិនមែនតាមរយៈសាច់នោះទេ ប៉ុន្តែតាមរយៈនំប៉័ង។ ដូច្នេះ មនុស្សម្នានៅក្នុងទីរហោស្ថានក៏ពិតជាស័ក្តិសមក្នុងការទទួលការស្តីបន្ទោសដែរ មិនមែនដោយសារពួកគេចង់បានសាច់នោះទេ ប៉ុន្តែដោយសារក្នុងការប្រាថ្នាចង់បានម្ហូប នោះពួកគេក៏បានរអ៊ូរទាំទាស់ប្រឆាំងនឹងព្រះអម្ចាស់។

៤៧. ក្នុងចំណោមសេចក្តីល្បួងទាំងអស់នេះ នោះទូលបង្គំក៏បានទាស់ប្រឆាំងជាប្រចាំថ្ងៃនឹងភាពស្រេកឃ្លាន ទាក់ទងនឹងចំណីអាហារ និងគ្រឿងផឹក។ ដ្បិតនេះមិនមែនជាប្រភេទនៃការស្រេកឃ្លានដែលទូលបង្គំមានសមត្ថភាពក្នុងការតមតែមួយដងសម្រាប់ទាំងអស់ដូចដែលទូលបង្គំអាចធ្វើបានជាមួយនឹងទង្វើនៃអំពើបាបខាងផ្លូវភេទនោះទេ។ ដាច់ខាត! ទូលបង្គំត្រូវតែទប់ភាពស្រេកឃ្លាននេះ ដោយមិនគ្រប់គ្រងលើវាខ្លាំងពេក ឬក៏ធូរពេក។ ឱព្រះអម្ចាស់អើយ! តើមានបុគ្គលណាមិនធ្លាក់ចុះក្នុងកម្រិតណាមួយលើសពីចំណងនៃភាពចាំបាច់ដែរឬទេ? ប្រសិនបើមានបុគ្គលបែបនោះមែន នោះគាត់គឺពិតជាអស្ចារ្យណាស់។ សូមអនុញ្ញាតឲ្យគាត់សរសើរតម្កើងព្រះនាមទ្រង់ចុះ។ ប៉ុន្តែ ទូលបង្គំមិនមែនជាបុគ្គលនេះនោះទេ «ដ្បិតទូលបង្គំជាមនុស្សមានបាប»។[១៦] ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំសរសើរតម្កើងព្រះនាមព្រះអង្គដែរ ដ្បិតព្រះយេស៊ូវដែល «បានឈ្នះលោកីយ៍នេះហើយ»[១៧] ក៏ទទូចអង្វរជាមួយនឹងព្រះអង្គសម្រាប់អំពើបាបរបស់ទូលបង្គំ ដាក់ទូលបង្គំក្នុងចំណោមតួលេខសមាជិកខ្សោយនៃព្រះកាយរបស់ព្រះអង្គ។ ដ្បិតព្រះនេត្ររបស់ព្រះអង្គបានទតឃើញនូវភាពមិនល្អឥតខ្ចោះក្នុងទូលបង្គំ ហើយក្នុងព្រះគម្ពីររបស់ព្រះអង្គមានសរសេរវាចុះផងដែរ។[១៨]

៦០. ឱព្រះអម្ចាស់អើយ! តាមរយៈសេចក្តីល្បួងទាំងនេះ និងការល្បងលជាប្រចាំថ្ងៃផ្សេងទៀត គឺយើងកំពុងតែទទួលការល្បងលឥតឈប់ឈរ! អណ្តាតមនុស្សគឺជា «ឡ» ប្រចាំថ្ងៃរបស់យើង។[១៩] ហើយក្នុងអត្ថន័យនេះ ក៏ព្រះអង្គបានបញ្ជាឲ្យយើងគ្រប់គ្រងលើ

---

១៦ លូកា ៥:៨។
១៧ យ៉ូហាន ១៦:៣៣។
១៨ ទំនុកតម្កើង ១៣៩:១៦។
១៩ សុភាសិត ២៧:២១។

ខ្លួនឯងផងដែរ។ សូមប្រទាននូវអ្វីដែលទ្រង់បញ្ជា ហើយបញ្ជានូវអ្វីដែលទ្រង់សព្វព្រះហឫទ័យ។ ទាក់ទងនឹងប្រធានបទនេះ ព្រះអង្គជ្រាបហើយអំពីការថ្ងូរនៃដួងចិត្ត និងទឹកភ្នែកនៃភ្នែករបស់ទូលបង្គំ ដ្បិតទូលបង្គំមិនមានសមត្ថភាពក្នុងការដឹងយ៉ាងពិតប្រាកដថា ទូលបង្គំមានភាពស្អាតស្អំដល់ដំណាក់កាលណានៃជំងឺមួយនេះ។ ហើយទូលបង្គំឈរក្នុងភាពភ័យខ្លាចដ៏ខ្លាំងនៃសេចក្ដី «ខុសឆ្គងរបស់ខ្លួន»[២០] ដែលព្រះនេត្ររបស់ព្រះអង្គទតឃើញ ទោះបើភ្នែករបស់ទូលបង្គំមើលមិនឃើញក៏ដោយ។

៦៣. «ដ្បិតទូលបង្គំជាមនុស្សក្រីក្រ ហើយទុគ៌ត»។[២១] ទោះជាយ៉ាងណាក្តី ក៏ទូលបង្គំមានស្ថានភាពល្អប្រសើរជាងនៅពេលដែលទូលបង្គំកំពុងតែថ្ងូចថ្ងូរក្នុងការលាក់បាំងពេលទូលបង្គំមិនសប្បាយចិត្តជាមួយនឹងខ្លួនឯង ហើយស្វែងរកក្តីមេត្តាករុណារបស់ព្រះអង្គទាល់តែទូលបង្គំទទួលបានជាថ្មីនូវអ្វីដែលទូលបង្គំខ្វះខាត ហើយត្រូវបានបំពេញឡើងយ៉ាងពេញទី ទាក់ទងទៅនឹងសន្តិភាពដែលមនុស្សដែលមានអំនួតតែមិនស្គាល់។ ការរាយការណ៍ដែលកើតចេញពីមាត់ និងពីទង្វើគឺជាទូទៅគេស្គាល់ជាសាធារណៈថាក្នុងពួកវាគឺជាសេចក្តីល្បួងដែលមានគ្រោះថ្នាក់យ៉ាងខ្លាំងបំផុតក្នុងការស្រឡាញ់ការសរសើរ។ ការស្រឡាញ់បែបនេះសាងសង់ភាពពេញចិត្តពិតប្រាកដមួយក្នុងភាពល្អឥតខ្ចោះរបស់ខ្លួន ហើយវានឹងចេញទៅដោយប្រមូលការសរសើរពីអ្នកដទៃបែបជាការសុំ។ វាបានមកល្បួងទូលបង្គំ សូម្បីតែពេលដែលទូលបង្គំបានស្តីបន្ទោសវាខាងក្នុងខ្លួនឯងផ្ទាល់ក៏ដោយ ហើយវាដូច្នោះ ពីព្រោះទូលបង្គំបានស្តីបន្ទោសវា។ ដ្បិតជារឿយៗ បុគ្គលម្នាក់ទំនងជាផ្តល់សិរីល្អដ៏ឥតប្រយោជន៍ក្នុងការស្តីបន្ទោសផ្ទាល់នៃសិរីល្អដ៏ឥតប្រយោជន៍មួយនោះ—ហើយក្នុងករណីនេះ វាលែងជាការស្តីបន្ទោសផ្ទាល់ដែលឥតប្រយោជន៍ ដែលគាត់កំពុងតែថ្វាយសិរីល្អទៀតហើយ ដ្បិតគាត់មិនបានស្អប់វាយ៉ាងពិតប្រាកដនោះទេពេលដែលគាត់ថ្វាយសិរីល្អដល់វានៅខាងក្នុងខ្លួន។

៦៧. តើទូលបង្គំទៅរកអ្នកណា ដើម្បីឲ្យផ្សះផ្សាទូលបង្គំជាមួយនឹងព្រះអង្គបាន? តើទូលបង្គំគួរទៅសួរពួកទេវតាមែនឬ? តើអធិស្ឋានដោយរបៀបណា? តើប្រារព្ធពិធីសាសនាដោយរបៀបណា? មានគេបានប្រាប់ទូលបង្គំថា មានមនុស្សជាច្រើនបានព្យាយាមត្រឡប់

២០ ទំនុកតម្កើង ១៩:១២។
២១ ទំនុកតម្កើង ១០៩:២២។

ទៅរកព្រះអង្គ ហើយក៏មិនមានសមត្ថភាពផ្ទាល់ក្នុងការព្យាយាមធ្វើបែបនោះ ហើយក៏បានធ្លាក់ចូលក្នុងការប្រាថ្នាចង់មានការបើកសម្ដែងចម្លែកៗ ហើយក៏ស័ក្ដិសមក្នុងការឲ្យអ្នកផ្សេងមកបោកប្រាស់ដែរ។ ក្នុងការលើកតម្កើង ពួកគេបានព្យាយាមរកព្រះអង្គក្នុងអំនួតនៃការរៀនសូត្ររបស់ខ្លួន ហើយក៏បានបោះខ្លួនចូលទៅមុខជាជាងការគក់ទ្រូងរបស់ខ្លួនទៅវិញ។[២២] ដូច្នេះ តាមរយៈការមានដួងចិត្តដូចគ្នា នោះពួកគេក៏បាននាំគ្នាចូលទៅរក «មេគ្រប់គ្រងរាជ្យលើអាកាស»[២៣] អ្នករៀបចំផែនការសម្ងាត់ និងគូកនក្នុងអំនួតរបស់ខ្លួន ដែលតាមរយៈវា ពួកគេក៏ត្រូវបានចាញ់បោកតាមរយៈអំណាចវេទមន្ដ។ ពួកគេបានស្វែងរកមនុស្សកណ្ដាល ដើម្បីឲ្យខ្លួនទំនងជាទទួលបានការសម្អាត ប៉ុន្តែមិនមានទេ។ ដ្បិតមនុស្សកណ្ដាលដែលពួកគេកំពុងស្វែងរកគឺជាអារក្ស ដែលកំពុងបំបាំងខ្លួនធ្វើជាទេវតានៃពន្លឺ។[២៤] ហើយវាក៏បានដាក់ស្នេហ៍លើសាច់ឈាមដែលពេញដោយអំនួតរបស់ពួកគេខ្លាំងជាងមុន ពីព្រោះវាមិនមានសាច់ឈាមខាងឯរូបកាយទេ។

ពួកគេអាចស្លាប់ ហើយមានអំពើបាប ឱព្រះអម្ចាស់អើយ ពួកគេកំពុងតែស្វែងរកការផ្សះផ្សាយ៉ាងក្រអឺតក្រទមជាមួយទ្រង់ ប៉ុន្តែទ្រង់មិនចេះស្លាប់ ហើយក៏គ្មានអំពើបាបដែរ។ ប៉ុន្តែ មនុស្សកណ្ដាលរវាងព្រះជាម្ចាស់ និងមនុស្សដាច់ខាត គាត់ត្រូវតែមានលក្ខណៈសម្បត្តិជាព្រះ ហើយក៏មានលក្ខណៈសម្បត្តិជាមនុស្សដែរ ប្រសិនបើមិនដូច្នោះ បើគាត់គ្រាន់តែដូចជាមនុស្ស នោះគាត់នឹងនៅឆ្ងាយពីព្រះជាម្ចាស់ ឬក៏ថាប្រសិនបើដូចតែព្រះជាម្ចាស់ នោះគាត់ក៏ទំនងជានៅឆ្ងាយពេកពីមនុស្ស ដូច្នេះមិនអាចធ្វើជាមនុស្សកណ្ដាលបានឡើយ។ មនុស្សកណ្ដាលដែលបោកបញ្ឆោតម្នាក់នោះមានចំណុចមួយដូចនឹងមនុស្សគឺថាវាមានបាប។ ក្នុងអត្ថន័យមួយទៀត វាហាក់បីដូចជាមានចំណុចមួយដូចព្រះជាម្ចាស់ដែរ ត្រង់ថាវាមិនមានសណ្ឋានក្នុងការស្លាប់ដូចសាច់ឈាម វាអាចអួតអាងថាវាមានជីវិតអមតៈ។ ប៉ុន្តែ ដោយសារ «ឈ្នួលរបស់បាប ជាសេចក្ដីស្លាប់»[២៥] នោះអ្វីដែលវាពិតជាមានដូចមនុស្សនោះគឺត្រង់ថា ជាមួយគ្នា វាត្រូវថ្កោលទោសឲ្យស្លាប់។

៦៨. ប៉ុន្តែ មនុស្សកណ្ដាលដ៏ពិតដែលព្រះអង្គ ក្នុងសេចក្ដីមេត្តាករុណាដ៏អាថ៌កំបាំង

---

២២ សូមមើល «រឿងប្រៀបធៀបអំពីអ្នកផារិស៊ី និងអ្នកទារពន្ធ» ក្នុងកណ្ឌគម្ពីរ លូកា ១៨:៩-១៤។
២៣ អេភេសូរ ២:២។
២៤ ២កូរិនថូស ១១:១៤។
២៥ រ៉ូម ៦:២៣។

របស់ទ្រង់ បានបើកសម្តែងមកកាន់ពួកអ្នកដែលបន្ទាបខ្លួន ហើយក៏បានចាត់ឲ្យមកពួកគេ ដើម្បីឲ្យថាតាមរយៈគំរូរបស់ទ្រង់ នោះពួកគេទំនងជាអាចនឹងរៀនបានការបន្ទាបខ្លួនដូច នោះដែរ—ពោលគឺ «អ្នកកណ្តាលតែមួយ រវាងព្រះនឹងមនុស្ស គឺព្រះគ្រីស្ទយេស៊ូវ ដែល ជាមនុស្ស»[២៦] បានលេចមករវាងមនុស្សមានបាបដែលទៀងនឹងស្លាប់ និងព្រះអង្គដែល ពេញទៅដោយភាពយុត្តិធម៌ដែលមានជីវិតអមតៈ។ ព្រះអង្គអាចសុគតដូចជាមនុស្ស អាចស្លាប់ដែរ។ ព្រះអង្គសុចរិតដូចជាព្រះជាម្ចាស់សុចរិតដែរ ហើយដោយសាររង្វាន់នៃ សេចក្តីសុចរិតគឺជាជីវិត និងសេចក្តីសន្តិភាព នោះតាមរយៈសេចក្តីសុចរិតដែលរួបរួមជា មួយនឹងព្រះជាម្ចាស់ នោះព្រះអង្គអាចលុបចោលសេចក្តីស្លាប់នៃមនុស្សមានបាបដែល ត្រូវបានរាប់ជាសុចរិត។ ជាការសុគតដែលទ្រង់មានព្រះហឫទ័យក្នុងការមានដូចពួកគេ ដែរ។ ដូច្នេះ ព្រះអង្គត្រូវបានបើកសម្តែងទៅកាន់មនុស្សបរិសុទ្ធនៅជំនាន់ចាស់ ដើម្បីឲ្យ ថានៅចុងបញ្ចប់ពួកគេទំនងជាអាចទទួលបានសេចក្តីសង្គ្រោះ តាមរយៈជំនឿក្នុងការរង ទុក្ខដែលនឹងកើតឡើងចំពោះទ្រង់ ដូចដែលយើងបានតាមរយៈជំនឿក្នុងការរងទុក្ខរបស់ ទ្រង់ដែលបានកើតឡើងពីអតីតកាលនេះដែរ។ ជាមនុស្សទ្រង់គឺជាមនុស្សកណ្តាល ប៉ុន្តែ ជាព្រះបន្ទូលព្រះអង្គមិនមែនជាអ្វីមួយនៅរវាងទាំងពីរឡើយ ពីព្រោះព្រះអង្គស្មើនឹងព្រះ ជាម្ចាស់ ហើយព្រះជាមួយនឹងព្រះ និងជាមួយនឹងព្រះវិញ្ញាណបរិសុទ្ធដែលជាព្រះតែមួយ។

៦៩. ឱព្រះវរបិតាដ៏ល្អអើយ! ព្រះអង្គបានស្រឡាញ់យើងយ៉ាងខ្លាំង ព្រះអង្គមិន បានសំចៃព្រះរាជបុត្រាតែមួយគត់របស់ទ្រង់ ប៉ុន្តែបានផ្តល់ទ្រង់ជូនសម្រាប់អស់អ្នក ដែលអាក្រក់![២៧] ព្រះអង្គបានស្រឡាញ់យើងយ៉ាងខ្លាំង ដែលសម្រាប់ជាប្រយោជន៍ របស់ព្រះរាជបុត្រារបស់ទ្រង់ ទ្រង់ក៏មិនបានរាប់ថាជាការប្លន់ក្នុងការមានលក្ខណៈស្មើ នឹងព្រះអង្គដែរ «...ក៏បន្ទាបអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់ រហូតដល់ទីមរណៈ គឺ ព្រះអង្គទទួលសុគតជាប់លើឈើឆ្កាងផង»។[២៨] មានតែព្រះអង្គមួយអង្គគត់ «ដែលត្រូវ គេបោះបង់ចោលនៅកណ្តាលពួកមនុស្សស្លាប់»។[២៩] មានតែព្រះអង្គមួយអង្គគត់ដែល មានអំណាចក្នុងការលះបង់ព្រះជន្មរបស់ទ្រង់ផ្ទាល់ ហើយក៏មានអំណាចក្នុងការយក

២៦ ១ធីម៉ូថេ ២:៥។
២៧ រ៉ូម ៨:៣២។
២៨ ភីលីព ២:៦-៨។
២៩ ទំនុកតម្កើង ៨៨:៥។

ជីវិតនោះវិញជាថ្មីម្ដងទៀតបាន។ ហើយសម្រាប់យើង ចំពោះព្រះអង្គ ទ្រង់បានក្លាយអ្នកមានជ័យជម្នះ និងអ្នករងគ្រោះ ហើយជាអ្នកមានជ័យជម្នះ ពីព្រោះទ្រង់ជាអ្នករងគ្រោះ។ ចំពោះព្រះអង្គ សម្រាប់យើង ទ្រង់ក៏ជាសម្ដេចសង្ឃ និងជាយញ្ញបូជា ហើយជាសម្ដេចសង្ឃ ពីព្រោះទ្រង់គឺជាយញ្ញបូជា។ ចេញពីស្ថានភាពជាទាសករ ព្រះអង្គបានយកយើងធ្វើជាកូនរបស់ទ្រង់ ពីព្រោះទ្រង់បានមកពីព្រះអង្គ ហើយក៏បានបម្រើយើងផងដែរ។ ដូច្នេះ ពិតជាត្រឹមត្រូវណាស់! ដែលទូលបង្គំបានដាក់សេចក្ដីសង្ឃឹមដោយសម្លឹងយ៉ាងខ្លាំងទៅលើព្រះអង្គ ដើម្បីឲ្យព្រះអង្គ «ប្រោសជំងឺទាំងប៉ុន្មានរបស់ឯងឲ្យបានជា»[៣០] តាមរយៈទ្រង់ដែលកំពុងតែគង់នៅឯខាងស្ដាំព្រះហស្ដរបស់ព្រះ ហើយក៏កំពុងតែទទូចអង្វរសម្រាប់យើងផងដែរ។[៣១] បើមិនដូច្នោះទេ នោះទូលបង្គំនឹងគ្មានសង្ឃឹមឡើយ។ ដ្បិតទូលបង្គំមានជំងឺយ៉ាងធ្ងន់ធ្ងរជាច្រើន ប្រាកដណាស់វាធ្ងន់ធ្ងរយ៉ាងក្រៃលែង ហើយច្រើនរាប់មិនអស់។ ប៉ុន្ដែ ថ្នាំរបស់ព្រះអង្គនៅល្អប្រសើរអស្ចារ្យខ្លាំងបំផុត។ បើមិនដូច្នោះទេ នោះយើងទំនងជានឹងគិតថា ព្រះបន្ទូលរបស់ព្រះអង្គត្រូវបានដកចេញពីការរួបរួមជាមួយនឹងមនុស្ស ហើយក៏នឹងគ្មានសង្ឃឹមដោយខ្លួនឯង ប្រសិនបើទ្រង់មិនបាន «ត្រឡប់ជាសាច់ឈាម ហើយគង់នៅក្នុងចំណោមយើង»[៣២] ទេ។

៧០. ដោយមានភាពភ័យខ្លាចតាមរយៈអំពើបាបរបស់ទូលបង្គំ និងទុក្ខវេទនាដ៏ធ្ងន់ធ្ងររបស់ទូលបង្គំ នោះទូលបង្គំក៏បានសម្រេចចិត្ត ហើយពិចារណាថា នឹងរត់គេចទៅទីរហោស្ថាន។ ប៉ុន្ដែ ព្រះអង្គបានហាមទូលបង្គំ ហើយក៏បានប្រទានកម្លាំងដល់ទូលបង្គំដោយមានព្រះបន្ទូលថា ដោយសារ «ព្រះអង្គបានសុគតជំនួសមនុស្សទាំងអស់ ដើម្បីឲ្យអស់អ្នកដែលរស់នៅ លែងរស់សម្រាប់តែខ្លួនឯងទៀត គឺរស់សម្រាប់ព្រះអង្គដែលបានសុគត» ។[៣៣] ឱព្រះអម្ចាស់អើយ! មើល៍! ទូលបង្គំផ្ទេរនូវរាល់ទុក្ខកង្វល់ទាំងអស់របស់ទូលបង្គំទៅកាន់ព្រះអង្គ ដើម្បីឲ្យទូលបង្គំទំនងជារស់នៅ ហើយ «បានឃើញការដ៏អស្ចារ្យនៅក្នុងក្រឹត្យវិន័យរបស់ព្រះអង្គ»។[៣៤] ព្រះអង្គជ្រាបអំពីអសមត្ថភាព និងជំងឺរបស់ទូលបង្គំ។ សូមបង្រៀនទូលបង្គំ ហើយព្យាបាលទូលបង្គំ។ ព្រះរាជបុត្រាតែមួយអង្គគត់របស់ព្រះ

៣០ ទំនុកតម្កើង ១០៣:៣។
៣១ រ៉ូម ៨:៣៤។
៣២ យ៉ូហាន ១:១៤។
៣៣ ២កូរិនថូស ៥:១៥។
៣៤ ទំនុកតម្កើង ១១៩:១៨។

អង្គ—ទ្រង់មាន «គ្រប់ទាំងកំណប់នៃប្រាជ្ញា និងចំណេះដឹងលាក់ទុកក្នុងព្រះអង្គ»[៣៥]—បានសង្គ្រោះទូលបង្គំតាមរយៈព្រះលោហិតរបស់ទ្រង់។ សូមកុំអនុញ្ញាតឲ្យមនុស្សមានអំនួតនិយាយអាក្រក់អំពីទូលបង្គំឡើយ ពីព្រោះតម្លៃដែលត្រូវបានបង់ថ្លៃសម្រាប់សេចក្ដីសង្គ្រោះរបស់ទូលបង្គំគឺតែងតែមាននៅក្នុងចិត្តគំនិតរបស់ទូលបង្គំ។ ដ្បិតទោះបើទូលបង្គំក្រីក្រក៏ដោយក៏ទូលបង្គំនៅប្រាថ្នាចង់មានភាពស្កប់ស្កល់ក្នុងព្រះអង្គដែរ គឺជាមួយនឹងអស់អ្នកដែលបរិភោគហើយមានការស្កប់ស្កល់៖ «អស់អ្នកដែលស្វែងរកព្រះយេហូវ៉ានឹងសរសើរតម្កើងព្រះអង្គ»។[៣៦]

៣៥ កូឡូស ២:៣។
៣៦ ទំនុកតម្កើង ២២:២៦។

# ២៨

# ការកាត់ស្រាយ កាលដើមដំបូង

១. ឱព្រះអម្ចាស់អើយ! ដោយសារព្រះអង្គគង់នៅក្នុងភាពអស់កល្បជានិច្ច តើទ្រង់មិនជ្រាបនូវអ្វីដែលទូលបង្គំកំពុងតែទូលទៅកាន់ព្រះអង្គដែរឬទេ? ឬក៏ថា តើព្រះអង្គទតឃើញក្នុងពេលវេលាដែលព្រឹត្តិការណ៍ណាមួយកើតឡើងនៅក្នុងពេលវេលានោះ? ប្រសិនបើមិនទតឃើញ ចុះហេតុអ្វីបានជាទូលបង្គំកំពុងតែរៀបរាប់រឿងទាំងអស់នេះទៅកាន់ព្រះអង្គអញ្ចឹង? ប្រាកដណាស់! មិនមែនដើម្បីឲ្យព្រះអង្គជ្រាបនោះទេ ដ្បិតព្រះអង្គបានជ្រាបរួចហើយ។ ប៉ុន្តែ ផ្ទុយទៅវិញ តាមរយៈការនេះវាអាចបណ្ដាលឲ្យទូលបង្គំកាន់តែស្រឡាញ់ព្រះអង្គ ហើយអស់អ្នកដែលកំពុងតែអានក៏កាន់តែស្រឡាញ់ព្រះអង្គដែរ ដើម្បីឲ្យទាំងអស់គ្នាអាចលើកឡើងថា៖ “ព្រះយេហូវ៉ាទ្រង់ជាធំ ក៏គួរសរសើរណាស់ ហើយគួរ

ស្វែងខ្លាចលើសជាងអស់ទាំងព្រះ»។[១] ទូលបង្គំបានលើកឡើងពីមុន ហើយទូលបង្គំនឹងលើកឡើងជាថ្មីម្ដងទៀតថា៖ «សម្រាប់សេចក្ដីស្រឡាញ់នៃសេចក្ដីស្រឡាញ់របស់ព្រះអង្គនោះទូលបង្គំធ្វើការនេះ»។ ហេតុដូច្នេះហើយ យើងក៏អធិស្ឋាន—ហើយទោះជាយ៉ាងណាក៏ដោយក៏សេចក្ដីពិតបានប្រាប់យើងថា៖ «ព្រះវរបិតារបស់អ្នករាល់គ្នាជ្រាបនូវអ្វីដែលអ្នករាល់គ្នាត្រូវការ មុនអ្នករាល់គ្នាទូលសូមព្រះអង្គទៅទៀត»។[២] ដូច្នេះ យើងលាតត្រដាងអារម្មណ៍របស់យើងនៅចំពោះព្រះអង្គ ដើម្បីឲ្យថាតាមរយៈការលន់តួនៃទុក្ខព្រួយរបស់យើងទៅកាន់ព្រះអង្គ និងសេចក្ដីមេត្តាករុណារបស់ទ្រង់មកកាន់យើង នោះព្រះអង្គនឹងយាងមករំដោះយើងទាំងស្រុង ដូចដែលទ្រង់បានចាប់ផ្ដើមធ្វើរួចហើយ។ ហើយដើម្បីឲ្យយើងទំនងជាឈប់អស់សង្ឃឹមលើខ្លួនឯង ហើយទទួលបានព្រះពរក្នុងព្រះអង្គ—ដោយសារទ្រង់បានត្រាស់ហៅឲ្យយើងមានសេចក្ដីកម្សត់ខាងវិញ្ញាណ ស្លូតត្រង់ យំសោក ស្រេកឃ្លានសេចក្ដីសុចរិត មានចិត្តមេត្តាករុណា និងមានចិត្តបរិសុទ្ធ។[៣] ហេតុដូច្នេះទូលបង្គំបានទូលទៅកាន់ព្រះអង្គនូវចំណុចជាច្រើន តាមលទ្ធភាពដែលទូលបង្គំអាចធ្វើបាន ហើយមានឆន្ទៈក្នុងការធ្វើ ដោយសារវាគឺជាព្រះហឫទ័យរបស់ព្រះអង្គពីដើមទីមកម្ល៉េះ ដែលឲ្យទូលបង្គំលន់តួទៅកាន់ទ្រង់ ឱព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់នៃទូលបង្គំអើយ—«ព្រះអង្គល្អ ព្រះហឫទ័យសប្បុរសរបស់ព្រះអង្គស្ថិតស្ថេរអស់កល្បជានិច្ច!»។[៤]

៤. ឱព្រះអម្ចាស់អើយ! សូមមានសេចក្ដីមេត្តាករុណាមកលើទូលបង្គំ ហើយព្រះសណ្ដាប់នូវសំណូមពររបស់ទូលបង្គំផង។ ដ្បិតសេចក្ដីអធិស្ឋានរបស់ទូលបង្គំគឺមិនមែនសម្រាប់អ្វីៗនៅលើផែនដីនេះនោះទេ មិនថាមាស ឬប្រាក់ និងត្បូងមានតម្លៃនោះទេ ឬក៏ខោអាវស្អាតៗ ឬក៏កិត្តិយស និងអំណាច ឬក៏ភាពអរសប្បាយខាងឯសាច់ឈាម ឬក៏សូម្បីតែភាពចាំបាច់ខាងឯរូបកាយនៃជីវិតនេះដែរ។ ដ្បិតរាល់ចំណុចទាំងនេះ «នឹងបានប្រទានមក» ចំពោះអស់អ្នកដែលស្វែងរកនគររបស់ព្រះអង្គ និងសេចក្ដីសុចរិតរបស់ទ្រង់។[៥]

សូមអនុញ្ញាតឲ្យវាជាការគាប់ចិត្តក្នុងព្រះនេត្រនៃសេចក្ដីមេត្តាករុណារបស់ព្រះអង្គត្រង់ថាទូលបង្គំអាចរកឃើញការពេញចិត្តជាមួយនឹងព្រះអង្គ ហើយថាទ្រង់នឹងបើក

១ ១របាក្សត្រ ១៦:២៥។
២ ម៉ាថាយ ៦:៨។
៣ ម៉ាថាយ ៦:៨។
៤ ទំនុកតម្កើង ១១៨:១; ១៣៦។
៥ ម៉ាថាយ ៦:៣៣។

ភ្នែកឲ្យទូលបង្គំយល់នូវចំណុចអាថ៌កំបាំងនានានៃព្រះបន្ទូលរបស់ព្រះអង្គនៅពេលដែលទូលបង្គំគោះ។ តាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង ដែលជាព្រះរាជបុត្រារបស់ទ្រង់ និងជាបុរសនៅខាងស្តាំព្រះហស្តរបស់ទ្រង់ ជាកូនមនុស្ស ទូលបង្គំសូមការនេះពីព្រះអង្គ។ ទ្រង់បានប្រទានកម្លាំងដល់ព្រះអង្គ ដើម្បីធ្វើជាមនុស្សកណ្តាលរវាងយើង និងទ្រង់។ ហើយតាមរយៈព្រះអង្គ ទ្រង់បានស្វែងរកយើងនៅពេលដែលយើងមិនបានស្វែងរកព្រះអង្គ។ ព្រះអង្គបានស្វែងរកយើង ដើម្បីឲ្យយើងទំនងជាស្វែងរកទ្រង់វិញ។ ទូលបង្គំទូលសូមអំពីចំណុចនេះ តាមរយៈព្រះបន្ទូលរបស់ទ្រង់ ដែលតាមរយៈនោះព្រះអង្គបានបង្កើតនូវរាល់គ្រប់អ្វីៗទាំងអស់ ដែលមានរួមទាំងទូលបង្គំដែរ។ ទូលបង្គំសូមអធិស្ឋានក្នុងព្រះនាមនៃព្រះរាជបុត្រាតែមួយគត់របស់ព្រះអង្គ ដែលតាមរយៈទ្រង់ ព្រះអង្គបានត្រាស់ហៅរាស្ត្រដ៏បរិសុទ្ធរបស់ព្រះអង្គឲ្យមកធ្វើជាកូនចិញ្ចឹម ដែលមានរួមទាំងទូលបង្គំដែរ។ ទូលបង្គំទូលសូមចំណុចនេះពីទ្រង់តាមរយៈព្រះអង្គដែលកំពុងគង់នៅខាងស្តាំរបស់ទ្រង់ ហើយក៏កំពុងតែទទូចអង្វរសម្រាប់យើង។ «គ្រប់ទាំងកំណប់នៃប្រាជ្ញា និងចំណេះដឹងលាក់ទុកក្នុងព្រះអង្គ»។[៦] គឺទ្រង់ហើយដែលទូលបង្គំកំពុងតែស្វែងរកក្នុងសៀវភៅរបស់ព្រះអង្គ។ លោក ម៉ូសេ បានសរសេរអំពីព្រះអង្គ។ ព្រះអង្គក៏បានប្រាប់យើងអំពីចំណុចនេះផ្ទាល់ផងដែរ។ ហើយសេចក្តីពិតក៏បានប្រាប់យើង។

៥. សូមអនុញ្ញាតឲ្យទូលបង្គំឮ ហើយយល់អំពីរបៀបនៃការដែលព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដីកាលនៅដើមដំបូង។[៧] លោក ម៉ូសេ បានសរសេរអំពីការនេះ។ គាត់បានសរសេរ ហើយក៏បានស្លាប់បាត់ទៅ ហើយឥឡូវនេះគាត់មិនបន្តនៅពីមុខយើងទៀតទេ។ ប្រសិនបើគាត់នៅ នោះទូលបង្គំនឹងចាប់គាត់ ហើយសួរគាត់ ហើយអង្វរករយ៉ាងម៉ត់ចត់ឲ្យគាត់ប្រាប់ទូលបង្គំក្នុងព្រះនាមរបស់ព្រះអង្គថា សូមបើកបង្ហាញចំណុចទាំងនេះមកកាន់ទូលបង្គំ ហើយទូលបង្គំនឹងស្តាប់ពាក្យពេចន៍របស់គាត់ដោយយកចិត្តទុកដាក់។ ប៉ុន្តែ ប្រសិនបើគាត់និយាយក្នុងភាសាហេប្រឺ នោះសំឡេងនឹងធ្លាក់លើទូលបង្គំក្នុងរបៀបដែលគ្មានប្រយោជន៍ ហើយទូលបង្គំនឹងមិនអាចយល់អ្វីបានឡើយ។ ប៉ុន្តែ

---

៦ កូឡុស ២:៣។

៧ លោកគ្រូ អហ្គូស្ទីន មានការភ្ញាក់ផ្អើលយ៉ាងខ្លាំងទាំងក្នុងចិត្ត និងគំនិតអំពីអាថ៌កំបាំងដ៏អស្ចារ្យនៃការបង្កើត និងទីបន្ទាល់អំពីវាក្នុងព្រះបន្ទូល។ ដូច្នេះហើយបានជាគាត់វិភាគជាច្រើនលើពេលវេលា និងការបង្កើតដូចដែលមាននៅក្នុងជំពូកនេះ ហើយគាត់ក៏បានត្រឡប់ទៅដំណើររឿងនេះម្តងហើយម្តងទៀតនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិក្នុងការនិពន្ធនានារបស់គាត់ផងដែរ។

ប្រសិនបើគាត់និយាយក្នុងភាសាឡាតាំង នោះទូលបង្គំនឹងយល់អំពីអ្វីដែលគាត់នឹងលើកឡើង។ ប៉ុន្តែ តើឲ្យទូលបង្គំអាចដឹងថា អ្វីដែលគាត់និយាយពិត ឬក៏មិនពិតដោយរបៀបណាទៅ? ប្រសិនបើទូលបង្គំអាចដឹងបានប៉ុននេះ ក្នុងបន្ទប់ដ៏ជ្រៅនៃគំនិតរបស់ទូលបង្គំ នោះសេចក្ដីពិតនឹងនិយាយថា «គាត់កំពុងតែនិយាយសេចក្ដីពិត» នោះទូលបង្គំនឹងអាចទុកចិត្តបាន។ បន្ទាប់មក ទូលបង្គំនឹងនិយាយទៅកាន់លោក ម៉ូសេ ដោយមានទំនុកចិត្តថា «លោកកំពុងនិយាយសេចក្ដីពិត»។[៨] ទោះជាយ៉ាងណាក៏ដោយ ដោយសារទូលបង្គំមិនអាចសួរលោក ម៉ូសេ បាន នោះទូលបង្គំនឹងអង្វរករសួរព្រះអង្គដែលជាសេចក្ដីពិត ដែលចេញពីចំណុចពេញលេញរបស់ព្រះអង្គ លោក ម៉ូសេ បាននិយាយសេចក្ដីពិត។ ឱព្រះជាម្ចាស់អើយ! ទូលបង្គំសូមអង្វរព្រះអង្គ សូមអត់ទោសអំពើបាបទូលបង្គំ ហើយដូចដែលព្រះអង្គប្រទានអំណោយទានដល់អ្នកបម្រើរបស់ទូលបង្គំក្នុងការនិយាយអំពីចំណុចទាំងនេះ សូមទ្រង់ប្រទានមកកាន់ទូលបង្គំនូវអំណោយទាននៃការឲ្យយល់អំពីវាបានផងដែរ។

៦. ចូរមើលជុំវិញ នោះអ្នកនឹងឃើញផ្ទៃមេឃ និងផែនដីយ៉ាងច្បាស់លាស់។ វាប្រកាសយ៉ាងឮៗថា ព្រះអាទិករបានបង្កើតវាមក ដ្បិតវាផ្លាស់ប្រែ និងផ្លាស់ប្ដូរ។ អ្វីដែលមាន តែមិនបានបង្កើតមក តែនៅមានជីវិត នោះវាមិនមានអ្វីក្នុងវា ដែលមិនធ្លាប់មានពីមុននោះទេ។ អត្តចរិតនៃការមានអ្វីមួយដែលមិនធ្លាប់មានពីមុនគឺជាអត្ថន័យនៃការផ្លាស់ប្រែ និងផ្លាស់ប្ដូរ។ ដូច្នេះ ផ្ទៃមេឃ និងផែនដីនិយាយយ៉ាងច្បាស់លាស់ថា ពួកវាមិនបានបង្កើតខ្លួនឯងផ្ទាល់នោះទេ៖ «យើងមានជីវិត ពីព្រោះយើងត្រូវបានបង្កើតឡើង។ យើងមិនមានជីវិតពីមុនទេ ប៉ុន្តែយើងត្រូវបានបង្កើតឡើងឲ្យមានជីវិត។ ដូច្នេះ យើងមិនអាចបង្កើតខ្លួនឯងបានឡើយ!»។ ហើយសំឡេងដែលពួកគេបាននិយាយគឺគ្រាន់តែជាវត្តមានរបស់ពួកគេដែលអាចមើលឃើញបាន។ គឺទ្រង់ហើយ ឱព្រះអម្ចាស់អើយ ដែលបានបង្កើតរបស់ទាំងនេះ។ ព្រះអង្គស្អាត ហេតុដូច្នេះពួកវាក៏ស្អាតដែរ។ ព្រះអង្គល្អ ហេតុដូច្នេះពួកវាក៏ល្អដែរ។ ព្រះអង្គមានព្រះជន្ម នោះពួកវាក៏មានជីវិតដែរ។ ប៉ុន្តែ ពួកវាមិនស្អាត ឬក៏ល្អ ឬក៏ពិតដល់កម្រិតដូចទ្រង់ទាំងស្រុងនោះទេ។ ពេលប្រៀបធៀបជាមួយនឹងព្រះអង្គ ពួកវា

---

៨ ចំពោះលោកគ្រូ អហ្គស្ទីន ការល្បងលចុងក្រោយលើសេចក្ដីពិតគឺភស្តុតាងផ្ទាល់ និងការដែលព្រះបន្ទូលគង់នៅជាប្រភពចុងក្រោយនៃសេចក្ដីពិត។

មិនស្អាត ឬក៏ល្អ ហើយពួកវាក៏គ្មានជីវិតដែរ។ យើងដឹងអំពីចំណុចទាំងនេះ ពីព្រោះព្រះអង្គបានបើកសម្ដែងឲ្យយើងឃើញវា។ ទោះជាយ៉ាងណាក៏ដោយក៏ចំណេះដឹងរបស់យើងគឺជាភាពល្ងីល្ងើនៅពេលដែលយើងយកវាទៅប្រៀបធៀបជាមួយនឹងអ្វីដែលទ្រង់បានជ្រាបរួចទៅហើយដែរ។

៧. ប៉ុន្តែ តើព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដីដោយរបៀបណាទៅ? តើព្រះអង្គបានប្រើប្រាស់ឧបករណ៍អ្វីដែលមានព្រះចេស្ដាយ៉ាងខ្លាំងដូចនោះក្នុងការដែលទ្រង់បង្កើត? ដ្បិតវាមិនមែនដូចជាពេលដែលមនុស្សយើងបង្កើតអ្វីមួយចេញពីអ្វីមួយទៀតនោះទេ យោងតាមគំនិតដែលមានក្នុងខួរក្បាលរបស់យើង។ នៅពេលដែលមនុស្សយើងបង្កើតអ្វីមួយ នោះគេដាក់នូវអ្វីដែលមានរួចស្រេចទៅហើយ ដូចជាដីឥដ្ឋ ឬក៏ថ្ម ឬក៏ឈើ ឬក៏មាស ឬក៏អ្វីមួយផ្សេងទៀតដូចនោះ (ហើយថា តើរបស់ទាំងនោះបានមកពីណា ប្រសិនបើព្រះអង្គមិនបានផ្ដត់ផ្ដង់ដល់ពួកគេ?)។ ដ្បិតព្រះអង្គបានបង្កើតសិប្បករ ហើយព្រះអង្គក៏បានបង្កើតគំនិតដែលនាំអវយវៈរបស់គាត់ឲ្យធ្វើអ្វីដែរ។ ហើយព្រះអង្គបង្កើតសារធាតុដែលគាត់ប្រើប្រាស់ ដើម្បីទៅបង្កើតអ្វីមួយផ្សេងទៀត។ ព្រះអង្គបានបង្កើតសមត្ថភាពនោះ ដែលតាមរយៈវា គាត់អាចយល់បាន។ ព្រះអង្គបានប្រទានញាណដល់រូបកាយគាត់ ដែលតាមរយៈញាណនោះ គាត់អាចទំនាក់ទំនងពីខួរក្បាលរបស់គាត់ទៅកាន់អ្វីដែលគាត់មានបំណងចង់ធ្វើ ហើយវាអាចប្រាប់មកខួរក្បាលគាត់វិញអំពីអ្វីដែលបានសម្រេចឡើង ដើម្បីឲ្យខួរក្បាលអាចប្រឹក្សាជាមួយនឹងសេចក្ដីពិតដែលគ្រប់គ្រងលើវា ដើម្បីឲ្យដឹងថាអ្វីដែលបានសម្រេចឡើងគឺត្រូវបានសម្រេចឡើងយ៉ាងល្អ ឬក៏អត់។

របស់ទាំងនោះសរសើរតម្កើងព្រះអង្គ ដែលជាព្រះអាទិកររបស់ពួកវា។ ប៉ុន្តែ តើព្រះអង្គបានបង្កើតពួកវាដោយរបៀបណា? ដោយរបៀបណា ឱព្រះជាម្ចាស់អើយ ដែលទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី? ពិតណាស់! ដ្បិតគឺមិននៅលើមេឃ ឬក៏លើផែនដីនោះទេដែលព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដី។ គឺមិននៅលើលំហអាកាស ឬក៏នៅក្នុងទឹកដែរ។ ពីព្រោះទាំងអស់នោះក៏ជាកម្មសិទ្ធិរបស់ផ្ទៃមេឃ និងផែនដីដូចគ្នា។ គឺមិនមែននៅក្នុងផែនដីទាំងមូលនេះនោះទេដែលព្រះអង្គបានបង្កើតផែនដីទាំងមូលនេះ ពីព្រោះមិនមានកន្លែងណាដែលអាចបង្កើតបាន មុនវានៅឡើយ។ ហើយព្រះអង្គក៏មិនបានកាន់អ្វីនៅក្នុងព្រះហស្ដរបស់ទ្រង់ ដើម្បីយកមកបង្កើតផ្ទៃមេឃ និងផែនដីដែរ ដ្បិតតើព្រះអង្គ

យកនូវអ្វីនោះបានមកពីណាដែលទ្រង់មិនបានបង្កើត ដើម្បីបង្កើតនូវអ្វីមួយផ្សេងទៀតពីវា? តាមពិតទៅ តើមានអ្វីផ្សេងទៀត ក្រៅពីអ្វីដែលមានរួចស្រេចទៅហើយដោយសារព្រះអង្គដែរឬទេ? ដ្បិតព្រះអង្គមានព្រះបន្ទូល នោះអ្វីៗក៏កើតមាន[៩] ហើយតាមរយៈព្រះបន្ទូលរបស់ទ្រង់ នោះព្រះអង្គបានបង្កើតរាល់គ្រប់អ្វីៗទាំងអស់។

១១. ឱព្រះជាម្ចាស់អើយ! កាលដើមដំបូងឡើយ ទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដី—តាមរយៈព្រះបន្ទូល ព្រះរាជបុត្រា អំណាចព្រះចេស្ដា ព្រះប្រាជ្ញាញាណ និងសេចក្ដីពិតរបស់ទ្រង់៖ ដែលមានបន្ទូល ហើយក៏បង្កើតយ៉ាងអស្ចារ្យ។ តើឲ្យអ្នកណាយល់បានពីចំណុចដូចនេះបាន ហើយតើអ្នកណានឹងនិយាយអំពីវា? តើអ្វីទៅដែលបានចែងចាំងពន្លឺដាក់ដួងចិត្តរបស់ទូលបង្គំដោយមិនបានធ្វើឲ្យវារបួស ដើម្បីធ្វើឲ្យទូលបង្គំញាប់ញ័រ ហើយឆេះបាត់ក្នុងពេលតែមួយ? ទូលបង្គំញាក់ញ័រ ពីព្រោះទូលបង្គំមិនដូចវាទេ។ ទូលបង្គំឆេះបាត់ ពីព្រោះទូលបង្គំដូចវា។ គឺព្រះប្រាជ្ញាញាណផ្ទាល់ដែលបានចាំងដាក់ទូលបង្គំ ដោយដកចេញនូវភាពស្រអាប់ចេញពីគំនិតរបស់ទូលបង្គំ ដែលត្រៀមខ្លួនជានិច្ចក្នុងការយកឈ្នះលើទូលបង្គំ ដើម្បីឲ្យទូលបង្គំខ្យល់គរក្នុងវា ក្នុងភាពងងឹត និងបន្ទុកនៃទារុណកម្មរបស់ទូលបង្គំ។ ដ្បិតកម្លាំងរបស់ទូលបង្គំត្រូវបានដួលរលំក្នុងតម្រូវការ ដល់ថ្នាក់ថាទូលបង្គំមិនអាចទ្រាំនឹងព្រះពររបស់ខ្លួន រហូតទាល់តែព្រះអម្ចាស់ដែលមានសេចក្ដីមេត្តាករុណាលើអំពើបាបទាំងអស់របស់ទូលបង្គំ ហើយក៏បានព្យាបាលភាពទន់ខ្សោយរបស់ទូលបង្គំដែរ។ ដ្បិតគឺព្រះអង្គហើយដែល «ជួយជីវិតឯងឲ្យរួចពីរណ្ដៅហើយយកព្រះហឫទ័យសប្បុរស និងព្រះហឫទ័យមេត្តាករុណាបំពាក់ជាមកុដដល់ឯង ព្រះអង្គប្រោសប្រទានឲ្យជីវិតឯងបានស្កប់ស្កល់ដោយរបស់ល្អ ដើម្បីឲ្យវ័យក្មេងរបស់ឯងបានកែឡើងជាថ្មីដូចសត្វឥន្ទ្រី»។[១០] ដ្បិតគឺតាមរយៈសេចក្ដីសង្ឃឹមនេះហើយដែលយើងទទួលបានការសង្គ្រោះ ហើយតាមរយៈការអត់ធ្មត់ នោះយើងបន្តរង់ចាំសេចក្ដីសន្យារបស់ទ្រង់។ ចំពោះអស់អ្នកដែលមានលទ្ធភាព សូមអនុញ្ញាតឲ្យពួកគេឮការដែលព្រះអង្គកំពុងតែមានបន្ទូលទៅកាន់គំនិតខាងក្នុងរបស់គេចុះ។ ទូលបង្គំនឹងស្រែកឡើងដោយមានទំនុកចិត្ត ដោយពឹងលើព្រះបន្ទូលដែលទ្រង់បានបណ្ដាលឲ្យតែង «ឱព្រះយេហូវ៉ាអើយ! ស្នាព្រះហស្ដរបស់

---

៩ ទំនុកតម្កើង ៣៣:៩។

១០ ទំនុកតម្កើង ១០៣:៤, ៥។

ព្រះអង្គមានច្រើនប្រការណាស់!ព្រះអង្គបានធ្វើការអស់នោះដោយព្រះប្រាជ្ញាញាណ»។[១១] ហើយព្រះប្រាជ្ញាញាណនេះឯងគឺជាដើមចម ហើយក្នុងដើមចមមួយនេះ នោះព្រះអង្គក៏បានបង្កើតផ្ទៃមេឃ និងផែនដី។

១២. ប៉ុន្តែ តើអស់អ្នកដែលមានពេញទៅដោយសណ្ឋានចាស់ខាងឯសាច់ឈាម មិននៅបន្តសួរយើងថាៈ «មុនព្រះអង្គបង្កើតផ្ទៃមេឃ និងផែនដី តើទ្រង់កំពុងធ្វើអ្វី? ដ្បិតប្រសិនបើព្រះអង្គនៅទំនេរ ចុះបើមិនធ្វើអ្វី ហេតុអ្វីបានជាព្រះអង្គមិននៅបន្តក្នុងស្ថានភាពនោះយ៉ាងអស់កល្បជានិច្ចអញ្ចឹង—ដោយមិនធ្វើអ្វី ដូចដែលទ្រង់ធ្លាប់បានធ្វើ? ប្រសិនបើមានចលនាថ្មីបានរើបម្រះឡើងនៅក្នុងព្រះអង្គ ហើយមានឆន្ទៈថ្មីក្នុងការបង្កើតរបស់សព្វសាររពើ ចុះបើអញ្ចឹងតើឲ្យវាជាភាពអស់កល្បជានិច្ចយ៉ាងដូចម្ដេចបាន ដែលក្នុងនេះទង្វើនៃឆន្ទៈបានកើតឡើងដែលមិនធ្លាប់មានពីមុនមក? ដ្បិតឆន្ទៈរបស់ព្រះជាម្ចាស់គឺមិនមែនជាអ្វីដែលត្រូវបង្កើតឡើងមកនោះទេ ប៉ុន្តែមានតាំងពីមុនការបង្កើតមកម្ល៉េះ។ ហើយការនេះពិត ពីព្រោះគ្មានអ្វីអាចកើតឡើងបាន លុះត្រាតែព្រះហឫទ័យនៃព្រះអាទិករមានមុនវាសិន។ ដូច្នេះ ព្រះហឫទ័យរបស់ព្រះជាម្ចាស់គឺទាក់ទងទៅនឹងចំណុចស្នូលនោះផ្ទាល់តែម្តង។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើមានអ្វីមួយផុសឡើងក្នុងចំណុចស្នូលរបស់ព្រះជាម្ចាស់ដែលមិនធ្លាប់មានពីមុន នោះយើងមិនអាចហៅចំណុចស្នូលមួយនោះថាពិតជាបានកើតឡើងពីអស់កល្បជានិច្ចបានឡើយ។ ប៉ុន្តែប្រសិនបើវាជាព្រះហឫទ័យដ៏នៅអស់កល្បជានិច្ចរបស់ព្រះជាម្ចាស់ត្រង់ថាឲ្យមានរបស់សព្វសាររពើទាំងអស់កើតមកមែន ចុះហេតុអ្វីបានជារបស់សព្វសាររពើទាំងនោះផ្ទាល់មិនមែនមកពីអស់កល្បជានិច្ចអញ្ចឹង?»។

១៣. ឱព្រះប្រាជ្ញានៃព្រះជាម្ចាស់ និងជាពន្លឺនៃព្រលឹងវិញ្ញាណអើយ! អស់អ្នកដែលនិយាយបែបនោះមិនទាន់យល់អំពីព្រះអង្គនៅឡើយទេ។ ពួកគេមិនទាន់យល់អំពីរបៀបដែលការទាំងអស់នោះត្រូវបានបង្កើតឡើងតាមរយៈ និងក្នុងព្រះអង្គនៅឡើយ។ ពួកគេព្យាយាមយល់អំពីអ្វីដែលនៅអស់កល្បជានិច្ច ប៉ុន្តែដួងចិត្តរបស់ពួកគេនៅហោះហើរក្នុងអតីតកាល និងក្នុងចលនានៅឯអនាគតនៃរបស់ដែលត្រូវបានបង្កើតឡើងមក ហើយក៏មិននឹងធឹងផងដែរ។ តើអ្នកណានឹងកាន់វាឲ្យនៅមួយកន្លែង ដើម្បីឲ្យវាអាចសម្រាកមួយ

---

១១ ទំនុកតម្កើង ១០៤:២៤។

ក្លែតសិនបាន? ហើយបន្ទាប់មក ក្នុងកម្រិតខ្លះៗ អាចមើលឃើញមួយភ្លែតនៃសិរីល្អនៃភាពអស់កល្បជានិច្ចដែលរបស់ទាំងនោះមាននៅជារៀងរហូតបាន? បន្ទាប់មក ប្រៀបធៀបភាពអស់កល្បជានិច្ចជាមួយនឹងដំណើរការបណ្ដោះអាសន្នដែលគ្មានអ្វីអាចនៅបាននោះពួកគេទំនងនឹងអាចឃើញថា ខ្លួនគ្មានសមត្ថភាពក្នុងការវិនិច្ឆ័យបានយ៉ាងត្រឹមត្រូវនោះទេ? ពួកគេនឹងឃើញថា ពេលវេលាដ៏សែនយូរគឺនឹងមិនក្លាយជាការយូរនោះឡើយលើកលែងតែពីព្រឹត្តិការណ៍ខុសៗគ្នាជាច្រើនដែលបានកើតឡើងក្នុងដំណើរឆ្លងកាត់ដែលមិនអាចកើតឡើងបានក្នុងពេលតែមួយឡើយ។ មួយទៀតសោត ក្នុងភាពអស់កល្បជានិច្ច គ្មានអ្វីរំលងផុតបានឡើយ ប៉ុន្តែភាពទាំងមូលមានក្នុងពេលតែមួយបាន។ ប៉ុន្តែគ្មានដំណើរការបណ្ដោះអាសន្នណាអាចកើតឡើងទាំងមូលក្នុងពេលតែមួយបានឡើយ។ ដូច្នេះ សូមអនុញ្ញាតឲ្យអស់អ្នកដែលគិតក្នុងរបៀបនេះឃើញថា ពេលវេលាទាំងមូលត្រូវបានបង្ខំឲ្យកន្លងទៅមុខតាមរយៈការដែលអនាគតមកដល់។ ហើយថា អនាគតទាំងអស់ទៅតាមអតីតកាល។ ហើយទាំងអស់ (ទាំងអតីតកាល និងអនាគតកាល) គឺត្រូវបានបង្កើតឡើង ហើយកើតចេញពីអ្វីដែលមានវត្តមានយ៉ាងអស់កល្បជានិច្ចហើយ។ តើអ្នកណានឹងកាន់ដួងចិត្តរបស់មនុស្សយើង ដើម្បីឲ្យវានៅស្ងៀម ហើយឃើញអំពីរបៀបដែលភាពអស់កល្បជានិច្ចដែលតែងតែឈរនៅស្ងៀមគឺផ្ទាល់មិនមែនជាអនាគតកាល ហើយក៏មិនមែនជាអតីតកាលដែរ ប៉ុន្តែគឺជាការបង្ហាញខ្លួនក្នុងពេលវេលាដែលជាអនាគត និងអតីតកាលបាន? តើដៃរបស់ទូលបង្គំអាចធ្វើការនេះបានដែរឬទេ? តើពាក្យពេចន៍របស់ទូលបង្គំអាចសម្រេចនូវចំណុចដ៏ពិបាកនេះបាន សូម្បីតែតាមរយៈការជជែកវែកញែកដែលគួរឲ្យស័ក្តិសមនឹងទទួលបានដែរឬទេ?

១៤. តើឲ្យទូលបង្គំឆ្លើយតបដោយរបៀបណាទៅកាន់បុគ្គលដែលសួរថា “មុនព្រះជាម្ចាស់បង្កើតផ្ទៃមេឃ និងផែនដី តើទ្រង់កំពុងធ្វើអ្វី?”។ ទូលបង្គំមិនឆ្លើយ តាមរយៈការគេចចេញពីសំណួរដ៏ជ្រាលជ្រៅនេះដោយមានការលេងសើច ដូចដែលគេធ្លាប់បានរាយការណ៍អំពីការដែលមនុស្សមួយចំនួនបានធ្វើនោះទេ៖ “ពេលនោះព្រះអង្គកំពុងតែរៀបចំស្ថាននរកសម្រាប់អស់អ្នកដែលសួរជ្រៅៗពេក”។

វាជារឿងមួយក្នុងការមានការយល់ដឹងជ្រៅជ្រះ ប៉ុន្តែគឺជារឿងមួយទៀតក្នុងការសើចចម្អកដាក់បុគ្គលដែលកំពុងសួរសំណួរ។ ហើយចំពោះទូលបង្គំ នោះទូលបង្គំនឹងមិន

ឆ្លើយដោយរបៀបនោះនោះទេ។ ទូលបង្គំចូលចិត្តចម្លើយនេះជាង «ខ្ញុំមិនដឹងអំពីអ្វីដែលខ្ញុំមិនដឹងនោះទេ»។ ចម្លើយបែបនោះនឹងមិនបណ្ដាលឲ្យបុគ្គលដែលកំពុងសួរសំណួរដ៏ជ្រៅនេះទទួលការសើចចំអក ហើយក៏នឹងមិននាំឲ្យបុគ្គលដែលឆ្លើយទទួលការសរសើរតម្កើង ទាក់ទងនឹងអ្វីដែលមិនពិតដែរ។

ផ្ទុយទៅវិញ ទូលបង្គំនឹងលើកឡើងថា ព្រះអង្គដែលជាព្រះជាម្ចាស់របស់យើងគឺជាព្រះអាទិករនៃរាល់របស់សព្វសារពើទាំងអស់។ ហើយប្រសិនបើក្នុងឃ្លា «ផ្ទៃមេឃ និងផែនដី» មានរួមបញ្ចូលនូវរាល់របស់សព្វសារពើ នោះទូលបង្គំនឹងលើកឡើងយ៉ាងមោះមុតបន្ថែមទៀតថា «មុនព្រះអង្គបង្កើតផ្ទៃមេឃ និងផែនដី ព្រះអង្គមិនបានបង្កើតអ្វីផ្សេងទៀតឡើយ។ ដ្បិតប្រសិនបើព្រះអង្គបានបង្កើត នោះតើព្រះអង្គបានបង្កើតអ្វី ក្រៅពីរបស់សព្វសារពើ?»។ ទូលបង្គំពិតជាចង់ដឹងនូវរាល់អ្វីៗដែលទូលបង្គំបានប្រាថ្នាចង់ដឹងណាស់ ដើម្បីជាប្រយោជន៍ដល់ទូលបង្គំឲ្យបានប្រាកដថាទូលបង្គំដឹងថា គ្មានរបស់សព្វសារពើណាត្រូវបានបង្កើតឡើង មុនរបស់សព្វសារពើមួយបានបង្កើតឡើងមកនោះទេ។

១៥. ប៉ុន្តែ ប្រសិនបើមានបុគ្គលណាម្នាក់ឆ្ងល់អំពីមូលហេតុដែលព្រះអង្គបានរង់ចាំក្នុងពេលវេលាដែលមិនអាចរាប់បាន មុនព្រះអង្គបង្កើតអ្វីមួយ នោះពួកគេគួរយល់ថា ខ្លួនកំពុងតែងឿងឆ្ងល់នឹងភាពរវើរវាយហើយ។ ដ្បិតតើឲ្យ «ពេលវេលាដែលមិនអាចដឹងបាននោះ» ដែលទ្រង់បានរង់ចាំក្នុងការបង្កើតអ្វីមួយកន្លងផុតបានដោយរបៀបណាក្នុងពេលវេលា ដោយសារព្រះអង្គគឺជាអង្គនិពន្ធ និងជាអង្គបង្កើតពេលវេលាទាំងអស់? តើមានពេលវេលាប្រភេទណាផ្សេងទៀតដែលព្រះអង្គមិនបានបង្កើតមែនឬ? ហើយប្រសិនបើមិនមាន តើឲ្យពេលវេលាប្រភេទនោះអាចកន្លងផុតបានទៅដោយរបៀបណាប្រសិនបើវាមិនទាន់ទាំងមាននៅឡើយផង? ដូច្នេះ ដោយសារព្រះអង្គគឺជាព្រះអាទិករនៃរាល់ពេលវេលាទាំងអស់ ប្រសិនបើមានពេលវេលាមួយណាផ្សេងទៀតមុនព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដី ចុះហេតុអ្វីបានជាមានការលើកឡើងថា ទ្រង់បានតមពីការធ្វើការ? ដ្បិតព្រះអង្គបានបង្កើតពេលវេលានោះផ្ទាល់តែម្ដង ហើយដំណាក់កាលនៃពេលវេលាមួយៗក៏មិនអាចកន្លងផុតបានមុនព្រះអង្គបង្កើតឲ្យមានពេលវេលាដែរ។ ប៉ុន្តែ ប្រសិនបើមិនមានពេលវេលាមុនការបង្កើតផ្ទៃមេឃ និងផែនដី ចុះតើឲ្យយើងសួរបែបនេះដោយរបៀបណាបានទៅ៖ «តើព្រះអង្គកំពុងធ្វើអ្វីនៅពេលនោះ?»។ ដ្បិតគ្មាន «នៅពេលនោះ»

ព្រោះគ្មានពេលវេលានៅឡើយ។

១៦. សម្រាប់ព្រះជន្មរបស់ព្រះអង្គ ទ្រង់មិនពឹងផ្អែកលើពេលវេលាទេ។ ដ្បិតប្រសិនបើព្រះអង្គត្រូវពឹងផ្អែក នោះព្រះអង្គនឹងមិនអាចមានព្រះជន្មមុនមានពេលវេលាបានឡើយ ហើយពេលវេលាក៏នឹងមានដោយគ្មានព្រះអង្គបង្កើតវាបានដែរ។ ប៉ុន្តែ ផ្ទុយទៅវិញ ក្នុងស្ថានភាពនៃការមានព្រះវត្តមានដ៏នៅអស់កល្បជានិច្ចរបស់ទ្រង់ គឺមានព្រះអង្គមុនមានពេលវេលានៃអតីតកាល ហើយទ្រង់ក៏បានបន្លាយពេលលើសហួសពេលវេលានៃអនាគតទៀតផង ដ្បិតពួកវានៅត្រូវកើតឡើងនៅឡើយ។ ហើយពេលដែលពេលវេលានៅអនាគតកាលនោះបានមកដល់ នោះវានឹងក្លាយជាអតីតកាល។ ប៉ុន្តែ “ព្រះអង្គនៅតែដដែលហើយព្រះជន្មរបស់ព្រះអង្គគ្មានទីបញ្ចប់ឡើយ”។[១២] ព្រះជន្មរបស់ព្រះអង្គមិនមកហើយក៏មិនទៅណាដែរ។ ប៉ុន្តែ ឆ្នាំរបស់យើងទៅ និងមក ដើម្បីឲ្យនិន្នាការដោយឡែកៗអាចកន្លងផុតបាន។ ព្រះជន្មទាំងអស់របស់ព្រះអង្គឈរជាមួយគ្នាហាក់បីដូចជាតែមួយដោយសារវាបន្តនៅយ៉ាងអស់កល្បជានិច្ច។ ហើយព្រះជន្មដែលកន្លងផុតរបស់ព្រះអង្គក៏មិនមានរួមទាំងព្រះជន្មដែលនឹងមកដល់ផងដែរ ពីព្រោះព្រះជន្មរបស់ព្រះអង្គមិនចេះកន្លងផុតឡើយ។ ឆ្នាំទាំងប៉ុន្មានរបស់យើងនឹងទៅនៅជាមួយព្រះអង្គ ពេលដែលវាលែងមានទៀត។ ព្រះជន្មទាំងប៉ុន្មានរបស់ព្រះអង្គគឺគ្រាន់តែជាមួយថ្ងៃ ហើយថ្ងៃរបស់ព្រះអង្គក៏មិនកើតឡើងម្តងហើយម្តងទៀតដែរ ប៉ុន្តែគឺនៅតែថ្ងៃនេះរហូត ។ “ថ្ងៃនេះ” របស់ព្រះអង្គមិនប្តូរទៅជាថ្ងៃស្អែកទេ ហើយវាក៏មិនកើតឡើងតាមថ្ងៃម្សិលមិញដែរ។ “ថ្ងៃនេះ” របស់ព្រះអង្គគឺជាភាពអស់កល្បជានិច្ច។ នេះឯងគឺជារបៀបដែលព្រះអង្គអាចមានព្រះបន្ទូលទៅកាន់ព្រះរាជបុត្រារបស់ទ្រង់ដែលមានព្រះជន្មយ៉ាងអស់កល្បជានិច្ចជាមួយនឹងព្រះអង្គថាៈ “អ្នកជាកូនរបស់យើង យើងបានបង្កើតអ្នកនៅថ្ងៃនេះ”។[១៣] ព្រះអង្គបានបង្កើតពេលទាំងអស់ ហើយមុនមានពេលនានាទាំងអស់គឺមានព្រះអង្គរួចស្រេចទៅហើយ។ ហើយ “ពេលវេលា” (ប្រសិនបើយើងអាចហៅវាថាដូច្នោះបាន) មុនមានពេលវេលាគឺមិនមែនជាពេលវេលាទេ។

១៧. ដូច្នេះ គឺមិនមានពេលវេលាទេពេលព្រះអង្គមិនទាន់បានបង្កើតអ្វីមួយ ពីព្រោះ

---

១២ ទំនុកតម្កើង ១០២:២៧។

១៣ ទំនុកតម្កើង ២:៧។

ពេលវេលាផ្ទាល់គឺជាអ្វីណាមួយដែលព្រះអង្គបានបង្កើតមក។ ហើយក៏គ្មានពេលវេលាដែលមានយ៉ាងអស់កល្បជានិច្ចជាមួយនឹងព្រះអង្គដែរ ព្រោះទ្រង់គង់នៅយ៉ាងអស់កល្បជានិច្ច។ ហើយប្រសិនបើពេលវេលាមានយ៉ាងអស់កល្បជានិច្ចមែន នោះវាលែងជាពេលវេលាទៀតហើយ។

ដ្បិតតើអ្វីទៅជាពេលវេលា? តើអ្នកណាអាចពន្យល់អំពីវាយ៉ាងងាយស្រួល និងត្រួសៗបាន? តើឲ្យអ្នកណាអាចយល់អំពីវានៅក្នុងគំនិត ហើយដាក់ចម្លើយក្នុងពាក្យពេចន៍បាន? ទោះជាយ៉ាងណាក៏ដោយក៏តើវាមិនមែនជាការពិតក្នុងការសន្ទនារបស់យើងដែលយើងនិយាយអំពីពេលវេលាដោយស្គាល់ និងមានចំណេះដឹងយ៉ាងខ្លាំងនោះមែនឬទេ? ហើយប្រាកដណាស់! យើងក៏យល់អំពីវានៅពេលដែលយើងនិយាយអំពីវាដែរ។ ហើយយើងក៏យល់អំពីការនោះនៅពេលដែលយើងឮអ្នកដទៃនិយាយអំពីវាដែរ។

បើអញ្ចឹង អ្វីទៅជាពេលវេលា? ប្រសិនបើមិនមានបុគ្គលណាសួរទូលបង្គំទេ នោះទូលបង្គំនឹងដឹងអំពីវា។ ប៉ុន្តែ ប្រសិនបើទូលបង្គំប្រាថ្នាចង់ពន្យល់អំពីវាទៅកាន់បុគ្គលដែលសួរទូលបង្គំអំពីវា នោះទូលបង្គំនឹងមិនដឹងអំពីរបៀបនៃការពណ៌នាអំពីពេលវេលានោះទេ។ ទោះជាយ៉ាងណាក៏ដោយក៏ទូលបង្គំលើកឡើងដោយមានទំនុកចិត្តដោយដឹងថា ប្រសិនបើគ្មានអ្វីបានកន្លងផុត នោះនឹងគ្មានពេលវេលាពីអតីតកាលទេ។ ហើយប្រសិនបើគ្មានអ្វីនៅបន្តកើតឡើង នោះក៏នឹងគ្មានពេលវេលានៅអនាគតដែរ។ ហើយប្រសិនបើគ្មានអ្វីទាល់តែសោះ នោះក៏នឹងគ្មានពេលវេលាបច្ចុប្បន្ននេះដែរ។

ប៉ុន្តែ បើអញ្ចឹង តើឲ្យមានពេលវេលាពីរពេលបានដោយរបៀបណាទៅ អតីតកាល និងអនាគតកាល ខណៈពេលដែលសូម្បីតែអតីតកាលក៏លែងមាន ហើយអនាគតកាលក៏មិនទាន់កើតឡើងនៅឡើយឥឡូវនេះ? ប៉ុន្តែ ប្រសិនបើបច្ចុប្បន្ននៅតែបន្តជាបច្ចុប្បន្នកាល ដោយមិនកន្លងផុតដោយក្លាយទៅជាអតីតកាល នោះប្រាកដណាស់វាមិនមែនជាពេលវេលាទេ ប៉ុន្តែជាភាពអស់កល្បជានិច្ចវិញ។ អញ្ចឹង ប្រសិនបើពេលវេលាបច្ចុប្បន្នកាលនេះ—ប្រសិនបើវាជាពេលវេលាមែន—បានកើតមាន ដើម្បីឲ្យវាអាចគ្រាន់តែក្លាយទៅជាពេលវេលានៃអតីតកាល តើឲ្យយើងអាចនិយាយថានេះ “គឺជា” បានដោយរបៀបណា ដោយសារបុព្វហេតុដែលធ្វើឲ្យវា “គឺជា” និងលែងមានទៀត? សរុបសេចក្តីទៅ តើយើងមិនអាចនិយាយដោយពិតប្រាកដថា ពេលវេលា “គឺ” គ្រាន់តែជាអ្វីដែលទំនងជា

លែងមានបានដែរឬទេ?

២៨. ព្រលឹងរបស់ទូលបង្គំឆេះឆួលយ៉ាងក្លៀវក្លាក្នុងការយល់អំពីអាថ៌កំបាំងដ៏គួរឲ្យស្មុគស្មាញនេះណាស់។ ឱព្រះអង្គដ៏ជាម្ចាស់របស់ទូលបង្គំ ឱព្រះវរបិតាដ៏ល្អអើយ! ទូលបង្គំសូមអង្វរករព្រះអង្គតាមរយៈព្រះគ្រីស្ទ សូមមេត្តាកុំបិទចំណុចទាំងនេះ ទាំងអ្វីដែលងាយស្រួល និងអ្វីដែលពិបាកពីការប្រាថ្នារបស់ទូលបង្គំឡើយ។ តើឲ្យទូលបង្គំទៅសួរអំពីចំណុចនេះពីអ្នកណា? ហើយថា តើឲ្យទូលបង្គំទៅលន់តួអំពីភាពល្ងីល្ងើអំពីវាទៅកាន់អ្នកណា ដើម្បីជាប្រយោជន៍ដ៏ធំធេង ជាងទៅកាន់ព្រះអង្គ? ចំពោះទ្រង់ ការសិក្សារបស់ទូលបង្គំមិនមែនជាការអផ្សុកទេ។ សូមប្រទាននូវអ្វីដែលទូលបង្គំស្រឡាញ់ ដ្បិតទូលបង្គំពិតជាស្រឡាញ់វាមែន។ ហើយចំណុចនេះ ព្រះអង្គបានប្រទានមកកាន់ទូលបង្គំ។ ឱព្រះវរបិតាអើយ! ទ្រង់ពិតជាជ្រាបអំពីរបៀបនៃការប្រទានអំណោយទានដ៏ល្អៗទៅកាន់បុត្រាបុត្រីរបស់ទ្រង់មែន។ សូមប្រទានអំណោយទាននេះមកកាន់ទូលបង្គំ។ សូមមេត្តាប្រទាន ដោយសារទូលបង្គំបានព្យាយាមយល់អំពីវា ហើយការខិតខំប្រឹងប្រែងដ៏លំបាកលំបិនគឺជាអ្វីដែលទូលបង្គំត្រូវធ្វើ លុះត្រាតែព្រះអង្គបើកសម្ដែងដល់ទូលបង្គំ។ ទូលបង្គំសូមអង្វរករព្រះអង្គតាមរយៈព្រះគ្រីស្ទ និងក្នុងព្រះនាមរបស់ទ្រង់ ដ៏ជាទីបរិសុទ្ធបំផុត សូមកុំអនុញ្ញាតឲ្យបុគ្គលណាមករារាំងទូលបង្គំឡើយ។ "ខ្ញុំបានជឿ ទោះជាពេលដែលខ្ញុំពោលថាៈ "ខ្ញុំមានទុក្ខព្រួយខ្លាំងណាស់""។[១៤] នេះគឺជាសេចក្ដីសង្ឃឹមរបស់ទូលបង្គំ ដ្បិតចំពោះការនេះគឺទូលបង្គំរស់នៅ៖ ដើម្បីឲ្យទូលបង្គំពិចារណាលើការអរសប្បាយរបស់ព្រះអម្ចាស់នៃទូលបង្គំ។[១៥] ព្រះអង្គបានធ្វើឲ្យអាយុកាលរបស់ទូលបង្គំចាស់ទៅៗ ហើយវាក៏បានកន្លងផុតទៅដែរ—ហើយដោយរបៀបណា នោះទូលបង្គំមិនដឹងទេ។

៣២. ឱព្រះអម្ចាស់អើយ! ហើយទូលបង្គំក៏រៀបរាប់ទៅកាន់ទ្រង់ថា ទូលបង្គំនៅបន្តមិនដឹងថា តើអ្វីទៅជាពេលវេលា។ ហើយឱព្រះអម្ចាស់អើយ! ទូលបង្គំរៀបរាប់ទៅកាន់ទ្រង់ជាថ្មីម្ដងទៀតថា ទូលបង្គំដឹងថាទូលបង្គំកំពុងតែនិយាយអំពីចំណុចទាំងអស់នេះក្នុងពេលវេលា ហើយថាទូលបង្គំក៏បាននិយាយអំពីពេលវេលាជាយូរណាស់ទៅហើយដែរ ហើយ "ភាពជាយូរណាស់នោះ" ក៏មិនយូរដែរ លើកលែងតែពេលដែលយើងវាស់

---

១៤ ទំនុកតម្កើង ១១៦:១០។

១៥ ម៉ាថាយ ២៥:២១, ២៣។

ផែងវាជាមួយនឹងរង្វាស់រយៈពេលនៃពេលវេលា។ ដូច្នេះ តើទូលបង្គំអាចដឹងអំពីចំណុចនេះបានដោយរបៀបណា ខណៈពេលដែលទូលបង្គំមិនបានដឹងថា អ្វីទៅជាពេលវេលាផង? ឬក៏ថា តើវាអាចទៅរួចបានទេដែលទូលបង្គំមិនអាចដឹងអំពីរបៀបដែលទូលបង្គំអាចលើកឡើងអំពីអ្វីដែលទូលបង្គំដឹង? គួរឲ្យអាណិតណាស់ខ្ញុំអើយ! ទូលបង្គំមិនទាំងដឹងអំពីវិសាលភាពនៃភាពល្ងីល្ងើរបស់ខ្លួនបានផង។ ឱ! ព្រះជាម្ចាស់នៃទូលបង្គំអើយ! ក្នុងព្រះវត្តមានរបស់ទ្រង់គឺទូលបង្គំមិនកុហកទេ។ ដូចដែលមានក្នុងចិត្តរបស់ទូលបង្គំ នោះទូលបង្គំក៏និយាយឡើង។ ព្រះអង្គនឹងដុតទៀនរបស់ទូលបង្គំ។ ឱ! ព្រះអម្ចាស់ដ៏ជាព្រះនៃទូលបង្គំអើយ! ព្រះអង្គនឹងបំភ្លឺសេចក្ដីងងឹតរបស់ទូលបង្គំ។[១៦]

---

១៦ ទំនុកតម្កើង ១៨:២៨។

សៀវភៅទី១២

# ៣៩

# ការបន្ទាបខ្លួនក្នុងការកាត់ស្រាយ

១. ឱព្រះអម្ចាស់អើយ! ដួងចិត្តរបស់ទូលបង្គំទទួលបានការរង្គើយ៉ាងខ្លាំង នៅពេលដែលព្រះបន្ទូលនៃព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គបានជះឥទ្ធិពលលើជីវិតដែលក្រីក្ររបស់ទូលបង្គំ។ ភាពក្រីក្រខាងឯចំណេះដឹងរបស់មនុស្សជាតិយើងអាចនិយាយបានយ៉ាងច្រើន ពីព្រោះការសួរសំណួរទាមទារឲ្យមានពាក្យពេចន៍ច្រើនជាងការស្វែងរកដំណោះស្រាយទៅទៀត។ ការទូលសុំអ្វីមួយត្រូវការប្រើពេលយូរជាងការទទួលបានអ្វីមួយនោះទៅទៀត។ ហើយដៃដែលគោះនោះមានសកម្មភាពច្រើនជាងដៃដែលទទួលយក។ ប៉ុន្តែយើងមានសេចក្តីសន្យា ហើយតើអ្នកណានឹងក្បត់វា។ “ប្រសិនបើព្រះកាន់ខាងយើង តើអ្នកណាអាចទាស់នឹងយើងបាន?”[១] “ចូរសូម នោះនឹងឲ្យមកអ្នក ចូរស្វែងរក នោះអ្នក

១ រ៉ូម ៨:៣១។

នឹងបានឃើញ ចូរគោះ នោះនឹងបើកឲ្យអ្នក។ ដ្បិតអស់អ្នកណាដែលសូម នោះនឹងបាន ទទួល អ្នកណាដែលរក នោះនឹងបានឃើញ ក៏នឹងបើកឲ្យអ្នកណាដែលគោះដែរ»។[២] ឱព្រះអម្ចាស់អើយ! ទាំងនេះគឺជាសេចក្ដីសន្យាផ្ទាល់របស់ទ្រង់។ ហើយយើងក៏មិនចាំបាច់មានការភ័យខ្លាចថា មានការបោកបញ្ឆោតខណៈពេលដែលសេចក្ដីពិតផ្ទាល់គឺជាអង្គដែលបានធ្វើការសន្យាទាំងអស់នោះ។

២. ក្នុងភាពទាបថោក អណ្ដាតទូលបង្គំក៏ប្រកាសការសរសើរតម្កើងរបស់ព្រះអង្គ ដ្បិតព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដី។ ផ្ទៃមេឃនេះដែលទូលបង្គំមើលឃើញ ហើយផែនដីនេះដែលទូលបង្គំដើរលើ។ ព្រះអង្គបានបង្កើតពួកវា។

៣. ហើយពិតណាស់ផែនដីនេះគឺមើលមិនឃើញ ហើយក៏មិនទាន់បានទទួលការរចនាឡើង ហើយក៏មានភាពទទេ ដែលមិនអាចលើកឡើងបានយ៉ាងច្បាស់លាស់ទៀតផង។ ក្រៅពីហ្នឹង លើសនោះក៏មិនមានពន្លឺដែរដោយសារមិនទាន់មានទម្រង់នៅឡើយ។ ព្រះអង្គបានបង្គាប់ឲ្យវាសរសេរថា «មានតែភាពងងឹតនៅគ្របលើជម្រៅទឹក»។[៣] តើអ្វីទៅជាភាពងងឹតលើកលែងតែអវត្តមាននៃពន្លឺ។ ដ្បិតប្រសិនបើមានពន្លឺនៅកាលនោះ តើឲ្យវានៅទីណាលើកលែងតែនៅខាងលើដោយជះពន្លឺធ្លាក់មកលើអ្វីទាំងអស់? ដូច្នេះ មិនទាន់មានពន្លឺនៅឡើយទេ។ ហេតុដូច្នេះហើយបានជាមានការលើកឡើងថាភាពងងឹត «គ្របលើ» ជម្រៅ ដោយសារភាពអវត្តមាននៃពន្លឺ។ ដូចដែលថា នៅកន្លែងដែលគ្មានសំឡេងនោះក៏មានភាពស្ងៀមស្ងាត់ដែរ។ តើអ្វីទៅជាការមានភាពស្ងាត់ស្ងៀម នៅកន្លែងណាមួយតែមិនមានសំឡេង? ឱព្រះអម្ចាស់អើយ! តើទ្រង់ធ្លាប់បានបង្រៀនព្រលឹងមួយនេះ ដែលកំពុងលន់តួទៅកាន់ទ្រង់ដែរឬទេ? ឱព្រះអម្ចាស់អើយ! តើទ្រង់មិនដែលធ្លាប់បង្រៀនអំពីចំណុចនេះមកកាន់ទូលបង្គំដែរឬទេ ដែលថា មុនព្រះអង្គបង្កើត ហើយញែករូបរាងដែលនៅទទេនោះគឺថាគ្មានអ្វីទេ៖ គ្មានពណ៌ គ្មានទ្រង់ទ្រាយ គ្មានរូបរាង និងគ្មានវិញ្ញាណ? ទោះជាយ៉ាងណាក៏ដោយក៏វាមិនមែននៅទទេទាំងស្រុងនោះដែរ។ វាគឺជារូបរាងទទេមួយប្រភេទដែលគ្មានសភាពនៅឡើយ។

៤. ដូច្នេះ តើយើងគួរហៅរូបរាងទទេនោះដោយរបៀបណា ដើម្បីឲ្យអស់អ្នកដែលមាន

---

២ ម៉ាថាយ ៧:៧-៨។

៣ លោកុប្បត្តិ ១:២។

ការយល់ដឹងតូចទាបអាចយល់វាបានដែរ លុះត្រាតែយើងប្រើប្រាស់ពាក្យណាមួយក្នុងភាសាសាមញ្ញ? ប៉ុន្តែ តើយើងអាចរកអ្វីណាផ្សេងទៀតនៅលើលោកនេះដែលមានភាពស្រដៀងគ្នានោះ ដើម្បីមកប្រៀបធៀបរូបរាងទទេទាំងស្រុង ជាជាងផែនដី និងភាពទទេនេះបាន។ ដូច្នេះ ហេតុអ្វីបានជាទូលបង្គំទំនងមិនអាចពិចារណាលើសភាពនៃរូបរាងទទេនេះ—ដែលទ្រង់បានបង្កើតឡើងដោយគ្មានសភាពនៃរូបរាង ដើម្បីបង្កើតផែនដីនេះដែលមានរូបរាង—ដូចដែលយើងអាចបង្ហាញយ៉ាងស័ក្តិសម និងត្រឹមត្រូវទៅកាន់មនុស្សម្នាតាមរយៈឃ្លានេះ «ផែនដីនេះគឺមើលមិនឃើញ ហើយក៏មិនទាន់បានទទួលការរចនា»?

៦. ឱព្រះអម្ចាស់អើយ! ប៉ុន្តែ ប្រសិនបើទូលបង្គំលើកឡើងទៅកាន់ព្រះអង្គតាមរយៈមាត់ និងប៊ិករបស់ទូលបង្គំអំពីចំណុចទាំងអស់ដែលព្រះអង្គបានបង្រៀនមកកាន់ទូលបង្គំ ទាក់ទងនឹងសារធាតុដែលមិនទាន់បានទទួលការរចនានេះ នោះជាដំបូងទូលបង្គំត្រូវតែលើកឡើងថា ពេលដែលទូលបង្គំទើបតែឮជាលើកដំបូងអំពីចំណុចដូចនោះគឺ ទូលបង្គំមិនទាន់យល់អំពីវាបាននៅឡើយទេ។ ហើយអស់អ្នកដែលបានប្រាប់ទូលបង្គំអំពីវាក៏មិនបានយល់អំពីវាដែរ។ ទូលបង្គំបានគិតអំពីវាហាក់បីដូចជាថាមានទម្រង់ខុសៗគ្នា ហើយក៏មិនអាចរាប់អស់បាន។ ដូច្នេះ ទូលបង្គំក៏មិនបានគិតអំពីវាយ៉ាងត្រឹមត្រូវបានដែរ។ ក្នុងការដែលមានចិត្តខកខាន គំនិតរបស់ទូលបង្គំធ្លាប់គិតអំពី «រូបរាង» ដ៏អាក្រក់ និងមិនល្អជាច្រើន ប៉ុន្តែវានៅតែជា «រូបរាង» ប៉ុណ្ណោះ។ ប៉ុន្តែ ទូលបង្គំនៅតែហៅវាថាគ្មានរូបរាង មិនមែនដោយសារវាមិនទាន់បានទទួលការរចនានៅឡើយនោះទេ ប៉ុន្តែដោយសារចំពោះទូលបង្គំវាមានរូបរាងបែបប្រភេទដែលគំនិតរបស់ទូលបង្គំបានគេចចេញពីវា ក្នុងលក្ខណៈយ៉ាងចម្លែក និងសម្ងាត់។ ហើយខណៈពេលដែលទូលបង្គំកំពុងសញ្ជឹងគិតអំពីចំណុចទាំងអស់នេះ នោះទូលបង្គំក៏មានការភ័ន្តច្រឡំដោយសារភាពទន់ខ្សោយរបស់មនុស្សយើង។ ហើយសូម្បីតែអ្វីដែលទូលបង្គំបានគិតថាមិនទាន់មានការរចនាជារូបរាងនៅឡើយ មិនមែនដោយសារវាមិនមានរូបរាងទាំងស្រុងនោះទេ ប៉ុន្តែគ្រាន់តែក្នុងលក្ខណៈមួយ ខណៈពេលដែលធ្វើការប្រៀបធៀបវាជាមួយនឹងរូបរាងនានាដែលស្អាតជាងប៉ុណ្ណោះ។ ដូច្នេះ ការមានហេតុផលត្រឹមត្រូវក៏បានបញ្ចុះបញ្ចូលទូលបង្គំថាទូលបង្គំគួរតែដកចេញនូវដានទាំងអស់នៃរូបរាង ប្រសិនបើទូលបង្គំប្រាថ្នាចង់យល់អំពីចំណុចនោះត្រង់ថាវាមិនមានការរចនាទាំងស្រុងនោះទេ។ ប៉ុន្តែ ទូលបង្គំមិនអាចធ្វើការ

នេះបានឡើយ។ ដ្បិតទូលបង្គំឃើញថាវាងាយស្រួលជាងក្នុងការគិតថាអ្វីដែលមិនមានរូបរាងទាល់តែសោះគឺតាមពិតទៅមិនមានជីវិតផង ជាជាងការដែលទូលបង្គំអាចគិតអំពីអ្វីណាមួយរវាងចំណុចដែលថា វាមានរូបរាង ឬក៏គ្មានទាល់តែសោះ—អ្វីមួយដែលមិនមានរូបរាង ឬក៏គ្មាន អ្វីមួយដែលមិនមានការរចនាជារូបរាង ឬក៏ស្ទើរតែថាគ្មានតែម្តង។

ប៉ុន្តែ ទូលបង្គំប្រាថ្នាចង់ដឹង មិនមែនគ្រាន់តែទាយនោះទេ។ ហើយប្រសិនបើសំឡេង និងប៊ិករបស់ទូលបង្គំរៀបរាប់ទៅកាន់ព្រះអង្គអំពីចំណងជាច្រើនដែលទ្រង់បានស្រាយសម្រាប់ទូលបង្គំអំពីសំណួរមួយនេះ នោះតើអ្នកណាក្នុងចំណោមអ្នកអានរបស់ទូលបង្គំនឹងស៊ូទ្រាំយល់អំពីការរៀបរាប់ទាំងមូលនេះបាន? ទោះជាយ៉ាងណាក៏ដោយ ទាក់ទងទៅនឹងចំណុចនេះ ក៏ដួងចិត្តរបស់ទូលបង្គំនឹងមិនឈប់ថ្វាយព្រះកិត្តិយសទៅកាន់ព្រះអង្គ ឬក៏ឈប់ច្រៀងការសរសើរតម្កើងទ្រង់ ទាក់ទងទៅនឹងចំណុចទាំងនេះដែលទូលបង្គំមិនមានលទ្ធភាពក្នុងការលើកឡើងដែរ។

៧. ដូច្នេះ ឱព្រះអម្ចាស់អើយ! គឺទ្រង់ហើយដែលមិនមែនជាអង្គដែលជាអ្វីមួយនៅកន្លែងមួយ ហើយជាអ្វីមួយផ្សេងទៀតនៅកន្លែងមួយផ្សេងទៀត ប៉ុន្តែគឺដូចបេះបិទ ដូចបេះបិទ ដូចបេះបិទ «បរិសុទ្ធ បរិសុទ្ធ បរិសុទ្ធ គឺព្រះអម្ចាស់ ជាព្រះដ៏មានព្រះចេស្តាបំផុត»។[៤] ហើយដូចដែលកាលនៅដើមដំបូងឡើយ ហើយតាមរយៈព្រះប្រាជ្ញាញាណរបស់ព្រះអង្គដែលមានពីទ្រង់ ហើយកើតពីព្រះអង្គ នោះព្រះអង្គបានបង្កើតអ្វីៗផ្សេងទៀត។ ហើយអ្វីផ្សេងនោះ ព្រះអង្គបានបង្កើតចេញពីភាពសូន្យសុង។[៥] ដ្បិតព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដី—មិនមែនចេញមកពីព្រះអង្គផ្ទាល់នោះទេ ដ្បិតបើដូច្នោះនោះពួកវានឹងមានលក្ខណៈស្មើជាមួយនឹងព្រះរាជបុត្រាតែមួយអង្គគត់របស់ទ្រង់ ដែលរស់នៅមានន័យថាក៏ស្មើនឹងទ្រង់ដែរ។ ដូច្នេះ វានឹងមិនសមហេតុផលទេក្នុងការគិតឲ្យត្រូវថាមានអ្វីមួយផ្សេងទៀតមានលក្ខណៈស្មើនឹងព្រះអង្គ ដែលមិនមែនពីព្រះអង្គ។ ប៉ុន្តែ ឱព្រះជាម្ចាស់ដ៏ជាព្រះត្រៃឯកតែមួយ និងជាព្រះត្រៃឯកដែលមានការរួបរួមគ្នាអើយ តើមានអ្វីផ្សេងទៀតក្រៅពីព្រះអង្គដែលទ្រង់ទំនងជាបង្កើតរបស់ទាំងនោះដែរឬទេ? ដូច្នេះ គឺចេញពីភាពសូន្យសុងទាំងស្រុងដែលព្រះអង្គបានបង្កើតផ្ទៃមេឃ និងផែនដី។ ដ្បិត

---

៤ វិវរណៈ ៤:៨; អេសាយ ៦:៣។

៥ ក្នុងភាសាឡាតាំងគឺ “De nihilo”។

ព្រះអង្គមានពេញទៅដោយព្រះចេស្តា និងសេចក្តីសប្បុរស ហើយក៏មានលទ្ធភាពក្នុងការបង្កើតអ្វីៗទាំងអស់ឲ្យល្អដែរ៖ សូម្បីទាំងផ្ទៃមេឃដ៏អស្ចារ្យ និងផែនដីដ៏តូចតាច។ មានព្រះអង្គ ហើយមានអ្វីផ្សេងទៀតដែលចេញពីនោះទ្រង់បានបង្កើតផ្ទៃមេឃ និងផែនដីទេ។ ព្រះអង្គបានបង្កើតទាំងពីរនេះ មួយនៅជិតព្រះអង្គ ហើយមួយទៀតមិននៅជិតអ្វីទេ។ មួយគឺមានតែព្រះអង្គមួយអង្គគត់ដែលខ្ពង់ខ្ពស់ជាង (ផ្ទៃមេឃ) ហើយមួយទៀតគ្មានអ្វីដែលទាបជាងដែរ (ផែនដី)។

៨. ប៉ុន្តែ ផែនដីនេះផ្ទាល់ដែលព្រះអង្គបានបង្កើតគឺជាសារធាតុដែលមិនទាន់មានការរចនាចេញជារូបរាងនៅឡើយ។ យើងមិនអាចមើលវាឃើញ ហើយវាក៏មិនទាន់មានការរចនាចេញជារូបរាងដែរ ហើយភាពងងឹតក៏គ្របលើភាពទទេនោះ។ ចេញពីការមិនមើលឃើញមួយនេះ និងការដែលផែនដីមិនទាន់ទទួលបានការរចនាឡើង ចេញពីការគ្មានរូបរាងនេះ ដែលស្ទើរតែគ្មានអ្វីសោះ នោះព្រះអង្គបានបង្កើតរាល់គ្រប់អ្វីៗនៃផែនដីដែលទៀងនឹងផ្លាស់ប្រែនេះឲ្យមានឡើង។

១០. ឱសេចក្តីពិត និងពន្លឺនៃដួងចិត្តរបស់ទូលបង្គំអើយ! សូមកុំអនុញ្ញាតឲ្យភាពងងឹតរបស់ទូលបង្គំនិយាយមកកាន់ទូលបង្គំឡើយ! ទូលបង្គំបានធ្លាប់ធ្លាក់ចូលក្នុងភាពងងឹតនោះ ហើយក៏បានងងឹតតាមរយៈវាដែរ។ ប៉ុន្តែ ក្នុងវា សូម្បីតែក្នុងជម្រៅដ៏ជ្រៅរបស់វា ក៏ទូលបង្គំបានចាប់ផ្តើមស្រឡាញ់ព្រះអង្គដែរ។ ទោះបើទូលបង្គំបានបង្វែរផ្លូវក៏ដោយក៏ទូលបង្គំនៅចងចាំព្រះអង្គ។ ទូលបង្គំបានឮព្រះសូរសៀងរបស់ទ្រង់ពីខាងក្រោយទូលបង្គំត្រាស់ហៅឲ្យទូលបង្គំបែរត្រឡប់ ទោះបើទូលបង្គំមិនសូវជាឮវាខ្លាំងប៉ុន្មាន ដោយសារការរអ៊ូរទាំនៃភាពច្របូកច្របល់ដែលភាពងប់ងុលរបស់ទូលបង្គំកំពុងតែបង្កើតឡើង។ ហើយមើល៍ ឥឡូវនេះទូលបង្គំក៏កំពុងតែត្រឡប់ទៅ ចេះជួយ ហើយស្រេកឃ្លានចង់បានប្រភពទឹករបស់ទ្រង់។ សូមកុំអនុញ្ញាតឲ្យនរណាមករារាំងទូលបង្គំឡើយ! ត្រង់នេះទូលបង្គំនឹងពិសា ហើយមានជីវិត។ សូមកុំអនុញ្ញាតឲ្យទូលបង្គំធ្វើជាម្ចាស់លើជីវិតខ្លួនឯងឡើយ។ ដ្បិតពេលនៅដោយឯងៗ នោះទូលបង្គំបានរស់នៅយ៉ាងអាក្រក់។ ចំពោះខ្លួនឯង ទូលបង្គំគឺជាសេចក្តីស្លាប់។ ក្នុងព្រះអង្គ ទូលបង្គំត្រូវបានប្រោសឲ្យរស់ឡើងវិញ។ សូមមានបន្ទូលមកកាន់ទូលបង្គំ។ សូមមានការសន្ទនាជាមួយនឹងទូលបង្គំ។ ទូលបង្គំបានទទួលជឿលើសៀវភៅរបស់ទ្រង់ហើយ ហើយពាក្យពេចន៍របស់វាក៏ជ្រៅជ្រះណាស់ដែរ។

១៥. ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! ទាំងនេះទូលបង្គំបានពិចារណាតាមដែលទ្រង់បានប្រទានឲ្យទូលបង្គំមានសមត្ថភាពអាចធ្វើបាន និងតាមដែលទ្រង់បានធ្វើឲ្យទូលបង្គំមានការរីករាយក្នុងការគោះ ហើយតាមដែលទ្រង់បានបើកមកកាន់ទូលបង្គំពេលទូលបង្គំគោះ។

១៧. ជម្រៅនៃការបើកសម្ដែងរបស់ព្រះអង្គគឺអស្ចារ្យណាស់។ ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! អត្ថន័យនៃផ្ទៃលើរបស់វាគឺមាននៅពីមុខយើង ដោយអញ្ជើញមនុស្សតូចតាចឲ្យយល់ ហើយជម្រៅរបស់វាក៏អស្ចារ្យណាស់ ជម្រៅរបស់វាគឺអស្ចារ្យណាស់! វាគឺជាចំណុចដ៏គួរឲ្យកោតខ្លាចណាស់ក្នុងការសម្លឹងមើលវា៖ ជាចំណុចនៃកិត្តិយស និងការញាប់ញ័រនៃសេចក្ដីស្រឡាញ់។ ទូលបង្គំស្អប់ខ្មាំងសត្រូវនៃព្រះបន្ទូលរបស់ទ្រង់យ៉ាងខ្លាំងណាស់។ ប្រសិនបើព្រះអង្គសម្លាប់ពួកវាដោយដាវមុខពីររបស់ទ្រង់ នោះពួកវានឹងលែងជាខ្មាំងសត្រូវទៀតហើយ! ដ្បិតទូលបង្គំចង់ឲ្យពួកគេស្លាប់ក្នុងខ្លួនឯង ដើម្បីឲ្យពួកគេអាចរស់នៅសម្រាប់ព្រះអង្គ។ ប៉ុន្តែ មើល៍! នៅមានមនុស្សមួយចំនួនដែលមិនរកឃើញចំណុចខុសឆ្គងក្នុងកណ្ឌគម្ពីរលោកុប្បត្តិ ប៉ុន្តែប្រាកដណាស់សរសើរតម្កើងវា។ ពួកគេនិយាយថា៖ «ព្រះវិញ្ញាណរបស់ព្រះជាម្ចាស់ដែលបានតែងចំណុចទាំងនោះតាមរយៈលោក ម៉ូសេ ដែលជាអ្នកបម្រើរបស់ទ្រង់មិនមានព្រះហឫទ័យចង់ឲ្យយើងយល់ពាក្យពេចន៍ទាំងនោះដូចនេះទេ។ ព្រះអង្គមិនសព្វព្រះហឫទ័យឲ្យលោកអ្នកយល់ដូចដែលលោកអ្នកនិយាយនោះទេ ប៉ុន្តែផ្ទុយទៅវិញឲ្យយល់ដូចយើងនិយាយ»។

២៧. ប៉ុន្តែ ទូលបង្គំគ្មានបំណងក្នុងការឈ្លោះគ្នាអំពីពាក្យពេចន៍ទេ ដ្បិតការឈ្លោះប្រកែកគ្នាគ្មានប្រយោជន៍អ្វីលើកលែងតែការបង្ខូចអ្នកស្ដាប់ប៉ុណ្ណោះ។[៦] ប៉ុន្តែ ក្រឹត្យវិន័យមានប្រយោជន៍សម្រាប់ការកែតម្រង់ ប្រសិនបើបុគ្គលណាម្នាក់ប្រើប្រាស់វាតាមផ្លូវច្បាប់៖ ដ្បិតទីបញ្ចប់នៃក្រឹត្យវិន័យ «មានសេចក្ដីស្រឡាញ់ ដែលកើតពីចិត្តស្អាត ពីមនសិការជ្រះថ្លា និងពីជំនឿដ៏ស្មោះត្រង់»។[៧] ហើយចៅហ្វាយរបស់យើងក៏ពិតជាជ្រាបអំពីចំណុចនោះដែរ ដ្បិតគឺលើបទបញ្ញត្តិទាំងពីរនេះហើយដែលទ្រង់ដាក់ក្រឹត្យវិន័យ និងពួកហោរាពីលើ។ ឱព្រះដ៏ជាម្ចាស់នៃទូលបង្គំអើយ! ព្រះអង្គគឺជាពន្លឺក្នុងកែវភ្នែករបស់ទូលបង្គំក្នុងអ្វីដែល

---

៦ ២ធីម៉ូថេ ២:១៤។

៧ ១ធីម៉ូថេ ១:៥។

មិនច្បាស់ ទូលបង្គំអះអាងអំពីចំណុចទាំងនេះ ខណៈពេលដែលទូលបង្គំកំពុងតែលន់តួយ៉ាងឆេះឆួលទៅកាន់ទ្រង់។ តើនៅមានគ្រោះថ្នាក់អ្វី ប្រសិនបើទូលបង្គំគួរកាត់ស្រាយអត្ថន័យនៃការនិពន្ធដ៏បរិសុទ្ធខុសពីរបៀបដែលអ្នកដទៃកាត់ស្រាយ? ដ្បិតមានចំណុចជាច្រើនដែលអាចនឹងយល់ចេញពីពាក្យពេចន៍ទាំងនេះ ដែលទាំងអស់ក៏ទំនងជាការពិតដែរ។ ប្រាកដណាស់! យើងទាំងអស់គ្នាដែលអានគឺកំពុងតែព្យាយាមស្វែងរក ហើយចង់យល់អំពីអ្វីដែលអ្នកនិពន្ធប្រាថ្នាចង់ឲ្យយើងយល់។ ហើយដោយសារយើងជឿថាគាត់និយាយសេចក្ដីពិត នោះយើងមិនហ៊ានសន្មតថាអ្វីដែលគាត់បានលើកឡើងគឺជាចំណុចដែលយើងស្គាល់ ឬជឿថាជាអ្វីដែលខុសឆ្គងនោះទេ។ ដូច្នេះ ដោយសារបុគ្គលគ្រប់រូបព្យាយាមយល់អ្វីដែលអ្នកនិពន្ធបានយល់ក្នុងព្រះគម្ពីរបរិសុទ្ធ នោះតើនឹងមានគ្រោះថ្នាក់អ្វីកើតឡើង ប្រសិនបើបុគ្គលណាម្នាក់យល់អំពីអ្វី ដែលទ្រង់ជាពន្លឺក្នុងគំនិតដែលនិយាយសេចក្ដីពិតទាំងអស់បើកបង្ហាញពីចំណុចពិតនោះទៅកាន់គាត់ ទោះបើថាអ្នកនិពន្ធដែលគាត់កំពុងអានមិនបានយល់អំពីចំណុចនៃទស្សនៈនៃសេចក្ដីពិតនេះ ទោះបើគាត់បានយល់សេចក្ដីពិត ប៉ុន្តែក្នុងទស្សនៈខុសគ្នា?[៨]

៣២. ទូលបង្គំឃើញថាអាចមានការមិនឯកភាពគ្នាពីរប្រភេទពេលមានអ្វីមួយទាក់ទងទៅនឹងភាសារបស់មនុស្សយើង សូម្បីតែតាមរយៈអ្នកសារព័ត៌មានដែលយើងអាចទុកចិត្តបានដែរ។ ទី១ ការមិនឯកភាពគ្នាអំពីសេចក្ដីពិតនៃអ្វីមួយដែលមានចំណែក។ ទី២ ទាក់ទងទៅនឹងការមិនឯកភាពគ្នាអំពីអត្ថន័យនៃអ្វីមួយដែលបុគ្គលម្នាក់ទៀតបានលើកឡើង។ វាគឺជារឿងរ៉ាវម្យ៉ាងទៀតក្នុងការសួរដេញដោលអំពីចំណុចពិត ឬក៏ចំណុចមិនពិតទាក់ទងទៅនឹងការដែលរបស់សព្វសារពើនេះត្រូវបានបង្កើតឡើងមក។ ទោះជាយ៉ាងណាក៏ដោយ វាក៏នៅតែជារឿងមួយទៀតក្នុងការសួរអំពីអ្វីដែលលោក ម៉ូសេ ដែលជាអ្នកបម្រើដ៏ស្មោះត្រង់អស្ចារ្យរបស់ព្រះអង្គបានប្រាថ្នាចង់ឲ្យអ្នកអាន និងអ្នកស្ដាប់យល់ចេញពីពាក្យពេចន៍ទាំងនេះ។ ទាក់ទងទៅនឹងសំណួរទី១ សូមឲ្យអស់អ្នកដែលបាននឹក

៨ នេះគឺជាមូលដ្ឋានគ្រឹះនៃចំណុចការពាររបស់លោកគ្រូ អហ្គូស្ទីន ទាក់ទងទៅនឹងការប្រៀបប្រដូច ក្នុងលក្ខណៈជាហេតុផល និងប្រយោជន៍ក្នុងការកាត់ស្រាយព្រះបន្ទូល។ គាត់មិនបានមានន័យថា មានសេចក្ដីពិតក្នុងអត្ថន័យចំៗជាច្រើនក្នុងព្រះបន្ទូលនោះទេ ប៉ុន្តែមានលក្ខណៈខុសៗគ្នាលើសេចក្ដីពិត ដែលមានបរិមាណសរុបក្នុងកម្រិតខុសៗគ្នា និងការកាត់ស្រាយលើសេចក្ដីពិត។ ចំណុចនេះបណ្ដាលឲ្យលោកគ្រូ អហ្គូស្ទីន មានមូលដ្ឋានទ្រាំទ្របែបវិជ្ជមានលើការកាត់ស្រាយខុសៗគ្នាដែលមិនគាំទ្រជាចម្បងលើចំណុចអំពីឋានៈខ្ពស់របស់ព្រះជាម្ចាស់ក្នុងនាមជាព្រះអាទិករ។ (សូមមើលបន្ថែមក្នុងការនិពន្ធរបស់លោក M. Pontet, *L'Exégèsede Saint Augustin prédicateur* (Lyons, ឆ្នាំ១៩៤៤), ជំពូកទី២ និង៣)។

ស្រមៃថាលោក ម៉ូសេ បាននិយាយអំពីចំណុចដែលមិនត្រឹមត្រូវចាកចេញពីទូលបង្គំចុះ។ ប៉ុន្តែ ឱព្រះអម្ចាស់អើយ! សូមអនុញ្ញាតឲ្យទូលបង្គំមានការរួបរួមជាមួយនឹងអស់អ្នកដែលទទួលទានចេញពីសេចក្ដីពិតរបស់ទ្រង់ក្នុងព្រះអង្គក្នុងចំណងនៃសេចក្ដីស្រឡាញ់ ហើយសូមអនុញ្ញាតឲ្យទូលបង្គំមានអំណរក្នុងទ្រង់ជាមួយនឹងពួកគេចុះ។ សូមអនុញ្ញាតឲ្យយើងចូលជាមួយគ្នាទៅកាន់ព្រះបន្ទូលនៃព្រះគម្ពីររបស់ព្រះអង្គ ហើយស្វែងយល់ដោយយកចិត្តទុកដាក់ក្នុងវានូវអត្ថន័យ តាមរយៈអត្ថន័យនៃអ្នកបម្រើរបស់ព្រះអង្គ ដែលទ្រង់បានប្រទានមកកាន់យើងតាមរយៈការនិពន្ធរបស់គាត់។

៣៣. ប៉ុន្តែ ដោយសារមាន «សេចក្ដីពិត» ខុសៗគ្នាជាច្រើនពីអ្នកកាត់ស្រាយពាក្យពេចន៍របស់លោក ម៉ូសេ (ដែលអាចមានការយល់ដឹងក្នុងរបៀបខុសៗគ្នាបាន) តើមានអ្នកណាក្នុងចំណោមយើងអាចស្វែងរកការកាត់ស្រាយតែមួយគត់ហើយធានាថាលើកឡើងថាមានតែការកាត់ស្រាយរបស់យើងតែមួយគត់ដែលអាចមានទំនុកចិត្តដូចទៅនឹងអ្វីដែលលោក ម៉ូសេ បានគិតក្នុងការឲ្យគេយល់ការនិពន្ធរបស់គាត់បាន? តើមានបុគ្គលណាម្នាក់បាននិយាយថា ខ្លួនបានរកឃើញនូវការកាត់ស្រាយដ៏ពិតដោយមានទំនុកចិត្តដូចដែលខ្លួននិយាយថាអ្វីដែលលោក ម៉ូសេ បាននិពន្ធគឺជាការពិតដែរឬទេ? ដ្បិត ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! សូមទតមើល ហើយឃើញថាទូលបង្គំគឺជាអ្នកបម្រើរបស់ព្រះអង្គ ហើយទូលបង្គំក៏បានស្បថក្នុងសៀវភៅនេះដែលជាការថ្វាយនូវការលន់តួទៅកាន់ព្រះអង្គ ហើយទូលបង្គំសូមថាតាមរយៈក្ដីមេត្តាករុណារបស់ព្រះអង្គ សូមអនុញ្ញាតឲ្យទូលបង្គំបំពេញសម្បថរបស់ទូលបង្គំទៅកាន់ព្រះអង្គដែរ។ ឥឡូវសូមមើល! តើទូលបង្គំអាចអះអាងថាលោក ម៉ូសេ មិនមានន័យអ្វីផ្សេងទៀតក្រៅពីនេះ [ឧទាហរណ៍៖ ការកាត់ស្រាយរបស់ទូលបង្គំ] ពេលគាត់បានសរសេរ «កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី» ដោយមានទំនុកចិត្តដូចដែលទូលបង្គំអាចអះអាងថា ក្នុងព្រះបន្ទូលរបស់ទ្រង់ដែលមិនចេះប្រែប្រួល ទ្រង់បានបង្កើតនូវរាល់គ្រប់អ្វីៗទាំងអស់ អ្វីដែលមិនអាចមើលឃើញ និងអ្វីដែលអាចមើលឃើញ? ទេ! ទូលបង្គំមិនអាចធ្វើដូចនេះបានទេ ពីព្រោះចំពោះទូលបង្គំវាមិនច្បាស់លាស់យ៉ាងខ្លាំងដែលថានេះគឺជាអ្វីដែលមាននៅក្នុងគំនិតរបស់លោក ម៉ូសេ នៅពេលដែលគាត់និពន្ធចំណុចទាំងអស់នេះនោះទេ ទោះបើទូលបង្គំមានភាពប្រាកដប្រជាក្នុងសេចក្ដីពិតរបស់ទ្រង់ថា

អ្វីដែលគាត់បាននិពន្ធគឺជាការពិត។ ដ្បិតនៅពេលគាត់លើកឡើងថា “កាលដើមដំបូងឡើយ” នោះគំនិតរបស់គាត់ទំនងជាបានផ្ដោតលើកាលដើមដំបូងផ្ទាល់ ហើយក៏ទំនងជាមិនប្រាថ្នាឲ្យយើងយល់ថា “ផ្ទៃមេឃ និងផែនដី” សំដៅទៅលើអ្វីដែលបានរចនាឡើង ឬក៏វត្ថុដ៏ល្អឥតខ្ចោះ មិនថាខាងឯវិញ្ញាណ ឬក៏សាច់ឈាមនោះទេ។ ប៉ុន្ដែ សំដៅទៅលើអ្វីដែលបានចាប់ផ្ដើមឡើងថ្មី ហើយក៏មិនទាន់មានរូបរាងនៅឡើយដែរ។ មិនថាជម្រើសមួយណាក៏ដោយក្នុងចំណោមជម្រើសទាំងអស់នេះដែលបានលើកឡើងក៏ទូលបង្គំអាចឃើញថា មួយណាក៏អាចជាការពិតបានដែរ។ ប៉ុន្ដែ តើគាត់ពិតជាចង់ឲ្យមានអត្ថន័យមួយណាក្នុងពាក្យពេចន៍ដែលបានលើកឡើងនេះ? នោះទូលបង្គំមិនអាចឃើញយ៉ាងច្បាស់លាស់បាននោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ មិនថាចំណុចមួយនោះ ឬក៏អត្ថន័យមួយណាផ្សេងទៀតដែលទូលបង្គំមិនទាន់បានលើកឡើងដែលគាត់បានឃើញក្នុងគំនិតរបស់គាត់នៅពេលដែលគាត់ប្រើប្រាស់ពាក្យពេចន៍ទាំងនោះ នោះក៏ទូលបង្គំមិនមានមន្ទិលសង្ស័យអ្វីទាក់ទងទៅនឹងចំណុចដែលគាត់ពិតជាបានឃើញហើយក៏បានលើកឡើងយ៉ាងសមរម្យផងដែរ។

៣៤. ឥឡូវនេះ សូមកុំអនុញ្ញាតឲ្យអ្នកណាម្នាក់មករំខានទូលបង្គំដោយនិយាយថា “លោក ម៉ូសេ មិនបានមានអត្ថន័យដូចអ្វីដែលលោកនិយាយនោះទេ ប៉ុន្ដែអ្វីដែលខ្ញុំនិយាយ”។ ឥឡូវ ប្រសិនបើគាត់សួរខ្ញុំ “តើលោកដឹងថាលោក ម៉ូសេ មានអត្ថន័យអ្វីដោយរបៀបណា យោងតាមសេចក្ដីសន្និដ្ឋានចេញពីពាក្យពេចន៍របស់គាត់?” នោះទូលបង្គំត្រូវតែឆ្លើយតបយ៉ាងស្ងប់ស្ងាត់ ហើយលើកឡើងដូចដែលទូលបង្គំបានលើកឡើង ឬក៏ថាក្បោះក្បាយជាងនេះទៅទៀតប្រសិនបើគាត់មិនបានទទួលការបង្ហាត់បង្រៀន។ ប៉ុន្ដែពេលគាត់លើកឡើងថា “លោក ម៉ូសេ មិនបានមានអត្ថន័យដូចអ្វីដែលលោកនិយាយនោះទេ ប៉ុន្ដែអ្វីដែលខ្ញុំនិយាយ” ហើយបន្ទាប់មកមិនបដិសេធនូវអ្វីដែលយើងទាំងពីរបានលើកឡើង ប៉ុន្ដែអនុញ្ញាតឲ្យទាំងពីរជាសេចក្ដីពិតបាន—ឱព្រះជាម្ចាស់នៃទូលបង្គំអើយ! ទ្រង់ជាប្រភពជីវិតសម្រាប់អ្នកទាបថោក ក្នុងព្រះចិន្ដារបស់ទ្រង់ក៏គ្មានការប្រឆាំងគ្នា នោះសូមព្រះអង្គដាក់ថ្នាំលាបដែលធ្វើឲ្យដួងចិត្ដរបស់ទូលបង្គំធូរស្បើយ ដើម្បីធ្វើឲ្យទូលបង្គំអាចទ្រាំទ្រឲ្យមានការអត់ធ្មត់ជាមួយនឹងអស់អ្នកដែលនិយាយបែបនោះ! ពួកគាត់មិនមែននិយាយនូវអ្វីដែលពួកគាត់បាននិយាយដោយសារពួកគាត់ជាមនុស្សដែលកោត

ខ្លាចព្រះអង្គ ហើយបានឃើញក្នុងដួងចិត្តនៃអ្នកបម្រើរបស់ទ្រង់នោះទេ។ ប៉ុន្តែ ផ្ទុយទៅវិញ ពួកគាត់គឺជាមនុស្សដែលមានពេញទៅដោយអំនួត ហើយក៏មិនដែលធ្លាប់ពិចារណាលើអត្ថន័យរបស់លោក ម៉ូសេ នៅឡើយ ប៉ុន្តែស្រឡាញ់តែអត្ថន័យរបស់ខ្លួនប៉ុណ្ណោះ—មិនមែនដោយសារវាជាការពិតនោះទេ ប៉ុន្តែគឺដោយសារវាគឺជារបស់ផងពួកគាត់ផ្ទាល់។ បើមិនដូច្នោះទេ នោះពួកគាត់ក៏អាចនៅស្រឡាញ់យោបល់ដ៏ពិតរបស់អ្នកផ្សេងទៀតបានយ៉ាងស្មើគ្នាដែរ ដូចដែលទូលបង្គំស្រឡាញ់នូវអ្វីដែលពួកគាត់និយាយ ពេលអ្វីៗដែលពួកគាត់និយាយនោះគឺជាសេចក្តីពិត។ ទូលបង្គំស្រឡាញ់វាមិនមែនដោយសារវាគឺជាគំនិតរបស់ពួកគាត់នោះទេ ប៉ុន្តែគឺដោយសារវាគឺជាសេចក្តីពិត។ ដូច្នេះ វាមិនមែនជារបស់ពួកគាត់ទេ ប៉ុន្តែគឺជាសេចក្តីពិត។ ហើយប្រសិនបើពួកគាត់ស្រឡាញ់យោបល់ណាមួយដោយសារវាគឺជាសេចក្តីពិត នោះវាក៏ក្លាយជារបស់ពួកគាត់ និងជារបស់ទូលបង្គំដែរដោយសារវាជាកម្មសិទ្ធិទូទៅរបស់អស់អ្នកដែលស្រឡាញ់សេចក្តីពិត។ ប៉ុន្តែទូលបង្គំមិនព្រមទទួលយកវាពេលដែលពួកគាត់ប្រឆាំងថាអ្វីដែលលោក ម៉ូសេ បានលើកឡើងគឺមិនមែនជាអត្ថន័យដែលទូលបង្គំនិយាយ ប៉ុន្តែជាអ្វីដែលពួកគាត់និយាយទៅវិញ—ហើយនេះដោយសារ ទោះបើវាអាចជាការនោះមែន ភាពប្រញាប់ប្រញាល់បែបនេះគឺមិនបានកើតឡើងចេញពីចំណេះដឹងឡើយ ប៉ុន្តែពីការសន្មត។ វាមិនបានកើតចេញពីចក្ខុវិស័យនោះទេ ប៉ុន្តែបានកើតចេញពីអំនួត។

ដូច្នេះ ឱព្រះអម្ចាស់អើយ! យើងគួរតែមានការស្ញប់ស្ញែងចំពោះយោបល់របស់ព្រះអង្គពីព្រោះសេចក្តីពិតរបស់ព្រះអង្គគឺមិនមែនជាកម្មសិទ្ធិរបស់ទូលបង្គំ ឬក៏របស់ពួកគាត់ ឬក៏របស់នរណាម្នាក់ផ្សេងទៀតដែរ។ ប៉ុន្តែ វាជាកម្មសិទ្ធិចំពោះយើងទាំងអស់គ្នាដែលព្រះអង្គបានត្រាស់ហៅជាសាធារណៈឲ្យមានវារួមគ្នា។ ហើយព្រះអង្គក៏បានព្រមានពួកយើងទាំងអស់គ្នាថាកុំឲ្យកាន់វាទុកហាក់បីដូចជាកម្មសិទ្ធិពិសេសរបស់ខ្លួនដែរ ដ្បិតបើយើងធ្វើបែបនោះ នោះយើងនឹងបាត់បង់វាមិនខាន។ ដ្បិតប្រសិនបើបុគ្គលណាម្នាក់ទាមទារយកសម្រាប់តែខ្លួនឯងនូវអ្វីដែលព្រះអង្គបានដាក់សម្រាប់ឲ្យមនុស្សទាំងអស់មានអំណរជាមួយ ហើយប្រសិនបើគាត់ប្រាថ្នានូវអ្វីមួយសម្រាប់ខ្លួនឯងផ្ទាល់ដែលជាកម្មសិទ្ធិចំពោះមនុស្សទាំងអស់ នោះគាត់នឹងទទួលការបង្ខំឲ្យដើរចេញពីអ្វីដែលជាកម្មសិទ្ធិចំពោះមនុស្សទាំងអស់គ្នា ប្រាកដណាស់គឺរបស់គាត់ផ្ទាល់—ដែលនេះពីសេចក្តីពិត គឺទៅជា

ការខុសឆ្គងវិញ។ ដ្បិតបុគ្គលណាដែលពោលពាក្យភូតភរគឺគាត់និយាយចេញពីគំនិតរបស់ខ្លួនផ្ទាល់។[៩]

៣៥. ឱព្រះជាម្ចាស់អើយ! សូមព្រះសណ្ដាប់ ដ្បិតទ្រង់គឺជាអ្នកកាត់ទោសដ៏ល្អបំផុត! ឱព្រះដ៏ជាសេចក្ដីពិតអើយ! សូមព្រះសណ្ដាប់នូវអ្វីដែលទូលបង្គំកំពុងតែនិយាយទៅកាន់អស់អ្នកដែលប្រឆាំង។ សូមព្រះសណ្ដាប់ដោយសារទូលបង្គំបានលើកវាឡើងក្នុងព្រះវត្តមានរបស់ព្រះអង្គ និងនៅចំពោះមុខបងប្អូនរបស់ទូលបង្គំដែលប្រើប្រាស់ច្បាប់យ៉ាងត្រឹមត្រូវ ដើម្បីជាការស្រឡាញ់។ សូមព្រះសណ្ដាប់ ហើយឮនូវអ្វីដែលទូលបង្គំនឹងនិយាយទៅកាន់គាត់ ប្រសិនបើព្រះអង្គសព្វព្រះហឫទ័យនឹងវា។

ដ្បិតទូលបង្គំនឹងនិយាយបកនូវពាក្យពេចន៍ទាំងនេះទៅកាន់គាត់ដោយមានសន្តិភាព និងការស្រឡាញ់បែបជាបងប្អូនៈ «ប្រសិនបើយើងទាំងពីរនាក់ឃើញថាអ្វីដែលលោកបានលើកឡើងគឺជាសេចក្ដីពិត ហើយប្រសិនបើយើងទាំងពីរនាក់និយាយថាអ្វីដែលខ្ញុំនិយាយគឺជាសេចក្ដីពិត ចុះបើអញ្ចឹង ខ្ញុំចង់សួរថា តើយើងឃើញអំពីចំណុចនេះនៅកន្លែងណា? ពិតណាស់! ខ្ញុំមិនឃើញនៅក្នុងលោកទេ ហើយលោកក៏មិនឃើញនៅក្នុងខ្ញុំដែរ យើងទាំងពីរនាក់ឃើញវានៅក្នុងសេចក្ដីពិតផ្ទាល់ ដែលមិនចេះប្រែប្រួល ដែលនៅខាងក្រៅគំនិតរបស់យើង»។ បើដូច្នោះមែន នោះយើងនឹងមិនជំទាស់គ្នាអំពីពន្លឺដ៏ពិតរបស់ព្រះជាម្ចាស់ដែលជាព្រះអម្ចាស់របស់យើងនោះទេ ហេតុអ្វីបានយើងមិនឯកភាពគ្នាអំពីគំនិតនានារបស់អ្នកជិតខាងយើង ដែលយើងមិនអាចឃើញយ៉ាងច្បាស់លាស់ដូចដែលសេចក្ដីពិតដែលមិនចេះប្រែប្រួលឃើញដែរ? ប្រសិនបើលោក ម៉ូសេ ផ្ទាល់លេចមកឲ្យយើងឃើញ ហើយនិយាយថាៈ «នេះគឺជាអ្វីដែលខ្ញុំចង់មានអត្ថន័យ» នោះយើងក៏នឹងមិនឃើញដែរ ប៉ុន្តែត្រូវតែជឿគាត់។ ដូច្នេះ សូមកុំឲ្យយើង «គិតខ្ពស់លើសជាងសេចក្ដីដែលបានចែងទុកមក ដើម្បីកុំឲ្យអ្នកណាមានអំនួត ដោយកាន់ជើងម្នាក់ រួចទាស់នឹងម្នាក់ទៀតនោះឡើយ»។[១០] ផ្ទុយទៅវិញ ចូរឲ្យយើង «ស្រឡាញ់ព្រះយេហូវ៉ាជាព្រះរបស់អ្នកឲ្យអស់ពីចិត្ត អស់ពីព្រលឹង និងអស់ពីកម្លាំងរបស់អ្នក ហើយត្រូវស្រឡាញ់អ្នកជិតខាងរបស់អ្នកដូចខ្លួនឯង»។[១១] អ្វីដែលលោក ម៉ូសេ ចង់មានអត្ថន័យនៅក្នុងព្រះគម្ពីរនេះ

---

៩ យ៉ូហាន ៨:៤៤។

១០ ១កូរិនថូស ៤:៦។

១១ ចោទិយកថា ៦:៥; លេវីវិន័យ ១៩:១៨ និងម៉ាថាយ ២២:៣៧, ៣៩។

គឺគាត់ចង់ឲ្យយើងយល់វាក្នុងពន្លឺនៃផ្នត់គំនិតទាំងពីរនៃសេចក្តីស្រឡាញ់នេះ។ យើងនឹងធ្វើឲ្យព្រះជាម្ចាស់ក្លាយជាអ្នកកុហក ប្រសិនបើយើងថ្កោលទោសព្រលឹងនៃអ្នកបម្រើរបស់ព្រះអង្គក្នុងរបៀបណាមួយផ្សេងទៀត ជាជាងក្នុងរបៀបដែលព្រះអង្គបានបង្រៀនយើង។ ដោយសារ មានយោបល់ដ៏ពិតៗជាច្រើនដែលអាចទាញចេញពីពាក្យពេចន៍ទាំងនេះ ដូច្នេះវាពិតជាល្ងីល្ងើណាស់ក្នុងការប្រកែកយ៉ាងឆាប់រហ័សពេកថាលោក ម៉ូសេ បានមានបំណងតែមួយគត់ចេញពីចំណោមការកាត់ស្រាយទាំងនេះ។ វាជារឿងដ៏ល្ងីល្ងើណាស់ក្នុងការអះអាងដូចនេះ ហើយបន្ទាប់មកប្រព្រឹត្តល្មើសលើសេចក្តីស្រឡាញ់ផ្ទាល់ដែលលោក ម៉ូសេ បានលើកឡើងអំពី និងតាមរយៈការបំផ្លាញអ្នកដទៃ នៅពេលដែលយើងជជែកវែកញែកអំពីអ្វីដែលយើងគិតថាគាត់ចង់មានអត្ថន័យ!

៣៦. ទោះជាយ៉ាងណាក៏ដោយ ឱព្រះជាម្ចាស់ដ៏ជាព្រះនៃទូលបង្គំអើយ! ព្រះអង្គព្រះសណ្តាប់ឮនូវការលន់តួរបស់ទូលបង្គំ ហើយក៏អត់ទោសនូវអំពើបាបរបស់ទូលបង្គំ។ ដោយសារទ្រង់បានបញ្ជាឲ្យទូលបង្គំស្រឡាញ់អ្នកជិតខាងរបស់ទូលបង្គំដូចខ្លួនឯង ទូលបង្គំមិនជឿសោះថា ព្រះអង្គបានប្រទានទៅកាន់លោក ម៉ូសេ ដែលជាអ្នកបម្រើដ៏ស្មោះត្រង់បំផុតរបស់ទ្រង់នូវអំណោយទានតូចជាងអ្វីដែលទូលបង្គំគួរប្រាថ្នាចង់បានសម្រាប់ខ្លួនឯងពីព្រះអង្គ។ ប្រសិនបើទូលបង្គំជាលោក ម៉ូសេ ក្នុងសម័យដែលគាត់នៅរស់ ហើយប្រសិនបើព្រះអង្គបានបង្គាប់ឲ្យទូលបង្គំនិពន្ធកណ្ឌគម្ពីរលោកុប្បត្តិ នោះទូលបង្គំនឹងពិតជាប្រាថ្នាចង់បានអំណាចនៃការរៀបរាប់បែបនោះ ដើម្បីឲ្យថា ចំពោះអស់អ្នកដែលមិនទាន់យល់អំពីរបៀបដែលព្រះជាម្ចាស់បានបង្កើត ក៏នឹងមិនបដិសេធពាក្យពេចន៍របស់ទូលបង្គំដោយសារពាក្យពេចន៍របស់ទូលបង្គំលើសកម្រិតនៃការយល់ដឹងរបស់ពួកគេឡើយ។

៤២. ដូច្នេះ នៅពេលដែលបុគ្គលលើកឡើងថា "លោក ម៉ូសេ មានន័យដូចអ្វីដែលខ្ញុំមានន័យ" ហើយបុគ្គលផ្សេងទៀតលើកឡើងថា "អត់ទេ! គាត់មានន័យដូចអ្វីដែលខ្ញុំចង់មានន័យវិញ" នោះទូលបង្គំគិតថា ទូលបង្គំនិយាយយ៉ាងស្មោះត្រង់ជាងពេលទូលបង្គំលើកឡើងថា "ហេតុអ្វីបានជាគាត់មិនអាចមានអត្ថន័យពីរយ៉ាង ប្រសិនបើយោបល់ទាំងពីរជាសេចក្តីពិត?"។ ហើយប្រសិនបើនៅមានសេចក្តីពិតទី៣ ឬក៏ទី៤ ហើយប្រសិនបើនៅមានបុគ្គលណាម្នាក់ព្យាយាមរកសេចក្តីពិតដែលខុសប្លែកពីនោះផ្សេងទៀតក្នុងពាក្យពេចន៍ទាំងនេះ ចុះហេតុអ្វីបានជាវាមិនមែនជារឿងត្រឹមត្រូវក្នុងការជឿថា លោក ម៉ូសេ

ក៏បានឃើញសេចក្តីពិតខុសៗគ្នាទាំងនេះផងដែរ ដោយសារតាមរយៈគាត់ ព្រះជាម្ចាស់បានដាក់ព្រះបន្ទូលដ៏បរិសុទ្ធឲ្យមានការយល់ដឹងសម្រាប់មនុស្សខុសៗគ្នាជាច្រើននាក់? ប្រាកដណាស់!—ហើយទូលបង្គំ និយាយចំណុចនេះដោយមិនខ្លាច ហើយក៏ចេញពីដួងចិត្តរបស់ទូលបង្គំដែរ—ប្រសិនបើទូលបង្គំអាចសរសេរអ្វីមួយលើអំណាចដ៏ខ្ពង់ខ្ពស់បែបនេះបាន នោះទូលបង្គំនឹងជ្រើសរើសសរសេរអំពីវា ដើម្បីឲ្យពាក្យពេចន៍របស់ទូលបង្គំឆ្លុះបញ្ចាំងនូវសេចក្តីពិតដែលបុគ្គលនីមួយៗអាចយល់បានទាក់ទងនឹងចំណុចទាំងអស់នេះជាជាងសរសេរចុះនូវយោបល់ដ៏ពិតតែមួយគត់យ៉ាងច្បាស់លាស់លើចំណុចតែមួយ ដល់ថ្នាក់ថាទូលបង្គំបដិសេធការកាត់ស្រាយទាំងអស់ផ្សេងទៀតចោល។ ប៉ុន្តែ ទូលបង្គំមិនមែននិយាយអំពីការកាត់ស្រាយដ៏ខុសឆ្គងយ៉ាងច្បាស់លាស់នោះទេ។ ឱព្រះដ៏ជាម្ចាស់នៃទូលបង្គំអើយ! ទូលបង្គំមិនសុខចិត្តទេក្នុងការមានក្បាលរឹងដល់ថ្នាក់ថាមិនជឿថាលោក ម៉ូសេ បានទទួល យ៉ាងហោចណាស់ប៉ុននេះពីព្រះអង្គផ្ទាល់។ ប្រាកដណាស់! ពេលដែលគាត់កំពុងសរសេរពាក្យពេចន៍ទាំងនេះ គាត់បានឃើញយ៉ាងពេញទី ហើយក៏យល់ទាំងអស់នូវសេចក្តីពិតដែលយើងមានសមត្ថភាពក្នុងការរកឃើញក្នុងវា ហើយក៏នៅមានចំណុចជាច្រើនទៀតដែលយើងមិនទាន់មានសមត្ថភាពក្នុងការវែកញែកឲ្យបានយល់នៅឡើយ ឬក៏មិនទាន់បានរកឃើញ ទោះបើថាវាមាននៅក្នុងនោះរួចស្រេចទៅហើយដែលយើងមិនទាន់ឃើញក៏ដោយ។

៤៣. ប៉ុន្តែ ឱព្រះអម្ចាស់អើយ! ចំពោះយើង សូមទ្រង់ចង្អុលលើអត្ថន័យដូចគ្នា ឬក៏នៅអត្ថន័យពិតណាមួយផ្សេងទៀតតាមព្រះហឫទ័យទ្រង់ចុះ។ ហើយតាមរយៈនេះ មិនថាព្រះអង្គបើកសម្តែងឲ្យយើងដឹងនូវអ្វីដែលព្រះអង្គបាននាំឲ្យលោក ម៉ូសេ ដឹង ឬក៏ក្នុងអត្ថន័យណាមួយផ្សេងទៀតតាមរយៈរបៀបពាក្យពេចន៍ដូចគ្នានេះ នោះក៏ព្រះអង្គនៅតែផ្គត់ផ្គង់ដល់យើងដែរ។ សូមកុំអនុញ្ញាតឲ្យសេចក្តីខុសឆ្គងមកបោកបញ្ឆោតយើងឡើយ! មើល៍! ឱព្រះអម្ចាស់ដ៏ជាព្រះជាម្ចាស់នៃទូលបង្គំអើយ! យើងបានសរសេរយ៉ាងច្រើនណាស់ទាក់ទងទៅនឹងពាក្យពេចន៍តែបន្តិចនេះ—ពិតជាច្រើនណាស់! តើត្រូវការកម្លាំងពីគំនិត និងពេលវេលាយ៉ាងយូរបែបនេះ ដើម្បីឲ្យបានគ្រប់គ្រាន់ក្នុងការកាត់ស្រាយនូវរាល់កណ្ឌគម្ពីររបស់ព្រះអង្គក្នុងរបៀបនេះមែនឬ? ដូច្នេះ សូមអនុញ្ញាតឲ្យទូលបង្គំធ្វើសេចក្តីសន្និដ្ឋាន ដើម្បីលើកឡើងត្រួសៗទៅកាន់ព្រះអង្គ ហើយជ្រើសរើសសេចក្តីពិតមួយ

យ៉ាងប្រាកដ និងការកាត់ស្រាយយ៉ាងល្អដែលទ្រង់បានបណ្ដាលឲ្យមាន ទោះបើថាមានអត្ថន័យជាច្រើនបានផុសឡើងដោយខ្លួនឯងផ្ទាល់ ហើយក៏អាចមានជម្រើសជាច្រើនបានផងដែរក៏ដោយ។ នេះគឺជាជំនឿនៃការប្រកាសរបស់ទូលបង្គំ ដែលថាប្រសិនបើទូលបង្គំអាចនិយាយនូវអ្វីដែលអ្នកបម្រើរបស់ព្រះអង្គចង់មានន័យ នោះពិតយ៉ាងខ្លាំង ហើយល្អបំផុត នោះដាច់ខាតទូលបង្គំត្រូវតែព្យាយាមធ្វើ។ ប៉ុន្តែ ប្រសិនបើទូលបង្គំមិនបានជោគជ័យ សូមអនុញ្ញាតឲ្យទូលបង្គំនិយាយយ៉ាងហោចណាស់អំពីសេចក្ដីពិតរបស់ព្រះអង្គដែលទ្រង់សព្វព្រះហឫទ័យចង់មានបន្ទូលមកកាន់ទូលបង្គំតាមរយៈពាក្យពេចន៍ទាំងនោះ ដូចដែលវាលើកឡើងនូវអ្វីដែលវាចង់មានន័យទៅកាន់លោក ម៉ូសេ ដែរ។

# ៣០

# ការសម្រាករបស់យើង គឺនៅក្នុងព្រះអង្គ

១. ឱព្រះជាម្ចាស់ដ៏ជាសេចក្ដីមេត្តាករុណារបស់ទូលបង្គំអើយ! ទូលបង្គំអំពាវនាវរកទ្រង់ ដែលបានបង្កើតទូលបង្គំ ហើយក៏មិនបានភ្លេចទូលបង្គំដែរ ទោះបើទូលបង្គំបានភ្លេចព្រះអង្គក៏ដោយ។ តាមរយៈសេចក្ដីប្រាថ្នាដែលព្រះអង្គបានបណ្ដាលឲ្យទូលបង្គំមាន ទូលបង្គំបានអំពាវនាវរកទ្រង់ឲ្យយាងចូលមកក្នុងព្រលឹងទូលបង្គំ ដែលព្រះអង្គបានត្រៀមទុកក្នុងការទទួលទ្រង់។ សូមមេត្តាកុំបោះបង់ទូលបង្គំចោលនៅពេលដែលទូលបង្គំអំពាវនាវរកទ្រង់។ ព្រះអង្គបានរង់ចាំទូលបង្គំមុនទូលបង្គំបានអំពាវនាវហើយក៏បានជំរុញទូលបង្គំម្ដងហើយម្ដងទៀតក្នុងរបៀបជាច្រើន ដើម្បីឲ្យទូលបង្គំអាចស្ដាប់ឮព្រះអង្គពីចម្ងាយ ឲ្យបែរ ហើយអំពាវនាវរកទ្រង់ ដែលជាអង្គដែលបានត្រាស់ហៅទូលបង្គំ។ ដ្បិត ឱព្រះអម្ចាស់អើយ! ទ្រង់បានលុបចោលនូវរាល់ការប្រកាន់ទោសនៃអំពើអាក្រក់ទាំងអស់ដែលទូលបង្គំ

ធ្លាប់បានប្រព្រឹត្ត។ ព្រះអង្គនឹងមិនត្រូវដាក់ទោសទូលបង្គំសម្រាប់អ្វីដែលទូលបង្គំធ្លាប់បានប្រព្រឹត្តឡើយ។ ព្រះអង្គបានគង់នៅទីនោះតាំងពីមុនទូលបង្គំធ្លាប់បានធ្វើអ្វីមួយដែលល្អទៅទៀត។ ហើយក្នុងអំពើល្អដែលទូលបង្គំធ្លាប់បានប្រព្រឹត្ត ព្រះអង្គក៏បានប្រទានរង្វាន់ដល់ទូលបង្គំសម្រាប់អ្វីដែលព្រះហស្តរបស់ទ្រង់បានសម្រេចដែរ—ព្រះហស្តដែលបានបង្កើតទូលបង្គំ។ ដ្បិតមុនមានទូលបង្គំ គឺមានព្រះអង្គហើយ ហើយក៏គ្មានហេតុផលអ្វីក្នុងទូលបង្គំដែលព្រះអង្គគួរប្រទានជីវិតដែរ។ ទោះជាយ៉ាងណាក៏ដោយក៏ទូលបង្គំមានជីវិតតាមរយៈសេចក្ដីសប្បុរសរបស់ទ្រង់ដែរ ដែលបានផ្គត់ផ្គង់សម្រាប់រាល់អ្វីៗដែលព្រះអង្គបានបង្កើតឲ្យទូលបង្គំមាន និងអ្វីៗដែលព្រះអង្គបានបង្កើតទូលបង្គំចេញពីផងដែរ។ ដ្បិតព្រះអង្គមិនត្រូវការទូលបង្គំ ហើយទូលបង្គំក៏មិនមែនជាអ្វីមួយដែលល្អដែលអាចជាជំនួយដល់ព្រះអង្គដែលជាព្រះអម្ចាស់ និងជាព្រះជាម្ចាស់របស់ទូលបង្គំដែរ។ ទ្រង់មិនបានបង្កើតទូលបង្គំមក ដើម្បីឲ្យបម្រើព្រះអង្គ ហាក់បីដូចជាថាព្រះអង្គអស់កម្លាំងក្នុងការធ្វើការឡើយ ឬក៏ហាក់បីដូចជាថាទូលបង្គំអាចបន្ថែមអ្វីមួយផ្សេងទៀតទៅកាន់ព្រះចេស្ដារបស់ទ្រង់។ ហើយការបម្រើដែលទូលបង្គំថ្វាយទៅកាន់ព្រះអង្គក៏មិនមែនដូចជាការមើលថែទីវាល ហាក់បីដូចជាថាព្រះអង្គនឹងមិនទទួលមានការមើលថែ ប្រសិនបើទូលបង្គំមិនមើលថែទ្រង់នោះទេ។ ផ្ទុយទៅវិញ គឺដើម្បីឲ្យទូលបង្គំអាចបម្រើ និងថ្វាយបង្គំព្រះអង្គ ដែលចេញពីការនោះនឹងដើម្បីឲ្យទូលបង្គំអាចទទួលបានសេចក្ដីល្អពីព្រះអង្គ ដ្បិតព្រះអង្គគឺជាប្រភពនៃចំណុះនៃការដែលទូលបង្គំមានសេចក្ដីល្អ។

២. ប្រាកដណាស់! គឺចេញពីសេចក្ដីសប្បុរសដ៏ពេញទីរបស់ព្រះអង្គដែលរបស់សព្វសារពើរបស់ទ្រង់ជាជីវិត។ ទោះបើថារបស់សព្វសារពើមិនអាចថ្វាយអ្វីមួយទៅកាន់ព្រះអង្គក៏ដោយ ហើយក៏មិនមែនជាចំណែកនៃព្រះជន្មរបស់ព្រះអង្គ ឬក៏ស្មើទ្រង់ដែរ—ដោយសារការបង្កើតឡើងឲ្យមានជីវិតរបស់វាកើតចេញពីព្រះអង្គ។

ដ្បិតតើផ្ទៃមេឃ និងផែនដី ដែលព្រះអង្គបានបង្កើតតាំងពីដើមដំបូងមក ស័ក្ដិសមនឹងទទួលបានអ្វីពីព្រះអង្គ? សូមអនុញ្ញាតឲ្យពួកវាប្រកាស—របស់សព្វសារពើខាងឯវិញ្ញាណ និងសាច់ឈាមទាំងនេះ ដែលព្រះអង្គបានបង្កើតឡើងក្នុងព្រះប្រាជ្ញាញាណរបស់ទ្រង់—សូមអនុញ្ញាតឲ្យពួកវាប្រកាស តើពួកវាមានគុណសម្បត្តិអ្វីនៅក្នុងព្រះហស្តទ្រង់ដែលបណ្ដាលឲ្យពួកវាស័ក្ដិសមនឹងមានជីវិត ចុះបើថាតាមពិតទៅ ពួកវាតែងតែគ្មាន

សណ្ដាប់ធ្នាប់ ហើយក៏គ្មានលក្ខណៈដូចជាទ្រង់ទាល់តែសោះ? របស់សព្វសារពើខាងឯវិញ្ញាណដែលមិនទាន់បានទទួលការរចនាឡើងគឺមានភាពល្អប្រសើរជាងរបស់សព្វសារពើខាងឯសាច់ឈាមដែលត្រូវបានរចនាឡើង។ ហើយរបស់សព្វសារពើខាងឯសាច់ឈាម សូម្បីតែពេលដែលមិនទាន់បានរចនាឡើងក៏នៅមានភាពល្អប្រសើរជាង ប្រសិនបើជាសាមញ្ញវាមិនមានអ្វីទាល់តែសោះ។ ទោះជាយ៉ាងណាក៏ដោយ ក៏របស់សព្វសារពើទាំងនេះដែលមិនទាន់មានរូបរាងកំពុងស្ថិតក្នុងសភាពរបស់វាតាមរយៈព្រះអង្គ រហូតទាល់តែទ្រង់ត្រាស់ហៅឲ្យពួកវាមានភាពរួបរួមរបស់ទ្រង់ ហើយទទួលរូបរាង ហើយការដែលកើតចេញពីព្រះអង្គដែលពេញទៅដោយសេចក្ដីសប្បុរសពេញទៅដោយអធិបតេយ្យភាពតែមួយព្រះអង្គគត់។ តើពួកវាស័ក្ដិសមនឹងទទួលបានអ្វីពីព្រះអង្គ ដែលតាមពិតទៅពួកវាមិនមែនទាំងជារបស់សព្វសារពើដែលមិនមានរូបរាងផង លុះត្រាតែពីព្រះអង្គសិន?

២៩. គឺមិនមែនជម្រៅទឹកនៃសមុទ្រទេ ប៉ុន្តែ «ផែនដី» ដែលត្រូវបានញែកចេញពីទឹកប្រៃ ដែលបាននាំមកឲ្យមាន «ព្រលឹងដែលមានជីវិត» ផ្ទាល់ មិនមែន «គ្រប់ទាំងសត្វដែលលូនវារលើដី និងអស់ទាំងសត្វស្លាបដែលមានជីវិត» ទេ![១]

សូមចាត់ព្រះបន្ទូលរបស់ទ្រង់ឲ្យចូលទៅផែនដីតាមរយៈភ្នាក់ងារនៃអ្នកនាំសាររបស់ព្រះអង្គចុះ។ ដ្បិតយើងគ្រាន់តែបានប្រាប់អំពីទង្វើរបស់ពួកគេ ប៉ុន្តែគឺព្រះអង្គទេដែលជាអង្គសម្រេចព័ន្ធកិច្ចក្នុងពួកគេ ដើម្បីឲ្យពួកគេទំនងជាអាចនាំមកនូវ «ព្រលឹងដែលមានជីវិត» ក្នុងផែនដីនេះបាន។

ការប្រកាសរបស់អ្នកផ្សាយដំណឹងល្អដំបូងគឺត្រូវបានត្រាស់ហៅឡើងចេញតាមរយៈបុព្វហេតុនៃភាពមិនស្មោះត្រង់របស់មនុស្ស ប៉ុន្តែពួកអ្នកស្មោះត្រង់ក៏ទទួលបានការដាស់តឿន ហើយក៏ទទួលបានព្រះពរតាមរយៈពួកគេក្នុងរបៀបជាច្រើនពីមួយថ្ងៃទៅមួយថ្ងៃ។ «ព្រលឹងដែលមានជីវិត» មានប្រភពចេញពី «ផែនដី» ពីព្រោះគឺចំពោះតែអស់អ្នកដែលស្មោះត្រង់ប៉ុណ្ណោះដែលនឹងទទួលបានអត្ថប្រយោជន៍ក្នុងការរារាំងខ្លួនចេញពីការស្រឡាញ់លោកីយ៍នេះ ដើម្បីឲ្យព្រលឹងរបស់ពួកគេអាចរស់នៅចំពោះព្រះអង្គបាន។ ព្រលឹងនេះបានស្លាប់ខណៈពេលដែលវាកំពុងរស់នៅក្នុងភាពអរសប្បាយ—ក្នុងភាពអរសប្បាយដែលមានសេចក្ដីស្លាប់ក្នុងវា—ខណៈពេលដែលទ្រង់ដ៏ជាព្រះអម្ចាស់ គឺជា

---

១ នេះគឺជាការប្រៀបប្រដូចមួយប្រភេទក្នុងការមាន «ភាពល្អឥតខ្ចោះ» ក្នុងក្រុមជំនុំ។

អំណារដែលមានព្រះជន្មសម្រាប់អស់អ្នកដែលមានចិត្តបរិសុទ្ធ។

៣០. ចូរស្វែងរកព្រះអម្ចាស់ចុះ នោះព្រលឹងរបស់លោកអ្នកនឹងមានជីវិត[២] ហើយ "ផែនដី" ក៏អាចនាំមកនូវ "ព្រលឹងដែលមានជីវិត"។ ចូរកុំត្រាប់តាមសម័យនេះឡើយ[៣] ប៉ុន្តែចូរញែកខ្លួនចេញពីវាវិញ។ ព្រលឹងមានជីវិតតាមរយៈការគេចចេញពីរបស់ដែលនាំឲ្យមានសេចក្ដីស្លាប់ ប្រសិនបើវាស្រឡាញ់របស់ទាំងនោះ។ សូមទប់ចិត្តខ្លួនឯងពីការមានអំនួតដ៏ព្រហើនដែលមិនអាចគ្រប់គ្រងលើបាន និងពីភាពខ្ជិលច្រអូសនៃភាពត្រេកត្រអាលនៃភាពស្រណុកសុខស្រួល និងពីសេចក្ដីដែលគេច្រឡំហៅថាជាចំណេះដឹង។[៤] ក្នុងរបៀបនេះ នោះសត្វព្រៃដ៏កាចសាហាវនឹងអាចទទួលបានការផ្សាំង អាចបង្ក្រាបសត្វពាហនៈបាន ហើយអាចធ្វើឲ្យសត្វពស់លែងជាគ្រោះថ្នាក់។ ដ្បិត ក្នុងការប្រៀបប្រដូច រូបភាពទាំងនេះគឺជាចលនានៃគំនិតរបស់យើង៖ នេះគឺ ដើម្បីនិយាយថា ភាពក្រអឺតក្រទមនៃអំនួត ការចូលចិត្តភាពត្រេកត្រអាល និងពិសពុលនៃការចង់ដឹងចង់ឮគឺជាចលនានៃព្រលឹងដែលស្លាប់—មិនស្លាប់ដល់ថ្នាក់ថាវាបាត់បង់ចលនាទាំងស្រុងនោះទេ ប៉ុន្តែស្លាប់ដោយសារវាបានបោះបង់ប្រភពនៃជីវិតចោល ហើយលោកីយ៍ដែលនៅបណ្ដោះអាសន្ននេះក៏បានយកវា ហើយវាក៏បានត្រាប់តាមលោកីយ៍នេះដែរ។

៣១. ប៉ុន្តែ ឱព្រះជាម្ចាស់អើយ! ព្រះបន្ទូលរបស់ទ្រង់គឺជាប្រភពនៃជីវិតដ៏នៅអស់កល្បជានិច្ច ហើយវាក៏នឹងមិនកន្លងផុតទៅដែរ។ ដូច្នេះ ការបោះបង់ចោលនេះក៏ទទួលបានការរារាំងតាមរយៈព្រះបន្ទូលរបស់ព្រះអង្គពេលវានិយាយមកកាន់យើងថា "មិនត្រូវត្រាប់តាមសម័យនេះឡើយ" ដើម្បីឲ្យ "ផែនដី" ទំនងជាអាចនាំមកនូវ "ព្រលឹងដែលមានជីវិត" ក្នុងប្រភពនៃជីវិត—ព្រលឹងដែលទទួលបានការណែនាំតាមរយៈព្រះបន្ទូលរបស់ព្រះអង្គ តាមរយៈអ្នកផ្សព្វផ្សាយដំណឹងល្អរបស់ទ្រង់ និងតាមរយៈការដើរតាមនៃអ្នកដើរតាមរបស់ព្រះគ្រីស្ទនៃទ្រង់។ បុគ្គលម្នាក់តែងតែដើរតាមគំរូនៃមិត្តភក្ដិរបស់គាត់។ ដូច្នេះ សាវ័ក ប៉ុល បានមានប្រសាសន៍ថា "បងប្អូនអើយ ខ្ញុំសូមអង្វរអ្នករាល់គ្នាឲ្យបានដូចជាខ្ញុំ ដ្បិតខ្ញុំក៏បានដូចជាអ្នករាល់គ្នាដែរ"។[៥]

---

២ ទំនុកតម្កើង ៦៩:៣២។

៣ រ៉ូម ១២:២។

៤ ១ធីម៉ូថេ ៦:២០។

៥ កាឡាទី ៤:១២។

៣២. ឱព្រះអម្ចាស់ដែលជាព្រះជាម្ចាស់ និងជាព្រះអាទិកររបស់យើងអើយ! សុច្ឆន្ទៈរបស់យើងទទួលបានការបែរចេញពីការស្រឡាញ់លោកីយ៍នេះ ដែលក្នុងវាយើងស្លាប់តាមរយៈការរស់នៅដោយមានជីវិតយ៉ាងអាក្រក់ ហើយនៅពេលដែលយើងចាប់ផ្ដើមក្លាយជា «ព្រលឹងដែលមានជីវិត» តាមរយៈការរស់នៅយ៉ាងត្រឹមត្រូវ។ ហើយនៅពេលដែលព្រះបន្ទូលលើកឡើងថា «មិនត្រូវត្រាប់តាមសម័យនេះឡើយ» ដែលព្រះអង្គបានមានព្រះបន្ទូលតាមរយៈសាវ័ករបស់ទ្រង់ បានទទួលការបំពេញក្នុងយើង នោះយើងនឹងអាចដើរតាមអ្វីដែលទ្រង់បន្ថែមភ្លាមៗនោះបន្ទាប់ពីនេះ នៅពេលដែលព្រះអង្គមានបន្ទូលថា «តែចូរឲ្យបានផ្លាស់ប្រែ ដោយគំនិតរបស់អ្នករាល់គ្នាបានកែជាថ្មី»។[៦] យើងលែងជា «តាមពូជ» ទៀតហើយ ហាក់បីដូចជាយើងកំពុងតែដើរតាមអ្នកជិតខាងរបស់យើងដែលបានចេញទៅមុនយើង ឬក៏ហាក់បីដូចជាយើងកំពុងតែរស់នៅតាមគំរូដ៏ល្អនៃបុគ្គលណាម្នាក់ផ្សេងទៀត—ដ្បិតព្រះអង្គមិនបានមានព្រះបន្ទូលថា «ចូរឲ្យមនុស្សកើតឡើងតាមពូជរបស់គេ» ប៉ុន្តែ ផ្ទុយទៅវិញ «ចូរយើងបង្កើតមនុស្សឲ្យដូចជារូបយើង ឲ្យមានភាពដូចយើង»[៧] ដើម្បីឲ្យមនុស្សអាចបង្ហាញពីធាតុពិតនៃព្រះហឫទ័យរបស់ព្រះអង្គបាន។

នេះហើយជាមូលហេតុដែលសាវ័ក ប៉ុល ដែលជាអ្នកបម្រើរបស់ព្រះអង្គបានបង្កើតកូនចៅតាមរយៈដំណឹងល្អ។ គាត់មិនចង់ឲ្យពួកគេនៅបន្តជាទារកយ៉ាងអស់កល្បជានិច្ចឡើយ ដែលគាត់ត្រូវនៅបន្តផ្ដល់អាហារជាទឹកដោះ និងការមើលថែ។ នេះគឺជាមូលហេតុដែលគាត់បានលើកឡើងថា «តែចូរឲ្យបានផ្លាស់ប្រែ ដោយគំនិតរបស់អ្នករាល់គ្នាបានកែជាថ្មី ដើម្បីឲ្យអ្នករាល់គ្នាអាចស្គាល់អ្វីជាព្រះហឫទ័យរបស់ព្រះ គឺអ្វីដែលល្អ អ្វីដែលព្រះអង្គគាប់ព្រះហឫទ័យ ហើយគ្រប់លក្ខណ៍»។[៨] ដូច្នេះ ព្រះអង្គមិនបានមានបន្ទូលថា «ចូរឲ្យមនុស្សកើតឡើង» ប៉ុន្តែផ្ទុយទៅវិញ «ចូរយើងបង្កើតមនុស្ស»។ ហើយព្រះអង្គបានមានបន្ទូលថា «តាមពូជរបស់គេ» ប៉ុន្តែ «ឲ្យដូចជារូបយើង» និង «ឲ្យមានភាពដូចយើង»។ ប្រាកដណាស់! គឺតាមរយៈតែពេលដែលបុគ្គលណាម្នាក់ទទួលបានការបំផ្លាស់បំប្រែក្នុងគំនិតរបស់គាត់ ហើយនោះទើបគាត់មើលឃើញ និងយល់សេចក្ដីពិតរបស់ទ្រង់បាន ត្រង់ថាគាត់មិនត្រូវការបុគ្គលណាម្នាក់ផ្សេងទៀតឲ្យមកធ្វើជាអ្នកនាំផ្លូវគាត់ទេ ដើម្បីបង្ហាញ

---

៦ រ៉ូម ១២:២។

៧ លោកុប្បត្តិ ១:២៦។

៨ រ៉ូម ១២:២។

គាត់អំពីរបៀបនៃការត្រាប់តាមគំរូរបស់មនុស្សណាផ្សេងទៀតឡើយ។ ផ្ទុយទៅវិញ តាមរយៈការដឹកនាំរបស់ព្រះអង្គ នោះគាត់នឹងបង្ហាញអំពីចំណុចល្អ ចំណុចដែលគួរឲ្យទទួលយក និងព្រះហឫទ័យដ៏ល្អឥតខ្ចោះរបស់ព្រះអង្គ។ ហើយព្រះអង្គបង្រៀនគាត់ ដោយសារឥឡូវគាត់មានសមត្ថភាពអាចយល់ ហើយឃើញពីភាពនៃព្រះត្រៃឯកនៃការរួបរួមគ្នាតែមួយ និងការរួបរួមគ្នាតែមួយនៃភាពជាព្រះត្រៃឯក។

នេះហើយជាមូលហេតុនៃប្រយោគពហុវចនៈ «ចូរយើងបង្កើតមនុស្ស» ក៏មានការភ្ជាប់គ្នាជាមួយនឹងប្រយោគឯកវចនៈ «ព្រះបានបង្កើតមនុស្ស» ហើយក៏មានការលើកឡើងក្នុងប្រយោគពហុវចនៈ «ឲ្យមានភាពដូចយើង» ហើយបន្ទាប់មកក្នុងប្រយោគឯកវចនៈ «ឲ្យដូចជារូបអង្គទ្រង់»។ ក្នុងរបៀបនេះ មនុស្សក៏បានទទួលការបំផ្លាស់បំប្រែក្នុងចំណេះដឹងរបស់ព្រះជាម្ចាស់ យោងតាមរូបអង្គទ្រង់ដែលបានបង្កើតគាត់មក។ ហើយដោយសារព្រះជាម្ចាស់បានបង្កើតមនុស្សលោកឲ្យមានវិញ្ញាណ នោះមនុស្សអាចវិនិច្ឆ័យបានទាំងអស់—នេះគឺថា រាល់គ្រប់អ្វីៗដែលសមក្នុងការទទួលការថ្កោលទោស—ហើយក៏គ្មានអ្នកណាអាចថ្កោលទោសគាត់បានឡើយ។[៩]

៣៣. ហើយឥឡូវឃ្លានេះមនុស្សខាងវិញ្ញាណ «វិនិច្ឆ័យបានទាំងអស់» មានន័យថាមនុស្សលោកមានអំណាចលើត្រីក្នុងសមុទ្រ លើបក្សាបក្សីលើអាកាស លើសត្វពាហនៈ និងសត្វព្រៃទាំងអស់ លើផែនដីទាំងមូល និងលើគ្រប់ទាំងសត្វលូនវារ ដែលផ្លាស់ទីនៅលើផែនដីនេះ។ ហើយគេធ្វើការនេះតាមរយៈអំណាចនៃការគិតគូរក្នុងគំនិតរបស់គេតាមអ្វីដែលគេ «ពិចារណាយល់ខាងវិញ្ញាណ»។[១០] ប៉ុន្តែ នៅពេលដែលមនុស្សទទួលបានឋានៈដ៏ខ្ពស់មួយនេះ នោះគាត់ក៏មិនបានយល់អំពីអ្វីដែលមានការជាប់ទាក់ទិនគ្នា ដូច្នេះក៏បានធ្លាក់ដល់កម្រិតនៃសត្វតិរច្ឆាន ហើយក៏មានលក្ខណៈដូចទៀតផង។[១១]

៣៤. មនុស្សជាតិ ទោះបើគាត់ត្រូវបានបង្កើតឡើងក្នុងរូបអង្គទ្រង់ផ្ទាល់ មិនបានទទួលអំណាចនៃការគ្រប់គ្រងលើពន្លឺនៅលើមេឃ ឬក៏លើស្ថានសួគ៌ដ៏លាក់កំបាំង ឬក៏លើថ្ងៃ និងយប់ដែលព្រះអង្គបានហៅឲ្យមានមុនទ្រង់បង្កើតផ្ទៃមេឃ ឬក៏លើការដែលទឹកប្រមូលផ្ដុំគ្នាទៅជាសមុទ្រផងដែរក៏ដោយ។ ផ្ទុយទៅវិញ គាត់ទទួលបានអំណាចលើ

---

៩ ១កូរិនថូស ២:១៥ (គខប)។

១០ ១កូរិនថូស ២:១៤។

១១ ទំនុកតម្កើង ៤៩:២០។

ត្រីក្នុងសមុទ្រ បក្សាបក្សីលើអាកាស លើសត្វពាហនៈទាំងអស់ លើផែនដីទាំងមូល និងលើគ្រប់ទាំងសត្វលូនវារ ដែលវារនៅលើផែនដី។

ប្រាកដណាស់! គាត់វិនិច្ឆ័យ និងទទួលយកនូវអ្វីដែលគាត់ឃើញថាត្រឹមត្រូវ ហើយមិនទទួលយកនូវអ្វីដែលគាត់ឃើញថាមិនត្រឹមត្រូវទេ។ បុគ្គលខាងឯវិញ្ញាណក៏វិនិច្ឆ័យតាមរយៈការទទួលយកនូវអ្វីដែលត្រឹមត្រូវ និងស្តីបន្ទោសលើអ្វីដែលគាត់ឃើញថាមិនត្រឹមត្រូវក្នុងទង្វើ និងសីលធម៌នៃពួកស្មោះត្រង់ ដូចជាការធ្វើទានរបស់ពួកគេ ដែលមានសម្គាល់ក្នុងឃ្លា «ដីក៏បង្កើតផលផ្លែឡើង»។[១២] ហើយគាត់វិនិច្ឆ័យលើ «ព្រលឹងដែលមានជីវិត» ដែលបន្ទាប់មករស់នៅតាមរយៈការមានវិន័យនៃការពេញចិត្តក្នុងភាពបរិសុទ្ធរបស់គាត់ ក្នុងការតម និងក្នុងការសញ្ជឹងគិតដ៏បរិសុទ្ធ។ ហើយគាត់ក៏វិនិច្ឆ័យលើរាល់ចំណុចទាំងអស់នោះដែលទាក់ទងទៅនឹងអ្វីដែលញាណខាងឯរូបកាយបានដឹង។ ដ្បិតយើងក៏អាចលើកឡើងបានដែរថា គាត់គួរវិនិច្ឆ័យលើចំណុចទាំងអស់អំពីអ្វីៗដែលគាត់ក៏អាចមានអំណាចលើក្នុងការកែតម្រង់ដែរ។

៣៥. ប៉ុន្តែ តើនេះជាអ្វីទៅ? តើនេះជារឿងអាថ៌កំបាំងប្រភេទណា? មើល៍! ឱព្រះអម្ចាស់អើយ! ព្រះអង្គបានប្រទានពរមនុស្សលោក ដើម្បីឲ្យពួកគេអាច «បង្កើតកូនឲ្យចម្រើនជាច្រើនឡើង ឲ្យមានពាសពេញលើផែនដី»។[១៣] ក្នុងចំណុចនេះ តើព្រះអង្គមិនមែនកំពុងបង្កើតចំណុចសម្គាល់ចំពោះ ដើម្បីឲ្យយើងអាចយល់អ្វីមួយបែបជាការប្រៀបប្រដូចមែនឬ? ហេតុអ្វីបានជាព្រះអង្គក៏មិនប្រទានពរលើពន្លឺដែលទ្រង់ដាក់ឈ្មោះថា «ថ្ងៃ» ឬក៏ផ្ទៃមេឃ ឬក៏ពន្លឺនានា ឬក៏ហ្វូងតារា ឬក៏ផែនដី ឬក៏សមុទ្រអញ្ចឹង? ឱព្រះដ៏ជាព្រះជាម្ចាស់នៃយើងអើយ! ទូលបង្គំទំនងជានឹងឆ្លើយតបថា ក្នុងការដែលព្រះអង្គបង្កើតយើងតាមរូបអង្គទ្រង់ គឺទ្រង់សព្វព្រះហឫទ័យតែលើការប្រទានអំណោយទាននៃអំណរនេះលើមនុស្សជាតិមួយគត់ ប្រសិនបើព្រះអង្គមិនគ្រាន់តែប្រទានពរលើសត្វត្រី និងត្រីបាឡែន ដើម្បីឲ្យពួកវាអាចបង្កើតកូនឲ្យចម្រើនជាច្រើនឡើងបាន ឲ្យមានពាសពេញទឹកសមុទ្រ។ ព្រមទាំងបក្សាបក្សី ដើម្បីឲ្យពួកវាអាចបង្កើតកូនឲ្យចម្រើនជាច្រើនឡើងលើផែនដី។ ក្នុងរបៀបដូចគ្នានេះ ទូលបង្គំប្រហែលជានឹងលើកឡើងថា ព្រះពរដូចនេះគឺជាកម្ម

---

១២ យ៉ាកុប ៥:១៨។

១៣ លោកុប្បត្តិ ១:២៨។

សិទ្ធិសម្រាប់តែរបស់សព្វសារពើបែបនេះ ដែលបង្កើតកូនចៅតាមពូជរៀងៗខ្លួនរបស់វាតែប៉ុណ្ណោះ ប្រសិនបើទូលបង្គំអាចរកឃើញព្រះពរដូចនេះទៅកាន់ដើមឈើ រុក្ខជាតិ និងសត្វនានាលើផែនដី។ ប៉ុន្តែ ព្រះអង្គមិនបានមានបន្ទូលទៅកាន់រុក្ខជាតិ ដើមឈើ សត្វនានា ឬក៏សត្វពស់ថា "ឲ្យចម្រើនជាច្រើនឡើង" និង "ឲ្យមានពាសពេញ" ទេ—ទោះបើទាំងអស់នេះ រួមជាមួយសត្វត្រី បក្សាបក្សី និងមនុស្សលោកក៏ពិតជាចម្រើនជាច្រើនឡើងតាមរយៈការបង្កបង្កើតក៏ដោយ ដែលចេញពីនោះក៏បានរក្សាទុកនូវពូជពង្សរបស់ខ្លួនមែនដែរ។

៣៦. ឱសេចក្តីពិតដែលជាជីវិតនៃទូលបង្គំអើយ! តើឲ្យទូលបង្គំគួរនិយាយយ៉ាងដូចម្តេចទៅថា៖ វាជាការលើកឡើងដែលមិនមានគោលបំណង ហើយពេញទៅដោយភាពឥតប្រយោជន៍មែនឬ? ទេ! ឱព្រះវរបិតានៃសេចក្តីសប្បុរសអើយ! សូមកុំអនុញ្ញាតឲ្យអ្នកបម្រើនៃព្រះបន្ទូលរបស់ទ្រង់និយាយដូចនេះឲ្យសោះ! ប៉ុន្តែ ប្រសិនបើទូលបង្គំមិនបានយល់អំពីអត្ថន័យដែលព្រះអង្គមានតាមរយៈឃ្លានោះ សូមអនុញ្ញាតឲ្យអ្នកដែលប្រសើរជាងទូលបង្គំ—គឺអស់អ្នកដែលឆ្លាតជាងទូលបង្គំ—កាត់ស្រាយវាឲ្យបានប្រសើរជាងនេះទៅចុះ ក្នុងកម្រិតដែលព្រះអង្គបានប្រទានដល់យើងម្នាក់ៗនូវសមត្ថភាពនៃការយល់ដឹងផ្សេងៗពីគ្នាបាន។

ប៉ុន្តែ សូមព្រះអង្គអនុញ្ញាតឲ្យការលន់តួរបស់ទូលបង្គំជាការសព្វព្រះហឫទ័យចំពោះព្រះនេត្ររបស់ទ្រង់ ដ្បិតឱព្រះអម្ចាស់អើយទូលបង្គំរៀបរាប់ទៅកាន់ព្រះអង្គ៖ ទូលបង្គំជឿថាព្រះអង្គមិនបានមានបន្ទូលអំពីចំណុចទាំងនេះក្នុងរបៀបឥតប្រយោជន៍ឡើយ។ ហើយទូលបង្គំក៏នឹងមិននៅស្ងៀមទាក់ទងទៅនឹងអ្វីដែលទូលបង្គំគិតថាជាអត្ថន័យរបស់វាដែលទូលបង្គំបានអានដែរ។ ដ្បិតវាអាចយកជាការបាន ហើយទូលបង្គំក៏មិនឃើញថាមានអ្វីអាចមករារាំងទូលបង្គំពីការកាត់ស្រាយក្នុងរបៀបប្រៀបប្រដូចលើការនិពន្ធនេះក្នុងព្រះគម្ពីររបស់ព្រះអង្គដែរ។ ដ្បិតទូលបង្គំដឹងថាចំណុចមួយដែលមានការយល់ដឹងក្នុងរបៀបតែមួយគត់ក្នុងគំនិតទំនងជាអាចមានការបង្ហាញក្នុងរបៀបជាច្រើនតាមរយៈរូបកាយ។ ហើយទូលបង្គំក៏ដឹងថាចំណុចមួយដែលមានអាចមានការបង្ហាញក្នុងរបៀបតែមួយគត់តាមរយៈរូបកាយក៏ទំនងជាការយល់ដឹងក្នុងរបៀបជាច្រើនក្នុងគំនិតដែរ។ ដ្បិតចូរពិចារណាលើឧទាហរណ៍តែមួយនេះ—ការស្រឡាញ់ព្រះជាម្ចាស់ និងអ្នកជិតខាងរបស់

យើង—តាមរយៈអាថ៌កំបាំងខុសៗគ្នាជាច្រើន និងភាសាដែលរាប់មិនអស់ ហើយក្នុងភាសានីមួយៗក៏មានរបៀបនិយាយខុសៗគ្នាជាច្រើនផងដែរ ហើយយើងក៏អាចឃើញចំណុចនេះបានខាងឯសាច់ឈាម! ក្នុងរបៀបដូចគ្នា «ត្រីតូច» ក្នុង «ទឹក» ក៏ចម្រើនជាច្រើនឡើងយ៉ាងពាសពេញដែរ។ មួយវិញសោត មិនថាអ្នកដែលកំពុងអានចំណុចនេះជាបុគ្គលណាក៏ដោយ ចូរគោរពតាម ហើយសង្កេតមើលអ្វីដែលព្រះបន្ទូលប្រកាសចុះ និងអំពីរបៀបដែលសំឡេងអានវាក្នុងរបៀបតែមួយគត់ថា «កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី»។[១៤] តើចំណុចនេះមិនមានការយល់ដឹងក្នុងរបៀបខុសៗគ្នាជាច្រើនតាមរយៈរបៀបផ្សេងៗនៃការកាត់ស្រាយដ៏ពិតៗដែលមិនមានលាយឡំជាមួយនឹងការបោកបញ្ឆោតនៃចំណុចខុសឆ្គងមែនឬ? ដូច្នេះ ក្នុងរបៀបនេះកូនចៅមនុស្សអាចចម្រើនឡើង ហើយមានផលផ្លែជាច្រើន។[១៥]

៥០. ឱព្រះអង្គដ៏ជាព្រះជាម្ចាស់អើយ! សូមប្រទានភាពសន្តិភាពរបស់ព្រះអង្គមកកាន់យើង—ដ្បិតព្រះអង្គបានប្រទានមកដល់យើងនូវរាល់គ្រប់អ្វីៗទាំងអស់ហើយ។ សូមប្រទានមកកាន់យើងនូវសន្តិភាពនៃការស្ងប់ស្ងៀម សន្តិភាពនៅថ្ងៃសប្ប័ទ សន្តិភាពដែលគ្មានពេលល្ងាច។ របស់របរដែលស្រស់បំព្រងទាំងអស់នេះ ដែលស្អាតទាំងអស់នឹងកន្លងផុតទៅពេលវាឆ្លងកាត់ដំណាក់កាលនៃចុងបំផុត—ដ្បិតក្នុងវាមានទាំងពេលព្រឹក និងពេលល្ងាច។

៥១. ប៉ុន្តែ ថ្ងៃទី៧មិនមានពេលល្ងាចទេ ហើយវាក៏គ្មានពេលលិចដែរ ដ្បិតព្រះអង្គបានញែកវាទុកជាបរិសុទ្ធឲ្យមានរយៈពេលយ៉ាងអស់កល្បជានិច្ច។ ព្រះអង្គបានសម្រាកនៅថ្ងៃទី៧ បន្ទាប់ពីទ្រង់បានបញ្ចប់ព័ន្ធកិច្ចនៃការបង្កើតទាំងអស់របស់ទ្រង់ដែលសុទ្ធតែល្អ។ ទោះបើព្រះអង្គបានបង្កើតពួកវាទាំងអស់ដោយមិនមានការសម្រាកក៏ដោយ—ហើយនេះគឺដើម្បីឲ្យព្រះសូរសៀងតាមរយៈព្រះគម្ពីររបស់ព្រះអង្គទំនងជាមានបន្ទូលមកកាន់យើងដោយមានការធានាជាគោលដែលថាពីកិច្ចការរបស់យើង—ហើយវាក៏ពិតជាល្អមែនដែរ

១៤ ជាថ្មីម្តងទៀត ដូចនៅក្នុងឃ្លាបន្ទាប់លោកគ្រូ អហ្គូស្ទីន ក៏បានលើកឡើងសាជាថ្មីនូវអត្ថន័យគោលរបស់គាត់ និងមូលហេតុទាំងមូលនៃ *«ការលន់តួ»* របស់គាត់៖ ឋានៈខ្ពង់ខ្ពស់របស់ព្រះជាម្ចាស់ ភាពច្នៃប្រឌិតឥតឈប់ឈររបស់ទ្រង់ អាថ៌កំបាំងរបស់ព្រះអង្គ ការមិនចេះនឿយហត់របស់ទ្រង់ និងសេចក្តីស្រឡាញ់នៃការប្រោសលោះដែលមិនអាចមានការអាក់ខានបាន។ ទាំងអស់គឺត្រូវបានសង្ខេបឡើងក្នុងអាថ៌កំបាំងនៃការបង្កើតនេះ ដែលក្នុងវាគោលបំណងនានារបស់ព្រះជាម្ចាស់ក៏ត្រូវបានប្រកាសឡើង ហើយចេញពីវាក៏គ្រីស្ទបរិស័ទគ្រប់ៗរូបមានសង្ឃឹមបានដែរ។

១៥ ត្រង់នេះ គឺមានន័យថា ចេញពីមូលដ្ឋាន និងគំនិតដ៏សាមញ្ញយ៉ាងសំខាន់ នោះពួកគេក៏បង្កើនបរិមាណយ៉ាងឆាប់រហ័ស—ហើយអាចទទួលយកបាន—ការអនុវត្ត និងលទ្ធផល។

ពីព្រោះព្រះអង្គបានប្រទានវាមកកាន់យើង—ក៏យើងនឹងរកបានការសម្រាករបស់យើងក្នុងព្រះអង្គក្នុងថ្ងៃសប្ប័ទនៃជីវិតដ៏នៅអស់កល្បជានិច្ចដែរ។

៥៣. ហើយឥឡូវនេះ ក្នុងពេលវេលាបច្ចុប្បន្ននេះ ព្រះអង្គបាននាំឲ្យយើងប្រព្រឹត្តល្អ ពីព្រោះឥឡូវនេះព្រះអង្គបានធ្វើឲ្យចិត្តយើងមានជីវិតតាមរយៈព្រះវិញ្ញាណរបស់ទ្រង់។ ប៉ុន្តែ កាលពីមុន ដោយសារយើងបានបោះបង់ព្រះអង្គចោល នោះយើងក៏ទទួលបានការណែនាំឲ្យទៅប្រព្រឹត្តការអាក្រក់ដែរ។ ប៉ុន្តែ ឱព្រះអង្គដ៏ល្អតែមួយអង្គអើយ! ព្រះអង្គមិនដែលឈប់ធ្វើល្អទេ! ហើយយើងក៏បានសម្រេចកិច្ចការល្អមួយចំនួនដែរ តាមរយៈអំណោយទានដ៏ល្អៗរបស់ទ្រង់។ ហើយទោះបើវាមិននៅយ៉ាងអស់កល្បជានិច្ចក៏ដោយក៏យើងនៅសង្ឃឹមថា (បន្ទាប់ពីអ្វីទាំងអស់នៅទីនេះ) នឹងរកឃើញការសម្រាករបស់យើងក្នុងការញែកជាបរិសុទ្ធដ៏ធំបំផុតរបស់ព្រះអង្គដែរ។ ប៉ុន្តែ ព្រះអង្គល្អ ហើយក៏មិនត្រូវការការសម្រាកដែរ ហើយក៏តែងតែសម្រាក ពីព្រោះព្រះអង្គផ្ទាល់គឺជាការសម្រាករបស់ទ្រង់។

តើបុគ្គលណានឹងបង្រៀនអ្នកដទៃឲ្យយល់អំពីចំណុចនេះ? ហើយតើទេវតាណាមួយនឹងបង្រៀនទេវតាផ្សេងៗទៀត? ឬក៏ថា តើទេវតាណានឹងបង្រៀនមនុស្សម្នាក់ណា? យើងត្រូវតែទូលសួរព្រះអង្គ ដើម្បីឲ្យមានការយល់ដឹងបាន។ យើងត្រូវតែស្វែងរកការយល់ដឹងក្នុងព្រះអង្គ។ យើងត្រូវតែគោះរកវានៅឯទ្វាររបស់ទ្រង់។ គឺមានតែនៅពេលនោះទេ ដែលយើងនឹងទទួលវាបាន។ គឺនៅតែពេលនោះទេដែលយើងរកឃើញបាន។ គឺនៅតែពេលនោះឯងដែលទ្វាររបស់ទ្រង់នឹងត្រូវបើកឡើង។

# មានធនធានជាច្រើនទៀតនៅ៖

ផ្លូវពិត
plovpit.com

**For ordering information please visit:**
ប្រសិនបើលោកអ្នកចង់ជាវសៀវភៅនេះ សូមចូលទៅកាន់គេហទំព័រ៖
confessionskhmer.com

# ហើយទាញយកសៀវភៅជាច្រើនទៀតដោយឥតគិតថ្លៃនៅ៖

CambodianChristianResources.com